ពាក្យសុទ្ធ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ





ឆ្នាំទី ២៤ ខែមករា លេខ ១

ព.ស.២៤៩៤ – គ.ស.១៩៥២



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
សារាណីយធម្មកថា	ព្រះមហា កែ អឿន	៣
ពន្ធអាស៊ីទ្វីប (តមក)	លោកវ៉ាយ-ប៊ុក	១១
ពុទ្ធសាសនាធិប្បាយ	ព្រះជាឡាត់ ង្វ ឧម	១៦
ផ្នែកអក្សរសាស្ត្រ		
ការប្រើអក្សរខ្មែរ	នាយ គីត-ពិន	២៤
រឿងគ្រូសាញ់អ្នកខ្លាំងពូកែ	សាស្ត្រាចារ្យផេង-ជ្រឹវ	៣១
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៊ម ...	៣៩
រឿងសាមកុក (តមក)	ឧកញ៉ា ង្វ-កន	៤៣
រឿងអារក្សថ្លែងរឿងម្តែប្រាំ (តមក)	លោកសាង-សាវ៉ាត	៥៦
កំណត់ទឹងប្រវត្តិការណ៍		
ពិធីបុណ្យដំឧឡារិកនៅវត្តដើមអំពិល ខេត្ត ចៅណាវ (យៀកណាម)	ព្រះមហា ឈិត-កំលិន	៦៩
ឧត្តមគតិនៃពុទ្ធបរិស័ទវត្តលង្កា	សមាគមមិត្តសាលាបាលី	៧៩

— មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ១៨៣.១០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE		Pages
Saraniyadhammakathâ.....	*Vén. Ker-Œurn*	3
La lumière de l' Asie (suite).....	*M. RAY-BUC*	11
Buddhasasnadhippaya.....	*Vénérable Nou-Om*	16

PARTIE LITTERAIRE		
Usage de la langue cambodgienne	*Monsieur KIT PINN*	24
Crécanau, le vaillant	*M. Phéng-Chrieu*	31
Education morale (suite).....	*Vén. PŒUNG-PAM.*	39
Histoire de SAMKOK (suite)	*Oknha NOU-KAN*	47
Les vingt-cinq récits du mauvais Génie (suite).....	*M. SANG-SAVATH*	56

NOTES ET CHRONIQUES		
Cérémonies religieuses de Vatt Dœum Ampil, à Baclieu (Sud-Vietnam)...	*Vénérable Chhit-Komlin*.	69
Idéal des bouddhistes de la pagode de Langkar.	*Association des amis de l'Ecole de PALI*	79

Prix d'un abonnement annuel (12 numéros:) 183$00

សាវណ្ណីយធម្មកថា

ព្រះមហា កែ - អឿន (វិរិយប្បញ្ញោ)

វត្តព្រះពេហ្វតន៍ ខេត្តសៀមរាប រៀបរៀង

ឃុនសុវត្ថិវេទី យូរ - អ៊ុន អ្នកពិនិត្យកែ

.....

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ ខ្ញុំព្រះករុណា អាត្មាភាព នឹងសូមដកស្រង់យកសាវ-ណីយធម៌ ដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ទ្រង់សំដែងទុកក្នុងគម្ពីរ អង្គុត្តរនិកាយឆក្កនិបាត មកអធិប្បាយជាផ្លូវលោកខ្លះ ផ្លូវធម៌ខ្លះ តាមសមគួរ ដូចតទៅនេះ:

មនុស្សគ្រប់ជាតិគ្រប់ភាសា ដែលកើតមកក្នុងពិភពលោកនេះ សុទ្ធតែមានកិច្ចការ គួរប្រកបគួរប្រឹស័យគ្នាទៅវិញទៅមក ដែលជាផ្លូវធម៌សាសនា ឬក៏ផ្លូវលោក ។

ក្នុងក្រុម ឬ សង្គមនីមួយៗ ត្រូវអាស្រ័យប្រឹស័យការទាក់ទងចង ចាប់គ្នាជាកំឡាំង, បើមិនមានកំឡាំងការចងចាប់គ្នាទេ, ពុំអាចនឹងប្រកប កិច្ចការប្រឹស័យគ្នាបានឡើយ ។ កំឡាំងការចងចាប់គ្នានេះជាធម្មជាតិ

សំខាន់បំផុតក្នុងកិច្ចការគ្រប់យ៉ាង ព្រោះហេតុនោះ បុគ្គលគួរតែរក្សាការ
ចងចាំចំពោះគ្នាជាភក្តីមាំងឲ្យរឹងប៉ឹង សម្រាប់ប្រកបកិច្ចការតាមក្រុមសង្គមរបស់
ខ្លួន ។ ក្រុមសង្គមនីមួយៗ ដែលនឹងបានសេចក្តីសុខសេចក្តីចម្រើន
អស់កាលយូរអង្វែងទៅបានមិនបែកចិត្តគំនិតគ្នា មិនច្រណែនឈ្នានីះ
គ្នា មិនប្រឆាំងប្រជែងប្រណាំងគ្នាជាដើម តាំងដោយអាស្រ័យសារណី-
យធម៌ ។

សារណីយធម៌នោះ ប្រែថា "ធម៌ជាទីតាំងនៃសេចក្តីរឭកដល់គ្នា
ទឹងគ្នាទៅវិញទៅមក" មាន ៦ យ៉ាង គឺ:

១- មេត្តាកាយកម្ម - អំពើកាយប្រកបដោយមេត្តា

២- មេត្តាវចីកម្ម - អំពើវាចាប្រកបដោយមេត្តា

៣- មេត្តាមនោកម្ម - អំពើចិត្តប្រកបដោយមេត្តា

៤- សាធារ: - ការចែករំលែកលាភដល់គ្នីគ្នា

៥- សីល: - ការរក្សាសីលចរិយាឲ្យមានសណ្តាប់ធ្នាប់ល្អ

៦- ទិដ្ឋិ - ការធ្វើសេចក្តីយើញឲ្យត្រឹមត្រូវ ។

សារណីយធម៌នេះ ព្រះភគវន្តមុនីទ្រង់សំដែងថា "ម្នាលភិក្ខុទាំង
ឡាយ ! ធម៌ទាំង ៦ យ៉ាងនេះ តែងធ្វើអ្នកប្រតិបត្តិឲ្យជាទីស្រឡាញ់
ជាទីគោរពរាប់អានរបស់អ្នកដទៃ នាំឲ្យមានសេចក្តីសង្គ្រោះដល់គ្នាទឹង

គ្នា នាំឲ្យមានសេចក្តីមិនទាស់ខែងវែងគំនិតគ្នា នាំឲ្យមានសេចក្តីព្រៃមព្រៀងគ្នាជាពួកមួយ ។ ។

លំដាប់តពីនេះ នឹងដកស្រង់យកបទមាតិកាមួយ។ មកអធិប្បាយតាមលំដាប់រៀងទៅ ដូចតទៅនេះ :—

មេត្តាកាយកម្ម·— កិច្ចសាមណេរមានចិត្តមេត្តាជួយទ្រលំទ្រាយធ្វើកិច្ចការដែលគួរធ្វើដល់គ្នានឹងគ្នា គឺកិច្ចសាមណេរជាអន្តេវាសិក សទ្ធិវិហារិកត្រូវធ្វើកិច្ចវត្តប្រតិបត្តិដល់ឧបជ្ឈាយ៍អាចារ្យ មានការបែគេនទឹកក្តៅត្រជាក់នឹងឈើស្លនជាដើម ។ កាលបើអន្តេវាសិកឬសទ្ធិវិហារិកមានរោគាពាធ ត្រូវតែឧបជ្ឈាយ៍អាចារ្យ ជួយព្យាបាលរក្សា មានដាក់ថ្នាំ ថែទាំជម្ងឺជាដើម ។ បើមិនបានធ្វើដូច្នោះទេ គ្រាន់តែមកត្រួតត្រាមើលឲ្យឃើញថាជាការអើពើដោយកាយ ។ ពុំនោះសោត កិច្ចសាមណេរទាំងឡាយឯណា កាលបើកិច្ចសាមណេរជនគ្នាមានកិច្ចអ្វីដែលត្រូវធ្វើដោយកាយមានកាត់ដេរចីវរជាដើម កិច្ចសាមណេរនោះ។ មកជាគ្នាជួយធ្វើកិច្ចការទាំងនោះ ឬកិច្ចណាមួយដែលជាកិច្ចត្រូវគ្នាស្រួយនឹងបុរសបុគ្គលច្រើនគ្នាទើបប្រព្រឹត្តទៅបាន ដូចជាទ្រលំទ្រាយកេរ្តាំធ្វើថ្នាំរក្សាបឫដែលទុព្វលភាពដោយអាពាធមានគ្រុនពិសជាដើម ខាងក្រៅមានសត្វអាស៊ីវិសចឹកជាដើម ។

មេត្តាវចីកម្ម·— កិច្ចសាមណេរមានចិត្តមេត្តាជួយណែនាំប្រៀនប្រដៅធម៌វិន័យ ជួយជាស់តឿនក្រឿនលើកបង្អុលបង្ហាញទៅស កន្ត

ផ្លូវដែលខុស ឲ្យលះបង់អំពើទុច្ចរិត ចង្អុលហេតុផលក្នុងផ្លូវដែលល្អប្រពៃ ដែលប្រកបដោយធម៌វិន័យឲ្យមានដំណើរដើរទៅក្នុងផ្លូវល្អ ។

ម្យ៉ាងទៀត កិកុសាមណេរមានមេត្តាពោលប្រស្រ័យគ្នាដោយផ្លូវបដិសណ្ឋារៈ សួរសេចក្តីសុខទុក្ខដល់គ្នាទឹងគ្នាតាមសមគួរ ឬកិកុសាមណេរមានមេត្តាប្រាប់វិធីរៀនវិជ្ជាខាងដើមតាំងពីសរសេរ មើលខនូញ បង្ហាញគន្ថធុរៈ វិបស្សនាធុរៈ ឧរ៉ាពានុសាសនី ។

មេត្តាមនោកម្ម —កិកុសាមណេរមានចិត្តមេត្តាប្រាថ្នាប៉ុនប៉ងមិនចងពៀរដល់គ្នាទឹងគ្នា មិនបៀតបៀនដល់គ្នាទឹងគ្នា ប្រាថ្នាសេចក្តីសុខសេចក្តីចម្រើនដល់គ្នាទឹងគ្នាដោយចិត្តស្មោះត្រង់ ។

លាភ:— កិកុសាមណេរណាបានវត្ថុណាមួយ គឺចីវរ, បិណ្ឌបាត, ទីដេក ទីអង្គុយឬថ្នាំតែរោគ ជារបស់ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ គួរកិកុសាមណេរនោះចែករំលែកលាភនោះៗ ដល់គ្នាទឹងគ្នា ឲ្យបរិភោគប្រើប្រាស់តាមដែលបានមកតិចច្រើន ។ ឧបជ្ឈាយ៍អាចារ្យក៏ដោយ កាលបើលាភសក្ការៈ កើតមានបានមកដោយធម៌ក៏ត្រូវចែករំលែកដល់សទ្ធិវិហារិក អន្តេវាសិក បរិភោគប្រើប្រាស់តាមវត្ថុដែលមានបាន ។

សីល:— កិកុសាមណេរត្រូវប្រព្រឹត្តខ្លួនឲ្យស្មើនឹងពួកសព្រហ្មចារីទាំងឡាយដោយសីល គឺមិនត្រូវធ្វើសីលរបស់ខ្លួនឲ្យពព្រួសពពាល

សៅហ្មង ដែលជាទីរង្កៀសមិនទុកចិត្ត ដល់ពួកសត្រហ្មចារីទាំងឡាយ ត្រូវធ្វើខ្លួនឲ្យជាអ្នកបរិសុទ្ធស្អាត ប្រាសចាកសេចក្តីវិបត្តិនៃសីល ។

ទិដ្ឋិ— កិក្ខុសាមណេរត្រូវប្រព្រឹត្តខ្លួនឲ្យស្មើនឹងពួកសត្រហ្មចារីទាំងឡាយដោយទិដ្ឋិ គឺ សត្រហ្មចារីទាំងឡាយប្រព្រឹត្តកាយវាចាចិត្ត យ៉ាងណា ដើម្បីជាដំណើរទៅរកបញ្ញា ដែលជាគ្រឿងឃ្លាតអំពីសត្រូវ គឺកិលេសនាំជនអ្នកប្រព្រឹត្តតាមឲ្យដល់នូវសេចក្តីអស់ទៅ នៃទុក្ខដោយប្រពៃ, កិក្ខុសាមណេរនោះត្រូវប្រព្រឹត្ត កាយ វាចា ចិត្តឲ្យស្មើនឹងពួកសត្រហ្មចារីទាំងឡាយនោះ ។

ធម៌ទាំង ៦ យ៉ាងនេះ មានអានុភាពនាំឲ្យអ្នកកាន់អាចរលឹកដល់គ្នាទីគ្នា ធ្វើមនុស្សឲ្យស្រឡាញ់គ្នា នាំឲ្យមានសង្គ្រោះគ្នា មិនឲ្យទាស់ទែងគ្នា ឲ្យមានសេចក្តីព្រមព្រៀងគ្នាជាពួកមួយ ។ ព្រោះធម្មតាការរលឹកក្តី ការស្រឡាញ់គោរពក្តី តែងកើតមានព្រោះអាស្រ័យនូវការគុណដែលខ្លួនបានធ្វើទុកដល់គេម្យ៉ាង, ព្រោះអាស្រ័យកាយវាចាចិត្តម្យ៉ាង ។ កាលបើកិក្ខុសាមណេរ បានធ្វើសេចក្តីខ្វល់ខ្វាយក្នុងកិច្ចព្រមរបស់ពួកសត្រហ្មចារីដោយកាយវាចាប្តូរដោយមេត្តាចិត្ត គិតនឹងជួយមើនៗ មិនចង់បានផលប្រយោជន៍ផ្ទាល់ខ្លួន ក្នុងទីចំពោះមុខយ៉ាងណា ក្នុងទីកំបាំងមុខក៏យ៉ាងនោះដែរ, ពួកសត្រហ្មចារីបានទទួលនូវការរបស់លោកហើយតែងមានចិត្តគិតនឹងតបស្នងសងខ្លះ ក្នុងវេលាដែលគួរ ។ មិនត្រឹមតែ

ប៉ុណ្ណោះសោតទេ សូម្បីមិនបានជួយខ្វល់ខ្វាយក្នុងកិច្ចធ្វើដោយកាយ វាចា តែចិត្តប៉ុនប៉ងប្រាថ្នាសេចក្តីសុខប្រយោជន៍ដល់គ្នានឹងគ្នាហើយ, អាការកាយវាចា ដែលសំដែងឲ្យប្រាកដចេញមកខាងក្រៅនោះ ក៏គង់មិនជាទីគួរដល់ភ្នែកនៃពួកសព្រហ្មចារីនោះ, បានមេត្រីចិត្តដូច្នេះហើយ ក៏រមែងសំដែងមេត្រីចិត្តតបស្នងវិញខ្លះមិនខាន ។

មួយទៀត កិក្ខុសាមណេរបានលាកមកដោយធម៌ហើយមិនទុកជាក់លាក់បរិភោគប្រើប្រាស់តែម្នាក់ឯង តែងចែករំលែកដល់ពួកសព្រហ្មចារីផងគ្នា, កាលបើពួកសព្រហ្មចារីបានទទួលវត្ថុអំពីលោកណា លុះគេបានលាកមកដោយធម៌ ក៏នឹងចែករំលែកតបលោកវិញមិនខាន ។ បើទុកជាមិនធ្វើឧបការគុណក៏ដោយចុះ ប្រសិនជាកិក្ខុសាមណេរ គ្រាន់តែប្រព្រឹត្តខ្លួនឲ្យជាអ្នកមានសីលបរិសុទ្ធ ឲ្យជាអ្នកមានទិដ្ឋិ សេចក្តីយល់ឃើញប្រពៃហើយ ពួកសព្រហ្មចារីតាំងឡាយ ក៏នឹងជ្រះថ្លាចំពោះគុណ គឺសេចក្តីត្រេកអររបស់លោកមិនខាន ។ កិក្ខុសាមណេរដែលប្រព្រឹត្តដូច្នេះ រមែងជាទីរឭកជាទីស្រឡាញ់គោរពរាប់អាន របស់ពួកសព្រហ្មចារីដទៃៗ នាំគ្នាគិតសង្គ្រោះគ្នានឹងគ្នា ។ មនុស្សដែលរឭកទាស់ខែងគ្នា ក៏ព្រោះមិនមានចំណងឲ្យជាប្រយោជន៍ដល់គ្នានឹងគ្នាខ្លះ ព្រោះមិនមានធ្វើឧបការគុណដល់គ្នានឹងគ្នាខ្លះ ។ ចំណែកបុគ្គលដែលមានសេចក្តីសាមគ្គីព្រមព្រៀងគ្នា ក៏ព្រោះអាស្រ័យការសង្គ្រោះគ្នាខ្លះ ព្រោះការលែលកធ្ងន់

ស្រាលគ្នាខ្លះ ។ កាលបើកិក្ខុសាមណេរតាំងនៅក្នុងគុណធម៌តាំង ៦ ប្រការនេះហើយ អាចគាញចិត្តពួកសព្រហ្មចារីមិនឲ្យវិវាទទាស់ខែងគ្នា ធ្វើឲ្យមានសាមគ្គីជាមួយគ្នាធ្វើឲ្យជាទីស្រឡាញ់គ្នា នាំឲ្យមានសេចក្តីសង្គ្រោះគ្នា មិនឲ្យទាស់ខែងខ្វែងគំនិតគ្នា ឲ្យមានសេចក្តីព្រមព្រៀងគ្នា ។

ធម្មតាបុគ្គលដែលគ្មានមិត្ត កាលបើកិច្ចធ្ងន់តឹងម្តង ។ ត្រូវតែខ្វល់ខ្វាយខ្លះខ្វែងកខ្វេសកខ្វាសដោយកម្លាំងខ្លួនម្នាក់ឯង មិនមានបុគ្គលដទៃជួយផង ។ រូបកាយមានដៃជើងសម្រាប់ជួយ បើខ្លះដៃឬជើងរមែងមានសេចក្តីលំបាក: ដើមឈើមានឫសនឹងមែកសម្រាប់ជួយឲ្យរស់នៅបាន បើរុក្ខាយុវៈតាំងនោះគ្មានទេ ដើមឈើនោះក៏រស់នៅមិនបាន, ត្រូវខ្សោលបក់មកវិលបានដោយងាយ ។ ធម្មតាមនុស្សតាំងពួនបើរួបរួមគ្នាច្រើន ក៏រមែងមានកម្លាំងច្រើន ។ អម្បោះមួយសរសៃមិនស្តុតជាប់ប៉ុន្មានទេ គាញតែមួយប្រឹបក៏ដាច់ បើវេញចូលជាធ្នូងមួយ ទើបគាញមិនដាច់ បើទុកជាគោគាញក៏មិនដាច់ ។ ស្រមោចមួយតាំងនឹងទៅជាអ្វី? មនុស្សយើងក៏ដូចគ្នាដែរ ចំពោះខ្លួនមួយនឹងតស៊ូអ្នកណាក៏មិនឈ្នះធ្វើអ្វីក៏មិនបានច្រើនដែរ, លុះតែជួយគ្នាទើបបានកម្លាំងច្រើនឡើង, ដោយហេតុនៅ សូម្បីនៅក្នុងទីណា ហើយក្រៃឡែកមើលជុំវិញមិនស្គាល់អ្នកណាម្នាក់សោះ ក៏រមែងមិនបានសុខ ។ ព្រោះហេតុដូច្នេះសេចក្តីមេត្រីស្និទ្ធស្នាលគ្នាល្អ ទើបជាផលដែលបុគ្គលត្រូវស្វែងរកយ៉ាងក្រៃលែង

សមដូចពុទ្ធភាសិតថា វិស្សាសា បរមា ញាតី ‘សេចក្តីស្និទ្ធស្នាល
មេត្រីភាប់អានគ្នា ជាញាតិយ៉ាងក្រៃលែង” ។ ឯសេចក្តីមេត្រីនោះ តែង
កើតឡើងដោយសាឧណាយធម៌ចំនួន ៦ យ៉ាង ដូចសំដែងមកនេះ ។ ធម្មតា
បុគ្គលដែលជាទីស្រឡាញ់គោរពភាប់អានរបស់ប្រជុំជន ក៏ព្រោះអាស្រ័យ
នូវឧបការគុណដែលខ្លួនបានធ្វើទុកដល់គេ ។ បើបុគ្គលបានធ្វើសេចក្តី
ខ្នះខ្នែងខ្វល់ខ្វាយក្នុងកិច្ចធុរៈរបស់គ្នានឹងគ្នា ដោយកាយវាចាក្តី ដោយ
មេត្តាចិត្តគិតនឹងជួយពិតៗក្តី មិនមានបំណងផលប្រយោជន៍ ក្នុងទី
ចំពោះមុខយ៉ាងណា ក្នុងទីកំបាំងមុខក៏យ៉ាងនោះដែរ អ្នកដែលបានទទួល
នូវឧបការដូច្នោះ ក៏នឹងមានចិត្តសោមនស្សស្មោះសរចំពោះនូវឧបការគុណ
គិតនឹងតបស្នងនូវឧបការខ្នះខ្នែងវេលាដែលគួរ ។ អ្នកដែលទទួលមេត្រីចិត្ត
ដូច្នេះ ខាងក្រោយក៏នឹងសំដែងមេត្រីចិត្តតបវិញ ។

ម្យ៉ាងទៀត កាលបើបានទ្រព្យសម្បត្តិដោយផ្លូវស្អាត ហើយមិន
លាក់លៀមទុកបរិភោគប្រើប្រាស់តែម្នាក់ឯង អាចចែករំលែកដល់បុគ្គល
ដែលគួរឲ្យតាមមានតាមបាន, អ្នកដែលទទួលសេចក្តីសង្គ្រោះដូច្នោះ
ក៏នឹងមានចិត្តសោមនស្សស្រឡាញ់ បើបានទ្រព្យអ្វីៗ ក៏នឹងរំលែកចែកមក
វិញ ។ សមដូចភាសិតថា ឫជុកោ លភតេ ឫជុំ “អ្នកឫជុរមែងបានគេ
ឫជុវិញ” ឫទ្ធកោ ឫទ្ធិំ “អ្នកសំពះគេ រមែងបានគេសំពះវិញ” ភាសិតខ្មែរថា
“ចោកអ្នកនឹងដៃ ថ្ងៃអ្នកនឹងមាត់” ។

(មានត)

ពន្លឺអាស៊ីទ្វីប

វគ្គទី ៣

La Lumière de l'Asie

លោក ស៊ីរ - អេតវ៉ាំង អាណូលត៍ តែន

លោកវ៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

តែកាលណាព្រះមហាក្សត្រិយ៍ចាន់ជាបថា: "ព្រះសិទ្ធត្ថស្តេចយាងមកដល់ ដាក់ព្រះកេសា, ស្លៀកពាក់ស្បង់ចីវរពណ៌ប្រផេះរបៀបជាអ្នកសូមហើយកាន់អម្បែងសូមទានគោជនាហារ ដែលសេសសល់អំពីអ្នកមានវណ្ណៈតាប" ដូច្នេះហើយទ្រង់កើតទុក្ខលំបាកក្នុងព្រះជង្ហាទំយពន់ពេក ហើយទ្រង់ព្រះក្រោធជាខ្លាំង ។ ព្រះពាជាទ្រង់ព្រះនុដ្ឋហា (ស្តោះ) លើផែនដីដោយខ្ពើមរអើមណាស់, ទ្រង់ចោចព្រះហនុកមស្សុ (ពុកចង្កាពុកមាត់) ដែលមានពណ៌សដូចប្រាក់ ហើយទ្រង់ចេញពីព្រះប៉ះមកជកាំង់ដោយឆាប់រហ័ស ។ ពួកអាមាត្យសេនាញ៉ាំរន្ធត់ជាខ្លាំងក្នុងពេលដែលទ្រង់កំពុងស្តេចទៅ តាមវីថីនៃព្រះពជធានី ។ ព្រះពាជាទ្រង់គង់ព្រះទីនាំង៍អស្សតែរ ទ្រង់ញាក់ព្រះកូមេ (ចិញ្ចើម) ដោយទ្រង់ព្រះក្រោធជាខ្លាំង, ហើយគោះដែកឈ្នាន់ទៅលើពោះអស្សតែរ បំផាយយ៉ាង៍លឿនទៅតាមមហាវីថីនីវីថីក្នុងព្រះពជធានី ដែលគោរពេញទៅ

ដោយបណ្តាក្រសួណែនណាន់តាន់តាប់មានចិត្តរឿងឆ្ងល់ទឹងព្រះអាការៈ
នៃព្រះវរបិតា ហើយពោលស្តីរមិនខាន់ថា: "សូមថ្វាយបង្គំព្រះគុណា"
មុនអស្ចារ្យរត់លឿនទៅមុខ ។ ក្នុងពេលនោះ, នៅប្រជញ្ជាំងវត្ត
ដែលគេក្រឡេកទៅឃើញក្លោងទ្វារព្រះបរមរាជវាំងខាងត្បូង, ព្រះមហា-
ក្សត្រិយ៍ទ្រង់ចាន់ទតទៅឃើញមហាជនជាច្រើន គឺកងរំពងឈរត្រៀប
គ្រាប់ចាំងផ្លូវជិត, ហើយមានបណ្តាក្រសួប្រមូលចូលមករួបរួមជាថ្មី ឈរ
បន្តគ្នាណែនណាន់តាន់តាប់ដើរតាមក្រោយនៃព្រះសិទ្ធត្ថ ដែលមានព្រះ
នេត្រាក្តីស្រឡះចោលទៅចំព្រះវរបិតា ។ ដល់ព្រះសម្មាសម្ពុទ្ធទ្រង់
ទតដោយទឹកព្រះទ័យដ៏ខន់កូន ព្រមទាំងគារវភាពទៅកាន់ព្រះវរបិតា
ដែលទ្រង់កំពុងក្រោធជាខ្លាំង, ព្រះទ័យព្រះវរបិតាក៏អន់ថយចុះ ហើយ
ទ្រង់ក៏លុតព្រះជន្ទុកា (ជង្គង់) ចំពោះព្រះដ៏មានព្រះភាគ ព្រោះព្រះ
វរបិតា ទ្រង់មានព្រះទ័យស្មោះចំពោះព្រះពាជនុរសពន់ពេក ទ្រង់មាន
ព្រះពាជបំណងចង់យល់ច្បាស់លាស់ នូវព្រះកិត្តិគុណជាអស្ចារ្យនៃព្រះ
ពាជនុរស ដែលមានឆ្វូណ្ណវង្សីផ្សាយចេញពីព្រះនលាដ៍ ហើយនឹង
អាកប្បកិរិយាគួរឲ្យជ្រះថ្លាពន់ពេក ដែលនាំឲ្យមនុស្សជាច្រើនដើរតាម
ក្រោយព្រះពាជនុរស ដោយសេចក្តីសុប់ស្ងៀម ។ តែព្រះវរបិតាទ្រង់
មានព្រះបន្ទូលទៅព្រះពាជនុរសថា "ហេតុម្តេចក៏ព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់
ប្រសើរផុត ត្រឡប់មកកាន់ព្រះពាជធានី វិញដោយទ្រង់ព្រះពស្តកណ្តាច

រំហែក ? ជាក់ព្រះកេសា ? ខ្ញុំព្រះសុតណាំបានសង្កែក ហើយខ្ញុំ
ទទួលទានក្រយាហារបស់បុគ្គលដែលមានវណ្ណៈថាប ? ព្រះអគ្គម្ចាស់
កែឆ្នៃខ្ញុំមានជីវភាព ដូចជាព្រះអាទិទេពឬ ? ព្រះពជបុត្រ ! ខ្ញុំជា
ព្រះពជាយាទ សោយរាជ្យនៅព្រះពជអាណាចក្រដ៏ធំទូលាយអស្ចារ្យ
ជាស្តេចចក្រពត្តិជាពជ មានឫទ្ធានុភាព គ្រាន់តែខ្ញុំទះព្រះហស្តតល
(ជាតដៃ) ប៉ុណ្ណោះ កំពូលអាមាត្យអាចយកព្រះក្រយាហារមកថ្វាយ
ខ្ញុំមួយរំពេចបាន ។ ព្រះអគ្គម្ចាស់គួរតែខ្ញុំត្រឡប់វិលមកព្រះពជ-
ទិវេសនដ្ឋានវិញ តាមព្រះរាជកិត្តិយសមានពួកទាហានការពារលំពែង ព្រម
ទាំងមនុស្ស អស្សតរហែហមជាបរិវារទើបគួរ ។ ព្រះអគ្គម្ចាស់ខ្ញុំ
តមកឃើញទាហានបិតានៅឈរចាំយាមគ្រប់ផ្លូវ ហើយប្រជាពលស្តេ
ទៅក្នុងព្រះពជធានី បានចេញទៅរង់ចាំធ្វើបដិសណ្ឋារៈខ្ញុំ ទៅខាង
មុខក្លោងទ្វារជំ, តើក្នុងប៉ុន្មានឆ្នាំមុននេះខ្ញុំគង់ទៅទីណា ? ឯបិតាសោយ
រាជសម្បត្តិជាទុក្ខលំបាកពន់ពេក ហើយព្រះអគ្គជាយារបស់ខ្ញុំរស់នៅ
ដូចជាស្ត្រីមេម៉ាយ លះបង់អាមិសក្នុងលោកចាំងអស់, លែងសាវនាទ្វា
ចម្រៀងភ្លេងតូរ្យតន្ត្រី ហើយបោះបង់លែងគ្រងព្រះកូសាសម្រាប់បុណ្យ
សប្បាយសោះឡើយ ចាស់មកដល់សព្វថ្ងៃនេះ ។ ពេលនេះ, ព្រះនាង
ខ្ញុំព្រះកូសាប៉ាក់ដោយឱនមាស រង់ចាំទទួលព្រះស្វាមី ដែលគ្រង
សំពត់កណ្តាចលឿង, ហើយថែមទាំងកាន់អម្បែងដើរសូមទានគេទៀត
ព្រះអង្គម្ចាស់ហេតុម្តេចក៏ខ្ញុំធ្វើយ៉ាងដូចនេះ ?" ។

ព្រះសម្មាសម្ពុទ្ធទ្រង់តបទៅព្រះវរបិតាថា: "នេះជាប្រវេណីរបស់តថាគតពីបុរាណមក" ។

ព្រះវរបិតាទ្រង់តបវិញថា: "ប្រវេណីទ្រង់ គឺព្រះមហាក្សត្រិយ៍សោយរាជសម្បត្តិមួយរយសន្ដតិវង្សមកហើយ តាំងពីព្រះបាទមហាសម្មតៈ (មហាសម្មតិរាជ) តែព្រះមហាក្សត្រិយ៍ទាំងអស់នោះ ទ្រង់មិនដែលប្រព្រឹត្តបែបនេះឡើយ" ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះបន្ទូលតបវិញថា: "តថាគតមិនបានពោលអំពីសន្ដតិវង្សតាមការសាម៉ញនេះទេ ពោលអំពីព្រះពុទ្ធវង្សតាំងអំពីអតីតកាលនឹងអនាគតកាល ។ កាលចំណាមព្រះពុទ្ធទាំងអស់ តថាគតជាព្រះពុទ្ធមួយព្រះអង្គ ទើបនឹងត្រាស់ដឹងក្នុងពេលនេះ ហើយប្រវេណីព្រះពុទ្ធធ្លាប់ប្រព្រឹត្តពីបុរាណយ៉ាងណា, តថាគតក៏ត្រូវធ្វើតាមយ៉ាងនោះ, ហើយព្រឹត្តិការណ៍ដែលកើតក្នុងពេលនេះ គឺកើតតាំងពីពេលមុនដូចគ្នា ។ រឿងរ៉ាវពីអតីតកាល មានព្រះមហាក្សត្រិយ៍មួយព្រះអង្គ ទ្រង់យាងមកដល់ខាងមុខព្រះរាជធានី ដើម្បីនឹងវាយចាំទទួលព្រះរាជទូតដែលគេងស្បាន់ដូចតាបស ហើយជាសោធិសត្វដែលមានទិស្សុយត្រាស់ជាព្រះពុទ្ធក្នុងកប្បកំណើរនេះ ប្រកបដោយព្រហ្មវិហារដ៏ប្រសើរ ហើយមានព្រះទ័យរឹងប៉ឹង ព្រមទាំងពលភាព, ក្រាបសំពះព្រះមហាក្សត្រិយ៍ ដូចតថាគតធ្វើក្នុងពេលនោះ (ប្រហែលគ្រាន់តែធ្វើគារវភាព) ហើយក៏ចាំទ

ប្ដូរដោយកត់ញ្ញាតតវ៉ា ចំពោះបុគ្គលដែលមានគុណូបការៈ សម្បើម អស្ចារ្យខ្លួកំណប់ទ្រព្យ ដ៏វិសេសវិសាលដែលទ្រង់ចាន់កឃើញ កំណប់ទ្រព្យនេះហើយដែលតថាគតយកមកថ្វាយក្នុងពេលនេះ" ។

ព្រះមហាក្សត្រិយ៍ ទ្រង់ព្រះកន្សាហើយទូលសួរទៅព្រះសម្មាសម្ពុទ្ធ ថា: "តើកំណប់ទ្រព្យនោះនៅឯណា ?" ។ ព្រះបរមគ្រូជាម្ចាស់ ទ្រង់ចាន់កាន់ព្រះហស្តព្រះវរបិតា ហើយទ្រង់ត្រាច់តាមវីថីជាមួយនឹងប្រជារាស្ត្រ ដែលមានអាការៈ សំដែងសេចក្តីគោរពជាយ៉ាងក្រៃលែង, ហើយទ្រង់តបទៅព្រះវរបិតាវិញ អំពីធម៌ដែលនាំមនុស្សទៅកាន់សេចក្តីសុខ សេចក្តីចំរើនទុំ គឺធម៌ចតុរារិយសច្ចដែលមានប្រាជ្ញាជាមូលធម៌ ប្រៀបដូចជាមាត់សមុទ្រ ស្ថិតនៅជុំវិញសមុទ្រដូចនោះ, ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាអំពីបទបញ្ញត្តិ ៨ យ៉ាង ដែលព្រះមហាក្សត្រិយ៍ឬពួកគាស-កម្មករ មានប្រាថ្នាចង់ត្រាច់ទៅតាមអរិយមគ្គ ដែលមានសភាពជា ៤ ថ្នាក់ ហើយនឹងសិក្ខាបទ ៨ ប្រការ ដែលអ្នករស់នៅប្រកបដោយពលភាព ឬ ខ្សោយលំបាក, អ្នកវិញ្ញជន ឬលង្ឃ, បុរស ឬស្ត្រី, ក្មេង ឬចាស់ ត្រូវតែវៃឬណាមួយមានបំណងចាកចេញពីកងនៃដីវភាព ទៅកាន់ព្រះនិញ្វន ជាស្ថានបរមសុខ ។

(មានត)

ពុទ្ធសាសនាធិប្បាយ

ព្រះបាទ្បាត់ ដូ-ឱម វត្តព្រះពុទ្ធមាឧបុណ្យ ក្រុងភ្នំពេញ

ទេសនាជាកវីឬឃោសនសព្វនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ រោចខែដល្គុន ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ (៨-៤-៤៩)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការ ចំពោះព្រះដ៏មានបុណ្យ អរហន្តសម្មាសម្ពុទ្ធអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ អាត្មាភាពនឹងសូមលើកយកផលប្រយោជន៍នៃពុទ្ធសាសនា មកអធិប្បាយ ដោយសង្ខេប ដើម្បីឲ្យពួកខេមរបុត្រទាំងអស់កុងកម្ពុជរដ្ឋ គិតជញ្ជឹងរំពឹងពិចារណា ក្នុងចិត្តគ្រប់ៗគ្នាឲ្យឃើញជាក់ច្បាស់ថា ជាសាសនាមានដំណែឲ្យថ្លៃថ្លា ក្នុងផ្លូវលោកផង ផ្លូវធម៌ផង ជាសាសនាប្រដៅមនុស្សឲ្យភ្ញាក់កំណើតឆើតឆៃមុខផង ជាសាសនាប្រដៅមនុស្សឲ្យចង់សាមគ្គីធម៌គ្នា ជាលទ្ធិរួមសម្បាចាប់ខុបសគ្គណាមួយ ដែលជាគ្រឿងពារពាំងកុងលោកផង ជាសាសនាអាចសង្គ្រោះសង្គ្រិនខ្លួនពួកជនដែលពួនតែខ្លួន យកសុខផ្ទាល់ខ្លួនតែម្នាក់ឯងផង ដូចសេចក្តីដែលនឹងថ្លែងតទៅនេះ ។

ក៏ពាក្យថាសាសនា។ នេះ គឺជាបង្គោលប្តូរទីពឹងផ្អែកយ៉ាងសំខាន់ថ្លៃថ្នូរបស់ពួកជនក្នុងសាកលលោក តាំងពីបុរាណសម័យត្រែងនាយ

មក ។ តួយ៉ាងដូចដូនជាតិខ្មែរយើងនេះសឹងជាអ្នកសំដែងសេចក្តី
គោរពរាប់អាន ដោយស្មោះត្រង់អស់ពីចិត្តចំពោះពុទ្ធសាសនា ខ្ជល់
ខ្ជាយក្បាត្រគប់ៗគ្នា អស់ចំនួនជាងពីរពាន់ឆ្នាំមកហើយ ។

ពាក្យថា សាសនា នេះ ប្រែថា «ការជាគ្រឿងប្រៀនប្រដៅ» ឬថា «ពាក្យបណ្តាំ» ពុទ្ធៈ នេះជាឈ្មោះរបស់មហាវីរបុរស ដែលបានប្រតាសសាសនាទុក ។

រួមពាក្យ ពុទ្ធៈ នឹង សាសនា ទាំងពីរនេះភ្ជាប់គ្នាជា ពុទ្ធ-សាសនា ។ នេះសំគាល់សេចក្តីថាការជាគ្រឿងប្រៀនប្រដៅរបស់ព្រះសក្យមុនីគោតមសម្មទ្ធដែលជាបុគ្គលឆ្នើមកងវៃត្រកព ដែលពុទ្ធបរិស័ទទាំងឡាយធ្លាប់គោរពរាប់អានរៀងៗមក ជាសាសនាយ៉ាងចំណានល្អ ចំណាប់ពន់ពេក ទុកឲ្យសត្វទាំងឡាយក្នុងសកលលោក ប្រតិបត្តិតាមដោយមច្ឆរដើម្បីនឹងកំចាត់សេចក្តីទុក្ខសោកគ្រប់យ៉ាង ហើយឲ្យបានសេចក្តីសុខក្សេមក្សាន្តយ៉ាងអស្ចារ្យ ។

ព្រោះហេតុដូច្នោះ ព្រះពុទ្ធបានតាមប្រកាសថាជាម្ចាស់នៃសាសនា គឺព្រះធម្មសាមី ព្រោះទ្រង់ព្រះមេត្តានឹងប្រោសប្រាណព្រះពុទ្ធបន្ទូលព្រះធម៌ដែលទុកជាច្បាប់ដ៏ថ្កើងថ្កាន ឲ្យសត្វការតាមលំអានហានន្តរៈនឹងដំណែរថ្ងៃថ្ងូរបស់ខ្លួន ។

នរជនណាដែលមានសន្ដានចិត្ដជោកជាំបន្ទោកន្ដង់លោកនេះ ខ្ញុំដ
ក្រាស់ក្រែនហួសប្រមាណពេក គឺថាមានចិត្ដជ្រុលជ្រប់ដ៏ក់ដោកមិនគិត
ខ្លួន គេអង្រែនមិនញ៉ែរមិនរង្គើ ព្រះអង្គក៏ទ្រង់ប្រោសព្រះពរជ័យធម៌
យ៉ាងជាន់ខាប ឲ្យត្រូវតាមអធ្យាស្រ័យតាមសភាព តាមបែបនៃនរជន
នោះ ឲ្យយ៉ាងធូរៗ ល្មមៗ ពីពេះស្ដាប់ សង្រ្គោះតាមភាពនៃមនុស្សដែល
មានឥន្ទ្រិយអន់ ទ្រង់ប្រដៅឲ្យប្រកបការងារក្នុងបច្ចុប្បន្ន ដែលជា
ប្រយោជន៍ឃើញជាក់ជាន់ហាន់នឹងភ្នែក ឲ្យបានស្រាកស្រាន្ដចាកសេចក្ដី
ទុក្ខបានសុខគ្រប់ៗប្រាណ ។

ប៉ុន្ដែក្នុងពេលនេះ ខ្ញុំសូមលើកយកផលប្រយោជន៍យ៉ាងសំខាន់
របស់មនុស្សក្នុងបច្ចុប្បន្នមកចង្អុលបង្ហាញ ឲ្យឃើញជាក់ច្បាស់គ្រប់ៗគ្នា
យ៉ាងនេះថា:

១ - កើតមកជាមនុស្សត្រូវតែឲ្យមានសេចក្ដីព្យាយាមប្រឹងប្រែង
ជៀតបៀតប្រដែងធ្វើការងារចិញ្ចឹមជីវិត កុំខ្ជិលច្រអូស កុំថយក្រោយ
ឲ្យសោះ ត្រូវតែរុករកកុំរួញរា ។

២ - ត្រូវឲ្យមានស័ីលធម៌ក្នុងចិត្ដ ខ្ញុំ ត្រូវឲ្យស្រឡាញ់សេចក្ដី
សុចរិតរាយ កុំនិយាយពាក្យនាំឲ្យបែកសាមគ្គីធម៌ ។

៣ - ត្រូវឲ្យប្រតិបត្ដិតាមច្បាប់សម្រាប់ស្រុកដោយម៉ត់ចត់ ដួយ
គយគន់រកមើលហើយបង្ហាញ កុំទុកលាក់មនុស្សធ្វើខុសច្បាប់ផ្សេងៗខ្ញុំ

អ្នកមានចិត្តក្សត់ចំពោះម្ចាស់ផែនដី ដែលព្រះអង្គទ្រង់សេពគប់ពាជធម៌មានទឹកព្រះពាជហឫទ័យ ពោលគឺមេត្តាផ្សាយទៅលើនាហ្មឺនសព្វមុខមន្ត្រីនឹងអាណាប្រជាទុកស្មើគាំងអស់ ។

៤ - ត្រូវស្រឡាញ់ប្រទេសជាតិ សាសនា មហាក្សត្រ ហើយទំនាំគ្នារក្សាស្រុកទេសរបស់ខ្លួន ត្រូវពួតដៃគ្នាការពាររន្ធពាយគ្រប់ផ្លូវដើម្បីធ្វើប្រទេសជាតិយើងឲ្យចំរើនរុងរឿងគាន់នាជាតិដុំខ្លួន ។

៥ - ត្រូវឲ្យមានសេចក្តីចេះដឹងចូលចិត្តក្នុងផ្លូវជំនួយម ហើយទំនាំគ្នាប្រតិបត្តិឲ្យបានផលប្រយោជន៍គាន់ភ្នែក កុំឲ្យជាតិដ៏ទៃហៅទៅប្រដូចជាគោក្របី ។

៦ - ត្រូវឲ្យចេះប្រឹងប្រែងអំណាចស្មើភាគគ្នា ទទឹងសេចក្តីគោរពតាមសមគួរដល់ច្បាប់ នឹងប្រពៃណីនិយម ដែលឥតខាស់ខុសនឹងច្បាប់ ។

៧ - ត្រូវឲ្យយកចិត្តទុកដាក់ ក្នុងការធ្វើស្រែចំការច្បារដំណាំ ដ្បិតការធ្វើបែបនេះ មានប្រយោជន៍ដល់ប្រទេសជាតិនឹងពាការរដ្ឋបាលជាសំខាន់បំផុត ។

៨ - មាតាបិតាត្រូវដឹកនាំបង្ខំបុត្រប្រុសស្រី ឲ្យចិតទំរៀនសូត្រចំណេះវិជ្ជាមានលេខនឹងអក្សរជាដើម ដែលជាផ្លូវលោកក្តី ផ្លូវធម៌ក្តី កុំបណ្តែតបណ្តោយឲ្យកូនទៅលូនលំទៀ ព្រោះការដែលសិក្សាវិជ្ជា ក៏ដើម្បី

ឲ្យកើតបញ្ញា គិតឃើញដោយខ្លួនឯងក្នុងមួយថ្ងៃ។ មិនមែនសម្រាប់តែយកការគំនិតរបស់គេ មកប្រើគ្រប់បែបយ៉ាងនោះទេ ។

៩ - សូមឲ្យពួកខេមរបុត្រគ្រប់ស្រុកគ្រប់ភូមិ-ឃុំតូច ទំបោសសំអាតទីភូមិស្ថានផ្ទះសម្បែង កន្លែងដេក-អង្គុយ គ្រឿងបរិភោគគ្រឿងស្លៀកពាក់ គ្រឿងប្រើប្រាស់គ្រប់មុខជាដើម ទើសំអាតកូនចៅធំ-តូចកុំឲ្យមានកើតកមរមាស់ តាមវិធីអនាម័យផ្សេងៗ ។

អាត្មាភាពដែលសំដែងពន្យល់អស់លោក-អ្នកយ៉ាងនេះ មិនមែនជាការខាស់ខុសនឹងព្រះពុទ្ធដីកាទេ ព្រោះព្រះអង្គទ្រង់សំដែងពន្យល់អំពីប្រយោជន៍បច្ចុប្បន្ន ល្អិតជាងនេះទៅទៀតរហូតដល់ទ្រង់ហាមមិនឲ្យចាយវាយទ្រព្យសម្បត្តិខ្ទះខ្ទាយហួសប្រមាណពេក ។

នែពួកខេមរបុត្រ! បើអ្នកពិតជាខេមរសុទ្ធមែន ចូរអ្នកប្រឹងប្រយ័ត្នគោរពប្រតិបត្តិឲ្យមាំមួន តាមទំនាំង ៩ យ៉ាង ដូចអាត្មាភាពបានអធិប្បាយញែកចេញមកនេះ ប្រទេសរបស់អ្នកក៏ទើងបានសេចក្តីចំរើនសប្បាយយ៉ាងខ្លួលខ្លាយច្រើន គឥតមានទុក្ខកង្វល់អ្វីបៀតបៀនបាន ដោយសារតែអ្នក, បើប្រសិនជាកូនកម្ពុជាទាំងឡាយ នៅធ្វើសោះអង្គើយកន្តើយមិនខំខ្នើយ្ហាតគោរពចំពោះជាតិ សាសនា មហាក្សត្រទេ នោះកុំសង្ឃឹមថាប្រទេសយើងនឹងមានដម្កៃស្មើនឹងប្រទេសជាតិដទៃឡើយ ។

ហេតុនេះ សូមឲ្យកូនកម្ពុជាទាំងឡាយ តាំងចិត្តគោរពកាលយប់ព្រឹក ប្រឹងស្វែងប្រឹងគំនិតគិតជ្រាន្ទិច្ចជាអាលដ្ឋិ ចំពោះជាតិ សាសនា

មហាក្សត្រ របស់យើង កុំឲ្យមានលោះពេលវេលាឡើយ, ប៉ុន្តែមានជន
ជាតិខ្មែរខ្លះមិនគាំងចិត្តគោរពសេះ បែរទៅជាមានចិត្តក្បត់ទៅវិញ,
បើម្ដេចៗ តើជាតិប្រទេសរបស់យើងនឹងថ្កើងអំពីផ្លូវណា ? ។

កូនកម្ពុជាគោងអ្នកសង្កេតគ្រប់គ្នា ឲ្យឃើញជាក់ច្បាស់ទៅចុះ កុំ
ទៅច្រមក់ពួនតែខ្នងយកសុខផ្ទាល់ខ្លួនតែម្នាក់ឯង : ឃើញទេជាតិដទៃ
ដែលគេបានសេចក្ដីសុខ-ចំរើន មកអំពីគេមិនដេកឆ្នេចដូចយើងៗគួរភ្ញាក់
កំណើត ហើយកុំនៅដេកលក់ដល់ណាទៀត ។

កូនកម្ពុជាពាំងឡាយ ! បើអ្នកចង់ឲ្យប្រទេសរបស់អ្នករុងរឿងទៅថ្ងៃ
មុខ គោងអ្នកខំផ្សុំភ្ញាស់បណ្ដុះពូជពោលគឺវិជ្ជាចំណេះ ដែលបុគ្គលត្រូវ
ស្វែងរករៀនសូត្រក្នុងលោក មិនត្រូវដំអក់ទំនេរទេមើយមិនបើក
ភ្នែកមើលទេ ព្រោះកម្ពុជរដ្ឋពដ្ឋានី អស់លោកពដ្ឋការធំៗ បានបន្ទូ
វិជ្ជាភ្លឺព្រោងព្រាត ត្រូវកូនកម្ពុជា ខំនាំគ្នាធ្វើតរៀនសូត្រឡើង កុំ
ស្ងាត់ស្ងើរដល់ណាទៀត ។ កូនកម្ពុជាពាំងឡាយ ! អ្នកគង់យល់
ច្បាស់ថា "ពោះរស់ពីជាយ" ពង្គកាយនេះហើយដែលជាដង្កែកសម្រាប់
ផ្ទុកវិជ្ជាសព្វគ្រប់ប្រការ ប្រសិនណាជារូបនេះ ដល់ទូវគាពវិកលវិការ
ជាបដល់ស្ដាំងស្គមពាំងសង្វារហើយ បុគ្គលមិនបានព្យាយាម ព្យាបាល
បរិហារទេ ចំណេះវិជ្ជាគ្រប់យ៉ាងក៏មិនចេះ ។


យើងបានដឹងជាក់ថា រូបនេះរស់ដោយអាហារពិត ថាបើមិនគិតរកចំណេះទេ បើរោគកាមកប្រជុំខ្លុំពុំរបេះ ពិតជាមាត់លិទ្ធផេះមិនលែងឡើយ ។

តែង់ន័យនេះ សូមបញ្ជាក់ថា មានជនចំពួកខ្លះ ស្នេហានឹងនគរកាយរបស់ខ្លួនដែរ តែដំអក់ទំនង់មិនទំរៀនវិជ្ជាមិនទំការពារទេ ទុកបណ្តោយឲ្យនគរកាយរបស់ខ្លួននៅជាលង្ហិរខ្មៅជាក់ខៅជាខ្ញុំគេ តែមានចិត្តនោះពុះក្តៅខៅដោយអំណាចឧបក្កិលេសទាំង ១៦ ប្រការ នឹងអកុសលចេតសិក ១៤ ប្រការ ជាមេបណ្តាលដឹកនាំមនុស្សឲ្យប្រព្រឹត្តល្មើស នាំឲ្យជ្រួលច្រាល់អន្ទះសា នាំឲ្យច្បាច្បាំងហួសហេតុ ខៅជាចង់សោយរាជ្យជាស្តេច នេះដោយអំណាចសេចក្តីលង្ហិរខ្មៅ ។ ខ្លះខៅជាឆាស្តុចាំងហួនលួចប្លន់ទ្រព្យ បង្កើតធ្វើទំពាំងតួរបស់ខ្លួនតនឹងម្ចាស់ផែនដី ខ្លះខៅជាធ្វើឲ្យកើតកលិយុគ ចាក់រុករកវឿងរកហេតុ ធ្វើឲ្យពួករដ្ឋបាលកើតសេចក្តីរំខាន ទាំងនេះព្រោះសេចក្តីលង្ហិរខ្មៅ គឺអវិជ្ជាកចាំងបិទមិនឲ្យគិតពិចារណាឃើញល្អបាន បែរខៅជាវង្វេងវល់ចិត្តឥតចេះស្ងាត់ កសាងតែបាបកម្មសព្វឥតស្តាប់សោះ ធ្វើឲ្យទើសទាស់អំពាលចិត្ត រួបតែដល់ពងកាយថែមទៀត ក្លាយខៅជាជាប់ទោសដល់ទុគ្គតិ ហ្នឹងហើយផលនៃសេចក្តីលង្ហិរខ្មៅ ដែលជាផលនាំឲ្យទាតបង់ប្រយោជន៍ក្នុងលោកនេះ លុះដល់ទម្លាយពងកាយអំពីលោកនេះខៅ នឹងនាំទុក្ខណឲ្យខៅជ្រកអបាយមិនខាន ។

ហេតុនេះ កូនកម្ពុជាទាំងឡាយ មិនត្រូវប្រមាទមើលងាយសាសនាមហាក្សត្រទេ ត្រូវតែគោរពប្រណិប័តន៍ ថ្វាយបង្គំរំលឹកពល់យប់ថ្ងៃ ទើបពេញជាអ្នកមានកតញ្ញូកតវេទីចំពោះសាសនា មហាក្សត្រមែន ព្រោះព្រះអង្គជាបុព្វការីលើមន្ត្រីនឹងប្រជាពលរដ្ឋទាំងអស់ ព្រមទាំងមានទសពិធរាជធម៌ទាំង ១០ យ៉ាងនឹងព្រហ្មវិហារ ៤ ជាប្រមុខរបស់ទ្រង់ ជាមានទាមជាកដ្ឋា (រាជូបការៈ) ទ្រង់ចាត់ថាជាបុព្វការី ។

សេចក្តីដែលបានរៀបរាប់មកខាងលើនេះ ជាឈ្មោះនៃពាក្យថា សាសនា មានដំណែថ្លៃថ្លូវថ្លៃថ្លា សម្ងួត សន្តតថាចប់ដោយសង្ខេបប៉ុណ្ណេះ ឯង ។

ចប់



ការប្រែអក្សរខ្មែរ

ដាយ គិត-ពិន

ប្រែសណើយ៍នឹងទូរគមនាគមន៍ មេមត់ រៀបរៀង

ធម្មតា អក្សរជាតិជនក្នុងលោកដែលនឹងបានចំរើនរុងរឿង ហើយ ថ្ងៃថ្នូរនោះអាស្រ័យមកពីជនរួមជាតិនិយមប្រើ និយមរចនាវិចិត្រឲ្យមានលំអឡើង. ហើយយកចិត្តទុកដាក់ ប្រើឲ្យមានរបៀបរៀបរយទៅតាមសម័យលោកនិយម ។

ពាក្យពោលថា "អក្សរខ្មែរ ពីបុកប្រើពេក ច្រេងច្រងាងក្ងូកក្ងក់ច្រែនណាស់" ។ ពាក្យនេះជាពាក្យទាល់ច្រកផ្ទះ ដោយសារតែខ្លួនមិនចេះហើយក៏ថាទៅ ជាពាក្យតួតជនដែលពុំមានសេចក្តីស្រឡាញ់អក្សរសាស្ត្ររបស់ខ្លួន ពុំមានសេចក្តីស្នេហាជាតិ សាសនារបស់ខ្លួន ជាជនដេកចាំដកដង្ហើមតាមគេ ដេកផ្សងចាំព្រេងសំណាង ។

តាមពិតអក្សរខ្មែរយើងពុំមែនជាពីបុកប្រើទេ អ្នកដែលថាពីបុកប្រើនោះ មកពីអ្នកនោះឯងខ្វះសេចក្តីចេះដឹងក្នុងរបៀបប្រើអក្សររបស់ខ្លួនឲ្យបានរៀបរយសមរម្យទៅតាមសម័យនោះឯង ។

ក្នុងការប្រើអក្សរជាតិយើង យើងគួរយកលំនាំអក្សរបុរាំងវិសេសជារបៀប ព្រោះអក្សរជាតិបុរាំងនេះចំរើនរុងរឿងជាងគេក្នុងលោក ហើយយើងក៏ធ្លាប់បានឃើញ បានប្រើ បានតាំងសរសើរថា សម-ល្អ ថ្ងៃថ្នូរជាច្រើនឆ្នាំណាស់មកហើយ ។

ការប្រើមកុដរាជាតិយើងឲ្យខាន់សម័យនោះ, មុនដំបូងបង្អស់យើងត្រូវចេះប្រើនៅលើស្រោមសំបុត្រ ដែលយើងតែងផ្ញើទៅ - មកជារឿយៗ តាមប៉ុស្តិ៍ ប្រៃសណីយ៍ ទៅញាតិ - មិត្តយើង ព្រោះក្រសួងប្រៃសណីយ៍នេះ ជាទីចលនាចេញចូលនូវសំបុត្រស្មាម ដែលមានអក្សរសាស្ត្រគ្រប់ជាតិពាំងអស់ក្នុងសកលលោក ឋានចារនៅលើស្រោម ហើយមានរបៀបយ៉ាងប្លែកៗ ជាច្រើនយ៉ាងច្រើនបែប ។

អក្សរដែលចារនៅលើស្រោមសំបុត្រ ជារូបនិមិត្តរបស់អក្សរដែលនៅក្នុងស្រោមនោះឯង គឺថា បើអក្សរនឹងពាក្យនៅលើស្រោមមានសេចក្តីរៀបរយល្អ មានរបៀបល្អ អក្សរនឹងពាក្យដែលនៅខាងក្នុងស្រោមក៏មានសេចក្តីនឹងរបៀបរៀបរយល្អដែរ ។ បើខាងក្រៅពុំមានរបៀបល្អទេ នោះខាងក្នុងក៏អាចឲ្យគេសន្និដ្ឋានបានជាមិនល្អដែរ ។ ឯពាក្យថាល្អៗក្នុងទីនេះ ពុំបានបំណងយកតួអក្សរល្អដាច់តាំងទេ គឺយករបៀបល្អជាគោល ។

សូមអធិប្បាយយ៉ាងខ្លីៗ អំពីស្រោមសំបុត្រ នឹងរបៀបការស្រោមដូចតទៅនេះ :-

១ - ស្រោមសំបុត្រ - តាមរបៀបធម្មតា ស្រោមសំបុត្រដែលយកឲ្យសមល្អ គឺមានពាងបួនជ្រុងទ្រវែង បណ្តោយប្រវែង ១៤ សង់ទីម៉ែត្រ ទទឹង ១១ សង់ទីម៉ែត្រ (តែគង់មានតូចមានធំខ្លះ ច្រើន

បៃថ - យ៉ាង ស្រែចំតែនឹងចូលចិត្ត) កុំឲ្យតែធំពេកតូចពេក ។ ក្រដាស
ធ្វើស្រោម គេត្រូវចៀសវាង ក្រដាសដែលក្រាស់ឬរឹងពេក នឹងក្រ-
ដាសសសុទ្ធ ឬ ដែលមានបន្ទាត់ខ្វាត់ខ្វែង ។

๒ – ការស្រោម .– ការស្រោមសំបុត្រត្រូវសរសេរនឹងទឹកខ្មៅ
ជានិច្ច ហាមកុំឲ្យសរសេរនឹងខ្មៅដៃ ។ ត្រូវចាប់សរសេរពីពាក់កណ្តាល
ស្រោមចុះមកក្រោម ត្រូវដាក់នាមនឹងនាទីលំនៅយ៉ាងដាក់លាក់នៃអ្នក
ដែលយើងផ្ញើព្រមទាំងឈ្មោះ ដំបន់ ប៉ុស្តិ៍ប្រៃសណីយ៍នាទីនោះផង ។
សំបុត្រផ្ញើតាមប៉ុស្តិ៍ ត្រូវយកឈ្មោះប៉ុស្តិ៍ជាប្រធាន លើឈ្មោះស្រុកភូមិ
ដ្បូតប៉ុស្តិ៍ជាទីចាត់ការកន្លងកិច្ចនេះ ។ ប៉ុន្តែឈ្មោះប៉ុស្តិ៍ នឹងឈ្មោះស្រុក
ច្រើនតែស្របត្រូវគ្នា ស្ទើរតែទាំងអស់ តែគង់មានខ្វះខុសគ្នាដែរ ដូច
យ៉ាងស្រុកស្ទឹងត្រង (កំពង់ចាម) ប៉ុស្តិ៍ប្រៃសណីយ៍ហៅព្រៃកកក់ ។
សំបុត្រដែលកាន់ ដាក់ស្រុកស្ទឹងត្រង ពុំបានដាក់ប៉ុស្តិ៍ព្រៃកកក់ផង
នោះ ច្រើនច្រឡំហួសរហូតដល់ស្ទឹងត្រែងឯណោះ ទំរាំនឹងបានមក
ដល់ទីកន្លែងដើមវិញ ត្រូវខាតពេលអស់ប្រហែលជាដប់ថ្ងៃ នឹងបន្ទោស
នរណាក៏ពុំបាន ព្រោះជាការច្រឡំនាំឲ្យខកដំណឹងទេតើ ។

ចំណែកនាមនឹងទីលំនៅនៃយើងអ្នកផ្ញើត្រូវដាក់កាត់យ៉ាងខ្លី នៅ
ខាងលើពីខាងមុខឬពីខាងខ្នងស្រោមក៏បាន ប្រយោជន៍ដើម្បីបើសំបុត្រ
នោះទៅមិនដល់ឬរកឈ្មោះពុំឃើញ គេនឹងផ្ញើត្រឡប់មកយើងជាម្ចាស់
ដើមវិញ ។

តែមប្រើត្រូវបំពេញខាងលើតាមមុខស្រែមជានិច្ច ហើយបើយកឲ្យសមល្អ ត្រូវបំពេញនៅជ្រុងខាងស្តាំ ត្រូវបំពេញគ្នាតែកន្លែងមួយ កុំបំពេញឯណេះមួយឯណោះមួយឡើយ ដើម្បីឲ្យប៉ុស្តាយនឹងបោះត្រាសម្គាល់ផង ឲ្យមានកន្លែងទំនេរល្អមើលផង នៅលើកន្លែងទំនេរនេះ គេនឹងបោះត្រាមួយទៀតជានិច្ច ដែលអ្នកទទួលសំបុត្រអាចដឹងថាសំបុត្រនេះ ជាក់ប៉ុស្តនៅមាំងប៉ុណ្ណេះ ថ្ងៃនេះ ខែនេះ ឆ្នាំនេះជាដើម ។

ឯពាក្យត្រូវប្រើក្នុងរបៀបការស្រែមនោះ ត្រូវកុំប្រើពាក្យខ្មែនលំខោន, ពាក្យគួរសមឬពាក្យដែលឥតប្រយោជន៍ឲ្យសោះ ត្រូវប្រើតែពាក្យយ៉ាងងាយហើយបានការជានិច្ច ។

កុំការស្រែមដូចខាងក្រោមនេះ:

> សូមអាណិតមេត្តាបញ្ជូនសំបុត្រនេះឲ្យដល់ទៅឈ្មោះ មាស-ចន នៅឃុំកំពង់ស្វាយ ស្រុកស៊ីសុផុន ខែត្រ បាត់ដំបង ឲ្យបានជាប្រញាប់ៗ ផង

ការស្រោមបែបនេះ សូម្បីស្រោមទាំងមូលក៏ស្ទើរតែជាក់ពាក្យទាំងនេះមិនអស់ បើជាក់អស់គង់គ្មានកន្លែងនឹងបិទតែមប្រិ បើបិទបានក៏គ្មានរបៀប ។ ពាក្យ "សូមអាណិតមេត្តាបញ្ជូនសំបុត្រនេះ" ជាពាក្យសាបរលាបច្រើនឥតប្រយោជន៍ ។ យើងពុំបាច់សូមមេត្តាអំពីអ្នកណាទេ បើត្រូវការផ្ញើសំបុត្រគ្រាន់តែទិញតែមប្រិ ១រៀ ៥០ បិទជាក់ប៉ុស្តែទៅក៏រួចគ្នាស្រេច ។ ប្រាក់ ១រៀ ៥០ នេះជាថ្លៃឈ្នួលសំបុត្រយើង ដែលគេត្រូវតែផ្ញើឲ្យយើងដល់ទីកន្លែងខានមិនបាន ។

ពាក្យថា "ប្រញាប់ៗ" នេះ ក៏គ្មានបានផលអ្វី គ្រាន់តែគាប់ច្រើនឥតការ ហើយនាំតែឲ្យគេជិនឆ្អន់ ។ សំបុត្រជាក់ប៉ុស្តមិនត្រូវប្រញាប់ជាង កប៉ាល់ ឡាន ឬយន្តហោះ ដែលតែងតែធ្វើចលនាបើកបរហោះហើរសព្វទីកន្លែងរាល់ៗថ្ងៃនោះទេ ព្រោះសំបុត្រគេត្រូវចាត់ផ្ញើតាមយានទាំងនេះឯង ។

សូមកែរបៀបការស្រោមខាងលើនោះដូច្នេះវិញ :–

លោក មាស-បង

ឃុំកំពង់ស្វាយ-ស៊ីសុផុន

ចាត់ដំបង

ចាត់ដំបងដាក់ក៏ចានមិនដាក់ក៏ចាន ព្រោះជាឈ្មោះបន្ទាប់បន្សំទេ ហើយសូមកុំគិតខ្លាចថាប៉ុស្តិ៍មិនស្គាល់ ស៊ីសុផ្លូនោះ ។

របៀបការស្រោមមានច្រើនបែបច្រើនយ៉ាងណាស់ក្នុងទីនេះ ខ្ញុំពុំអាចដំរាបបានសព្វគ្រប់ទេ ទាំងគំរូការស្រោមក៏ពុំបានយកមកបង្ហាញជូនមើលដែរ ព្រោះយល់ថាអស់លោកគង់ធ្លាប់បានប្រទះឃើញពុំខាន ហើយការធ្វើសំបុត្រនេះមិនមែនជាការក្រទេ គឺគ្រាន់តែបានឃើញក៏អាចយល់បានធ្វើកើតដោយងាយ ។

ភាសាសជាតិ មារយាទសព្វជ

អក្សរដែលគេបានចារនៅលើស្រោមនេះ ទុកដូចជាភាសា ហើយសជាតិបានថាថ្លៃថ្លូរ ថារុងរឿងមានអារ្យធម៌ចំរើនថ្កុំថ្កើង ប្តូនថយអាប់ខ្មួយ៉ាងណាបានដែរ ។

ចំណែកស្រោមសំបុត្រវិញទុកដូចជាមារយាទដែលអាចសព្វជ នៃជនអ្នកច្រើចាស់ ថាមានសេចក្តីចេះដឹងច្រើន មានចារយាទរម្យទមល្អ មានរបៀបរៀបរយល្អ ប្តូកមានមារយាទអាក្រក់មិនសមសួន ។ល។ ជាដើម ។

ហេតុការណ៍ដូចពោលមកនេះ តើពាក្យថា "អក្សរសាស្ត្រជាគោលចារីតរបស់ជាតិ" នោះនឹងមានសេចក្តីសំខាន់ខ្លួលខ្លួលយ៉ាងណាទៅ កូនកិច្ចដែលត្រូវប្រែអក្សរជាតិនេះ ? ។

តាមពិត ស្រោមសំបុត្រ ១ ដែលជនម្នាក់ចាយជាអក្សរជាតិ
នៅលើនោះ ទោះជាមានរបៀបអាក្រក់ក្តី ល្អក្តី ក៏ពុំអាចឲ្យផលអាក្រក់
ឬផលល្អ ដល់ជនទាំងនេះបានឡើយ ។ ន័យនេះត្រូវយកភាគច្រើន
ជាប្រមាណគឺថាបើចេះមានភាគច្រើន ត្រូវថាចេះ បើល្ងង់មានភាគច្រើន
ត្រូវថាល្ងង់ ។

ដូច្នេះ ធម៌សាមគ្គី នឹងមានប្រយោជន៍សំខាន់ដូចម្តេចខ្លះក្នុង
រឿងនេះ?

ធម៌សាមគ្គីជាកម្លាំងធំបំផុត គឺបើសាមគ្គីរបរួមគ្នាជីកទន្លេនឹងបាន
កើតជាទន្លេ, បើរួបរួមគ្នាជួសជុលប្រាសាទនគរវត្តឲ្យបានគង់ទ្រង់ព្រះ
រាជដំហរទៅអនាគត នោះនឹងបានសម្រេចជាពុំខាន ។ បើរួបរួមគ្នាក-
សាងអក្សរសាស្ត្រ គឺយើងមានធម៌សាមគ្គីព្រមព្រៀងគ្នាប្រើអក្សរជាតិ
យើងវិញ តើអក្សរសាស្ត្រជាតិយើងនឹងមានវិវឌ្ឍរឿងស្ថិតស្ថេរបែរកាល
ទៅអនាគត ឬយ៉ាងណា? ។

សូមជនអ្នកស្រឡាញ់អក្សរសាស្ត្រ អ្នកស្រឡាញ់ជាតិសាសនា
រិនិច្ឆ័យ !!! ។

រឿងគ្រូសាញ់អ្នកខ្វាក់ទទួលគ្រែ

លោក ផេង-ជ្រើរ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែទំនៀមរៀបរៀង

(តពីរឿងអាយោនទាហានចាស់)

ក្នុងកាលដ៏កន្ទុងអង្វែងទៅហើយ មានព្រះរាជាមួយព្រះអង្គព្រះនាម ព្រះបាទវត្តា ។ ព្រះអង្គតែងព្រួយព្រះរាជហឫទ័យជានិច្ច ព្រោះក្នុងរាជ្យព្រះអង្គ ពួកយក្សបានធក់យកព្រះអាទិត្យព្រះចន្ទ្រពីលើមេឃទៅបាត់ ។

ព្រះមហាក្សត្រតែងញាំងរាជបុរសឲ្យប៉ាវគេងទួងកេរ៉ គ្រប់ស្រុកគ្រប់ភូមិថា បើឈ្មោះណា អាចធ្វើដូចម្តេចយកព្រះអាទិត្យព្រះចន្ទ្រពីកណ្តាប់ដៃយក្សមកបាន នោះព្រះអង្គនឹងប្រទានព្រះរាជធីតាឲ្យធ្វើជាភរិយា បែងព្រះរាជ្យជាពីរភាគ ហើយចែក១ភាគឲ្យទៀត, ប៉ុន្តែបើឈ្មោះណាហ៊ានទទួលបំពេញកិច្ចនេះ ហើយធ្វើការមិនសម្រេចវិញ នោះត្រូវយកទោសដល់ប្រហារជីវិត ។

មានអ្នកហ៊ាវហានជាច្រើនរូប បានលះបង់បំពេញកិច្ចដ៏ក្លាហាននេះ ។ ប៉ុន្តែវេលាចាប់ធ្វើការ គេរកមធ្យោបាយនឹងធ្វើពុំកើត ទំរាំងសុះចុះសុះខ្សែងរកផ្លូវទៅប្លាំងនឹងយក្សមិនកើត ។ ចំណែកព្រះមហាក្សត្រទ្រង់តាន់ពាក្យសត្យជានិច្ច ។

សម័យមួយ អ្នកហ៊ាវហានឈ្មោះគ្រូសាញ់ លុះបានជួនព្រះរាជ-បំណងដូច្នោះ ក៏គិតពិចារណាខ្លួរឿងនេះអស់អំឡុងដ៏យូរ ។ លុះទីបំផុត

មានសេចក្តីទុកចិត្តកង់ជំនួយនៃព្រះជាម្ចាស់ ទើសេចក្តីអង់អាចនៃខ្លួន
គាត់ប្រថុយទៅយកអាសានៃព្រះចៅផែនដី ។

ទៅតាមផ្លូវ គាត់ជួបមនុស្សពីរនាក់ដែលកំពុងនាំយក
ទៅគាន់ព្រះបរមរាជវាំងដើម្បីទទឹងសម្លាប់ ពីព្រោះគេបានរត់ចោលព្រះ
រាជាដែលកំពុងច្បាំងតដៃនឹងពួកយក្ស ។ អ្នកទោសទាំងពីរព្រួយពេក
មុខស្រងូត ។ បានឃើញដូច្នោះ គ្រូសាញ់ប្រើបិយភាដើម្បីលួង
លោមអ្នកទាំងពីរ ហើយនិយាយថាបាប់ថា ត្រូវឲ្យមានសេចក្តីក្លាហាន
ឡើងវិញ ព្រោះគ្រូសាញ់ធ្លាតក្នុងការនិយាយណាស់ សំដីផ្អែមដូចស្ករ ។

ការជួបទទឹងមនុស្សពីរនាក់នេះ ទាំងឲ្យគាត់មានសេចក្តីសង្ឃឹមហើយ
គិតទុកថា "អញផ្សងសំណាងលមើល ។ បើអាត្មាអញសុំទោសឲ្យ
មនុស្សពីរនាក់នេះ ពីព្រះករុណាបាន នោះអញក៏ត្រូវហានប្រថុយ
បំពេញកិច្ចដទៃទៀត, បើមិនដូច្នោះទេ អញត្រូវបង្ហាញខ្លួន ដោយ
ត្រូវវិលទៅផ្ទះវិញ ។ ធ្វើដូច្នេះទើបល្អ មិនត្រូវបង្ហាញខ្លួនដោយការ
ពិសោធន៍ឥតប្រយោជន៍" ។

កំពុងវិតក្កកង់ចិត្តគិតចុះឡើង គាត់បានទៅដល់ព្រះរាជដំណាក់
គ្រូសាញ់ចូលគាល់ព្រះមហាក្សត្រ ហើយចេះក្រាបទូលពីនេះពីនោះ
ដោយការប្រើសំដីដ៏ពីរោះ ទាល់តែព្រះរាជាទ្រង់ជ្រាបដោយព្រះអង្គឯង
ថាទ្រង់ជាបុគ្គលអសប្បុរស បើសម្លាប់អ្នកទោសពីរនាក់នេះ, បើទុកវា

ពៅ ទឹងបានកើនមនុស្សជាពលរដ្ឋពីរនាក់ បើទ្រង់ឥតព្រះមេត្តា នោះ
ទឹងបាត់តឿមានក្តើអាក្រក់ដល់រូបទ្រង់ឡើងទៀត ។

បុរសកំសត់ទាំងពីរនាក់ លុះបានដឹងថាគ្រូសាញ់សុំឲ្យខ្លួនបានរួច
ពីទោសកាលណា ក៏មានសេចក្តីត្រេកអរក្រៃលែងប្រៀបគ្មាន ។ គេសូម
អរគុណជាអនន្តអានេកដល់គាត់ ហើយសូមយកជីវិតរបស់គេទៅប្តូរជួយ
បំពេញមហន្តកិច្ចរបស់គាត់ ហើយសូមស្បថស្បែនៅចំពោះមុខកណ្តាល
ខេត្ត ។

ជ័យជំនះទីមួយរបស់គាត់ជាប្រផ្លូវដ៏ត្រៃ ដែលនាំគ្រូសាញ់
ហ៊ានចូលទៅគាល់ព្រះពជាជាថ្មីម្តងទៀត ហើយក្រាបបង្គំទូលដូច្នេះថា:
បពិត្រព្រះសម្មតិទេពដ៏ទ្រង់ទូវតេជាទុកាព សូមព្រះអង្គទ្រង់ជាសុខក្តី
សិរីរាជសម្បត្តិអស់កាលជាយូរអង្វែងតទៅ ។ ឥតមានពួកអ្នក
ហាវហានជាច្រើនរូប ទំយកចិត្តទុកជាក់ដើម្បីដណ្តើមព្រះអាទិត្យនឹង
ព្រះចន្ទ្រពីក្រងអស្ចារ្យ ហើយបានត្រូវស្លាប់ខ្លួនអស់ដោយការបំពេញ
ការណីយកិច្ចមិនសម្រេច ។ បពិត្រព្រះទ្រង់យសទូលព្រះបង្គំមានបំណង
ចង់ផ្សងព្រេងសនាម្តងមើល ក្នុងការស្វះស្វែងដើម្បីរកចាប់ពួកអាចិត្តមោហា
ទាំងនោះ ។ ដោយអាស្រ័យជំនួយនៃព្រះជាម្ចាស់ ប្រហែលទូលព្រះ
បង្គំអាចនឹងសម្រេចជាក់ខ្លួនកម្ម ដល់ពួកយក្សទាំងនោះ ព្រោះតែចិត្ត
ព្រហើនកោងកាចរបស់វាជាមិនខាន ។ តើព្រះគុណាថ្លៃវិសេសនឹង
មានព្រះហឫទ័យមេត្តាករុណាចំពោះទូលព្រះបង្គំផងឬដូចម្តេច ? ។

ព្រះរាជាមានព្រះរាជឫទ្ធារថា: ម្នាលគ្រូសាញ់! យើងនឹងមិនអាចផ្ទាស់ប្តូរនូវសេចក្តីសម្រេចរបស់យើងតែម្តងបន្តិចបន្តួចក៏ពុំបាន ។ ពាក្យទាំងនោះគឺជាការជាប់ស្រេចឥតរើរុះ ព្រោះយើងជាអ្នកកាន់ពាក្យសត្យ ។ យើងចង់ឲ្យព្រះរាជបញ្ជាយើងតាំងនៅ មានតម្លៃស្មើគ្នា ទាំងផ្ទៃដែនព្រះរដ្ឋ ។ យើងមិនចង់ឲ្យមានការជំនិតស្តិតរវាងយើងឡើយ ។

បានឃើញសេចក្តីសម្រេចនោះ ពាក្យសត្យនៃព្រះរាជានឹងព្រះរាជ-បំណងដែលបន្ទន់មិនបានដូច្នោះ គ្រូសាញ់ក្រាបទូលដោយសំដីភ្ញាក់ផ្អើលថា: បពិត្រព្រះករុណាវិសេស សូមព្រះរាជបំណងសម្រេចចុះ? តោះបើទូលព្រះបង្គំជំងឺថា សេចក្តីស្លាប់ដេញតាមកិតពីក្រោយក៏ដោយ ក៏ទូលព្រះបង្គំមិនថយរួញរាឡើយ មុនដែលមិនទាន់បានបំពេញឲ្យដល់ទីបំផុតនូវការណីយកិច្ចដែលត្រូវធ្វើដោយសេចក្តីពេញចិត្តនេះ ។

លុះបានចុះខសន្យាទៅវិញទៅមក រវាងព្រះរាជានឹងគ្រូសាញ់ហើយគាត់ទៅពីរបីថ្ងៃក្នុងព្រះរាជធានី ដើម្បីរៀបចំប្រជាប់ប្រជានឹងធ្វើការជំនុំឲ្យប្រកបដោយសិរីសួស្តី រួចទើបគាត់ធ្វើដំណើរចេញទៅ ។

គ្រូសាញ់នាំបុនរបស់គាត់ទៅផង ។ ជនទាំងពីរត្រែចទៅអស់កាលជិយូរ គាត់ដៃព្រៃ គាត់កំភូ ធ្វើទន្ទេបីងបួ ហើយបានដល់ផ្ទះជាងដែកមួយជាសំឡាញ់គាត់គឺជាជាងធ្នាតវៃបំផុតលើផែនដី ថែមទាំងជាអ្នកចេះខាងមន្តវិជ្ជាដ៏ប្រពន្ធផង ។ បង្អួនពីរនាក់ឈប់នៅទីនោះអស់បីថ្ងៃបី

យប់ រួចគ្រូសាញ់ទឹងជាងដែក ចូលកន្ទបទូប់មួយតែពីរនាក់ ហើយ
ជំនុំធ្វើកត្តិកាសញ្ញានឹងគ្នា ។ ព្រឹកស្អែកឡើង ជនជាបងប្អូនកំបន្ត
ដំណើរទៅទៀត ។ ចំណែកជាងដែក គិតតែធ្វើរូបតំណាងរូបគ្រូសាញ់
មួយពីដែកហើយយកទៅជាក់ក្នុងក្តើង សប់ឲ្យឡើងក្រហមទាំងយប់
ទាំងថ្ងៃឥតឈប់ឈរ ។

គ្រូសាញ់ទឹងប្អូន ដើរទៅ។ បានដល់ផ្ទះបំបែកមួយ នាំគ្នាឈប
បរិភោគអាហារដែលនៅសល់ រួចក៏បែកគ្នា យំសោកដូចក្មេង ។ មុនទឹង
ធ្វើដំណើរចេញ បងប្អូនប្លែកូនកន្ទែងគ្នា ហើយមានពាក្យថា កាលណា
កូនកន្ទែងដែរហែកតែជាយទេ យើងទាំងពីរនាក់នៅមានសេចក្តីសង្ឃឹម
ថា ទឹងអាចបានជួបគ្នាវិញ បើកាលណាកូនកន្ទែងរហែកចំកណ្តាល
គឺអ្នកណាម្នាក់ស្លាប់ហើយ ។ គេយកកាំបិតស្នៀតមួយ ជាក់ទុកក្នុងដី
ទៀត ហើយមានសេចក្តីថា: បើអ្នកណាត្រឡប់មកមុន ហើយដក
កាំបិតឡើងឃើញមានច្រែះ នោះមិនត្រូវឈប់ចាំឡើយ ត្រូវតែជាអ្នក
ម្នាក់ទៀតស្លាប់ហើយ ។ រួចពីនោះ គ្រូសាញ់ទៅតាមផ្លូវខាងស្តាំ
ប្អូនទៅតាមផ្លូវខាងឆ្វេង ។

ប្អូនគ្រូសាញ់ ខាងក្រោយដែលបានដើរត្រចុះឡើងឥតប្រយោជន៍
អស់អំឡុងដ៏យូរ ក៏ត្រឡប់មកផ្ទះបំបែកវិញ ដកកាំបិតមើលឃើញគ្មាន
វិតអ្វីសោះ ហើយរង់ចាំបងនៅទីនោះ ដោយសេចក្តីតែងរកអ្វីប្រៀប

គ្មាន ។ បើមានដូចជាគេបានឃើញព្រះអាទិត្យនឹងព្រះចន្ទមកបាំតនៅឰដ៏លើមេឃជាថ្មីឡើងវិញ ។

ចំណែកគ្រូសាញ់ ត្រែចទៅៗ តាមផ្លូវតែមួយ ក៏បានដល់នគរស្ពៃច្រយក្សដែលតាំងនៅកណ្តាលទីបំផុតនៃផែនដី ។ ឃើញដូច្នោះ គាត់សូត្រអាគមន៍ លោតបាដង និម្មិតខ្លួនជាព្រាបតាមសេចក្តីបង្គាប់របស់ជាងផែនដី រួចហើរទៅទំលើដើមឈើមួយ ជុះអំពីមុខប្រាសាទយក្ស ។

ពេលនោះ កូនស្រីរបស់យក្សចេញមក ឃើញព្រាប ហើយចូលទៅវិញភ្លាម និយាយប្រាប់ម្តាយ នឹងប្អូនស្រីឲ្យចេញទៅមើលបក្សីអ្វីល្អអស្ចារ្យ ។

ប្អូនស្រីវានិយាយថា: នែលោកម្តាយ ! នែអ្នកបង ! បក្សីល្អនេះបើតាមយោបល់ខ្ញុំ គឺដូចជាប្រផ្នូលអកុសលដល់ប្រាសាទយើង ។ ក្អែកវាដូចជាមិនច្បាំនឹងក្អែកបក្សីឯទៀតសោះ គឺដូចជាក្អែកគ្រូសាញ់សក់ក្រហម ។ បើពិតដូច្នោះមែន សេចក្តីអន្តរាយរបស់យើងមកដល់ហើយ ខ្ញុំ ! ពីពេលនេះទៅ សូមព្រះជាម្ចាស់អាណិតមេត្តាដល់យើងនឹងក្រុមញាតិរបស់យើងផង ។ ជ្រុតពួកយក្សទាំងប៉ុន្មានមិនមែនជាមិនដឹងសេចក្តីហាវហានរបស់គ្រូសាញ់ឡើយ ។

មេយក្ខិនីទាំងបីអង្គ ត្រឡប់ចូលទៅកាន់ប្រាសាទវិញ ដើម្បីពិចារណាគ្នា ។ គ្រូសាញ់លោតបាដងក្រឡាខ្លួនជារុយ ហើរចូល

តាមមេយក្ខិនីក្នុងបន្ទប់ លះបង់ពួនខ្លួនដ៏ឮពិតាន ក្នុងក្រហែងផ្ទាន ហើយស្តាប់ឮក់និយាយប្រឹក្សាគ្នាអំពីអ្វីៗទាំងអស់ ។ ឮស្តាប់ឮសព្វគ្រប់ហើយ គាត់ត្រឡប់ចេញមកវិញ ធ្វើដំណើរទៅព្រៃបៃតង ក្លែងខ្លួនជាមនុស្សឡើងវិញ ហើយចូលពួនចាំនៅក្រោមស្ពានមួយ ។

ឥឡូវនេះ គាត់ដឹងច្បាស់ថា ពួកយក្សទាំងឡាយទៅបរបាញ់ក្នុងព្រៃបៃតង ហើយវិលត្រឡប់មកវិញ ខ្លះពេលព្រលប់ ខ្លះកណ្តាលអធ្រាត្រ ចំណែកក្រុងអស្តរិន្ទ ស្តេចយក្ស ពេលសងកើតជិតព្រះអរុណរះ ។

មិនយូរប៉ុន្មាន ក្រឡេកពីក្រោមស្ពានទៅ គ្រូសាញ់ឃើញកូនយក្សដែលក្មេងជាងគេមកដល់ ប៉ុន្តែសេះដែលវាជិះ លុះដឹងនឹងក្លិនស្ពានស្រែកកញ្ជ្រៀវលោតថយក្រោយ ជ្រុំពីរដំហាន ។ កូនយក្សខឹងណាស់ស្រែកថា: យី! ចចកបំរុងនឹងស៊ីសេះ? អញគ្មាននរណាមកធ្វើឲ្យភ័យខ្លើយក្នុងលោកនេះ ក្រៃជាតែគ្រូសាញ់ ។ សូម្បីគ្រូសាញ់ក៏ដោយ កំសុះនឹងដៃអញមិនរួចដែរ ។

ឮពាក្យដូច្នោះ គ្រូសាញ់ឡើងឈរលើស្ពានហើយស្រែកថា : ម្នាលចោរចង្រៃ អាឯងមកដល់ហើយ ? យើងច្បាំងគ្នាដោយអាវុធឬលេងនឹងដៃទេ ? ។ ដោយដៃទេ គឺត្រឹមត្រូវល្អ ។

ជនទាំងពីរចាប់ចោកគ្នាទៅវិញទៅមក ។ យក្សចាប់គ្រូសាញ់លើកឡើង បុកចុះទៅក្នុងដីកប់ដល់ជង្គង់ ។ ចំណែកគ្រូសាញ់ចាប់យក្ស

លើកម្ពង់វិញ បុកកប់ចុះដល់ក រហើយយកដាវកាត់ត្រីមក្បាល ។ រួច
ចាប់ខ្មោចយក្សចោលទៅក្រោមស្ពាន គាត់ឈប់សម្រាកបន្តិច ។

ដល់កណ្តាលអធ្រាត្រ យក្សមួយទៀតមកភ្លាម ម្ពង់នេះលោត
ថយក្រោយដប់ជុំពីរដំហាន ភ្ញាក់ផ្អើល ហើយនិយាយដូចយក្សជាប្អូន
ទៀត ។ គ្រូសាញ់ស្ទុះចេញមកឆ្លើយដូចមុន ហើយចាប់តយុទ្ធគ្នា ។
យក្សនេះចាប់លើកគ្រូសាញ់បុកចុះទៅក្នុងដីលិចដល់ចង្កេះ ។ ប៉ុន្តែ
គ្រូសាញ់បម្រះស្ទុះងើបឡើងយ៉ាងរហ័ស ហើយចាប់យក្សបុកលិចត្រឹមក
រួចយកដាវកាត់កម៉ាត់ ។ គាត់ចោះខ្មោចយក្សទង់ខ្មោចសេះ ឲ្យទៅ
ជួបគ្នានៅឯក្រោមស្ពានទៀត ។

លុះសងកើត ម្ពង់នេះមែនទែនហើយ ។ ក្រុងអសុរិន្ទ្រដិះលើសេះ
ឆាំតមេយផាយមកពីនាយ ។ លុះរៀបទ្វង់ស្ពាន សេះលោតចិតសិប
ជំហានថយក្រោយ ។ ខឹងក្រៃពេក រឿងបន្តិចបន្តួចនេះហាក់ដូចជា
ការណ៍ដ៏សំខាន់អស្ចារ្យ ក្រុងអសុរិន្ទ្រស្រែកគំហឹមថា : យី! ចចកចង់
ស៊ីសេះ ? អញគ្មានខ្លាចអ្នកណា ទាំងអស់នៅលើផែនដី រៀវលែងតែ
គ្រូសាញ់សក់ក្រហម ។ ហើយគ្រូសាញ់ហ្នឹងទៀតសោត អញសំឡឹង
ឲ្យចំព្រវលែងតែមួយព្រួញក៏ទំនឹងសូន្យដីរឹត ។

(មានត)

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាចាល័រង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណាគុរ័ក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យអ្នកពិនិត្យកែ

(តមក)

---

៥ – បិត្តប្រកបដោយយុត្តិធម៌ :– បានដល់ចិត្តដែលប្រកបដោយធម៌ទៀងត្រង់ រក្សាសិទ្ធិគឺអំណាចដែលត្រូវតាមធម៌ ក្នុងចំណោមគួរបានគួរមានរបស់មនុស្ស ធ្វើឲ្យអ្នកបានអ្នកមានពេញចិត្ត ដោយឃើញថាជាការស្មើភាគគ្នា សមគួរដល់ចំណែកដែលខ្លួនគួរបានគួរមាន ប្រាសចាកការកិតក្បត់ខ្ពស់ទាប ដែលជាហេតុឲ្យកើតទោមនស្សគួចចិត្ត ឬអៀនខ្មាសចំពោះគ្នានឹងគ្នា នេះជាការយុត្តិធម៌ ។ ការយុត្តិធម៌ដែលពិតប្រាកដនោះ ត្រូវប្រកបដោយអង្គគឺការទៀងត្រង់ ការត្រឹមត្រូវតាមធម៌ នឹងការដឹងទាន់ នេះជាអង្គនៃសេចក្តីយុត្តិធម៌ ។

អង្គគឺការទៀងត្រង់ ជាគោលត្រូវមានដល់អ្នកដែលមានចំណែកគួរបានគួរមាន ។ អង្គគឺការត្រឹមត្រូវតាមធម៌នឹងការដឹងទាន់ ជាគោលត្រូវមានដល់អ្នកមេចំណែក ដែលត្រូវបែងចែកឲ្យត្រឹមត្រូវដល់បុគ្គលដែលមានសិទ្ធិគួរបាន ខ្នួលតាមចំណែករបស់ខ្លួន ។ អង្គទាំង ៣ នេះជារនាំងដែកនៃយុត្តិធម៌ អាចការពារភ័យបានល្អបំផុត ។ នៅទាង

ក្រែមម្ចប់នៃសេចក្តីយុត្តិធម៌ដែលច្រកបត្រមដោយអង្គ ៣ នេះ នឹងមិនមាននរណាជាមនុស្សវៀចវេរ នឹងមិនមាននរណាត្រូវរងអំពើអយុត្តិធម៌ឡើយ ។

ចិត្តដែលច្រកបដោយយុត្តិធម៌នោះ ជាចិត្តអាចច្រៀសចេញនូវសេចក្តីខ្វៀងត្រង់ឲ្យដល់អ្នកដទៃ ជាគោលសន្តិសុខនៃពួកគណៈជាម្ចប់ពោធ៌ ម្ចប់ជ្រៃដែលអ្នកកេ្តៀចូលមកជ្រកបានត្រជាក់ ។ បើមានតាទីត្រួតត្រងមនុស្សក៏ត្រួតត្រងដោយមនោសិទ្ធិ នឹងមនោរសជាភ្លក្ស គឺដៃឆ្វេងកាន់ស្បោងជ្រាក់ ដៃស្តាំកាន់រំពាត់ ។ បើនឹងធ្វើទោសដល់អ្នកខុស ក៏គិតពិចារណាអង្កេតការណ៍ច្រើនលើកសិន ។ សូម្បីនឹងឲ្យបំណាច់រង្វាន់ដល់អ្នកធ្វើត្រូវ ក៏សាកសួរថ្លឹងមើល លៃមើល ឲ្យគាល់តែចិត្តយល់ច្បាស់សិន ។ មិនត្រួតត្រងដោយមនោឫទ្ធិនឹងអាជ្ញាសិទ្ធិ គឺដៃឆ្វេងកាន់ជាវ ដៃស្តាំកាន់លំពែងដែលជាការមានតែសត្រូវខាំងអស់ ។

បើមានតាទីជាក្រុមសំងាត់ ឬសួរចម្ងើយ ចំពោះអ្នកដែលមានកំហុសក្នុងព្រះពុទ្ធញ្ញត្តិច្បាប់ទំលាប់ ក៏មិនភ្លេងធ្វើការដែលមិនគួរធ្វើ ឬវៀរការដែលមិនគួរវៀរ មិនជួយអ្នកខុសឲ្យរួចចាកអាជ្ញា មិនភ្លេងធ្វើឲ្យអ្នកឥតខុសទទួលអាជ្ញា ឬឲ្យអ្នកខុសតិចទទួលអាជ្ញាច្រើនហួសកំហុស ។ សូម្បីមានតាទីខាងតុលាការ ក៏ធ្វើការកាត់ក្តីដោយច្រយ័ត្នច្រយែង មិនច្រើអំណាចឲ្យខុសច្បាប់ដោយឃើញសំណូក ដូចជាមិនឃើញសំណូក មិន

ទទួលសំណូក កុងតាលដែលមានគេមកសូក គោះជាសំណូកនោះ ធ្វើឲ្យចម្រើនដល់ខ្លួនក៏ដោយ ប្តូរប្តេជ្ញាចិត្តថា នឹងមិនទទួលសំណូក ជាអាណាប្រយោជន៍ផ្ទាល់ខ្លួន ។ មនុស្សថោកទាប តែរមែងបានទទួលសេចក្តីកុំណា ដែលគេគ្មានទឹកសង្ឃឹមថានឹងបានទទួលសោះ ។ សូម្បីអ្នកសូកសួរ ក៏ខ្លួនមិនក្លែងជាក់ទោសគ្រោះយើញថា ជាអ្នកមានសម្បត្តិដើម្បីឲ្យគេសូកដែរ ។ មនុស្សបែបនេះឯងជាគោលនៃការរៀបរយត្រជាក់ត្រជុំ ជាទីសុខសម្រាន្តនៃក្រលែងរបស់ប្រទេសជាតិ ។

អ្នកមានចិត្តប្រកបដោយយុត្តិធម៌ សូម្បីមានអំណាចក៏នៅតែប្រើអំណាចត្រឹមតាមខ្នែត្រជែន ចំលាក់អំណាចរបស់ខ្លួនចេញ មិនត្រាន់តែថាមានអំណាចហើយ ក៏សង្កត់សង្កិនគេតាល់តែហួសហេតុនោះឡើយ ដូចជានាយក្នាក់ងារដែលប្រើអំណាចកុងដំណែងខុសច្បាប់ នឹងអ្នកដែលមាននាទីខាងការថែរក្សាសុខទុក្ខរបស់ប្រជាពលស្តួ តែឲ្យប់ជាប្រើអំណាចរបាន់បង្កាប់កំហែងឲ្យគេឲ្យប្តូរឲ្យគេរកទ្រព្យប្តូរផលប្រយោជន៍ដែលខុសច្បាប់មកឲ្យខ្លួន ធ្វើការសង្កត់សង្កិនពលរដ្ឋឲ្យបានសេចក្តីក្តៅក្រហាយ ធ្វើដោយល្មើសច្បាប់ បង្កាប់ឲ្យគេចូលទ្រព្យ ប្លាក់ មានដោយឥតហេតុ នឹងលំអៀងទៅកុងអគតិ យើញថាច្បាប់ឲ្យជាក់ទោសហើយ ក៏គិតតែពីជាក់តាមអំពើចិត្ត, រឿងក្តីប្តឹកិច្ចការដទៃទៀត ដែលគួរធ្វើហើយភ្លាម ក៏ក្លែងធ្វើឲ្យយឺតយូរ ធ្វើឲ្យប្រជាពលស្តួរកខានខាតការងារអាជីវៈដែលជាគ្រឹងចំរើនដល់ប្រទេសជាតិ ។

មនុស្សអយុត្តិធម៌ មនុស្សចិត្តអាក្រក់ឱនឯមនុស្សល្អ ចាត់ជាកេត
របស់ជាតិ ព្រោះអាចធ្វើឲ្យប្រទេសជាតិ កើតរឹតវេចលាចល ជ្រួល
ជ្រើម ក្តៅក្រហាយ ។ អ្នកប្រើអំណាចខុសធម៌ មើលងាយដាក់ជាន់
គេឲ្យវិនាសនឹងក្តៅក្រហាយយ៉ាងនេះ ឈ្មោះថាដុតលោកឲ្យឆេះ ។
មិនតែប៉ុណ្ណោះឡើយថែមទាំងដុតខ្លួនឯងឲ្យវិនាសផង ព្រោះនឹងត្រូវទទួល
អំណាចបៃបនោះមកវិញ ក្នុងកាលដែលខ្លួនអស់អំណាច ដូចពស់វែក
ដែលត្រូវស្រមោចស៊ីវិញ ក្នុងកាលដែលវាថយកំឡាំងដូច្នោះ ។ "ទឹក
ឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី" នេះជាដម្រាបុរាណ
ចូរចាំឲ្យជាក់ ។

លោក-អ្នកប្រុសស្រីទាំងឡាយ ត្រូវកុំធ្វើដូចគេទាំងនោះឡើយ
ទោះជាតាំងនៅក្នុងដំណែងនាទីបៃបណាក៏ដោយ ក៏គួរតែមានចិត្តប្រកប
ដោយយុត្តិធម៌ ធ្វើការឲ្យត្រឹមត្រូវតាមទំនងនីតិធម៌ នឹងប្រតិបត្តិឲ្យត្រូវ
តាមមុខក្រសួងរបស់ខ្លួនដោយសុចរិត ត្រូវធ្វើឲ្យសមគួរដល់ចិត្តគេចិត្ត
យើង ស្រឡាញ់មិត្តភក្តិក្នុងលោកឲ្យដូចជាស្រឡាញ់ខ្លួន ។ អំពើ
ណាដែលគេធ្វើមកលើយើងៗ មិនពេញចិត្ត យើងមិនត្រូវធ្វើអំពើនោះ
ដល់គេឡើយ លុះតែអំពើណាដែលគេធ្វើមកលើយើងៗ ពេញចិត្ត សឹម
យើងធ្វើអំពើនោះតបទៅគេវិញ ។ សេចក្តីល្អ សេចក្តីត្រូវនោះទៀត
បើខុកជាលោក-អ្នកខំធ្វើទៅហើយ ត្រឡប់ជាបានអន្តរាយ បានគាប់

ខ្មុចមាត់ ជាខ្លួលភ័យ ជាខ្លួលខ្លុកខោសដល់ជីវិត ជាខ្លួលការខើសខាក់ ខឹងជាខ្លួលពាក្យដំខៀលថាជាមនុស្សអាក្រក់ក៏ដោយ ក៏កុំលះបង់សេចក្តីល្អ សេចក្តីត្រូវនោះចោលខ្លើយ គួរប្រតិបត្តិឲ្យមាំមាំ ចំពោះតែដែលត្រូវធម៌ ។ សូម្បីសេចក្តីល្អរបស់មនុស្សដទៃ ក៏ជាកិច្ចដែលលោកអ្នកគួរនឹកដល់ នឹកឲ្យត្រូវធម៌ ដើម្បីរក្សាសិទ្ធិក្នុងផ្លូវល្អដែលគេគួរបាន ដូចជារបស់ណាមួយដែលជាប់ទាក់ទងនឹងលោក-អ្នក បើតាមផ្លូវយុត្តិធម៌ ត្រូវបានទៅគេ តែគេលំបាកយក ព្រោះទៅជាប់ទាក់ទងក្នុងអំណាចរបស់លោក-អ្នក ឬអ្នកដទៃ ក៏លោកអ្នកគួរអើពើរកវិធីដែលនឹងឲ្យគេបានខ្លួលតែនោះដោយស្រួលខ្លើង ។

អត្ថន័យនៃសេចក្តីល្អដែលគួរឲ្យដល់សត្រូវ គឺកុំប្រកាន់ខោស ដែលគួរឲ្យដល់មិត្ត គឺចងមិត្តភាពឲ្យស្និទ្ធ, ដែលគួរឲ្យដល់ខ្លួនឯង គឺកែខ្លៃ ឈ្មោះ ហើយដែលគួរឲ្យដល់មនុស្សខ្លួខៅ គឺចិត្តប្រែកបដោយយុត្តិធម៌ ។ ដូច្នេះ លោក-អ្នក ចូរយកឈ្នះមនុស្សក្រោធដោយមិនក្រោធតប, ផ្តាញ់មនុស្សមិនល្អ ដោយធ្វើល្អតប, រម្ងាប់ពៀរចេញ ដោយមិនចងពៀរចុះ, ព្រោះវិធីនេះ ជាគន្លងផ្លូវនៃយុត្តិធម៌ មិនមែនជាវិធីធ្វើឲ្យខោសចំរើនខ្លើង ដោយការធ្វើអាក្រក់តបនឹងអាក្រក់ខេ គឺជាវិធីតបតនឹងសេចក្តីអាក្រក់ដោយសេចក្តីល្អ ។

លក្ខណៈចិត្តសុភាព ៩ ប្រការនេះ រមែងធ្វើភាពជាមនុស្សសុខសម្បន្នរុងរឿងឲ្យសម្រេច នាំឲ្យមនុស្សចេះគិតជួយមិត្តភក្តិផងគ្នាឲ្យ

ផ្តួចចាកទុក្ខភ័យ ផ្តើមសេចក្តីចំរើនរបស់ពួកគណៈឲ្យចំរើនត្រៃលែងឡើង នឹងចងក្រងសេចក្តីព្រមព្រៀងគ្នាឲ្យជាប់នៅកងសន្តិសុខ ។ កងណាមានសេចក្តីវិនាសអន្តរាយ ឬសេចក្តីលំបាកខ្លាំងឡើង ឬក៏សេចក្តីទីគាល់ត្រូវលំបាក ត្រូវជាបត្តដ្ឋស អ្នកដែលមានចិត្តសុភាព រមែងបញ្ជូនដៃចូលទៅជួយគេកងទីនោះ ព្រោះការបានឃើញគេមានទុក្ខភ័យ ឬបានឮសំឡេងគេស្រែកថ្ងូរនោះ ជាការដែលនាំឲ្យរន្ធត់ដល់ចិត្តរបស់អ្នកសុភាព ។ ទឹកដែលថ្លាបំផុតគឺទឹកចិត្ត ។ ដូច្នេះ អ្នកមានទឹកចិត្តសុភាព ទើបត្រាំនៅស្ងៀមពុំបាន ទំរាំបញ្ជាប់ប្រញាប់បញ្ជូនអង្គាស្រយ័មេត្រី ចូលទៅជួយភ្លាមៗ ធ្វើឲ្យអ្នកមានទុក្ខកើតសេចក្តីកក់ក្តៅចិត្តនឹងមានសេចក្តីរីករាយ បំបាត់ទុក្ខទៅបានដូចជាពន្លឺភ្លឺរុងរឿងដែលចូលទៅកងបន្ទប់ អាចកំចាត់ងងឹតចេញបានដូច្នោះ ។

ចិត្តសុភាពជាចិត្តខ្ពស់ សូម្បីមេឃដែលថាខ្ពស់ ក៏នៅតែទាបជាងចិត្តសុភាព ។ ចិត្តសុភាពនេះជាឫសគល់នៃសេចក្តីសុភាពទាំងពួង ។ ព្រោះថាកាលបើចិត្តសុភាពហើយ រមែងនាំឲ្យកាយវាចាសុភាពតាម បើចិត្តខូច កាយវាចាក៏ខូចតាមដែរ បើទុកជាខំកែងធ្វើកិរិយានឹងវាចាឲ្យសុភាពយ៉ាងណាក៏ដោយ ក៏គង់មិនផុតពីពាក្យថា "ខាងក្នុងដំហៅ ខាងក្រៅសរជា" ឬថា "ខាងក្រៅរលាំ ខាងក្នុងលួយ" ឬក៏ថា "ចិត្តជាទេវតា មាត់ជាទេវតា" ។ ព្រោះការកែងធ្វើឲ្យសុភាពតែខាងក្រៅ

មិនមែនសុភាពចេញមកអំពីកិតចិត្ត គន់តែឆ្លាក់នៅកន្លែងភាពជាអ្នកមានចិត្តខ្ពប អាចឲ្យកើតពោសកន្លែងគ្រោយបាន ដូចកន្លែងដម្រាមួយថា:

កាលពីមុន នឹកថាមាស ដម្លុះ
ជាតិបរិសុទ្ធ ដូចសាច់មាស នឹកជុំបី
លុះដេញទៅ ស្រាប់តែយើញ ខុសប្រក្រតី
ទើបដឹងថ្មី ថាជាពូជ នៃទង់ដែង ។

មនុស្សចិត្តសុភាព រមែងមានភូមិធម៌ជាទីអាស្រ័យ មិនយើញចំពោះតែសេចក្តីសុខ សេចក្តីចំរើនចំណែកខ្លួនម្យ៉ាងទេ រមែងសំឡឹងយើញដល់សេចក្តីសុខ សេចក្តីចម្រើនរបស់អ្នកឯទៀតផង ប្រើកាលវេលាក្នុង ១ ជីវិត ធ្វើតែសេចក្តីល្អ ដើម្បីសេចក្តីស្ងប់ចំពោះខ្លួនឯងមនុស្សពាលមូល សូម្បីនៅកន្លែងស្រុកតូច។ ក៏គន់ប្រសើរជាងមនុស្សមានចិត្តជាទាស:ថោកទាបដែលសម្ងំនៅកន្លែងស្រុកធំៗ ។ ព្រោះសេចក្តីវិនាសនឹងការមិនរៀបរយ រមែងកើតមកតែអំពីមនុស្សចិត្តអាក្រក់ម្យ៉ាង ។ ចំណែកសេចក្តីចំរើននឹងការស្ងប់រៀបរយ ទើបកើតមកតែអំពីមនុស្សចិត្តសុភាព ។ បើលោក-អ្នកមានចិត្តសុភាពហើយ លោក-អ្នកនឹងអាចលើកស្ទួយថ្លៃប្រមាត់របស់ប្រទេសជាតិ ឲ្យខ្ពស់ក្រៃលែងឡើងបាន ទាំងបានឈ្មោះថាជាអ្នកធ្វើគុណយ៉ាងធំបំផុតឲ្យដល់ប្រទេសជាតិ ។ ដូច្នេះ ការរំលាយចិត្តអាក្រក់ ឲ្យក្លាយទៅជាចិត្តសុភាព ឲ្យក្លាយទៅជាចិត្តខ្ពស់ ឲ្យក្លា

ទៅជាចិត្តមានប្រយោជន៍ ទើបជានាទីដែលយើងត្រូវតែយកចិត្តទុកដាក់ធ្វើឲ្យណាស់ ដើម្បីធ្វើសន្តិសុខឲ្យកើតមានឡើងក្នុងលោកនេះ ។

កិរិយាសុភាព, វាចាសុភាព នឹងចិត្តសុភាព ចាត់ថាជាខ្លឹមសារយ៉ាងសំខាន់ របស់និស្ស័យសុភាព ។ តែគោលធំបំផុតរបស់និស្ស័យសុភាពនោះ នៅត្រង់ចិត្តសុភាព ដែលមានការស្ងប់ស្ងៀម, ឧបអាសាទរ, ឃើញចិត្តគេចិត្តឯង, នឹងខ្នះខ្នែងខ្ជាប់ខ្ជួន នឹងមានយុត្តិធម៌ជាលក្ខណៈ ។ លក្ខណៈទាំងនេះ ជាតេជះដែលអាចធ្វើឲ្យមនុស្សនិស្ស័យសុភាពមានដំណែ បណ្តាលឲ្យអ្នកដទៃមានសេចក្តីនិយមកប់អានឡើង ។

ពិតមែនហើយ! អ្នកធំនឹងមានដំណែបាន ព្រោះតែមានអ្នកតូចនិយមកប់អាន ។ អ្នកតូចនឹងមានដំណែបាន ព្រោះតែមានអ្នកធំអាណិតអាសូរ ។ គ្រូនឹងមានដំណែ ព្រោះតែមានសិស្សស្រឡាញ់ ។ ខ្ញុំពជការនឹងមានដំណែ ព្រោះតែមានប្រជាជនចូលចិត្តនឹងទុកចិត្តចំពោះការពជការនោះ ។ អ្នកសរសេរ អ្នកនិពន្ធ នឹងមានដំណែ មានកេរ្តិ៍ឈ្មោះ ព្រោះតែរឿងរបស់ខ្លួននោះ មានអ្នកអាននិយមចូលចិត្តច្រើន ។ កាលបើយើងមិននិយមក្នុងមុត្តកក្តី កំគ្មានដំណែ ។ សូម្បីមិត្តភក្តិមិននិយមចូលចិត្តចំពោះខ្លួនយើង ព្រោះយើងគ្មានគ្រឿងល្អអ្វីឲ្យគេចូលចិត្តបាននោះ យើងក៏ទៅជាមនុស្សអសំដែ គ្មានគេចូលចិត្ត ។ នេះជារឿងពិត ដែលផុសចេញមកពីការពិត ។

(មានត)

កណ្ឌទី ១១

ឧកញ៉ាវិបុលរាជសេនា ន្ង-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវិឆ្ងាសបើបានអាន
ធឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ខណៈនោះ តាំងសុំនទឹងអៀវហង៉រត់ទៅដល់តំបន់ ១ ក៏ឮតែងព្រះតម្រាប់ព្រះចៅហៀនតេ ២ ច្បាប់ គឺ ១ ច្បាប់ជាសេចក្តីលួងលួងលោមលើឈុយ គុយតី,១ ច្បាប់ទៀតឲ្យទៅដល់ហាន់សៀម លីដាក់ ឧទ្ធហោ-ចាយ ៣ នាយនេះជាពួកចោរនៅជែនស្រុកហោតាំង ។ សេចក្តីសំបុត្រនោះថា ទ្រង់ឲ្យលើកទោសហើយ ឲ្យអ្នកទាំង ៣ នាំយកបក្សពួកមកបំរុងខ្លួនស្តេចទៅឯស្រុកហោតាំង ។ ឯហាន់សៀម លីដាក់ ឧទ្ធហោចាយ បានខ្លួនព្រះតម្រាស់នោះហើយ ក៏លើកបក្សពួកមកគ្រាបបង្គំគាល់ ។ តាំងសុំនឃើញពួកចោរមកដល់ក៏ប្រកាសថា យើងឧទ្ធលើក

កងទ័ពត្រឡប់ទៅវាយយកស្រុកហង្សាវិញ ឲ្យបានដាច់មាំសិន រួចសឹមគិតការតទៅ ។ នាយចោរតាំង ៣ នាក់ ក៏ស្ម័គ្រចូលចិត្តព្រមផងតាំងសុំនក៏លើកកងទ័ពត្រឡប់ជាមួយនឹងព្រះចៅហៀនតេ មកប្រទល់នឹងកងទ័ពលីឈុយ គុយគី ។ ឯលីឈុយ គុយគី កាលលើកទ័ពទៅតាមនោះ លុះដល់ទៅទីតំបន់ណាក៏ឲ្យទាហានបែកគគ្នាតពាំយាជមនុស្សចាស់ដកជាច្រើន ណាដែលមានកំលាំងខ្លាំងពូកែក៏ឲ្យយកទុកជាទាហាន ហើយឲ្យឈ្មោះថា ពួកមិនខ្លាចស្លាប់ ។

កាលកងទ័ពលីឈុយគុយគីនឹងកងទ័ពតាំងសុំន បានចូលប្រទះគ្នានោះទៅតំបន់យូអៀង ។ ទាហានតាំងសងខាងបានតយុទ្ធគ្នាជាយូរថ្ងៃ ។

លីឈុយគុយគីប្រឹក្សាគ្នាថា ឥឡូវនេះ តាំងសុំនបានពួកចោរមកធ្វើជាកំលាំងច្រើនណាស់ បើដូច្នេះយើងត្រូវប្រើឧបាយឲ្យទាហានយើងយកអស់របស់ទ្រព្យ នឹងសំពត់អាវសាវិស្សទៅចោះចោលរាយក្បែរផ្លូវ បើពួកចោរបានទៅឃើញ មុខជាមានសេចក្តីប្លុងថ្នាលចិត្តគិតតែរើសយក មិនរាំងខ្លួន យើងត្រូវលើកទាហានទៅពួនបង្កប់ ហើយចេញមកវាយខ្ទប់តាំងសងខាង ទ័ពតាំងសុំនក៏នឹងអស់ទីអាងបែកឆ្កាត់ទៅឯង ។

គុយគីបានស្តាប់ក៏ចាប់ចិត្តគិតឃើញត្រូវ ទើបចាត់ឲ្យទៅយករបស់ទ្រព្យ នឹងសំពត់សាវអាវសិស្សរាយចោលតាមផ្លូវរៀងទៅ ហើយឲ្យ

ឥឡូវនេះបងប្អូនចាំដែរទេ ។ កងទ័ពភូកចោរឃើញដូច្នោះ ក៏ចេះតែបបួលគ្នាដើរលើសយកមិនបានរកាំងខ្លួន ។ លើឈុយគុយតីឃើញថាគ្មានការ ទើបលើកសេនាឥឡូវចូលវាយចាក់កាប់សម្លាប់កងទ័ពតាំងស៊ុនទីឯពួកចោរវិនាសស្លាប់ជាច្រើន ។ លុះតាំងស៊ុនទីឯអៀវហង៉តឈ្លាតុំឈ្នះកំទាំព្រះចៅហៀនតេរត់ទៅទិសឯដើង, លើឈុយគុយតីក៏លើកតាមទៅ ។

លើដាក់នាយចោរឃើញដូច្នោះ ទើបក្រាបទូលព្រះចៅហៀនតេថា កងទ័ពតាមមកជិតនឹងទាន់ហើយ អញ្ជើញព្រះអង្គឆ្លងចុះចាកព្រះរាជរថាឡើងគង់ព្រះទីនាំងអស្សាឥឡូវរត់ទៅមុនចុះ ទូលព្រះបង្គំជាខ្ញុំតាំងពួនទីឯតឈ្លាការពារពីខាងក្រោយ ។ ព្រះចៅហៀនតេត្រាស់ថា ដែលយើងទីឯរត់ទៅមុននោះមិនគួរទេ បើអ្នកតាំងអស់គ្នាទីឯជាប្រការម្តេចយើងក៏ត្រូវដូច្នោះផង ។ នាហ្មឺនទីឯនាយចោរតាំងពួន ទាំងគ្នាខ្លួញយំរងំហើយក៏ឲ្យឥឡូវចាំងការពារជាលំដាប់ទៅ ។ ហោចាយនាយចោរឃើញកងទ័ពសន្ធាប់តាមមកជិតណាស់ ក៏បរសេះចេញទៅតតាំងរាំងក។ ឥឡូវលើឈុយគុយតីបានជាញ៉ាំងចម្រុះទៅ ត្រូវហោចាយធ្លាក់ពីលើសេះស្លាប់ ។

តាំងស៊ុនទីឯអៀវហង៉ឃើញកងទ័ពជាប់មកជិតណាស់ ក៏អញ្ជើញព្រះចៅហៀនតេទីឯព្រះមហេសីស្រីស្តុំរត់ទៅដល់ឆ្នេរស្ទឹងហង៉ហោ ។

លំដាប់កំចុះទៅមាត់ស្ទឹងប្រឹងរកបានទូក ១ ចែវមកចម្ងឹងស្តេចចុះ តែមាត់ច្រាំងនោះខ្ពស់ទន់យាងចុះពុំបាន ។ ខាហានលីឈុយគុយតីកំកាន់តែដេញដិតប្រកិតដល់មាត់ពៃ ។ ហុកតិកជាបងព្រះមហេសីកំយកពៃសូត្រនឹងដើមឫស្សីបងព្រះអគ្គព្រះចៅហៀនតេនឹងព្រះអគ្គមហេសីយោងចុះទៅជាក់លើទូកបាន, រៀបនឹងចានចេញ ពួកនាហ្មឺននឹងខាហាននោះមិញ ក៏ដណ្តើមគ្នាចុះទៅលើទូករៀបនឹងកុកលិចកងជលធី ។ លីដាំក់ដកគ្រប់កាប់នាហ្មឺននឹងខាហានស្លាប់ជាច្រើននាក់ ទើបនាំគ្នាចាក់ទូកនោះអណ្តែតចេញទៅដល់ត្រើយម្ខាង ស្តេចកំយាងឡើងទៅលើមាត់ច្រាំងហើយតាំងតែទៅមកចម្ងឹងគ្នាជាច្រើនសា មិនទាន់អស់គ្នាទំពីលីឈុយគុយតីលើកមកដល់ មនុស្សដែលនៅសល់មិនទាន់បានធ្លឹង ក៏ស្រែកហៅគ្នាអឺងកងទៀរិញទៅមក ខ្លះស្រែកយំសោករត់ធ្វេធ្វា មុខគួរឱ្យអនិច្ចាកម្មស្តេចនឹងពស្ត្រតែវនិកសចាកគ្នាកងរេលានោះ ។ អៀវហង់ឱ្យស្វែងរកវរទេះបាន ១ ហើយអញ្ជើញព្រះចៅហៀនតេ នឹងព្រះអគ្គមហេសីស្តេចយាងទៅ ។

នាហ្មឺន ១១ ១២ នាក់នឹងមេចារតីវនាក់ ចាននាំព្រះចៅហៀនតេស្តេចទៅដល់ស្រុកថៃហៀង ទទួលពេលយប់ ក៏ចានចូលទៅឈប់សំណាក់កងរោងក្បឿង, តាចាស់ជាម្ចាស់រោងនោះចានយកចាយសម្ងួមកថ្វាយ, ព្រះចៅហៀនតេសោយមិនចាន លុះព្រឹកឡើងស្តេចកំយាងចាក

ទីនោះ ទទួលបួបប្រទះនឹងអៀវពីរ ដែលជានាហ្មឺនខ្វិកជការជាន់ចាស់ ចូលមកគ្រាបសំពះហើយយំសោកា អាណិតអនាថព្រះចៅហ្វានតែក្សត្រាពន់ប្រមាណាស់ ។ ហាន់យ៉ីងគ្រាបបង្គំទូលថា លីឈុយគុយគីនោះ រមែងជឿស្តាប់ពាក្យទូលព្រះបង្គំជាខ្ញុំ សុំព្រះអង្គគង់ប្រថាប់នៅទីនេះសិន ទូលព្រះបង្គំជាខ្ញុំនឹងវិលទៅនិយាយទុកាយហាមឃាត់ ឲ្យលើកទ័ពត្រឡប់ទៅវិញឲ្យបាន ។ ព្រះចៅហ្វានតែទ្រង់ព្រះសណ្តាប់ទើបត្រាស់តបថា ដែលអ្នកមានសន្តានអាណិតដល់យើង ទទួលវិលទៅហាមឃាត់លីឈុយគុយគីវេលានេះក៏ទៅចុះ ។ ហាន់យ៉ីងគ្រាបថ្វាយបង្គំលាចេញទៅ ។ លីងាក់មិនត្រមស្តាប់ពាក្យ, ហាន់យ៉ីងទើបប្រៀបប្រដូនាំស្តេចទៅដល់តំបន់អាន់អឹប ជួនពេលយប់ ក៏អញ្ជើញស្តេចទៅឈប់កងកេង ១ ហើយឲ្យមនុស្សទាំងអស់គ្នានោះផ្ទាស់វេនយាមរក្សា ។

ឯលីឈុយគុយគីកាលលើកទ័ពមកដល់ស្ទឹងហង៉ហោ ឃើញពួកស្រីសុំក្រមការនឹងបណ្តាខ្វិកជការត្រមទាំងពួកខន្ធី ក៏ឲ្យចាប់ខ្លួនឃុំទុកនៅទីនោះ ។ លុះហាន់យ៉ីងទៅដាន់បាននិយាយហាមឃាត់លីឈុយ-គុយគីថា ដែលលោកលើកឫទ្ធិទ័ពជាប់តាមស្តេចព្រះចៅហ្វានតែមកធ្វើបាបដោយឥតកំហុសនឹងធ្វើឲ្យអន្តរាយដល់ព្រះអង្គនោះមិនគួរទេ បណ្តាកស្តេទាំងពួងនឹងមនសេចក្តីគរហានិភ័យបាន លោកប្អូរលើកសេនាទាហានវិលទៅ

វិញចុះ បើលោកស្តាប់ពាក្យខ្ញុំ មនុស្សទាំងពួងនឹងនិយមសរសើរដល់លោកតទៅឯមុខ ។ លើឈុយគុយតីបានស្តាប់ក៏ចុះចិត្តថាត្រូវ ទើបបើកលែងនាហ្នឹងខ្ញុំពជការនឹងក្រុមការស្រែសុំឲ្យចេញទៅទាំងអស់ ។ គ្រានោះស្រូវថ្លៃណាស់ អាណាប្រជានុកស្តេកើតទុក្ខក្រអត់ឃ្លានជាច់ពោះស្ទាប់គ្រប់តំបន់ ។

តៀវហៀវចៅហ្វាយស្រុកហោឡាយ ហាងអុបចៅហ្វាយស្រុកហោតង ដឹងដំណឹងដូច្នោះក៏ចាត់ចែងសំពត់សារអារស្បៃនឹងចំណីអាហារនាំយកទៅថ្វាយព្រះចៅហៀនតៅ មានព្រះពជហ្ឫទ័យត្រេកអរណាស់ ។ ឯតាំងសុនឧនឹងអៀវហាងប្រឹក្សានឹងបណ្តាជាខ្ញុំទាំងពួងថា យើងនឹងឲ្យទាហានទៅធ្វើដំណាក់កន្លែងស្រុកឡុកអៀង ទឹងបានអញ្ជើញព្រះចេយាងទៅប្រថាប់ ។ លើងាក់ធ្វើយថា ដែលលោកគិតដូច្នេះខ្ញុំមិនយល់ត្រមង់ទេ ។ តាំងសុនតបថា ស្រុកឡុកអៀងនោះជាទីក្រុងមកពីដើមយូរហើយ គួរនឹងអញ្ជើញព្រះចាទហៀនតេទៅគង់, ដែលអ្នកនឹងឲ្យតាំងក្រុងទៅទីនេះខ្ញុំឃើញមិនសប្បាយសោះ ។ លើងាក់និយាយថា បើលោកនឹងអញ្ជើញស្តេចទៅគង់ឯក្រុងឡុកអៀងក៏តាមចិត្តចុះ តែខ្លួនខ្ញុំនឹងសុំតាំងទ័ពបញ្ជាប់នៅតំបន់អានអុបនេះ ។ តាំងសុនអៀវហាងក៏លើកកងទាហានាំព្រះចៅហៀនតេនឹងព្រះអគ្គមហេសីស្រីព្រះស្នំ ឲ្យឡើងគង់រទេះលើកតម្រង់ទៅស្រុកឡុកអៀង ។

ឯលីង៉ាក់ប្រែចិត្តគិតក្បត់ ទើបលបប្រើមនុស្សស្និទ្ធស្នាលឲ្យទៅប្រាប់លិឈុយគុយគីថា "តាំងសុិនទឹងអៀវហង នាំយកព្រះថៅហៀនតេទៅស្រុកឡុកអៀង ហើយទឹងសុំខ្ចីលើកកងទ័ពទៅស្កាត់ចាប់ព្រះថៅហៀនតេសម្លាប់ចេញ ។ លីឈុយគុយគីភ្លាដូច្នោះ ក៏ប្រែត្រឡប់ចិត្តគិតត្រេកអរនាំគ្នាទៅធ្វើការជាមួយ ។

ខណ នោះតាំងសុិនទឹងអៀវហង ជានដឹងកិត្តិស័ព្ទថាលីង៉ាក់ប្រែចិត្តក្បត់ ក៏នាំបំតេ់ព្រះថៅហៀនតេទៅតាំងយប់តាំងថ្ងៃគ្មានឈប់ឈរ ។ លីង៉ាក់ជាមនុស្សលោភោ មិនដឹងចាំលីឈុយគុយគីឲ្យព្រមគ្នា ម្ល៉ឺម្ល៉ាលើកទាហានរបស់ខ្លួនស្រេតតាមស្តេចទៅដល់កុំគីសាន់ ជួនពេលយប់ប្រមាណយាមញ្ចាយក៏តាន់ស្តេចនៅទីនោះ ។ លីង៉ាក់ក៏ស្ទុះចេញទៅស្រែកឃាត់ជាខ្លាំយកលថា នរណាដែលនាំស្តេចត្រេចទៅនោះ ឲ្យឈប់ពិគ្រោះនិយាយគ្នាសិន ជ្រាបលីឈុយនឹងគុយគីលើកទ័ពសង្កិនមកពីក្រោយហើយ ។ ព្រះថៅហៀនតេឮដំព្រះសណ្តាប់ច្បាស់ក៏ទោមនស្សព្រួយព្រះទ័យស្ងុតព្រះកាយា ។ អៀវហងក្រាបទូលថា "សំឡេងដែលស្រែកមកនេះចំពោះជាសំឡេងលីង៉ាក់ ជាចោរអ័ប្បល័ក្ខខ្លែងកលខ្លាំយសុំឲ្យព្រះអង្គឆ្លងដំស្រួតទៅចុះ" ទូលហើយក៏ចាត់ឲ្យស៊ីឡុងភថយទៅក្រោយចាំតយុទ្ធគ្នានឹងលីង៉ាក់ចាន ៣ ភ្លេង ។ ស៊ីឡុងយកពួថៅគាប់ត្រូវលីង៉ាក់ធ្លាក់ពីលើសេះស្លាប់ ដេញចាក់គាប់សម្លាប់ពួកចោរទាំងនោះវិនាសស្លាប់ជាច្រើន ទើបត្រឡប់តាមស្តេចទៅឆ្លៃត រហូតផុតកុំគីសាន់ ។

លុះពេលព្រឹកឡើង ទទួលដួបប្រទះនឹងគៀវអៀនន៎ាំយកស្បៀង អាហារចូលមកថ្វាយ ព្រះចៅហៀនតេក៏ទ្រង់ពេះពាយទទួល ហើយត្រាស់ឲ្យឡើងទីជាតៃស៊ូ តឹមន្តិធំ ។ គៀវអៀនក្រាបបង្គំលាទៅវិញ ព្រះចៅហៀនតេក៏លើកចូលទៅក្នុងក្រុងឡុកអៀង ទ្រង់យាងតម្រើញទីព្រះដំណាក់ពន្ធាគាក់ក្នុងព្រះពដរាំង នឹងតឹកឃ្យាំងពេជន្ន ផ្ទះសម្បែងអាណាប្រជានុពស្តុផង សឹងតែក្លើងឆេះវិនាសខ្ទាត់ខ្ទាយអស់ ស្មៅទឹងដើមឈើតាំងឡាយក៏ដុះលូតលាស់ទៅជាព្រៃរហាស្ថាន ។ ព្រះចៅហៀនតេទប់ពុំបាន ទ្រង់ព្រះកន្សែងសោកពិលាប ព្រះអស្សុជលនេត្រហូរជ្រួតជ្រាបសព្វព្រះកាយ ទ្រង់មានព្រះពជនុង្គារថា ទីនេះជារបស់ព្រះមហាក្សត្រអំពីបុរាណលោកបានតសាងទុក ជាទីបរមសុខរៀងមកយូរហើយ ម្តេចឡើយមកវិនាសសាបសូន្យដូច្នេះ ។

គ្រានោះ អស់នាហ្មឺនសព្វមុខមន្ត្រីពិភពការ បានចាត់ឲ្យមនុស្សម្នាកាប់ឆ្ការចោសដំរះក្នុងទីបរិវេណកំឡាចាស់នោះ ហើយឲ្យរៀបសង់ជាប្រាសាទដំណាក់ខាងមុខខាងក្រោយនឹងទីព្រះពដរាជវម្ស សម្រាប់ខ្ញុំពដការតូចធំចូលក្រាបបង្គំគាល់តាមទំនៀម ។ ឯអាណាប្រជានុពស្តុតាំងឡាយនាំគ្នាខ្ចល់ខ្ចាយរុះរើផ្ទះសម្បែង ចូលទៅសង់ក្នុងកំពែងក្រុងប្រហែល ៥០០ ខ្នង ។

ក្នុងសម័យនោះស្រូវថ្លៃណាស់ អស់បណ្តាពស្តេតប់ស្រុកអត់ឃ្លាន គ្មានស្រូវអង្គរបរិភោគ ដាច់អាហារស្ងប់ច្រើនណាស់ ទ្រុនាំគ្នាទៅដឹកបុសស្មៅនូវមើមឈើមកបរិភោគតាងអាហារ បណ្តានាហ៊ុនតូច - ធំទ្រុពជ-ការនឹងអាណាប្រជានុពស្តេនៅក្នុងស្រុកឡុកអៀង ទ្រុសេងទៅជ្រែតជ្រករកកាច់ទុសបេះស្ទឹកឈើនៅតែព្រៃតំណាក់ចាស់ ទ្រុដឹកគាស់ដំឡូងក្តួចគ្រាមពេងតឹកយ៉ាងដែលក្តៅងនេះ ធ្នឹមផ្ទោងផ្ទានពុករបេះបាក់ធ្លាក់មកត្រូវមនុស្សស្លាប់ជាច្រើន ។

ខណៈនោះអៀវពីរយកសេចក្តីក្រាបបង្គំទូលព្រះចៅហៀនតេថា ឣ្ឃាយព្រះហស្តរបស់ព្រះអង្គ ដែលទ្រង់ប្រគល់ឲ្យទូលព្រះបង្គំជាខ្ញុំកនោះ កំមិនទាន់បានយកទៅឲ្យចូឣូនៅឡើយ ។ ព្រះចៅហៀនតេជ្រាបហើយត្រាស់បង្គាប់អៀវពីរថា: ចូរអ្នកនាំយកទៅឲ្យចូឣូចុះ ដើម្បីនឹងបានចូលមកជួយធ្វើពជការក្រងអៀវពីរ ចាត់ប្រើបំរើឲ្យនាំ ឣ្ឃាយព្រះហស្តនោះទៅឲ្យចូឣូ។ ឃើញព្រះសុកអក្សរកំសោមនស្សត្រេកអរណាស់ ទើបប្រឹក្សានឹងសេនាគហានចាំងតួងថា ឥឡូវនេះមានព្រះតំពស់ត្រាស់ហៅឲ្យយើងចូលទៅជួយធ្វើពជការក្នុងក្រងឡុកអៀងហើយ អ្នកចាំងឣ្ឃាយនឹងយល់ឃើញដូចម្តេច ? ។

(មានត)

រឿងអាវ័ក្សខ្ទែងរឿងម្ភៃគ្រាំ

លោកសាង · សារ៉ាត លេខាធុការ ក្រសួងបរិញ្ញវត្ថុ

ប្រែពីភាសាថៃមកជាខ្មែរ

(តមក)

រឿងទី ៤

អាវ័ក្សទូលថា: "បពិត្រព្រះមហាក្សត! កន្លងអតីតកាលមានស្តេច ១ ព្រះអង្គព្រះនាមព្រះបាទរូបសេន (Rupsén) សោយរាជ្យនៅទីក្រុងភោគវតី (Bhogavati) ទ្រង់មានសេកមួយឈ្មោះឆូរាមាន (chûraman) ។ ថ្ងៃមួយនោះ ព្រះរាជាទ្រង់សួរសេកអំពីរ៉ាចេះអ្វីខ្លះ ។ សេកទូលថា: "សូមព្រះបរមកពន្ធទ្រង់ជ្រាប, ខ្ញុំព្រះបង្គំចេះគាំងអស់" ។ ព្រះករុណាមានព្រះរាជឧង្កាសួរទៀតថា: "បើឯងស្គាល់គាំងអស់ដូច្នេះ ចូរឯងធ្វើឲ្យអញមើល តើស្រីដែលមានរូបឆោមល្អសក្តិសមនឹងអញមាននៅទីកន្លែងណា?" ។

សេកទូលថា "សូមទ្រង់ជ្រាប! នៅក្នុងស្រុកមាគធី (Magadhi) មានស្តេចមួយអង្គព្រះនាមមាគធេវរ (Magadhevar) ។ ព្រះរាជានេះមានបុត្រីមួយល្អ ហើយមានឈ្មោះព្រះនាងចន្ទ្រវតី (ពាក្យភូមិន្ទ្រប្រែថា: ព្រះកត្តុល្អដូចព្រះចន្ទ្រ) ។ ព្រះនាងនេះហើយដែលព្រះមន្ត្រីនឹងបានរៀបអភិសេកជាមួយ" ។ លុះទ្រង់ព្រះសណ្តាប់ពាក្យរបស់

សេកកាលណា ព្រះមហាក្សត្រិយ៍ ទ្រង់ហៅពិជ័យហោរាដែលមានឈ្មោះចន្ទ្រក្រាន្ត (chandrakrant) មកហើយទ្រង់សួរថា: "តើខ្ញុំរៀបមង្គលការជាមួយអ្នកណា?" ។ ហោរាលុះបើកគាំងពិនិត្យស្រែចក៏ទូលយ៉ាងម៉ឺងម៉ាត់ថា: "មានកាវីម្នាក់ ឈ្មោះចន្ទវតី គឺនាងនេះហើយដែលព្រះអង្គរៀបអភិសេកជាមួយ" ។ ព្រះរាជាលុះទ្រង់ឮដូច្នោះ ទ្រង់ហៅព្រាហ្មណ៍ម្នាក់មកដល់ ទើបទ្រង់ឥទ្យាល់ព្រាហ្មណ៍នេះសព្វគ្រប់អស់ ហើយមានព្រះបន្ទូលថា: "ចូរឯងទៅជិតស្តេចមាគធេរាកុំខាន, ដល់ឯងរៀបចំអាពាហ៍ពិពាហ៍របស់អញរួចហើយ ចូរឯងត្រឡប់មកវិញ, អញនឹងធ្វើឲ្យឯងសប្បាយមិនខានឡើយ" ។ ឯព្រាហ្មណ៍ជាពដូតនោះក៏ក្រាបបង្គំលាព្រះរាជាចេញទៅ ។

ឯព្រះរាជបុត្រីរបស់ស្តេចមាគធេរា មានសត្វល្អាចេកញីមួយឈ្មោះមទនាមញ្ជរី (Mada-na (Manjari) ។ ព្រះនាងបានសួរបក្សីដូចស្តេចដែរថា: "ប្រុសឯណាជាប្តីដែលសមនឹងអញ?" ។ សត្វល្អាចេកបានទូលថា: "ស្វាមីរបស់ព្រះនាង គឺព្រះបាទរូបសេនព្រះចៅនៃក្រុងគោតវតី" ចាប់ដើមពីបានដំណឹងនេះ យុវជនទាំងពីរស្រឡាញ់គ្នាដោយឥតបានឃើញមុខគ្នាសោះ ។

ចំនួនច្រើនថ្ងៃក្រោយមក ព្រាហ្មណ៍ពដូតបានទៅដល់នគរមាគធ ហើយចូលទៅថ្វាយពដសារបស់ម្ចាស់ខ្លួនដល់ព្រះបាទមាគធេរា។

ខ្ញុំតែមនឿរៀបរាប់ហេតុការព្រះពាជបុត្រីព្រះអង្គ ទើបត្រាស់ហៅព្រាហ្មណ៍ម្នាក់ ក្នុងបណ្តាព្រាហ្មណ៍ចាំងអស់របស់ព្រះអង្គ មកដល់ហើយខ្ញុំប្រគល់ដំនូនចាំងប៉ុន្មាន ដែលគេធ្លាប់ដូនក្នុងពេលនោះឲ្យទៅព្រាហ្មណ៍នោះ រួចខ្ញុំឲ្យព្រាហ្មណ៍នោះទៅជាមួយនឹងពាជនូតរបស់ព្រះចាន្ទរូបសេន ដោយខ្ញុំត្រាស់ថា: "ចូរឯងទៅថ្វាយសេចក្តីគោរពរបស់អញដល់ព្រះអង្គផង លុះកាលណាទូលព្រះអង្គថាអញយកវ់ព្រមថ្វាយព្រះពាជបុត្រីហើយ ត្រូវត្រឡប់មកវិញឲ្យឆាប់ ព្រោះកាលណាឯងមកដល់ភ្លាម អញនឹងរៀបអស់គ្រឿងនៃបុណ្យអាពាហ៍ពិពាហ៍នេះតុំខាន" ។

ក្រោយមកព្រាហ្មណ៍ចាំងពីរ នាំគ្នាដើរអស់ចំនួនច្រើនថ្ងៃ ទើបបានមកដល់ប្រាសាទព្រះចាន្ទរូបសេន ហើយក៏នាំគ្នាថ្វាយសារដែលខ្ញុំនាំមកនោះ ដោយរីករាយ ។ ព្រះមហាក្សត្រិយ៍ខ្ញុំរៀបចំគ្រឿងប្រដាប់ប្រដា រួចព្រះអង្គខ្ញុំយាងទៅកាន់ទីបុណ្យ ។ ខ្ញុំយាងទៅដល់ស្រុកនេះចំនួនច្រើនថ្ងៃក្រោយមក ។ លុះអភិសេកនឹងទទួលដំនូនការរួច ខ្ញុំសូមលាព្រះចាន្ទមាគធេវរ ហើយយាងត្រឡប់មកទីប្រាសាទរបស់ព្រះអង្គវិញ ។ ចំណែកព្រះនាងខត្តិយានីបានដឹកនាំខ្ញុំមនោមញ្ជរី របស់ព្រះនាងមកជាមួយផង ។ ចំនួនច្រើនថ្ងៃមក ជនចាំងអស់ក៏បានមកដល់ប្រទេសរបស់ខ្ញុំវិញ ហើយបានរស់នៅយ៉ាងក្សេមក្សាន្តក្នុងដំណាក់របស់ខ្ញុំ ។

ថ្ងៃមួយនោះ ទ្រង់សេកនឹងទ្រង់ល្ងាចេកញីនៅជិតគ្នាក្នុងដំណាក់ ។ ព្រះមហាក្សត្រិយ៍នឹងព្រះពជអគ្គមហេសីទ្រង់ពិភាក្សាគ្នាថា: "គ្មានអ្នកណាមួយនៅម្នាក់ឯង ក្នុងទីស្ងប់ស្ងាត់ប៉ុនទេ. យើងត្រូវផ្សំផ្គុំសេកនឹងល្ងាចេក រួចយើងដាក់វាក្នុងទ្រង់តែមួយ ដើម្បីឲ្យវារស់នៅបានសប្បាយផង" ។

ស្តេចទាំងពីរអង្គទ្រង់ឲ្យគេយកទ្រង់ធំមួយមក ឯសេកនឹងល្ងាចេកក៏ត្រូវគេដាក់ជាមួយគ្នាទៅ ។

ចំនួនច្រើនថ្ងៃមក គាប់ជួនព្រះមហាក្សត្រិយ៍ នឹងព្រះពជឯកអគ្គមហេសីទ្រង់ប្រថាប់ជជែកជិតគ្នា ។ សេកនិយាយទៅកាន់ល្ងាចេកថា: "ចំណង់ទាំងអស់របស់សេចក្តីស្នេហា ជាវត្ថុយ៉ាងល្អប្រពៃបំផុតនៅនាលោកិយនេះ បើរូបជនណារស់នៅនាស្ថានកណ្តាលនេះ ដោយឥតស្គាល់ចំណង់នេះ ជននោះរស់នៅឥតប្រយោជន៍ ហេតុដូច្នេះ ឱល្ងាចេកអូន, បង់សូមឲ្យនាង់ត្រមឲ្យបង់ចង់ទៅនឹងអូន ដោយចំណង់នេះ?" ។

ប៉ុន្តែមទនាមញ្ជីរឆ្លើយតបវិញថា: "ខ្ញុំគ្មានត្រែកត្រអាលន៍ឯណាឈ្មោលណាទេ" ។

ឆ្លូវមានិយាយឡើងវិញថា: "តើហេតុម្តេចក៏យ៉ាងដូច្នោះ"? ។ ពីព្រោះប្រុសទាំងអស់ សុទ្ធតែពួកឧក្រិដ្ឋចិត្តមិនត្រង់ ជាមនុស្សក្បត់ជាអ្នកពិឃាតស្រី ។

សេកកាត់ពាក្យថា: "តើស្រីនោះយ៉ាងណា? តើស្រីមិនមែនអ្នកអាក្រក់, អ្នកចិត្តវៀច, អ្នកលួង, អ្នកកំណាញ់ ឥងអ្នកសម្លាប់ប្រុសដែរឬអី?" ។

ការជជែកគ្នានេះជាហេតុឲ្យសត្វទាំងពីរប្រឈ្លោះគ្នា ។ ឯស្តេចទ្រង់ចាន់សាកសួរអំពីហេតុនៃការឈ្លោះនេះ ។ សត្វល្អាចក្រាបទូលថា: "ព្រះមហាក្សត្រ! មនុស្សប្រុសទាំងអស់ តែងតែមានទន់ភ្លន់ផ្លូវចិត្ត ហើយសុទ្ធតែជាអ្នកសម្លាប់ស្រី ព្រោះហេតុយ៉ាងនេះហើយ ខ្ញុំបានជាទូលព្រះបង្គំគ្មានចូលចិត្តនឹងអ្នកណាមួយសោះឡើយ សូមព្រះមហាក្សត្រស្តាប់រឿងដែលទូលព្រះបង្គំនិទានថ្វាយដូចតទៅនេះ, រឿងនេះអាចបង្ហាញព្រះអង្គឲ្យទ្រង់យល់ថា "មនុស្សប្រុសតែងប្រព្រឹត្ត ដូចទូលព្រះបង្គំបានរៀបរាប់ទូលព្រះអង្គមិនខាន" ។

នៅក្នុងទីក្រុងអិលាបុរៈ (Jlapur) មានអ្នកជំនួញម្នាក់ឈ្មោះមហាធន (Mahadhan) ប្រែថា មហាសម្បត្តិ ។ ដោយសារគ្មានកូនចៅអ្នកជំនួញនេះតែងដើរធុតង្គ សូត្រធម៌ មើលគម្ពីរបុរាណ (Puronas) គម្ពីរស្តីអំពីរឿងកកើតកព រឿងវិនាស រឿងចំរើនលោកិយ រឿងទេវតា រឿងព្រះចាតមនុ (Manus) ហើយមានចិត្តជ្រះថ្លាយដល់ព្រាហ្មណ៍ទាំងអស់ ។

នៅថ្ងៃក្រោយបង្អស់ កន្ទងយូរពីនោះមក, ដោយចំណាន់របស់ព្រះ នាយឈ្មួញបានកូនប្រុសមួយ ។ សេចក្តីសប្បាយទាំងពួងក្នុងការ

ទទួលកំណើតនេះបានមានឡើងយ៉ាងអីក៏អាចដឹក? នាយឈ្មួញជ្រុនជាក់
ថានដល់ព្រហ្មណ៍នឹងកើតជាដែរច្រើន ។ ពួកអ្នកគ្រីគ្រាំងឆ្ងាយ ដែល
ឃ្លានហើយដែលស្រេក ក៏គ្មានត្រូវភ្លេចឡើយ ។ កាលណាកូននាយ
ឈ្មួញនេះបានអាយុប្រាំឆ្នាំ នាយឈ្មួញបង្រៀនឲ្យមើលអក្សរ ។ ប៉ុន្តែ
កូននេះ គ្មានរៀនសូត្រទេ គិតតែទៅលេងជាមួយក្មេងឯទៀត ។
លុះកាលណានាយឈ្មួញទទួលមរណភាព ក្រោយពីពេលនោះបន្តិចមក
បុរសក៏ទៅជាមេផ្ទះ គិតតែលេងបៀប៉ោកល់ថ្ងៃ ហើយនៅវេលាយប់គិត
តែខ្ជូចនឹងស្រីញី ។ អស់ស័យហេតុនេះ ទ្រព្យសម្បត្តិក៏រលាយ
បន្តិចម្តងៗ ក្នុងចំនួនច្រើនឆ្នាំក្រោយមក ធនធានក៏អស់គ្មានសល់ ។
បុរសចាកចោលស្រុករបស់ខ្លួន ហើយបានទៅដល់ទីក្រុងមួយ ឈ្មោះ
ក្រុងចន្ទ្របុរៈ (chandrapur) ទីក្រុងព្រះចន្ទ្រ ។

នៅក្នុងទីក្រុងនេះ មាននាយឈ្មួញម្នាក់ ឈ្មោះហេមគុប្ត (Hemgupt)
ដែលជាអ្នកមានទ្រព្យ ។ បុរសដើរចូលទៅជិតនាយឈ្មួញនោះ រំលឹក
អំពីឈ្មោះឪពុករបស់ខ្លួនប្រាប់ឈ្មួញនោះ ហើយនិយាយអំពីដំណើរការ
របស់ខ្លួនផង ។ នាយឈ្មួញសប្បាយចិត្តនឹងស្តាប់បុរសនេះណាស់ ។
គាត់ក្រោកឈរឡើងទុបបុរស ហើយសាកសួរអំពីហេតុដែលបុរសនោះ
មក ។ ឯបុរសក៏និយាយរឿងប្រាប់វិញថា ដល់ខ្លួនផ្ទុកទំនិញជាក់ក្នុង
កប៉ាល់រួចកាលណា គាត់ទៅកន្លែកោះមួយដើម្បីធ្វើដំណើរ រួចលុះកាល

ណាលក់ទំនិញអស់ នោះស្រែចគាត់ផ្ទុកទំនិញថ្មីៗ ម្តងទៀត រួចត្រឡប់ទៅស្រុករបស់គាត់វិញ ។ បុរសនិយាយតទៅទៀតថា: "ប៉ុន្តែស្រាប់តែមានព្យុះមួយក្នុងកន្លះនោះ ឯនាវរបស់ខ្ញុំក៏បែកបាក់ខូចខ្លី ខ្ញុំនៅក្តារមួយសន្ធឹក ទើបខ្ញុំបានមកដល់ទីប្រាំងនេះ ប៉ុន្តែខ្ញុំខ្វាសគេដោយខាតបង់អស់ទំនិញ នឹងទ្រព្យសម្បត្តិខ្ញុំនេះ តើឲ្យខ្ញុំហ៊ានត្រឡប់ចូលទៅក្នុងស្រុកខ្ញុំវិញ ហើយទៅបង្ហាញមុខយ៉ាងនេះ ដល់អស់ជនដែលខ្ញុំស្គាល់ម្តេចកើត?" ។

ព្រោះសំដីបុរសនិយាយដូច្នោះ អ្នកជំនួញក៏នឹកថា: អញអង្គុយនៅផ្ទះអញដោយសុខសោះ វាស្មាបានខះខំបណ្តេញទូរអំពល់ទាំងឡាយអំពីរូបអញអស់ តុកាសដែលលេចឡើងនេះ ជាអំណោយរបស់ទេវតាអាត្មាអញមិនត្រូវបណ្តោយឲ្យតុកាសនោះរបូតផុតទៅវិញទេ, ដូច្នេះគួរតែអញរៀបការកូនអញនឹងបុរសនេះទៅ, ឥឡូវនេះអញនឹងធ្វើតែតាមការណ៍ដែលគេអាចធ្វើបាន ព្រោះថាតើអ្នកណាអាចដឹងថាថ្ងៃក្រោយនោះយ៉ាងណាកើត" ។

លុះក្លួចគំនិតដូច្នេះហើយ នាយឈ្មួញទៅជិតប្រពន្ធរបស់គាត់ហើយនិយាយថា: "កូនរបស់ឈ្មួញម្នាក់មកដល់ទីនេះ, បើប្អូនសុខចិត្តផងយើងនឹងរៀបការវានឹងរតនាវតី (Ratnavati)ប្រៃថា ស្រឡាញ់ត្បូងពេជ្រ, នាងកវិយា លុះបានឮក៏រីករាយតែកន្លះចិត្តហើយនិយាយទៅកាន់ប្តីថា:

"ម្នាលអ្នក! កាលណាទៅតាប្រាន កាត់សំណាងនេះលើផ្លូវដែលអ្នកដើរ ត្រូវតែអ្នកចាប់យកកាត់សំណាងនេះ, បំណងរបស់យើងក៏នឹងបានសម្រេច, កុំចាំអ្វីឲ្យយូរការ យើងទៅនិមន្តលោកមកហើយកំណត់វេលាដែលគួរលោកបង្ហាញឲ្យរៀបការបាន" ។ នាយឈ្មួញបានទៅអញ្ជើញព្រាហ្មណ៍ម្នាក់មក ។ លុះកំណត់ពេលល្អជាស្រេច ទើបឈ្មួញរៀបអាពាហ៍ពិពាហ៍កូនស្រីឲ្យទៅបុរស ហើយបានតាំងឲ្យចំណងដៃជាច្រើនផង ព្រមទាំងបានឲ្យគូសង្ឃរាវថ្មីនេះទៅជាមួយទៀត ។

ក្រោយពីនោះបន្តិចមក កូនរបស់នាយឈ្មួញនិយាយទៅកាន់តាយាថា: "ចំនួនច្រើនថ្ងៃណាស់មកហើយ តាំងតែអំពីបងមកទៅក្នុងស្រុករបស់អ្នក បងគ្មានបានដំណឹងអ្វីអំពីគ្រួសាររបស់បងសោះ, បងព្រួយចិត្តណាស់, ឥឡូវអ្នកដឹងការតាមរបស់បងហើយ ចូរអ្នកទៅដំរាបម្តាយអ្នកផង ដើម្បីឲ្យលោកយល់ព្រមឲ្យបងទៅ បងនឹងទៅស្រុករបស់បងវិញ, ហើយបើអ្នកបង់ អ្នកជូនបងទៅផង" ។ រតនាវតីនិយាយប្រាប់ម្តាយរបស់ខ្លួនថា: "ប្តីរបស់ខ្ញុំចង់ទៅស្រុករបស់គេ សូមកុំឲ្យអ្នកម្តាយព្រួយ" ។

ឯមាតានេះ ក៏ទៅជជែកប្តីរបស់ខ្លួន ហើយបញ្ជូនពាក្យសុំរបស់កូនប្រសាខ្លួន ។ ឯនាយឈ្មួញ លុះឮដូច្នោះ ឆ្លើយថា: "មានអ្វី! យើងឲ្យវាទៅ ព្រោះយើងគ្មានអំណាចអ្វី ទៅលើកូនរបស់គេទេ យើង

បំពេញតាមចំណង់វា" ។ លុះកាលណាហៅកូនស្រីរបស់ខ្លួនមកហើយ
និយាយថា: "ចូរឯងធ្វើបាប់យោបល់ឯងមកអញមើល! តើឯងចង់ទៅផ្ទះ
ឪពុកក្មេកឯងឬទេ? ឬមួយឯងចូលចិត្តនៅជាមួយម្តាយឯង? ។ នាង
ក្តីកក្តាំងអស់ស្មារតី តតង្វើយ៉ូឡើយ ប៉ុន្តែលុះកាលណា នាងទៅដឹក
ប្តីនាង នាងនិយាយថា "ឪពុកនឹងម្តាយខ្ញុំសន្យា ធ្វើតាមចិត្តបងចង់
ទាំងអស់ ប៉ុន្តែសូមបងកុំចោលប្អូនឲ្យសោះ" ។

ដល់ចុងបង្អស់មក នាយឈ្មួញបានហៅកូនប្រសារបស់ខ្លួនមកឲ្យ
ចម្រាប់ទៅ ដោយបានឲ្យគ្រែស្នែងមួយទៅនាងជាបុត្រីផង ព្រមទាំង
ខ្ញុំកំដរផង ដនទាំងពីរចេញដំណើរទៅ ។

មិនយូរប៉ុន្មាន ដនទាំងពីរនេះ បានទៅដល់កងវៃព្រមួយ ។ បុរស
ជាប្តីនិយាយទៅកាន់ប្រពន្ធថា: "នៅទីនេះ មានគ្រោះថ្នាក់ច្រើនណាស់
ចូរប្អូនដោះគ្រឿងអលង្ការរបស់ប្អូនទាំងអស់ឲ្យមកបង បងទុកឲ្យ, ហើយ
បងឲ្យប្អូនត្រឡប់ទៅវិញ កាលណាយើងចូលទៅក្នុងស្រុក" ។
ប្រពន្ធដោះគ្រឿងអលង្ការរបស់ខ្លួនឲ្យទៅបុរសជាប្តី។ ដល់បាន
គ្រឿងអស់នោះកាលណា ក៏សម្លាប់ខ្ញុំម្នាក់ចោះទៅក្នុងអណ្តូង, រួចបាន
ប្រពន្ធដែលខ្លួនបានហ៊ូតយកទ្រព្យអស់ហើយទំលាក់ទៅក្នុងអណ្តូងនោះ
ហើយចាប់ដើរទៅមុខទៀតទៅ ។

ប៉ុន្តែមានអ្នកដំណើរម្នាក់ដើរតាមផ្លូវនោះ បានឮសូរមនុស្សម្នាក់យំរ
កំឈប់រកមើល តើសូរទំនួញនោះចេញពីខាងណា ក្នុងព្រៃនោះមក? ។

អ្នកដំណើរលុះបានដម្រង់ទៅទីដែលស្ងួរសេតួហាក់ចេញមកនោះ គេបានទៅដល់មាត់អណ្តូងមួយ លុះចោលកន្ទុយក្អែកទៅ ក៏ភ្ញាក់ស្មារតី ដោយឃើញស្រីម្នាក់យំ. លុះតាញស្រីនោះចេញអំពីអណ្តូងមក គេសួរថា: "នាងកូនចៅអ្នកណា ហើយនាងធ្លាក់ចូលក្នុងអណ្តូងនេះយ៉ាងណា?" ។ នាងឆ្លើយវិញថា: "ខ្ញុំជាកូនរបស់អ្នកដំនួញម្នាក់ឈ្មោះ ហេមគុប្ត ខ្ញុំជូនប្តីខ្ញុំទៅស្រុករបស់គេវិញ ស្រាប់តែពួកចោរមកព័ទ្ធដុំវិញខ្លួនយើង សម្លាប់ខាសីខ្ញុំម្នាក់ ទំលាក់ខ្ញុំមកក្នុងអណ្តូងនេះ រួចទៅបាត់ទៅ ដោយបានយកគ្រឿងមាសពេជ្រ ទ្រព្យប្តីរបស់ខ្ញុំដែលរាចង់ជាប់ហើយ, តាំងពីនោះមក ខ្ញុំគ្មានបានដំណឹងអ្វីអំពីប្តីខ្ញុំសោះ ឯគាត់ក៏គ្មានបានដំណឹងអ្វីពីខ្ញុំដែរ?" ។

លុះឮដូច្នោះ អ្នកដំណើរយកនាងទៅជាមួយខ្លួន ហើយនាំនាងទៅដល់មាត់ព្រៃឪពុករបស់នាង ។

ឪពុកម្តាយរបស់នាង ដល់បានឃើញនាង សួរនាងអំពីហេតុដែលកើតឡើងនោះ ។ នាងឆ្លើយថា: "ពួកចោរបានប្លន់យើងតាមផ្លូវ រាសម្លាប់អ្នកបំរើខ្ញុំម្នាក់ ចោលភ្ញោចទៅក្នុងអណ្តូងមួយ, ឯរូបខ្ញុំរាយកទៅទំលាក់ក្នុងអណ្តូងឯទីតមួយទៀត រួចលុះកាលណារាវាយដំប្តីខ្ញុំហើយ រាអូសយកទៅព្រមទាំងគ្រឿងមាសពេជ្ររបស់ខ្ញុំផង រាចារលុយអំពីប្តីខ្ញុំ គាត់ក៏ឆ្លើយទៅរាវិញថា: គាត់អស់គ្មានសល់ឡើយ ខ្ញុំមិនដឹងជារាសម្លាប់គាត់ ឬ ចោលគាត់យ៉ាងណាទេ" ។

ឪពុករបស់នាងនិយាយថា: "កូនស្រីកុំព្រួយអ្វី ព្រោះរឿងនេះ ប្តីឯងរស់ដដែរ ហើយបើទេវតាលោកជួយ ប្តីឯងនឹងមករកឯងឆាប់ៗ មិនខាន ព្រោះបើចោរវាយកលុយ វាមិនយកជីវិតទេ"។

នាយឈ្មួញបានឲ្យគ្រឿងមាសពេជ្រឯទៀតទៅនាង ដើម្បីជំនួសរបស់ប៉ាត់ផង ដើម្បីកុំឲ្យនាងព្រួយផង ដើម្បីលួងលោមនាងផង។

ឯប្តីរបស់នាង លុះលក់គ្រឿងមាសពេជ្រអស់ស្រេចកាលណា ដើរលេងល្បែងផ្សេង។ ទាំងថ្ងៃទាំងយប់គាល់តែអស់លុយទៅ។

គាត់ត្រូវការប្រាយ ក៏រស់នៅក្នុងទុក្ខវេទនាមួយយ៉ាងធំ។ លុះគាត់លំ-ប៉ាកដូច្នេះ ទើបគាត់នឹកឃើញថា: "អញនឹងត្រឡប់ទៅផ្ទះរបស់ឪពុកក្មេកអញវិញ រួចអញសុំទោសគាត់ដោយនិយាយថា ឪពុកក្មេកអញមានចៅមួយហើយ, អញមកនេះ ដើម្បីជូនពរសព្វសាធុការ"។ លុះគិតស្រេចយ៉ាងនេះ បុរសក៏ចេញដើរទៅ បន្តិចក្រោយមក ចានទៅដល់ផ្ទះឪពុកក្មេករបស់ខ្លួនវិញ។ គាត់ចង់ចូលទៅ ប៉ុន្តែប្រពន្ធរបស់គាត់ ដែលទៅចំពីមុខគាត់ក្នុងពេលនោះ ចានឃើញគាត់ ហើយខ្លាចជាពន់ពេក គាត់ក៏ពុំហ៊ានដើរទៅមុខទៀត ប៉ុន្តែមិនត្រឡប់ទៅក្រោយវិញដែរ។ នាងក៏ដើរទៅជិតហើយនិយាយរកគាត់ថា: "ម្ចាស់បង! កុំខ្លាចអ្វីឲ្យសោះ ប្អូនបាននិយាយប្រាប់ឪពុកប្អូនថា ចោរមកដល់ សម្លាប់អ្នកបំរើរបស់ប្អូនម្នាក់ យកមាសពេជ្ររបស់ប្អូន រួចដល់ពាំលាក់ចោលប្អូនទៅក្នុង

អណ្តើកមួយហើយ ក៏យកប្តីរបស់ប្អូនទៅ ក៏ក៏យដំប្តីរបស់ប្អូននេះទៀត; ហេតុដូច្នេះ ចូរបង្ខិតខ្ជាប់នូវកុសលរបស់ប្អូន តាមរឿងនេះចុះ រួចប្អូនជាខ្ញុំកម្ពុជរបស់បង្កើយ" លុះនិយាយដូច្នោះហើយ នាងក៏ចូលទៅកន្លែងវិញ ។ ឯបុរសក៏ទៅដឹតទាយឈ្មួញដែលត្រាតឈរឡើងនូវបុរសនោះ ហើយសាកសួរបុរសអំពីដំណើរទំនងដែលមាននោះ ។ បុរសក៏និយាយរឿងតាមដែលប្រពន្ធរបស់ខ្លួនបាននិយាយប្រាប់ រួចសេចក្តីសប្បាយក៏កើតមានឡើងពេញត្រួសារ ។

ឯទាយឈ្មួញ ក៏ឲ្យបុរសងូតទឹក បរិភោគអាហារ ធ្វើឲ្យបុរសប្រុងស្មារតី រួចនិយាយថា: "ផ្ទះនេះរបស់កូនហើយ! នៅចុះ ហើយឲ្យបានសុខសប្បាយ" ។

កន្លងក្រោយពីនោះមក ក្នុងពេលកន្លែមួយនោះ នាងប្រពន្ធ លុះពាក់ត្រឹងមាសពេជ្រួច ក៏ដេកដឹតបុរសហើយលក់ទៅ ។ ដល់ពេលម៉ោងពីរយប់ កន្លងផុតទៅ គឺដល់បុរសឃើញនាងលក់ស្កប់ស្កល់ ក៏យកកាំបិតស្នៀតមួយ ក៏ចាក់នាងចំដើមក រួចនាងក៏ស្លាប់ទៅ, លុះយកត្រឹងមាសពេជ្រអស់ពីខ្លួននាងហើយ ក៏រត់ទៅស្រុកវិញ ។

លុះនិយាយដូច្នេះហើយ ស្លាចេកបន្ទែមថា: "មហាក្សត្រ! ខ្ញុំសូមក្សត្រីធំនៃរឿងនេះ, ហេតុដូច្នេះហើយ បានជាខ្ញុំមិនចង់ត្រាកាន់ធំឈ្មោលណាមួយឡើយ, ទ្រង់មហាក្សត្រិយ៍! សូមទ្រង់យល់ថា:

មនុស្សប្រុសជាចោរប្លន់មួយ, សូមទ្រង់មានព្រះពាជនុគ្គារធ្វើបាប់មកទូលបង្គំមើល? តើតួប្រុសដូចជាគេចិញ្ចឹមពស់មួយនៅកន្ទងផ្ទះឬទេ, ដែលស្រីទៅជាប់ខ្ជួននឹងសត្វបែបនេះ? មហាពាជ! សូមទ្រង់គិតពិចារណាមើលរឿងនេះ រួចសូមទ្រង់មានព្រះពាជនុគ្គារធ្វើបាប់ទូលបង្គំជាខ្ញុំវិញ តើពោសបែបណាដែលស្រីហ៊ានប្រព្រឹត្តអាក្រក់ទៅរកស្វាមី? សូមនិមានមកមើល ។

លុះទ្រង់ព្រះសណ្តាប់យ៉ាងដូច្នេះ ស្តេចទ្រង់បែរទៅរកសេកហើយមានបន្ទូលថា: "នែសេក! ចូរឯងធ្វើបាប់អញមកមើល តើអំពើអាក្រក់ដែលគេប្រទះនៅកន្ទងរូបស្រីនោះយ៉ាងណាខ្លះ? ។

សេកនិយាយថា: "មហាពាជ! សូមទ្រង់ស្តាប់ទូលព្រះបង្គំ" ។

(មានត)

តំណឹងបុណ្យដឹងឧទ្ទិសកុសល

នៅវត្តដើមអម្ពិល ខែត្រកំពង់ឆ្នាំង (យៀកណាម)

ព្រះមហាឈិត កំលីន

សិស្សសាលាបាលីជាន់ខ្ពស់ ថ្នាក់ទី ៤ (ក) វត្តឧណ្ណាលោម ក្រុងភ្នំពេញ រៀបរៀង

កាលពីថ្ងៃ ១៤-១៥ កើតខែមាឃ ឆ្នាំខាលទោស័ក ព. ស. ២៤៩៣ ក្រុមពុទ្ធបរិស័ទចំណុះវត្តដើមអម្ពិល ខែត្រកំពង់ឆ្នាំង (យៀកណាម) មានព្រះគ្រូសុទ្ធមប្បញ្ញោ ចៅអធិការ, ព្រះគ្រូវិបស្សនាចារ្យសឹន-ទុត្តម ធម្មានុសាសនវិធី, ព្រះតេជព្រះគុណមហាគីម-ឃួន អតីតសាស្ត្រាចារ្យ ជាអ្នកទទួលបត្តម្ភក៍នៃសាសនសិក្សា សម្រាប់សាលាបរិយត្តិបឋមវិជ្ជា វត្តដើមអម្ពិល ព្រះមហាលី-កែម សាស្ត្រាចារ្យ សម្រាប់សាលាបរិយត្តិបឋមវិជ្ជាវត្តដើមអម្ពិល (បច្ចុប្បន្ន) បានធ្វើពិធីបុណ្យដ៏ទទ្ធារិក ច្រើនផ្នែក គឺ:

១ – បុណ្យសម្ពោធធ្វើសាលាបរិយត្តិបឋមវិជ្ជា បណ្តាយ ២៦ ម. ៥០, ទទឹង ១១ ម.៥០ ជញ្ជាំងឥដ្ឋ, សសរទ្វារបង្អួចនឹងគ្រឿងលើធ្វើពីឈើ ប្រក់ក្បឿង ។

២ – បុណ្យសម្ពោធធ្វើអគ្គិកត្តសាលា (ពេងភ្លើង) បណ្តាយ ២០ ម. ទទឹង ៩ ម, ជញ្ជាំងឥដ្ឋ សសរទ្វារបង្អួចនឹងគ្រឿងលើធ្វើពីឈើ ប្រក់ក្បឿង ។

៣- បុណ្យសម្ពោធធ្វើសមាធិដ្ឋាន ១០ ខ្នងធ្វើពីឈើ ហើយក្នុងសមាធិដ្ឋានមួយខ្នងៗ មានបណ្តាយ ២ ម. ៥០, ទទឹង ២ ម. ដូចគ្នាទាំងអស់ ។

៤- បុណ្យផ្កាស្រូវ ដើម្បីប្រមូលផ្តុំទូរហិរញ្ញវត្ថុយកទៅកសាងក្លោងទ្វារ និងកំពែងជាអារាមកិច្ចតទៅ ។

៥- បុណ្យសម្ពោធសមណសក្តិ ស្រោចទឹកតាំងគ្រូសូត្រថ្មី ។

កម្មវិធីបុណ្យ

ថ្ងៃទី ១- ក្នុងថ្ងៃ ១៤ រោតខែមាឃ មុនម៉ោង ៩ យប់ សូវរំពងខ្លោងព្រមគ្នាក្នុងព្រះវិហារ ដែលជាសូវសព្ទចេញពីមាត់ពុទ្ធសាសនិកជន ចំនួនជាប្រមាណ ៥៥០ នាក់ ។ លុះដល់ម៉ោង ៩ យប់ពុទ្ធបរិស័ទបាននិមន្តព្រះសង្ឃចំរើនព្រះបរិត្ត លុះព្រះសង្ឃចំរើនព្រះបរិត្តចប់ហើយ កិត្តិមហា ឈិត - កំលន ក្រោកឡើងប្រកាសព្រះសង្ឃ នឹងពុទ្ធបរិស័ទទាំងអស់គ្នាឲ្យស្ងាត់មាត់ ដើម្បីចាំស្តាប់សុន្ទរកថា របស់អ្នកបណ្ឌិតស៊ុន - សាន គ្រូបង្រៀនសាលាបឋមវិជ្ជាជាំង - ខ្នែរ (សុន្ទរកថាថ្លែងដោយមាត់ទេ) ។ លុះចប់សុន្ទរកថាហើយ ព្រះសង្ឃសូត្រ "ជយន្តោ" ជាកិត្តិយសដល់អ្នកកសាងអគ្គិកត្តសាលា (ភោងភ្លើង) លុះព្រះសង្ឃសូត្រ "ជយន្តោ" ចប់ហើយអ្នកបណ្ឌិតហាង - កៀង ក៏សូត្រសុន្ទរកថាតបទៅអ្នកបណ្ឌិតស៊ុន - សានវិញ (មាននៅខាងចុង) ។

ចំណែកនៅទីបដ្ឋានសាលា កន្លងរយៈវេលាមោង ៨ ទឹង ៣៩ នាទី ពុទ្ធបរិស័ទបានប្រជុំគ្នាមស្សការព្រះរតនត្រ័យ រួចនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត ។ បន្ទាប់ពីព្រះសង្ឃចំរើនព្រះបរិត្តមក អ្នកបណ្ឌិតឡឿង-ចាន់ ក្រោកឡើងសូត្រសុន្ទរកថា ជាដំនួសកិក្ខុមហាលីវ-តែម (មាននៅខាងចុង) ។ រួចហើយព្រះសង្ឃសូត្រ "ជយន្តោ" ជាកិត្តិយសដល់អ្នកគាំងសាលាបរិយត្តិបឋមវិជ្ជាតទៅ ។ លុះចប់កិក្ខុមហា ឈិត-កំលីន ក្រោកឡើងសូត្រសុន្ទរកថាជាតំណាងដំនួស កិក្ខុមហាគីម-ឃួន (មាននៅខាងចុង) ។

ដល់មោង ១០ ទឹង ១៥ នាទី កិក្ខុមហាលីវ-តែមនិងកិក្ខុមហា ឈិត-កំលីន សំដែងធម្មទេសនា ជាវេរប្បិបប្បុច្ច-វិសជ្ជនា ។

ថ្ងៃទី ២— វេលាមោង ៩ ព្រឹកថ្ងៃ ១៥ កើតខែមាឃ ជួបជុំពុទ្ធបរិស័ទនិងកិក្ខុសាមណេរ អ្នកបណ្ឌិតឡឿង-ចាន់ ក្រោកឡើងថ្លែងសុន្ទរកថា ដោយមាត់ទេ អំពីសេចក្តីនុបអរនៃការគាំងកិក្ខុមហាឈិតកំលីន និងកិក្ខុសែម-ហេង ឲ្យធ្វើជាគ្រូសូត្រឡើងក្នុងអាវាសវត្តដើមអម្ពិលតទៅ ។

មោង ១០ អ្នកអាចារ្យឡឹម-ឃួន អាចារ្យសម្រាប់វត្តដើមអម្ពិល ក្រោកឡើងប្រកាសដល់ពុទ្ធបរិស័ទគាំងអស់គ្នាថា "អស់លោក-អ្នកគាំងឡាយ! ដែលជាអ្នកមុខអ្នកការ ក្នុងអាវាសវត្តដើមអម្ពិលនេះគាំង

អស់គ្នា, សូមអញ្ជើញមកអង្គុយក្នុងទីចំពោះព្រះភ័ក្ត្រ កិត្តិមហា ឈិត - កំលឹន នឹងកិត្តិ សែម - ហេង ដើម្បីនឹងនិមន្តព្រះសង្ឃសូត្រ "ជយន្តោ" ជាជយមង្គលដល់កិត្តិទាំងពីរបូននេះ ។

ម៉ោង ១០ នឹង ១៥ នាទីអ្នកអាចារ្យឡឹម ឃួន បានយកទឹកដែលពុទ្ធបរិស័ទអប់ដោយគានឹងដូច យកទៅស្រោចលើព្រះហស្តរបស់កិត្តិមហាឈិត - កំលឹន. សែម ហេង ។ រួចហើយ ព្រះសង្ឃសូត្រ "ជយន្តោ" ។ លុះចប់ "ជយន្តោ" ហើយ កិត្តិមហាឈិត - កំលឹន កំគ្រាកឡើងថ្លែងសុន្ទរកថា ទៅកាន់ព្រះសង្ឃនឹងពុទ្ធបរិស័ទ ដោយមាត់ទេវិញដែរ តបនឹងសុន្ទរកថារបស់អ្នកបណ្ឌិតខ្មឹង ចាន់ ។

ឯកឧរបស់ព្រះមហាគីម - ឃួន

ជាអាចារ្យ វត្តដើមអម្ពិល

កិត្តិមហាឈិត - កំលឹន សូត្រជំនួស

កន្លងកាសនេះជាវេលាល្ម . ប្រកបដោយនក្ខត្តឫក្សមានសិរីសួស្តី ដល់ក្រុមពុទ្ធបរិស័ទទាំងឡាយ បានមកជួបជុំគ្នាក្នុងទីសន្និបាតនេះ ដើម្បីនឹងធ្វើពិធីបើកសាលាបរិយត្តិនេះ ។ ដូច្នេះសូមលោកអ្នកទាំងឡាយគ្រាបថា: សាលាបរិយត្តិបឋមវិជ្ជា ក្នុងវិទ្រៃបោ"លៀវនេះ មានខ្វះដែរហើយ តែសាលាបរិយត្តិធម៌នោះ មិនទាន់ជាស្តុកស្តម្ភ មាំមួនប៉ុន្មាននៅឡើយទេ ។ ហេតុនេះហើយបានជាព្រះតេជព្រះគុណជាសាស្ត្រាចារ្យ

របស់អាត្មាភាពទាំងពីរប្រយ៉ង នឹងខ្ញុំព្រះករុណាអាត្មាភាព ព្រមដោយពួកពុទ្ធបរិស័ទចំណុះវត្តទាំងអស់គ្នា បានខំប្រឹងប្រែងផ្គួចផ្តើមបង្កើតសាលាបរិយត្តិធម៌នេះឡើង មិនមានគិតដល់សេចក្តីនឿយហត់សោះឡើយ ។ ទោះស្រុកទេសដែលកំពុងវិបត្តិប្រែប្រួលយ៉ាងនេះ ក៏ដោយក៏នៅតែមានសេចក្តីប្រឹងប្រែងរកគ្រូបាអាចារ្យ ឲ្យខាងតែបានមកបង្ហាត់បង្រៀនបា្រប់ព្រះពុទ្ធសាសនាតទៅ មិនឲ្យអាក់ខាន ព្រោះឃើញថា: ខេមរជាតិយើងទាំងអស់គ្នា សុទ្ធតែជាអ្នកគោរពរាប់អានព្រះពុទ្ធសាសនា តាំងពីបុពណាកាលមកហើយ ដូច្នេះគួរយើងទាំងអស់គ្នា យកចិត្តទុកជាក់ខំសិក្សារៀនសូត្រដោយហ្មត់ចត់ កុំធ្វើព្រងើយកន្តើយនឹងការរៀនសូត្រក្នុងផ្លូវបរិយត្តិនោះឲ្យសោះ, ព្រោះបុពណាគាសិតលោកពោលទុកថា:

"អក្សរសោភស្តែខ្មែរនេះ	ត្រូវខ្មែរចេះឲ្យហ្មត់ចត់
រៀនតាមបែបបទ	សព្វសន្ធតអ្នកប្រាជ្ញប្រាយ ។
ជាតិខ្មែរមិនសាបសូន្យ	ព្រោះតែកូនខ្មែរទាំងឡាយ
ខំសិក្សាឲ្យល់ឲ្យយ	ដោយសប្បាយយ៉ាងក្រៃក្លា ។
ជាតិខ្មែរនឹងថ្កើងថ្កាន	ដោយសារបានកូនអក្ខរ
មានបែបបទថ្លៃថ្លា	តាមតម្រាអក្សរសោភស្តែ ។
បើអក្សរសូន្យហើយ	កូនខ្មែរអើយនឹងវិនាស
គេដៀលថាផ្តេសផ្តាស	ទុកជាសាសន៍គ្មានតម្លៃ ។

អក្សរសាស្ត្រចំរើន　　នាំបង្កើនឲ្យជាតិថ្កៅ
ថ្កុំថ្កើងជាងសព្វថ្កៅ　　ពាន់សម័យយ៉ាងសំខាន់ ។
អក្សរគាងប្រទេស　　គេវិសេសឃើញជាក់ស្មាន់
ត្រូវខ្មែរដើរឲ្យពាន់　　ដោយរួសពាន់កុំរង៉ាក ។
ខំផ្គិតគម្រង់ចិត្ត　　ប៉ងគំនិតគិតគ្រប់គ្នា
គាត់តែងក្លួនតម្រា　　គ្រាន់ទុកជាបែបទៅមុខ ។
ក្លួនខ្មែរក្លួននានា　　ជាតិថ្កៅថ្នាឲ្យរើសទុក
រួបរួមឲ្យគ្រប់មុខ　　ទុកជាក្លួនអក្សរសាស្ត្រ ។
ជាតិខ្មែរនឹងបានថ្កើង　　ចំរើនខ្ពើងដោយជាក់ច្បាស់
ដោយសារអក្សរសាស្ត្រ　　កើតដេរដាសពេញផែនដី ។ ។

ដូចេ្នះត្រូវយើងគ្រប់គ្នា ខំគ្រែបជញ្ជក់យកវេជ្ជាតិព្រះពុទ្ធសាសនាមកកំណត់ទុកក្នុងចិត្តគ្រប ។ គ្នាតទៅ ។

ព្រះតេជព្រះគុណ !

ព្រះករុណា ទាំងឡាយ !

អស់លោកសាធុសប្បុរសទាំងអស់គ្នា !

លំជាប់តទៅនេះ ខ្ញុំព្រះករុណា - អាត្មាភាព នឹងសូមដកស្រង់ពុទ្ធភាសិតខ្លះ មកអធិប្បាយប្រគេន នឹងដំរាបប្រសាសន៍ ដើម្បីឲ្យសមទៅតាមភាពដីកា របស់មហា ( ) ដែលលោកបានថ្លែង

អម្ប្រាញ់មិញនោះថា: "សូមឲ្យខ្ញុំព្រះករុណា-អាត្មាភាព មេត្តាជ្រោស
ប្រទានជម្លើនដល់កិច្ច សាមណេរ ឧបាសក ឧបាសិកា" ។ ហេតុ
នេះ ខ្ញុំព្រះករុណា-អាត្មាភាពសូមឧកាសដ៏ខ្លីនេះបន្តិច អំពីសំណាក់
ព្រះតេជព្រះគុណ! ព្រះករុណាទាំងឡាយ! អស់លោកសាធុសប្បុរស
ទាំងអស់គ្នា! អធិប្បាយអំពីកិច្ច ២ យ៉ាង ដែលព្រះអរហំសម្មាសម្ពុទ្ធ
ជាម្ចាស់ទ្រង់ត្រាស់សំដែងតម្រៀបជាបទមាតិកាដូចតទៅនេះ:

๑) បហានកិច្ច កិច្ចគឺការលះបង់ ។

๒) ភាវនាកិច្ច កិច្ចគឺការចំរើន ។

អធិប្បាយថា: បហានកិច្ច កិច្ចគឺការលះបង់នោះ គឺលះបង់នូវ
បាបគឺអំពើដែលកើតឡើងអំពីកាយវាចាចិត្ត; បណ្តាបាបទាំងនេះ ឥត
មានចំណែកណាមួយ ដែលជារបស់គួរធ្វើ គួរប្រព្រឹត្តសោះឡើយ ។

កាលបើបុគ្គលណាមួយជ្រុលកាយ វាចា ចិត្ត ធ្វើអំពើបាបជា
ករណីយកិច្ចនោះហើយ ត្រូវដឹងខ្លួនថាមុខជានឹងមានទោស គឺសេចក្តី
ក្តៅក្រហាយក្នុងលោកទាំងពីរ គឺ: លោកនេះក្តៅក្រហាយដោយគិតថា:
អាត្មាអញបានធ្វើបាបយ៉ាងនេះយ៉ាងនោះ លុះច្យុតចាកលោកនេះទៅ
ហើយនឹងធ្លាក់តែក្តៅក្រហាយជាងនេះទៅទៀត ។ ព្រោះហេតុនោះ
បានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា: បាបនេះជាអំពើគួរលះបង់ចេញនេះ
ហៅថា បហានកិច្ច ។

ការនាកិច្ច *កិច្ចគឺការចំរើននោះ* *ចានដល់ការបំពេញកុសលឲ្យ*
បរិបូណ៌ ។ *កុសលនេះបើសំដែងដោយបុគ្គលចានខាង* អលោភោ
គឺការមិនជំពាក់ចិត្តក្នុងទ្រព្យសម្បត្តិ *មិនចង់ចានទ្រព្យរបស់បុគ្គលដទៃ*
ទាំងមិនលួចលាក់ឆក់ដណ្តើមបំចាត់ប្រព័ន្ធ *សង្កត់សង្កិនរបជាន់យក*
ធនធានរបស់បុគ្គលដទៃ, អទោសោ *គឺការមិនប្រទុស្តរោសឹង* *មិនរក*
រឿងរកហេតុអ្នកដទៃឲ្យដល់នូវសេចក្តីវិនាស, អមោហោ *មិនវង្វេង*
គាន់តាំងក្នុចស្មារតី *ដោយអ្នកដទៃគេគំរាមកំហែង* *បំភាន់គំនិតជាដើម*
ទៀយ ។

មួយទៀត *កុសលនេះបើសំដែងដោយទីតើតមាន* ๑๐ *ប្រការ*
មានការឲ្យនូវវត្ថុដ៏គួរដល់បុគ្គលដែលគួរឲ្យដោយសេចក្តីសន្ធឹះ *ឬបូជា*
គុណ *មានឲ្យដល់មនុស្សកំសត់* *ឬបូជាដល់លោកអ្នកមានសីលធម៌*
និងមាតាបិតាជាដើម, *មានការតាំងចិត្តស្តាប់ធម៌* *ស្តាប់ពាក្យនុវាទ*
ពាក្យប្រៀនប្រដៅ *ដោយប្រុងឲ្យចេះចាំស្តាត់* *ធ្លើតើតនិយាយបាន*
ជាទីបំផុត ។

បុគ្គលណា *ចានធ្វើកុសលដូចពោលមកនេះ* *បុគ្គលនោះឲ្យ*
សង្ឃឹមខុកចិត្តចុះ *ថាមុខជាជួបប្រទះនូវសេចក្តីសុខ - សេចក្តីចំរើនក្នុង*
លោកនេះ *និងលោកខាងមុខមិនខាន* *នេះហៅថា* *ការនាកិច្ច* ។

កិច្ចទាំង ២ យ៉ាងនេះ ជាដំណើរខាងផ្លូវធម៌, បើជាខាងផ្លូវលោកវិញ បហានកិច្ច (កិច្ចគឺការលះបង់) ត្រូវសំដៅយកការលះបង់នូវកិរិយាមារយាទអាក្រក់ ក្រអឺតក្រអោង គោងកាចឆ្គៃឆ្គួលអួស ដើរលេងស៊ីផឹក ចាយវាយខ្ជះខ្ជាយសម្បត្តិឥតប្រយោជន៍ ឥតសណ្តាប់ធ្នាប់ មានធ្វើចោរកម្ម លួចឆក់ដណ្តើមរបស់ជាន់សង្កត់សង្កិនយកធនធានរបស់អ្នកដទៃជាដើម ។ អំពើទាំងអស់នេះ សុទ្ធតែជាអំពើនាំឲ្យថោកទាបបន្តិចខ្សោយអាប់ស្មើដល់ខ្លួនឯង ទីបំផុតទេសជាតិមាតុភូមិ ។ បុគ្គលអ្នកស្រឡាញ់សេចក្តីល្អ គួរតែនាំគ្នាលះបង់ចោល នូវអំពើអាក្រក់នេះចេញ ។

ភាវនាកិច្ច (កិច្ចគឺការចំរើន) សំដៅដល់ការព្យាយាមបំពេញកិច្ចរបស់ខ្លួនដែលត្រូវធ្វើឲ្យបានគ្រប់គ្រាន់ ព្រោះមនុស្សនិមួយៗ សុទ្ធតែមានសេចក្តីសុខ-ទុក្ខ ។ សេចក្តីសុខ-ទុក្ខកើតមកអំពីសេចក្តីព្យាយាមបំពេញចំរើនផលជាមុខការត្រូវធ្វើ ។

សូមតាញរឿង បមាខ្លះមកសំដែងក្នុងទីនេះ ឲ្យឃើញអានិសង្សនៃសេចក្តីព្យាយាម ។ យើងគួរយកតម្រាប់តាមសត្វកណ្តៀរ, កណ្តៀរជាសត្វមានខ្លួនតូចណាស់, តែកណ្តៀរមានសាមគ្គីភាពព្រមព្រៀងគ្នាព្យាយាមជញ្ជូនដីបន្តិចម្តងៗ ពាល់ថ្ងៃក៏ធូនកើតទ្បើងទៅជាដំបូកមួយយ៉ាងធំបាន ទៅជាផ្ទះសំបែងសម្រាប់ការពារញាតិមិត្តកូនចៅរបស់ពួកបានសេចក្តីសុខ-ចំរើន ឥតមានសត្រូវហ៊ានចូលលុកលុយ ទាំងសម្បុរណាដោយគ្រឿងចិញ្ចឹមជីវិតរបស់ពួកឥតមានខ្វះខាត ។

ម្យ៉ាងទៀត យើងគួរយកតម្រាប់រុក្ខជាតិផ្សេងៗ ធម្មតារុក្ខជាតិផ្សេងៗ ដំបូងឡើងមានឫសខ្លីខ្លះខ្សោយកម្ចាស់ ទោះបីរុក្ខជាតិនោះដុះចាក់ឫសចុះទៅលើធម្មជាតិណាមួយយ៉ាងរឹងប្រហែលគ្នានឹងថ្ម ក៏រុក្ខជាតិនោះ ខំរុលត្បុលប្រឹងចាក់ចុចស៊កសៀតបន្តិចម្តងៗ រាល់ថ្ងៃរហូតធ្វើឲ្យរបស់ដែលរឹងនោះ របើករបេះប្រែរបែកទៅដោយកម្លាំងព្យាយាមរបស់វាបាន, ហើយចាក់ឫសទៅដល់ផែនដីស្រូបយកកម្លាំងជាតុមកចិញ្ចឹមដើមរបស់វា ឲ្យរឹងរឹតតែមានកម្លាំងខ្លាំងឡើង ។ បុគ្គលណាពេញចិត្តកង់ការបំពេញកិច្ចរបស់ខ្លួន ហើយបើទុកជាស្លាប់ក្នុងពេលកំពុងព្យាយាមបំពេញកិច្ចក៏បានឈ្មោះថាប្រសើរបំផុត ។ ខ្លួនបាត់ទៅហើយមែន! តែកេរ្តិ៍ឈ្មោះនៅល្អ, ខ្លួនស្លាប់ទៅចុះ! កុំឲ្យតែស្លាប់សេចក្តីព្យាយាម ។ សមដូចជាពុទ្ធភាសិតថា: "រូបនៃសត្វទាំងឡាយ រមែងស្លាប់ទៅ តែនាមនឹងគេតែមិនស្លាប់ឡើយ" មួយទៀតថា "គេកន្ធងនូវសេចក្តីទុក្ខបានដោយសេចក្តីព្យាយាម" ។

ក្នុងទីបំផុតនៃសុន្ទរកថានេះ សូមសុខសួស្តីសិរីវុឌ្ឍិភាព មានដល់ព្រះតេជព្រះគុណ, ព្រះករុណាទាំងឡាយ, អស់លោកសាធុសប្បុរសទាំងអស់គ្នា ។

សូមព្រះតេជព្រះគុណ, ព្រះករុណាទាំងឡាយ, អស់លោកសាធុសប្បុរសទាំងអស់គ្នា ខ្ញុំសូមន្តដ្ឋីមេត្រីចិត្ត ដោយអភិវាទាសាធុៗ គ្រប់ៗរូបតទៅ ។

(មាន)

ឧត្តមកតិឯពុទ្ធបរិសទ្យវត្តលង្កា ក្រុងភ្នំពេញ ដែលអ្នកធំឯកគួរយកតម្រាប់តាម

សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សា ចៅអធិការវត្តលង្កា ក្រុងភ្នំពេញ បានពន្យល់ពុទ្ធបរិសទ្យ វត្តលង្កា អំពីប្រយោជន៍នៃការចូលជាសមាជិកភាព ក្នុងសមាគមមិត្តសាលាបាលី ព្រះសង្ឃទំនង ឧបាសក - ឧបាសិកាដែលបានស្តាប់ តើគាមានបសាទសទ្ធាចុះជាសមាជិក សមាជិកាបាន ២០៧ រូប ។ បន្ទាប់ពីនោះមក កាលនៅថ្ងៃ ២៧ ខែធ្នូ ឆ្នាំ ១៩៥១ មានធ្វើពិធីចែកបណ្ណសមាជិក ក្នុងទីវត្តនោះដល់ពុទ្ធបរិសទ្យ ដែលស្នើគ្រូចូលហើយ, ក្នុងពិធីនេះ មានព្រះសង្ឃ, ឧបាសក - ឧបាសិកា ដែលមិនទាន់ចុះជាសមាជិកក៏បានចុះជាលំដាប់មកទៀត ចំនួន ៥០០ រូប ត្រូវជាប្រាក់ ៥០០០ រៀល ។

ឧត្តមគតិនៃពុទ្ធបរិសទ្យ វត្តលង្កានេះ ជាអនុស្សាវរីយ៍ចារឹកទុកក្នុងប្រវត្តិសាស្ត្រ នៃសមាគមមិត្តសាលាបាលី។ សូមឲ្យកុសលចេតនានេះធ្វើជាដល់ពុទ្ធបរិសទ្យគ្រប់វត្តក្នុងព្រះរាជាណាចក្រខ្មែរក្រៅ គឺសូមឲ្យជួយឧបត្ថម្ភសមាគមនេះ ឲ្យបានចំរើនតទៅអនាគត ។


សមាគមមិត្តសាលាបាលី សូមគោរពទទួលអំណរដ៏ក្រៃលែង ចំពោះពុទ្ធបរិសទ្យវត្តលង្កា មានសម្តេចព្រះធម្មលិខិត ល្វី-ឯម ជា

ប្រជាន ដោយតេជានុភាពនៃព្រះត្រៃរ័តន៍ នឹងបុញ្ញនិធីនេះ សូមសម្តេច, ព្រះថេរានុត្ថេរៈ, លោក-អ្នកចាំងឡាយ ឲ្យបានសមប្រកបតាមសេចក្តីប្រាថ្នា! សូមឲ្យមានសួស្តីជយមង្គលជានិរន្តរ៍! ក្នុងអាសានជាតិ សូមឲ្យបានសម្រេចព្រះនិព្វាន គ្រប់រូប នាម កុំបីឃ្លៀងឃ្លាតឡើយ!

សមាគមមិត្តសាលាបាលី



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៤ ខែកុម្ភៈ លេខ ២

ព.ស. ២៤៩៤ — គ.ស. ១៩៥២



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
សារាណីយធម្មកថា (តចប់)	ព្រះមហា កែ - អឿន	៨៣
ពន្ធអាស៊ីទ្វីប (តមក)	លោកវ៉ាយ - ប៊ុក	៩១
សុភោជាយកថា	ព្រះអាចារ្យ ទូច - ឡេង	៩៧
ផ្នែកអក្សរសាស្ត្រ		
រឿងគ្រូសាញ់អ្នកខ្លាំងពូកែ (តចប់)	សាស្ត្រាចារ្យផេង - ជ្រឿ	១០៩
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម ...	១១៩
រឿងសាមកុក (តមក)	ឧកញ៉ា ទូ - កន	១២៧
រឿងអារក្សថ្លែងរឿងម្តែប្រាំ (តមក)	លោកសាង - សាវ៉ាត	១៣៥
រឿងស្នេហាជាតិ	លោក គង់ - លឹម	១៤៣
កំណត់ទឹងប្រវត្តិការណ៍		
ពិធីបុណ្យដំឡើងឆ្នាំរកនៅវត្តដើមអម្ពិល ខេត្ត ដោំណាវ (យៀកណាម) (តចប់)	ព្រះមហា ឈិត - កំលិន	១៥៤

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ១៨៣.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE

		Pages
Saraniyadhammakathâ (Suite et fin)	*Vén. Ker-Œurn*	83
La lumière de l'Asie (suite)	*M. RAY-BUC*	91
Sukhopâyakathâ	*Vén. TOUCH-LENG*	97

PARTIE LITTERAIRE

Créçanau, le vaillant (Conte romain) (suite et fin)	*M. Phéng Chrieu*	109
Education morale (suite)	*Vén. PŒUNG-PAM*	119
Histoire de SAMKOK (suite)	*Oknha NOU-KAN*	127
Les vingt cinq récits du Mauvais Génie (suite)	*M. SAN-SAVAT*	135
L'Amour de la partie (pièces de Théâtre)	*M. Kong-Lim*	143

NOTES ET CHRONIQUES

Cérémonies religieuses de Vatt Dœum Ampil, à Baclieu (Sud-Vietnam)	*Vénérable Chhit-Kemlin*	154

Prix d'abonnement annuel (12 numéros:) 180$00

ព្រះមហា កែ-អឿន (រ៉ីរ៉ុយប្បញ្ញោ)

វត្តព្រះពុទ្ធរតន៍ ខេត្តសៀមរាប រៀបរៀង

ឃុនសុវុត្ថិវេទី យូរ-អ៊ុន អ្នកពិនិត្យកែ

(តបប់)

ន័យ ១ ទៀត បុគ្គលប្រព្រឹត្តខ្លួនឲ្យមានកាយវាចារៀបរយល្អ ចើនធ៌ធ្វើអ្វី ក៏មិនឲ្យអ្នកដទៃលំបាកដោយឥតហេតុ បើនធ៌ពោលអ្វីពោលតែវាចាពីកេះ គួរខ្មុកកង់ចិត្ត, តែធ៌មានសេចក្តីយើញត្រូវតាមហេតុតាមផល, កាលចើគិតអ្វីៗ ក៏សុទ្ធតែជាហេតុឲ្យសម្រេចផលល្អ ជាប្រយោជន៍ដល់ខ្លួននធ៌អ្នកដទៃ, អ្នកដែលប្រព្រឹត្តដូច្នេះ អាស្រ័យគុណគឺសេចក្តីល្អរបស់ខ្លួន តែធ៌ជាទីរែកយកនៃប្រជុំជន នាំគ្នាសរ្រើរចិត្តគ្នានធ៌គ្នា ។ ព្រោះហេតុដូច្នោះហើយ អ្នកមានចំណង់ចង់បានសេចក្តីសុខដល់ពួកក្រុម សង្គម គណៈ ប៉ង់នធ៌ចង់មេត្រីនធ៌អ្នកដទៃ មិនច្បាច្បំពោះប្រយោជន៍ខ្លួនតែម្យ៉ាង គប្បីបំពេញសាភណ័យធម៌ ៦ យ៉ាងនេះ ឲ្យបរិបូណ៌ក្នុងសន្តានដូចអធិប្បាយមកនេះ ។

បន្ទាប់អំពីនេះ នធ៌សំដែងបំភ្លឺដល់គ្រហស្ថជាសេចក្តីល្មមសមគួរ ។ ធម៌តាំង ៦ យ៉ាងនេះ គ្រហស្ថក៏ត្រូវប្រព្រឹត្តប្រតិបត្តិបានដូចគ្នា ។ ឯកិច្ចការរោងគ្រហស្ថនេះ មានក្រុម ឬ គណៈសង្គមច្រើនជាអនេកប្បការ

ណាស់ រាប់ចាប់តាំងអំពីព្រះពុទ្ធជាម្ចាស់ផែនដីទឹងអ្នកពុទ្ធការជាលំដាប់ៗ ក្នុងព្រះពុទ្ធអាណាចក្រទាំងមូល រហូតទៅដល់ប្រជាពុទ្ធស្តេចទាំងអស់ សុទ្ធតែមានក្រុម សង្គម គណៈគ្រប់ៗមុខមាត្រ ។ ក្នុងក្រុម សង្គម គណៈនីមួយៗ សុទ្ធតែមានមេបញ្ជាការ ជានាយកលើក្រុមសង្គមគណៈនោះៗ មានការត្រួតត្រាបញ្ជាការទៅលើអ្នកនៅក្រោមបង្គាប់របស់ខ្លួន ។, លោកជានាយកទាំងនោះ ដែលជាអ្នកបញ្ជាការត្រួតត្រាលើគេ ត្រូវជាអ្នកប្រកបដោយធម៌ជាគុណសម្បត្តិ សម្រាប់ខ្លួន ៦ ប្រការគឺ :-

១ _ ខ្មៅ - ជាអ្នកមានសេចក្តីអត់ធន់ ចំពោះអនិដ្ឋារម្មណ៍គឺអារម្មណ៍ដែលនាំឲ្យកំហឹងកើតឡើងផ្សេងៗ ។

២ _ ជាការ: - ជាអ្នកមានសេចក្តីភ្ញាក់រលឹករឿយ ។ ចំពោះការណ៍យកចិត្តគ្រប់យ៉ាង ។

៣ _ ឧដ្ឋាធ: - ជាអ្នកមានសេចក្តីឧស្សាហ៍ព្យាយាម ក្នុងការណ៍យកចិត្តដែលត្រូវធ្វើ មិនរួញរា ។

៤ _ សំវិភាគ: - មានការចែកវិភាគលាភដែលបានមក ដល់អ្នកដែលនៅក្រោមបង្គាប់ ជាសាធារណៈ តាមមានបាន ។

៥ _ ទ្យុ - ជាអ្នកមានសេចក្តីអាណិតអាសូរដួងចិត្ត ដល់អ្នកនៅក្រោមបញ្ជាការ ។

៦. ឥក្ខជា - មានការពិនិត្យត្រួតត្រា ពិចារណាមើលហេតុផ្សេងៗ ដោយម៉ត់ចត់ ។

បុគ្គលជានាយកលើគេ បើប្រកបដោយធម៌ជាគុណសម្បត្តិ ទាំង ៦ យ៉ាងនេះហើយទើបមានសម្ភគាពស័ក្តិសមជានាយកបាន ។

បុគ្គលដែលនៅក្រោមបង្គាប់បញ្ជាការ របស់នាយកនោះៗ ត្រូវស្តាប់បង្គាប់គោរពកោតខ្លាចលោកជានាយករបស់ខ្លួន មិនត្រូវព្រងើយកោងកាចតាមអំណាចចិត្តអន្ធពាលឡើយ ។

មួយទៀតបុគ្គលជាគ្រហស្ថតាមតែក្រុម សង្គម គណៈណាក៏ដោយ ដែលនឹងនៅដោយសេចក្តីព្រមព្រៀងគ្នា ជាទីស្រឡាញ់គោរពរាប់អានគ្នា បានសេចក្តីសុខ សេចក្តីចម្រើនអស់កាលជាយូរអង្វែងទៅបាន ក៏ដោយអាស្រ័យសាកណិយធម៌ទាំង ៦ ប្រការដែរ ។ ដូច្នេះនឹងលើកយកសាកណិយធម៌នោះមកអធិប្បាយតាមសមគួរតទៅទៀតគឺ :

១. អំពើកាយប្រកបដោយមេត្តា_ នោះបានដល់ការទ្រទ្រង់ខ្នែងខ្លាំងខ្លាយជួយគ្នា ដូចជាពួកក្រុមមនុស្សណាមួយ មានកិច្ចធ្ងន់ កើតឡើងដែលជាកិច្ចត្រូវធ្វើដោយកាយ ពួកមនុស្សដែលនៅក្នុងក្រុមនោះក៏ជួយទ្រទ្រង់ខ្នែងខ្លាំងខ្លាយធ្វើកិច្ចនោះ ឲ្យសម្រេចទៅតាមកំឡាំងរៀងខ្លួន ដូចជាជួបប្រទះមនុស្សឈឺគ្រុនយ៉ាងធ្ងន់ យើងមានសេចក្តីករុណាបន្តក់ថ្នាំ ជួយឈឺផ្ទាល់រកគ្រូពេទ្យមករក្សាថែទាំមើលជម្ងឺ, ឬមានភ្លើងឆេះផ្ទះ

អ្នកដទៃយើងទៅជួយលត់ ជួយជញ្ជូនយកទ្រព្យរបស់គេ ឲ្យផុតអំពីអន្តរាយ, ទូកលិចក្នុងលង់ទឹក យើងហែលទៅជួយឲ្យរួចផុតពីសេចក្តីអន្តរាយ ដោយហោចទៅ សូម្បីគ្រាន់តែឃើញគេឈឺគ្រុនធ្ងន់ យើងទៅសួរទៅមើលតែប៉ុណ្ណោះក៏គង់ឃើញថា យើងមានសេចក្តីអាណិតអាសូរករុណា, កាលបើយើងមានកិច្ចធុរៈ ឬអន្តរាយកើតដូច្នោះវិញ អ្នកដទៃគេក៏គង់មកជួយកិច្ចធុរៈយើងវិញដែរ, នេះហើយហៅថាចង់មិត្តមេត្រីនឹងគ្នាទៅវិញទៅមក ។

២- អំពើវិបាប្រកបដោយមេត្តា— នោះបានដល់ការជួយនិយាយជាស់តឿនក្រែនរំលឹកអ្នកណាមួយ ដែលធ្វើខុសអំពីបញ្ញត្តិច្បាប់របស់ស្រុក-នគរជាដើម, មានសេចក្តីករុណាជួយហាមប្រាមឃាត់មិនឲ្យធ្វើ ឬក៏ជួយប្រៀនប្រដៅឲ្យប្រព្រឹត្តក្នុងផ្លូវល្អប្រពៃ ឲ្យប្រកបរបរដែលមានប្រយោជន៍ដោយមេត្តាចិត្ត ។

ម្យ៉ាងទៀត ការសំដែងមេត្តាដោយវាចានោះ អ្នកប្រាជ្ញលោកសំដែងទុកថា សូម្បីតែនិយាយសាកសួរសុខទុក្ខដល់គ្នានឹងគ្នា ក៏រាប់ថាជាមនុស្សមានចិត្តល្អ ។ ឯវាចាដែលពីរោះទន់ភ្ញន់គួរទុកក្នុងចិត្តនេះ ជាវាចាដែលនិយាយងាយស្រួលជាងវាចាត្រគោះបោះបោក, វាចាត្រគោះបោះបោកនោះជាវាចាពិបាកនិយាយ ព្រោះត្រូវប្រយ័ត្នវៃងគេគ្រាធ្វើនឹងឬមិនពេញចិត្ត ។

ឯកាចាដែលហាមៅរកគេ រមែងទទួលផលជា ២ យ៉ាងគឺ កាចាអាក្រក់ រមែងឲ្យផលអាក្រក់, កាចាពីពោះទន់ភ្លន់រមែងឲ្យផលល្អ អាចឲ្យបានទទួលសេចក្តីកប់អានទឹងសាមគ្គីអំពីអ្នកស្តាប់ជាដើម តាំងអាចមានចិត្តអាណិតអាសូរដល់គ្នាផង ។

៣- អំពើបិត្តប្រកបដោយមេត្តា — នោះបានដល់មេត្តាចិត្តប្រាថ្នាមិនចង់ឲ្យដល់គ្នាទឹងគ្នា សូម្បីមិនបានជួយទុក្ខវេទនាកង្វល់កិច្ចការដោយកាយកាចាទេ តែចិត្តប៉ងជួយហើយ អាការកាយទឹងកាចាដែលប្រាកដចេញមកខាងក្រៅនោះ ក៏គង់ទឹងត្រូវចិត្តអ្នកជាមែន ។ មនុស្សយើងធ្វើប្តូតអាក្រក់ល្អក៏ព្រោះចិត្ត បើចំពោះតែកាយដូចរូបតុក្កតា, ឯចិត្តដូចមនុស្សខាញកាយ ទឹងកាចាប្រព្រឹត្តទៅយ៉ាងណា ក៏ប្រព្រឹត្តទៅតាមចិត្តនោះ ។

សូមចាំកុំភ្លេចថា: យើងមេត្តាគេ។ មេត្តាយើង, យើងធ្វើឲ្យគេប៉ុណ្ណា គេធ្វើឲ្យយើងប៉ុណ្ណោះវិញ ។ ការសំដែងមេត្តាចិត្តនេះ កុំថាតែមនុស្ស សូម្បីសត្វតិរច្ឆានតាំងឡាយ មានឆ្កែនឹងឆ្មាជាដើម កាលបើមនុស្សស្រឡាញ់ទៅហើយ ក៏សំដែងអាការញ៉ែកញ៉ាក់បក់កន្ទុយមករកយើង, បង្ហាញឲ្យឃើញថាក៏មានសេចក្តីស្រឡាញ់យើង ។

៤ — ការចែករំលែកលាភដល់គ្នីគ្នា — នោះគឺកាលបើបានបច្ច័យប្តូតរបស់ណាមួយដោយធម៌ហើយ អាចចែករំលែកលាភនោះឲ្យ

ដល់ពួកគ្រួសារ សង្គម ឬដល់កូនប្រពន្ធនៅក្នុងទីកន្លែង ផ្ទះសំបែងរបស់ខ្លួន ឬដល់ពួកជនដែលនៅជិតខាងបរិភោគប្រើប្រាស់តិច-ច្រើនតាមមានតាមបាន ។

៥ - រក្សាសីលបរិយាទ្យមានសណ្តាប់ធ្នាប់ល្អ - បានដល់ការមិនធ្វើឲ្យជាទីរអ៊ូរទាំរបស់អ្នកដទៃពោលគឺការធ្វើ កិរិយាចរិយាសណ្តាប់ធ្នាប់នៃកាយវាចាស្មើគ្នា ដែលហៅថាសីល ។ សីលនេះអាចនាំអ្នកដទៃសូម្បីផ្សេងជាតិផ្សេងភាសា ដូចខ្មែរ, ភូមា, មន, លាវជាដើម ឲ្យមានសេចក្តីប្រព្រឹត្តិត្រូវគ្នាជាធ្លុងមួយបាន ព្រោះកាន់ព្រះពុទ្ធសាសនាដូចគ្នា ។ សីលនេះលោកប្រៀបដូចជាអម្បោះ សម្រាប់ត្រង់ផ្កាឈើ មានពណ៌ផ្សេងគ្នាយកមកបញ្ចូលជារបៀបមួយ អាចត្រេកត្រអាលមើលទៅឃើញល្អគួរចាប់កែកចាប់ចិត្ត ។ បើអ្នកកាន់សាសនាត្រូវគ្នាហើយ តែប្រព្រឹត្តផ្សេងអំពីពួករបស់ខ្លួន, ក៏រមែងជាទីរអ៊ូរទាំរបស់អ្នករួមសាសនាជាមួយគ្នា ជាហេតុឲ្យបែកសាមគ្គីគ្នា ។

៦ - ធ្វើសេចក្តីឃើញឲ្យត្រឹមត្រូវ - បានដល់សេចក្តីយល់ឃើញត្រូវគ្នា គឺបុគ្គលដែលនឹងគ្រប់គ្រងគ្នា ជាគណៈ សង្គមបានព្រោះអាស្រ័យសេចក្តីរួមគ្នាទើបគ្រប់គ្រងគ្នាបាន, បើមានសេចក្តីឃើញម្នាក់ឆ្លួមួយ ឃ្លាងគ្នាមិនស្របមតិគ្នា ទោះបីមានសេចក្តីប្រព្រឹត្តិល្អក៏ដោយ ក៏គង់សមាគមនឹងគ្នាទៅមិនបានរហូតឡើយ, ព្រោះខ្វះខាតសេចក្តីយល់

មិនព្រមព្រៀងគ្នា រមែងជាហេតុឲ្យកើតទាស់ខែងខ្វែងគំនិតគ្នា មិនអាច
ធ្វើការណាយកិច្ចដែលត្រូវគ្រប់ស័យច្រើនគ្នានោះឲ្យសម្រេចប្រយោជន៍ទៅ
បានទេ, ដូចជាអូសឈើប្តូសែងសសរជាដើម សូម្បីតាំងចិត្តឲ្យឈើនោះ
ទៅដល់កន្លែងដែលខ្ទង់ប៉ងប្ដូច្ចាជាមួយគ្នានោះ តែគំនិតមិនស្របគ្នា
ព្រោះមួយឃើញថាធ្វើក្នុងវេលាព្រឹក, មួយឃើញថាធ្វើក្នុងវេលារសៀល,
ពុំនោះសោតដូចកិច្ចការប្រជុំធំៗ មានការប្រជុំរបស់ផ្នែកចំបាលក្នុងនគរ
ន៍មួយៗ បើម្នាក់មានសេចក្តីយល់ឃើញផ្ទុយមួយ ឃ្លាំងគំនិតគ្នាមិនស្រប
មតិគ្នា ក៏គង់ការប្រជុំនោះមិនបានសម្រេចប្រយោជន៍ ។ ហេតុដូច្នោះ
ការឃើញរួមគ្នាក្នុងការដែលគឺមត្រូវដែលសម្រេចប្រយោជន៍, ជាគុណ-
ជាតិសំខាន់យ៉ាងខ្លាំងបំផុតក្នុងការណាយកិច្ចគ្រប់យ៉ាង ។

គណៈសង្គមណា ប្រកបដោយសាមគ្គីយធម៌ ៦ ប្រការនេះ
គណៈសង្គមនោះ គួរជាទីស្រឡាញ់ គោរពរាប់អានរបស់មហាជនទាំង-
ពួង នាំឲ្យមានសេចក្តីសង្គ្រោះដល់គ្នានឹងគ្នា មានសេចក្តីព្រមព្រៀងជា
មួយគ្នានឹងនាំឲ្យមានសេចក្តីសុខ សេចក្តីចម្រើនអស់កាលជាយូរអង្វែង
មិនមានសេចក្តីសាបសូន្យឡើយ ។

សំដែងមកអំពីសាមគ្គីយធម្មកថា ក៏ល្មមសមគួរដល់វេលា សូម
សន្មតថាចប់តែប៉ុណ្ណេះ ។

ទុក្ខប្បត្តា ច និទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

សព្វសត្វទាំងឡាយ ដែលដល់ហើយនូវទុក្ខ សូមឲ្យជាសត្វបាត់ទុក្ខទៅ! ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ! ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យបាត់សេចក្តីសោកទៅ! ។

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ
វុឌ្ឍី វិរុឡ្ហិ បប្បោន្តុ សទ្ធិភាវិញ្ច នាញ្ញថា ។

ដោយតេជៈនៃព្រះរតនត្រ័យ (មានពុទ្ធរតនៈជាដើម) សូមឲ្យប្រជាជនទាំងឡាយ អ្នកកើតនៅក្នុងកម្ពុជរដ្ឋ ដល់នូវការៈលូតលាស់ចម្រើន ទំាងសទ្ធិកាព កុំបីឃ្លៀងឃ្លាត ក្វាយទៅជាប្រការដទៃឡើយ ។

ចប់

ស្វាប់ព្រោះដួយជាតិប្រសើរបំផុត

អ្នកណាកើតមក ហើយស្លាប់ទៅវិញ ដោយ
ឥតបានទុកនាមនឹងគោត្រ ឲ្យប្រជាជនដឹងធឹង
សោះ អ្នកនោះទុកដូចមិនធ្លាប់មានជីវិតរស់នៅ
ក្នុងលោកឡើយ ។ យ. ភ.

ពន្លឺអាស៊ីទ្វីប

វគ្គទី ៨

La Lumière de l'Asie

លោក ស៊ីរ-អេតវ៉ាដ អាណូលត៍ តែង

លោករ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ព្រះមហាក្សត្រិយ៍, ព្រះសម្មាសម្ពុទ្ធ, ព្រះនាងយសោធរ នឹងប្រជាពស្ត្រីបានតាំគ្នាទៅដល់ពីមុខព្រះបរមរាជវាំង ព្រះបាទសុទ្ធោទនៈដែលទ្រង់មានព្រះនលាដ៍តមានជ្រួញជ្រីវអ្វីឡើយ ទ្រង់បានសោយជាសុខនូវព្រះតុជារស នៃតុពព្រះសម្មាសម្ពុទ្ធ ដែលទ្រង់កាន់នូវអម្បែងសូមបាន, ហើយក្នុងពេលនោះ អាកាស្វាងសែងចេញចាកព្រះនេត្រានៃព្រះនាងយសោធរាក្តីយល់ជាក់ច្បាស់, ទ្រង់ប្រាត់សោយសោក; ហើយក្នុងយប់នោះ ព្រះវរបិតានឹងព្រះនាងយសោធរា ទ្រង់ក៏បានយាងទៅកាន់ផ្ទះសន្និកាពដ៏ប្រសើរជាអវសាន ។

វគ្គទី ៨

មានវាលស្មៅមួយនៅតាមមាត់ជ្រោះកុហានៈនឹងនគរៈ, បើចង់ទៅកាន់វាលនេះ ត្រូវតែធ្វើដំណើរប្រាំថ្ងៃដោយរទេះគោ តម្រង់ទៅខាងទិសឦសានៃទីក្រុងប៉ែណារេស ក្រុងដែលមានវត្តច្រើនជាងគេ ។

ភ្នំហិមាល័យ មានកំពូលស្រួច មានទឹកកកតាសពេញស្ថិតនៅទី
នោះ មានពុទ្ធជាច្រើន ទីដ៏គុម្ពោតព្រៃដែលមានទឹកស្ទឹងហូរស្រោចធ្វើ
ឲ្យធម្មជាតិទាំងនោះមានពណ៌ខៀវស្រស់ល្អ, ភ្នំនោះមានខ្ពង់ទេរស្រួល
ហើយមានមូលត្រសុំសាខា ផ្សាយនូវគន្ធពិជោរគ្រអូបឈ្ងុយឈ្ងប់ត្រជាក់
ចេញតាមវាយោផាត់កិនសន្ធឹកាត ផ្សព្វផ្សាយតាសពេញទីកន្លែងនោះ
គួរជាទីគោរព រាយោក្នុងសាយណ្ហសម័យបក់ប្រាកមកលើគុម្ពោតព្រៃ
ដែលមានរុក្ខជាតិដុះគ្រាស់ហើយមានដុំថ្មគ្រឹមធ្ងាក់ជាកម្បាច់ ប្រែក្រ-
ហែងដោយឫសនឹងមែកព្រៃ ដែលធ្លាក់សំយុងមកចាក់ឆ្ងាយកាន់ប្រថពី
ហើយមានស្មៅនឹងស្លឹកឈើរុំពន្ធដុំជិត ។ មានសត្វតស៊ីវលូនដោយ
សូបស្រូមចេញពីប្រហោងរុក្ខជាតិទាំងនោះ ដែលមានជ័រអាចម៍លិ្ងហូរ
ចេញកកក្រៀមក្រពឹតពីប្រហោងឈើ សៃដ្រ (cèdre) រាបះជ្រុះផុយធ្លាក់,
ហើយពេនខ្លួនវាបញ្ចេញស្រកាមានគំនូរគួចាំងនៅលើកម្រាលថ្មតែវាមាន
ពណ៌ក្ងីដូចថៃ្ម, បង្គុយភាពរហំសរត់ទៅលើកម្រាលឥដ្ឋ មានគំនូរពណ៌
ដែលព្រះមហាក្សត្រីទ្រង់តាប់ចុះឡើង, សត្វកន្ធោងមានសម្បុរប្រផែះ
ដេកសុខស្រួលនៅក្រោមព្រះបល្ល័ង្កដែលបាក់បែក, ក្រៅពីនោះមានតែ
កំពូលភ្នំ, ស្ទឹង, វាលស្មៅ មានចង្កេះចោតនឹងកៈយាបក់រំភើយ ។ ដែល
មានស្ថានភាពមិនប្រែប្រួល ។ សល់ខាងអំពីនេះ វត្តទាំងឡាយដូចជា
ទស្សនិយដ្ឋាននៃដីវភាព ក៏រលត់រលាយសូន្យឈឹងដោយហេតុថានៅទី

នោះឯងដែលស្ថាបនាទូវព្រះពាជធានីនៃព្រះបាទសុទ្ធោទន: ទីដ៏កុំតូចៗ ដែលពេលសាយណ្ហសម័យមានមេឃរៀបប្រែហាមដូចមាស ព្រះសម្មាសម្ពុទ្ធទ្រង់គង់ដើម្បីសំដែងធម៌ប្រោសសត្វនិករ ។

អ្នកអាចអានទូវគម្ពីរពិសិដ្ឋហើយយល់បានថានៅទីគួរពិតពិលរមិលមើលនេះ ពីដើមជាខ្ទមមានផ្ទះដើងចិញ្ចើមចោត, ប្រកពត្រពាំងបឹង, កម្រាលមាត់ថ្លល់មានដាំកុលាប ហើយមានប្លាសាទដំណាក់មានក្លោងទ្វារដ៏វិចិត្រ ព្រះបរមគ្រូជាម្ចាស់នៃយើងទ្រង់គង់ចំពោះមុខប្រជាជនសំដែងគារវភាព ដែលរង់ចាំស្តាប់ដោយសេចក្តីសូមស្បៃមទូវព្រះតុរាទដែលចេញហូរពីព្រះឧស្ន ដើម្បីនឹងរចនាសត្វនិករឲ្យមានប្រាជ្ញាភ្លឺស្វាងរុងរឿងដែលអប់រំឲ្យខ្ចីបអាស៊ីទាំងមូលមានសភាពស្ងួតត្រង់; ហើយក្នុងពេលនោះមានសត្វនិករចំនួនបួនភាគសែនទាក់ ដែលគ្រែបតុជារសទូវព្រះសទ្ធម្មទេសនារបស់ព្រះអង្គ នឹងថាដូចម្តេចទៅ?

ព្រះសម្ពុទ្ធទ្រង់គង់ខាងស្តាំព្រះមហាកស្សបត្រ ហើយព្រះអង្គម្ចាស់សាក្យ: អានន្ទ, ទេវទត្តនឹងមន្ត្រីកងព្រះបរមាជវាំង ត្រមាំងព្រះពាជវង្សានុវង្សគ្រង់ដំកង់ជុំវិញទ្រង់ ។

ពីខាងក្រោយព្រះអង្គ ព្រះសារីបុត្តនឹងព្រះមោគ្គល្លាន អរិយសាវកបរស់ទ្រង់ ក្នុងចំណោមព្រះកុលបុត្តស្បង់លឿងទាំងអស់គង់ជាកិត្តិយសក្នុងក្រមដ៏ប្រសើរនោះ ។ នៅចំបែងព្រះដនកព្រះអង្គ, ព្រះរាហុល

ទ្រង់ព្រះសិតការណ៍ (ហេតុនៃការញញឹម) ហើយទ្រង់ត្រៀនព្រះនេត្រ
តម្រង់ចំព្រះភ័ក្ត្រគួរជាទីជ្រះថ្លានៃព្រះវរបិតា, ហើយនៅខាងព្រះបាទ
ទ្រង់ នាងយសោធរាចាកចេញពីកិលេសហើយ មានចំណង់ទៅកាន់
ព្រហ្មវិហារដ៏ឧត្តម ដែលផុតពីអាហារពោលគឺអាយតនៈទាំងខាងក្នុងខាង
ក្រៅ, ដីវិកាពដែលគ្មានជរា ហើយដល់អស់ព្រះជន្មាយុជាបរិយោសាន
ដែលនឹងមានមកកន្លងពេលខាងមុខនេះ, ដល់សេចក្តីស្ងាប់ៗ បាត់បង់លែង
មានតទៅទៀត, កន្លងកាលដែលព្រះសិទ្ធត្ថនឹងព្រះនាងទទួលនូវជោគជ័យ
ជំប្រុសើរ ។ ព្រះនាងបានយកម្រាមព្រះហស្តទៅប៉ះនឹងព្រះហស្តព្រះ
សម្ពុទ្ធ ហើយយកជាយព្រះពស្ត្រមានពណ៌សដូចប្រាក់ទៅរុំព័ទ្ធនឹងស្បង់
ស្បៃនឹងព្រះពាជស្វាមី ដែលជាបុគ្គលជាទីពេញព្រះពាជហឫទ័យនៃព្រះ
នាងជាងសត្វលោកក្នុងត្រៃយកាល ពេញចិត្តចង់ស្តាប់ព្រះពុទ្ធដីកាទៅ
ទៀត ។ ខ្ញុំមិនអាចពណ៌នាអំពីឧត្តមគតិ នៃព្រះនាងដ៏វិសេសវិសាល
ដែលហូរពីរមព្រះឧស្ម័នៃព្រះសម្មាសម្ពុទ្ធ ។

ខ្ញុំជាអ្នកនិពន្ធមកដល់ក្រោយគេបង្អស់ ដែលជាអ្នកពេញចិត្តខាង
ព្រះសម្មាសម្ពុទ្ធ ជាព្រះបរមគ្រូដែលមានព្រះទ័យអាណិតអាសូរដល់
មនុស្សសត្វក្នុងកាល ហើយជាអ្នកថ្លែងរឿងកំរាំងនេះ ដោយយល់ឃើញ
ថាព្រះអង្គជាព្រះសព្វញ្ញុពុទ្ធ តែខ្ញុំពុំមានប្រាជ្ញាគ្រប់គ្រាន់ ដើម្បីនឹង
ពណ៌នាឲ្យច្បាស់លាស់ដោយមិនបាច់អានសៀវភៅគម្ពីរ ដែលកាលបាន

ធ្វើឲ្យរលុបរលាយនូវអក្សរ ដែលពីបុរាណកាលមានន័យដ៏ឆ្ងាលឆ្ងៃ
ពិបាកនឹងយល់ តែមានឥទ្ធិពលអស្ចារ្យអាចញាំងសទ្ធាមនុស្សក្នុងកាល
នៅពេលនោះឲ្យមានឡើងបាន ។ ខ្ញុំបានដឹងនូវព្រះសទ្ធម្មទេសនាដែល
ព្រះសម្មាសម្ពុទ្ធបានថ្លែងនៅក្នុងសាយណ្ហសម័យនៃបឋមទេសវស្សា, ខ្ញុំ
ដឹងថាមានអ្នកប្រាជ្ញបានចារឹកទុកនូវអ្នកស្តាប់មានចំនួនជាអនេក គឺមនុស្ស
ពាន់សែនហាននាក់, ទេវតាពាន់អស់ ទើបពួកបិសាចបាននាំគ្នាមក
ស្តាប់ត្រៃបិតា ហើយក្នុងពេលនោះកាលលោកចាកចេញស្ងាត់រហូត
ដល់ទេវលោកប្រាំពីរដងជាន់ព្រមពាន់អប្បាយកូដិពាន់អស់, ក្នុងពេលនោះ
រស្មីព្រះសូរ្យាបង្គំនៅលើនាលីយខុសពីមោឃធម្មតា, បំភ្លឺដោយពណ៌
កុលាបនូវកំពូលភ្នំគិរីទេបមាបីដូចនិសា (យប់) រង់ចាំស្តាប់ក្នុងជ្រោះ
បព្វតា ហើយទិនមុខ (ថ្ងៃ) រង់ចាំស្តាប់នៅលើខ្នងភ្នំ; គេបានចារឹក
ទុកថា ស្រមោលចោលរូបកាន់គ្នាទៅវិញទៅមកមានសភាពដូចជានាង
កញ្ញាទេពអប្សរដុះដួលដោយកាមទេពដូចនោះ; ពពកអណ្តែតខ្ពស់ខ្ពាញ់
លើអដ្ឋាកាសដូចជាព្រះកេសាអង្គាញ់របស់នាង, តារាភ្លឺដូចគជខ្ចីងនឹង
តេជដែលភ្លឺចាំងពីមុជនាង ព្រះចន្ទូចោលរស្មីក្សាំងមុជ ហើយយប់ងងឹត
ជាព្រះពស្ត្ររបស់នាង ។ ខ្យល់អស្សាសៈបស្សាសៈរបស់នាងបក់ចេញ
មិនដាច់ ផ្សព្វផ្សាយពាសពេញកលមានក្លិនផ្សែង ។, ហើយក្នុងពេល
នោះព្រះសុម្ងាសម្ពុទ្ធបរមគ្រូជាម្ចាស់សំដែងព្រះសទ្ធម្មទេសនា, ហើយបើ

អ្នកណា ស្គាប់ព្រះតថាគត, បើទុកជាអសេយ្យសាសន៍ ឬថាសក្កមាន
វណ្ណៈខ្ពស់ថាបឬជាតិអារ្យៈឬម្ល៉ិតថា (mletcha) (១) ឬពួកអញ្ញជន ទៅ
ជាស្តាប់តាមភាសារបស់ជាតិខ្លួន ។ មិនតែប៉ុណ្ណោះ, គេបានឱពន្ធ
ទុកថាជនជាតិធំ-តូចដែលនៅតាមមាត់ស្ទឹង, សត្វតិរច្ឆាន, បក្សាទីងពួក
ទុវគសត្វ ទៅជាមានចិត្តស្រឡាញ់ព្រះសម្មាសម្ពុទ្ធពន់ពេក, ទទួលគ្រែប
ន្ទប់តថាគតជាវាសនៃតថាគតព្រះអង្គ បានជាដីរាគនៃសត្វទាំងអស់នៅក្នុងទ្រង់
សត្វស្វា, ខ្លាដំបង, ក្រែស, ខ្លាឃ្មុំ, ចចក, ឆ្កែព្រៃ, គ្នាតអាស្រ័យគ្រង់
លលកគ្រាំងពណ៌ប្រផែះភ្លឺ ឬក្អែកមានស្លាបភ្លឺដូចត្បូង, ត្រីឆ្កក់សម្បុរស្រឡែម,
ពស់មានស្រកាភ្លឺ, បង្កួយ, ប្រដៀវ ឬជាមច្ចាហែលក្នុងទឹកស្ទឹង, បាន
ឆ្លងទៅដល់ដែនគាតរគាត ។ ចំពោះមនុស្សជាតិដែលមានលក្ខណៈស្លូត
ត្រង់ មិនស្មើនឹងសត្វតិរច្ឆាន, ហើយមានបីតិប្រាមោជៈសប្បាយក្នុង
ហទយវត្ថុដោយបានយល់ថា ចំណងដែលចងសត្វឲ្យនៅក្នុងទាសភាព
ដាច់ខ្ចាត់ខ្ចាយពីកសន្តានអស់រលីង, ហើយព្រះសម្មាសម្ពុទ្ធទ្រង់បានព្រះ
រាជទានព្រះតថាគតចំពោះព្រះមហាក្សត្រថា :

តុម, អមិតយៈ ! កុំឲ្យចង់ពិសោធន៍ល្បងនឹងវាថានៃអនន្តមាត្រ
(Incommensurable) ឬជ្រមុជខ្សែចិន្តាទៅក្នុងអវិជ្ជនេត (Impénétrable)
អ្នកណា ស្ងួរកាន់ច្រឡំ, អ្នកណាឆ្លើយ, កាន់ច្រឡំ, ។ កុំឲ្យនិយាយអ្វី ?

(មានត)

---

១ ម្ល៉ិតថា ជាពួកអនារ្យធម៌, ជាតាមដែលពួកអារ្យជនហៅចំពោះពួកឈ្លើសឺ ដែលស្ថិត
នៅប្រទេសឥណ្ឌា ។

សុខោទាយកថា

ព្រះអាចារ្យទូច - ទ្បែង វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្វនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំជូត
សំរឹទ្ធិស័ក ព.ស. ២៤៩១ (២២—៥—៤៨)

ឥមេ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខ្ញុំព្រះករុណា សូមបង្អោនកាយ - វាចា - ចិត្ត ក្រាបថ្វាយបង្គំចំពោះ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្តីគោរព ។

លំដាប់តពីនេះទៅ អាត្មាភាពសូមសំដែងនូវព្រះសទ្ធម្មទេសនា ដើម្បីបំភ្លឺការសុខ - ទុក្ខ គ្រប់ចំពូក តាមរបៀបច្បាប់ព្រះពុទ្ធសាសនា ដែលមានចារកត់ក្នុងព្រះត្រៃបិដក ផ្សាយចែកជូនដល់អស់លោក - អ្នក កាន់ព្រះពុទ្ធសាសនា ដោយសង្ខេបដូចតទៅនេះ :

សព្វសត្វទាំងឡាយ សុទ្ធតែស្វែងរកសេចក្តីសុខគ្រប់ៗ ក្នុងលោក តែមិនងាយនឹងបានជួបប្រទះនូវសេចក្តីសុខនោះសោះ ដូចយ៉ាងខ្មែរ: ជនយើងនេះ ច្រើនតែជួបប្រទះនូវសេចក្តីទុក្ខលំបាក ច្រើនជាងជនជាតិនានា នោះមិនមែនមកពីយើងកាន់ព្រះពុទ្ធសាសនាទេ ក្រែងជាមកពីយើងមិនដឹងច្បាប់ព្រះពុទ្ធសាសនាឲ្យច្បាស់លាស់ ឬក៏យើងដឹងដែរតែយើងមិនប្រតិបត្តិតាមឲ្យសព្វគ្រប់ បានជាយើងឃ្លាងចាកសុខ ដែលគួរបានអំពីផ្លូវព្រះពុទ្ធសាសនា ។

ហេតុនេះ អាត្មាភាពសូមពណ៌នាអំពីផ្លូវសុខ ។ ពាក្យថាសុខ។ នេះបានដល់សេចក្តីសប្បាយ រីករាយ ធូរធូលាយ ស្រួលនៃកាយ - និងចិត្ត ។ ឯសុខ សម្រាប់មនុស្សជាតិ ក្នុងសកលលោកនេះ លោកចែកចេញជា ៦ពួកគឺ :

១ - សុខរបស់អ្នកគ្រប់គ្រងផ្ទះ ។

២ - សុខរបស់មនុស្សមួយរូប។ ។

៣ - សុខរបស់អ្នកមានប្តីប្រពន្ធ ។

៤ - សុខរបស់អ្នកជាមាតាបិតា នឹងកូនប្រុស - ស្រី ។

៥ - សុខរបស់អ្នកជានាយ ចៅហ្វាយ នឹងកូន - កុយ ។

៦ - សុខរបស់គ្រូអាចារ្យ នឹងកូនសិស្ស ។

សូមអធិប្បាយមួយពួកម្តង។ ដោយសេចក្តីសង្ខេបដូចតទៅនេះ

សុខរបស់អ្នកនៅគ្រប់គ្រងផ្ទះ - ជនជាគហស្ថអ្នកមានផ្ទះសំបែងគ្រួសារនៅក្នុងស្រុកភូមិមួយ។ នោះ លុះតែបានប្រតិបត្តិប្រតិបត្តិនូវ "យាវាសធម៌" ទើបកើតសុខ ។ យាវាសធម៌នោះមាន ៤ យ៉ាងគឺ:

១ - សច្ចៈ ត្រូវប្រតិបត្តិរក្សាសេចក្តីពិតត្រង់ នឹងមិនកុហកបោកបញ្ឆោតដល់គ្នា ដោយផ្សេងដំណូញដូញប្រែផ្សេង។ ឬតាំងសមាគមក្រុមហ៊ុន។ ជាដើម ។

២— ទម: ត្រូវប្រព្រឹត្តបន្ទន់កាយ វាចា ចិត្តឲ្យទន់ភ្លន់នឹងមិនរំលោភបំពានគ្នាទៅវិញទៅមក ដោយកំលាំងលោភៈ ទោសៈ មោហៈ ជាដើម ។

៣— ខន្តី ត្រូវមានអំណត់អត់ធន់មិនខឹងចំពោះអ្នកនៅរួមនឹងអត់ធន់ចំពោះការងារដ៏លំបាក។ ដែលខ្លួនត្រូវធ្វើ ដូចកសិកម្មបុគ្គណិជ្ជកម្ម ជាដើម ។

៤— ចាគៈ ត្រូវលះវត្ថុឲ្យជាប្រយោជន៍ដល់អ្នកនៅជាមួយ ដែលគួរបែកជាដើម ។

សុខរបស់មនុស្សម្នាយ៉ាងៗ— មនុស្សម្នាក់ៗដែលតាំងចិញ្ចឹមជីវិតខ្លួនឲ្យរស់នៅបានសុខក្នុងបច្ចុប្បន្ននោះ លុះតែប្រកបដោយសុខរបស់អ្នករស់នៅ ៤ យ៉ាងគឺ :

១— <u>សុខកើតអំពីមានទ្រព្យសម្បត្តិដ៏ឋិតបូណ៌</u> ។ ឯទ្រព្យសម្បត្តិរបស់បុគ្គលម្នាក់ៗ ដែលពេញបរិបូណ៌បាននោះ លុះតែប្រកបដោយសម្បទា ៤ យ៉ាងទៀត គឺត្រូវមានការប្រឹងប្រែងខ្នះខ្នែងស្វែងរកគោគសម្បទាតាមផ្លូវចិកផ្លូវគោរកដោយលក់ចេញទិញចូល ចំណូលចំណាយឲ្យច្រើន ១, ត្រូវឲ្យចេះរក្សាថែទាំទ្រព្យសម្បត្តិ ដែលរកបានមកនោះឲ្យគង់វង្សនៅមាំជាប់បិតថេរល្អ ១, ត្រូវឲ្យចេះសេពគប់មិត្តល្អៗ គឺលោកបណ្ឌិតនឹងលោកសត្តិធ៌ៗ ឲ្យបានជាទីពំនុកចុកចិត្ត ១, ត្រូវឲ្យចេះចាយធនធានឲ្យមានប្រយោជន៍ នឹងចេះលៃលកសំចៃតែគ្មានរឹងឲ្យសមល្មម

តាមកំណាន់ដែលរកបាន គឺមិនចំណាយចាយវាយឥតខ្ចះខ្ចាយឲ្យហួសកម្លាំងដែលរកបាន១ ។

២— សុខកើតអំពីបានចាយទ្រព្យ ។ ជនខ្លះមានទ្រព្យមិនចេះចាយ, អ្នកចេះចាយតែងចាយទំនុកបំរុងលោកមាតាបិតារបស់ខ្លួនឲ្យបានសុខរីករាយផង ចាយចិញ្ចឹមគ្រួគ្រួសារឲ្យបានរុងរឿងផង ចាយក្នុងកាលដែលខ្លួនមានទោសគ្រោះថ្នាក់ផង ។

៣— សុខកើតអំពីមិនមានចំពាក់បំណុលគេ ។ ការណ៍ដែលមិនចំពាក់បំណុលគេនោះ លុះតែបុគ្គលនោះវៀរបង់ទោសពីរយ៉ាង គឺជាអ្នកមិនបង្កហេតុឲ្យកើតក្តីក្តាំដល់គ្នានឹងគ្នា ១, មិនប្រព្រឹត្តអបាយមុខដែលជាគ្រឿងវិនាសមានលេងស្រី - ស្រា - បៀ - ហ៊ោ ជាដើម ១ ។

៤— សុខកើតអំពីប្រកបការងារគ្មានទោស ។ ការណ៍ដែលប្រកបការងារគ្មានទោសនោះ លុះតែជាអ្នកប្រតិបត្តិឲ្យល្អត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធអាណាចក្រស្តេចផែនដី មានមិនប្រព្រឹត្តចោរកម្មល្មួចប្លន់ជាដើម ។

សុខរបស់អ្នកមានប្តី - ប្រពន្ធ— បុរសស្ត្រីដែលបានគ្នាជាគូស្រករហើយ ត្រូវប្រតិបត្តិធម៌គ្នាៗ ម្នាក់ ទើបកើតសុខដល់គ្នាបាន គឺប្តីត្រូវទំនុកបំរុងប្រពន្ធរបស់ខ្លួនដោយធម៌ ៥ យ៉ាង:

១ - ត្រូវពាប់អានលើកមុខប្រពន្ធថាជាប្រពន្ធពិតប្រាកដ ។

២ - ត្រូវកុំមើលងាយប្រពន្ធរបស់ខ្លួន ដូចជាទាសី ។

៣ - ត្រូវកុំក្បត់ចិត្តប្រពន្ធដោយមានស្រីដទៃទៀត ។

៤ - ត្រូវប្រគល់ការងារក្នុងផ្ទះឲ្យប្រពន្ធត្រួតត្រា ។

៥ - ត្រូវកេគ្រឿងអលង្ការឲ្យប្រពន្ធ ។

ចំណែកប្រពន្ធត្រូវប្រតិបត្តិស្វាមីដូចជាទេវតាក្នុងផ្ទះ ត្រូវគោរពស្វាមីដោយធម៌ ៥ យ៉ាង គឺ :

១ - ត្រូវចេះតាក់តែងកោជនាហារឲ្យមានឧជារសធ្ងាញ់ពីសារជូនស្វាមីដូចជានាង "អមព" កាលចាត់ចែងបំរើព្រះមហោសថជាស្វាមីរបស់នាងដូច្នោះ ។

២ - ត្រូវពាប់អានញាតិមិត្ត - វង្សត្រកូលខាងស្វាមី ។

៣ - ត្រូវកុំក្បត់ចិត្តប្តីដោយមានប្រុសដទៃ ។

៤ - ត្រូវចេះថែទាំទ្រព្យសម្បត្តិដែលស្វាមីរកបានមក យកទៅខ្ចុកជាក់ឲ្យស្រួលបួលល្អ គឺមិនមែនជាស្រីខ្ជះខ្ជាយ ។

៥ - ត្រូវជាស្រីឈ្លាសវៃ ក្នុងការគ្រប់គ្រងផ្ទះ ទើងជាអ្នកមិនខ្វៃលច្រអូស ក្នុងកិច្ចការទាំងពួង គឺដួសដុល ដេរ ប៉ះ គ្រឹប ជាក់ ចាក់ អន្ទង តា្បញ រវៃ ការទាងស្រីទាំងប៉ុន្មានត្រូវឲ្យចេះស្ទាត់ទាំងអស់ ។

សុខរបស់អ្នកជាមាតា-បិតាធំឯកូនប្រុសស្រី — ជនជាមាតាបិតាអាចទទួលសុខអំពីកូនប្រុស-ស្រីបាននោះ លុះតែបានសង្គ្រោះកូនដោយធម៌ ៥ យ៉ាងគឺ:

១ - ត្រូវហាមឃាត់កូនកុំឲ្យធ្វើអំពើអាក្រក់ឲ្យសោះ, ត្រូវទំបង្ហាត់ពត់បង្វឹកកូនតាំងពីនៅតូច ។ ឲ្យមានសណ្ដាប់ធ្នាប់ល្អ ។

២ - ត្រូវដឹកនាំកូន ឲ្យតាំងនៅក្នុងសុចរិតធំ ១០ មានកាយ-សុចរិតជាដើម ។

៣ - ត្រូវដឹកនាំកូនប្រុស-ស្រីឲ្យរៀនដម្រែវិជ្ជាផ្លូវលោកផ្លូវធម៌ឲ្យបានចេះដឹង ត្រូវទំនុកបំរុងកូនឲ្យចូលសាលាសិក្សា ឲ្យចេះដឹងអក្សរសាស្ត្រភាសាសាស្ត្រ លេខក្បាច់-នព្វន្ត ដញ្ជីង-នាឡិ-ហាប-រង្វាស់រង្វាល់ក្បួនច្បាប់ សម្រាប់លោកិយគ្រប់ផ្លូវ ។ ត្រូវស្រឡាញ់គ្រូដែលបង្រៀនកូនរបស់ខ្លួន ត្រូវជូនចំណីអាហារដល់គ្រូរបស់កូនខ្លួននោះតាមផ្លូវតាមការដ៏គួរ ។

៤ - លុះកូនប្រុសស្រីធំចំរើនឡើងល្មមរកស្វាមី-ភរិយាឲ្យ គប្បីផ្សំផ្គុំឲ្យល្មមតាមវង្សត្រកូលរបស់ខ្លួន ។

៥ - ត្រូវបែងចែកទ្រព្យមតកឲ្យកូនប្រុស-ស្រី ឲ្យមានត្រឹមសំគាល់ជាប្រក្រតជ ឲ្យកូនមានហានៈល្អ តាំងពីខ្លួនៅរស់ ដើម្បីការពារសេចក្ដីសុខដល់កូន ។

- ចំណែកកូនប្រុស - ស្រី ត្រូវគោរពប្រតិបត្តិមាតា - បិតា ដោយកិច្ច តបគុណូបការធម៌ ៥ យ៉ាងគឺ :

១ - ត្រូវបិញ្ចឹមមាតាបិតា ឲ្យបានរស់នៅជាសុខ ឲ្យដូចជាលោក បិញ្ចឹមខ្លួន ។

២ - បើមាតាបិតាកំពុងធ្វើកិច្ចការណា យើងជាកូនត្រូវនាំគ្នា ជួយធ្វើកិច្ចការនោះជូនលោក, បើលោកចាស់ជរា ត្រូវថែទាំរក្សាបំរើ ដោយទឹកក្តៅត្រជាក់គ្រប់យ៉ាង, លោកចូលដំណេក ត្រូវ គក់ច្រចាប់ជក់ដើងដៃ, ទឹងរំតសរសៃជូនលោក, លោកមានជម្ងឺ ត្រូវមើលព្យាបាលដោយថ្នាំពេទ្យ ហ្មប្រចាំការ ។

៣ - ត្រូវរក្សាវង្សត្រកូលរបស់មាតាបិតាឲ្យតាំងនៅល្អ ។

៤ - ត្រូវប្រតិបត្តិខ្លួនឯងឲ្យបានសមរម្យល្មមឲ្យមាតាបិតាទុក បម្រុងទុកចិត្តបាន ជាអ្នកគួរទទួលយកទ្រព្យកេរ្តិ៍មតិកបាន ល្មមលោក ចែកឲ្យដោយងាយ ។

៥ - លោមាតាបិតាធ្វើកាលកិរិយាទៅ កូនប្រុស - ស្រីត្រូវនាំ គ្នាធ្វើសរីរកិច្ចតាមធនធានគ្រប់គ្នា រួចត្រូវធ្វើបុណ្យទក្ខិណាទានុទ្ទិស ផ្សាយផលជូនដល់លោក ។

ឯកិច្ចទាំង ៥ យ៉ាងនេះ បើកូនប្រុស - ស្រីណាបានធ្វើហើយ កូន ប្រុស - ស្រីនោះ លោកហៅថាជាអ្នក "កតញ្ញូកតវេទី" ។

សុខរបស់លោកជានាយចៅហ្វាយនឹងកូនក្មួយ - ពួកជនដែលនៅជ្រកកោន ឬធ្វើការស៊ីឈ្នួលនៅក្រោមបង្គាប់របស់លោកជានាយចៅហ្វាយណា នាយចៅហ្វាយនោះត្រូវសង្គ្រោះដល់ចាវព្រាវ ឬកូនក្មួយនោះដោយធម៌ ៥ យ៉ាង គឺ

១ - ត្រូវចេះចាត់ចែងការឲ្យស្អាតដំនាញ ហើយចេះលៃលកការឲ្យសមគួរដល់កំលាំងនឹងជម្រៃវិជ្ជាដែលចាវព្រាវកូនក្មួយល្មមធ្វើបាន ។

២ - ត្រូវតាំងចិត្តអាណិតចាវព្រាវ - កូនក្មួយឲ្យស្មើៗគ្នា, ត្រូវចែករង្វាន់ផ្តាក់តាស ឲ្យបរិភោគចាយវាយល្មមគ្រប់គ្រាន់ ។

៣ - ត្រូវថែទាំចាវព្រាវ - កូនក្មួយ កន្លងវេលាមានជម្ងឺឈឺចាប់ ត្រូវជួយព្យាបាលថ្នាំនឹងរកពេទ្យ - ហ្មត ជួយការពារកន្លងវេលាមានទោសទុក្ខគ្រោះថ្នាក់ផ្សេងៗ ។

៤ - ត្រូវចែកលាភៈសក្ការៈ នឹងអាហារដែលមានឧជារសប្លែកៗឲ្យចាវព្រាវ - កូនក្មួយបរិភោគផង ។

៥ - ត្រូវបើកឲ្យចាវព្រាវ - កូនក្មួយបានសប្បាយតាមដូវ ត្រូវមានពេលឈប់សម្រាក មានដូវចូលឆ្នាំជាដើម ។

ចំណែកចាវព្រាវ - កូនក្មួយ ត្រូវប្រតិបត្តិលោកនាយចៅហ្វាយដោយធម៌ ៥ យ៉ាងដែរ គឺ:

១ - ត្រូវគ្រោកឡើងធ្វើការមុននាយចៅហ្វាយ ជាអ្នកមិនឲ្យលែងប្រើ-អូសប្រវែងប្រចាំ នឹងនាយចៅហ្វាយឡើយ ។

២ - ត្រូវធ្វើការងារ ជាងគ្រោយនាយចៅហ្វាយ មិនហ៊ានផ្តើមការងារមុននាយចៅហ្វាយ លុះតែការណាដែលលោកអនុញ្ញាតឲ្យ ទើបខ្លួនត្រូវធ្វើការនោះបាន ។

៣ - ត្រូវទទួលយកតែរបស់ដែលនាយចៅហ្វាយឲ្យ ។

៤ - ត្រូវធ្វើការងារឲ្យគ្រឹមត្រូវល្អជូននាយចៅហ្វាយ ។

៥ - ចាំព្រាវ-កូនក្មួយត្រូវនាំយកគុណសម្បត្តិ នឹងសមត្ថភាពរបស់នាយចៅហ្វាយ ទៅសរសើរអួតប្រាប់ក្នុងទីប្រជុំជន នឹងមិត្តអាមាត្យធំ ។ ជាដើម ។

សុខរបស់គ្រូនឹងកូនសិស្ស - ចំណែកគ្រូដែលគួរទទួលសុខអំពីកូនសិស្សបាននោះ លុះតែសង្គ្រោះកូនសិស្ស ដោយធម៌ ៥ យ៉ាងគឺ :

១ - ត្រូវដឹកនាំសិស្សឲ្យរៀនដោយល្អ ត្រូវញុំាងសិស្សឲ្យតាំងចិត្តប្រកបដោយសុចរិត យុត្តិធម៌យ៉ាងចំណាន ឬ ថ្លៃថ្នូរ ។

២ - ត្រូវដឹកនាំសិស្សឲ្យរៀនចប់ផ្លូវលោក ផ្លូវធម៌ ឲ្យចេះចំណានដើម្បីរក្សាជាតិ - សាសនា មហាក្សត្រ ។

៣ - ត្រូវបង្ហាត់បង្ហាញសិល្បវិជ្ជា ដល់សិស្សឲ្យអស់ដម្រែវិជ្ជាខ្លួនមិនលាក់លៀមទុក ។

៤ - ត្រូវលើកតំកើងសិស្ស ក្នុងទីប្រជុំមិត្តអាមាត្យ មិនបន្ទោសបង្អាប់សិស្សក្នុងទីប្រជុំជន ។

៥ - ត្រូវធ្វើសេចក្តីការពារសិស្ស ក្នុងទិសទាំងពួងថា មិនឲ្យសិស្សលំបាកដោយអាហារជាដើម ក្នុងវេលាមានដំណើរទៅកាន់ទិសទាំងពួង ។

ចំណែកយុវជន នារី ជាសិស្សទាំងឡាយ ត្រូវនាំគ្នាប្រតិបត្តិគោរពគ្រូអាចារ្យរបស់ខ្លួនដោយធម៌ ៥ យ៉ាងគឺ :

១ - សិស្សត្រូវនាំគ្នា ធ្វើសេចក្តីគោរពចំពោះគ្រូអាចារ្យ របស់ខ្លួន មានការបបួលគ្នាក្រោកទទួលគ្រូជាដើម ។

២ - សិស្សត្រូវនាំគ្នា ចាំបំរើគ្រូដោយកិច្ចផ្សេងៗ ក្តីមិនមានកិច្ចអ្វីក្តី មានទឹកក្តៅត្រជាក់ជានិច្ចជាដើម ។

៣ - សិស្សត្រូវនាំគ្នា ទំនុកបំរុងគ្រូ ពេលណាដែលគ្រូមានអាពាធឬជម្ងឺ សិស្សត្រូវរកថ្នាំ ឬពេទ្យឬ មកព្យាបាលគ្រូ ទំាងជូនចំណីអាហារផ្សេងៗ ដល់គ្រូរបស់ខ្លួនជារឿយៗ ក្តី ក្នុងវេលាមួយឆ្នាំមួយកាលក្តី ឬក៏វេលាបួលឆ្នាំថ្មីជាដើមក្តី ។

៤ - សិស្សត្រូវដឿនតាមដែលគ្រូប្រៀនប្រដៅ គឺត្រូវយកចិត្តទុកដាក់ស្តាប់ឲ្យបានការ ដើម្បីយកទៅធ្វើជាច្បាប់ទម្លាប់របស់ខ្លួនឲ្យចេះចាំច្រើនដូចចិត្តឲ្យច្បាស់លាស់ ។

៥ - សិស្សត្រូវនាំគ្នារៀនសូត្រដោយគោរព, ពាក្យថារៀនសូត្រដោយគោរពនោះ គឺត្រូវខំប្រឹងប្រែងខ្នះខ្នែងរៀនសូត្រ មិនខ្វល់ច្រអូសក្នុងការសិក្សា បើសិក្សាវិជ្ជាណា ។ ត្រូវខ្មស្បាហ៍ទន្ទេញឲ្យចេះចាំស្ទាត់រត់មាត់, ចូលចិត្តច្បាស់លាស់ក្នុងសិស្សវិន្យានោះ ។ ទើបឈ្មោះថារៀនសូត្រដោយគោរព ។

ភៃយុវជន-យុវនារី អ្នកត្រូវការសិក្សាសិល្បសាស្ត្រ-អក្សរសាស្ត្រ-វិទ្យាសាស្ត្រ នឹងនព្វន្តសាស្ត្រ-លេខជាដើម ត្រូវនឹកពិចារណាដល់ច្បាប់លោកនីតិបករណ៍ថា:

កុំមើលងាយមន្តសិល្បសាស្ត្រ គិតថាតិចតួចគ្រែងមិនស្រេច
វិជ្ជាមួយមែនបើមិនក្ងេច គង់នឹងសម្រេចប្រយោជន៍បាន ។
ចេះមួយចេះពីរឲ្យតែស្ទាត់ ប្រកបច្បាកដអ្នកចំណាន
ជាហេតុចិញ្ចឹមជីវិតបាន សន្ធានដួលពឹងពំនឹងអើយ ។
សិល្បសាស្ត្រឯណាមិនស្ទាត់ពិត នៅក្នុងស្មឹកតែប្តូរសៀវភៅ
ទ្រព្យធនឯណាដែលមាននៅ ជ្លាក់ទៅក្នុងដៃអ្នកដទៃ ។

បើមានកិច្ចការណាដល់មក សិល្បទ្រព្យនោះយកមកអាស្រ័យ
ពុំបានដូចចិត្តដ្បិតឆ្ងាយដៃ សិល្បទ្រព្យនោះនៃហៅគ្មានហោង ។

សុភាសិតថា :

មានទ្រព្យលើកឲ្យគេខ្លីទៅ ដង្រែះចេះនៅតែកន្ត្រក់ក្បួន
ប្រពន្ធនៅឆ្ងាយអំពីខ្លួន ដល់ជួនត្រូវការអាចិត្ត ។

ធម៌ទេសនាសំដែងមកនេះ ដើម្បីឲ្យខេមរជនចាំងឡាយស្ទុះគ្រាក
ខ្មើង ខំប្រឹងប្រែងស្វែងរកសេចក្តីសុខដល់ខ្លួន ទឹងដល់ជាតិប្រទេស
ក្នុងបច្ចុប្បន្ននេះ សូមសន្តតថាចប់តែប៉ុណ្ណេះ ឯរំ ។

ដោយអំណាចនៃធម៌ទេសនានេះសូមឲ្យជាតិ សាសនា មហាក្សត្រនៃ
ខេមរជាតិយើង ចំរើនសេចក្តីសុខគ្រប់ប្រការអស់កាលជ័យរវែងទៅ ។

ចប់

ជោគវាសនាញញឹមទទួលបំពោះតែអ្នកក្លាហាន

អ្នកចិត្តក្លាហានបានជួយជាតិ
យិតយោងឲ្យឃ្លាតឥតសាកាព
រមែងមានឈ្មោះខ្ចស់ដកប
បើទុកជុនដាបតង់ទេពជួយ ។

យ. អ.

រឿងក្រូសាញ់[1] អ្នកខ្លាំងឆ្លៀក

លោក ផេង-ជ្រឿ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែនិងរៀបរៀង

(ត—ចប់)

ខណៈនោះគ្រូសាញ់ចេញពីក្រោមស្ពានមក ហើយស្រែកថា នែអាយក្បាច់ក្តៅ! មកយើងច្បាំងគ្នា! តើអាឯងចូលចិត្តបែបណា? ចង់អាវុធឬដៃទេ? ។

ក្រុងយក្សស៊ុះក្តែតមកដល់ ហើយតយុទ្ធជាមួយគ្រូសាញ់ ។ ម្ខាងនេះ គេច្បាំងគ្នាដោយអាវុធ ។ មិនយូរប៉ុន្មាន ជាវិលតែងក៏ចាក់បែកអស់ ។ រួចការចាប់ផ្តើមវាយគ្នា ដៃនឹងដៃ ក៏តាំងមានឡើង ។ គេច្បាំងគ្នាតាល់តែកម្រើកដៃនឹង ។ គ្រូសាញ់ដឹងថាការនុបតែនៃយក្សកាន់តែតឹងឡើង ។ គាត់ចេះប្រឹងចំកោងទប់នឹងកំឡាំងយក្សបាន ហើយចាប់តែយក្សតាល់តែលាន់ធ្មឹងឆ្អែងតាំងអស់ ។

ចម្បាំងបែបនេះ គ្មាននរណាដែលឃើញឡើយ ។ ដល់ថ្ងៃត្រង់ គេក៏នៅតែប្រយុទ្ធគ្នា ស្រែកទឹកទះក អស់កំលាំងតែរៀងខ្លួន ។ វេលានោះ មានក្អែកមួយហើរពីលើ ។ យក្សឃើញដូច្នោះ ហៅថា បងក្អែក។ មឆ្ងាយឯងយកទឹកមកឲ្យអញផឹកមួយលេប អញនឹងឲ្យខ្មោចអ្នកហាវហានម្នាក់ត្រមាំងសេះ របស់ក់ យកទៅស៊ី ។

---

១ ក្នុងរឿងព្រេងរួមមាំងថា «ក្រេសាណូ» អ្នកប្រែចង់ឲ្យស្រួលអាន ទើបបកថា «គ្រូសាញ់» ។

ខណៈ នោះ គ្រូសាញ់និយាយមួងថា. បងអ្នកៗ យកទឹកច្បាស្អុមក ឲ្យខ្ញុំផឹកវិញ នោះខ្ញុំនឹងឲ្យ ភ្នាចយកក្បាប៊ី នឹងខ្មោចសេះបី ដល់បងឯងឆាអាហារ ។

ឮសំដីគ្រូសាញ់ អ្នកយកទឹកមកឲ្យគាត់ផឹកបំបាត់ការស្រេក ហើយធ្វើឲ្យគាត់មានកំលាំងនឹងសេចក្តីក្លាហានឡើងវិញ ។ មានកំលាំងក្លាម គ្រូសាញ់ចាប់យកក្បាលើកឡើងស្ទង បុកចុះក្នុងដីលិចខ្លួនដល់កយកដៃដាន់ក្បាល ដើម្បីទប់ឲ្យនឹងហើយស្រែកសួរថា: ម្នាលអាចោរបិសាចចង្រៃ! អាឯងត្រូវឬបាប់អញ តើអាឯងលាក់ព្រះអាទិត្យនឹងព្រះចន្ទក្នុងទីឯណា? ព្រោះពេលនេះ អាឯងមុខជាមិនរួចព្រ័ត្តណាប់ដៃអញហើយ ។

យក្សខំត្រដរវ៉ៃខ្លួន ឡើងមុខក្រហមងាំងដើម្បីស្ទុះរត់ ហើយនិយាយរង្គុំៗ តែក្នងមាត់ ។ គ្រូសាញ់និយាយទៀតថា: ទោះបីអាឯងឬបាប់ក៏ដោយ មិនឬបាប់ក៏ដោយ គង់តែអញរកឃើញ ព្រះចន្ទនឹងព្រះអាទិត្យនោះ. ប៉ុន្តែ អាឯងទៀងតែមានក្បាលជាប់ជាមិនខាន ។

លុះចំបង្អុត យក្សមានសង្ឃឹមថា បើឬបាប់កាលណា ប្រហែលបានរួចជីវិត ទើបស្រែកឬបាប់ថា: នោកុងវៃវៃតង មានរូងមួយ គឺកងរូងនោះហើយដែលអញលាក់ព្រះអាទិត្យនឹងព្រះចន្ទ. កូនម្រាមដៃស្តាំរបស់អញជាកូនសោ សម្រាប់ចាក់បើករូងនោះ ។

ឮដូច្នោះហើយ គ្រូសាញ់កាត់ក្បាលយក្សភ្លាម រួចកាត់យកម្រាមកូនដៃស្តាំដោយស្រួលបួល ។

ខាងក្រោយដែលបានឲ្យភ្នែចយក្ស ទឹងភ្នែចសេះដល់ភ្លែតហើយ គាត់ត្រាច់ទៅក្នងព្រៃបៃតង ឃើញរូងគុហាមួយ យកម្រាមកូនដៃយក្សចាកបើកទ្វារ ហើយឃើញព្រះអាទិត្យនឹងព្រះចន្ទ្រនៅទីនោះ ។ គាត់ចាប់ព្រះអាទិត្យដោយដៃម្ខាង ព្រះចន្ទ្រដោយដៃម្ខាងទៀត ហើយបោះទៅលើអាកាសវេហាស៍ រួចគាត់មានសេចក្តីសប្បាយរីករាយអ្វីប្រៀបគ្មាន ។

បណ្តាជនទាំងអស់ កាលបើបានព្រះអាទិត្យនឹងព្រះចន្ទ្រត្រឡប់វិលមកកាន់ទីគោចរតាមធម្មតាវិញ ក៏មានចិត្តត្រេកអរជាអនេក ថែមទាំងអរគុណចំពោះព្រះជាម្ចាស់ ដែលមានព្រះទ័យមេត្តាជួយកំលាំងដល់គ្រូសាញ់ ដើម្បីញាំងការផ្តាញ់នូវបច្ចាមិត្ត នៃមនុស្សលោកឲ្យបានសម្រេច ។ រួចបុរសហាវហានធ្វើដំណើរយ៉ាងរីករាយវិលមកវិញ ។

ដល់ផ្លូវបំបែក គាត់បានឃើញប្អូនរបស់គាត់ឈប់ចាំនៅទីនោះ ជនទាំងពីរសុំចាប់ឧបគ្គា យំថ្លែងសេចក្តីសុខទុក្ខចំពោះគ្នាទៅវិញទៅមក ទិញសេះពីរយ៉ាងលឿនជូចព្រួញ ហើយជិះត្រឡប់មកកាន់ព្រះរដ្ឋដើមវិញ ។

នៅតាមផ្លូវ គេបានឃើញទន្លាប់មួយដើម ពេញដោយផ្លែក្រហមជូចមាស ។ ប្អូនគ្រូសាញ់អង្វរបងសុំឈប់ក្រែមម្ចប់ទន្លាប់សិន ដើម្បី

ឲ្យសេរចាត់ហាត់ផង បំបាត់សេចក្តីឃ្លានដោយបរិភោគផ្លែទន្ទាប់ខ្ទុំមួយ ពីរម្នាក់ផង ។ គ្រូសាញ់ដែលយល់កលនៃមេយក្ខិនី ក៏សុខចិត្តព្រម ឈប់តាមពាក្យសុំរបស់ប្អូន ។ ប៉ុន្តែ គាត់មិនបណ្តោយឲ្យប្អូនគាត់បេះ ផ្លែទន្ទាប់ឡើយ និយាយថា ទុកឲ្យគាត់បេះឲ្យវិញ ។ ខាញកាំបិត លៀមចេញមក គាត់កាប់ដើមទន្ទាប់ជាប់ត្រឹមដី ។ គ្រានោះ គេ ឃើញឈាមពុលគួរស្ញែងហូរចេញឡើងហើយ ក្មួសរសំឡេងនិយាយពី កន្ធដើមឈើមកថា: បើអាឯងស៊ីអញតែមួយម៉ាត់ គាត់ឯងទៀងតែស្លាប់ ដូចជាប្តីអញដែរ ។

កន្ធមួយសន្ទុះតមក ដើមទន្ទាប់ខោះក៏អន្តរាយចាត់ គេឃើញខៅ មានតែផេះនឹងធ្លី ។ ចំណែកប្អូនគ្រូសាញ់ស្រឡាំងកាំង មិនយល់- សោះនូវរឿងហេតុដែលបានឃើញប៉ុន្មាន ។

បងប្អូននាំគ្នាធ្វើដំណើរតទៅទៀត ។ លុះឆ្ងាយបន្តិចមក ជនទាំង ពីរដំរេសេះបរកែ្សរបក្សាមួយដ៏រុងរឿងអស្ចារ្យ ពេញដោយបុប្ផាផ្សេង ។ នឹងមេអំបៅគ្រប់ពណ៌ ហើយមានទឹកយ៉ាងថ្លាហូរខាងកន្ត ។

ប្អូនគ្រូសាញ់និយាយទៅកាន់បងថា: ត្រូវយើងឈប់ត្រង់នេះបន្តិច សិន បង! សេះយើងនឹងសំរាកបន្ទុកំលាំង ហើយយើងក៏អាចងូតទឹក ថ្លានេះបំបាត់សេចក្តីស្រេក ព្រមទាំងបេះផ្កាពីរបីកំសាន្តលេងផង ។

គ្រូសាញ់ឆ្លើយថា: មែនហើយ ប្អូន! ប៉ុន្តែ សូមឲ្យបុប្ផជាតិទាំង នោះជារបស់មនុស្សលោកចាំ ហើយទឹកជារបស់ផងព្រះជាម្ចាស់ ។

ហើយគាត់ញ៉ាំលៀមចេញមក គាត់កាត់ផ្ចាំមួយដើមយ៉ាងធំតាំងតែ
ផ្តេកទៅដី រួចយកដើមក៉ាំរុកក្នុងទឹកជ្រោះ ។ តឹមនៃមែនជាទឹកធម្មតា បែរ
ត្រឡប់ជាឈាមខ្មៅហូរមកវិញ បំពេញអាកាសដោយក្លិនអសោចឹកគ្រក
ពេក ។ ម្តងនេះគឺកូនស្រីច្បងនៃមេយក្ខិនី ដែលក្លាយជាជួលី មកនិម្តិត
ជាច្បារនឹងជាជ្រោះ ដើម្បីបំពុលគ្រូសាញ៉ាឲ្យស្លាប់ ។

បានកន្លងផុតពីគ្រោះកាច ម្តងជាពីរដងហើយ ជនចាំងពីរលោត
ផែលលើខ្នងសេះបំផាយយ៉ាងលឿនដូចខ្យល់ ។ មិនយូរប៉ុន្មាន មេយក្ខិនី
ជាប្រពន្ធក្រែងយក្ស ហោះតាមមកទៀត ហារមាត់យ៉ាងធំអស្ចារ្យពីដី
ដល់មេឃ បំរុងនឹងលេបត្រចាក់គ្រូសាញ៉ាតែមួយឃុបឲ្យស្រេច ។ វាក្តៅ
ក្រហាយនឹងគ្រូសាញ៉ាដែលសំឡាប់ប្តី កូនស្រីនឹងកូនប្រសារបស់វា ។

គ្រូសាញ៉ាដឹងថា មេយក្ខិនី ដេញតាមមកហើយ ក៏និយាយប្រាប់
ប្អូនថា: នែអូន! ចូរឯងក្រឡេកមើលក្រោយមើល បើឃើញអ្វី ចូរប្រាប់
បង ។ ប្អូនឆ្លើយថា: គ្មានឃើញអ្វីទេបង! មានតែពពកខ្មៅមួយដុំរសាត់
មកតាមក្រោយយើងលឿនដូចខ្យល់កំបុតត្បូង ។

បងប្អូនពីរ ទំាយសេះរៀងខ្លួនបំផាយឲ្យលឿនដូចខ្យល់ហើយ
ស្មើមស្មាត់ដូចចិត្តនឹក ។ គ្រូសាញ៉ាប្រាប់ប្អូនទៀតឲ្យក្រឡេកមើល
ក្រោយ ហើយប្អូនប្រាប់ថា ពពកនោះកាន់តែអណ្តែតជិតណាស់មក
ហើយ ។ ដូចជាអណ្តាតភ្លើងផង ។ គេទំាយសេះបំប្លែ លុះទីបំផុត
ក៏បានដល់លំនៅជាងដែកផែនដី ។

លោតពីលើខ្នងសេះ បុរសបង់ប្អូនរត់ចូលពួនក្នុងកន្ទែងដំដែក ។ ខេសកាលល្អសំណាងមាន បើមេយក្ខិនីតាមទាន់ សមនៅសល់តែធ្មេញតែឥឡូវវាកេរ្តិ៍អ្វីមិនកើត ។

ម្ខាងនេះ មេយក្ខិនីប្រើឧបាយវិញ: វាអង្វរសុំឲ្យគ្រូសាញ់ចោះប្រហោងមួយគូទនៅជញ្ជាំង គ្រាន់តែវាអាចមើលឃើញមុខគ្រូសាញ់ៗធ្វើហាក់ដូចជាយល់ព្រមតាម ។ ប៉ុន្តែនៅខាងក្រោយជញ្ជាំងនោះ ជាកន្ទែងរបស់ជាងដែកផែនដី នឹងរូបសំណាកគ្រូសាញ់អ្នកហាវហាន គឺជារូបដែកចាំងដុលទើបតែយកចេញពីភ្លើង មានចាំងព្រាចភ្លើងផ្ទុះប្រែះៗទៅឡើយ ។ កាលមេយក្ខិនីយកមាត់ទៅផ្អឹបនឹងរន្ធជញ្ជាំងដើម្បីលេបគ្រូសាញ់ ជាងដែកឮរូបដែកក្រហមចាំងជាក់មាត់ ហើយរុញឲ្យចូលដល់បំពង់ក ។ មេយក្ខិនីច្រេះក្តាម ហើយបែកពោះផ្ងួត ។ ខ្មោចក្លាយទៅជាក្តាំដែកមួយរំពេច ។ សំឡាញ់យើងពីរនាក់ ក៏បានរួចជីវិតដោយសារ ។

គ្រានោះជាងដែកផែនដី បើកទ្វារបន្ទប់ដំដែក បង់ប្អូនចាំងពីរចេញមក មានសេចក្តីសប្បាយរីករាយអស់ចិត្តចិយប់ អំពីជ័យជំនះដ៏ធំនេះ ។ ជាងដែកផែនដីសប្បាយជាងគេ ដោយបានក្តាំដែកមួយធំ ចាត់ឲ្យក្លាយជាងធ្វើរទេះដែកប៉ិទិមដោយសេះដែកប៉ិដែរ គាត់ផ្តុបញ្ចូលវិញ្ញាណក្នុងរូបសេះចាំងនោះឲ្យមានជីវិត រួចប្រគល់ឲ្យគ្រូសាញ់ជាសំឡាញ់ ។ អ្នកហាវ

ហានទេះលាសំឡាញ់ ឡើងជិះរទេះជាមួយនឹងប្អូន ហើយធ្វើដំណើរទៅ
កាន់ព្រះបរមរាជវាំងនៃព្រះបាទវត្តា ដើម្បីសូមយកវង្វាន់ ។

ជនទាំងពីរទៅជាមួយគ្នា រហូតដល់ផ្លូវបំបែកមួយហើយឈប់សំរាក
ក្នុងទីនោះ ។ រួចគ្រូសាញ់ ដោះសេះឲ្យទៅប្អូន ដើម្បីទៅមុន យក
ដំណឹងទៅថ្វាយ ព្រះរាជាអំពីការវិលត្រឡប់ប្រកបដោយជ័យជំនះ ។
ខ្លួនគាត់ចាំទៅជាខាងក្រោយ ។

ចំណែកគ្រូសាញ់កំពុងតែធ្វើដំណើរបន្តិចៗ ដេកលេងក្នុងរទេះស្រាប់
តែគ្រាច់ទៅក្បែរបិសាច កំបាក់ដើងមួយនៅខាងផ្លូវដែលមានកិច្ចខាង
ចាំធ្វើទុក្ខដល់អ្នកដំណើរទាំងឡាយ ។ បិសាចនោះមិនហ៊ានធ្វើបាប
គ្រូសាញ់ តែមិនចង់ឲ្យគាត់ទៅដោយគ្មានអន្តរាយតែអ្វីមួយ ក៏លួចដក
ដែកគោលមួយដែលបោះភ្ជាប់ដុំកង់ខាងក្រោយ យកបោះចោលទៅខាង
ក្រោយឆ្ងាយហើយស្រែកថា នែសំឡាញ់! ដុំកង់ក្រោយរដកធ្លាក់ហើយ។

លោតចុះពីរទេះទៅដើ គ្រូសាញ់ក្រេចកាន់លៀមទៅផង ។ បិសាច
ឈ្មោះសាតានលួចយកលៀមបាន រួចលោតបីដង ក៏ក្លាយខ្លួនទៅជាថ្ម
មួយដុំនៅក្បែរថ្នល់ ។

គ្រូសាញ់រើសយកដែកគោលមកវិញ យកទៅបោះភ្ជាប់ត្រង់កន្លែង
ដដែល រួចបរទេះតទៅទៀត មិនបានចាប់ភ្ញីភ័អំពីលៀមបាត់ឡើយ ។

ក្នុងគ្រានោះ មានទីប្រឹក្សាព្រះរាជាណាចក្រម្នាក់ចិត្តអាក្រក់ បាន
សន្យាថានឹងឲ្យដួងវិញ្ញាណនៃខ្លួនដល់បិសាចសាតាន បើបិសាចនេះ

អាចយកកូនស្តេចមកឲ្យវាធ្វើជាប្រពន្ធបាន ។ ម្យ៉ាងទៀត អាចិត្ត
អាក្រក់នេះ បានតាំងខ្មៅសហាយជាមួយនឹងព្រះរាជធីតារួចហើយផង ។
ចំណែកអាបិសាចបង្កៃបានដឹងច្បាស់ថា គេជាខ្មុកាពនៃគ្រូសាញ់ស្ថិតនៅ
ក្នុងលៀម ។ ហេតុដូច្នេះ បានជាវាខំលួចយកលៀមទៅប្រគល់ឲ្យ
ទីប្រឹក្សាចំកួតនេះ ។ ឥស្សរជននេះ លុះបានលៀមហើយ ក៏ចូលទៅ
គាល់ព្រះរាជាក្រាបបង្គំទូលទ្បូស្នាដៃនៃគ្រូសាញ់ថាជាស្នាដៃរបស់ខ្លួន ។
ព្រះមហាក្សត្រជ្រុងជ្រឿតាម ។ រួចគេកំពុងតែរៀបចំប្រជាប់ប្រជា
ដើម្បីនឹងធ្វើអាពាហ៍ពិពាហ៍រវាងទីប្រឹក្សា នឹងព្រះរាជធីតា ស្រាប់តែប្អូន
គ្រូសាញ់មកដល់ ហើយថ្វាយដំណឹងដ៏យូរជំនះ ទើងការដឹងមកដល់នៃ
គ្រូសាញ់ ចំពោះព្រះរាជា ។

បានដំណឹងនេះ ទីប្រឹក្សាទៅគាល់ព្រះរាជាភ្លាម ហើយក្រាបទូល
ថាស់ថា អ្នកដែលមកថ្វាយដំណឹងនេះគឺជាមនុស្សចោកបញ្ឆោតទេ គួរ
តែព្រះករុណាយកទៅដាក់គុកទើបសម ។ ព្រះរាជាជ្រងជ្រយល់តាម ។
កាលបើទីប្រឹក្សាបង្គំព្រះរាជាឲ្យប្រញាប់ រៀបអាពាហ៍ពិពាហ៍ ព្រះអង្គ
គ្មប់ជាមិនសព្វព្រះរាជហ្ឫទ័យ ហើយថែមទាំងបន្ថយថ្ងៃមង្គលការ
នោះទៅទៀត (អាចិត្តអាក្រក់គិតឃើញថា ឲ្យតែបានរៀបការហើយ
គ្រូសាញ់មកក៏មិនអាចថ្វាស់បួរវើងនេះបានឡើយ) ។

មិនយូរប៉ុន្មាន គ្រូសាញ់មកដល់ ទៅក្រាបបង្គំគាល់ព្រះរាជាដែល
ទ្រង់មិនដឹងជាយកណាចោលណា ។ ព្រះរាជាទ្រង់ធ្វើគ្រូសាញ់ដែរ

ប៉ុន្តែ ទាស់ត្រង់គាំបិតលៀម ហេតុដូចម្តេច ក៏ទៅនៅកន្ថែដៃនៃទីប្រែក្សាវិញ ! ។ ពេលនេះហើយទើបគ្រូសាញ់ក្រាក់ខ្លួនដឹងថាត់លៀម ហើយនឹកដល់ថ្នូមួយដុំនៅក្បែរថ្នល់ដែលគាត់ប្រទះឃើញ កន្ថែវេលាដែលគាត់ត្រឡប់មកពីរើសដែកគោលវិញ ។ ដឹងច្បាស់ថាជាក់ជាមានហេតុកេតត្រង់ទីនោះហើយ គ្រូសាញ់ក៏ក្រាបទូលព្រះពជាថា បពិត្រព្រះមហាក្សត្រដ៏ខ្ពង់ខ្ពយសព្ពដ៏ខ្ពស់ ទេសពិធពជធម៌នៃព្រះករុណាថ្ងៃវិសេស តែងទៅតាសពេញព្រះពជរង្ស! បើដូច្នេះ សូមខ្ញុំផ្សាយសេចក្តីសប្បុរសនេះដល់ទូលព្រះបង្គំជាខ្ញុំផង, ព្រះអង្គខ្ញុំព្រះខន្តីយូរណាស់មកហើយឥឡូវសូមព្រះមេត្តាអត់ទោសបន្តិចទៀត នោះខ្ញុំនឹងឃើញការពិតចំពោះព្រះនេត្រជាមិនខាន ។

ព្រះពជាក៏ខ្ញុំយល់ព្រម ។ ហើយគ្រូសាញ់ត្រឡប់ឡើងជិះរទេះដែកបរលៀទៅកែកន្ថែថ្នូនោះ ហើយស្រែកថា នែអាកំចាប! អាមហាចោរដល់មនុស្សលោក អាឯងលួចលៀមអញ ត្រឡប់ឲ្យមកអញវិញ បើមិនដូច្នោះទេ អាឯងមុខជានឹងស្លាប់ជាងផ្លូវទៅទៀតឥឡូវ ។

ប៉ុន្តែ ដុំថ្នូនៅព្រងើយ ឥតកម្រើក ។ គ្រានោះគ្រូសាញ់លោតបីងឯងទិម្ចិតខ្លួនជាដុំដែក យ៉ាងរឹងមាំហើយស្ងួត តាំងលោតទង្គិចពីលើដុំថ្នូយ៉ាងខ្លាំងអស្ចារ្យទាល់តែញ័រផែនដី ។ កន្ថែការលើកអុកពីលើម្តងៗមានខ្ចាតកំទេចថ្នូចេញព្រាតៗ ។ ហើយការលោតអុកនេះគ្មានឈប់ឈរ

សោះ ទាល់តែកំពូលដុំថ្មបែកខ្ទេចខ្ទី អស់រលីង ។ កាលណោះ ដុំថ្ម ចាប់តម្រែករហើយសូមទោស ។ ប៉ុន្តែដុំដែកអុកជានិច្ចកាន់តែខ្លាំងឡើង ។ ឥតបង្អង់សោះ ទាល់តែដុំថ្មបែកម៉ដ្ឋទៅជាធូលី ។ គ្រូសាញ់កកាយរកកូនធូលីថ្ម ហើយបាននើញរលៀម ដែលបិសាចសាតានលួចយកពីគាត់ទៅនោះមកវិញ ។

គាត់កាន់លៀមរត់ទៅយ៉ាងលឿនឥតបង្អង់ ចូលបង្គំគាល់ព្រះពជាម្ចាស់ទៀតហើយនិយាយថា បពិត្រព្រះមហាក្សត្រដ៏ឧត្តុង្គឧត្តមវិសុទ្ធិ! ទូលព្រះបង្គំប្រគល់ស្រេចហើយ នឹងសំដែងវិទ្ធិថ្វាយ តើឈ្មោះណាអាចតវ៉ាថាជាស្នាដៃនៃគ្រូសាញ់, សូមឲ្យអាចារអប្រិយឥតខ្មាសដែលវាបានបំភាន់ព្រះអង្គចូលមក ហើយយើងនឹងដែកគ្នាល្បងមើល ។

ព្រះពជាមានព្រះពជឫទ្ធានុភាពបង្គាប់ឲ្យគេហៅទីប្រឹក្សាចូលមក ។ អ្នកនេះ លុះបានឃើញកាំបិតលៀមកាលណា ក៏ញាក់ដូចកូនសត្វ សុំទោស ហើយព្រមទទួលកំហុសទាំងអស់ ។

ដោយសេចក្តីអង្វរបស់គ្រូសាញ់ ព្រះពជាក៏ទ្រង់ព្រមអត់ទោសដល់ទីប្រឹក្សា ប៉ុន្តែព្រះអង្គទ្រង់នឹរទេសឲ្យចេញពីពជវង្ស របស់ព្រះអង្គ ។

រួចព្រះពជាទ្រង់បង្គាប់ ឲ្យគេដោះលែងអ្នកគ្រូសាញ់ចេញពីគុក ហើយតាំងរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងកូនស្រីរបស់ព្រះបាទដោយសេចក្តីសប្បាយរីករាយយ៉ាងក្រៃលែង ។

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុង-ប៉ែម

អាចារ្យសាលាបាលីវគ្គ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាគុរុក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

និស្ស័យសុភាពនេះ មានអំណាចខ្លាំងក្លាកែលែងជាងអំណាចនឹងកំឡាំងដទៃទាំងអស់ក្នុងលោក ។ សូម្បីមនុស្សពាល ដែលមានមាន: រឹងត្អឹង រឹងរូសប្រដៅក្រែ អាចធ្វើសេចក្តីអាក្រក់ ចំពោះនរណា ។ បានដោយឥតរើសមុខ មិនគោតក្រែងចំពោះអំណាចអ្វីមួយនោះ ក៏គង់តែគោតក្រែងចំពោះអ្នកដែលខ្លួនដឹងថា ជាមនុស្សមាននិស្ស័យសុភាពចំពោះខ្លួនដែរ ។ ការហាមប្រាមទាំងឡាយ បើហាមប្រាមដោយអំណាចមិនសម្រេច ក៏អាចហាមប្រាមឲ្យសម្រេចដោយនិស្ស័យសុភាពបាន ។ ការគំរាមកំហែង ជាគ្រឿងបង្កឲ្យកើតការមើលងាយប្រដៅក្រែរឹងរូស ។ ឯនិស្ស័យសុភាពវិញ មានអំណាចឲ្យកើតសេចក្តីស្រឡាញ់នឹងជឿស្តាប់ ធ្វើឲ្យខាងអ្នកជួយនឹងខាងអ្នកទទួលដឹងគុណគឺសេចក្តីល្អដែលបានធ្វើចំពោះគ្នា ។ ខាងអ្នកទទួល សូម្បីមិនដឹង កាលនឹកមក

ដល់ត្រង់រឿងនេះ កំតង់នឹងកើតសេចក្តីដឹង មានគតញ្ញូដឹងគុណ នឹង
មាននិស្ស័យសុភាព តបស្នងចំពោះអ្នកដែលជួយខ្លួនវិញ ។

សរុបសេចក្តី.— និស្ស័យសុភាព គឺនិស្ស័យសូបសៀមសុខ
ស្រួល ត្រជាក់ត្រដំ ។ និស្ស័យសុភាពនោះ ចាត់ថាជាលោហិត
របស់ជីវិត ដែលអាចបញ្ជូនវស្តីដល់ជួនវិញ្ញាណរបស់អ្នកដែលទ្រទ្រង់
ពុក ចាំងរក្សាអ្នកដែលទ្រទ្រង់នោះ ឲ្យនៅគង់វង្សនឹងចំរើនរុងរឿង
សមគួរដល់បំណងរបស់ជីវិត ។ កាលបើយើងមាននិស្ស័យសូបសៀម
ត្រជាក់ត្រដំហើយ និស្ស័យនេះ អាចជួយឲ្យយើងមានលក្ខណៈល្អបាន
នឹងធ្វើឲ្យអ្នកដទៃសូបសៀមត្រជាក់ត្រដំផង ប្រៀបដូចទឹកត្រជាក់ដែល
យើងបរិភោគចូលទៅ អាចធ្វើឲ្យយើងរីករាយចិត្តនឹងធ្វើអ្នកដទៃទៀត
ដែលបានបរិភោគឲ្យត្រជាក់ដួងចិត្តផង ត្រមាំងស្រោចស្រពូជពង្ស
ឲ្យត្រជាក់ចិត្តទៀត ។ បើយើងមាននិស្ស័យមិនសុភាពរៀបរយវិញ
និស្ស័យនេះ នឹងធ្វើឲ្យយើងក្តៅក្រហាយ ត្រមាំងធ្វើឲ្យមនុស្សដទៃ
កើតក្តៅក្រហាយក្រវល់ក្រវាយ មិនរៀបរយដែរ ប្រៀបដូចទឹកក្តៅដែល
យើងបរិភោគចូលទៅ អាចធ្វើឲ្យយើងក្តៅនឹងធ្វើអ្នកដទៃទៀតដែលបាន
បរិភោគឲ្យក្តៅដូចគ្នា ត្រមាំងស្រោចផ្សពង្សឲ្យក្តៅទៀតផង ។

តាមពិត សេចក្តីចេះដឹង អាចជួយយើងបាន ១៥ ភាគ លក្ខណៈ-
និស្ស័យសុភាព អាចជួយយើងបានដល់ទៅ ៨៥ ភាគ ។ ដូច្នេះ លោកអ្នក

ទើបគួរប្រើវេលា តាំងអំពីព្រឹកដល់ល្ងាច បណ្តុះតែនិស្ស័យនេះ ត្រូវធ្វើ
ឲ្យចាស់តែគេសរសើរថា "តាំងពីព្រឹកដល់ល្ងាច តាំងពីកើតដកបដល់
ស្លាប់ទៅជាខ្មោច, ការគង់ជីវិតនៅរបស់លោក អ្នកពេញទៅដោយ
និស្ស័យសុភាព តាំងកិរិយា តាំងវាចា តាំងចិត្តជានិច្ច" ។ សូម្បីក្នុង
ចំណោមរួមគ្នាក៏ត្រូវធ្វើឲ្យចាស់តែគេសរសើរថា "តាំងពីព្រឹកដល់ល្ងាច
តាំងពីកើតដល់ស្លាប់ទៅជាខ្មោច, ការគង់ជីវិតនៅនៃជាតិខ្មែរតាំងមួល
ពេញត្រៀបទៅដោយនិស្ស័យសុភាព តាំងកាយ តាំងវាចា តាំងចិត្ត" ។
សូមកុំភ្លេចថា "ការរីកពាយសើចហោរបស់មនុស្សឃើញសឃឹងក្នុងការបំបែក
បំបាក់គេនោះ ជាការថោកទាបក្រៃលែងជាងការស្រែកថ្ងូរបស់មនុស្ស
និស្ស័យសុភាពទៅទៀត" ។ "ឯម សុភាព មហាសុភាព
ឧមោត្រាយ ៥ សា្វសុ" នេះជាគាថា សម្រាប់ដបខ្លួនឲ្យក្លាយទៅ
ជាមនុស្សមានទិស្ស័យសុភាពពេញតាំងត្រៃទ្វារ អញ្ជើញសែករឿយៗ
ទៅ ។

ត្រូវសុភាព ពាបសាសុខ្ញ ឲ្យផុតទៅ
គ្រាន់តែកូនចៅ ដែលកើតមក យកតម្រាប់
ការសុភាព ជានីតិ ល្អចំណាប់
ក្នុងផ្លូវច្បាប់ គ្មានរឿងអ្វី ក្រៃលែងជាង ។

ធិសុយ្យស្មោះត្រង់

ស្មោះត្រង់ជាអគ្គមានខ្លឹមសារ

ស្មោះត្រង់ជាការជួយថែទាំ

ស្មោះត្រង់ជាបុណ្យគួរចាប់តាំ

ស្មោះត្រង់នេះនាំឲ្យផុតភ័យ ។

លោកអ្នកសប្បុរសទាំងឡាយ ! សេចក្តីស្មោះត្រង់ជាមគ្គជសិរីដ៏ផ្តល់ឲ្យនូវកេរ្តិ៍ឈ្មោះ ជាកំពូលនៃការដឿការស្តាប់ការទុកចិត្តរបស់មនុស្សជវៃ ជាគុណធម៌ទាងដើមនឹងទីបំផុតនៃសេចក្តីល្អទាំងឡាយ ជាមគ្គុទ្ទេសក៍ដ៏ប្រសើរដែលយើងគួរកេទុក ដើម្បីនាំផ្លូវយើងទៅកាន់សេចក្តីល្អជវៃ។ ទៀតតាមដែលត្រូវការ ។ អ្នកស្វែងរកសេចក្តីសុខនឹងកិត្តិយសគួរអប់រំសេចក្តីស្មោះត្រង់នេះឲ្យជានិស្សយរបស់ខ្លួន ។ អ្នកណាបានពាក់មកុដ គឺ ការស្មោះត្រង់នេះហើយ អ្នកនោះឈ្មោះថាមានថ្លៃដែលជាទីដឿស្តាប់ទុកចិត្តនៃមនុស្សជវៃ ប្រកាសកេរ្តិ៍ឈ្មោះរបស់ខ្លួនឲ្យគឹកកងទូទៅកងលោកមិនឈប់ ។ មានសុភាសិតដែលចេញមកពីព្រះឧស្ឋនៃព្រះសម្មាសម្ពុទ្ធថា **សច្ចំ វេ អមតា វាចា** "សេចក្តីស្មោះត្រង់ជារបស់មិនចេះស្លាប់" ។

សេចក្តីស្មោះត្រង់ ជាធម៌គួរនិយាយរឿយ។ គួរប្រដៅញយ។ គួរនាំគ្នាអប់រំឲ្យញឹកញាប់ កុំបណ្តែតបណ្តោយ ព្រោះមនុស្សវៀចវេរទៅ

មានកន្លែងលោកនៅឡើយ ។ មើលចុះកន្លែងមហាវិទ្យាល័យ ក្នុងសាលារៀន
ក្នុងគ្រឹះស្ថានតូចធំ សូម្បីតែមតែកន្លែងផ្ទះរបស់មនុស្សសូមទាន ក៏គង់តែ
ត្រូវសេចក្តីរៀបរៀងដឹកនាំឲ្យវង្វេងលេងកលមាយា លបបិទកពេងល្បែង
ដោយប្រើផ្លូវពីរដៃរឹតរៀចនឹងត្រង់លាយគ្នា ។ នៅមុខថ្ងាយបង្គុំ នៅ
ក្រោយឡក, មុខត្រង់ ចិត្តវៀច ។ កាលនៅមុខសាច់ធ្វើចិត្តជាខ្លា នៅ
មុខព្រះធ្វើចិត្តជាមារ មិនគួរវង្វេងស្រឡាញ់មុខក្រែឡមាសដូច្នេះសោះ ។
កាលដែលទិញក៏ប្រើលុយក្លែងក្លាយ កាលដែលលក់ក៏ឲ្យរបស់បន្ទុំ ជា
អាជីវកិច្ចរាល់ថ្ងៃ ។ កន្លែងនេះមិនមានអ្វីដែលគប្បីរៀបរាយមិនបាន
មិនមានអ្វីដែលអ្នកប្រាជ្ញមិនដឹង មិនមានពាក្យពុសណាមួយដែលមនុស្ស
ស្រវឹងមិននិយាយ ទឹងមិនមានផ្លូវត្រង់ណាមួយដែលជាទីបំផុតនៃមនុស្ស
មេកលមាយាទេ ។

នេះជាកិរិយារបស់មនុស្សវៀច ដែលកាលហុចដៃពីចំងាយមក
ឃើញដួងក្តែកថ្ងា សំដែងឲ្យស្គាល់ថា "ស្រឡាញ់" គួរឲ្យជឿជាក់ គួរ
ឲ្យអញ្ជើញពាក់ពាក់ឲ្យរួមទីអង្គុយជាមួយនឹងខ្លួនដែលជាមនុស្សកណ្តាល
ចូលមកនុបរូបតែដូចជាស្រឡាញ់ណាស់ គួរឲ្យក្តើតក្តើនចិត្ត មាត់សាក
សួរឿងរ៉ាវញយៗ ដោយសំដីដ៏ពីពេះ គួរឲ្យរែកយ តែតាមពិតទៅ
គឺលាក់ពិសអាក្រក់ទុកខាងក្នុង សំដែងកំសួលចេញមកសុទ្ធតែទឹកឃ្មុំ
ផ្អែមឆ្ងាញ់ ព្រោះជាមនុស្សជំនាញក្នុងកលមាយា គ្មានទិស្ស័យស្មោះ

គ្រង់ចំពោះនរណាពិតជ្រាកដមែនឡើយ មានតែនាំឲ្យចលាចលរឹតតែរកគ្នាកាលគ្រាយមក៉ាង ។

នេះឯងជាដំណើរប្រព្រឹត្តរបស់គេ ដែលជាការប្រព្រឹត្តិលុបជ្រុងវៀចវេរគ្រឡប់គ្រឡិនចេញគ្រាន់តែប៉ុណ្ណោះ ដូចយ៉ាងខ្ទីរបស់គេទៅ ធ្វើជាក្ងេចមិនយកមកសងគេ, ធ្វើរបស់គេឲ្យបែកធ្លាយឬខូចហើយ ធ្វើព្រងើយ, ទិញរបស់គេ ឃើញគេថែមលុយលើសមកហើយ ធ្វើជាមិនដឹង, ជិះរទេះរថយន្ត ឬ រថភ្លើង ឃើញអ្នកលក់មូលបត្រក្ងេចយកប៉ាថ្ម កំធ្វើព្រងើយ, អ្នកបង្គាប់បញ្ជាមេការ ឬនាយចៅហ្វាយមិននៅ ក៏មិនធ្វើការងារ បែរជាអង្គុយលេង ឬ ដេកលេង, ចូលចិត្តធ្វើការងារតែពេលដែលគេនៅចំពោះមុខ, កាលធ្វើការងារដែលយូរ មិនទាន់ដល់ពេល ក៏លបឈប់, ធ្វើការងារតែស្ទើរៗ កំពុងធ្វើក៏លបគេចវេះ, មាត់ប្រស៊ាយទៅ ១ បែប ចិត្តគិតបំណងទៅមួយបែប ពាំងសេចក្តីប្រព្រឹត្តិក៏ល្អៀងទៅមួយបែបទៀត ។

ការធ្វើដូច្នេះ មនុស្សវៀចយល់ឃើញថា ជាការមានមុខមានមាត់អតនឹកដល់សេចក្តីស្មោះត្រង់បន្តិចបន្តួចសោះ ។ កាលបើមនុស្សវៀចនៅតែស្រឡាញ់សេចក្តីវៀចវេរ ព្រោះយល់ឃើញដំណើរប្រព្រឹត្តបែបនោះថាជាការមានមុខមានមាត់ហើយ គប្បីជ្រាបថា ការមានមុខ ការលេចមុខរបស់មនុស្សវៀចនោះ គឺការឈានទៅកាន់រណ្តៅកប់ខ្លួន ។

អ្នកដែលត្រូវមន្ទិលដឹកនាំឲ្យក្លាយទៅជាមនុស្សវៀច តែងរងួនភ្លើតភ្លើនក្នុងកម្មរបស់មនុស្សវៀច មិនយល់ឃើញដល់ការធ្វើខ្លួនឲ្យជាទី

ខុសចិត្ត ជាទីជឿ ជាទីពប់អាន នៃមនុស្សដទៃជាសំខាន់ឡើយ ឃើញតែការវៀចវេរ ការឧច្ចរិត ការទុស្សន្យា ការមិនសង្ឃឹមណុល ការពោលកុហក ការប្រែហើនគោងកាច ទើងការលួងតែមាត្រាថាជារបស់សំខាន់ ទើងឃើញថាបើជាប្រយោជន៍ចំពោះខ្លួនហើយ ក៏គួរធ្វើ ឬ សូម្បីការឧបាកបំបាត់លាក់លួចយក បើអស់អំណាចច្បាប់ គ្មាននរណាអាចទើងធ្វើអ្វីខ្លួនបានហើយ ក៏ឃើញថាគួរយកដែរ នេះជាគំនិតអ្នកវៀចវេរ ។

សំពប់អ្នកស្មោះត្រង់វិញ ឃើញថា ការធ្វើឲ្យគេជឿទុកចិត្តពប់អាន ជាជីវិតដ៏ប្រសើរ ។ មនុស្សស្មោះត្រង់ តែងធ្វើត្រឹមត្រូវតាមធម៌រក្សាពាក្យសន្យា មិនពោលកុហកបោកប្រាស ឬ លួចលួនណា. តាំងនៅក្នុងសច្ចធម៌គ្រប់ត្រៃត្រា ទើងនិយាយអ្វី ក៏មានមនុស្សជឿមនុស្សស្តាប់ ទើងបរទាំខ្លីជ្រុកគេតាំងពាន់ ដោយមិនចាំបាច់មានសំបុត្រសន្យា ឬ សាក្សី សូម្បីអ្នកខ្មោះមិនមែនជាបងប្អូន ក៏អាចបានដាយ។ ព្រោះមនុស្សដទៃគេជឿជាក់ថា "យើងខ្លីទៅហើយ គាលរកបាន មុខជាសងវិញ" ។ ហេតុនេះ ក្នុងធម្មនីតិ ទើបលោកពោលថា "បើសេចក្តីជឿទើងសេចក្តីស្រឡាញ់គ្នានៅមាន សូម្បីប្រាក់តាំងរយមិនចាំបាច់ពប់ក៏មាន តែបើមិនមានសេចក្តីជឿទើងសេចក្តីស្រឡាញ់គ្នាវិញ សូម្បីប្រាក់ត្រឹមតែ ១ រៀល ក៏ត្រូវតែពប់មានពុំបាន" ។

ឧបាយសំរាប់បង្ក្រាបមនុស្សកោងនោះ បុរាណពោលថា ទើបបង្ក្រាប
ដោយការពោលប្រចុបប្រចែងក៏មិនបាន សូម្បីដោយការលើកតំកើង
ដោយការនុនលំទោន ដោយការយកចិត្តយកថ្នើម ដោយការធ្វើទោស
ទើដោយការបង្គាប់ ក៏មិនសម្រេចទាំងអស់ ។ ពិតមែន មនុស្ស
វៀចវេរ មានអ្នកប្រាជ្ញតត់ទោសទុកថា "មនុស្សវៀចវេរ ប្រតិបត្តិ
សេចក្តីស្មោះត្រង់ចានដោយលំបាក មនុស្សស្មោះត្រង់ទើបប្រតិបត្តិចាន
ដោយងាយ តែប្រតិបត្តិសេចក្តីវៀចវេរចានដោយកម្រ លុះតែអ្នក
វៀចវេរ ទើបប្រតិបត្តិចានដោយងាយ" ទើបចាត់មនុស្សវៀចវេរ ថាជា
មនុស្សអាក្រក់គ្រប់យ៉ាង ។

តែទោះបីដូច្នោះ ក៏គង់នៅមានឧបាយដែលសម្រាប់តែខ្លះចានដែរ
ដូចជាប្រើព្រះពជ្ឈញ្ញត្តិ ប្បាប់ទំលាប់ រៀបវិន័យបង្គាប់បញ្ជានឹង
ប្រវែណីជាគ្រឿងអប់រំ នឹងថ្នឹងសេចក្តីខុស - ត្រូវឲ្យគេដឹងថា ធ្វើយ៉ាង
ណាជាមនុស្សវៀចវេរ ធ្វើយ៉ាងណាជាមនុស្សខ្ជឹងត្រង់ មានពល
ភាហានកងត្រៀលនាយជម្រត ព្រមទាំងគ្រឿងសស្ត្រាវុធទុកសម្រាប់
ការពារនឹងបង្ក្រាប ឲ្យមនុស្សវៀចវេរត្រឡប់ចិត្តជាមនុស្សស្មោះត្រង់
នឹងរក្សាមនុស្សស្មោះត្រង់ឲ្យនៅជាសុខសាន្ត តាំងពិធីសត្យាធិដ្ឋានឲ្យ
បញ្ចេញវាចីសច្ចៈធ្វើសច្ចាប្រណិធានប្តេជ្ញាខ្លួន ទើងដាក់អាជ្ញា ឬ សន្យា
ល្មមដើម្បីឲ្យទៅជាមនុស្សស្មោះត្រង់ ។

(មានត)

រឿងសាមកុក

កណ្ឌទី ១៤

ឧកញ៉ាវិបុលរាជសេនា ដួ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

តាំងពីចូលដូនាំពលរេហ៍ចូលទៅក្នុងក្រុងរួកអៀងតាមព្រះរាជតម្រាស់ តរៀងទៅដល់អូនសុតចៅហ្វាយស្រុកលុំយុងលើកកងទ័ព ១០ ហ្មឺន ទៅវាយឡោពីចៅហ្វាយស្រុកឈីដែរ ។

ស៊ុនហ៊ុកឆ្លើយថា រដ្ឋការព្រះចៅជីវសង៏អង៏បានសោយរាជសម្បត្តិនោះ អាណាខេត្តកើតចលាចលខ្លាំង៏ណាស់ ព្រះចៅជីវសង៏អង៏ទ្រង់គ្រាស់ឲ្យហៅជនប៊ុនកុង៏ទៅដួយធ្វើរាជការជាល់ព្រះអង្គ បណ្តាខាហ្មឺនក្នុង៏ស្រុកក្រុង៏ ក៏នៅគ្រាមបង្គាប់ជនប៊ុនកុង៏ទាំង៏អស់ អំណើះតមកជនប៊ុនកុង៏បានសោយរាជសម្បត្តិដោយងាយ គ្រានេះព្រះចៅហៀនតេឲ្យហៅលោកចូលទៅដួយធ្វើរាជការ ខ្ញុំយល់ថាជាការប្រែ៏ណាស់

គួរលោកវាស់ចូលទៅតាមព្រះបង្គាប់ បើលោកបង្អង់ឲ្យយឺតយូរទៅ
ទៀត អាណាខេត្តខាងអស់ ណាដែលមានថ្លៃដែនដីតែខៃចូលទៅ
មុនលោកបាន ការពាជការខាងប៉ុន្មានក៏នឹងបានជាកម្មសិទ្ធិដល់គេនោះ
ឯខ្លួនលោកដែលមានឈ្មោះក៏នៅសោះទេ ហេតុនេះគួរលោកគ្រោងគិត
តាមគំនិតរបស់ខ្ញុំបានចូលទៅឲ្យឆាប់ ។

ចូតូបានស្តាប់ក៏យល់ឃើញត្រូវ ទើបចាត់ឲ្យទៅប្រុងប្រៀបរៀប
សេនាខាហាន ប្រមូលបាន ៣០ ម៉ឺនស្រេចហើយ លើកជាកងទ័ពទៅ
ដល់ពាក់កណ្តាលផ្លូវ ទទួលមានបំរើសេះ នាំសេចក្តីចូលទៅស្រុកក្រុង
ក្រាបបង្គំទូលព្រះចៅហៀនតេថា លីឈុយនឹងគុយគីលើកទ័ពទៅដិតដល់
ស្រុកក្រុងឡុកអៀងហើយ ដោយគិតបំណងប៉ងនឹងវាយទំលាយចាប់យក
ព្រះចៅហៀនតេធ្វើអន្តរាយ ។ ព្រះចៅហៀនតេទ្រង់ព្រះតំរិះថា ទីស្ថាន
នៅមិនទាន់បានរៀបគាក់តែនធ្វើបន្ទាយរាយចំរូង ជាកន្លែងតំបែងជាមាំមួន
នាហ្នឹងនឹងបណ្តាកស្តុកក្នុងក្រុងក៏មានតិចណាស់ ឯបំរើដែលនាំសំបុត្រ
ទៅហៅចូតូក៏មិនឃើញត្រឡប់មកវិញ បើដូច្នេះអស់អ្នកទាំងឡាយនឹង
យល់ឃើញដូចម្តេច ដ្បិតបើលីឈុយនឹងគុយគីលើកទ័ពមកជិតហើយ ។

អៀវហាន់នឹងហាន់សៀមយកសេចក្តីក្រាបបង្គំទូលថា ដែលលីឈុយ
គុយគីលើកទ័ពមកនោះសូមកុំឲ្យព្រះអង្គទ្រង់ព្រះវិតក្កឡើយ ទូលព្រះ
បង្គំជាខ្ញុំនឹងសូមអាសាចេញទៅច្បាំងវាំងក ជាទីស្នងព្រះតេជព្រះគុណ
ត្រាតែអស់ជីវិត ។ តាំងសិនធ្វើយតបថា កងស្រុកឡុកអៀងនេះ

នៅមិនទាន់រៀបចំតាំងទ័ពខ្ជាយជាមាំមួនសោះ ដែលអ្នកតាំង ២ នឹងក៏ប់
រងនានាលើកសេនាខាហាន ចេញទៅតតាំងច្បាំងនឹងលីឈុយគុយតី
នោះ យើងយល់ឃើញថា នឹងបរាជ័យចាញ់គេជាក្រុកជ យើងគិតនឹង
អញ្ជើញព្រះចៅហៀនតេស្តេចរត់ចេញពីទីនេះ ទៅនៅខាងអាណាខេត្ត
ខិសបូពិញ ទើបនឹងបានរួចអំពីភ័យ ។

ព្រះចៅហៀនតេទ្រង់យល់ឃើញដូច តាំងស៊ុនឌឹងនាហ្មឺនមុខមន្ត្រី
តាំងពួងក៏រៀបអញ្ជើញស្តេច ព្រមតាំងព្រះអគ្គមហេសីស្រីស្នំក្រមការ
ឡើងគង់ព្រះពរថាចេញចាកក្រុងឡុកអៀង យាងតាមផ្លូវទៅប្រហែល
បម្ងាយ ២០ សិន (៨០០ គ.ម.) ក៏ក្រឡេកឃើញកងទ័ពតាន់តាប់លើក
រន្ទាន់ចូលមកពីទិសបូពិ សួរគាហានហ៊ោកញ្ជ្រៀវគឹកកងរំពងតាំងដែន
ពស់ជា ។ ឯព្រះពជអាជ្ញាដែលតាន់ព្រះតម្រាស់ក៏ជិះសេះចូលមកមុន
ដល់ចំពោះមុខព្រះទីនាំងរថាហើយ យកសេចក្តីក្រាបបង្គំទូលថា ឥឡូវ
នេះបួនទ្រូលើកសេនាយោធាមកដល់កណ្តាលផ្លូវហើយ ត្រូវតិត្តិស័ព្ទថា
លីឈុយគុយតីលើកកងទ័ពមកនឹងធ្វើអន្តរាយដល់ព្រះអង្គ កងក្រុងឡុក-
អៀង, បួនទ្រូក៏ប្រើហែហួនុន ទៅធ្វើ តៀនអ៊ុយលើកគាហាន ៥ ម៉ឺនដែក
ចូលមក ដើម្បីនឹងបានជួយការពារការពារព្រះអង្គ ។ ព្រះចៅហៀនតេ
បានទ្រង់ព្រះសណ្តាប់ ក៏មានព្រះទ័យត្រេកអរពន់ប្រមាណ ។ ទទួល
ហែហួនុន ទៅធ្វើ នឹងតៀនអ៊ុយចូលមកក្រាបថ្វាយបង្គំកងទីនោះ ។

មានបំរើសេះចូលមកគ្រាបទូលទៀតថា ឃើញកងទ័ពលើកមកពីទិសបូព៌ា
ជាគ្រោះបណ្តាយដល់មកទៀតហើយ ។ ព្រះចៅហៀនតេត្រាស់
ប្រើហៅហួនទៅពិនិត្យមើលឲ្យច្បាស់ ។ ហៅហួនក៏បរសេះចេញទៅ
ជួបនឹងចោហង លីតៀន, ងាក់ជំនួសលើកទាហានមក ក៏នាំនាយទាហាន
ចាំង ៣ នាក់នោះចូលទៅគ្រាបបង្គំគាល់ ហើយទូលថា ចូរប្រើហៅ-
ហួន ទៅធ្វើ នឹងតៀនអ៊ុយលើកទ័ពមកមុននោះ ក្រែងមិនធ្វើការបាន
ជាប្រើទូលព្រះបង្គំជាខ្ញុំចាំង ៣ នាក់ ឲ្យលើកទាហានមកជួយថែមទៀត
ដើម្បីនឹងចាប់អាសត្រូវសម្លាប់ចេញឲ្យបាន ។ ព្រះចៅហៀនតេទ្រង់
ព្រះសណ្តាប់ ក៏ចាបព្រះរាជហ្វូទ័យណាស់ត្រាស់ថា ចូរនោះពេញជា
មនុស្សមានសតិប្បញ្ញាឆ្លៀវឆ្លាត ហើយត្រង់សុចរិតពិតល្អដល់យើង គួរ
នឹងដំកើងលើកឲ្យធ្វើជាសេនាបតីធំសម្រេចរាជការតទៅ ។

ខណៈនោះ មានបំរើសេះពីទិសបស្ចឹមនាំដំណឹងចូលមកគ្រាបបង្គំ
ទូលព្រះចៅហៀនតេទៀតថា ទ័ពលីឈុយគុយគីលើកចូលមកដល់ដែន
ស្រុកឡុកអៀងហើយ ឥឡូវនេះ គ្មានអ្នកឯណានឹងទប់ទល់សោះ ។
ព្រះចៅហៀនតេត្រាស់សួរហៅហួនថា ដែលលីឈុយគុយគីលើកទ័ព
មកដូច្នេះ អ្នកនឹងគិតប្រការម្តេច ។ ហៅហួនគ្រាបបង្គំទូលថា "សូមព្រះ
អង្គទ្រង់កុំព្រួយព្រះរាជហ្វូទ័យព័យនឹងទ័ពលីឈុយគុយគីឡើយ ទុកជា
ទូលព្រះបង្គំជាខ្ញុំហើយនឹងសេនាទាំងពួង ជាកងទ័ពមុខចូរ ទទួលយក

អាសាភៅជាន់សង្គត់ពួកអាចារកំណាចទាំងនោះ ឲ្យរៀបដូចផ្លែផែនដី" ថាហើយក៏គ្រាបថ្វាយបង្គំលាចេញវៃភៅចាត់ផ្លែផែនសេនាគាហាន រៃហ្ហុនជាកងស្មាំ ចោហាងជាកងឆ្វេងហើយលើកចេញភៅ លុះភៅដល់ប្រទល់កងទ័ព ក៏បរពលចូលប្រកាប់គ្នាពារទំលាយដោយកំលាំងអាវុធនឹងសេនាគាហាន ។ ពលលីឈុយគុយគីទាំងប៉ុន្មានក៏សឹងតែបបួសពិការស្ងាប់ត្រៀបត្រានឹងគណនាពុំពុំចុះ លីឈុយគុយគីទប់ពុំបាន ក៏នាំគាហានដែលសល់នោះស្ទុះរត់រួចភៅ ។ រៃហ្ហុនទឹងចោហាងក៏លើកកងទ័ពដេញសង្កៀភៅទៀត ឃើញថាលីឈុយគុយគីរត់ព្រាត់ព្រាយឆ្ងាយភៅហើយ ក៏លើកកងទ័ពត្រឡប់មកវិញ ហើយអញ្ជើញព្រះចៅហៀនតេ ស្តេចយាងចូលភៅក្នុងក្រុងឡុកអៀងជូចដើម រួចចាត់ចែកបំបែកកងទ័ពឲ្យទៅឃុំយកទីក្រុងជុំវិញ ។

លំដាប់នោះ ចូឆូលើកកងទ័ពធំមកដល់ ហើយចូលភៅលុតជង្គង់គ្រាបបង្គំគាល់ព្រះចៅហៀន តៈដោយគោរព ។ ព្រះចៅហៀនតេទតឃើញមុខចូឆូក៏ទ្រង់សោមនស្សស្មោះសរ មានព្រះពាក្យថ្លាវត្រាស់ថា អ្នកកុំគប្បីលុតជង្គង់គ្រាបបង្គំគាល់យើងដូច្នេះឡើយ ចូរអង្គុយឈរដោយប្រក្រតីចុះ ។ ចូឆូក៏ធ្វើតាមព្រះតម្រាស់ហើយទូលថា ដែលព្រះអង្គដប់លៀងទូលព្រះបង្គំជាខ្ញុំមកតាំងពីដើមដំរៃ ព្រះតេជព្រះគុណមិនមានទំបំផុតទូលព្រះបង្គំជាខ្ញុំ តាំងចិត្តគិតនឹងធ្វើពាក្យថ្វាយតួនព្រះតេជព្រះគុណ

នៅជាដរាបមិនមានក្តៅចសោះ គ្រានេះលើឈុយគុយតីមានសេចក្តីប្រទូស-
រាយដល់ព្រះអង្គនេះ សូមកុំឲ្យទ្រង់បរិតក្កៈឡើយ ពុកជារទូលព្រះបង្គំ
ជាខ្ញុំនឹងគ្រែរិះរកឧបាយសម្លាប់លើឈុយគុយតីបញ្ឈឲ្យបាន ។ ព្រះបៅ
ហៀនតេ ទ្រង់មានព្រះរាជហ្ឫទ័យបីតិប្រាមោជពន់ប្រមាណ ទើបតាំង
ឲ្យចូលទ្បើងទីជាសេនាបតីធំសំរេចរាជការ តាងព្រះគាណាព្រះនេត្រទូ
តាំងព្រះរាជអាណាខេត្តក្នុងត្រៃត្រប់ត្រសួង ។

ឯលើឈុយគុយតីដែលបែកទ័ពទៅនោះ កំតាំងតែហ្វឹកហាត់សេនា
ឥហានបានជាច្រើន លុះដឹងថាចូលមកដល់ហើយ ទើបប្រឹក្សាគ្នាថា ឥឡូវ
នេះឥហានចូលកំពុងខ្សោយកំឡាំងណាស់ ហេតុនេះគួរយើងប្រញាប
លើកកងទ័ពទៅខួបក់យកុំឲ្យដឹងខ្លួនក៏នឹងបែកៈដាយងាយ ។ ការសឹង
ឆ្លើយថា លោកគិតដូច្នោះមិនស្រួលទេ ព្រោះចូលនោះមានសេនាឯក
នឹងឥហានច្រើនណាស់ លើសនឹងគណនា ឯសេនាឥហានខាងយើង
ស្តើងស្តួចពេក បើពុកជានឹងលើកទៅច្រឹងក៏យកបំបែកដូចម្តេចក៏ពុំបាន
ឧបមាដូចសត្វតិរច្ឆានតូចៗ ទៅខូចប្រយុទ្ធនឹងខ្លា គំនិតខ្ញុំយល់ថាត្រូវ
ឲ្យលោកចាត់បំរើចូលទៅសុំទោសចូលវិញស្រួលជាង ហើយសុំផ្ញើរប
ពន្ធគ្រកោន ឲ្យបានចូលមានមេត្តាដល់លោកទាំង ២ ។ លើឈុយ
គុយតីឮបានស្តាប់ពាក្យការសឹងនិយាយដូច្នោះ ក៏ពុះពារក្រដូរខឹងនឹងការ-
សឹងណាស់យកដៃទះតប់តុហើយថា "យើងកំពុងគិតធ្វើសង្គ្រាមនឹង

ចូរឆ្លូជាមាំមួន ហេតុម្តេចខ្ញុំបានហ៊ានមកនិយាយបន្ទាបបន្ទោកយើងដូច្នេះ ដែលខ្ញុំនិយាយយ៉ាងនេះ ឱងចង់ឲ្យសេនាគាហានរបស់យើងរួញរាឬ?" ថាហើយក៏កន្ត្រាក់ក្រហ៊ីមឡើងកាន់ គិតនឹងសុះទៅកាប់សម្លាប់ការសឿងកុងខណៈនោះ ។ បណ្តាគាហានក៏សុះទៅពាំងប្រឹងជួយសុំទោសបាន ។ ការសឿងទោមនស្សគួចចិត្តពេកណាស់ លុះវេលាយប់ក៏ឡើងសេះដើរតេះទៅនៅស្រុកខេសរបស់ខ្លួន ។ លុះព្រឹកឡើងលើឈុយគុយគីផ្តុំពលយោធាជាកម្លាំងខ្លាំង បង្គាប់ប្រើឲ្យលើសឿមនឹងលើប៉ែកជានាយទ័ពស្រួចលើកទៅច្បាំងនឹងចូរឆ្លូ ។

ខណៈនោះ ចូរឆ្លូចាត់ប្រើ ទៅឆ្លូ តឿនអ៊ុយ ចោយិន ឲ្យលើកគាហានសេះ ៣០០ ចេញទៅតយុទ្ធនឹងកងទ័ពលើឈុយគុយគី តាំងតែចាក់កាប់សម្លាប់កងទ័ពនោះស្ងាប់រៃអនាសជាច្រើន ។ ឯលើសឿមនឹងលើប៉ែកជាសេនាក៏ចេញមកតនឹងទៅឆ្លូមិនបានបន្តិច ១ ភ្លែត ទៅឆ្លូ ក៏ចាក់នឹងលំពែងត្រូវលើសឿមធ្លាក់ពីលើសេះស្ងាប់ ។ ឯលើប៉ែកនោះគ្រាន់តែក្រឡេកឃើញទៅឆ្លូក្អាមក៏តក់ស្លុតក្អាត់ធ្លាក់ពីលើសេះខ្លោក ទៅឆ្លូ សុះទៅចាក់នឹងខ្លួនស្ងាប់ទៅទៀតហើយកាត់យកក្បាលលើសឿមនឹងលើប៉ែកនាំទៅឲ្យចូរឆ្លូ។ មានសេចក្តីត្រេកអរណាស់ យកដៃទះអង្គែលខ្លួនទៅឆ្លូហើយសរសើរថា មានថ្លើដៃខ្លាំងពូកែសមគួរជាសេនាឯក ។

ចូរឆ្លក់ប្រើហែហូរខ្លួនជាមេកងទ័ពស្រួច ចោយនជាមេកងបែកស្តាំ ខ្លួនចូរឆ្លងជាមេកងទ័ពហ្លួង លើកជាស្ងាចក្អែកដែកចូលទៅច្បាំងនឹងកងទ័ពលីឈុយគុយតី សម្ងាប់រេហ៍ពលលីឈុយគុយតីស្ងាប់ច្រើនណាស់ លីឈុយគុយតីក៏បែកទ័ពរត់ទៅ ចូរឆ្លងតាមក្រោយដេញតាមទៅទៀត រើសបានគ្រឿងសស្ត្រាវុធជាច្រើនណាស់ នៅតែលីឈុយទឹងគុយតីទាំង ២ នាក់ នាំគ្នារត់ទៅជ្រកពួនទៅក្នុងកៀនកុំ ១ ចូរឆ្លក់លើកទ័ពថយត្រឡប់មកវិញ ។

ឯអៀវហង៉ដឹងថា ចូរឆ្លាយទំលាយទ័ពលីឈុយគុយតីបែកហើយក៏ប្រឹក្សានឹងហាន់សៀមថា ចូរឆ្លើសង្គ្រាមគ្រានេះធំពន្លឹកពេកណាស់ យូរទៅពួកការទាំងអស់ក្នុងស្រុកក្រុងនឹងនៅក្នុងកន្ទាប់ដៃចូរឆ្លតែម្តង យើងទាំង ២ ក៏នឹងនៅគ្រាមអំណាចចូរឆ្លួ បើដូច្នេះយើងត្រូវតែគិតគលល្បាយលើកស្តេចបក្សពួករបស់យើងទាំងឡាយ ទៅចាប់លីឈុយគុយតីសម្ងាប់ចោល ហើយរត់យកខ្លួនទៅជ្រកពួនឯស្រុកតែលៀងវិញ ។ ហាន់សៀមឃើញត្រូវផង ទើបនាំគ្នាចូលទៅគ្រាបបង្គំគាល់ព្រះចៅហៀនតេទូលថា ដែលចូរឆ្លលើកទ័ពទៅសម្ងាប់រេហ៍ពលលីឈុយគុយតីបែកខ្ចាត់ខ្ចាយទៅហើយនោះ ទូលព្រះបង្គំជាខ្ញុំសូមចេញយកអាសាលើកគ្នាតាមទៅទៀត បើជួបប្រទះលីឈុយគុយតី នៅទីណានឹងចាប់ខ្លួនវាសម្ងាប់ចេញឲ្យបាន ។ ព្រះចៅហៀនតេក៏ទ្រង់យល់ព្រម អៀវហង៉នឹងហាន់សៀម ក៏គ្រាបបង្គំលាម្ចាស់មកវៀបប្រមូលស្មុគស្មាញបក្សពួក លើកចេញពីទីក្រុងឡុកអៀងទៅ ។

(មានត)

រឿងអាត់ស្ប៊ែនរឿងម្ភៃថ្ងៃ

លោកសាង - សារ៉ាត លេខាធិការ ក្រសួងបរិញ្ញាវុត្ត

ប្រែពីភាសាបាលីមកជាខ្មែរ

(តមក)

រឿងទី ៤

នៅក្នុងក្រុង កាញ្ចនបុរៈ (Kanchanpur ប្រែថាក្រុងមាស) មានអ្នកជំនួញម្នាក់ឈ្មោះ សាគរទត្ត (Sâgardatt ប្រែថា កើតដោយសារសមុទ្រ) ។ អ្នកជំនួញនេះ បានរៀបការកូនប្រុសឈ្មោះ សិរីទត្ត (Ciridatt ប្រែថា កើតមកអំពីទ្រព្យ) ជាមួយនឹងនាងជយសិរី (Jayacri) បុត្រីរបស់អ្នកជំនួញម្នាក់ទៀតឈ្មោះសោមទត្ត (Sômdatt) ដែលស្ថិតនៅ ក្នុងទីក្រុងមួយទៀតជិតក្រុងជយសិរីបុរៈ (Jayacripur) ។ ប៉ុន្តែគ្រាន់តែការហើយនាងជយសិរី នៅជាមួយនឹងឪពុកម្តាយរបស់នាង, ចំណែកប្តីរបស់នាង បានទៅស្រុកមួយទៀត ដើម្បីធ្វើជំនួញ ។ ជនទាំង ២ ឥតបានរួមជំណេកគ្នាទេ ។

ចំនួន ១២ ឆ្នាំកន្លងទៅ បុរសជួញបានចំណេញចំណូលច្រើន ។ ឯនាងជយសិរីជាកវិយោ ដែលគាត់បានរៀបការពេញច្បាប់ ថ្ងៃមួយនាងនិយាយទៅកាន់ស្រីជំនិតរបស់នាងថា "ទុបង! យូរចរិយារបស់ប្អូនកន្លងមក ឯរូបប្អូនមិនទាន់ស្គាល់តម្រែកណាមួយរបស់លោកិយសោះឡើយ" ។

ស្រីសហជីវិនរបស់នាង ឆ្លើយវិញថា "បូរអ្នកនាងកាន់ចិត្តអត់ទ្រាំសិនទៅ បើទៅតាលោកដួយ គង់តែប្តីរបស់អ្នកនាងត្រឡប់មកនុបក្រសោបអ្នកនាងវិញទេ" ។

ប៉ុន្តែនាងទាំងបានឡើងទៅលើផ្ទះ ហើយៈចាលត្រាប់ក្អែកតាមបង្ហិចស្រាប់តែឆ្ងល់ដោយបានឃើញបុរសម្នាក់ដើរចូលមក ។ កាលបុរសនោះមកដល់ជិតនាងក៏ងើបក្បាល ។ ក្អែកជនទាំងពីរខ្វែងគ្នា ។ ជនទាំងពីរចាប់ចិត្តស្នេហានឹងគ្នាទៅវិញទៅមក ។ នាងបានបង្គាប់ឲ្យស្រីបំរើទៅនាំបុរសនោះចូលមក ។ ស្រីបំរើក៏ទៅជិតបុរសហើយនិយាយថា "កូនស្រីរបស់លោកសោមទត្ត ឲ្យខ្ញុំមកអញ្ជើញលោកទៅ ដ្បិតនាងចង់ចួបនឹងលោកតែម្នាក់ឯង សូមលោកអញ្ជើញទៅទីកន្លែងរបស់ខ្ញុំ" ដូច្នេះរួច នាងបង្ហាញកន្លែងផ្ទះរបស់នាង ។ បុរសឆ្លើយទៅវិញថា ខ្ញុំនឹងទៅក្នុងពេលយប់នោះ ។ កាលណានាងស្ងួយកវឿង (ការគំណាត់ពេល) នេះទៅច្បាប់នាងជយសិរីហើយ នាងជយសិរីនិយាយថា "ត្រឡប់ទៅផ្ទះបងឯងវិញចុះ កាលណាគេមក ចូរបងច្បាប់ខ្ញុំឲ្យដឹងមុន រួចខ្ញុំនឹងចេញពីផ្ទះទៅដោយឥតញញើតឡើយ" ។

លុះបានឮពាក្យអស់នោះហើយ នាងស្មគ្រ័ទៅផ្ទះរបស់នាងវិញ ហើយអង្គុយនៅលើមាត់ទ្វារ រង់ចាំមើលផ្លូវ ។ ក្នុងពេលនោះ បុរសមកដល់ ។ នាងស្មំនោះ លុះឲ្យបុរសអង្គុយនៅមាត់ទ្វារហើយ និយាយថា "បូរ

លោកអង្គុយនៅទីនេះចុះ ខ្ញុំនឹងទៅជំរាបនាងជយសិរី" ដូច្នេះហើយគេ
ទៅប្រាប់នាងថា "មិត្តរបស់អ្នកនាងមកដល់ហើយ" ។

នាងជយសិរីនិយាយថា: "ចាំបន្តិចទៅ, កាលណាជនក្នុងផ្ទះដេក
លក់អស់ ទើបខ្ញុំទៅ" ។ មួយសន្ទុះក្រោយមក នាងទៅដល់ ។ ជន
ទាំងពីរក៏បានជួបគ្នាក្នុងផ្ទះនោះ ដោយរីករាយ ។

ម៉ោងបួនមុនភ្លឺ នាងក្រោកឡើងរួចត្រឡប់ទៅផ្ទះរបស់នាងវិញ ទៅ
ទំរេតយ៉ាងស្ងួល ហើយដេកលក់ទៅ ។ ដល់ព្រលឹមឡើង បុរស
ត្រឡប់ទៅផ្ទះរបស់ខ្លួនវិញដែរ ។

ច្រើនថ្ងៃក្នុងឆ្នាំមក ជនទាំងពីរនេះតែងប្រព្រឹត្តយ៉ាងនេះឯង ។
ក្រោយមក ប្តីរបស់នាងត្រឡប់មកពីប្រទេសដទៃ ហើយចូលមកក្នុងផ្ទះ
ដោយក្លែករបស់ខ្លួនវិញ ។ កាលណាមានឃើញ នាងគិតក្នុងចិត្ត រួច
និយាយទៅកាន់នាងស្មំថា: "ខ្ញុំចង្អៀតចិត្តណាស់ តើឲ្យខ្ញុំនិយាយយ៉ាង
ណា? តើឲ្យខ្ញុំទៅណា? ខ្ញុំលែងដេក លែងផឹក លែងស៊ី អស់ហើយ
ជាតុក្តៅនឹងជាតុត្រជាក់ គ្មានផលអ្វីមកលើខ្ញុំសោះ" ។ គឺនាងនិយាយ
អំពីទុក្ខតានតឹងចិត្តប្រាប់នាងស្មំរបស់នាង ។

ថ្ងៃក្នុងទៅទាំងល្ងាចអាក្រក់, ប៉ុន្តែដល់ពេលយប់ កាលណា
សិរីខេត្ត បរិភោគអាហារួច ម្តាយក្លែករបស់គាត់ ដែលបានឲ្យគេរៀប
ចំគ្រែមួយទៅក្នុងគ្រឹស្ថានមួយដាច់ពីគេនោះ បានឲ្យសិរីខេត្តទៅសម្រាក

កាយ រួចបង្គាប់កូនស្រីឲ្យទៅកម្ចាត់ផង ។ ប៉ុន្តែនាងចង់ចិញ្ចើមទៅរកម្ចាយ
ឥតកំរើក ។ ម្ចាយរបស់នាងក៏កំហែងហើយបង្គាប់នាងម្តងទៀត ជា
គំរប់ពីរដងឲ្យទៅជិតប្តីនាង ។ ដោយពុំអាចរើនទទឹង នាងក៏ទទួលបង្គាប់
ហើយទៅដេកលើគ្រែដោយងាកក្បាលចេញ ។ នាងមានទុក្ខព្រួយកាន់
តែខ្លាំងឡើង។ ក្នុងពេលដែលបុរសថ្នាក់ថ្នមនាង ។ កាលណាបុរស
បង្ហាញអាវាំងឡាយទឹងគ្រឿងមាសពេជ្រគ្រប់មុខ ដែលខ្លួនបានយក
ពីគ្រប់ភូមិស្រុកមកនោះ ហើយកាលណាបុរសឲ្យប្រដាប់តាំងអស់ ទៅ
នាងពាក់នោះ នាងរើរឹតតែទទឹងឡើង ចង់ចិញ្ចើមបែរខ្នងដាក់ប្តី ។ បុរស
ក៏អស់សង្ឃឹមមិនដឹងធ្វើយ៉ាងណាឲ្យនាងសប្បាយចិត្ត ហើយដោយអស់
កំលាំងផង ក៏ដេកលក់ទៅ ។ ចំណែកខាងនាងវិញ ដោយសារគំនិត
ដែលគិតដល់សហាយធ្វើឲ្យនាងដេកពុំលក់ឡើយ ។

កាលណានាងឃើញថា សំរែតដេកលក់ស្កប់ស្កល់ហើយ, នាង
ក៏ក្រោកឡើងយ៉ាងថ្នម ។ ដោយទុកឲ្យបុរសដេកលក់ ដើរតម្រង់ឥត
ញញើតទាំងកណ្តាលភក្តីជ្រៅ, ទៅកាន់ទីផ្ទះមិត្តរបស់នាង ។ ចោរមួយ
លុះឃើញនាងទៅតាមផ្លូវដូច្នោះ ទឹកឆ្អល់ក្នុងចិត្តថា តើស្ត្រីដែលមាន
ពាក់គ្រឿងមាសពេជ្រនេះ ទៅណាតែឯងកណ្តាលយប់ដូច្នេះ? ។
ឯនាងក៏ដើរទៅដល់ផ្ទះមិត្តរបស់នាងនោះ ដោយលំបាកខ្លះស្រួលខ្លះតាម
ធម្មតា ។ ប៉ុន្តែប្រុសជាសហាយរបស់នាងដួលស្លាប់នៅលើដីដោយពស់

ចឹក ។ នាងនឹកស្មានថាដេកលក់, នាងហេតុតែមានទុក្ខព្រួយ ព្រោះ
ឃ្លាតអំពីសហាយនេះ ក៏ឃានឧបវូបបុរសយ៉ាងស្និទ្ធពេញដៃ ហើយ
អង្អែលបុរសនោះថែមទៀត ។ ក្នុងពេលនោះ ចោរពិនិត្យមើលរឿង
នេះពីចម្ងាយ ។ មានបិសាចវិលមួយ អង្គុយទៅលើដើមដៃ ក៏មើល
រឿងនេះដែរ ។ ស្រាប់តែបិសាចនេះ មានគំនិតចង់ចូលក្នុងរូបភ្ញោច
សហាយរបស់នាងនេះ ដើម្បីត្រែបតម្រែកស្នេហាអំពីនាង ។ លុះ
គិតដូច្នោះ ក៏ចូលទៅក្នុងរូបភ្ញោចមួយរំពេច ហើយធ្វើអាកប្បកិរិយា
ស្នេហាជាមួយនាង រួចបានទាំច្រមុះនាងនឹងធ្មេញ ហើយទ្បើងទៅលើ
ព្រីក្បារបស់អាត្មាវិញទៅ ។ ចោរមើលឃើញអស់ ។ ឯស្ត្រីអភ័ព្វ
ឈាមស្រាក់ត្រឡប់ទៅជិតនាងស្ទុះ ហើយនិយាយរឿងច្បាប់ ។
ស្រីសហជីវនៃរបស់នាងនិយាយថា: "ចូរអ្នកនាងត្រឡប់យ៉ាងឆាប់ទៅ
ជិតសិទ្ធិជាប្តីរបស់អ្នកនាងវិញ ឲ្យបានមុនគាត់ភ្ញាក់ពីដេក, រួចអ្នក
នាង ស្រែកយំទាំធ្មេញ ហើយបើអ្នកណាសួរ ឆ្លើយទៅវិញភ្លាមថា ប្តី
របស់នាងទាំច្រមុះអ្នកនាង" ។

នាងក៏ទៅវិញ តាមពាក្យមិត្តរបស់នាងរួចតាំងយំនឹងទាំធ្មេញ ។
ដោយសូរសំរែកនេះ ក្រុមញាតិទាំងអស់ក៏មកជល់ បានភ្ញាក់ត្រង់គ្នា
កាលឃើញនាងអង្គុយដាច់ច្រមុះបាត់ដូច្នោះ ក៏ខឹងទាំងអស់គ្នានិយាយ
ទ្បើងថា "អាចង្រៃ! អាចិត្តប្រែត! អាឯងមិនខ្មាសគេទេឬ? គ្មានគ្មាន
ទោសហេតុអ្វីសោះ ហេតុដូចម្តេចបានជាអាឯង ទាំច្រមុះវា? " ។

សិរីទត្ត ដោយឃើញរឿងរ៉ាំរ៉ៃខ្លែកនេះទើបគិតយូរបន្តិចទៅ និក
ម្នាក់ឯងថា: "គេមិនត្រូវទុកចិត្តមនុស្សខ្លួរអាក្រក់, សត្វពស់ខ្មៅ, មនុស្ស
ដែលមានកាន់អាវុធ ឬសត្រូវណាមួយទេ, រួចគេត្រូវខ្វាចអំពើរបស់ស្ត្រី,
តើត្រង់ណាដែលកវីបណ្ឌិតមិនអាចប្រៀងបាន, តើត្រង់ណាដែលអ្នក
ប្រាជ្ញមើលមិនឃើញ, តើមានរបស់អ្វីដែលមនុស្សស្រែងពុំអាចនិយាយ
បាន, ហើយតើអ្វីខ្លះ ដែលមនុស្សស្រីពុំអាចធ្វើបាន. ចំណង់ដល់ទៅ
ទេវតាម៉ែចគង់មិនស្គាល់កំហុសរបស់សត្វសេះ, ភង់ភៅរបស់ពពក, កិច្ច
កលរបស់ស្រី នឹងវាស្អាណរបស់មនុស្សប្រុស ចុះទម្រាំមនុស្សលោក
តើនឹងអាចអះអាងថាស្គាល់ម្តេចកើត . . . " ។

ក្នុងសេលនោះ ឥតុកវបស់នាងបានទៅប្តឹងក្សាត់ជាវគង្គវែល។
មកដល់ក្រាម ចាប់សិរីទត្តចងហើយនាំខ្លួនទៅ ។ លោកមេគង្គវែល
ទៅទូលស្តេច ។ ស្តេចទ្រង់បានហៅសិរីទត្តមកហើយ មានព្រះឱង្ការ
សួរដំណើរដើមទង ។ សិរីទត្តឆ្លើយថា: " ទូលព្រះបង្គំមិនដឹងការណ៍
អ្វីសោះ" ។ ស្តេចទ្រង់មានព្រះបន្ទូលហៅកូនស្រីរបស់នាយដំនួញមក
ទ្រង់បានសាកសួរ ។ នាងឆ្លើយទូលតបថា "សូមព្រះករុណាជំគល់
លើត្បូងទ្រង់ជ្រាប មិនចាំព្រះអង្គសាកសួរទូលព្រះបង្គំទេ ព្រោះព្រះ
អង្គទតឃើញជាក់ស្តែងនឹងព្រះនេត្រស្រាប់" ។ ស្តេចក៏ទ្រង់ឆាកទៅ
រកសិរីទត្ត ហើយមានព្រះរាជឱង្ការថា "ឯងត្រូវមានទោស" ។

សិរីវត្តទូលតបថា: "សូមព្រះអង្គធ្វើតាមដែលទ្រង់យល់ឃើញថាត្រូវគន្លងយុត្តិធម៌ចុះ" ។ ព្រះរាជាទ្រង់បង្គាប់ថា: "ចូរនាំខ្លួនសិរីវត្តនេះទៅ ហើយយកទៅធ្វើគោសចុះ" ។

ជនទាំងឡាយលុះបានទទួលបង្គាប់ហើយ ក៏នាំសិរីវត្តទៅដើម្បីយកទៅធ្វើគោស ប៉ុន្តែចោរដែលជាសាក្សីនៃរឿងអស់នេះបានចូលមកដល់ ។ កាលណា ចោរនេះ ឃើញថាគេមុខជាធ្វើគោសបុរសប្រាកដហើយក៏សុំខ្លួនវិលយុត្តិធម៌ ។ ស្តេចទ្រង់ឲ្យហៅចោរមក ហើយទ្រង់សាកសួរចោរនេះ ។ ចោរឆ្លើយថា: "សូមទ្រង់ដំកល់លើត្បូងផ្ទាប! ទូលព្រះបង្គំជាចោរ ឯបុរសនេះគ្មានទោសអ្វីទេ រូបឈាមរបស់គាត់ដែលត្រូវហូរនោះមិនសមសោះ ព្រះអង្គគ្មានគាត់សេចក្តីតាមយុត្តិធម៌សោះ" ។ ព្រះរាជាទ្រង់ឲ្យហៅសិរីវត្តមក ហើយសួរចោរថា: "ចូរឯងនិយាយតាមសម្បជញ្ញៈរបស់ឯង រួចចូរឯងប្រាប់ការពិតមកយើងអំពីរឿងនេះ" ។ ចោរក៏និទានរឿងហូរហែគ្មានបាត់កន្លែងណាឡើយ ។ ឯស្តេចក៏ទ្រង់ឲ្យទាសាទៅមើលការណ៍ ទាសាក៏យកច្បុះដែលបានទាញចេញអំពីមាត់ខ្មោចមក ។ លុះទ្រង់ទតឃើញដូច្នោះ ស្តេចទើបយល់ថាសិរីវត្តគ្មានទោសហេតុអ្វីទេ ហើយចោរនេះនិយាយការពិតប្រាកដ ។ ចោរទូលព្រះមហាក្សត្រថា: "សូមទ្រង់ដំកល់លើត្បូងផ្ទាបការណីយកិច្ចសម្រាប់ស្តេចគ្រងផែនដីទាំងអស់ គឺត្រូវស្រឡាញ់អំពើល្អ ហើយធ្វើទោសមនុស្សកំណាចៗ"

លុះនិយាយដូច្នោះហើយ សេកដូរ៉ាមាន (Churaman) ក៏ឈប់ដើម្បីនិយាយការទៅព្រះមហាក្សត្រិយ៍ថា: "មហារាជ! នោះហើយគឺរឿងអាក្រក់ ដែលគេប្រទះឃើញក្នុងមនុស្សស្រី" រួចសេកនិយាយតទៅទៀតថា: "ស្តេចនោះក៏ទ្រង់បង្គាប់ឲ្យគេលាងចម្ការស្រីនោះ ដោយពណ៌ខ្មៅ រួចបង្គាប់ឲ្យគេកោរសក់នាងនោះទៀត លុះឲ្យនាងនោះដេកលើសត្វលាមួយហើយ ស្តេចទ្រង់ឲ្យបណ្តើរអោកាសតាមទីក្រុង រួចឲ្យនាងនោះទៅ។ ។ កាលណាទ្រង់ប្រទានម្ហូបដល់សិរីទត្ត ទ្រង់ចារហើយទើបទ្រង់ឲ្យជនទាំងពីរនេះថយខ្លួនទៅ" ។

លុះដល់និយាយរឿងនេះចប់ អាវក្សនិយាយថា: "បពិត្រព្រះមហារាជ! តើជនទាំងពីរនេះ ជនណាខុសជាងគេ ។ ព្រះបាទពិភវនត្រាស់ថា "គឺស្រីជាកិរិយាទោះឯង" ។ អាវក្សសួរថា: ហេតុម្តេចក៏យ៉ាងដូច្នោះ? ។ ព្រះអង្គទ្រង់មានបន្ទូលថា ទោះបីមនុស្សប្រុសអន់ថយយ៉ាងណាក៏ដោយ មនុស្សប្រុសនោះក៏គង់នៅមានសញ្ញាល្អនឹងអាក្រក់ដែរ តែឯស្រីវិញគ្មានទេ ។ ហេតុដូច្នេះ គឺស្រីហើយដែលខុសជាងគេ ។

លុះឮពាក្យអស់នេះ អាវក្សក៏ដើរចេញទៅ រួចត្រឡប់ទៅឮរខ្លួននៅលើដើមឈើ ។ ឯស្តេចវិញក៏ទ្រង់យាងចេញទៅដែរ ស្តេចយាងទៅរកអាវក្សនោះ ចង់អាវក្សជូបមុន លើលើស្មាព្រះអង្គ ហើយយាងទៅមុខទៀត ។

(មានត)

រឿងស្នេហាជាតិ

៤ ឈុត

លោក គង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

រឿងស្នេហាជាតិនេះ រង់ស្នេនកូនសិស្សសាលាគរុវិជ្ជា ភ្នំពេញ ដែលមានឈ្មោះ គង់-លឹម ជាមេបង្អាត់ ចាននលេងលើកដំបូង នៅពេលស្នេនចប្បារអំពៅ ក្នុងពត្រីនៃថ្ងៃអាទិត្យទី ៤ កុម្ភៈ ឆ្នាំ ១៩៥១

ម៉ារ៉ា	=	គង់-លឹម
មិត្តណា	=	អឿ-គឹមសាន
ភាណារិទ្ធ	=	បុយ-ហេង
ភាណានរា	=	ចាំង-ម៉ែងលី
ភាណី	=	ស្វាយ-ថន
មិត្តភាព	=	ម៉ាំង ម៉ារ៉ូណាល
ធិលនារី	=	ឆួន ស៊ីអិន
សុខា	=	តែម-សុខុម
វិណ្ណ័តារា	=	ផូ-ភ័
វិណ្ណ័នារី	=	អ៊ិន-សម្បត្តិ

វត្តល្អែនដដែលនេះ បានលេងលើកទី ២ ពីរលើកទៀតនៅមន្ទីរ
មហោស្រព ភ្នំពេញ ក្នុងថ្ងៃទី ៨ ទឹងទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៥១ ។

ក្ខ

ម៉ាក់ = គ្រូបង្រៀន

មិត្តាណា = ខេមរនិស្សិត កូនប្រុសលោកម៉ាក់

ភាណារិទ្ធិ = កូនសិស្សនៅវិទ្យាល័យ -

ភាណាធរ = អនុសេនីយ៍ទោ -

ភាណី = កូនសិស្ស្រគ្រួងសុខាកំបាល

មិត្តភាព = កូនសិស្សនៅសាលាសិប្បិយការ

ដែលនារី = កូនសិស្សនៅអនុវិទ្យាល័យនារី

សុខា = ស្រីមេម៉ាយមានសម្បត្តិ

វណ្ណ៍តារា = កូនស្រីអ្នកសុខា

វណ្ណ៍នារី = កូនស្រីអ្នកសុខា ប្អូនឆ៍វណ្ណ៍តារា

ភាណវិទ្ធិ - មិត្តភាព - ផលនារី

ភាណវិទ្ធិ

ឱកទៅតូចចិត្តពន់ពេកណាស់ ខ្ញុំសអើយសែនខ្ញុំសពន់ប្រមាណ
កាលដែលគេឈ្នះចិត្តសាមាន្យ ក្អាហានស្រែកហ៊ោសប្បាយចិត្ត ! ។

មិត្តភាព

សប្បាយមែន ! កូនចិត្តរីករាយ ស្ទាត់ចាត់ចាល់ជាយតែឈ្នះពិត
ស្រែកហ៊ោឥតក្រែងតាមគំនិត នរណាចិត្តច្រើនឯងណាសសោ ! ។

ភាណវិទ្ធិ

ហ៊ោបញ្ជឹចិត្ត ! សឹងធ្លាក់ថ្ងៃម

មិត្តភាព

ហ៊ោឲ្យសម្បើមតាមប្រាថ្នា ថ្ងៃមបងធ្លាក់ទៅកន្លែងណា
ខ្ញុំនឹងយាត្រាទៅតើសជូន ! ។

ភាណវិទ្ធិ

កុំបាច់និយាយផ្ញើឲ្យអញ តែក្អាញ៉ូកូនចិត្តឥតស្គាល់ប្អូន !

មិត្តភាព

បើស្ងាប់ខ្ញុំមួយមិនសាបសូន្យ បងប្អូនឯទៀតនឹងកើតខ្វល់ ! ។

បើបងដាល់ខ្ញុំ ចាប់ដៃស្អាត់ បើបងភាត់ ខ្ញុំធាក់វិញឲ្យឆ្ងល់
ឈ្មោះបងប្អូនឯងត្រែវល្បែងចាល់ ដឹងដល់លោកប៉ាយខ្លួចខ្លី ។

ភាណារិទ្ធិ

នៅស្ងៀម! នៅស្ងៀម! អាចម្កួត! អាងអួតតែកាប់ចាក់ដល់ទី
អាឯងគ្មានទេជមិសាមគ្គី ចាន់តែដេកស៊ីហើយឈ្លោះគ្នា ។

មិត្តភាព

នរណា? រូបបង ឬមួយខ្ញុំ សូមច្បាប់ឲ្យចំឲ្យធាប់ក៏
កំពុងចិត្តខ្ញុំនៅហានក្លា រូបនរណាមួយដែលពុំគួរ? ។

ភាណារិទ្ធិ

ឯងនៅឆ្ងល់ខ្មែតពីរឿងហ្នឹង,

មិត្តភាព

ត្រែតែមិនដឹងចាន់ជាសួរ

ភាណារិទ្ធិ

គឺជារូបឯង ធ្វើយដោយគួរ សំនួរយ៉ាងនេះ គួរឲ្យសើច ។

មិត្តភាព

សើចទៅ សើចទៅ កុំថាបង ឲ្យអស់ចំណង់ អាសំណើច
បើរូបណាខុស អញមិនសើច វាយស្តីបញ្ចើច អញគ្មានគុំ ។

ជលនារី - ភាណវិទ្ធិ - មិត្តភាព

ជលនារី

ខ្ញែតហើយបងចាំងពីរឈ្មោះគ្នា ! នាំឲ្យវេទនាដល់ចិត្តខ្ញុំ
តែដឹងដល់ប៉ាកើតទោសធំ ត្រៀមក្រែលពេលនាំរំខាន ។

ភាណវិទ្ធិ

តឹរបប្អូនហើយជាចៅក្រម ជំនុំដំរេរឿងនេះបាន

មិត្តភាព

ជលនារីកាត់ក្តីរឿងមិនក្បាន្ត ! បែកបានជាធំអញខ្មាសគេ ។
ឯងសមដើងបង ! អញដឹងហើយ ចិត្តអញមិនស្បើយពីក្មាញ់ទេ
ជជែកចុះខ្សើងគេចំនោ រ ទោសទូមកខុសអញចង្រៃ ។

ជលនារី

សិស្សសាលាបង ខូចអនេក ដូចក្អែកចោមសាច់ឆ្កែតហាលថ្ងៃ
តែឃើញស្រី សិស្សចោមច្រែនក្រៃ ចង្រៃតិដ៏ណាយគួរអនិច្ចា ។

ភាណវិទ្ធិ

មែនពិត អញឃើញកាលតាំងតុ ឯងដើរសំពុកគយនេត្រា
ឥតស្រីនៅក្បែរចន្លួចយា លោកប៉ាលបមើលជាមួយអញ ។

មិត្តភាព

បងឯងស្រែវេរ នៅដោយផ្សារ ក៏ដេរដល់ប៉ាំលោកកើតក្តាញ់
អាខ្នះ! អាគុក! អាគេចាញ់! ម្តេចលាងខ្លួនវិញនែលោកនាយ! ។

ធិលនារី

ឃើ! បងភាណវិទ្ធិដល់ម្ទឹងឬ!

ភាណវិទ្ធិ (ទះកំភ្លៀងមិត្តភាព)

នេះគឺ រង្វាន់អញចំណាយ បើអាដឹងហើយម្តេចនិយាយ?
អញវាយមួយដៃតាមចំនើន ។ (ចូល)

មិត្តភាព

ខ្ញុំពាមានកែកដួយចាំជាក់ ចង្រៃអប្បលក្ខណ៍កើតមានឡើង
នៅក្នុងក្រមញាតិអាប់មិនថ្លើង ដូចជាចម្បើងក្នុងគង្គា ។

ធិលនារី (យកកន្សែង ជោសទោ - អារឲ្យបង)

ធ្វើម្តេចខ្លួនខ្ញុំនឹងជួយបាន ចិត្តគាត់ក្លាហានក្នុងគ្រួសារ
វាយតែឆ្នាំងឯងឲ្យប្រែះធា អាប់យសសក្តាគេមើលងាយ ។ (ចូល)

មិត្តភាព

ខ្ញុំ! ផ្លែនារីនាងក្មេងតែខ្លួន តែចិត្តជាប់ជួនមិនរាយមាយ
ម្ល៉ះសមក្នុងទ្រង់តឹងស្មើរភ្នាយ ហាមាត់និយាយទៀតពុំបាន ។

ការសង្គ្រាមជាការរួចខ្លួន
នាងធ្វើពេលណាទើបស្រាកស្រាន្ត
ការណាទ្វិ - មិត្តការពជាប់ឈាមសាច់
បើនឹងសង្គ្រាម ទម្លាស់ថ្ងៃ!
បើនាងប្អូនខ្ញុំហាក់ក្តៅជិត
មិនឲ្យដឹងដល់វណ្ណៈតាព
បើរឿងនេះលេចឮសព្វសាយ
ទាំងក្រុមគ្រួសារកំអន់ថ្ងៃ

សេចក្តីគុំគួនព្រួយក្នុងក្រោណ
ហើយបានពេញចិត្តតែនៅភ័យ ។
កាលណាការត់ជាប់លែងអាល័យ
ខ្លួនខ្ញុំចង្រៃដល់មេបា ។
ពីបងការណាទ្វិក់យខ្ញុំណា
សមខ្ញុំជ្រះថ្លាក្នុងចិត្តក្រៃ ។
ក្តៅឈ្មោះអន្តរាយគ្មានដំណៀ
អ្នកផងពីទៃហ៊ានមើលងាយ ។

ឈុតទី ១ ជាកទី ៣

មិត្តាណា - ភាណី

មិត្តាណា

បងប្អូនសុទ្ធសឹងតែអ្នកចេះ
ប៉ុន្តែបុកពាធ្វើមិនសួន
មេបាចំណាយប្រាក់ឲ្យរៀន
មិនទំធ្វើការយកកំរៃ
គិតតែឈ្មោះគ្នាដណ្តើមធំ
ញាតិសាលោហិតនៅពាសពេញ

ដម្រែមានសព្វតែរៀងខ្លួន
មិនជួនសមជាតិជាអ្នកថ្លៃ ។
ចំណេះរបៀនជាដំណៀ
សង្គ្រាមចំណាយជួសលោកវិញ ។
នេះហៅជាចំគ្នានចំណេញ
ទន្ទេញទន្ទឹងចិត្តរំជួល ។

អ្នកច្រៀងនឹងមកវៀបចំញាតិ ធ្វើឲ្យចាកឃ្លាតពីទុក្ខព្រួយ
សព្វថ្ងៃនៅមានតែផ្លូវមួយ គឺ . . . . . .

ភាណី

ចាក់ថ្នាំការពារពេគាឆ្កួត ! ឆ្កួតស្រី ! ឆ្កួតស្រា !
អាកៀនកញ្ជា ! ស្រវឹងពុលស្លាប់ !
ក្មេចបងក្មេចប្អូន ក្មេច . . .

មិត្តាណា

ខ្លួនថាឯងឆ្កួតដែរ

ភាណី

ឆ្កួតស៊ីតាប៉ែលាយទឹកត្នោតជូរ ឆ្កួតផឹកទឹកប៉ោតក្មេមសាប៊ូ
ឆ្កួតផឹកទឹកត្នោតជូរ ក្មេមកង់ឡាន ឆ្កួត . . . . . .

មិត្តាណា (យកដៃខ្ទប់មាត់ភាណី)

និយាយតិចៗ កុំឲ្យខ្ទាំង មិនមែនចាក់ឯស្រវឹងទេ
ឡូឡាខ្ទាំងពេកខ្ទាចប៉ាដែរ ផ្ទះយើងហួសគេតែមាត់ ។

ភាណី

ឡូឡាខ្ទុំស្រែកប្អូនរណា (ខ្ទាំង) បងមិត្តាណាឯងម្តេចមិនយាត់

មិត្តាណា

កាល់ពេលវេលាតែងតួមាត់ ច្រោកដឹតតគិតឲ្យវែងឆ្ងាយ ។
មិនមែនតែឯងទេហ្ន៎ហ្នឹង កាណាទ្វិចិត្តផ្សាងគ្មានសប្បាយ
និយាយកាលណាមុខមិនស្រាយ ចិញ្ចើមមុខក្រាយខ្ញុំស្អប់មុខ ! ។

ភាណី

កាណាទ្វិ ! ចិត្តគេធំអស្ចារ្យ គេចង់ត្រួតត្រាលោកឥតុក
និយាយកាលណាបណ្តាលទុក្ខ ប៉ុន្តែឥតុកពប់ពេញទី ។
អាចារ ! ស៊ីចុាយហើយចោកឆ្នាំង

មិត្តាណា

ឯងថាត្រូវម៉ាំង ! ហើយកាណី

ភាណី

តែចុាយឆ្អែតហើយដើរកាល់ញី ថ្ងៃមុនឃើញពីរនៅមុខកំង ។

មិត្តាណា

តំនិតឯលខូចនាំខាបថោក ឲ្យស្រី ។ ចោកខ្លួនក្លាត់ភ្លាំង
ដល់ផ្ទះកាលណាផ្តើមតតាំង ច្របូតច្របាំងរកវឿងឈ្លោះ ។
មិនអាស្សរដល់ខ្លួនអ្នកហាត់ លំចាកខំអត់ជាបត្រដួស
តែឃើញកាលណាយើងធ្វើហួស ចំពោះខ្លួនលោកព្រួយយ៉ាងណា ។

ភាណី

អាណិតចា"ណាស់ណាបងអើយ! ម្ល៉ះហើយលោកតើតទុក្ខខ្លាំងក្លា

មិត្តាណា

អាណិតអី? បើឯងវៃស្រកឡូឡា

ភាណី

ពីថ្ងៃនេះណា ខ្ញុំលែងស្បាត ។ ខ្ញុំនៅឲ្យសៀមដូចអ្នកតា
បំរើលោកចា"ឲ្យអស់ចិត្ត!

មិត្តាណា

សាធុ! សាធុ! បងអរពិត ប្អូនប្រែគំនិតល្អត្រចះ ។

ភាណី

ខ្ញុំប្រែគំនិត ចិត្តជាថ្មី! រក្សាសេចក្តីសុខក្នុងផ្ទះ
ថែតាជម្ចីឲ្យស្រឡះ ថែញាតិក្នុងផ្ទះឲ្យសុខសាន្ត ។

មិត្តាណា

សេចក្តីសង្ឃឹមញញឹមខុក ថានឹងបានសុខគ្រប់អង្គជ្រុណ
បងប្អូនជិតឆ្ងាយញាតិសន្តាន ដោយសារប្អូនបានធ្វើសោភា។

ភាណី

ធ្វើចំពោះជាតិគ្មានវើសមុខ ថែតាសុខទុក្ខនៃរូបា
ប្រុស - ស្រីតាំងឡាយជាតិខេមរា ខ្ញុំការពារពេគគ្មានរវើ ។

ធ្វើការដោយកាយ ធំទៅចិត្ត គំនិតគិតឃើញហើយត្រូវធ្វើ
បំពេញកណីយឲ្យប្រសើរ បំពេញដំណើរយានសម័យ ។
កម្ពុជាបែរមុខទៅគ្រប់ទិស ត្រូវចំធ្វើពិសកុំដកដៃ
ឲ្យស្រុកផងយើងជឿនរាល់ថ្ងៃ ឲ្យជួចសម័យនគរវត្ត ! ។

(ភាណីរត់ចូលក្នុង ដោយឃើញមិត្តភាពកាន់កាំបិត)

(មានត)

ពិធីបុណ្យដ៏ឧឡារិក

នៅវត្តដើមអម្ពិល វ៉ខត្រ(ប៉ោ)លៀវ (យៀកណាម)

ព្រះមហាឈិត កំលឹង

សិស្សសាលាឆាលីជាន់ខ្ពស់ ថ្នាក់ទី-៤ (ក) វត្តឧណ្ណាលោម ក្រុងភ្នំពេញ រៀបរៀង

(តចប់)

សុន្ទរកថា

របស់ព្រះមហា គីម-ឃួន អាចារ្យ វត្តដើមអម្ពិល

អ្នកបណ្ឌិត ហាង-កៀង សូត្រជំនួស

ព្រះតេជព្រះគុណ !

ព្រះករុណា ទាំងឡាយ !

លោកអ្នកសប្បុរសទាំងអស់គ្នា !

ឧកាសនេះជាពេលប្រកបដោយមង្គលក្នុងក្តីប្រុងប្រយ័ត្ន ជាអតិលក្ខិតសម័យដ៏ប្រសើរ នៃបុណ្យរបស់យើងពាល់គ្នា ។ ហេតុនេះ ខ្ញុំព្រះករុណា អាត្មាភាព សូមឧកាសបន្តិចនឹងថ្លែងអំពីបុព្វហេតុបុណ្យនេះប្រគេនជូនជាដំណឹង ។ បុណ្យនេះមានមូលហេតុដែលនាំឲ្យកើតឡើង ដោយខ្ញុំព្រះករុណា អាត្មាភាពមានចិត្តនឹកក្តុកមមៃយ៉ាងមកញឹកថា ចង់ប្រតិស្ថានគោលបំណង ៣ យ៉ាងឲ្យសម្រេច គឺ :

១ - ដ្បិតសម្បត្តិគ្រប់យ៉ាងក្នុងលោក ទោះល្អអាក្រក់ មានតម្លៃឥតតម្លៃ ច្រើន តិច មានវិញ្ញាណ ឥតវិញ្ញាណ កាលណាពងកាយធ្លុះធ្លាយ វិញ្ញាណក្ខន្ធអណ្តែតបាត់ទៅហើយ ឥតមានអ្នកណាម្នាក់អាចវេចខ្ចប់ ស្តាយយកទៅតាមផងបានឡើយ ។

២ - ជីវិតមនុស្សសុទ្ធសឹងធ្លាក់ទៅក្នុងអំណាចនៃសេចក្តីស្លាប់ បើរស់នៅមិនបានកសាងបុណ្យទានអ្វីបន្តិចបន្តួច ដើម្បីជាសុភាវម្មណ៍ទេ, ឈ្មោះថាជាមនុស្សខ្វាតធំ ព្រោះកើតមកពុំបានបំពេញកុសលជាទីពឹងក្នុងពេលដែលខ្លួនត្រូវលះលោកនេះ ទៅកាន់លោកខាងមុខ ។ មានតែកុសលធម៌ដែលយើងបានកសាងទុកនេះហើយ ដែលជាមិត្តភក្តីគួរគប់ជូនដំណើរយើងទៅកាន់បរលោកបាន ។

៣ - អំពើជាកុសលដទៃ ។ មានបុណ្យពុទ្ធាភិសេកវិហារ, សាងព្រះវិហារ, សាងកុដិ, សាលា, សាងថ្នល់, ព្រះចេតិយជាដើម អស់លោកអ្នកជាសប្បុរសទាំងអស់គ្នា ធ្លាប់បានធ្វើខ្លះមកហើយ នៅសល់តែសាលាបរិយត្តិបឋមវិជ្ជា ឧត្តមត្តសាលាប៉ុណ្ណោះទេ ដែលមិនធ្លាប់បានធ្វើ ។ សម័យនេះ អាត្មាភាពនឹងលោកអ្នកទាំងឡាយមានអធ្យាស្រ័យស្រុះស្រួលគ្នាតែមួយថា នឹងកសាងបុញ្ញនិធានកិច្ចនេះឡើងវត្តុបំណងនោះក៏បានសំរេចហើយ ។

ឯធម៌ជាសត្រូវនៃគោលបំណងនេះគឺមច្ឆរិយៈ។ នេះបានដល់សេចក្តីកំណាញ់កាញ៉ាសម្បត្តិទុក ជាកិលេសនាំឲ្យសៅហ្មងចិត្ត ដឹកនាំឲ្យ

សុតូឲ្យលះធនធានឆ្ងើវៅជាទានមិនកើត ព្រោះខ្លាចអស់រលស់ទ្រព្យ
សម្បត្តិរបស់ខ្លួន ម្ល៉ោះហើយក៏ចំបរិហារការពារធនទុក ដូចជាបស្រែក
ការពារទ្រនំមិនឲ្យសត្វដទៃចំផង់បានដូច្នោះឯង ។ មច្ឆរិយធម៌នេះ ឈ្មោះ
ថាយើងបានឈ្នះ ព្រោះបានបរិច្ចាគលះធនធាន ឆ្ងើវៅជាទានហើយ ។

សមដូចសុភាសិតក្នុងលោកនីតិថា :-

ទាឆំ សិនេហភេសជ្ជំ មច្ឆេរំ ទោសនោសបំ
ទាឆំ យសស្សុ ភេសជ្ជំ មច្ឆេរំ កប្បនោសបំ

ទានជាថ្នាំនាំកើតក្តីស្នេហា កំណាញ់ជាឧសថនៃទោសទុក្ខ
ទានជាថ្នាំយសស័ក្តិចំរើនសុខ កំណាញ់ទុកជាថ្នាំនាំកំត្រា ។

មួយទៀតសមដូចពុទ្ធភាសិតថា :-

ទ្រព្យសម្បុរសទោះតិចតួច ប្រាថ្នាជាប្រយោជន៍ជនានា
ដូចទឹកអណ្តូងរសសាបថ្លា អស់មហាជនផង់ជង់អាស្រ័យ ។
ទ្រព្យអសប្បុរសទោះមានច្រើន ពុំបានចំរើនអ្នកដទៃ
ដូចទឹកសមុទ្រមានរសប្រៃ មនុស្សផង់អាស្រ័យផឹកពុំបាន ។

រតនត្តយតេជេន ដោយប្រដុំបីនៃព្រះត្រៃរត្ន សូមទេវតាទាំង
មួយម៉ឺនលោកធាតុ ពិភ័ក្តិរក្សាព្រះតេជព្រះគុណ, ព្រះករុណាទាំងឡាយ,
លោកអ្នកសប្បុរសទាំងអស់គ្នា ប្រកបដោយចតុព្វិធពរគឺ: អាយុ វណ្ណ
សុខ: ពល: បរិបូណ៌ដោយសតិប្បញ្ញាបរិហារជាបុរសស្ត្រីទៅហោង ។

សុទ្ធវាគថា

របស់ព្រះមហាឧត្តមវិជ្ជា លីវ-កែម អាចារ្យ វត្តដើមអម្ពិល

សូមពិតពុទ្ធដីកាព្រះតេជព្រះគុណ !

ព្រះករុណាទាំងឡាយ !

អស់លោកសាធុសប្បុរស ជាពុទ្ធបរិស័ទទាំងអស់គ្នា

សូមទានជ្រាប ទើង សូមជ្រាប ។

វត្តដើមអម្ពិលនេះ បានឧប្បត្តិឡើងតាំងពីឆ្នាំណាមកទល់ទើបបច្ចុប្បន្ននេះ ហើយមានសភាពយ៉ាងណា មានសេចក្តីប្រព្រឹត្តិមកយ៉ាងណា ព្រះតេជព្រះគុណ ព្រះករុណាទាំងឡាយ អស់លោកសាធុសប្បុរសទាំងអស់គ្នា សឹងបានជ្រាបសព្វគ្រប់ហើយ ។

ដល់ទីបំផុត ឧបាសកឧបាសិកាចំណុះដើងវត្តទាំងឡាយ អ្នកប្រាថ្នាឲ្យសេចក្តីចំរើនរុងរឿងដល់វត្ត, បានព្រមព្រៀងគ្នាទុកជាក់វត្តនេះ ឲ្យនៅក្រោមអធិបតេយ្យនៃព្រះតេជព្រះគុណទាំង ៣ ព្រះអង្គគឺ ព្រះតេជព្រះគុណ ឡឹម-យ៉ុក, ព្រះតេជព្រះគុណ សឺន-ឧត្តម៍, ព្រះតេជព្រះគុណ គីម-ឃួន, ដោយហេតុតែមានព្រខ័យដ៏បវរិសុទ្ធិ ប្រកបដោយសេចក្តីមេត្តាករុណា ទើបជនាការដ៏បវិសុទ្ធកង៏ការជួយទំនុកបំរុងផ្សេងៗ, ដើម្បីឲ្យវត្តនេះមានដំហានឈានទៅកាន់សេចក្តីចំរើនរុងរឿង, សមជាវត្តដ៏រមនីស្ងាយនទើងដែរថ្លា ដល់បណ្តាជនអ្នកត្រូវការ ដោយបុញ្ញ-

ភ្នែក្ត, របស់ព្រះតេជព្រះគុណចាំង ៣ ព្រះអង្គ, ហើយបានអនុញ្ញាត
ឲ្យកិក្ខុសាមណេរ មកគង់នៅក្នុងទីវត្តនេះ ថែមទាំងបាននិមន្តធម្មាចារ្យ
ដែលប៉ុនប្រសប់ផងវៃក្នុងវិធីបង្ហាត់បង្រៀនធម្មវិន័យផ្សេងៗ មកធ្វើជា
អាចារ្យបង្រៀន ដោយហេតុតែព្រះទ័យយល់ឃើញថា: "បណ្តាប្រទេស
ជាតិនានា ក្នុងលោកសន្និវាសនេះដែលនឹងឈានដើងលឿនទៅកាន់
ភាពជាអារ្យប្រទេស ឬ អារ្យជាតិទៅបាននោះ, លុះតែរាជរដ្ឋកិច្ចលុ
របស់ប្រទេសនោះ។ ទំប្រឹងប្រែងរកគុសលោបាយ វិធីបណ្តុះបណ្តាល
ការសិក្សាដល់ប្រជាជាតិខ្លួនៅក្នុងប្រទេសនោះ។ ឲ្យបានគ្រប់គ្រាន់ពេញ
លេញបរិបូណ៌ឡើង" ។ ចំណែកខាងព្រះពុទ្ធសាសនាក៏ដូចគ្នាដែរ
ដែលនឹងចំរើនរុងរឿងថ្កុំថ្កើងទៅបាន, លុះតែអ្នកដែលកាន់ពុទ្ធសាសនា
បានទទួលការសិក្សារៀនសូត្រប៉ែកខាងបរិយត្តិធម៌ ដ៏ងនុសត្រូវជ្រាលជ្រៅ
ខ្ពស់ខាប ក្នុងព្រះពុទ្ធសាសនាដោយគេញលេញ ព្រះពុទ្ធសាសនា
ក៏នឹងដល់នូវភាវៈនៃសេចក្តីប្រសើរជាអារ្យសាសនា ។

សេចក្តីពិតនោះ ព្រះពុទ្ធសាសនាជាអារ្យសាសនាស្រាប់ហើយ,
គ្រាន់តែឲ្យអ្នកកាន់គ្រប់ៗ គ្នា ទំសិក្សារៀនសូត្រនឹងប្រតិបត្តិធ្វើខ្លួនឲ្យ
ទៅជាអារ្យៈប៉ុណ្ណោះ ក៏បាននឹងថា ជាអ្នកជួយលើកដំកើងព្រះពុទ្ធ-
សាសនា ។ ដោយសារព្រះទ័យព្រះតេជព្រះគុណចាំង ៣ ព្រះអង្គ
យល់ឃើញដូច្នេះ បានជាទំយកព្រះទ័យទុកដាក់ដឹកនាំកិក្ខុ សាមណេរ

ឧបាសកនឹងឧបាសិកា ដែលនៅក្រោមម្ចាស់បារមីឲ្យចំប្រឹងប្រែងយកចិត្ត
ទុកដាក់ក្នុងការសិក្សារៀនសូត្រ សមភាពជាបិតាសង្ឃទាំង ៣ ព្រះអង្គ
ក្នុងឥនេះ ។

ក្នុងឆ្នាំថ្មីដែលជាឆ្នាំសុកនក្ខត្តឫក្សល្អ ព្រះតេជព្រះគុណទាំង ៣
ព្រះអង្គនេះ មានវត្តបំណងឲ្យកិត្តិ - សាមណេរក្នុងវត្តអម្ពិលនេះបានទទួល
ការសិក្សារៀនសូត្រ ព្រះធម្មវិន័យបរិយត្តិធម៌ ដែលជាបេះដូងរបស់
ព្រះពុទ្ធសាសនា ទើបបានចាត់ខ្ញុំព្រះករុណាអាត្មាភាពមកបង្ហាត់បង្រៀន
ជាគ្រាដំបូង ។ ខ្ញុំព្រះករុណាអាត្មាភាព, ក៏ចំប្រឹងប្រែងពេញទំហឹង
ក្នុងការបង្ហាត់បង្រៀនជាមួយនឹងព្រះតេជព្រះគុណព្រះអាចារ្យ គីម - ឃួន
ដើម្បីឲ្យសមប្រកបជូនបំណងនៃព្រះតេជព្រះគុណទាំង ៣ អង្គនេះ ។
ខ្ញុំព្រះករុណាអាត្មាភាព ឃាននទទួលសេចក្តីទុកបុរុងអំពីសំណាក់ព្រះតេជ
ព្រះគុណជាចៅអធិការ នឹងព្រះតេជព្រះគុណជាវិបស្សនាចារ្យវត្តនេះ ។

ឧបការគុណនេះ ខ្ញុំព្រះករុណាកត់សំគាល់ទុក មិនអាចនឹងរលុប
ចាត់ចង់ប្តូរភ្លេចភ្លាំងទៅបានឡើយ ។ ខ្ញុំព្រះករុណាអាត្មាភាពយល់ថា
វត្តនេះនឹងបិតបៀរយឺនយូរនៅក្នុងវង់នៃសេចក្តីចំរើនតទៅ ឰដ៏អនាគត-
សម័យបាននោះ ក៏ដោយសារដែកគ្រោមម្ចាស់ នៃសេចក្តីទុកបុរុងយ៉ាង
ប្រពៃល្អ របស់ព្រះតេជព្រះគុណទាំង ៣ ព្រះអង្គនេះ ។

ក្នុងទីបំផុតនៃសុន្ទរកថានេះ ខ្ញុំព្រះករុណាអាត្មាភាព, សូមព្រះតេជព្រះគុណទាំង ៣ ព្រះអង្គ មេត្តាជ្រោសប្រទានជម្ឡើងដល់បណ្តាភិក្ខុ - សាមណេរ - ឧបាសក - ឧបាសិកា ដើម្បីឲ្យបានប្រកបដោយជោគជ័យ សិរីសួស្តី ហើយនឹងសូមព្រះសង្ឃទាំងអស់អង្គផ្ចង់មេត្តាចិត្តសូត្រ "ជយន្តោ" ដើម្បីជាជយមង្គលនៃសាលារៀនព្រះបរិយត្តិធម្មវិន័យក្នុងវត្តដើមអម្ពិលនេះតទៅ ។

សេចក្តីបញ្ជាក់តាមការណ៍ពិត

អស់លោកអ្នកយល់ស្រាប់ហើយថា: សៀវភៅកម្ពុជសុរិយារបស់ពុទ្ធសាសនបណ្ឌិត្យ ជាទស្សនាវដ្តីមួយផ្សាយចេញពាល់ខែ សម្រាប់ពន្លឺកពុទ្ធសាសនានិងអក្សរសាស្ត្រ ។ ការផ្សាយចេញនូវពុទ្ធសាសនានិងអក្សរសាស្ត្រនេះ គឺជាគោលការរបស់ពុទ្ធសាសនបណ្ឌិត្យ ព្រោះពុទ្ធសាសនា ជាអត្ថបទផ្សាយនូវផ្លូវធម៌, អក្សរសាស្ត្រ ជាអត្ថបទផ្សាយនូវផ្លូវលោក ។ ផ្លូវធម៌និងផ្លូវលោក ត្រូវតែមានជាគូគ្នាដកបលះចោលគ្នាពុំបាន ដូចព្រះអាទិត្យនិងព្រះចន្ទ្រ ដែលត្រូវតែជាគូគ្នាបំភ្លឺលោក ។

ហេតុនេះ អស់លោក-អ្នក បងប្អូនរួមជាតិ ដែលជាអ្នកអានទស្សនាវដ្តីកម្ពុជសុរិយា សូមយល់ថា ក្នុងទស្សនាវដ្តីនេះ នឹងផ្សាយចេញតែសាសនាម្យ៉ាង ឬអក្សរសាស្ត្រម្យ៉ាង នោះយើញថាពុំកើត ត្រូវតែឲ្យគេនិពន្ធពីរ ទើបសមរម្យទៅតាមកាល:ទេស: ។

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៤ ខែមីនា លេខ ៣

ព.ស. ២៤៩៤ — គ.ស. ១៩៥២



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពន្ធអាស៊ីទូប (តមក)	លោកវ៉ាយ - ប៊ុក	១៦៣
លោកិយលោកុត្តរបញ្ហាកថា	ព្រះអាចារ្យ ទូច - ឃ្លាង	១៧៨
អត្តានុទិដ្ឋិ	ឧកញ៉ា សំ - ស៊ុន	១៨៦
កម្មវិភាគ	ព្រះមហា ឧម - ន៉ាត្រី	១៩២
ផ្នែកអក្សរសាស្ត្រ		
ល្បើកក្រើនជាតិ	លោក ប៊ូ - ប៊ូ	១៨៦
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ិង - ប៉ម ...	១៩៩
រឿងសាមកុក (តមក)	ឧកញ៉ា ឆ្ង - កន	១៩៦
រឿងអារក្សថ្លែងរឿងម្តែប្រាំ (តមក)	លោក សាង - សាភ័ត	២០៤
រឿងស្នេហាជាតិ (តមក)	លោក គង់ - លឹម	២១០
រឿងប៊ូលនឹងវីរ៉ស៊ីនី	សាស្ត្រាចារ្យ ផេង - ជ្រើរ	២២០
សំលៀកបំពាក់ខ្មែរ	ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ	២២៤
កំណត់ទឹកប្រែវត្តិការណ៍		
ពិធីបុណ្យកឋិន នៅវិទ្យាល័យសីសុវត្ថិភ្នំពេញ	ក្រុមសាស្ត្រាចារ្យនិងក្រុមសិស្ស ..	២៣១

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ១៨៣.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE

		Pages
La lumière de l'Asie (suite).. ..	*M. Ray-Buc*	163
Lokiyalokuttarapannâkathâ	*Vén. Touch-Long*	170
Attânuditthi	*Oknha Sam-Sun*	176
Kammavibhaga.....	*Vénérable Om-Nakry*	182

PARTIE LITTERAIRE

Conseil d'après l'alphabet khmer (Poême).....	*M. Bou-Po*	186
Education morale (suite).....	*Vén. Pœung - Pam*	189
Histoire de SAMŖOK (suite)	*Oknha Nou - Kan*	196
Les vingt cinq récits du Mauvais Génie (suite)	*M. Sang - Savat*	204
L'Amour de la Patrie (pièces de Théâtre).....	*M. Kong-Lim*	210
Paul & Virginie (Traduction).. .	*M. Phéng-Chrieu*	220
Les vêtements Camd >dgiens	*Commission des Mœurs et Coutumes*	224

NOTES ET CHRONIQUES

Compte - rendu de la fête des offrandes au Lycée Sisowath.....	*Groupe de professeurs et étudiants*	231

Prix d'abonnement annuel (12 numéros :) 183$00

ពន្លឺអាស៊ីទ្វីប

វគ្គទី ៨

La Lumière de l'Asie

លោកស៊ែរ-អេតវីង អារណ្យលុត្ត ត្រៃង
លោករ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

គម្ពីរសំដែងថា មុននឹងកើតវត្តចាំងអស់ ដំបូងមានអន្ធកាព (Ténèpres) នឹងព្រះព្រហ្មពិចារណាម្នាក់ឯងក្នុងពេលយប់; កុំឲ្យពិនិត្យនូវព្រះព្រហ្ម ឬបុព្វហេតុនៃលោក! ចក្ខុសាមញ្ញសត្វមិនអាចមើលឃើញនូវព្រះព្រហ្ម ឬវិស្ណុអ៊ីចឹងឡើយ ឬជាសាមញ្ញសត្វមិនអាចដឹងយល់នូវវត្តខាងលើនេះបាន; ផ្ទាំងឆកឹតនោះនឹងរបើកតាមលំដាប់តគ្នាម្តងមួយៗ តែត្រូវមានផ្ទាំងឆកឹតឯទៀត ចូលមកស្ថិតនៅតាមលំដាប់មុនក្រោយតទៅទៀត ។ តាក្រោចមុខក្រោយ តាមច្បាប់ស្ងួនតាកសាស្ត្រ តែមិនអាចសួរឆ្លើយឆ្លងគ្នាបាន ។ គ្រាន់តែមានជីវិតាពនឹងមរណភាព, សុខនឹងទុក្ខស្ថិតនៅត្រមាំងហេតុផល, កាលវេលា, នឹងទឹកដោះនាច នៃលំនាំជីវិតសត្វដែលប្រែប្រួលជានិន្នកាល, ប្រៀបដូចជាស្ទឹងមួយ ដែលមានរលកបោកបក់តាមលំដាប់, ហូរយឺត ឬ ធាប់មានសភាពដូចគ្នាពិតមែន, តែខុសគ្នា, តាំងពីប្រភពឆ្ងាយរហូតដល់សមុទ្រជាបរិយោសាន ។

ចំណែកសម្តេចនោះ_ មានទឹកដែលព្រះអាទិត្យស្រូបយកទៅផ្ទាស់ប្តូរ
ទឹករលកនោះសាបសូន្យ ប្រែទម្រង់ជាពពកដែលរសាត់ទៅប៉ះលើកំពូល
ភ្នំក្លាយទៅជាទឹកហូរថ្មីតាមលំដាប់ គ្មានពេលខំនេរតទៅទៀត ។
ឧទាហរណ៍ប៉ុណ្ណោះ, នាំឲ្យយល់នូវសភាពតាន់ច្រឡំ, ចំពោះមេឃ
ផែនដីពិភពលោកនឹងការប្រែប្រួល ដែលនាំឲ្យប្រែស្ថានភាពនៃវត្ថុខាង
លើ, ពុកជាគង់មានអានុភាពអាចវិលមានការតស៊ូ នឹងកម្លាំងជាជំនួយ
មិនមានបុគ្គលណាអាចបញ្ឈប់ ឬធ្វើឲ្យមានន័យផ្សេងចំពោះនឹងការចលនា
នោះបានឡើយ ។ កុំឲ្យអ្នកបន់ស្រន់អ្វីឡើយ អន្ធការមិនអាចក្លឹបបាន
កុំឲ្យអ្នកធ្វើទុក្ខចំពោះចិត្តអ្នកដែលមានទុក្ខស្ងប់នៅស្រាប់ហើយ! ឧបាសក
ប្រុស, បងស្រីអើយ! សូមអ្នកកុំឲ្យរង់ចាំនូវសារកនៃព្រះអាទិទេពដែល
គ្មានអាណិតអាសូរអ្នកឡើយ ដោយអាមិសបូជា ឬសូត្រធម៌ កុំឲ្យអ្នក
ធ្វើឲ្យលោកទាំងនោះពេញចិត្តនឹងអ្នក ដោយធ្វើពលិកម្មមានពិឃាតសត្វ
បូជា កុំអ្នកបូជាផ្លែឈើ ឬនំចំណី គឺកងពួកយើងនេះឯងដែលត្រូវស្វែង
រកនូវមធ្យោបាយដែលជាហេតុឲ្យយើងបានចេញចាកវដ្តសង្សារ; មនុស្ស
ម្នាក់ៗ បង្កើតគុកសម្រាប់ជាក់ខ្លួនៗ ឯង, បុគ្គលម្នាក់ៗ មានអំណាចស្មើ
នឹងអ្នកដែលមានបុណ្យនុភាព; ព្រោះថាចំពោះអគ្គបុគ្គលទាំងអស់ ដែល
ស្ថិតនៅពីលើយើង ឬជុំវិញយើងដូចជាពួកសត្វនិរយ ឬជាសត្វ, គឺកិរិ-
យាប្រតិកិរិនោះឯង ជាហេតុឲ្យសុខទុក្ខ ។ អតីតហេតុនាំមកនូវ

បច្ចុប្បន្នហេតុនឹងអនាគតៈហាតុ - ចាបបុណ្យ ប្រព្រឹត្តក្រោយសម្រាប់អ្នក
មុនៗ សម្រាប់អ្នកក្រោយ; សូម្បីតែពួកទេវតានៅស្ថានសួគ៌ក៏ច្រែតការ
ខ្លាចផលនៃអតីតជាតិ; ពួកអារក្សស្ថិតនៅក្នុងហ៊ីនភាព, ស្ញាយខ្លាចទោស
នៃចាបអកុសលដែលខ្លួនបានប្រព្រឹត្តពីកាលមុន; គ្មានអ្វីស្ថិតស្ទេរក្នុង
លោកទេ គុណធម៌ក៏ធ្លាក់វិនាសសាបសូន្យជាមួយនឹងកាល, ចាបអកុ-
សលអាចប្រែកែឲ្យបានបរិសុទ្ធស្អាតទៅវិញ ។ អ្នកណាដែលរស់នៅ
លំបាកក្នុងហាន: ជាទាសកម្មករអាចដល់អនាគតជាតិទៅចាប់បដិសន្ធិជា
ព្រះអង្គម្ចាស់ ដោយមានគុណធម៌នឹងបុណ្យកុសលដែលបានបំពេញ;
អ្នកដែលពីដើមជាព្រះមហាក្សត្រតែឡប់ទៅជាគ្រាប់រគ្នាត់ នៅលើផែនដី
ជាពួកទុគ៌តពាក់ភៅអាវកណ្តាចនោះគឺ ដោយហេតុចាបដែលខ្លួនប្រព្រឹត្ត
នឹងបុណ្យដែលខ្លួនកេចធ្វើ ។ អ្នកអាចដំតើងជោគវាសនាអ្នកនោះស្មើនឹង
សត្វដន្ទេនប្តូរកំទេចបរមាណូ; មានដំរីសត្វជាច្រើនលាននាក់អាចធ្វើដំណើរ
ទៅដល់លទ្ធផលទីមួយ, ខ្លះទៀតបានលទ្ធផលទីពីរ ។ ដរាបណាកង់ចក្រ
ដែលយើងមើលមិនឃើញនៅតែវិល, ដរាបនោះគ្មានសន្តិសុខទេ, គ្មាន
ពេលសម្រាក, គ្មានពេលឈប់ឈរទេ អ្នកណាដែលឡើង អាចធ្លាក់;
អ្នកណាដែលធ្លាក់ អាចឡើងវិញ; កាំកង់នោះវិលគ្មានទំនេរ ។

បើខ្លួនអ្នកគេចង្អាប់ខ្លួនក្តី ដែលមានសភាពប្រែប្រួលដោយគ្មាន
មធ្យោបាយអ្វីធ្វើឲ្យច្បាក់បែកខ្លួនចំណង់កង់នោះ, ហេយវាគ្មានឯដំរីសត្វសេរី

គួរឲ្យក្តៅចិត្តពន់ពេក, វិញ្ញាណនៃវត្តុទាំងឡាយមុខជានឹងរងទុក្ខលំបាកឥតល្អែ ។ តែអ្នកមិនមែនគេចង់ស្លាប់ទេ! វិញ្ញាណនៃវត្តុទាំងអស់មានសភាពស្ងួតត្រង់, ចិត្តនៃសត្វនិកប្រែកបដោយសន្តិភាព, ឆន្ទៈមានអាទុភាពជាធំទុក្ខ; អ្វីដែលល្អទៅជាសោភារិសេសតាមលំដាប់ ។ តថាគត, ព្រះពុទ្ធដែលបានអាណិតអាសូរដល់បងប្អូនទាំងអស់គ្នា ដែលចិត្តជាប់ចំពាក់នឹងសេចក្តីទុក្ខ ក្នុងលោកកាត តថាគតសើចហើយសប្បាយផង ព្រោះតថាគតបានឃើញផ្លូវដែលនាំទៅកាន់សេរីភាពហើយ, ឧអ្នកដែលមានទុក្ខ! ចូរអ្នកជ្រាបថាទុក្ខនោះមកពីអ្នកឯង ។ គ្មានអ្នកណាបង្ខំផ្សែងពីអ្នកឯងឲយញ្ជោរអ្នក ឬបង្ខំអ្នកឯងដើម្បីឲ្យអ្នកកើតរួចស្លាប់វិញ ហើយធ្វើឲ្យអ្នកវិលជាមួយនឹងកង់ហើយថ្ងូរងំទៅលើកាំកង់នោះឲ្យយ, យំទួញសោកនៅលើខ្នងកង់ហើយ បង្វិលដុំនោះទៅរកសភាពសាបសូន្យវិញ ។ ចូរអ្នកស្តាប់តថាគត។ នឹងបង្ហាញអ្នកអំពីអរិយសច្ចៈ នៅត្រើមៈស្ថាននរក, នៅខាងលើៈស្ថានសួគ៌, នៅឆ្ងាយជាងតារានោះទៅទៀត ឆ្ងាយសែនឆ្ងាយ, ម្ខាងស្ថានព្រហ្ម, មានអាទុភាពមួយជាបវរដ្ឋ, ខុត្តមផុតអស្ចារ្យដែលស្ថិតនៅមុនបុព្វហេតុ - ហើយគ្មានអវសានហេតុ, ប្រែកបដោយអនន្តកាលដូចមហាមេឃហើយពិតដូចជាសច្ចធម៌ ដែលវិលទៅរកសោភណភាពហើយប្រព្រឹត្តទៅតាមបទបញ្ជាគ្រប់ខ្លួន ។ អាទុភាពនោះធ្វើឲ្យកុប្បាបមានផ្លា, គឺសិល្បៈនៃអាទុភាពនោះដែលប្រទានសិល្បៈនៃស្នឹក

ប់ខុម; នៅក្រោមព្រះធរណីដ៏ងឹតហើយក្នុងពួជដែលសាបគ្រោះ ដោយ
ស្ងាត់ស្ងប់, អានុភាពនោះរចនាធម្មជាតិស្រស់ស្រាយនៃនិទាយ:វដ្ដវ,
នេះជាពណ៌នៃអានុភាពនោះ ស្ថិតនៅក្នុងពពកនឹងពណ៌មកតស្ថិតនៅ
លើកន្ទុយក្ងោក, ពួកតាពជាប្រធានៃអានុភាពនោះ, រស្មី, ខ្យល់;
ក្ងែជាអ្នកបម្រើ, អានុភាពនោះបញ្ចេញពីអន្ធភាពន្ធវចិត្តមនុស្សទាំង
អស់ ហើយបញ្ចេញពីពងដ៏ងឹត ន្ធវមានន់ទោ មានការលេចពណ៌ជា
ច្រើនយ៉ាង; អានុភាពនោះចេះតែបំពេញការណ៍យកចិត្តឥតមានស្រាក
ស្រាន, ហើយធ្វើឲ្យស្រឡាញ់, ធ្វើសភាពដែលស្អប់ឲ្យវិនាស ។
ពពកប្រផេះ នៅក្នុងសំបុកសត្វច្រៀមានសុវណ្ណពណ៌នេះ ជារតនវត្ថុ
របស់ព្រះអង្គ, រន្ធសំបុកឃ្លាំជាព្រះសុវណ្ណកង្ហានៃព្រះអង្គ, ស្រមោច
ប្រតិបត្តិតាមព្រះឧបាទហើយព្រាបញ៉ីសស្តាប់ព្រះពាដន្ធារ ។ ព្រះអង្គ
ទ្រង់ធ្វើស្ងាបបក្សាខ្មែងឲ្យត្រជាងហើរទៅនាំចំណីមកឲ្យកូនបរិភោគ ឯ
សំបុក, ទ្រង់នាំចចកញីឲ្យទៅនៅជិតកូនវា, ទ្រង់ស្វែងរកចំណីមកឲ្យ
សត្វនិករ នឹងមិត្រភាពមកកាន់សត្វដែលគ្មានអ្នកណាស្រឡាញ់ ។ គ្មាន
អ្វីដែលធ្វើឲ្យព្រះអង្គទ្រង់ស្អប់ខ្ពើម ឬដំណាស់នឹងចំណង់ព្រះអង្គឡើយ;
ព្រះអង្គទ្រង់ស្រឡាញ់ពាងអស់, ទ្រង់យកទឹកដោះទៅប្រគល់ក្នុងដោះ
នៃមាតាពាងឡាយ, តែទ្រង់យកពីសសទៅជាក់នឹងចង្កូមពស់ ។ ទ្រង់
បានធ្វើស្ថានពាងអស់ឲ្យមានរបៀបរៀបរយ, ស្ថានដែលវិលនៅលើ

និកាល័យ, ហើយទ្រង់ជានលាក់បំពួនក្នុងប្រថពី នូវមាស, ភ្លួងប្រផេះ
ក្រហម, ភ្លួងខៀវ, ភ្លួងខៀវផ្ទៃមេឃ ។ បញ្ចេញនូវវិទ្យាដ៏ស្ងាត់សុខុម,
ទ្រង់នៅសម្ងំពួនក្នុងព្រៃមានពណ៌ខៀវស្រងាត់ហើយ ប្រគល់ដីវាលទៅរុក្ខា
ដែលដុះនៅគល់ដើមសែដ (Cèdres) មានស្លឹក, ផ្កា ព្រមទាំងតំណ-
ជាតិ ។ ទ្រង់សម្ងាប់ហើយ ស្រោចស្រង់មិនមានបំណងក្រៅពីឲ្យ
វត្ថុទាំងនោះសម្រេចទៅតាមជោគវាសនាសព្វៗ ខ្លួនទេ, មរណៈទីដ៏
ទុក្ខគឺជាត្រលំនៃគ្រឿងតម្បាញរបស់ព្រះអង្គ, ព្រហ្មវិហារធីដ៏វាសាតគឺ
ជាអំបោះ ។ អានុភាពនេះ ធ្វើ ឬធ្វើជាថ្មី, តែប្រែទាំងអស់, ដែលអានុ-
ភាពនោះធ្វើក្នុងបច្ចុប្បន្នគឺវិសេសជាងដែលព្រះអង្គធ្វើពីអតីតកាល, ស្នា
ព្រះហស្តដែលព្រះអង្គធ្វើក៏ចំរើនតាមលំដាប់ ។ នេះគឺករណីយកិច្ចរបស់
ព្រះអង្គ បំពេញទៅលើវត្ថុទាំងអស់ដែលអ្នកឃើញគ្រប់គ្នា, តែវត្ថុដែល
មិនឃើញមានសារប្រយោជន៍ជាងគឺ ចិត្ត, ប្លាជ្ញារបស់មនុស្ស, ចិន្តា
នៃប្រជាភស្តុ ផ្លូវដែលប្រជាភស្តុត្រូវតាម, ឆន្ទៈរបស់ប្រជាភស្តុសុទ្ធ
តែនៅក្រោមបង្គាប់បញ្ជានៃបទបញ្ញត្តិដ៏ខ្ពស់នេះ ។ ម៉ើលមិនឃើញ
តែអានុភាពនោះទុបត្ថម្ភដោយព្រះមហាករុណាទិគុណ, គេស្តាប់មិនឮ
តែអានុភាពនោះពោលខ្ទាំងដូចព្យុះសង្ឃរា ។ មេត្តាករុណា គឺជាចរិយា
របស់មនុស្សល្អ ព្រោះប្រជាភវដែលខ្វាក់ងងឹតតែងងប់ក្នុងអំពើគាចសា-
ហាវ, អ្នកដែលមិនព្រមធ្វើតាមលោកតែងខាត, អ្នកដែលព្រមធ្វើតាម

លោកតែងចំណេញ, លោកចែកបុណ្យដែលស្ថិតនៅក្នុងសន្តិសុខ នឹងសុខភាព, ជាបអកុសល នៅក្នុងទុក្ខ ។ លោកឃើញទាំងអស់គ្រប់កន្លែង, និគមជនបទ, ច្រកល្ហក, ហើយលោកពិនិត្យទាំងអស់គ្មានសល់, បើអ្នកសុចរិត អ្នកនឹងបានទទួលវង្វាន់, បើអ្នកទុច្ចរិត អ្នកនឹងបានទទួលនូវផលដ៏លាមកនោះមិនខាន, បើសិនណាជាព្រះធម៌ បង្អង់មិនបានឲ្យផលភ្លាមៗ ។ លោកមិនស្គាល់ទោស: ឬទោសចំពោះទោស:, វិធានរបស់លោកត្រឹមត្រង់ពន់ពេក, តុល្យភាពថ្លឹងស្មើឥតខ្ចោះ កាលគ្មានចំពោះលោកទេ សម្រេចសេចក្តីស្អែកឬកាលក្រោយក៏បាន ។ ហេតុទាំងអស់មកពីព្រះអង្គ, អ្នកពេជ្ឈឃាតធ្វើឲ្យខ្លួនរបួសនឹងកាំបិតរបស់ខ្លួន, ចៅក្រមទុច្ចរិតគ្មានអ្នកណាការពារ, អណ្តាតបោកបញ្ឆោតគេធ្វើឲ្យឃើញកុហក, ចោរនឹងអ្នកកំហែងប្រគល់ផលិតកម្មដែលបានមកពីការលួចប្លន់ឬប្រព្រឹត្តលាមក ។ នេះជាបញ្ញត្តិដែលមានចលនាទៅតាមយុត្តិធម៌ដែលបុគ្គលណាមិនអាចកំឆ ឬ បញ្ឈប់បាន, ចិត្តព្រះអង្គជារូបព្រហ្មវិហារ, គំនិតជាអាសនរបស់ព្រះអង្គជាសន្តិភាព ឬសុភិតភាពត្រូវតែប្រតិបត្តិតាមខានមិនបាន!

(មានត)

លោកំ យលោកុត្តរបញ្ញាកថា

ព្រះអាចារ្យទូច-ទ្បែង វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ រោចខែពិសាខ ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (៦-៥-៤៨)

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខ្ញុំព្រះករុណា សូមនមស្សការ ចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្តីគោរព ។

ឧត្តំ បញ្ញាសមា អាភា

ពន្លឺស្មើដោយបញ្ញា មិនមាន ។

បណ្តាពន្លឺទាំងឡាយក្នុងលោក មានពន្លឺព្រះអាទិត្យ ព្រះចន្ទជាដើមនេះ គ្រាន់តែសម្រាប់ចំភ្នែកមហាជនទាំងពួង ឲ្យឃើញបានតែត្រឹមរូបផ្សេង ៗប៉ុណ្ណោះ នឹងអាចនុះយល់នូវហេតុនឹងផលនៃសេចក្តីសុខ-ទុក្ខ ទាំងពួងក្នុងលោកនេះ នឹងលោកខាងមុខពុំបាន ។ ដូចឃើញថា ការប្រព្រឹត្តិសុចរិត ជាហេតុនៃសេចក្តីសុខ, ការប្រព្រឹត្តិទុច្ចរិត ជាហេតុនៃសេចក្តីទុក្ខដូច្នេះជាដើម នេះក៏អាស្រ័យដោយពន្លឺពោលគឺបញ្ញានេះឯង ទើបពិចារណាឃើញបាន ។

ប្រភេទនៃបញ្ញាមាន ២ យ៉ាង គឺ:

๑ – លោកិយបញ្ញា បញ្ញាសម្រាប់ប្រើការក្នុងលោកនេះ នៃជនជាបុថុជ្ជន ។

๒ – លោកុត្តរបញ្ញា បញ្ញាសម្រាប់ពិចារណា នូវមគ្គនឹងផល ដើម្បីធ្វើទៅកាន់ព្រះនិព្វាន នៃព្រះអរិយបុគ្គលជាម្ចាស់ ។

បញ្ញាឈ្មោះថាពន្លឺក្នុងស្វាធ្យាយ ជាឯពន្លឺដែលមាននៅក្នុងលោកនេះទាំងមូល ។ ឯកង់លោកនេះទាំងមូល ហេតុជារបស់សំខាន់បំផុត បើបុគ្គលអ្នកស្គាល់នូវ "ហេតុ" បាន គេទុកជាមនុស្សសំខាន់បំផុត ។ ដូចស្គាល់ច្បាស់ថា: ការនាំឲ្យថោកទាបជាតិកំណើតរបស់ខ្លួន មកពីល្ងង់ខ្លៅជាហេតុ, ការល្ងង់ខ្លៅមកពីគ្មានដម្រែវិជ្ជាសម្រាប់ផ្សះលោកផ្សះធម៌ជាហេតុ, ការគ្មានដម្រែវិជ្ជាមកពីការខ្ជិលជាហេតុ ។

ការខ្ជិលច្រអូស ជាមេជាដើមបណ្តុះបណ្តាលទាំងបាប, សេចក្តីព្យាយាម ជាមេបណ្តុះបណ្តាលទាំងបុណ្យ ឲ្យចំរើនសព្វប្រការ ។

ឯដម្រែវិជ្ជានឹងកោគសម្ប័ទ ជាហេតុបណ្តុះបណ្តាលឲ្យសម្រេចប្រយោជន៍បានច្រើនប្រការណាស់ ដូចក្នុងប្រទេសជាតិនិមួយ ។ ដែលមានសេចក្តីចំរើនសុខដ៏ធំធូលាយ ឡើងទៅកាន់ថ្នាក់ជាន់លើខ្ពស់ត្រដែតគ្រប់ដំហានទៅបាននោះ ព្រោះមានដម្រែវិជ្ជាជាហេតុផង មានកោគសម្ប័ទជាហេតុផង ។

ក្នុងផ្លូវធម៌ ឃើញដូចព្រះបរមគ្រូរបស់យើង ដែលព្រះអង្គទ្រង់បំពេញព្រះបារមីមក ក៏អាស្រ័យកោគសម្បុទជាហេតុ ដូចកាលទ្រង់បំពេញ ទាន, សីល, នេក្ខម, បញ្ញា, វីរិយ, ខន្តិ, សច្ច, អធិដ្ឋាន, មេត្តា, ឧបេក្ខា; នេះអាស្រ័យកោគសម្បុទ ជាកំលាំង ជាគ្រឿងទំនុកបម្រុងដល់បារមីធម៌ទាំង ១០ ប្រការ ឲ្យបានត្រាស់ដឹងជាព្រះពុទ្ធនេះឯង ។

ចំណែកសាវក-សាវិកាទាំងឡាយរបស់ព្រះអង្គ ក៏អាស្រ័យកំឡាំងកោគសម្បុទ ជាហេតុដូចគ្នា គួយ៉ាងដូចអគ្គសាវកទាំងគូរបស់ព្រះអង្គ គឺព្រះមហាសារីបុត្តត្ថេរ កាលកើតជាសរទតាបសក្តី ព្រះមហាមោគ្គល្លានត្ថេរ កាលកើតជាសិរិវឌ្ឍកុដុម្ពិកៈក្តី លោកទាំងពីរនេះសុទ្ធតែមានកោគសម្បុទ មានខ្ទឹមច្រើនពាប់មិនអស់ បានចំណាយឲ្យទានកសាងបុណ្យ កសាងកុសលច្រើនប្រការណាស់ បានតាំងជាថ្នាជាអគ្គសាវករបស់ព្រះអង្គ មកបានសម្រេចដូចសេចក្តីប្រាថ្នា ក៏ឃើញថាអាស្រ័យកោគសម្បុទជាហេតុ ឲ្យបំពេញសាវកបារមីញាណដែរ ។

ព្រះអរិយសាវិការបស់ព្រះអង្គឈ្មោះអនាថបិណ្ឌិកក្តី ព្រះអរិយសាវិកាឈ្មោះវិសាខាមហាឧបាសិកាក្តី លោកទាំងនេះសុទ្ធតែមានកោគសម្បុទស្តុកស្តម្ភមាំមួនណាស់ ទាល់តែល្បីពេញក្នុងលោក ក៏អាស្រ័យកោគសម្បុទជាហេតុ ឲ្យមានឧបនិស្ស័យនៃសោតាបត្តិមគ្គ ឲ្យថ្លៃថ្លាខ្ពង់ខ្ពស់ពាល់ជាតិដរាបដល់ទីបំផុត នៃលោកុត្តរសម្បត្តិយ៉ាងនេះ ក៏អាស្រ័យកំលាំងកោគសម្បុទជាហេតុដូចគ្នា ។

មនុស្សជាតិម្នាក់ ។ ដែលបានកើតមកជាមនុស្សហើយ ត្រូវសម្ងាសម្ពុទ្ធទ្រង់ត្រាស់ថា ត្រូវដម្កល់ខ្លួនតាមវ័យរបស់ខ្លួន ទើបចំរើនជាសុខបាន ។

បុគ្គលឯណាដម្កល់ខ្លួនឯងមិនត្រូវតាមវ័យរបស់ខ្លួន បុគ្គលនោះមុខជាបានទុក្ខយ៉ាងធ្ងន់ ។ ឯវ័យនោះមាន ៣ បើតាមគម្ពីរវិសុទ្ធិមគ្គត្រង់បញ្ញានិទ្ទេសព្រះពុទ្ធឃោសាចារ្យ លោកតំណត់យកតាមអាយុរបស់មនុស្សចំនួន ១០០ ឆ្នាំ មកបែងជា ៣ ជាន់ គឺជាន់ដំបូងតំណត់តាំងពីឆ្នាំដែលកើតរៀងទៅដល់អាយុ ៣៣ ឆ្នាំ ហៅថា "បឋមវ័យ" វ័យជាដំបូងនេះ ត្រូវស្វះស្វែងរករៀនដម្រែះវិជ្ជាឲ្យចេះដឹងអក្សរសាស្ត្រសម្រាប់កត់ត្រាផ្សេងៗ ឲ្យចេះភាសាសាសន៍ សម្រាប់និយាយដោះស្រាយការផ្សេងៗ ឆ្លើយឆ្លងទាក់ទងទៅវិញទៅមករកគ្នានៃមនុស្សជាតិផ្សេងៗ ឲ្យចេះលេខ-ក្បាច់នព្វន្ត សម្រាប់គិតគូរពាក់ព្រៀការងារទាំងពួង, ឲ្យចេះជញ្ជីងនាឡិ-ហាប រង្វាស់រង្វាល់ជាដើម សម្រាប់លក់ដូរជួញប្រែកែច្នៃចំណូលចំណាយឲ្យចេះស្ទាត់ជំនាញក្នុងបឋមវ័យនេះ ។

ជំនាន់ទីពីរតាំងពីអាយុ ៣៤ ឆ្នាំ រៀងទៅដល់អាយុ ៦៧ ឆ្នាំ ហៅថា "មជ្ឈិមវ័យ" គឺវ័យតាំងទៅជាកណ្តាលនេះ ជាវ័យត្រូវយកដម្រែះវិជ្ជារបស់ខ្លួននោះ មកតាំងព្យាយាមចំប្រឹងខ្នះខ្នែងស្វែងរកកោគសម្ប័ទដោយជំនួញជួញប្រែ តាមផ្លូវទឹក-ផ្លូវគោក សន្សំទុកជាក់ច្បាស់សម្ប័ទ

មាននៅកុះករឡើង ឬ ទឹងពង្រីកទ្រព្យសម្បត្តិដែលរកបាននោះ ឲ្យមានប្រយោជន៍ធំទូលាយតទៅ ។

ដំនាន់ទី ៣ គឺកំណត់តាំងពីអាយុ ៦៨ រៀងទៅដល់អាយុ ១០០ ឆ្នាំ ហៅថាបច្ឆិមវ័យ" គឺវ័យតាំងនៅទីបំផុត វ័យនេះមិនមែនជាវ័យត្រូវរកត្រូវរៀនទេ ប្រាកដជាវ័យត្រូវទទួលផលជាសុខគ្រប់ប្រការ អំពីគុណដម្រែវិជ្ជានឹងផលនៃកោគសម្ប័ទ ។

កាលបើបុគ្គលដំកល់ខ្លួនមិនត្រូវតាមវ័យ បឋមវ័យជាវ័យត្រូវរៀនសូត្រដម្រែវិជ្ជាត្រឡប់ទៅជាតាំងខ្លួនស៊ីផឹក ដើរលេងល្បែងផ្តេសផ្តាសគាល់តែខ្លួនកន្ទុងផុតបឋមវ័យនេះទៅ ខ្លួនក៏ធ្លាក់ចុះទៅក្នុងកណ្តាប់ដៃលង់ខ្ទៅ ។

កាលតាំងនៅក្នុងមជ្ឈិមវ័យ គឺជាវ័យត្រូវរកកោគសម្ប័ទ ត្រឡប់ជាស្ទុះស្ទែងរករៀនដម្រែវិជ្ជាវិញ ធ្វើម្តេចនឹងបានគាន់ពេលសម័យយករិជ្ជាការនោះ មកប្រើការបានដូចបំណង ឬថាវល់ប្រព្រឹត្តលេងអបាយមុខដែលជាគ្រឿងនាំមកនូវសេចក្តីវិនាស, គឺជាអ្នកវល់នឹងលេងស្រី ជាអ្នកវល់លេងស៊ីផឹក។ ស្រា ជក់អាកៀន គ្រឿងញៀន - គ្រឿងស្រវឹង, ជាអ្នកវល់លេងវ៉ៃ ប្រដាស៊ី - សង ។ ជាអ្នកវល់ដើរលេងជាមួយនឹងមនុស្សពាល - អាក្រក់ យកមកជាមិត្តរបស់ខ្លួន ។ គ្មានបានឧកាសរកទ្រព្យសម្បត្តិអ្វីសោះ គាល់តែខ្លួនកន្ទុងផុតមជ្ឈិមវ័យនេះទៅ ក៏ធ្លាក់ចុះទៅកណ្តាប់ដៃនៃសេចក្តីក្រវេហមរហាមកើតទុក្ខវេទនាជាទីបំផុត ។

កាលតាំងនៅក្នុងបច្ចិមវ័យ ជាវ័យត្រូវបុគ្គលខ្ជួលផល គឺសេចក្តីសុខគ្រប់យ៉ាង ។ ឯបុគ្គលខ្លះបានសេចក្តីសុខអំពីណា ព្រោះវៃលែតែដេកថ្ងូរអំពីលូង នឹងសេចក្តីទីទ័លក្រដកបដល់ស្ងាប់ប៉ុណ្ណោះ ។

បុគ្គលសេពគប់ជនពាល រមែងលិចចុះក្នុងសេចក្តីវិនាសក្នុងលោកនេះនឹងលោកខាងមុខ ។ បុគ្គលសេពគប់ជនជាបណ្ឌិត រមែងដល់នូវសេចក្តីចំរើនក្នុងលោកនេះ នឹងលោកខាងមុខជាប្រាកដ ។ ដូចបានសំដែងមកហើយពីខាងលើនេះ សូមឲ្យពុទ្ធបរិស័ទនឹងយុវជន-យុវនារីរួមជាតិតាំងឡាយ ស៊ុះក្រោកឡើងចាកសេចក្តីខ្ជិល ចូរខំតាំងខ្លួនរៀបខ្លួនប្រកបកិច្ច ឲ្យត្រូវតាមលំដាប់វ័យ ដែលបានសំដែងមកនេះចុះ ទើបអ្នកនឹងបានចំរើនក្នុងលោកនេះ នឹងលោកខាងមុខជាប្រាកដមិនខាន ។

ធម្មទេសនាចប់ប៉ុណ្ណោះ

សប្បុរិសោ សុភំ ហោតុ វិឌ្ឍន្តុ សព្វេបិ ពុទ្ធសាសនេ

សូមសេចក្តីល្អគ្រប់យ៉ាង ចូរមានដល់អស់លោក-អ្នកសប្បុរសទាំង-ឡាយគ្រប់ពេលវេលាកុំបីចន្លោះ សូមឲ្យពួកពុទ្ធបរិស័ទគ្រហស្ថ-បព្វជិតទាំងអស់ ចំរើនសុខសួស្តីជយមង្គលក្នុងព្រះពុទ្ធសាសនាទៅហោង ។

អត្តានុទិដ្ឋិ

អ្នកឧកញ៉ាឥស្សរៈដង្ហែ សំ-ស៊ុន

ជាអ្នកប្រែរៀបរៀង

រឿងនេះជារឿងចំឡែក គួរពុទ្ធមាមកៈត្រិះរិះពិចារណាដោយប្រាជ្ញាឲ្យបរិបូណ៌ចុះ ព្រោះអ្នកសិក្សាផ្លូវព្រះពុទ្ធសាសនា ដោយភាគច្រើនប្រកាន់យកតែត្រង់អនត្តា ឯអត្តាវិញ ច្រើនតែថាគ្មានក្នុងទីពាំងពួង ព្រោះអាស្រ័យហេតុនេះ ទើបខ្ញុំយករឿងអត្តាមកអធិប្បាយជូនស្តាប់ ប្រែចេញពីសៀវភៅសៀមឈ្មោះថេរបញ្ហត្តិ ទំព័រលេខ ២៨ ។

អត្តានុទិដ្ឋិ ពាក្យនេះប្រែថា "សេចក្តីឃើញថាអត្តាមាន" សំគាល់យកសេចក្តីយល់ឃើញក្នុងខន្ធ ៥ ដែលជាសំខាតធម៌ថាជាខ្លួនប្រាណគឺខន្ធ ៥ ទុកជាអត្តា ជាខ្លួនប្រាណយើងនេះ; តាមយល់ឃើញនេះចាត់ជាសេចក្តីឃើញក្រៅអំពីអរិយសច្ចធម៌របស់ព្រះសម្មាសម្ពុទ្ធ ។ តែសេចក្តីចូលចិត្តរបស់អ្នកដឹងភាគធំក្នុងផ្លូវព្រះនិព្វាន ឃើញថាយើងឬខ្លួននោះមិនមានក្នុងទីពាំងពួង ហើយខាញ្ជក់សេចក្តីនឹងពាក្យផ្សេងៗតាមដែលបានដួបប្រទះដូចពាក្យថាអនត្តា ដែលប្រែថា "មិនមែនខ្លួន" នោះទុកជាឮស្តាប់ហាន ពាំងដឿតាមគ្នាខ្លះ ថែមពាំងដំរាជាច្រើនក៏សំដែងចេញជាល្អល្អាចទៅផង សឹងតែជាប់ដោយសេចក្តីឃើញឆ្នូងនោះឯង ។ តាមដែលបានសង្កេតមក រឿងនេះ ជាផ្លូវគាចសាហាវដ៏ខ្លាំង

បើអ្នកឯណាយល់ឃើញថាយើងមាន ខ្លួនមាន អ្នកនោះនឹងត្រូវជាអ្នកបណ្តុះទិដ្ឋិយ៉ាងនោះតែម្យ៉ាង ជាប់ការសមាគមគប់រកគ្នា ព្រោះសេចក្តីយល់ឃើញបែកគ្នា ឲ្យខ្ជួលធាយជាមិច្ឆាទិដ្ឋិក្នុងព្រះសាសនា, អាស្រ័យហេតុនេះ ទើបត្រូវតែនិយាយទៅតាមគ្នាថា "យើងមិនមានខ្លួនមិនមាន" ។

ក៏កងសៀវភៅច្បាប់នេះ បានប្រកាសសេចក្តីយល់ឃើញថា "យើងមាន ខ្លួនមាន" ដូចនិយាយថា "កាលបានសេចក្តីបរិសុទ្ធិជាវិភគធម៌ហើយ ក៏កប់ថាបានយើង ឬ អត្តា (ខ្លួនជ្ញាណ) ដែលពិតជ្រាកដ", ដូច្នេះមិនត្រូវគេតិះដៀលថាទុត្តរិ បញ្ញត្តិយើង ឬ អត្តាហើយឬ? ព្រោះគេតែងនិយាយប្រដៅគ្នាថា ឲ្យដកយើង ដកខ្លួនចេញ កុំធ្វើសេចក្តីចូលចិត្តថា "យើងមាន ខ្លួនមាន" ទើបចាត់ថាឃើញត្រូវត្រង់ពិតៗ, សូម្បីតែព្រះនិព្វានដែលជាវិសង្ខារក៏ថាយើង ឬ អត្តាមិនបាន ប្រៀបថាមិនមានកងទីតាំងពួន ។

ក៏សេចក្តីឃើញថា ខ្លួនមិនមាននោះ តើទុកជាត្រូវដូចម្តេចកើត រើនិយាយឲ្យអ្នកស្តាប់ៗ មិនចូលចិត្តសោះ ព្រោះរកអ្វីភ្ញាក់មកជាគោលមិនបាន និយាយរលំដូចទឹកកងអាង ស្តាប់ទៅដូចនិយាយលេងបញ្ឆោតមនុស្សចំពោះមុខ និយាយថា "យើងមិនមាន ខ្លួនមិនមាន" យ៉ាងនេះយ៉ាងនោះហើយ ក៏រត់ពីយើង ឬ រត់ពីខ្លួនទៅមិនផុត ត្រូវប្រឈូលមក

រកយើង រកខ្លួនវិញ; សែនខ្ពើមយើង ខ្ពើមខ្លួននេះហើយ តែដល់ទៅពឹងអ្នកណានៅពឹងមិនបាន ក៏ត្រឡប់ចូលមកពឹងយើង ពឹងខ្លួនវិញ នេះជាទំដ្ឋ។ នេះបើជាមនុស្សវិញ គេថាមនុស្សមិនល្អ; អ្នកទេសន៍តែងសំដែងធម៌ពោលបដិសេធយើង ឬ ខ្លួនដោយប្រការផ្សេង។ ។ យើង ខ្លួន រមែងមិនមានព្រោះហេតុនេះឯង ។ ល្មមតែឮទើបពោលថាយើងទៅបង្អាប់យកឯខ្លួនឯង, ដែលពិត យើង ខ្លួន នោះថាមិនមានទេ មានតែហេតុផ្តេសផ្តាសពាំងនោះ. បើថាយើងថាខ្លួនមិនមានហើយបានយើងពីណា ទៅបង្អាប់យើងឯណា ។ ក្នុងទីបំផុតនៃទេសនាពោលថា "យើងនឹងបានទទួលផលដោយគាប់ចិត្ត ព្រោះសេចក្តីឃើញត្រូវថា យើង ខ្លួន មិនមាននោះ ខ្លួនរមែងសុខសម្រាន្តគ្រប់ទិវាកត្រីកាល" ។ សេចក្តីដែលបានពណ៌នាមកនេះ ហៅសែនពិបាកស្តាប់ ។

មនុស្សខ្លះដើរតួត អាចតាញយកពុកមាត់អណ្តើកស្មែនទន្យាយមកត្រៀបធ្វៀបឲ្យឃើញថា រកយើងឬខ្លួននោះ ដូចមនុស្សដែលស្មែនរកពុកមាត់អណ្តើកស្មែនទន្យាយ រមែងមិនភ្លាសម្រេចដូចសេចក្តីប្រាថ្នា ។ រឿងនេះមិនមានអ្នកណាប្រកែកគ្រាន់, ក៏មាត់អណ្តើកធម្មជាតិសាងមកមិនមានពុកមាត់, ក្បាលទន្យាយ ធម្មជាតិសាងមកក៏មិនមានស្មែនដូចគ្នា, ។ នោះជាសេចក្តីពិត អ្នកណា ។ ដែលឆ្ងាប់

ឃើញមាត់អណ្តើកនឹងក្បាលទន្សាយហើយ កំត្រូវត្រមះទ្រួលថាមិនមានពិតមែន តែថាគ្រាន់តែរកពុកមាត់នៅមាត់អណ្តើក ឬស្នែងនៅក្បាលទន្សាយមិនបានប៉ុណ្ណោះ ម្តេចក៏ប្រញាប់បដិសេធថាពុកមាត់នឹងស្នែងក្នុងទីតាំងតួងមិនមានដែរ? បើពុកមាត់នឹងស្នែងមិនមានពិត ហើយពាក្យបញ្ញត្តិហៅពុកមាត់នឹងស្នែងនោះក៏មិនមានដែរ, តែដែលពិត ពុកមាត់នឹងស្នែងនោះមាន ព្រោះមិនមានតែត្រង់មាត់អណ្តើកនឹងក្បាលទន្សាយប៉ុណ្ណោះ, រកពុកមាត់នៅទីមាត់អណ្តើកមិនបាន ក៏នៅទីមាត់ឆ្នាមាន នៅមាត់យើងឯងក៏មានគរគោក, រកស្នែងនៅទីក្បាលទន្សាយមិនបាន នៅទីក្បាលគោក៏មានស្នែង នៅក្បាលក្របីសក៏មានស្នែង; បើសិនជាពុកមាត់មិនមានក្នុងទីតាំងតួងពិតហើយ យើងក៏មិនស្គាល់ពុកមាត់ ធ្វើម្តេចនឹងនិយាយបានថា អណ្តើកមិនមានពុកមាត់ដូច្នេះកើត, បើសិនជាស្នែងមិនមានក្នុងទីតាំងតួងពិតហើយ យើងក៏មិនស្គាល់ស្នែងអ្វី ម្តេចនឹងនិយាយបានថា ទន្សាយមិនមានស្នែងដូច្នេះកើត, ព្រោះតែយើងធ្លាប់ស្គាល់ពុកមាត់នឹងស្នែងមកហើយ ទើបយើងនិយាយចេញមកបានថាពុកមាត់អណ្តើក ស្នែងទន្សាយមិនមាន ។ ព្រោះដូច្នោះ ពុកមាត់នឹងស្នែង រមែងមានជាប្រាកដ នឹងបដិសេធថាមិនមានក្នុងទីតាំងតួងនោះមិនបាន គ្រាន់តែគន់រកមិនសព្វប៉ុណ្ណោះ ។ ចុះនេះដូចម្តេចមិញ? យើងឬអត្តានោះមាននៅជាប្រាកដ ព្រះសម្ពុទ្ធ

ខ្ញុំដូចយើញ ខ្ញុំស្គាល់ហើយ ទើបគ្រាស់ប្រដៅមិនឲ្យប្រកាន់ខ្ជាប់ក្នុងខន្ធទាំង ៥ ដោយព្រះពុទ្ធដូច្នេះថា "នុ៎ះមិនមែនយើង នុ៎ះមិនមែនរបស់យើង នុ៎ះមិនមែនអត្តា (ខ្លួនប្រាណ) របស់យើងដូច្នេះ ។ ពាក្យប្រដៅយ៉ាងនេះ គឺព្រះអង្គខ្ញុំប្រដៅយើង ប្រដៅអត្តា (ខ្លួនប្រាណ) នុ៎ះឯង ។ បើសិនជាយើងមិនមាន ខ្លួនមិនមានហើយ ពាក្យប្រដៅដូច្នោះក៏គ្មានប្រយោជន៍ ព្រោះមិនមានយើង មិនមានខ្លួននឹងស្តាប់ ព្រោះដូច្នោះយើងឬខ្លួននោះ ត្រូវមានជាពិតប្រាកដ, តែនឹងស្វែងរកក្នុងខន្ធទាំង ៥ ឬសង្ខតធម៌ឯណា ។ នោះមិនបានទេ ដូចការរកពុកមាត់នៅទីមាត់អណ្តើក នឹងរកស្នែងនៅទីក្បាលទន្សាយ រមែងមិនបានសម្រេច ដូចសេចក្តីបំណង, ព្រោះសង្ខតធម៌ទាំងឡាយ ជាចំណែកខាងបដិសេធដោយសេចក្តីជារបស់មិនល្អ មានទុក្ខជាសភាពមិនថាវៈ មិនមែនយើង មិនមែនខ្លួន រមែងត្រូវបានក្នុងព្រះនិព្វាន, ព្រះនិព្វាននោះឯងជាយើង ជាខ្លួន ។ ដូច្នេះកាលបើបដិសេធសង្ខារដែលជាតែយលោកិយហើយ ក៏ត្រូវទទួលព្រះនិព្វាន ដែលជាតែយលោកុត្តរ ព្រោះខាងមួយល្អ ខាងមួយអាក្រក់ ឬខាងមួយខ្មៀង ខាងមួយមិនខ្មៀង ខាងមួយមិនស្តាប់ តែម្ខាងខ្មៀតស្តាប់, ដូច្នេះបើខាងទទួលគឺមែន មិនមានហើយ ខាងបដិសេធគឺមិនមែន នោះក៏មានមិនបាន, បើអត្តា (ខ្លួនប្រាណ) មិនមានប្រាកដហើយ អនត្តា (មិនមែនខ្លួន) នោះ

ក៏មិនមានដូចគ្នា ។ ប្រការមួយទៀត បើព្រះនិព្វានមិនជាយើងមិនជាខ្លួនហើយ អរិយមគ្គ ៨ ប្រការនោះ មានគុណធ្វើអ្វី? ព្រោះអរិយមគ្គជាហេតុនៃវិគតធម៌ប្តនិព្វាន, តាលក្សាហ៍ធ្វើហេតុគឺអរិយមគ្គ ឲ្យចំរើនជាស់ក្នុង រហូតកើតផលគឺព្រះនិព្វាននោះឡើងហើយ ក៏បដិសេធបង់ទៀតថាមិនមែនជាអនត្តា (មិនមែនខ្លួន) យកអ្វីគេះ? ដូចគឹកនឹងសាប៊ូជាគ្រឿងលាងជោកដម្រះញើសក្អែលកង្វក់ពងកាយ បើសេចក្តីបរិសុទ្ធិម៉ត់ចត់ជាផលនៃការលាងដម្រះ មិនជាយើងហើយ គឹកនឹងសាប៊ូរកប្រយោជន៍កន្លែងនោះគ្មាន ។

អស្មិមាន: ប្រែថា "សេចក្តីប្រកាន់ថាយើងជា" គឺយើងជានោះជានេះ ដូចជាខ្លួន ៥ ឬការៈទីតែងតាំងឡើងជាកិលេសក្នុងខ្លាំងតែទៅចូលចិត្តអស្មិមាន:នោះថា "សេចក្តីប្រកាន់ថាយើងមាន" ទើបពោលប្រដៅគ្នាថាយើងមានមិនបាន ត្រូវដកយើងចេញ ទើបផុតចាកកិលេសនោះ នេះជាសេចក្តីចូលចិត្តខុស ។

(មានត)

ព្រះមហា ឱម-ន៉ាគ្រី

ឃុំស្វាយចេ៉ា ស្រុកសង្កែ ខេត្តបាត់ដំបង រៀបរៀង

ឃុនសុវត្ថិវ៉ៃទី យ៉ូរ-អ៊ុន ពិនិត្យកែ

---

១ – បុគ្គលណានៅនាលោកនេះ សំឡាប់សំឡេះបេះបំបាត់
ច្រហារដីវាដីវិតសត្វ កាប់កាត់ពិឃាតច្របូសព៉ាយ ។
បុគ្គលនោះឯងលុះស្លាប់ទៅ វាមែងកើតនៅក្នុងអបាយ
បើកើតជាមនុស្សតែងអន្តរាយ ជីវិតនឹងក្លាយអាយុខ្លី ។

២ – ជនណាវៀរបាណាតិបាត មិនបានពិឃាតសត្វអ្វី ។
ដោយចិត្តអាណិតគិតច្រណី សត្វលើផែនដីផងនានា ។
ជននោះលុះផុតរលត់ទន្ទ តែងបានទៅកាន់ស្ថានសួគ៌ា
បើកើតជាមនុស្សធម្មតា លោកថាតែងមានអាយុវែង ។

៣ – ជនណាបៀតបៀនធ្វើបាបសត្វ ជាល់តប់ព្យាត់ទាត់ធាក់ប៉ែង
ឲ្យឈឺឲ្យថ្វាឲ្យសង្រែង ឲ្យក្រែងខ្លួចខ្លាចអំណាចខ្លួន ។
ជននោះលុះស្លាប់វិលាណា តែងវង្វេងទុក្ខាអបាយបួន
បើកើតជាមនុស្សតែងឈឺខ្លួន រោគារុកកួនច្រើនឈឺចាប់ ។

៤ – ជនណាមានចិត្តអាណិតសត្វ មិនវាយមិនវាត់មិនចាក់កាប់
មិនបៀតបៀនសត្វឲ្យឈឺចាប់ ជននោះលុះស្លាប់វិលាណា ។

តែងតែទៅយោនយកកំណើត ឧប្បត្តិកើតជាទេវតា
បើកើតជាមនុស្សស្រាន្តសុខា លោកថាមិនសូវមានទោសគេ ។

๕ - ជនណាច្រើនគ្រាន់ច្រេឡាតចិត្ត ប្រកាន់ធម៌តឹងអាងមានោ
ក្រញ៉ូក្រញ៉ូវចិត្តពាលោ ខ្ពង់ខ្ពស់នោះកើតកន្លែងវេត ។
បើបែរកើតជាមនុស្សធម្មតា រូបពង់មុខាច្រើនអាត្រគក់
មុខមាត់ដូចមៀមចិត្តតក់ម៉ក់ សម្បុរអាត្រគក់សាច់សោះគ្រោះ ។

๖ - ជនណាមិនសូវចិត្តយោរយៅ មិនមានមួម៉ៅក្តៅកន្លែងទោះ
ចិត្តកើតចំការត់ឲ្យសូន្យសោះ ជនទោះលុះដល់ស្លាប់ដីវិត ។
តែងតែទៅកើតនៅសួគ៌សុខសាន្ត បើបានកើតជាមនុស្សពិត
ច្រើនមានរូបល្អសម្បុរល្អិត ជាទីត្រូវចិត្តគាប់នេត្រា ។

๗ - ជនណាផ្តេសផ្តាសផ្តើមទឹកចិត្ត តែងគិតឈ្នានិះរិះឫស្យា
ច្រណែនទឹងលាភ, យសសក្តា, សរសើរ, សុខា របស់គេ ។
ជនទោះលុះអស់ជីវិតទៅ រមែងកើតនៅក្នុងនិរយៈ
បើកើតជាមនុស្សៗ ច្បាំងខ្លៃ ពុំមានយសទេច្រើនថោកទាប ។

๘ - ជនណាមិនមានចិត្តឫស្យា មិនឈ្នានិះការណ៍គិតគន់លាភ
សក្ការបូជាតាំងខ្ពស់ទាប ជាលាភរបស់អ្នកដទៃ ។
ជនទោះលុះស្លាប់ដីវិតទៅ ទៀងតែកើតនៅសួគ៌ាល័យ
បើកើតជាមនុស្សក៏មនុស្សថ្លៃ ច្រើនមានសិរីសក្តាធំ ។

៩ - ជនណា មានចិត្តកំណាញ់សូរ ម៉ូ មិនមានអាសូរយោចកស្រមណ៍
មិនដែលឲ្យទានដល់អ្នកសុំ ដោយខ្លាចរលំរលាយទ្រព្យ ។
ជននោះលុះដំរិតក្បាលក្រយ ទឹងទៅកើតព្រហ្មគ្គតិជាប់
បើកើតជាមនុស្សតែងក្រទ្រព្យ ពីកើតទាល់ងាប់ពុតិតក្តាត់ ។

១០ - ជនណា មានចិត្តល្អទូលាយ ចំណែកចំណាយថាយសម្បត្តិ
ឲ្យទានដល់សង្ឃអ្នកខ្ចាត់ក្បាត់ បព្វជិតនៅវត្តឬព្រាហ្មណ៍ស្រមណ៍ ។
ជននោះលុះស្លាប់ដំរិតទៅ រមែងកើតនៅសួគ៌ឧត្តម
បើកើតជាមនុស្សក៏សំបូរសម សុភសម្ផស្សសម្បូណ៌សម្បត្តិគ្រប់ ។

១១ - ជនណា មាន:កោងក្រអឹត កិរិយាឫកឡឹតមិនគោរព
មិនក្រាបសំពះថាស់លើសលុប ឬអ្នកគួរគប់មានសីលវន្ត ។
ជននោះលុះដល់ដំរិតស្លាប់ ត្រូវជ្រុលថាទៅទុគ្គតិធ្ងន់
បើកើតជាមនុស្សតែងអាប់អន់ តែកូលទាបទន់អន់ពូជពង្ស ។

១២ - ជនណា សុភាពរាបរម្យទម គោរពបង្គំកិក្ខុសង្ឃ
កោតខ្លាចត្រីឝ្ករាវិយូរលង់ មិនមានទ្វេនង់ច្រៀងបះបរ ។
ជននោះលុះដល់ស្លាប់ដំរិត ទឹងទៅសណ្ឋិតសួគ៌សោឡស
បើកើតជាមនុស្សក៏ស្រួចស្រស់ តែកូលខ្ពង់ខ្ពស់មានយសស័ក្តិ ។

១៣ - ជនណា មិនស្មោគមសេពគប់ ទឹងប្រាជ្ញប្រសព្វពន្យល់ជាក់
ចូលចិត្តគប់ខ្លៅពាលអប្បស័ក្តិណ៍ ជាអ្នកកាប់ចាក់អប្បាយមុខ ។

ជននោះលុះស្លាប់ជិវិតទៅ តែងតែកើតនៅទីទោសទុក្ខ
បើកើតជាមនុស្សអវិជ្ជាលុត លង់ទៅមួរមុខអប្បុ្រជ្ញា ។
១៤- ជនណាចូលចិត្តសិក្ខាគម បណ្ឌិតឧត្តមមានបញ្ញា
ហើយចំរើនសូត្រសួរសិក្សា ធម៌អាថ៌ចុះសូត្រផ្សាយបុណ្យ ។
ជននោះលុះដល់ស្លាប់ជីវិត តែងទៅកើតពិតសួគ៌សុខសុន្ទរ
បើកើតជាមនុស្សមិនយ៉ាកចុន មានប្រាជ្ញដោះកុនចេះអាថ៌ធម៌ ។

និគមវិបាក:

អំពើបុណ្យបាបបើបានសាង តែងជាពស្តាងខាងឲ្យផល
កម្មថ្មីកម្មចាស់ផ្ទាស់ប្តូរផ្តល់ កុំសង្ស័យឆ្ងល់នាំសូញសាញ ។
ព្រោះសត្វមានកម្មប្រចាំប្រាណ គេចដៀសមិនបានប្រាននមិនគ្រាញ
នរណាធ្វើបាប បាបប្រាកញ ឲ្យទុក្ខទោសលាញវិនាសលាក ។
នរណាសន្សំធ្វើបុណ្យ បុណ្យនោះជាគុនវិញជាកប
សុខទុក្ខផ្ទាស់ប្តូរតាមបុណ្យបាប សូមគិតសូធ៌ស្មាបគធ៌ឃើញអើយ ។

លេខ្ចីតគ្រែនជាតិ

កាព្យឃាក្យពិតាមលំដាប់អក្សរ

ឃុនបណ្ណាន្ទុរក្ស ប៊ុ - ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ក – កបតើតមកជាកូនខ្មែរ

ខ – ខំគិតបែរប្រែគំនិត

គ – គួរសេពគប់លោកបណ្ឌិត

ឃ – ឃើញត្រូវពិតរួចសឹមថា ។

ង – ងើបមើលជាតិខ្មែរដូចគ្នា

ច – ចូរសមគ្គាជួយរដ្ឋា

ឆ – ឆបប្រកបដោយបញ្ញា

ជ – ជួយស្តីថាតឿនកូនចៅ ។

ឈ – កុំឈប់ស្ងៀមមើលចំណាំ

ញ – ញឹកខាងចាំពាក្យប្រដៅ

ដ – ដឹងឲ្យគ្រប់កុំល្ងង់ខ្លៅ

ប – ថែមចេះជ្រើរើសមុខ ។

ឋ – កុំដុកដាន់ដោលគ្នាឯង

ឍ – ងើបកខែងចង់ស្រណុក

ណ – ណាត់ញុះញង់ឲ្យអុកឡុក
ត – តោងសំពុកគិតឲ្យជ្រៅ ។
ថ – ថប់ៗមុខក្រែងវិនាស
ទ – កុំទីសាសចោលលំនៅ
ធ – ធ្វៀបដូចទូកឬសំពៅ
ន – នៅមិននឹងមួយកន្ទែង ។
ប – បើជ្រានធំកុំស្អប់តូច
ផ – ផាត់កាត់ខូចចេញឲ្យស្តែង
ព – ពិតជាប្រុសទំប៉ើងប្រែង
ភ – ភ័យខ្លាចក្រែងជាតិខ្ញែក ។
ម – មកពីចិតទំរៀនសូត្រ
យ – យោងឲ្យរបូតប៉ើងរិះរេ
រ – រកទុជាយកលគ្នាន់គ្នេរ
ល – លើកជាតិគេជាតួយ៉ាង ។
វ – កុំវិលវល់ទៅតាមខ្យល់
ស – សូមកុំធ្វេសនឹងសំណាង
ហ – ហាមចិត្តខ្លួនកុំឲ្យអាង
ឡ – កុំឡុងឡាងទាស់ខែងគ្នា ។

អ – អង់ស្នងជាតិចាស់បុរាណ

អា – អាងកូមិហានៃវិជ្ជា

ឥ – ឥតប្រយោជន៍កុំនឹកនា

ឦ – ឲ្យការនាំតែចំរើន ។

ឧ,ឩ– ឧស្សាហ៍តែងក្បួនច្បាប់

ឫ,ឬ– កាន់កាប់ការឲ្យច្រើន

ឭ,ឮ– ត្រូវខំធ្វើឲ្យកើន


ឯ,ឰ– ចំរើនប្រទេសជាតិ ។

ឱ – ឲ្យសុខាដល់គ្នីគ្នា

ឲ – ឧបរាំងរាកុំឲ្យឃ្លាត

អុំ,អំ– ចូរខំកុំរវាំង

អាំ,អះ– ខើបជាតិខ្មែរថ្កើងអើយ ! ។



ព្រះមហាឧត្តមរិដ្ឋា ធិលញ្ញាណោ ប៊ុង-ប៉ែម

អាចារ្យសាលាជាលីវង់ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាគុរ៍កូរ ប៊ូ-ប៉ូ នៅព្រំទ្វីសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(ត្រមក)

ឯទុជ្ឈាយកែវៃដ៏សំខាន់នោះ គឺត្រូវខ្ជល់ខ្ជាយសំដែងពាក្យប្រៀនប្រដៅអប់រំគេឲ្យដឹងគោលនៃការរៀបរៅ នឹងគុណនៃសេចក្តីស្មោះត្រង់ នឹងកេពីធីផ្សាស់និស្ស័យរៀបរៅឲ្យត្រឡប់ទៅជានិស្ស័យទៀងត្រង់វិញ ។ បើគេឃើញគោលនឹងគុណត្រឹមតាំងពីធីផ្សាស់និស្ស័យហើយ ក៏នឹងលះបង់និស្ស័យរៀបចេញ ហើយប្រព្រឹត្តតាមនិស្ស័យទៀងត្រង់វិញឯង ។ បើមនុស្សយើងគោរពសេចក្តីទៀងត្រង់ នាំគ្នាយកសេចក្តីទៀងត្រង់មកប្រើប្រាស់តិចបំផុតក៏ឲ្យបានស្មើនឹងការរៀបរៅហើយ មនុស្សយើងគង់តែឃើញថា សមគួរនឹងរាងជាមនុស្សមែន ។ លោកដែលនឹងកើតចម្រើន ក៏ព្រោះតែសេចក្តីរៀបរៅ, ដែលនឹងសូន្យរៀបរាយ ក៏ព្រោះតែសេចក្តីស្មោះត្រង់ ហើយលោកនឹងឈានឆ្ពោះទៅកាន់សន្តិសុខក្នុងសាសនាប្រកបដោយ ក៏ព្រោះតែសេចក្តីស្មោះត្រង់ដែរ ។

ការស្មោះត្រង់ជាហេតុឲ្យរុងរឿង មានការស្មោះត្រង់ ទៀងទាត់ ជាក់លាក់ពិតៗ នៃអធ្យាស្រ័យនឹងសេចក្តីប្រព្រឹត្តិរបស់បុគ្គលជាលក្ខណៈ មានអាការផ្សាយស្មើភ្លឺរុងរឿងច្បាស់ចាកមន្ទិលទោស ទឹងការពុំខ្ជិលគប់យ៉ាង ជាដួងវិស្ម័យដ៏ភ្លឺថ្លានៅដុំវិញ ធ្វើឲ្យទឹកមុខរបស់មនុស្សស្មោះត្រង់ស្អាតផូរផង់អស់សៅហ្មង ជារបស់បរិសុទ្ធក្នុងខ្លួនឯងនឹងនៅជិតបង្កើយត្រូវការពេលណាបានពេលនោះ មិនចាំចាប់គ្រាប់ស្វែងរកទេ ។ មនុស្សស្មោះត្រង់ រមែងកាន់យកសច្ចធម៌ជាទីតាំង រក្សាសេចក្តីទៀងត្រង់ជាធំ មិនភ្លេងសំដែងខ្លួនឲ្យល្អលើសសភាពពិត រក្សាខ្លួនឯងនឹងការងារ របស់ខ្លួនគប់យ៉ាងឲ្យដូចគ្នាតែ ១ ដោយរាប់អានសេចក្តីស្មោះត្រង់ថាជាគោលចារឹកក្នុងការអាជីវៈទូទៅ ។

ការវៀចវេរជាហេតុឲ្យងងឹត មានការវៀច ង លំអៀងភ្លេងក្លាយប្រែប្រួលត្រឡប់ត្រឡិន នៃអធ្យាស្រ័យនឹងដំណើរប្រព្រឹត្តិរបស់បុគ្គលជាលក្ខណៈ មានអាការងងឹតងងល់បិទបាំងខូចភ្នែក បែកចិត្ត លាក់លាមលបលួច មានទឹកមុខដូចជាគូសធ្យូងជាគ្រឿងចំណាំឲ្យស្គាល់ថាជាមនុស្សពាល ។ ការវៀចវេរជារបស់ផ្សំដែលលំបាកចាប់លំបាកផ្សំ តែបើរកមូលហេតុបានហើយ គង់នឹងប្រកបបួលគ្នាឲ្យបានរូបសណ្ឋានសមហេតុសមផលឡើង ។ ពាក្យកុហកតែមួយដែលពោលប្រៀបប្រដាយប្រកប ឲ្យប្រហែលនឹងសេចក្តីពិតនោះ ត្រូវយកពាក្យកុហកដទៃជាច្រើនទៀតមកប្រើផ្សំ ដើម្បីជួយបំភ្លឺ ។

អ្នកសំដែងសេចក្តីមិនពិត ដែលចាត់ថាជាមនុស្សរៀចវៃនោះ
ក៏ត្រូវតែប្រយ័ត្នខ្លួនខ្ចាតខ្ចាត់ចំណាប់ជានិច្ច ដូចគ្នានឹងអ្នកដែលឈរលើ
ជែកស្មួច ឬ មុខជាវដូច្នោះ សូម្បីនឹងថាខ្លួនអាចបិទបាំងសេចក្តីមិនពិត
ដោយការកូតកវប៉ំណាងនឹងបញ្ឆោតអ្នកដទៃឲ្យវង្វេងដៀកដោយ ។ ព្រោះ
ការរៀចវៃនោះ បើតាមពិតទៅ ត្រឡប់ជាបញ្ឆោតខ្លួនឯងវិញគឺសេចក្តី
ដឹងនោះ ធ្វើខ្លួនឯងឲ្យសាត់អណ្តែត បើកវស្តីនៃកំហុសឲ្យប្រាកដដល់
អ្នកដទៃ ។ ព្រោះវត្ថុដែលមិនគួរធ្វើនោះ បើនរណាដំនះធ្វើហើយ អ្នក
នោះក៏នឹងចូលក្នុងទំនងថា "ដំរីស្លាប់ ឃកចង្កើរជាំង" ដូចម្តេចនឹងជិត
បាន ឬដូចជាផ្សែងក្តៅង ដូចម្តេចនឹងគ្របទុកបាន ត្រូវប្រាកដចេញ
មកឲ្យឃើញជាក់ជាក់ជាមិនខាន ។

"អ្នកមានសេចក្តីទៀងត្រង់គ្រប់គ្រាន់ ជាមនុស្សល្អ គួរ
សរសើរពិត ។" នេះជាពាក្យប្រែចេញមកអំពី សុភាសិតថា:
"សាធុ រូបោ ប ប្បាសំសោ ទ្វារត្តយេន សច្ចេន" នេះឯង
ជាសេចក្តីស្មោះត្រង់ ដែលបំណងយកក្នុងទីនេះ មិនមែនសំដៅយកតែ
ការប្រព្រឹត្តទៀងត្រង់តាមផ្លូវកាយ ១ ទេ គឺត្រូវប្រកបដោយសេចក្តីស្មោះ
ត្រង់គ្រប់ទ្វារទាំងអស់ឲ្យដូចគ្នាទាំងខាងក្រៅទាំងខាងក្នុង ។ សេចក្តី
ស្មោះត្រង់មានប្រភេទតាមលក្ខណៈ ដែលប្រាកដក្នុងរូបបុគ្គលនោះ ៦
ប្រការ គឺ: ស្មោះត្រង់ចំពោះខ្លួនឯង, ស្មោះត្រង់ចំពោះកាយ, ស្មោះ

ត្រង់ចំពោះការងារ, ស្មោះត្រង់ចំពោះនាទី, ស្មោះត្រង់ចំពោះបុគ្គលនិង
ស្មោះត្រង់ចំពោះគណៈ ។

ស្មោះត្រង់ចំពោះខ្លួនឯង ការចង់ចុះខ្ពស់ ចង់បានសុខ ជា
តំណូលបំណងរបស់មនុស្សគ្រប់គ្នា គ្មាននរណាសូម្បីតែមួយតែម្នាក់ចង់បាន
អាក្រក់ឡើយ ។ តែបើចង់បានឲ្យដូចបំណង ត្រូវតែជាមនុស្សស្មោះ
ត្រង់ចំពោះខ្លួនឯង ប្រព្រឹត្តល្អឲ្យត្រង់គន្លឹះគោលបំណងរបស់ខ្លួនឯង
គឺធ្វើល្អវៀរអាក្រក់ ដើម្បីឲ្យខ្លួនបានល្អបានសុខផុតអំពីទុក្ខ ធ្វើអំពើល្អ
ដែលខ្លួនបំណងនោះឲ្យបានល្អទីបំផុត លះបង់អំពើអាក្រក់ឲ្យដាច់ស្រឡះ
និងវៀរអំពើអាក្រក់ឲ្យឆ្ងាយកៃលែង, កុំសាកល្បងកាលប្រព្រឹត្ត, សេចក្តី
ល្អយ៉ាងណា ត្រូវប្រព្រឹត្តធ្វើយ៉ាងនោះឲ្យពិតៗ កុំក្លែតក, ទៅចំពោះ
មុខគេប្រព្រឹត្តយ៉ាងណា សូម្បីកំចាំងមុខគេ ក៏ត្រូវប្រព្រឹត្តយ៉ាងនោះ,
កុំសង្ឃឹមក្នុងកាលដែលមិនបានទទួលផលនៃសេចក្តីល្អដែលខ្លួនប្រព្រឹត្ត,
កុំខ្ជិចប្តេជ្ញាចិត្តកុងកាលអ្នកដទៃពោលចាក់រុក ឬ ឡកឡឺយឲ្យ, សូម្បី
មានពួកច្រើនដឹកនាំទៅ ដើម្បីឲ្យឈ្នះចិត្តរបស់ខ្លួន ក៏កុំគោរ
ធន់តាម គួរគោរពតែក្នុងសេចក្តីល្អរបស់ខ្លួន និងរក្សាខ្លួនឲ្យតស៊ូនៅ
ល្អជានិច្ច ។ បើធ្វើបានដូច្នេះ ឈ្មោះថាលោក អ្នកជាមនុស្សពិតប្រាកដ
ខ្ជាប់ខ្ជួនក្នុងសេចក្តីល្អ មានសេចក្តីស្មោះត្រង់ចំពោះខ្លួនឯង អាចនឹង
ប្រព្រឹត្តសេចក្តីល្អបានយូរអង្វែង ។ (មានត)

មនុស្សវៀចវេរចំពោះខ្លួនឯង សូម្បីចង់ល្អ ក៏មិនអាចប្រព្រឹត្ត
សេចក្តីល្អឲ្យពេញលេញបាន ព្រោះថាចង់ល្អ តែបួលចិត្តធ្វើការងារ
លឹបលៗ លេងៗ ច្បិចៗ តិចៗ មិនជាដុំកំភួន ខ្ជិលច្រអូសចំពោះការងារ
ធ្ងន់ធ្ងរការងារធំៗ ដែលជាដុំកំភួន ខ្ជិលច្រអូសចំពោះការងារតូចតាច
ដែលមានដំឡៃច្រើន ដោយឃើញថាជាការងារថោកទាបជាការងារ
សម្រាប់ថ្នាក់កម្មករ ជាការងារដែលនាំឲ្យអាប់មុខ ។ គាំលចង់បានល្អ
តែមិនបានផលល្អភ្លាមៗ ហើយ ក៏កើតខឹឡាយកំឡាំងចិត្តលែងធ្វើការអ្វី
ឲ្យជាធំដុតទៅទៀត ប៉ុនតែខាងកុហកបញ្ឆោតខ្លួនឯង មានការខ្ជិល
ច្រអូសជាដើម។ សំគាល់ការខ្ជិលច្រអូសថាប្រសើរ ចិត្តមិនស្ងប់ ចូល
ចិត្តតែអាងលេស អាងហេតុបន្តិចបន្តួច ថាព្រឹកពេក ថ្ងៃពេក ល្ងាច
ពេកជាដើម ចាំស្អែកសឹមធ្វើ តែលុះដល់ព្រឹកឡើងក៏មិនធ្វើ ឬសូម្បី
ធ្វើខ្លះ ក៏គ្រាន់តែជាអាការលឹបលៗច្បិចច្បើមប៉ុណ្ណោះ ជាមនុស្សត្រឡប់
ត្រឡិន ធ្វើមិនពិតប្រាកដតាមសេចក្តីល្អ ជាមនុស្សមានពុតត្បុតធ្វើ
ល្អតែនៅចំពោះមុខគេ ជាមនុស្សសាវថ្យអួតអាង ធ្វើល្អដោយបំណង
ទឹងមង្គតគេ ជាមនុស្សធ្វើល្អយកមុខ គឺបើសេចក្តីល្អនោះ ជាការជួយ
អនុគ្រោះមនុស្សដទៃ ទឹងជាកិច្ចដែលត្រូវធ្វើទាំងចំពោះមុខទាំងកំបាំងមុខ
ក៏បែរជាធ្វើត្រឹមតែចំពោះមុខគេ ទាំងជាមនុស្សកុហកលោក គឺធ្វើល្អ
បំណងឲ្យមនុស្សជាច្រើន ច្រឡំនិយមរាប់អានខ្លួនថាជាមនុស្សល្អ តែ

កាលគេទៅអស់ហើយ កំលែងធ្វើសេចក្តីល្អនោះវិញ នេះជាអាការលាក់កំបួចរបស់មនុស្សវៀចចំពោះខ្លួនឯងទាំងអស់ ។

លោក-អ្នកចូរស្មោះត្រង់ចំពោះខ្លួនឯង កុំកុហកបញ្ឆោតខ្លួនឯង កុំជាមនុស្សត្រឡប់ត្រឡិន កុំជាមនុស្សបោកប្រាស កុំជាមនុស្សមាយាសាវេយ្យ កុំជាមនុស្សធ្វើល្អយកមុខ កុំជាមនុស្សបង្វែងលោកនឹងកុំជាមនុស្សពោរពេញតាមសំដីដែលគេដឹកនាំឲ្យខ្ជិចសេចក្តីល្អឡើយ ចូរអាស្រ័យតែផលរបស់សេចក្តីល្អ សន្យាតែសេចក្តីល្អ អត់រម្យតែក្នុងសេចក្តីល្អនោះ នឹងចូរប្រកបតែសេចក្តីល្អឲ្យភ្ជាប់ខ្លួន កុំអាស្រ័យផលនៃសេចក្តីល្អហើយទំលាយខ្លួនឯង ដោយការវៀចវេរឡើយ បើមិនដូច្នោះទេ នឹងត្រូវគេតិះដៀលថាគ្រាន់តែជាស្រមោលរបស់មនុស្ស ។ ព្រោះមនុស្សវៀច សូម្បីមានសាច់ស្បែកជារូបជាភាព គេអាចឃើញច្បាកដដោយភ្នែកបាន ក៏រាប់ថាគ្រឹមតែជាស្រមោលមនុស្សប៉ុណ្ណោះ ។

ស្មោះត្រង់បំពោះវាចា ·— លក្ខណៈនៃការស្មោះត្រង់ចំពោះវាចានេះ គេអាចដឹងបានត្រង់ការរក្សាវាចាឲ្យនិយាយតែតាមរឿងពិត នឹងធ្វើឲ្យពិតតាមពាក្យនិយាយ គឺរក្សាសំដីឲ្យនិយាយតែតាមសភាពពិតក្នុងការដឹកនាំគ្នាដោយវាចា នឹងរក្សាឲ្យពិតតាមវាចាដែលនិយាយដឹកនាំគ្នានោះ ។ វិស័យអ្នកស្មោះត្រង់ចំពោះវាចានោះ សូម្បីនៅក្នុងទំកណ្តាលអាវុធច្បាំងច្បាច់ ក៏មិនចរចាយ៉ាងដទៃក្រៅពីវាចាសច្ចៈរបស់

ខ្លួនដែរ មានលក្ខណៈស្មោះត្រង់ចំពោះវាចាពិតៗ ឥតមាននរណា អាចទំលាយបាន ទើបគួរចាត់មនុស្សបែបនេះ ថាជាអ្នកវង់ដំហរក្នុងវាចារបស់ខ្លួនគ្រប់ពេលវេលា ។

មនុស្សស្មោះត្រង់ចំពោះវាចា ជាអ្នកមានមារយាទរៀបរយនុនលំ-ពោន ធ្វើអ្វីក៏ជារបៀប មានសច្ចធម៌ជាឫសគែវ នេះជាលក្ខណៈនៃមនុស្សដែលពេញជាមនុស្ស បើផ្ទុយពីនេះវិញ ក៏ជាលក្ខណៈនៃម្នីគក្នុងពៃ ។ មើលចុះ មនុស្សរៀបស្វែងរកសេចក្តីល្អដើម្បីខ្លួន ដោយការប្រចុបប្រចែងញុះញង់ជានិច្ច មិនជួយគិត មិនជួយពិចារណា ជួយតែប្រចុបប្រចែងប៉ុណ្ណោះ គឺចេះតែអឺអើទាំងក្នុងកាលដែលគេធ្វើខុសទាំងក្នុងកាលដែលគេធ្វើត្រូវ សរសើរគេតែក្នុងទីចំពោះមុខ លុះកំបាំងមុខក៏និន្ទា ចូលចិត្តសរសើរមនុស្សដែលគួរតិះដៀល ទើតិះដៀលមនុស្សដែលគួរសរសើរ ។ ឯមនុស្សស្មោះត្រង់វិញ តែងស្វែងរកសេចក្តីល្អដើម្បីខ្លួនដោយវាចាស្អាត ច្បាស់ចាកទោសជាគ្រឿងសៅហ្មងរបស់វាចា ទើងដោយការងារដ៏សុចរិតជាគ្រឿងសម្បរិសុទ្ធរបស់កាយកម្ម ។

(មានត)

កណ្ឌទី ១២

ឧកញ៉ាវិបុលរាជសេនា ទួ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
ធំងបេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ព្រះថៅហៀនតេទន់គ្រាស់ប្រើតាំងដៀវឲ្យទៅហៅចូឆូ ឲ្យចូលមកប្រាវព្ធកិច្ចរាជការ, តាំងដៀវក៏ម៉ឺម្នាយាត្រាចេញទៅ លុះទៅដួបនឹងចូឆូ។ ក៏សំឡឹងមើលលក្ខណៈរូបរាង ឃើញថាតាំងដៀវវែងតាំងបុកពាក់វិយោព័ណសម្បុរក៏ជ្រះថ្លាស្អាតស្អាត ដួងនេត្រាក៏មូលធំ ចិញ្ចើមផុតកន្ទុយភ្នែក ចូឆូឃើញថ្លែកក៏សួរថា តុងទីក្រុងនេះខ្សត់អត់ស្បៀងអាហារ អស់បណ្តាជនក៏មានតែសេចក្តីទុក្ខអត់ឃ្លានណាស់ ហេតុម្តេចអ្នកឯង ចេះតាក់តែងរក្សារូបកាយឲ្យមានសាច់ឈាមលោមព័ណល្អសម្បុរស្អាតថ្លាថ្លាបាន ។ តាំងដៀវឆ្លើយថា ខ្ញុំខ្ញុំបានទឹងបានបំរុង

ថែរក្សាដោយប្រការម្តេចក៏គ្មានអង្គុីមាន ខ្ញុំបានទទួលទានតែអាហារដកបមកដល់អាយុ ៣០ ឆ្នាំហើយ ។ ចូឆូស្តាប់ហើយក៏អស់សំណើចហើយសួរថា អ្នកឯងជាអ្នាហ្នឹងដំណែងអ្វី ? ។ តាំងដៀវឆ្លើយថា ខ្ញុំបានជាពួកអ្នកស្រែកតេងតោ ជាទីប្រឹក្សាអ្នួនសៀវ លុះឮដំណឹងថា ព្រះចៅហៀនតេយាងត្រឡប់មកប្រថាប់នៅក្នុងស្រុកឡុកអៀងវិញ ក៏ចូលមកថ្វាយខ្លួនជាខ្ញុំព្រះពជការ ។ សូវថ្ងៃទ្រង់ព្រះមេត្តាប្រោសព្រះរាជទានជាទី « ដៀងយីឡុង » ប្រែថា « ទីប្រឹក្សាផ្ទាល់ព្រះអង្គ » ។ ចូឆូតបថា « យើងឮកេរ្តិ៍ឈ្មោះអ្នកឯងមកយូរហើយ តែមិនដែលឃើញខ្លួនសោះ វេលានេះយើងបានមកជួបប្រទះក៏ជាបុណ្យកុ័ឮណ្ណាស់ហស់យើង » ថាហើយក៏រៀបលៀងអាហារហើយឲ្យហៅស៊ុនហុកមកបរិភោគជាមួយ ដើម្បីនឹងបង្ហាញឲ្យស្គាល់រាប់អានគ្នា ។ ចូឆូនឹងតាំងដៀវ, ស៊ុនហុកបរិភោគតុរួមគ្នា ។

មានបំរើសេះចូលមកជំរាបចូឆូថា ឃើញទាហាន ១ កងលើកចេញមកអំពីក្រុងឡុកអៀងចេញទៅទិសបូព៌ តែមិនច្បាស់ជានរណា នាយទ័ពនោះ ។ ចូឆូក៏ចាត់បំរើសេះឲ្យតាមទៅស៊ើបចង់ដឹង តាំងដៀវក៏ប្តឹងជំរាបថា កុំឲ្យលោកប្រើគេធ្វើអ្វី នាយកងដែលលើកទាហានទៅនោះ ២ នាក់ ១ ឈ្មោះអៀវហ៊ង ជាបក្សពួកលីឈុយ, ១ ឈ្មោះហាន់សៀមជានាយចោរ បានចូលមកថ្វាយខ្លួនជាខ្ញុំពជការផ្ទាល់តាល់ព្រះចៅ

ហៀនតេ ស្តេចទើបយាងចេញពីក្រុងតៀវហាន់ ឥឡូវនេះឃើញលោក
ចូលមកធ្វើពាដការក្នុងស្រុកក្រុងនេះ ឈ្មោះតាំង ២ ក័យបារម្ភខ្លាចលោក
បានជានាំស៊ុំគ្រប់ក្បួនពួកលើកទៅដកពួននៅស្រុកគោលៀង ។ ចូឆួ
សួរថា ដែលឈ្មោះតាំង ២ នាក់ខ្លាចយើងហើយរត់ទៅនោះពីព្រោះហេតុ
អ្វី? ។ តាំងដៀវឆ្លើយថា ព្រះដំឆ្នាំរ៉ែប្រាជ្ញាវបស់លោកលើសហួស
ប្រាជ្ញាគំនិតរបស់ពួក បានជាខ្លាច ។ ចូឆួតបថា ដែលឈ្មោះតាំង ២
លបរត់ចេញទៅនេះ មុខជាមានស្តេចក្តីគិតធ្វើការផ្សេងៗ ជាការប្រទូស
រ៉ាយដល់យើងហើយ ។ តាំងដៀវឆ្លើយថា អាតាំង ២ នេះ ឧបមា
ដូចខ្លាគ្មានចង្កឹម ឬក៏ដូចសត្វឥតស្មារហើរ បើវាន៏ទៅគិតគំនិតយ៉ាង
ណា សូមកុំឲ្យលោកមានសញ្ញាជារឹតក្តួឡើយ ខ្ញុំបានយល់ថា យូរទៅ
ឯមុខគង់ន៏ឆាប់ខ្លួនវាបានដោយងាយ ។

ចូឆួស្តាប់ហើយក៏គិតថា តាំងដៀវនេះចរចាមុតមាំណាស់ ទើប
ប្រឹក្សាន៏តាំងដៀវថា ស្រុកឡុកអៀងនេះ កើតអន្តរាយដោយភ្លើងឆេះ
រំងាស់ច្រើនណាស់ យើងន៏ត្រូវគិតប្រការម្តេច ។ តាំងដៀវឆ្លើយ
ថា លោកលើកទាហានចូលមកកំចាត់លិឈុយគុយគីគ្រានេះ បីដូច
លោកមានដំរោនន៏ជួយព្រះចាហៀនតេ នៅប្រជាជនឲ្យបានសេចក្តី
សុខក្សេមក្សាន្ត គំនិតរបស់លោក ន៏ជួយឧបត្ថម្ភខ្នុកបំរុងផែនដី
ហើយគុណបំណាច់ក៏គង់ន៏មានដល់លោកជាយ៉ាងថ្លៃថ្លា ប្រពៃណាស់

តែថាខ្ញុំនេះបើលោកនឹងតុបតែងកំពែងលើកសែនដីគគូរជាស្នាមក្តោះ ប៉ុន្តែនឹងធ្វើបន្ទាយឲ្យខ្ពស់ក៏ពុំបាន ព្រោះអ្នកស្រុកក្រខ្សត់អត់ស្បៀងអាហារ បណ្តានាហ្នឹងខ្ញុំរាជការក៏នៅតាំងខ្វះមិនមួនមាំ បើមានសឹកសង្គ្រាមលើកមកញាំញីក៏គង់នឹងលំបាកដល់អាណាប្រជានុរាស្ត្រ នឹងខ្វះលោកជាប្រាកដ ខ្ញុំបានយល់ឃើញថាស្រុកហ្នឹតោងាទីធំល្អណាស់ សប្បាយដោយមនុស្សម្នាមហាជនច្រើនណាស់ តាំងស្បៀងអាហារក៏មិនមានខ្វះខាតបរិបូណ៌ជាងខែត្រខ័ណ្ឌដទៃ ប្រសិនលោកនឹងយកជាទីសមក្រមិជ័យនៃដែនខែត្រនោះចំពោះជាស្រួលណាស់ ហាក់បីដូចជាលោកចេះក្លែងផ្ទាស់ទិមិត្តទីថ្វាយព្រះចៅហ្នឹនតេ ដោយបុញ្ញបុទ្ធិរបស់លោក សូម្បីព្រះហឫទ័យព្រះចៅហ្នឹនតេ នឹងនាហ្នឹនសព្វមុខមន្ត្រីតាំងក្នុងក្រៅនឹងខែត្រក្រៅ ក៏មានឮវាក្យសរសើរតំរេះថ្លាជាលោកទូទៅ តាំងបណ្តារស្តេចក៏មិនមានសេចក្តីក្តៅក្រហាយ ខ្ញុំបានអធិប្បាយតាមសេចក្តីយល់ដូច្នេះ ស្រេចហើយតែលោកត្រិះរិះមើលតាមអធ្យាស្រ័យដោយគួរចុះ ។

ចូធូបានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរពន់ប្រមាណ ក្រោកឡើងចាប់ដៃតាំងដៀវហើយនិយាយថា ដែលអ្នកព័ណ៌នាមកដូច្នេះត្រូវនឹងគំនិតយើងគិតណាស់ តែថាបើយើងនឹងអញ្ជើញព្រះចៅហ្នឹនតេស្តេចយាងទៅកាលណា ក្រែងអៀវហាងនឹងហាន់សៀមលើកគ្នាមកធ្វើ

អន្តរាយកណ្តាលផ្លូវទេដឹង ប្រការ ១ បណ្តានាហ្នឹនសព្វមុខមន្ត្រីតូចធំ
ក្នុងក្រុងនេះ ក៏មិនទាន់ដឹងនឹងយល់ព្រមដូចយើងដែរឬទេ? ។ តាំង
ដៀវត្លើយថា សព្វថ្ងៃនេះបណ្តានាហ្នឹនមុខមន្ត្រីធំបណ្តាក្រុងតាំងស្រី
ប្រុសក្នុងព្រៃក្រុង ក៏ក្រខ្យត់អត់ឃ្លានជាច់ស្បៀងអាហារច្រើនណាស់
សូមឲ្យលោកប្រកាសឲ្យដឹងគ្រប់គ្នាថា ឥឡូវនេះក្នុងស្រុកឡុកអៀងក្រ
ខ្យត់អត់ឃ្លានជាច់ស្បៀងអាហារណាស់ លោកនឹងអញ្ជើញព្រះចៅ-
ហៀនតេស្តេចទៅគង់ឯស្រុកហ៊ីគោនៅជិតគ្នានឹងស្រុកឡោអៀង ស្រុក
នោះសម្បូណ៌សប្បាយដោយស្បៀងអាហារចំណីគ្រាន់ជាច់មិនមានខ្វះខាត
សោះ បើអស់នាហ្នឹននឹងបណ្តាក្រុងបានដឹងពុំហើយ ក៏គង់នឹងមាន
សេចក្តីត្រៃកអរសាទរតាមលោក មួយយ៉ាងទៀត អៀវហង់នឹង
ហាន់សៀង ដែលរត់ទៅនៅ ស្រុកតៃលៀងនោះ ក៏សុំឲ្យលោកមាន
សំបុត្រទៅបញ្ចុះបញ្ចូលល្បួងលោមយកចិត្ត គង់នឹងមិនគិតប្រទូសរ៉ាយ
នឹងលោកតទៅ ។

ចូឆូបានស្តាប់ក៏មានសេចក្តីត្រៃកអរណាស់ ហើយនិយាយថា
ចាប់តាំងពីថ្ងៃនេះតទៅ បើយើងមានកិច្ចការអ្វី ទឹងសូមអញ្ជើញអ្នក
ឲ្យមកជួយពិគ្រោះប្រឹក្សាឆង ។ តាំងដៀវទទួលពាក្យចូឆូហើយក៏លា
ចេញទៅ ។ ក្រោយពីពេលនោះមក ចូឆូបានប្រឹក្សាការនឹងសេនា
ធាហានឯទៀត អំពីរឿងដែលត្រូវអញ្ជើញព្រះចៅហៀនតេទៅគង់
ឯស្រុកហ៊ីគោ តែការរឿងនោះមិនបានយល់ព្រមគ្នាសោះ ។

ឯអង្គលិបនឹងឡៅង៉ាយជាពួជព្រះពជវង្សនឹងប្រថៅហៀនតេបាន
ប្រឹក្សាគ្នា អង្គលិបថាខ្ញុំបានឃើញផ្កាយថៃបេក គឺផ្កាយសនោះភ្លឺថ្លា
តែវជ្ជវិស្សា តែថាជល់វជ្ជវិជ្ជាំងកាលណា ក៏ដើរឆ្ងងមកត្រឡប់ស្មើ
អន់អាប់អស់ទៅ ខ្ញុំពិចារណាតាមក្បួនខ្នាតទៅឃើញថា ព្រះថៅ-
ហៀនតេ នឹងចុះពសីសាបសូន្យគ្រានេះ ហើយនឹងមានអ្នកជវៃមក
សោយរាជសម្បត្តិជាព្រះមហាក្សត្រវិញ ។ អង្គលិបក៏នាំយកសេចក្តីនោះ
លបចូលទៅ ក្រាបទូលព្រះថៅហៀនតេ។ ទ្រង់ព្រះសណ្តាប់ហើយ
មិនមានត្រាសថាប្រការម្តេច ។

ចូឆូបានឮកិត្តិស័ព្ទដែលអង្គលិបនឹងឡៅង៉ាយនិយាយគ្នានោះ លុះ
ពេលយប់ក៏ប្រើមនុស្សជំនិតឲ្យទៅនិយាយនឹងអង្គលិបថា បើខ្លួនអ្នកមាន
ចិត្តសុចរិតត្រង់នឹងផែនដីហើយ គេះបានជឹងឃើញហេតុកេទស្រុក
ទេសប្រការម្តេច ក៏កុំអាលនិយាយឲ្យបែកខ្ចាយផ្សាយសេចក្តីជាមុន
ព្រោះការនេះជ្រៅធំពន្ធឹកណាស់ ។ មនុស្សបំរើក៏ទៅនិយាយនឹងអង្គ-
លិបតាមពាក្យចូឆូបង្គាប់នោះគ្រប់ប្រការ ។ អង្គលិបក៏មិនបានថាប្រការ
ម្តេច ចូឆូក៏ឲ្យហៅស៊ុនហុកមកនិយាយទៀត តាមដំណើរដែលអង្គលិប
និយាយគ្នានោះ ។ ស៊ុនហុកឆ្លើយថា ព្រះថៅហៀនតេកំណើតជា
ជាតុក្លើង ខ្លួនលោកជាជាតុដី បើលោកនឹងគិតធ្វើការអ្វីក៏ត្រូវប្រឹងគិត
ឲ្យជ្រៅទូលាយជាធាប់ ដូចរឿងដែលលោកគិតទៅនៅស្រុកហ៊ូគោនោះ

ត្រូវទៅជាប្រញាប់កុំបង្អង់ លោកក៏គង់នឹងសម្រេចដូចពាក្យអង្វរថា ជាប្រាកដណាស់ ។

ប៊ូធូបានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរពន់ប្រមាណ លុះពេលព្រឹកក៏ចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេហើយទូលថា ស្រុកឡុកអៀងនេះ មានសេចក្តីអន្តរាយវិនាសសាបសូន្យតាំងពីគ្រាតាំងតុះម្តងហើយ ឥឡូវនេះព្រះអង្គទ្រង់យាងមកគង់ប្រថាប់វិញ ថែមទាំងទុក្ខកង្វល់ក៏អត់ឃ្លានផង មានតែសេចក្តីលំបាកគ្រប់គ្នា បើនឹងតាក់តែងជារាំងកំពែងឡើងវិញកាលណា ក៏មានតែសេចក្តីវេទនាដល់អាណាប្រជានុរាស្ត្រខ្លាំងណាស់ ឯស្រុកហ៊ូគោនោះ ប្រកបដោយសែនបន្ទាយទូលាយធំមាំមួន អាណាប្រជានុរាស្ត្រសឹងតែមានទ្រព្យសម្បត្តិជាធនធាន មានទាំងស្រែអង្កាចំណីគ្រើសាប់ចរបូណ៌ព្រម ហើយជិតនឹងស្រុកឡុកអៀងផង ប្រសិនបើមានសឹកសង្គ្រាមវេលាណាក៏នឹងបានលើកដួយគ្នាដោយស្រួលហ៊ាស ទូលព្រះបង្គំខ្ញុំបានស្គាល់ច្បាស់មកយូរហើយ សូមអញ្ជើញស្តេចយាងទៅគង់ក្នុងស្រុកនោះចុះ នឹងបានសេចក្តីសុខសប្បាយក្នុងព្រះកាយពល ព្រមទាំងនាហ្នឹងមុខមន្ត្រីនឹងអាណាប្រជានុរាស្ត្រទាំងពួង នឹងបានសេចក្តីសុខក្សេមក្សាន្ត ។

ព្រះចៅហៀនតេទ្រង់ព្រះសណ្តាប់ហើយទើបត្រាស់ថា បើអ្នកនឹងគិតការពារក្សាខ្លួនយើងដោយប្រការម្តេច នោះស្រេចទៅលើគំនិត

វេស់អ្នកចុះ យើងមិនយល់ទាស់ទេ ។ ឯនាហ្នឹនតូច - ធំដែលដួបជុំ បង្គំគាល់នៅទីនោះ លុះបានឮចូរឆ្លូវដូច្នោះសឹងខ្លាចអំណាចចូរឆ្លាល់គ្នា មិនមាននរណានឹងធ្វើយទាស់ថាដូចម្តេចឡើយ ។

កាលសម័យនោះ, ចូរឆ្លូកំបង្គំឲ្យមនុស្សម្នាមហាជនប្រុស - ស្រីរៀបជញ្ជូនវេស់ទ្រព្យផ្កុកទេះគោក្របី ហើយនឹងផ្ទុំសេនាគាហានមានសេះដំរីត្រៀបត្រាំរៀបចាំងព្រះពាជវាំងចូរស្រេច ក៏អញ្ជើញស្តេចព្រះចៅ-ហៀនតេ នឹងព្រះអគ្គមហេសី ស្រីស្នំឡើងគង់ព្រះពាជវេ ខ្ញុំពាជការនឹងសេនាគាហានក៏ហែហមអមចេញទៅ ។ ចូរឆ្លូដាមេទ័ពលើកនាំស្តេចចេញចាកព្រះពាជវាំងក្រុងឡុងអៀង ទៅចម្ងាយផ្លូវប្រមាណ ៥០ សិន (២ គីម.) ដល់ដើងកុំ ១ ក៏ដួបប្រទះអៀវហាង ហាន់សៀម លើកគាហានស្រែកហ៊ោមកស្កាត់ពីមុខ ។ ចូរឆ្លូឃើញដូច្នោះក៏បរសេះសុំទៅមុខគាហាន, ស៊ីឡុងស្រែកឲ្យចូរឆ្លូថា អ្នកនាំព្រះចៅហៀនតេស្តេចទៅទីឯណា ? ។ ចូរឆ្លូមិនឆ្លើយតប ប្រើទៅផ្លូសេនាឯកចេញទៅតយុទ្ធនឹងស៊ីឡុងបាន ១៥ ភ្លេងមិនទាន់ចាញ់ឈ្នះ ចូរឆ្លូឲ្យរាយឃ្មោះថយត្រឡប់ក្រោយវិញ, ស៊ីឡុងក៏ពាថយទៅចូលក្នុងបន្ទាយ ។ ចូរឆ្លូប្រឹក្សានឹងសេនាគាហានទាំងពួងថា អៀវហាងនឹងហាន់សៀមនោះ យើងត្រូវគិតចាប់សម្លាប់ចេញចុះ តែស៊ីឡុងនោះមានកំលាំងខ្លាំងពូកែយើងចង់បានទុកធ្វើសេនាឯក បើដូច្នេះ ត្រូវគិតកល់ឧបាយលួងលោមយកឲ្យបាន ។

(មានត)

រឿងអាវ៉ាក្យថ្លែងរឿងថ្លៃថ្លា

លោកសាង-សារ៉ាត លេខានុការ ក្រសួងបរិវត្តិ

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(តមក)

រឿងទី ៤

អាវក្យនិយាយថាដូច្នេះ "ឧមហាក្សត្រិយ៍! មានទីក្រុងមួយ ហៅថាក្រុងអុជ្ជន្ត (Ujjain) ។ ព្រះមហាក្សត្រនៃទីក្រុងនេះព្រះនាមព្រះបាទមហាបាល (Mahabal) មានអគ្គភរជទូតមួយឈ្មោះហរិទាស (Haridas) ។ ឯអគ្គភរជទូតនេះ មានកូនស្រីមួយឈ្មោះនាងមហាទេវី (Mahadévi) ។ កាលណាអគ្គភរជទូតនេះឃើញបុត្រពេញក្រមុំអាយុល្មមរៀបការអាពាហ៍ពិពាហ៍, លោកគិតរកប្តីមួយឲ្យនាង ។

ថ្ងៃមួយនោះ នាងកញ្ញានិយាយទៅកាន់ឪពុកថា: "ឧលោកឪពុក! សូមលោកឲ្យខ្ញុំទៅមនុស្សពេញលក្ខណៈដែលមានតម្រិះគ្រប់ចំពូក" ។ ឯឪពុកក៏ឆ្លើយវិញថា: "អើអញរៀបរាប់ហមង្គលការឲ្យឯងបានទៅអ្នកណាមួយដែលមានវិជ្ជាសាស្ត្រគ្រប់បរិបូណ៌ពាំងអស់" ។

កន្លងថ្ងៃមួយ ព្រះមហាក្សត្រទ្រង់មានព្រះរាជឧស្ការឲ្យហៅលោកហរិទាសទៅជិតព្រះអង្គហើយទ្រង់មានព្រះបន្ទូលថា: "ចូរលោកអញ្ជើញ

ទៅកាន់ប្រទេសព្រះបាទហរិចន្ទ (Harichand) ដែលសោយរាជ្យនៅ
ខាងត្បូងខ្ញុំ ។ រួចលោកទូលសួរអំពីដីវភាពនឹងសេចក្តីសុខទុក្ខរបស់
ព្រះអង្គផង ហើយយកដំណឹងនោះមកថ្លែងខ្ញុំវិញ" ។

លុះទទួលព្រះរាជឧទ្ទារនេះស្រេចកាលណា ហរិទាសក៏ក្រាប
ថ្វាយបង្គំព្រះបាទមហាបាលចេញទៅ ។ កន្ទងច្រើនថ្ងៃមកក៏បានទៅ
ដល់ប្រាសាទស្តេចហរិចន្ទ ហើយលោកបានថ្វាយព្រះរាជសារព្រះបាទ
មហាបាលហើយក៏អង្គុយនៅជិតព្រះអង្គនោះទៅ ។

ក្រោយបន្តិចស្តេចមានព្រះបន្ទូលសួរ
លោកថា: "ម្នាលហរិទាស! តើរយៈពេលដែលផុត ចាប់មានឡើង
ហើយឬនៅ?" ។ ហរិទាសទូបដៃក្រាបទូលព្រះអង្គវិញថា: "សូមទ្រង់
ជ្រាប ពេលទុក្ខចាប់ផ្តើមកើតមានហើយ ពីព្រោះពាក្យកូតកុហកចេះ
តែមានច្រើនឡើងៗ ក្នុងលោកិយនេះ ឯសេចក្តីពិតចេះតែថយទៅៗ ។
ក្នុងមាត់នៃមហាជនគ្រប់ទាំងអស់សុទ្ធតែមានពាក្យល្អ ប៉ុន្តែជនទាំងអស់
នោះលាក់របស់អាក្រក់ទុកនៅក្នុងដួងចិត្ត ។ អំពើយុត្តិធម៌ក៏ត្រូវគេរំលាយ
លះបង់ចោល ដោយមានមនុស្សហានេយ្យចេះតែកើតច្រើនឡើង ។
គតផែនដីចាប់ផ្តើមឲ្យផលតិច ។ ស្តេចគ្រប់ព្រះអង្គចាប់ផ្តើមដំឡើងពន្ធ។
ពួកព្រាហ្មណ៍ទៅជាមានចិត្តកំណាញ់ ។ ស្រីៗពុំបានតាំងចិត្តនៅ
ធឹងធឹង ។ បុត្រលែងស្តាប់បង្គាប់បិតារបស់ខ្លួន បងលែងទុកចិត្តប្អូន ។

រវាងមិត្តក៏ពុំមានសេចក្តីមេត្រីសោះ ។ ពួកគ្រូអាចារ្យលែងមានចិត្តស្មុគស្មាញ ឯពួកខាសាខាសីក៏ចោះបង់ការងារបស់ខ្លួន ។ រត្តុដែលអាត្រាក់តាំងប៉ុន្មានក៏លេចឡើង" ។

លុះកាលណា លោកគ្រាបទូលតបព្រះមហាក្សត្រួចហើយ ស្តេចទ្រង់ក្រោកឈរឡើង យាងចូលទៅក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ។ ឯហរិទាសក៏ត្រឡប់ទៅកាន់លំនៅនៃខ្លួនវិញ ។ លុះលោកអង្គុយហើយ មានកូនប្រុសរបស់ព្រាហ្មណ៍ម្នាក់ទៅដឹងលោក ហើយជំរាបលោកថា: "ខ្ញុំមករកព្រះតេជព្រះគុណ ដើម្បីសួរព្រះតេជព្រះគុណបន្តិច" ។

ហរិទាសនិយាយថា: និយាយមកមើល តើអ្នកចង់បានអ្វី? ។

_សូមព្រះតេជគុណមេត្តាឲ្យកូនស្រីរបស់ព្រះតេជគុណមកខ្ញុំបានឬទេ? ។

ហរិទាសតន្យល់ថា: "យើងឲ្យកូនស្រី ទៅមនុស្សណាដែលមានវិជ្ជាគ្រប់សព្វគ្រប់អស់" ។

លុះបានឮដូច្នោះ បុរសឆ្លើយតបទៅលោកវិញថា ខ្លួនមានវិជ្ជាគ្រប់គ្រាន់ដោយបរិបូណ៌ ។

ហរិទាសនិយាយទៀតថា: "មិនអីទេ ចូរអ្នកបង្ហាញតម្រិះរបស់អ្នកឲ្យយើងមើល ដើម្បីឲ្យយើងស្មង់ថ្នាក់តម្រិះរបស់អ្នក" ។

យុវៈព្រាហ្មណ៍ឆ្លើយថា: ខ្ញុំធ្លីរទេះមួយដែលមានកង់ប្លន ឯរទេះនេះ អាចនាំលោកទៅដំបន់ដែលលោកចង់អញ្ជើញទៅបានភ្លាមដូចប្រាថ្នា ។

ហរិទាសឆ្លើយថា: "អើដល់ព្រលឹមឡើង យកវេនោះមកឲ្យយើង" ។

ដល់ថ្ងៃស្អែក មុនព្រះអាទិត្យរះឡើង បុរសនាំវេនោះមកជូនលោកហរិទាស រួចអ្នកទាំងពីរក៏ឡើងទៅលើវេនោះ ហើយក៏បានបរទៅដល់ទីក្រុងអុជ្ជឆ្ន ។

ប៉ុន្តែមុននឹងទៅដល់ក្រុងនោះ មានកូនព្រាហ្មណ៍ម្នាក់ទៀតបានទៅរកកូនច្បងរបស់ហរិទាស បានសុំរៀបការជាមួយនឹងនាងបួន ហើយទទួលការយល់ព្រមដូចមុន គឺថា: បុរសឲ្យប្អូនរបស់ខ្លួនទៅអ្នកណាដែលមានវិជ្ជាគ្រប់ជំពូក ។ ឯបុរសដែលចូលស្តីដណ្តឹងនាងនោះ បានបញ្ជាក់ថាខ្លួនចេះដឹងទាំងអស់ ហើយបានទាំងធ្វើកិច្ចសន្យាថែមទៀតផង ។

មានកូនព្រាហ្មណ៍ទីបី បានជូនពាក្យសុំដូចមុនទៅម្តាយរបស់នាងដែលបានឆ្លើយដូចមុនថា នាងនេះនឹងបានទៅអ្នកណាដែលមានវិជ្ជាគ្រប់ជំពូក ។ ឯកូនរបស់ព្រាហ្មណ៍បានបញ្ជាក់វិញថា ខ្លួនមានវិជ្ជានោះយ៉ាងជ្រៅជ្រះ ហើយចេះទាំងបាញ់ព្រួញតាមសូរផង ។ ស្ត្រីជាមាតាក៏សុខចិត្តឲ្យបុត្រីទៅព្រាហ្មណ៍នេះ ។

គិតទៅគូកំណាន់បីនាក់ ទៅជួបជុំគ្នា ។ ឯហរិទាសក៏គិតថា ស្ត្រីម្នាក់ គូកំណាន់ដល់ទៅបី ... តើអញឲ្យទៅអ្នកណា? ... តើអញមិនឲ្យអ្នកណា? ។

លោកអគ្គភាជទូតកំពុងតែដញ្ជឹងគិតដូច្នោះ ស្រាប់តែមានយក្ខមួយ ចូលមកក្នុងពេលភត្រីស្ងាត់ ចាប់យកនាងកញ្ញាទៅ រួចនាំនាងទៅលើកំពូលភ្នំមួយឈ្មោះវិន្ធ្យាចល (Vindhyachal) ។ គេនិយាយថា អ្វីដែលជ្រុលហួសប្រមាណ គឺអាក្រក់ទាំងអស់ ។ នាងសិតា (Sita) នាងនេះជាកូនស្តេចជនក (janakas) ហើយជាភរិយារបស់ព្រះភម (Rama) ព្រះភមទៅធុតង្គ ទុកព្រះលក្ស្មណ៍ (Lachmana) ជាអ្នកឲ្យរក្សានាង ។ ព្រះលក្ស្មណ៍ចានព័ទ្ធសីមាជុំវិញខ្លួននាង ។ ក្នុងពេលដែលព្រះលក្ស្មណ៍មិននៅ យក្ខរាពណ៍ (Râvana) ក្លែងខ្លួនជាអ្នកសុំទាន ទៅស្រឡាញ់នាងសិតា ហើយនាំនាងតាមរទេះរបស់ខ្លួនទៅ ។ រាពណ៍ស្រឡាញ់នាង ។ ស្តេចពាលី (Bali) ធ្លើព្រះរាជអំណាចយ៉ាងច្រើន ស្តេចធ្វាក់ព្រះអគ្គទៅជាក្រុ ។ រាពណ៍ចិត្តឡើងក្រអើតៈគាត់ធ្លើគ្រួសាររបស់គាត់ឲ្យហិនហោច ។

នៅចុងក្រោយបង្អស់ ព្រះអាទិត្យកំរះឡើង... នៅក្នុងផ្ទះគ្មានអ្នកណាមួយឃើញនាង គេតាំងទាំគ្មាស្មានជាច្រើនបែប ។ ជនស្ងួគ្រតាំងចិដល់ដ៏ងដំណឹងនេះ ក៏មកដល់យ៉ាងប្រញាប់ ។ មានម្នាក់នោះជាអ្នកច្បាស ។ ហរិទាសសួរព្រាហ្មណ៍នោះថា: "នែបណ្ឌិត! ចូរអ្នកច្បាប់ខ្ញុំតើកូនខ្ញុំនេះទៅណា?" ។ លុះគិតចំនួនមួយមោងព្រាហ្មណ៍ទី ១ នោះឆ្លើយថា កូនស្រីរបស់លោកត្រូវយក្ខរក្សា យកទៅលើកំពូ

ចាត់ទៅហើយ ។ ព្រាហ្មណ៍ទីពីរបញ្ជាក់ថា ទៅសម្លាប់យក្ខនោះរួចនាំយកនាងមកវិញ ។ ឯព្រាហ្មណ៍ទីបី ប្រកាសថានឹងដុះលើរាងរបស់ខ្លួនដើម្បីទៅកេនាង ។ ថាហើយព្រាហ្មណ៍ទី ១-៣ ធ្វើតាមពាក្យរបស់ខ្លួន ។ តែព្រាហ្មណ៍ទីពីរចេញទៅ សម្លាប់យក្ខហើយយកនាងនោះមក ។

ក្នុងពេលនោះ ជនទាំងបី ចាប់ផ្តើមប្រឈ្លោះគ្នា ឯឥពុកក៏ខ្វល់ខ្វាយជាខ្លាំង លោកគិតថា: "ទាំងអស់គ្នា ចានជួយស្រោចស្រង់ជីវិតនាង ។ តើអញឲ្យនាងទៅអ្នកណា? ... តើអញមិនឲ្យទៅអ្នកណា?" ។

ដល់និយាយរឿងនេះហើយ អាកែវសួរថា: "បពិត្រព្រះបាទពិភវន! បុណ្ណាជនទាំងបី នារីនេះត្រូវបានទៅអ្នកណា" ។

ព្រះអង្គមានព្រះពាក្យថា "នាងត្រូវបានទៅអ្នកដែលសម្លាប់យក្ខ" ។

អាកែវនិយាយថា: សេចក្តីព្យាយាមរបស់ជនទាំងអស់មានស្មើគ្នា ហេតុម្តេចក៏អ្នកនោះត្រូវបាននាង?" ។

ព្រះពាជាមានព្រះពាក្យថា: "បុរសទី ១-៣ មុននោះគ្រាន់តែមានគុណសម្បត្តិប៉ុណ្ណោះទេ ពីព្រោះសុទ្ធតែធ្វើទៅតាមមេធ្យោបាយរឿងខ្លួន ឯចំណែកខាងបុរសទីពីរវិញ បានតតាំងនឹងយក្ខ សម្លាប់យក្ខនោះទៅ ហើយយកនាងមកវិញ អាស្រ័យហេតុនេះហើយ បុរសនោះត្រូវបានជាប្តីនាង" ។

លុះឮដូច្នោះ អាកែវត្រឡប់ទៅលើពិក្យារបស់ខ្លួនវិញ ឯព្រះអង្គក៏យាងទៅតាម យកអាកែវនេះមកចងលើព្រះអង្សាហើយនាំទៅ ។ (មានត)

៤ ឈុត

លោក គង់ - លឹម ធិសរិត្តសាលាគរុវិជ្ជា ភ្នំពេញ តែង

(តមក)

ឈុតទី ១ ជាកទី ៤

មិត្តភាព - មិត្តាណា

មិត្តភាព

អាវុធ មានមុខដ៏សម្ងាត់ សម្រាប់ច្រហារជន្មជីវិត
មនុស្សអាក្រក់ដែលមានចិត្ត ភាណាវិទ្ធិចិត្តខ្មៅហើយឈាមរាវ ។
ធ្វើបងអាងតែបុណ្យសក្តិធំ រាយដំចែងចាក់ដោយគោរគាវ
សម្លាប់អាចេញ ! ចោលខ្លួរក្បែរ រកការក្តើរឈ្មោះខ្ញុំឡើងវិញ ។

មិត្តាណា

សម្លាប់ភាណាវិទ្ធិបងប្អូនឯង ម្តេចមិនគិតក្រែងទុក្ខគោម្នេញ
លោកនឹងផ្តន្ទាទិវេសចេញ ចំណេញឫខាតឯងគិតមើល ! ។

មិត្តភាព

អាប់ស័ក្តិអាប់យសក្តើរឈ្មោះខ្ញុំ កិរិយាមិនសម អាបងត្រើល !
មើលឃើញតែគោសខ្ញុំងើល គេប៉ុនស្រមើលមើលមិនឃើញ ។

មិត្តណា

បងសូមអង្វរ ចិត្តប្អូនទៅ បើចិត្តប្អូនក្តៅ បងសន្ធើញ
ភ្លាយជាក់បងចុះ! គ្មានកំញើញ សន្ធើញតាមចិត្តឲ្យឆាត់ចិន ។

មិត្តភាព

បងចេះតែខ្លួលខ្លុកខោស នរណាគេខុស បងមិនដឹង
គេខ្លួលសាច់ បងយកឆ្អឹង ប៉ុណ្ណឹងហើយទៅតែឈឺញាញ់ ។

មិត្តណា

បងចង់ឲ្យប្អូនរួបរួមគ្នា មានធម៌សមគ្គាចេះស្រឡាញ់
កប់អានបងប្អូនឥតមានក្តាញ់ ដូចខ្វាញ់ជ្រែកហើយនឹងឆ្នាំងដែក ។
ស្រុះស្រួលស្រឡាញ់ត្រមកត់ទាក់ ជជែសណ្តារ: ល្អអនេក
ធ្មុគាបីដូចចង្កើះដែក ដោយដំរយ៉ាងឯកគឺសាមគ្គី ។
នរណាទឹងហ៊ានហូតដកចេញ ចង្កើះដែកវេញជាប់ដល់ទី
ចេះធ្វើដូចម្តេចក៏មិនលី - លាចេញចោលពីគ្នាបានឡើយ ។

មិត្តភាព

យល់ច្បាស់កុងចិត្តសព្វសំដី ខ្ញុំឥតថាអ្វីទេបងអើយ!
តែនឹកទៅខ្លាសវណ្ណតាពហើយ ពុំស្បើយទើបខ្ញុំកើតក្តាហាន ។

មិត្តណា

ខ្ញុំសង្ស័យ! សម្លាប់បងអ្នកឯង ធ្វើឲ្យចំបែងចិត្តសង្កាន
ធ្វើដូចមនុស្សល្ងង់ខ្លៅសាមាន្យ នែអ្នកប្រុសជ្រុលណាលែងទឹងទៀ! ។

មិត្តភាព

បើខ្ញុំលះចោលសេចក្តីគុំ គំនុំទៅមុខគេថាខ្លៅ
ខ្ញុំទឹងអន់ចិត្តគ្មានឈ្មោះហៅ វណ្ណគាកៈតាមផ្លូវលែងអាណិត ។
ដ្បិតនាងស្រឡាញ់ក្តីក្លាហាន ល្ងង់ខ្លៅសាមន្យខ្ញុំឥតគិត
ចាន់ជាផុងខ្លួនឆ្ងាយគំនិត សម្លាប់ការណ៍ខ្ចិដូចជ្រូកថ្លា! ។ (ស្ទុះចេញ)

មិត្តណា (ចាប់)

ឈប់ៗ! ប្អូនប្រុសថ្លើមដំរិត ឯងទៅដេកគិតឲ្យអស្ចារ្យ
ពីរឿងដែលអ្នកបង់ប្រហារ ការណ៍ខ្ចិគ្រួសារគិតឲ្យជ្រៅ! ។
ឥឡូវត្រូវចោះកាំបិតចោល ចាំស្តាប់បងពោលពាក្យប្រដៅ
ធ្វើអ្វីគិតមុនទើបចាន់ត្រូវ នេះហើយជាផ្លូវគន្ធឆមិ ។
តែបងឃាត់ប្អូនសូមនាងស្តាប់ ប្រញាប់ធ្វើតាមទើបបាន
សម្លាប់បងអ្នកគ្មានគិតធម៌ ភជការខាក់ទៅជាក់គុក ។

មិត្តភាព

ព្រួយចិត្តខាងបងខាងលោកប៉ា សេចក្តីហានក្លាងឹងចាន់ទុក្ខ
សំដីឯងបងខ្ចិចាំគុក បងអើយខ្ញុំសុខចិត្តស្រេចហើយ ។

មិត្តណា

សាធុ! សាធុ! លោកទេព្តា ជួយចាំសច្ចាប្អូនត្រាណត្រៃយ
ក្រុមញាតិចេះស្រឡាញ់កៀកកើយ ពីនេះទៅហើយលែងកលិយុគ ។

មិត្តភាព

លោកចុ"ដឹងហើយ ឬ រឿងនេះ? ស្រែចតែបង់ចេះខ្ចប់រៃចខ្ទុក
សច្ចាយា"ងនេះចំពោះមុខ បងអើយអ្នកផ្ទុកសព្វសំដី ។
វណ្ណ៌តាកខ្ញុំដកចិត្តចេញហើយ ទុបង់ប្រុសអើយរកជាតិស្ត្រី
ណាល្អលើសនាង ខ្ញុំមេត្រី ដែលខ្ញុំស្វាមីអាចពឹងបាន ។

មិត្តណា

ផលនាវីជាប្អូនវណ្ណ៌តាក លោកចាំបានស្តីប្រគាន់ច្បាណ
អ្នកសុខាត្រមថាន់ឆ្ងាយបាន រូបនាងកល្យាណល្អគួរស្នេហ៍ ។

មិត្តភាព

រូបល្អអាក្រក់ខ្ញុំមិនគិត ឲ្យតែគំនិតកិរិយាគេ
ចេះថែរក្សាចេះការពារគ្នា មិនទៅចំនេះខ្ញុំស្មូហា ។
ប្រពន្ធរូបល្អតែពាងកាយ មិនចេះជាំជាយឥតត្រូវការ
ត្រលឹមឡើងប្រើឲ្យទៅផ្សារ មិនចាប់ទាសាដើរតាមគ្រោយ ។
ញ៉ិកញ៉ាក់ញ៉ាំញ៉ើមិនចូលចិត្ត ខុពុកខុសចិត្តមិនឲ្យឆ្ងាយ
មិនមែនឃើញចេះតែបណ្តោយ ខុពុកត្រូវហើយទើបខ្ញុំយក ។ (ចូល)

ឈុតទី ១ ឆាកទី ៥

ម៉ារ៉ា - មិត្តាណា - ដួលនារី - ភាណី

ម៉ារ៉ា

ហត់កាយ មិនស្មើនឹងហត់ចិត្ត មានមិត្រ មិនស្មើមានគ្រួសារ
ទុក្ខអ្វីមិនស្មើក្តីស្នេហា កើតឡើងកាលណា តែងអន្ទោល ។
ស្តីបន្ទោសវាជារឿយ។ វានៅធ្លីឈ្លើយ បំភ្លេចចោល
ទៅណាតាមជាប់ដូចស្រមោល អន្ទោលតាមប្រាណពិប្រាកដ ។
មិត្តាណា ! កូនប៉ា ចូរមកអាយ ជួយស្រាយចំណងគំបញ្ហា
លើកឲ្យថ្កុំថ្កើងដល់គ្រួសារ កូនអើយ ! ដែលប៉ាជាទីពឹង ។

មិត្តាណា

បញ្ហាអ្វីខ្លះ? សូមអធិប្បាយ ខ្ញុំនឹងកំចាយ ជូនតំណឹង

ម៉ារ៉ា

ភានវិទ្ធិ - ឆ្កួតព្រោះស្នេហាដឹង ធ្វើគ្រួសារហ្នឹងឲ្យថយក្រោយ ។

មិត្តាណា

ហេតុការណ៍ទាំងនេះ សូមប៉ាជ្រាប មិត្តភាពភាណវិទ្ធិចិត្តគេផ្ងាយ
បែកការដឹងដល់ក្នុងពេលក្រោយ ភាណវិទ្ធិគំផ្ងាយវាយតក្លា ។
ញាប់ញ័រខឹងណាស់ចង់សម្លាប់ ខ្ញុំចាប់មិត្តភាពហ៊ាយស្តីថា
ចោះចោលពីដៃគាំបិតថ្នា ខ្ញុំគំស្តីថាប្រដៅបាន ។

ម៉ារ៉ា

កូនចេះនិយាយឲ្យគេស្តាប់ ឲ្យគេត្រេតត្រាប់តាមលំអាន
ចូរកូនធ្វើចិត្តឲ្យតាមច្បាណា ត្រែងដូចលំអានជាផ្លែល្អា ។
ធ្វើកាយធ្វើចិត្តឲ្យត្រឹមត្រូវ ដើរទៅតាមផ្លូវព្រះសម្មា -
សម្ពុទ្ធជាម្ចាស់ទ្រង់ទេសនា ប្រោសសត្វទេព្តាឲ្យផ្លូវផង់ ។
ឯងធ្វើត្រូវដូចជាបន្ទាត់ សម្រាប់គូសព័ទ្ធតត់តម្រង់
ឲ្យដើរទៅតាមផ្លូវដែលត្រង់ គន្ធយ៉ាងខ្ចង់សម្រាប់វត្ត ។
ប៉ុន្មានសតវត្សរ៍ហួសទៅហើយ កូនអើយ ! ខ្មែរយើងល្បីថ្កុតដ
តីជាតិកម្ពុជានគរវត្ត សរសើរត្រេប់មាត់ថាសុីវិល្ប៊ែ ។

មិត្តាណា

ការណ៍ណាដែលហួសលែងគិតថា ! ភាសាខំនើបថ្មី
លោកគិតជ្រើសរកបែបសំដី ភាសាបរទៃមកប្រើច្រាស់ ។

ម៉ារ៉ា

ភាសាសំដីឥតបើយ៉ា ប៉ុន្តែមាសប៉ាកុំក្ងេចចាស់
ខ្មែរជាន់ពីដើមពូកែណាស់ ធ្វើកេរ្តិ៍ខ្មែរច្បាស់ណាកូនអើយ ។

មិត្តាណា

វិញ្ញាណមានរូបជាដំរៃ ដូចចា៉ ចានស្តីរួចទៅហើយ
ឥឡូវគេលែងទៅកៀកកើយ ផ្ងាស់អស់ទៅហើយជីវិតធំ ។ (ចូល)

ធំលេងារី

ចា៎ ។ ! ខ្ញុំសូមទៅវាយចាល់ ឧទ្ធំនាងសារ៉ាលំពូតមាកខ្ញុំ

ម៉ារ៉ា

ទេ ! ទេ ! ទេ ! ទេ ! កូនក្រមុំ នាងកុំស្រែកខោបញ្ចេញក្លៅ ។
នាំឲ្យគេយើញកើតក្លាញ់ចិត្ត ស្រែកបិទឲ្យជិតទៅកូនអ៊ ?
តែដិះកន់ផុត ! តាមឥឡូវ អាស្រែកក្តីឈ្មោះដល់អញហើយ ។

ធំលេងារី

ស្រែកអាហ្នឹងហើយទើបបានសម បញ្ចេញមាឌមាំជាក់ប្រុស ។
ដេរម្តាយអាក្លាមតែមាត់ថ្នោះ

ភាណី

រង្គោះមួយដៃថ្កាមយំខ្លែ ។ ខ្ជូនអើយឥតមែយំខ្មាសគេ !
ទំពាំបាន់ដេរវាហូរហែ

ធំលេងារី

នៅស្ងៀមៗ ទៅកុំចេះតែ ខ្មោចខ្មែរស្អប់ណាស់បងចង់ផ្តែ ។
ខ្ពើមណាស់សំដី ! កុំទំនើង

ភាណី

តិច ! មួយដើងផ្កាសាយភាំថ្ម (ភ្ញាំង) កុំអាងបានចា៎ឯងហែហែ
អ្នកថ្លៃតិចស្មាប់ដោយអញគាត់ ! . . . ។

ម៉ារ៉ា

អាក្រែពេះទុក់មាត់ឲ្យតិចទៅ អាណិតកូនទៅ! អាកុំមាត់អាឯងធំហើយ អញសូមយាត់

ភាណី

ផលនារីមានមាត់ឲ្យខូចចុះ ។ ភាណីពេញកំឡោះ នៅឲ្យនឹង!

ម៉ារ៉ា

និយាយទៅវ៉ែង អាបំលាស់ថោស និយាយនឹងអញសំដីថ្នោស!
មើលចុះអាកូន!...

ភាណី

ឫកវាថ្នូ! ។

ធីលនារី

ថ្ងៃតែឫកមាយាទថោក! ប្រយ័ត្នស្រីចោកអស់តីដៃ
នាលិកាចញ្ជឿនមានដំឡៃ តែស្រីត្រូវការបង់ដោះឲ្យ ។

ភាណី

មិនមែនឫកថោក ដូចភាណាវិទ្ធិ និយាយមិនគិតនោះទេវើយ!
លោកប៉ាកូនប៉ាជ្រាបស្រាប់ហើយ រឿងអ្វីក៏ដោយសុទ្ធកូនឯង ។
ចំណេះវិជ្ជាមានសព្វខ្លួន ដូចកូនបក្សីដុះស្លាបវែង
តែស្លាបក្រាស់ហើយចង់ដំទែង គិតលែងសម្បុកហើរចាកចេញ ។

ម៉ារ៉ា

ធ្លើម្តេចកម្មត្រៃធ៍របស់អញ ដូចជាឆ្នាំធ៍ខ្ញុំញ៉ាំធ៍ណាមិញ
ចំរាញ់យកខ្ញុំញ៉ែកចាន់ពេញ យកចេញឰរចោលលែធ៍ចាប់អាន ។
ប៉ុន្តែនុពុកឥតបើទឹធ៍ ទិដ្ឋិនោះធ៍មិនសាមាទ្យ
កូនចៅទាំធ៍អស់ចិត្តក្លាហាន វាចាន់ច្បាប់ឯធ៍ថាសម័យ ។

ភាណី

សម័យឲ្យគ្រួសារកម្មក្រាស ចោកច្បាសឲ្យយើធ៍ចុះអន់ថ្លៃ
សម័យនេះហើយសែនចង្រៃ! កុំយកមកថ្លៃនាំតែហត់! ។

ម៉ារ៉ា

ផលនារី! កូនស្រីអាណិតទុ ផ្ញាស់ខោចេញទៅស្លៀកសំពត់
ចិទចាំធ៍ពធ៍កាយកូនឲ្យគត់ សំពត់នេះហើយចារិកខ្នែរ ។
ទុក៏ដឹធ៍ដែរ ភាពសម័យ កុំធ្វើហួសត្រៃ មិនល្អទេ
ស្លៀកពាក់ខោអាវបិទចាំធ៍ក្តៅ! តែឯធ៍ហួសគេ! ឈ្លើយ! គេថា ។

ភាណី

ដេក ដើរ ឋិតឈរ អង្គុយគិត គំនិតគិតឃើញ ពិចារណា
ទឹធ៍ពោល ចន្ទឹ សព្វវាចា ចេញមកកាលណា ថ្លាឋ្លុំល្អក់ ។
ច្រើយ័ត្នត្រៃធ៍ខកខានចាន់ល្អ គឺជាផលល្អ ឋ្លុអាក្រក់

កុំស្រែវែងនុយ គេបង្អក តែងកដល់កការនឹងផ្ទៃក ។
ច្រាជ្យាយ៉ាងឯក! អន្ទងច្រាណ រំខានទុក្ខព្រួយស្រក់ទឹកភ្នែក
រួមឈាមតែមួយ ចែកពីវង្សក ចំណែកសម្បកបានមកយើង ។
គិតទៅសំដីដែលខ្ញុំថ្លែង សំដែងយ៉ាងនេះឥតទំនើង
គេស្រែកសាប់ឫកចចើង ឯងតែមិនឡើង អន់ជាប!!! ។

ចប់ឈុត ទី ១



រឿងប៉ុល ធីង ភីស៊ីង

លោក ធៀង-ជ្រីវសាស្ត្រាចារ្យ នៅសាលាគរុជ្ជាភ្នំពេញ

ប្រែរៀបរៀង

នៅខាងកើតភូមិ ដែលមាននៅខាងក្រោយកំពង់ឈ្មោះ ពរ-ល្វី នា-គោះរបស់ចាក់ដី គេឃើញមានខ្ទមចាស់តូចៗ ពីរដែលគេចោះបង់ចោលក្នុងទីវាលមួយ ។ ខ្ទមទាំងពីរនេះ ស្ថិតនៅស្ទើរតែចុងភាក់កណ្តាលទីជ្រលងមួយពាសពេញសុទ្ធតែថ្ម ដែលមានច្រកចេញចូលតែមួយ នៅទិសខាងជើង ។ ខាងឆ្វេង មានភ្នំមួយឈ្មោះឡឹមនដឹឡាដេគូវាត ។ នៅលើភ្នំនុះ គេសំពាប់ឲ្យដំណឹងអំពីកប៉ាល់មកចតនៅគោះ ។ នៅជិតភ្នំនុះមានផ្សារមួយឈ្មោះ ពរ-ល្វី ខាងស្តាំមានផ្លូវមួយទៅពីផ្សារនុះ ដម្រង់ភូមិមួយឈ្មោះបំពូមូស គេឃើញមានវិហារចាក់ដីមួយនៅនោះដែរ ឆ្ងាយបន្តិចទៅទៀត ឃើញមានសុទ្ធតែព្រៃរហូតដល់ចុងគោះ ។ នៅមាត់សមុទ្រ មានភូមិមួយឈ្មោះគោមប្ញ ខាងស្តាំភូមិនុះមានជ្រោយមួយឈ្មោះម៉ាឡឺរើ ពីជ្រោយនេះទៅកណ្តាលសមុទ្រ មានកូនគោះពីរ-បីគ្មានមនុស្សនៅ ជុះលេចឡើងពីទឹកកណ្តាលរលកចោកបែកផ្កាយត្រង់ ។

នៅត្រង់ច្រកដែលចូលទៅក្នុងកន្លែងនោះ គេឃើញមានតុផ្សេងៗជាច្រើន ពួសរំពង់ខ្សាច់បក់នៅត្រជិតខាង នឹងសួរលេចទឹកសមុទ្រដែលឆ្លើយឆ្លងគ្នាមិនដាច់ តែនៅជិតខ្ទមនោះគ្មានពួសរសំឡេងអ្វីសោះ គេ

ឃើញមានតែថ្ពស់ដូចជាកំពែងនឹងរុក្ខជាតិ លតាជាតិដុះតាមគ្រែហាង ថ្ម តាំងពីគ្រាមដល់កំពូលលើ វេលាភ្លៀងឥន្ធនូពណ៌ប្លែកៗ តាំងនៅពីខាងលើ ហើយមានស្នឹមមួយតូចហូរត្រជាក់ៗ នៅទីនោះ ។ ត្រង់ច្រកកំសាត់ច្រៀប មានតែព្រះពាយ៉ាបក់មកវេហ៍ក្រៗ និងទឹកហូរស្រឡាំងៗ ហើយនឹងពន្លឺថ្ងៃបន្តិចបន្តួច ។

ខ្ញុំបានចូលចិត្តនៅកំសាន្តកន្លែងនោះ ព្រោះស្ងាត់ស្ងប់ហើយអាចក្រឡេកមើលក៏បានឆ្ងាយ ។ មានមួយថ្ងៃ ខ្ញុំអង្គុយនៅក្បែរមន្ទុះ ហើយសំឡឹងមើលប្រជាប់ដែលខោលនៅទីនោះ ស្រាប់តែឃើញមនុស្សម្នាក់ចាស់ដើរមកក្បែរខ្ញុំ ។ អ្នកមន្ទុះស្រែកពាក់ភៅខ្លី អាវកូនចិនតាមទំនៀមបុរាណ ។ គាត់ដើរដើងទេ កាន់ឈើច្រត់មួយធ្លើពីឈើខ្ចៅ សក់សរព្រោង តែទឹកមុខនៅស្រស់ហើយរបៀបមិនចេះប្រកាន់ ។ ខ្ញុំគន់ប្រាប់គាត់ដោយសេចក្តីគោរព គាត់ត្រឡប់គន់ប្រាប់ខ្ញុំមកវិញ ។ លុះសំឡឹងមើលខ្ញុំបានសព្វៗ មួយស្របក់គាត់ក៏ដើរចូលមកជិត ហើយអង្គុយលើដីខ្លួលមួយដែលខ្ញុំបានអង្គុយហើយនោះ ។ ដោយសេចក្តីគ្នុកចិត្ត ខ្ញុំក្តួយសួរគាត់ថា "បពិត្រលោកតាពុក! អ្នកប្រាប់ខ្ញុំបានឬទេ តើភ្នំតាំងពីរហ្នឹងជារបស់អ្នកណា?" ។ គាត់ឆ្លើយថា "ក្មួន! ភ្នំមហ្នឹង ជីហ្នឹង ជារបស់ត្រកូលពីរដែលអាស្រ័យនៅប្រហែល ២០ ឆ្នាំហើយ ។ រឿងត្រកូលតាំងពីរនេះគួរឲ្យអនិច្ចាណាស់ ។ តែនៅត្រង់សម្តែងផ្លូវទៅស្រុកកូឆ្ន តើ

ទឹងមានជាតិអីរុបណា ចូលចិត្តចង់ដឹងរឿងកំខេចកំទីនេះ? តើអ្នកណា ទឹងចង់រស់នៅសប្បាយ តែគ្រហើយគ្មាននរណាស្គាល់ឡើយ? មនុស្ស តាំងអស់ចង់ដឹងតែរឿងបុគ្គលមានយសសក្តិ ឬរឿងស្តេចដែលមិនមាន អ្វីជាប្រយោជន៍ដល់អាត្មា" ។ ខ្ញុំនិយាយឡើងថា: "បពិត្រលោក ឥតុក! គ្រាន់តែឃើញទឹកមុខនឹងពុះដំ ខ្ញុំបានអាចយល់ថា លោកឥតុក ជាអ្នកយល់ការខុសត្រូវច្រើន ។ បើលោកឥតុកមានពេល សូមមេត្តា ក៏យកចិត្តរឿងរបស់ជនដែលនៅកងទីនេះ ឲ្យខ្ញុំបានស្តាប់បន្តិច សូម លោកឥតុកជឿថា មនុស្សយើងសូម្បីជាអ្នកមិនជឿមនុស្សបុពណាគង់ ចូលចិត្តចង់ស្តាប់ការសុខទុក្ខដែលកើតពីធម្មតាលោកនឹងធម៌ដែរ" ។ ឥតុសាសនោះ តាចាស់ធ្វើដូចជានឹករកនូវកាលវេលាដែលកន្លងផុតទៅ យកដៃជាក់លើថ្ងាស ហើយថ្លែងថា:

ក្នុង គ. ស. ๑๗๒๖ មានប្រុសកំឡោះម្នាក់ នៅស្រុក នរម៉ង់ឌី ឈ្មោះឡាតួរ កាលណារកស៊ុំការធ្វើមិនបានឯប្រទេសជាំង ហើយពួក សាច់ញាតិមិនជួយទំនុកបំរុងផង ក៏ជាប់ចិត្តមកនៅរកស៊ីកងកោះនេះ ។ ចៅនេះមានប្រពន្ធមួយ តែងស្រឡាញ់គ្នាទៅវិញទៅមកអស់ពីចិត្ត ។ នាងនេះជាស្ត្រី នៃត្រកូលស្តុកស្តម្ភមួយ នៅក្នុងស្រុកដូចគេឯងដែរ ឡាតួរលបយកនាងនេះ ដោយសារតំហាំង តែឥតុកម្តាយនាងមិនព្រម រៀបការឲ្យ ព្រោះគេថាចៅនុ៎ះមិនមែនជាពូជនៃអ្នកអម្បូរខ្ពស់ ។ ចៅ

ឡាតួរ ទុកប្រពន្ធឲ្យនៅ ពរ-ល្វី តែងកោះ ហើយខ្លួនក៏ចុះកប៉ាល់ទៅ ប្រទេស ម៉ាដាគាស្កា ដើម្បីកេងប្រវ័ញ្ចធនធានពីរបីនាក់ ដោយមានបំណង នឹងត្រឡប់មកវិញយ៉ាងឆាប់នឹងធ្វើផ្ទះនៅ ។ គាត់ចេញទៅវេលាពាក់ កណ្តាលខែតុលាដែលជារដូវមិនល្អ លុះទៅដល់ស្រុកគេមិនបានប៉ុន្មាន ថ្ងៃ ក៏ស្លាប់នឹងគ្រុនពិសទៅ របស់ទាំងប៉ុន្មានដែលនាំមកពីស្រុកនាយ ក៏អាតអាយបាត់អស់ ។ នាងប្រពន្ធដែលនៅរង់ចាំឯកោះ ទៅ ជាស្រីមេម៉ាយមានផ្ទៃពោះផង គ្មានទ្រព្យអ្វីសោះ ហើយមានតែស្រីតូច ម្នាក់ទៅគ្រាន់បំរើជាគ្នា ។ ឈប់គិតត្រូវការនឹងប្តីសឹងជាប់ស្រឡះ ក្រៃ ដែលប្តីនាងស្លាប់ទៅ. នាងញាំងចិត្តក្លាហានឲ្យមានឡើងកងសន្ធាន នៅ បណ្តាសេចក្តីទុក្ខលំបាកដែលមកប៉ះពាល់ ។ នាងនេះពីរនាក់នឹងនាង តួង ស្រុះចិត្តគ្នានឹងទៅរកជាំដំណាំក្នុងដីតូចមួយ ដើម្បីយកផលមក ចិញ្ចឹមជីវិត ។

នាងមេម៉ាយនឹងនាងតួងចេញចាក ពរ-ល្វី ដើរលាក់ខ្លួនពួនអាត្មា នៅក្នុងកន្លែងមួយជាប់ពីគេ ជារហោស្ថានមានដីគ្រាន់តែជាំដំណាំបាន កែរដើងកំមួយ ។

(មានត)

អំពីបន្ទៀកបំពាក់ខ្មែរ

របស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

ក្រុមជំនុំទំនៀមទម្លាប់ចាន់តែឆ្នើងចំនួន ១៨ ឆ្នាំហើយ ប៉ុន្តែនៅមានជនជាច្រើនណាស់ពុំទាន់ស្គាល់ក្រសួងនេះនៅឡើយ ។

ជនខ្លះដែលចាន់ឮសូរឈ្មោះក្រសួងនេះ តែងឆាន់មាត់ថា "យី! ស្រុកខ្មែរយើង មានក្រសួងទំនៀមទម្លាប់ដែរ ចុះក្រសួងនេះធ្វើការអ្វីខ្លះទៅ មានប្រយោជន៍យ៉ាងណាទៅ?" ។ ពាក្យឆ្លើយបែបនេះ បង្ហាញឲ្យយើងឃើញថា ក្រុមជំនុំទំនៀមទម្លាប់ជាកន្ទែងកប់ — ព្រោះគេគិតស្មានថាជាការឥតប្រយោជន៍ ។

ក្នុងខណៈនេះ យើងសូមជំរាបអស់លោកអ្នកដែលតែងតែសួរពីប្រយោជន៍ក្រុមជំនុំទំនៀមទម្លាប់ថា ក្រុមជំនុំនេះមានដំណើរមិនត្រឹមតែធ្វើឲ្យប្រទេសជាទីស្គាល់របស់អ្វីខាងប៉ុន្មាន ដែលជាប្រពៃណីខ្មែរប៉ុណ្ណោះទេ ថែមទាំងរក្សាទុកនូវប្រពៃណីនេះទៅអនាគតផង ។ កន្លងយូរទៅលុះប្រទេសខ្មែរយើងមានអារ្យធម៌កាន់តែចំរើនឡើង ច្រើនតែភ្លេចទំនៀមទម្លាប់បុរាណខាងឡាយ រកឫសរកគល់ពុំឃើញ ។

ហេតុដូច្នេះហើយ ចាន់ជាក្រុមជំនុំទំស្រាវជ្រាវរកប្រពៃណីអស់ទាំងនេះមករក្សាទុក. តទៅមុខជនណាចង់ដឹងរឿងព័ត៌មាននេះមុខជានឹងមករកឃើញនៅមន្ទីរក្រុមជំនុំនៃពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញស្រាប់ ។

ក្នុងរឿងនេះ យើងបង់បង្ហាញឲ្យឃើញថា រឿងព័ទ៌ាំងប៉ុន្មានសុទ្ធ តែពីពេះពីសា បើកាលណាមានគោលចារិកត្រឹមត្រូវល្អ ហើយនឹងរៀបរាប់ឲ្យបានសព្វគ្រប់ផង ។

លុះអំណោះទៅអនាគត ជីវភាពនៃខ្មែរយើងបានចំរើនខ្ពាំងឡើង, រឿងព័ទ៌ាំងនេះអាចជួយឲ្យខេមរជនជាន់ក្រោយ សំដែងនូវសារជាតិរបស់ខ្លួនបាន ។

ម្យ៉ាងទៀត នាំឲ្យជននានាប្រទេសយើញច្បាស់ថា ជនជាតិខ្មែរមានអារ្យធម៌ប្រហែលគ្នានឹងប្រទេសណា យ៉ាងណាខ្លះ ហើយនឹងប្លែកពីគេ យ៉ាងណាខ្លះ ។

ក្រុមដំនុំសង្ឃឹមថា ការបង្កើតឲ្យមានក្រសួងទំនៀមទម្លាប់ខ្មែរឡើង នាំឲ្យអ្នកចេះចាំទំនៀមទម្លាប់ខ្មែរទាំងឡាយ សរសេរតែងរឿងផ្សេងៗ ផ្ញើទៅក្រុមដំនុំតាមដែលខ្លួនបានចេះចាំ ។

ក្នុងឆ្នាំ ១៩៥១ ដែលទើបនឹងដាច់ទៅនេះ ក្រុមដំនុំបានទទួលឯកសារចំនួនជាង ២០០ ប្លែកៗ គ្នា, បើប្រសិនជាយកការទាំងអស់នេះមកអធិប្បាយក្នុងពេលនេះតែម្តង យើញថាច្រើនពេកណាស់, ដូច្នេះយើងសូមរើសយកតែរឿងមួយមកអធិប្បាយជូនសិន ក្នុងខណៈនេះ "អំពីសម្បៀកបំពាក់ខ្មែរ, ដោយមានបណ្តាជនជាតិជាច្រើនចង់ដឹងដោយច្បាស់លាស់" ។

រឿងនេះ ការសែតកម្ពុជាបានទាំមកពណ៌នាម្តងរួចហើយ ។

តាលសម័យបុពណ ខ្មែរអ្នកចេះធ្លាប់ហ្លួបក្តី ចេះសិល្បអាគមក្តី ចេះចាំទំនៀមផ្សេង ។ ក្តី ចេះស្មូតខាងការតាក្យាវរៃក្តី ចេះសង់ផ្ទះ ចេះធ្វើរនេះគោ ឬធ្វើរបស់ឯទៀត ។ ក្តី ចំរើនតែតឹមកូនចៅខ្លួនប៉ុណ្ណោះ បើកូនចៅនោះយកចិត្តទុកដាក់ក៏ចេះចាំ ធ្វើដំណាងឪពុកម្តាយទៅ, បើកូនមិនរវៃទេ អំណើះពីឪពុកម្តាយទៅ, គ្មានអ្នកណាជាខែនឹងអាចចេះផងម្ល៉ោះហើយបានជាខ្មែរច្រើនតែល្ងង់ ដោយមិនបានគិតគត់ត្រាទុកជាក្បួនថែមទាំងចង់ល្ងាក់ចំណេះផង, ប៉ុន្តែជាយូរឆ្នាំក្រៃលមកហើយ ខ្មែរបានលះចោលគំនិតនេះខ្លះ ហើយអ្នកចេះដឹងគេចូលចិត្តចែកចំណេះទៅអ្នកឯទៀតឲ្យបានច្រើនគ្នា, ខ្លះខ្លាតក៏ទុកត់ត្រាទុកដើម្បីកុំឲ្យកប់ទៅជាមួយនឹងមរណភាពបាន ។

យើងតែងដឹងថា សម្លៀកបំពាក់ជាគ្រឿងសំគាល់ជាតិ បុគ្គលនិមួយ ។ តែងមានចិត្តរីករាយចំពោះការស្លៀកពាក់ ឲ្យសម្លៀកបំពាក់របស់ជាតិខ្លួន ជាជាងខ្លីរបៀបជាតិដទៃមកស្លៀកពាក់ជាជាតិ ។ បើដូច្នេះ គួរតែយើងខំតុបតែងសម្លៀកបំពាក់យើងឲ្យបានផលប្រសើរល្អ ហើយដើម្បីមិនឲ្យសាបសូន្យប្រពៃណីខ្មែរសុទ្ធ ។ ផង ។

អស់លោក អ្នកចាំងឡាយជ្រាបស្រាប់ហើយ ថាបណ្តាពស្ត្រខ្មែរសព្វថ្ងៃកំពុងតែវែកចេញពីពៃស្បាតគឺសេចក្តីអាប់ឧនទៅរកសេចក្តី

ចំរើន, តាំងសម្លៀកបំពាក់សោត ក៏ចេះតែផ្លាស់ប្តូររូបរាងទៅតាមកាលសម័យដែរ ។ ការដែលយើងនាំមកពណ៌នាដូចមានតទៅខាងមុខនេះ មិនមែនយើងចង់ឲ្យអស់លោក អ្នកអាន អ្នកស្តាប់រំលត់ឡប់ថយក្រោយទេ គឺគ្រាន់តែឲ្យស្គាល់ឲ្យដឹងសាវតារបស់ខ្លួនយ៉ាងណាខ្លះ; តាំងនានាជាតិក៏គេនិយមរិះរកគោលចរិក ដើមកំណើតទំនៀមទម្លាប់របស់គេឲ្យស្គាល់តាមពិតយ៉ាងនេះដែរ ។

តាមសេចក្តីកត់ហេតុរបស់អ្នកដំណើរជាតិចិនឈ្មោះ ជាវ - តា - គួន នឹងសេចក្តីឲ្យការរបស់សមាជិកប្រចាំខែត្រខ្លះ មានចំនងស្របគ្នាជាច្រើន ។

កន្លងំណោមនេះ អ្នកអង្គម្ចាស់ នរោត្តម - សុខានារី ជាន់ឲ្យការប្លែក ។ ហេតុនេះយើងសូមស្រង់សេចក្តីនោះយកមកពណ៌នាដូនអស់លោកអ្នកអានស្តាប់ដូចមានតទៅនេះ :

អំពីសម្លៀកបំពាក់ខ្មែរសម័យបុរាណ

(តាមដែលអ្នកអង្គម្ចាស់ នរោត្តម—សុខានារី ឲ្យការមក)

យើងសព្វថ្ងៃមិនអាចដឹងបានដោយសព្វគ្រប់ អំពីសំលៀកបំពាក់របស់បុព្វបុរសយើងទេ ដោយទំនៀមនេះ កន្លងជាយូរអង្វែងណាស់ទៅហើយផង ដោយយើងគ្មានឯកសារ ឬសៀវភៅឯណាកត់ត្រាទុកជាកន្លងសម័យនេះគេស្លៀកពាក់បែបនេះ, សម័យនោះគេស្លៀកពាក់បែប

នោះផង, តែដោយការសង្កេតមើលតាមរូបចម្លាក់ថ្ម ដែលមានសេស
សល់អំពីប្រាសាទបុរាណចាក់បែកមក យើងក៏អាចយល់ច្បាស់ថា កង
សម័យនោះបុព្វបុរសរបស់យើងស្លៀកសំពត់ចង្កឹះ អាវតមូល ដៃធ្លាក់
មកត្រឹមកំភួនដៃ ឬអាវតមូលតូចដៃវែងស្អិចនុបជាប់នឹងសាច់ ធ្លាក់ចុះ
មកត្រឹមចង្កេះ, ជួនកាលឃើញស្លៀកតែសំពត់ឥតអាវក៏មាន នេះ
ចំណែកបុរស, ចំណែកស្ត្រីវិញឃើញស្លៀកសំពត់សំឡុយពាន្ទាស្បៃ
ឬស្លៀកសំឡុយខ្លួនទទេមួយកំណាត់ក៏មាន ។

ចំណែកឯស្នាព្រះពាជទ្រព្យ របស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង
ដែលរក្សារបៀបស្លៀកពាក់របស់ខ្មែរអំពីបុរាណ ឥតមានប្រែប្រួលនោះ
យើងឃើញថា បុរសស្លៀកខោពីកង ជើងតូចធ្លាក់ដល់ត្រឹមកំភួនជើង
ហើយមានស្លៀកសំពត់ចង្កឹះពីលើខោថែមទៀត ព្រមទាំងមានចង
ផ្ចាំងក្រណាត់តូចវែងនៅពីមុខ ទំាងនៅសង្ខាងចង្កេះផង នេះចំណែក
បុរស, ឯចំណែកស្ត្រីឃើញស្លៀកសំពត់សំឡុយ ពាក់ស្បៃ ឬពាន្ទាផ្ចង
ច្បាក់ឱនមាសច្បាក់ ។ យើងក៏ឃើញខ្លះដែរ កាលពីដើមប្រុសខ្មែរ
ដែលប្រកាន់ទំនៀមបុរាណ ស្លៀកសំពត់ចង្កឹះជាមួយនឹងអាវកុតកត្រង់
ឬអាវឡៃវ៉ាខ្ពុំ ដែលហៅថាអាវចិន ឬជាមួយនឹងអាវតមូលដៃខ្លីធ្លាក់ស្មើ
តែងដៃ ឬជាមួយនឹងអាវកសន្ទះ ដៃធ្លាក់ត្រឹមកដៃ, ជួនកាលក៏ស្លៀកខោ
ដែរ ដែលយើងហៅថាខោចិន ។ ឯស្ត្រីខ្មែរវិញ ឃើញស្លៀកសំពត់

សំឡុយ សំពត់ចងក្បាច ពាក់អាវមានស្នាតែខាងឆ្វេង ហើយពាក្រមាវែង ដែលហៅតាមភាសាសៀមថាផាហុំ លើស្មាទាំងសងខាងសំយុងជាយទៅខាងមុខ ឬពាក់អាវបំពង់វែង កមូលដៃតូច ផ្លាក់ដល់កដៃ ខ្លួនតូចចង្កេរតូច ផ្លាក់ដល់ត្រឹមកំភួនជើង បង់កក្រមា, អាវម៉ាឡាយ បង់កក្រមា, អាវសន្ទះ បង់កក្រមា, ទឹងអាវហាតាចិប ក្រវាត់ក្រមាឈៀងមួយចំហៀងខ្លួន ។

សំពត់ចងក្បាច កាលអំពីសម័យព្រៃងនាយ មានតែបុរសទេដែលស្លៀកសំពត់ចងក្បាច ស្ត្រីមិនឃើញស្លៀកទេ ។ ឯសំពត់ចងក្បាចដែលគេស្លៀកសម័យបុរាណក៏មិនដូចយើងសម័យបច្ចុប្បន្នទេ, បើតាមរូបចម្លាក់នៅដញ្ជាំងក្រាសាទបុរាណ គេឃើញស្លៀកខ្លីច ។ នៅពាក់កណ្តាលភ្លៅ សូម្បីពួកស្មេនព្រះពជ្រឥន្ទ្រ ដែលជាសិល្បៈរក្សាទុកនូវទំនៀមសម្លៀកបំពាក់បុរាណមួយបែប ក៏ឃើញស្លៀកសំពត់ចងក្បាចខ្លីច នៅលើក្បាលជង្គង់ដែរ ។ ឯទំហុំសំពត់ សម័យបុរាណប្រហែលប៉ុន្មានទឹងទំហុំសំពត់សម័យបច្ចុប្បន្នដែរមើលទៅ គឺទទឹង ១ ម៉ែត្រ បណ្តោយ ៣ ម៉ែត្រ ២០ ។ របៀបស្លៀកនោះឃើញថាខុសគ្នាច្រើន អំពីបុរាណគេកង្ហាញ់ដើបជាយសំពត់ទាំងសងខាងឲ្យនៅតែប្រវែងមួយដុំចង្កេះ រួចហើយគេស្លៀកជាក់ជាយសំពត់នោះត្រួតលើគ្នា ចងជាថ្នាក់ហើយគេក្រវាត់ខ្សែក្រវាត់ដើម្បីមិនឲ្យរបូត ។ ឯជាយសំពត់ដែល

ដីបាំងសងខាងគេដេរភ្ជាប់ជាក់តម្រួតលើគ្នា ហើយគេយកចុងជាយ
ខាងក្រោមសឹកតាមប្រឡោះដើងបាំងសងខាង យកមកចុកនៅចង្កេះខាង
ក្រោយ, ចំណែកសំពត់ចងក្បាលដែលយើងស្លៀកក្នុងបច្ចុប្បន្ននេះក៏មាន
ទំហុំប្រហែលគ្នាដែរ តែរបៀបស្លៀកខុសគ្នា គឺគេយកសំពត់មកស្លៀក
ពុកចោលជាយបាំងសងខាង នៅរែងអង្ខាយអូសដី ហើយឲ្យមានប្រវែង
ស្មើមុខក្រោយ តោះខុសគ្នាក៏ខុសបន្តិចបន្តួចចំនួនត្រឹមមួយទះប៉ុណ្ណោះ
រួចគេផ្គួបជាយបាំងសងខាងរួមគ្នា ហើយគេមួរ រួចហើយគេស៊កតាម
ប្រឡោះដើងបាំងសងខាង យកចុងទៅចុកនៅចង្កេះខាងក្រោយ, ឯ
សំរុងសំពត់ដែលស្លៀកហើយគេឲ្យធ្លាក់ចុះនៅត្រឹមស្នងដើង ។

(មានត)

ទំនៀមទម្លាប់ ជាព្រំដែន របស់ជាតិនីមួយៗ,
អ្នកសិក្សាវិជ្ជាខាងទំនៀមទម្លាប់ របស់ជាតិ
ឈ្មោះហៅ "អ្នកស្នេហាជាតិ" ។

ទំនៀមបុណ្យភ្ជុំបិណ្ឌ

នៅវិទ្យាល័យស៊ីសុវត្ថិ ភ្នំពេញ

របស់ក្រុមសាស្ត្រាចារ្យនិងក្រុមសិស្ស

ពាល់តែធ្នាំកន្ធរថ្ងៃរោចខាងក្រោយចេញវស្សា ១ ខែ នៅវិទ្យាល័យ-ស៊ីសុវត្ថិ សឹងតែរៀបចំគ្រែ រចនាដោយស្លឹកឈើ ផ្កាឈើ, ទន់ជាតិ, ទឹងក្ងើងអគ្គិសនីរំលេចពណ៌ក្រហមសខៀវ ភ្លឺព្រាងព្រាត ។ ក្នុងវេលាយប់នោះមានព្រះសង្ឃចំរើនព្រះបរិត្ត រួចមានព្រះធម្មកថិកសំដែងព្រះធម៌ទេសនា ។ បន្ទាប់មក ពួកសិស្សវិទ្យាល័យស៊ីសុវត្ថិ ចាប់ផ្តើមលេងល្ខោនជារឿងបំភ្លឺជនរួមជាតិ ឲ្យស្គាល់គុណទឹងទោស ប្រយោជន៍ទឹងឥតប្រយោជន៍ ទឹង លេងក្ងើងតូរ្យតន្ត្រីពីរោះគួរជាទីចាប់ចិត្ត ។ ព្រឹកឡើងសាស្ត្រាចារ្យនិងសិស្សទាំងឡាយ សឹងតែតែងតួរស្លៀកពាក់ស្អាតបាត តាមទំនៀមជាតិខ្មែរដើរជឿនគ្នាជាដួរ ដៃកាន់គ្រែចីវរគ្រឿងបរិក្ខារនិងទេយ្យទានផ្សេង ។ ដង្ហែចេញពីសាលាវិទ្យាល័យទៅតាមផ្លូវនានាក្នុងក្រុង រួចបួលទៅក្នុងអារាមនៅក្រុង ឬ ក្រៅក្រុង វេរប្រគេនទូរគ្រែចីវរចំពោះព្រះសង្ឃ រួចហើយក៏វិលត្រឡប់មកវិញ ។

ពិធីបុណ្យនោះហៅថា បុណ្យកឋិនរបស់ក្រុមសាស្ត្រាចារ្យ និងក្រុមសិស្សនៅសាលាវិទ្យាល័យស៊ីសុវត្ថិ ដែលមានសទ្ធាជ្រះថ្លាក្នុង

ព្រះពុទ្ធសាសនា ប្រាន ព្រមព្រៀងគ្នាបវិច្ចាគធនធានរៀងខ្លួន បង្កើតធ្វើឡើងរាល់ឆ្នាំជាប់ជាទំនៀមរហូតមកដល់ឆ្នាំនេះ ។

កិច្ចដែលនឹងដង្ហែអង្គកឋិនទាននេះ ទៅថ្វាយព្រះសង្ឃគង់នៅវត្តណាមិមួយ មិនថាវត្តគណៈធម្មយុត្តិ ឬមហានិកាយទេ ស្រេចហើយតែស្ងាកដែលចាប់ឆ្នោតវត្តនោះ ។

នៅឆ្នាំ ១៩៥១ នេះ ក្រុមសិស្សបានចាប់ស្ងាកត្រូវលើឈ្មោះវត្តមង្គលវន (ស្វាយដង្គំ) សង្កាត់លេខ ៣ ក្រុងភ្នំពេញ ក៏នាំគ្នាហែកឋិនទៅប្រគេនព្រះសង្ឃគង់នៅវត្តនោះ ។

បុព្វហេតុដែលក្រុមសាស្ត្រាចារ្យ និងក្រុមសិស្សនៃវិទ្យាល័យនេះនាំគ្នាធ្វើបុណ្យកឋិនរាល់ឆ្នាំ គឺដែលខាងសឹងមានពោលក្នុងសុន្ទរកថាដែលសិស្សឈ្មោះ ហ៊ុយ - ឌឹម សូត្រជាដំណាងសិស្សទាំងអស់នៅពេលធ្វើកឋិនទានក្នុងឆ្នាំ ១៩៥១ ដូចមានចុះជូនអ្នកអានតទៅនេះ :

សុន្ទរកថា កាឯនឆាន

នៃសិស្សានុសិស្សវិទ្យាល័យស៊ីសុវត្ថិ ឆ្នាំ ១៩៥១

ហៅទៅវិរប្រគេនដល់ព្រះសង្ឃគង់នៅវត្តស្វាយដង្គំ ឃុំលេខ ៣ ក្រុងភ្នំពេញ

(ហ៊ុយ - ឆឹម : ជាអ្នកតែងនឹងសូត្រ)

សូមក្រាបបង្គំទូល !

ទ្រង់ !

សូមជំពាក់ឯកឧត្តម !

នូវអស់លោក - អស់អ្នកសប្បុរសទាំងឡាយ ព្រមទាំងមិត្តគ្រប់គ្នា !

ពេលនេះជាកិត្តិយសមួយដ៏ប្រសើរពណ្ណាយ ចំពោះវិទ្យាល័យ-ស៊ីសុវត្ថិទាំងមូល ដោយបានទ្រង់, ឯកឧត្តម នឹងអស់លោកអស់អ្នកសប្បុរសជាពុទ្ធមាមក: ទាំងឡាយ ដែលទ្រង់សព្វព្រះកដហឫទ័យសោមនស្ស យាងនឹងអញ្ជើញមកយ៉ាងឧឡារិក ជាអធិបតីនៃបុណ្យកឋិននេះ ។

ទូលព្រះបង្គំជាខ្ញុំ, ខ្ញុំបាទសូមថ្វែងអំណរដ៏វៃក្រៃលែងចំពោះទ្រង់ អស់លោក ក្នុងនាមនៃមិត្តរបស់ទូលព្រះបង្គំ ខ្ញុំបាទ នឹងក្នុងនាមនៃវិទ្យាល័យ ស៊ីសុវត្ថិ ដែលជាទីប្រជុំសិក្សាវិទ្យាសាស្ត្រក្នុងកម្ពុជរដ្ឋទាំងមូល ។

សូមខ្ញុំ ឯកឧត្តម អស់លោក មេត្តា ព្រះពរជ័យនៃសេចក្តី នឹង ត្រាប្រណីដល់ទូលព្រះបង្គំ យើងខ្ញុំ ក្នែងមានខុសឆ្គាំឆ្គងត្រង់កិច្ច បដិសណ្ឋារៈ នឹងឋានវិស្សាល័យចង្អៀតចង្អល់ ទាំងកន្លែងក៏ពុំសូវប្រពៃ តាមព្រះពរជ្ជានៈ នឹងសមរម្យ ចំពោះខ្ញុំ, អស់លោក ។

បុព្វហេតុដើម ដែលអាចញុំាងកថិនទានរបស់យើងខ្ញុំឲ្យពន្ធូកលូតលាស់ ដង្គើលដង្គំ រុងរឿងយ៉ាងដូច្នេះ គើតឡើងដោយបំណងច្រើនយ៉ាង :

๑- ដោយយើងខ្ញុំ មានចំណង់ចង់រក្សាទំនៀមទំលាប់រៀមច្បងរបស់យើងខ្ញុំដែលតែងតែធ្វើបុណ្យនេះ រៀងរាល់ឆ្នាំជាយូរយោរណាស់មកហើយ នឹងដើម្បីរក្សាប្រពៃណីរបស់ច្បាប់ព្រះពុទ្ធសាសនា ដែលធ្លាប់មានពិធីកថិនទាន ក្រោយវេលាចេញព្រះវស្សា តាំងពីសម័យព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ ។

๒- ដោយយើងខ្ញុំមានគំនិតយល់ជាក់ច្បាស់ថា: ការធ្វើបុណ្យនេះជាកិច្ចមួយដ៏ប្រពៃចំពោះយើងខ្ញុំ ពីព្រោះពិធីបុណ្យក្នុងព្រះពុទ្ធ-សាសនាជាច្បាប់មួយ អាចទូន្មានប្រដៅដល់យើងខ្ញុំ ឲ្យមានសាមគ្គីធម៌ ឲ្យចេះរួបរួមសន្ដានចិត្ត មូលមិត្តនឹងគ្នាធ្វើការដោយមាំមួន ហើយអាចនឹងបង្រៀន ឲ្យយើងខ្ញុំចេះចាត់ចែងការតាំងពីនៅកុមារ រហូតដល់ចាស់ជរា ។

៣ – ដោយយើងខ្ញុំមានបំណងប៉ងនឹងរក្សាលទ្ធិព្រះពុទ្ធសាសនា ដែលជាសាសនាប្រៀនប្រដៅមនុស្សលោក ឲ្យចេះរាប់អានគ្នា ឲ្យចេះស្រឡាញ់គ្នា ឲ្យមានចិត្តស្លូតត្រង់មេត្តាករុណាគ្នា នឹងឲ្យមានសាមគ្គីធម៌នេះហើយដែលជាកម្លាំងមួយយ៉ាងមាំ សំពាប់ដឹកនាំនឹងបំភ្លឺផ្លូវបណ្តាជនដែលមានសញ្ជាតិជាមួយគ្នា ឲ្យធ្វើដំណើរទៅមុខបានស្រួលស្រួល មិនគុំគួនប្រកួតប្រណាំងខឹងទាស់ខ្វែងគំនិតពីគ្នា មិនឲ្យបាក់បែកគ្នាឡើយ ។

ម្យ៉ាងទៀត ព្រះពុទ្ធសាសនា ដែលឧមរជនជាតិយើងកាប់អានគោរពប្រតិបត្តិសព្វថ្ងៃនេះ ពុំមែនមានប្រយោជន៍សំខាន់ តឹមតែហុចផលទៅបរលោក សួគ៌ និព្វាន ប៉ុណ្ណោះទេ! អាចផ្តល់ប្រយោជន៍សំខាន់ៗ ជារបៀនទៀតគឺ :

ជាឃ្លាំងសំដីភាសារបស់ខ្មែរ !

ជាឃ្លាំងច្បាប់ទំនៀមទំលាប់ខ្មែរ !

ជាឃ្លាំងវប្បធម៌ដ៏ធំធ្ងន !

នឹងជាឃ្លាំងទុតមគតិរបស់ជាតិយើង !

មួយវិញទៀត អារ្យធម៌របស់ជាតិយើង ដែលមានសេសសល់ទៅបន្តិចបន្តួច មកដល់សព្វថ្ងៃនេះ គ្រាយដែលនៅគ្រាមអំណាចឥទ្ធិពលរបស់ជាតិដទៃ អស់ពាន់ជាយូរអង្វែងឆ្ងាំមកហើយនោះ គួរណាស់តែរលត់លោយសាបសូន្យអស់រលីងទៅហើយ ប៉ុន្តែដោយសារមូលហេតុ

អក្សរនឹងអារម្មណ៍នោះ ក៏អាចជ្រកកោនគង់ជីវិតរស់ដល់មកសព្វថ្ងៃនេះ។ ថ្វីបើនៅតាមផ្សារ តាមផ្លូវនៃទីក្រុងនានា គេឮស្តែសព្វតែសម្លេងភាសាជាតិដទៃ មានចិនយួនជាដើម ហើយនៅមន្ទីរធ្វើការខាងផ្លូវពាជការទាំងពួងគេឮស្តែសព្វសំដី និយាយជាភាសាចាំង, តែកងវត្តទាំងឡាយនៅពេលធម្មតាក្តី ឬវេលាបុណ្យទានក្តី ខ្មែរ និយាយទៅគាន់ខ្មែរតែជាភាសាខ្មែរ ។

ខ្ញុំ!

ឯកឧត្តម!

អស់លោក!

គង់ខ្ញុំជ្រាប ចាន់ជ្រាប ចាន់ឮខ្លះ អំពីជនជាតិយើងជាច្រើនពាន់នាក់ដែលមានលំនៅក្នុងដែនកូសាំងស៊ីន នៅក្រោមអំណាចរដ្ឋាភិបាលរបស់ជាតិដទៃ ហើយនិយាយតែភាសាជាតិដទៃ ។ តើយើងអាចស្គាល់ជនអស់ពាំងនោះ ថាជាជាតិខ្មែរចាន់ដែរឬទេ? ប៉ែប្រសិនណាជាយើងស្គាល់ តើយើងសំគាល់ដោយហេតុអ្វី? ដោយពិតតែមានតែវត្តចាក់បែកដែលនៅសេសសល់ខ្លះនោះហើយជាគោលចារឹក បង្ហាញជាកស្តុតាងយ៉ាងជាក់ច្បាស់ ថាជាខេមរជាតិពិត ។ ហេតុដូច្នោះហើយចាន់ជាព្រះមហាចក្រពត្តាធិរាជព្រះនាមព្រះចាន់ " ណាប៉ូលេអុងទី ១ " (Napoléon 1) ដែលជាមហាក្សត្រយ៉ាងឯកនៃប្រទេសចាំងខ្ញុំចាន

ចេញព្រះពាជនុដ្ឋារថា : "សាសនា មានសណ្ឋានដូចត្រីវិស័យ, ប្រទេសណាឥតសាសនា ប្រទេសនោះដូចជានាវាមួយ ដ៏ធំធេងឥតត្រីវិស័យជាមគ្គុទ្ទេស" ។

ម្យ៉ាងទៀត ការដែលបង្ខំសន្ដានចិត្តរបស់ខ្ញុំព្រះបង្គំ, យើងខ្ញុំឲ្យផ្ដួចផ្ដើមធ្វើបុណ្យកឋិនេះ មិនមែនចំពោះតែតាមបំណងខាងលើនេះទេ គឺមានបំណងម្យ៉ាងទៀត ដ៏សំខាន់ :

"វត្តមង្គលវ័ន ស្ថាយជង្គុំ ជាបូជនីយស្ថានមួយបិតនៅកៀនចន្ទោះត្រង់កន្ទៀតជ្រោះ នៃទីក្រុងភ្នំពេញ ឆ្ងាយជាច់អាល័យពីទីប្រជុំការសិក្សានានា មានសាលាបឋមសិក្សាទីវិទ្យាល័យជាដើម ។ កុមារតូចៗ របស់អ្នកក្រីក្រកំសត់ទុគ៌ត មានចំនួនពាប់រយនាក់ច្រើនតែទៅនៅសំណាក់អាស្រ័យនឹងកុដិព្រះសង្ឃនាទីនោះ ដើម្បីនឹងស្វែងរកដំរេះវិជ្ជាអំពីលោក ។ ខ្ញុំព្រះបង្គំយើងខ្ញុំទាំងឡាយ យល់ឃើញជានិច្ចថា ធម្មតាសាលាបឋមសិក្សាខ្មែរ ដែលកើតឡើងក្នុងវត្តដោយសារលោកសង្ឃ មិនសូវរឹងប៉ឹង មិនសូវមាំទាំ អាចនឹងធ្វើឲ្យកុមារទុគ៌តទាំងនោះរៀនបានស្ទួលប៉ុន្មានទេ ! ម្ល៉ោះហើយដំរេះវិជ្ជារបស់កុមារ ក៏តែតែយឺតយូរមិនអាចនឹងធ្វើដំហានទៅដោយរួសរាន់ ឲ្យទាប់ហ៊ានសម័យនឹងគេឡើយ ច្រើនតែគាន់តែរៀនបានចេះមើលអក្សរអាក់រអួល ហើយក៏ប្ដូរជាកិក្ខុសាមណេរទៅ ។ ព្រោះហេតុនេះហើយបានជាអ្នកចេះនៅស្រុកខ្មែរយើងមានចំនួនតិចណាស់ ។

ខ្ញុំ! អាសូរជាតិខ្មែរល្ងង់ខ្លៅ! ម្តេចក៏ដេរអ្នយឺតយូរម្ល៉ះ! បើខ្លះវិជ្ជាជូរចេះតើបានសេចក្តីសុខ សេចក្តីចំរើនមកពីណាហ្ន៎, ព្រោះតាមមធ្យោបាយក្នុងស្រែហិតោបទេសរបស់លោក "អេឌួអ័ដ្ឋឡង់សារ៉ូ" (Edouard Lan Saro) ការបណ្តិតជាតិជាកំង វែប្រពីការសាសំស្តឹត លោកបានពោលទុកថា: "វិជ្ជានាំឲ្យបានវិន័យ, វិន័យនាំឲ្យកើតសេចក្តីថ្លៃថ្នូរ, សេចក្តីថ្លៃថ្នូរ នាំឲ្យបានទ្រព្យ, ទ្រព្យនាំឲ្យកើតធម៌, ធម៌នាំឲ្យបានសុខ" ។

ព្រោះហេតុនោះហើយ បានជាយើងខ្ញុំ ទំលែងចែករំលែកចតុប្បច្ច័យនៃកថិនទាននេះ ជា ២ ផ្នែក; ១ ផ្នែកសំរាប់បរិក្ខាគចំពោះការកសាងសាលាបឋមវិជ្ជាខ្មែរ ១ យ៉ាងតូចល្មម, ១ ផ្នែកទៀតវេប្រគេនព្រះសង្ឃសំរាប់បំពេញការខ្វះខាតក្នុងកិច្ចកសាងសាលាបាលីក្តី ជួសជុលព្រះវិហារក្តី ឬ សង់កុដិក្តី ។

ខ្ញុំ!

ឯកឧត្តម!

អស់លោកទាំងឡាយ!

ព្រោះហេតុទាំងនោះហើយ បើគុណជាយើងខ្ញុំមានជាប់ជំពាក់កង្វល់ បលិពោធទៅដោយការណីយកិច្ចយ៉ាងណា ឬ ក៏មានឧបសគ្គអ្វី មកឃាត់ឃាំង រាំងការងល់យើងខ្ញុំយ៉ាងណាក៏ដោយ ក៏យើងខ្ញុំ

មានអំណាត់ ទំស្ងួតៗអត់ប្រមូលបញ្ចូលគំនិតចង់ចាប់គ្នាជាចិត្តមួយ លះសេចក្តីកំណាញ់ ប្រឹងចំណាយបច្ច័យបន្តិចម្នាក់ៗ ដែលបានមកអំពីអំណោយរបស់មាតាបិតាយើងខ្ញុំ ក៏បានយកបច្ច័យនោះមករួមប្រមូលផ្សំផ្គុំនឹងបច្ច័យរបស់ខ្លួន ឯកទ្តម អស់លោក នឹងសប្បុរសទាំងឡាយស្មើរតែគ្រប់ដំបន់ ឲ្យតាល់តែអគ្គព្រះកឋិនេះ មានជីវិតលូតលាស់ដូច្នេះ ។ ទូលព្រះបង្គំ យើងខ្ញុំ សូមទូលខ្លួន នឹងដំកបអស់លោកថា សូមខ្លួន, អស់លោក, តាំងព្រះពុជហាឫទ័យ នឹងចិត្តសំគាល់ថា: អគ្គព្រះកឋិនេះ ជារបស់ខ្លួន, ឯកទ្តម នឹងអស់លោក-អ្នកពិតៗ ។

នៅវេលាម៉ោង ៨ ព្រឹកថ្ងៃអាទិត្យស្អែកនេះ យើងខ្ញុំនឹងរៀបក្បួនដង្ហែកឋិនទាន នៅវេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តមង្គលវ័ន (ស្វាយជង្គុំ) ឃុំលេខ ៣ ក្រុងភ្នំពេញ ។ សូមអញ្ជើញខ្លួន ឯកទ្តម អស់លោក យាងនឹងអញ្ជើញមកជួយហែអគ្គព្រះកឋិន នៃយើងខ្ញុំដើម្បីនឹងលើក ដំកើង កិត្តិស័ព្ទ នៃពិធីបុណ្យនេះ ឲ្យបានជាទ្ឋាវិកអុឹក-កធឹក ឈ្លូតរស្ងួដូច្នេះទៀត ។

នៅអវសាន ទូលព្រះបង្គំ, យើងខ្ញុំ សូមលើកហត្ថាបួងសួងដល់ព្រះមហាទេព ដ៏មានបុណ្យ ជាចមអមនិការ ប្រសិទ្ធីពរវរសួស្តី:

១ - ថ្វាយចំពោះព្រះគុណាជាអម្ចាស់ជីវិតលើត្បូង ដែលជាកំពូលនឹងម្លប់ត្រជាក់ របស់ពលរដ្ឋខ្មែរ ព្រមទាំងព្រះពុជវង្សានុវង្ស ។

២ - ថ្វាយចំពោះព្រះពុទ្ធសាសនា សូមឲ្យបិតបៀរបៀរកាលតទៅ

៣ - ដល់កម្ពុជរដ្ឋ សូមឲ្យប្រទេសខ្មែរ មានអនាគតភ្លឺរុងរឿង ចំញ្ចោចចំភ្នែក បញ្ចាំងរស្មីត្រចះត្រចង់ . ទៅលើសព្វជំបន់កង់សកលលោក នឹងឲ្យបានសម្បូរទៅដោយសន្តិសុខ, អារ្យធម៌ នឹងវឌ្ឍនធម៌គ្រប់យ៉ាង ។

ក្រោយបង្អស់គឺបច្ចុមវាចា មុននឹងបញ្ចប់នូវសុន្ទរកថានេះ ខ្ញុំព្រះបង្គំ, យើងខ្ញុំ សូមនុទ្ទិសកុសលវាសី ជូនចំពោះបុព្វការីជនមានគុណលើសលប់, ចំពោះឯកឧត្តម, អស់លោក, អស់អ្នកសប្បុរសជាពុទ្ធមាមក: នឹងមិត្តភូមិធំទាំងឡាយ ឲ្យប្រកបទៅដោយសេចក្តីសុខសេចក្តីចំរើន គ្រប់ប្រការដោយផលានិសង្សនៃកឋិនទាននេះចុះ ។

វិមានសុីសុវត្ថិ ថ្ងៃ ២៧ តុលា គ. ស. ១៩៥១

ហ៊ុយ-នឹម និស្សិត ថ្នាក់ទី ២ ទំនើប

តម្លៃមនុស្ស

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៤ ខែមេសា លេខ ៤

ព.ស. ២៤៩៤ – គ.ស. ១៩៥២



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជើរឿង	ទំព័រ
ពន្ធអាស៊ីទ្វីប (តមក)	លោកវ៉ាយ - ប៊ុក	២៤៣
មណ្ឌលកថា	ព្រះមហា ទេព - សរ	២៤៧
អត្ថានុទិដ្ឋិ (តមក)	ឧកញ៉ា សំ - ស៊ុន	២៦០
ផ្នែកអក្សរសាស្ត្រ		
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម	២៦៧
រឿងសាមកុក (តមក)	ឧកញ៉ា ទូ - កន	២៧៦
រឿងអារក្សថ្លែងរឿងម្តែប្រាំ (តមក)	លោក សាង - សាភ័ត	២៨២
រឿងស្នេហាជាតិ (តមក)	លោក គង់ - លឹម	២៩០
រឿងប៉ូល់និងវីរ៉ស៊ីនី (តមក)	សាស្ត្រាចារ្យ ផេង - ជ្រឿរ	២៩៨
សំលៀកបំពាក់ខ្មែរ (តមក)	ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ	៣០៤
កំណត់ទិដ្ឋប្រវត្តិការណ៍		
ដីប្រវត្តិ ព្រះសុធម្មបញ្ញាវ័រ កែវ - ផ្ទួប		
ចៅអធិការ វត្តកោះប្រាក់ (កំពង់ចាម)	ព្រះភិក្ខុ ម៉ី - សាន	៣១២

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ១៧៣.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

La lumière de l'Asie (suite).....	M. Ray-Buc	243
Malâmalakathâ	VÉN. TEP-SAR	247
Attânuditthi (suite).....	Oknha Sam-Sun	260

PARTIE LITTERAIRE

Education morale (suit).....	Vén.Pœung - Pam	267
Histoire de SAMŒOK (suite)	Oknha Nou - Kan	276
Les vingt cinq récits du Mauvais Génie (suite)	M. Sang - Savat	282
L'Amour de la Patrie (pièces de Théâtre) (suite).....	M. Kong-Lim	290
Paul & Virginie (suite).....	M. Phéng-Chrieu	298
Les vêtements Camdodgiens(suite)	Commission des Mœurs et Coutumes	304

NOTES ET CHRONIQUES

Biographie du vénérable Kèo-Chuop Chau - Adhikar de Vat Kos-Prak (Kg Cham)	VÉN.MI-SAN	312

Prix d'abonnement annuel (12 numéros:) 183800

ពន្លឺអាស៊ីទ្វីប

វគ្គទី ៨

La Lumière de l'Asie

លោក ស៊ីរ-អេតវ៉ាំង អាណូលត៍ តែង

លោករ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

*គម្ពីរពោលពិត, ឧបាសកអើយ! ជីវភាពនៃមនុស្សនីមួយៗគឺលទ្ធផលនៃការរស់នៅពីអតីតជាតិ, ការកំហុសពីអតីតជាតិ នាំមកនូវទុក្ខលំបាក, កុសលដែលបានបំពេញពីអតីតជាតិ នាំឲ្យកើតសោមនស្សចិត្ត។ អ្នកត្រូវតែប្រែតកាត់នូវពួជដែលអ្នកបានសាបព្រោះពីមុនមក។ អ្នកឃើញចម្ការនេះទេ! ស្រូវនេះពីដើមជាស្រូវសាលី។ ចមិស្ងាត់នឹងស្រមោលជ្រាបនូវរឿងនេះទាំងអស់, ព្រោះហេតុដូចនេះបានជាកើតជោគវាសនារបស់មនុស្ស។ មនុស្សទើបនឹងប្រែតកាត់ស្រូវនឹងស្រូវសាលី ដែលបានសាបព្រោះពីអតីតជាតិ, ហើយនឹងស្មៅអាក្រក់មានសកាពពុល ដែលធ្វើឲ្យមានជម្ងឺចំពោះមនុស្សនឹងទុក្ខចំពោះភពទាំងអស់។ បើមនុស្សនោះ, ប្រព្រឹត្តការណ៍យកចិត្តដោយដកស្មៅអាក្រក់នោះចេញស្រឡះពីសន្ដានហើយ ដាំពូជល្អបរិសុទ្ធស្អាតនៅកន្លែងដដែល គឺជីដែលមានជីជាតិល្អ មុខជាអ្នកត្រូវប្រែតនូវផលិតកម្ម

ដ៏ឋិរបុគ្គលិមិនមាន ។ បើអ្នកដែលរស់នៅ ជានដឹងនូវហេតុដែលកើត
ទុក្ខ ហើយទទួលទុក្ខនោះដោយខន្តីព្យាយាមសង្កំណុលចាស់ ដែល
ជំពាក់ដោយការកំហុសជាមុន ទំប្រព្រឹត្តនូវព្រហ្មវិហារធម៌សច្ចធម៌ តែ
កុំប្រព្រឹត្តនូវពាក្យណាមួយចំពោះអ្នកដទៃ, អ្នកនោះឈ្មោះថាជានលាងជម្រះ
មន្ទិលពីឈាមខ្លួន នូវពាក្យកូតកវកុហកនឹងអត្តទត្ថភាព (egoïsme) ឲ្យ
ស្អាតពីសន្តានឈ្មោះថាជានទទួលទុក្ខ ដោយសេចក្តីរីករាយហើយមិន
ប្រកាន់ទោស ព្រមទាំងធ្វើចិត្តឲ្យល្អចំពោះសេចក្តីរំលោភនៃជនដទៃ;
បើពាលថ្ងៃមនុស្សនោះខំព្យាយាមធ្វើចិត្តទន់ភ្លន់ ប្រកបដោយសន្តិភាព,
សុចរិតគួរជាទីពេញចិត្តស្មោះត្រង់ ហើយដកយកចេញគ្រប់កន្លែង
ទាំងអស់នូវតណ្ហាដែលបានចាក់ឫសក្តាប់ជ្រៅ ហូរឈាមសស្រាក់ខាល់
តែការស្រឡាញ់ដ៏វិភាពនោះរលត់រលាយអស់; បើអ្នកនោះប្រព្រឹត្តបែប
នេះបាន, ដល់ធ្លើមរណកាលទៅ មុខជានឹងទៅកើតជាជាតិថ្មីគេហៅថា
សំណុំអត្តាប្រកបដោយលទ្ធផលនៃដ៏វិភាព ដែលគេបញ្ឈប់នូវបញ្ហីបុណ្យ
ចាប ប្រកបដោយទុក្ខផុតរលត់សង្ឃរួចដុះស្រឡះហើយ, បញ្ហីបុណ្យ
ប្រព្រឹត្តថ្មីឬយូរមកហើយ ស្ថិតនៅមានអានុភាពឲ្យផលល្អ អាស្រ័យ
តាមហេតុកំរិនាសសាបសូន្យ ។ មនុស្សបែបនេះ មិនត្រូវការនឹងដ៏វិភាព។
ដែលស្ថិតនៅពីមុនមកមានលំទាំងផុតត្រឹមនេះ; អ្នកនោះបានបំពេញ
ករណីយកិច្ចចំពោះជោគវាសនាជាមនុស្សជាតិពេញលេញ ។ អ្នកនោះ

លែងខ្វល់ខ្វាយក្នុងទោស, ជាបអកុសលមិនអាចធ្វើចិត្តឲ្យមន្ទិលសៅហ្មង, សេចក្តីទុក្ខដែលជាន់មកពីការសេបញ្ជាយក្នុងអាមិស នឹងការរលំជាកនៅលើផែនដី លែងធ្វើឲ្យសន្តិភាព អ្នកនោះភកវល្អក់ ហើយសេចក្តីស្លាប់នឹងកើតលែងវិលចុះឡើងចំពោះបុគ្គលបែបនេះជាដាច់ខាត ។ អ្នកនោះចូលទៅកាន់ព្រះនិព្វាន ។ អ្នកនោះរួមសិទ្ធិជិតតែមួយឯកឯកក្នុងដីវភាព តែអ្នកនោះលែងសៅនៅក្នុងលោក ; អ្នកនោះជាន្រែបន្ទូរអនាមិសសុខ ដោយហេតុអ្នកនោះលែងរយោនយកកំណើតទៀត, ទុម-មុនី បទ្ធ, ទុម(๑) ដំណាក់ទឹកសន្សើមស្រែកចូលទៅជាត់ក្នុងមហាសាគរ ។

នេះជាលទ្ធិកម៌; ចូរអ្នកខំហាត់ស្វាធ្យាយឲ្យច្បាស់ ។ លុះត្រាតែលំអងនៃជាបនោះរលាយជាត់សាបសូន្យ, លុះត្រាតែដីវិតផុតរលត់ដូចជាអណ្តាតភ្លើងដែលឋមថយកំឡាំងដោយគ្មានប្រែឆ, ទើបសេចក្តីស្លាប់នោះរលត់រលាយទៅជាមួយនឹងដីវិតនោះជាអវសាន ។ កុំឲ្យពោលថា: "ខ្ញុំស្ថិតនៅទីនេះក្នុងបច្ចុប្បន្ន, ខ្ញុំស្ថិតនៅទីនោះពីអតីតកាល" ឬ "ខ្ញុំស្ថិតនៅទីនេះក្នុងអនាគតកាល" ។ កុំគិតថា អ្នកចេញពីផ្ទះសាច់មួយទៅនៅផ្ទះសាច់មួយទៀតដូចជាអ្នកដំណើរចាំច្បាស់លាស់ ឬក្លែចថាបានសំណាក់នៅទីនោះដោយស្រួលបួល ឬដោយលំបាក ។ ពីអតីត, ឥឡូវ

---

๑ ទុម, រតន: ក្នុងបុប្ផាបទុម ធម៌ដែលពួកពុទ្ធមាមកជនខាងទីបៃត៌សូត្រ ។ ព្រះពុទ្ធរូបគេតែងប្រតិស្ឋានព្រះហស្តកាន់ផ្កាឈូកដែលមានរតនវត្ថុនៅក្នុងនោះ ។

នោះស្ថិតនៅជាអធិបតេយ្យលើកពពាំងអស់មុនទើងក្តៅឆេះកល្ប ។ ចុបង
ប្អូនអើយ! តើអ្វីជាឧបសគ្គ? គឺឯងឯតដែលផ្សាយចេញពីអរិដ្ឋានាំឲ្យអ្នកពាំង
អស់គ្នាវង្វេង, យកសភាពគាន់ច្រឡំថាជាសភាពមែនពិត ហើយនាំឲ្យ
កើតទុវ្ទិតណ្ហាច្រាថ្នាទុវ្ទិសភាពគាន់ច្រឡំនោះ ។ ដល់សេចក្តីច្រាថ្នានោះ
មកដល់ពេលជាអវសាន, ត្រូវការបូកព្រមូលទុវ្ទិដីវភាពវិលត្រឡប់ចូល
ទៅក្នុងចក្រវាឡវិញ ; ដីវភាពនោះបានសន់ទុវ្ទិគេហដ្ឋានរបស់ខ្លួនដូចជា
ដង្កូវនាងចូលទៅស្ថិតនៅក្នុងសំបុក ។ ហើយបានចូលទៅរួមនាមនឹង
រូបតែមួយឯកឯងមានមុខការផ្សេង ។ ដូចជាពងសត់ក្នុងណៈដែលមេ
ក្រាប, ពងនោះអាចផ្សាំទុវ្ទិស្រែកានឹងចង្កឹមឲ្យបានស្រួល, ដូចជាពួជ
ដើមត្រែង ហិចហើរទៅលើថ្មកំ ថ្មជានឹងខ្សាច់ ពាល់តែទៅដល់បឹងជ្រះ
ធ្លាក់ចុះចំរើនដុះដាលឡើងជាលំដាប់ ។ ដូចគ្នានឹងដីវភាពនោះវិលត្រឡប់
មករកសុខ ឬទុក្ខវិញ ។ កាលណាសេចក្តីស្ងាប់នាំមកទុវ្ទិផលអាក្រក់
ចំពោះពេជ្ឈឃាត, ចាបអកុសលដែលមនុស្សប៉ុន្មាន កំត្រាច់ឆ្ងាត់ទៅក្នុង
សមុទ្រសង្សារដោយអំណាចវាយោដែលប្រកបដោយអជ្ឈាសាសនឹងចុះ
អព្វូហើយមានសភាពពុលនោះផង ។ តែបើមនុស្សនោះល្អសុចរិតទទួល
មរណភាព, មានវាយោបក់ត្រជាក់ស្រួល ; ពិភពលោកមានសភាពរីក
ស្រស់ស្រាយ, ដូចជាទន្លេនៅវាលខ្សាច់រហោស្ថានហូរចាត់ទៅក្នុងខ្សាច់
មួយរំពេចហើយខើបចេញហូរជាថ្មីភ្លឺចាំងបរិសុទ្ធស្អាតដូច្នោះ ។ (មានត)

មលាមលកថា

ព្រះមហាទេព - សរ វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ទេសនាជាកំវិឡុឃោសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែភទ្របទ
ឆ្នាំដូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (១៨ — ៩ — ៤៨)

ធម្មោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះអាត្មាភាពនឹងសំដែងអំពីមលាមលកថា ផ្សាយតាមវិទ្យុ ឃោសនសព្ទ ចែកជូនសប្បុរសទាំងឡាយ, តែមុននឹងសំដែងនូវ "មលា-មលកថា" នេះ សូមភាប់រៀបដម្រាលសេចក្តីខាងដើមបន្តិច ដើម្បីឲ្យ សមរម្យនឹងពុទ្ធកាសិតដែលត្រូវលើកមកសំដែង ។

អស់លោក-អ្នកទាំងឡាយសុទ្ធតែជាខេមរជាតិ គេដឹងសព្វប្រទេស ថាជាអ្នកកាន់ព្រះពុទ្ធសាសនា គួរតែឲ្យមានសេចក្តីរីករាយក្នុងចិត្តថាមាន កំព្វត្រៃងសំណាងយ៉ាងខ្លាំង ត្រង់ដែលបានមកជួបប្រទះនឹងព្រះពុទ្ធ-សាសនា ព្រោះព្រះពុទ្ធសាសនាជាគុណជាតិមានគោលចារិកត្រឹមត្រូវ ល្អ នឹងជាគុណជាតិដ៏ឧត្តម អាចធ្វើអ្នកប្រតិបត្តិតាមឲ្យបានចំរើនដោយ ការចេះដឹងនឹងសេចក្តីថ្លៃថ្នូ ។ តែអ្នកដែលមានឈ្មោះថា អ្នកកាន់ព្រះ ពុទ្ធសាសនាចំពូកខ្លះ ដែលពុំបានសិក្សាឲ្យស្គាល់ជាក់ នូវសេចក្តីព្រះ ពុទ្ធសាសនា ក៏នៅមានគំនិតច្រឡំជាដើងដោងដោយសេចក្តីងឿងឆ្ងល់ ។

ដូចជាអ្នកខ្លះ ដែលបានឃើញអ្នកកាន់ព្រះពុទ្ធសាសនាខ្លះ ដែលពុំសូវចេះដឹងជាអ្នកខាងថោក ជាអ្នកគ្រឹក្រលំបាក ក៏ចូលចិត្តថាព្រះពុទ្ធសាសនាខាងថោកណាស់, ធ្វើអ្នកប្រតិបត្តិតាមឲ្យលំបាក ឲ្យខាងថោក ឲ្យគ្រឹក្រលំបាក ម្ល៉ោះហើយក៏មិនយកចិត្តទុកដាក់នឹងព្រះពុទ្ធសាសនាឲ្យជាការមាំមួនឡើយ នេះមកពីអ្នកនោះឯងមិនបានសិក្សាមិនបានពិនិត្យឲ្យឃើញតាមការពិតមែន ។

មានជនខ្លះទៀត បានចូលមកសិក្សាចំណេះវិជ្ជាខាងផ្លូវព្រះពុទ្ធសាសនាមានចំណេះអក្សរជាដើម នៅទីវត្តអារាមដែលជាទីបណ្តុះនៃពួកចំណេះខាងព្រះពុទ្ធសាសនាតាំងពីក្មេងមក អ្នកខ្លះបានចាំងបួសថែមទៀត តែមិនច្បាស់ច្បែងរៀនសូត្រឲ្យចេះដឹងច្បាស់ជាមែនទែន លុះដល់វេលាដែលចេញពីវត្តអារាមទៅ បានទៅសិក្សាចំណេះឯទៀតក្រៅពីលទ្ធិព្រះពុទ្ធសាសនា ក៏ត្រឡប់ឃើញថាព្រះពុទ្ធសាសនាមិនរៀបរយ មិនថ្លៃថ្លាដូចជាចំណេះវិជ្ជាឯទៀត ម្ល៉ោះហើយក៏នាំគ្នានិយាយបន្ទុះបង្អាប់ចំណេះដែលចេះពីវត្តអារាមទៅ គឺថាបើឃើញចំណេះណាមួយដែលមិនច្បាស់ជាឃើញអក្សរដែលអ្នកណាមួយសរសេរមិនល្អ ក៏នាំគ្នានិយាយថាចំណេះវត្ត អក្សរវត្តប្រើការមិនកើត ដូចជាទីវត្តរមែងធ្វើមនុស្សអ្នករៀនមិនច្បាស់ជ ត្រង់ខ្លួនឯងដែលខ្វិលរៀនសូត្រមិនគិតឃើញដល់ នេះមកពីគំនិតឃើញខុសព្រោះលុះក្នុងអំណាចនៃសេចក្តីកាន់ច្រឡំ ។

អស់លោក អ្នកចាំឆ្លាយ ប្រយ័ត្នកុំឲ្យកាន់ច្រឡំគំនិតដូចមនុស្ស
ចំពូកខ្វះ ដែលគិតឃើញខុសដូចខាងលើនេះឡើយ ត្រូវបួលចិត្តឲ្យមាំថា
ព្រះពុទ្ធសាសនានេះ ជាច្បាប់ប្រដៅមនុស្សដែលដឿ ប្រតិបត្តិតាម ឲ្យ
មានប្រាជ្ញា, ឲ្យមានចំណេះវិជ្ជាផ្លូវលោក ព្រមទាំងផ្លូវធម៌ ឲ្យមានរបៀប
រៀបរយល្អ, ឲ្យបានបរិសុទ្ធផុតចាកមន្ទិលគ្រប់យ៉ាង ។

សាសង: ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃ
យើង ដែលមានមកក្នុងផ្លូវសាសនាមានច្រើនជាអនេក សុទ្ធតែជាពាក្យ
ប្រកបដោយប្រយោជន៍ទាំងអស់, ជាពាក្យតឿនក្រើនរំឭកមានហេតុ
ផលល្អ យ៉ាងសំខាន់ ឲ្យស្គាល់ផ្លូវចំរើននឹងវិនាស សមដូចពុទ្ធភាសិត
មួយកន្លែងមាននៅ ក្នុងគម្ពីរធម្មបទខុទ្ទកនិកាយពោលទុកមកថា:

អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។

ប្រែសេចក្តីថា: "មន្តសិល្បៈស្តុកទាំងឡាយ មានការមិន
ស្វាធ្យាយជាមន្ទិល, គេហដ្ឋាន (ប្រទេសជាតិមាតុភូមិ) មានការមិន
ក្រើនក្រតើនជាមន្ទិល, ការខ្ជិលច្រអូសជាមន្ទិលនៃពណ៌សម្បុរកាយ,
សេចក្តីធ្វេសប្រហែសជាមន្ទិលនៃបុគ្គលអ្នករក្សា" ។

ក្នុងន័យគាថានេះ អធិប្បាយចែកទៅជា ៤ មាតិកា នឹងសូមដកស្រង់តាម
លំដាប់មាតិកាយកមកអធិប្បាយ ដូចសេចក្តីដែលជាប់ខាងក្នុងគាថាទៅនេះ

ទី ๑ — អសជ្ឈាយមលា មន្តា មន្តវិទ្យាសាស្ត្រមានការមិនស្វាធ្យាយជាមន្ទិល ។ ក៏ពាក្យថា មន្តសព្ទនេះ បើតាមលោកវោហារដែលធ្លាប់នាំគ្នាចូលចិត្តមកអស់កាលជាយូរ សំដៅយកមន្តអាគមអូមអាមសម្រាប់ស្តោះបណ្តាញខ្មោចអាបព្រាយ ឧទ្ធំមន្តអាគមសម្រាប់សូត្រការពារគាប់ចាក់មិនមុតជុតមិនរេះតែម្យ៉ាងប៉ុណ្ណោះ, តែបើតាមសេចក្តីពិតដែលមានមកកាន់គម្ពីរផ្លូវសាសនា គឺសំដៅយកមន្តវិទ្យាផ្លូវព្រះពុទ្ធសាសនា ឧទ្ធំផ្លូវលោកតាំងស្រុង, ដែលជាមន្តវិទ្យាសម្រាប់ធ្វើខ្លួនឲ្យរួចពីឋានៈទន់ទាបឡើងទៅកាន់ឋានៈខ្ពង់ខ្ពស់, ឧទ្ធំមន្តវិទ្យាសម្រាប់ប្រែផ្លូវការរកស៊ីចិញ្ចឹមជីវិត ច្បាស់ចាកសោសគ្រប់យ៉ាង, វិជ្ជាអស់តាំងនេះខេមរជនតាំងឡាយ ត្រូវតែសិក្សាសូត្រវៀនឲ្យបានចេះចាំមាំមួនគ្រប់ៗគ្នាឡើង ព្រោះថាផ្លូវសាសនា ឧទ្ធំផ្លូវលោកតាំងពីរនេះ ត្រូវប្រែស្រ័យជាប់ទាក់ទងទៅវិញទៅមក បើមានតែណាមួយក៏មិនអាចប្រព្រឹត្តទៅបាន, គួរយ៉ាងដូចជារ៉ែគ្រឿងចក្រតាំងឡាយ មានរថយន្តជាដើម ដែលអាចបើកបរទៅបាន ត្រូវអាស្រ័យរ៉ែគ្រឿងទ្វូសម្ភារៈគ្រប់យ៉ាង បើមានតែកង់ហើយខ្វះតួរថ ឬក៏មានតែរថហើយខ្វះគ្រឿងម៉ាស៊ីន ក៏មិនអាចប្រព្រឹត្តទៅបាន ។

លោកអ្នកខេមរៈតាំងឡាយ ! មន្តវិទ្យាសាស្ត្រតាំងនេះដែលបានវៀនចេះចាំមក ហើយបើមិនទៅស្វាធ្យាយសូត្រខ្មែរ ម៉ែល

ឲ្យញឹកញាយទេ រមែងក្លេចក្លាំងបាត់បង់ទៅវិញពុំខាន, ត្រឡប់ទៅជា
របស់ឥតប្រយោជន៍ ប្រើការមិនកើត, បើទុកជាមានទៅចាំខ្វះក៏ពុំ
ប្រាកដ. ចៃបស្រួចស្រួលត្រឹមៗ ព្រាវៗ ស្អាក់ស្ទើរកន្លងចិត្តរក
ប្រាកដកន្លែងណាមិនបាន តែងត្រឡប់ឲ្យទោសដល់ខ្លួនវិញ សមដូច
បុពណាគាសិតពោលទុកមកថា:

អនភ្យាសេ វិមំ វិទ្យា អជិណេ ភោជនំ វិមម
វិមំសភា ទរិទ្រេស្យ រ្ជូទ្ធស្យ តរុណី វិមម ។

"មន្តសិល្បសាស្ត្រគាំងឡាយ ដែលរៀនចាំមិនប្រាកដចៃបស្អាក់
ស្ទើរ ប្រើការមិនកើត ទុកដូចជាគ្រឿងពិស ភោជនដែលបុគ្គល
បរិភោគទៅហើយមិនរលាយក៏ទុកដូចជាគ្រឿងពិសដែរ, ទីប្រជុំជា
គ្រឿងពិសដល់មនុស្សដែលកំសត់ទីទ័លក្រ, មនុស្សចាស់យកប្រពន្ធ
ក្រមុំ ទុកស្មើនឹងគ្រឿងពិសយ៉ាងចំហុតមួយដែរ" ។

ព្រោះបណ្តាមន្តវិទ្យាសាស្ត្រគាំងគស់ក្នុងលោក តែងមានការ
ទស្សាហ៍មើល, ទន្ទេញ-ស្វាធ្យាយ ឲ្យញឹកញាប់ជាប្រមុខ, បើរៀន
ចេះមកហើយ បណ្តែតបណ្តោយលះបង់ចោលរមែងលែងមានការប្រាកដ
ក្នុងចិត្តពុំខាន ។ ដោយហេតុនេះ សូម្បីតែលះបង់ចោលត្រឹមតែ ៥-៦
ថ្ងៃប៉ុណ្ណោះក៏គង់មានការភាន់ភាំងងើងងោង ចំណង់បើចោះបង់ចោលការ

សិក្សាអស់វែង - ឆ្ងាំ សូម្បីតែវិជ្ជាកំទេចកំទី រកាច់រកោចអ្វីមួយក៏គ្មានដក់នៅកន្លែងដែរ, សមដូចជាបាបាច់លោកនិតិសោលទុកមកថា :

បញ្ញវន្តា សុគន្ធញ្ញា សត្តវន្តា ធនុគ្គហា
ឯកមាសា សុភរិយោ អឌ្ឍមាសា សិស្សា មលា

"រថាំបង់លេងលង់ ៥ ថ្ងៃ ជាមន្ទិលគឺដៃខ្សត់អាន
នាយខ្នាន់ធ្លាបង់ជាញ់កន្ទុងជាន ៧ ថ្ងៃក៏មានមន្ទិលភ្លាត់ ។
ប្រពន្ធបង់ប្តីលង់ ១ វែ ជាមន្ទិលគឺប្រែចិត្តប្រែតិព្ធ
សិស្សបង់ការសិក្សាក្នុងវត្ត កន្ទុះវែកក៏ភ្លាត់ការសិក្សា" ។

ចំពោះសេចក្តីឲ្យឃើញថា : អ្នកណាមួយតែលះបង់ការសិក្សាចោលហើយឈ្មោះថា ជាអ្នកល្ងង់មិនចេះមិនដឹង កាលបើល្ងង់មិនចេះមិនដឹងហើយទុកស្មើគ្នានឹងសត្វគោ សមគ្នានឹងបុព្វណាសិត ១ ក្នុងឆក្កនិបាតជាតកថាគោបទេសថា :

អាហារនិទ្រា ភយំ បមៃថុនំ សាមញ្ញមេតត្បសុភិនរានាម
ធម៌៌បិភោ ធម៌៌មធិកោវិសេសោ ធម៌៌ណាហិនានះបសុភិះសមានាះ

"មនុស្សនឹងសត្វគោ មានការបរិភោគអាហារនឹងដេកនឹងភ័យនឹងសេពមេថុនដូចគ្នា តែមនុស្សមានចំណេះវិជ្ជាសម្រាប់ធ្វើឲ្យប្លែកអំពីគោ មនុស្សណាឥតមានចំណេះវិជ្ជា មនុស្សនោះឈ្មោះថាស្មើគ្នានឹងសត្វគោ" ។

ឯទោសនៃសេចក្តីល្ងង់នេះសឹងឃើញច្បាស់ក្នុងបច្ចុប្បន្ននេះដូចេ្នះ

๑) បើល្ងង់ក្នុងវិធីអក្សរគឺមិនចេះសរសេរ-មើល ទំនងាំឲ្យខាតបង់ នូវប្រយោជន៍ដូចេ្នះគឺ: មិនអាចមើលសៀវភៅដែលជាច្បាប់ប្រដៅល្អក្នុងព្រះពុទ្ធសាសនាឬក្រៅពីពុទ្ធសាសនា, មិនអាចសរសេរសំបុត្រដោយខ្លួនឯង ផ្ញើដំណឹងដល់ញាតិមិត្តដែលខ្លួនត្រូវការ, សេចក្តីកំចាំងឬការក្រែលញាតិមិត្តឲ្យដំណឹងមកចំពោះខ្លួន នឹងមិនសម្រេចប្រយោជន៍ ។

๒) អ្នកដែលល្ងង់ បើអាស្រ័យនៅជិតកោនក្នុងសំណាក់អ្នកធំ ចេះគោរពប្រតិបត្តិឲ្យអ្នកធំស្រឡាញ់មេត្តាដូចម្តេចក្តី អ្នកជំនោះក៏មិនអាចលើកដំកើងអ្នកនោះឲ្យមានក្តីរុងរឿងយសស័ក្តិបាន ឡើយ ។

๓) មនុស្សល្ងង់ ទោះមានយសស័ក្តិដោយព្រែងសំណាងជួយ បន្តិច បើចុះថ្លើងគ្រាន់បើបានតែក្នុងចំណោមគ្នាឯទៀត តែដល់ចូលកាន់ទីប្រជុំនឹងត្រឡប់ទៅជាមនុស្សឥតវាសីឥតមានជម្ងៃទៅវិញ ព្រោះហានិយាយឡើងមិនត្រូវតាមច្បាប់ ។

๔) មនុស្សល្ងង់ ជាមនុស្សខ្វះមិត្តសំឡាញ់ ព្រោះគេមិនត្រូវការយកខ្លួនធ្វើជាមិត្តសំឡាញ់ឡើយ ។ បើទុកជាមានមិត្តសំឡាញ់ក៏ច្រើនបានតែមិត្តសំឡាញ់ដែលជាមនុស្សល្ងង់ជាងខ្លួន ។

๕) មនុស្សល្ងង់ បើរកស៊ីតាមធម្មតា ក៏មិនអាចនឹងធ្វើឲ្យចំរើនដូចមនុស្សដែលមានប្រាជ្ញាចេះដឹងឡើយ បើទុកជាធ្វើទៅត្រូវលើទំនង ឬកាលដែលគួរធ្វើ ក៏មិនរួចពីសេចក្តីលំបាក ។

៦) មនុស្សល្ងង់ មិនដែលបានសេចក្តីសរសើរ អំពីសំណាក់អ្នកប្រាជ្ញណាមួយដល់ខ្លួនឡើយ បើបានសរសើរខ្លះ តែអំពីសំណាក់បុគ្គលដែលល្ងង់ជាងខ្លួន ។

ទោសនៃសេចក្តីល្ងង់នេះ មិនមែនមានតែក្នុងបច្ចុប្បន្ននេះទេ ខឹងមានទៅក្នុងលោកឯមុខទៀតជាអនេក តែមិនបានអធិប្បាយឲ្យសព្វគ្រប់ក្នុងទីនេះ ។

២— អ្នកឆ្លាសមលា ឃរា គេហដ្ឋាន (ប្រែទេសជាតិមាតុភូមិ) មានការបណ្តែតបណ្តោយមិនជួសជុលទល់ត្រជាមន្ទិល ។

ក៏ពាក្យ "ឃរៈ" សព្ទនេះ សំដៅយកទីសេនាសនៈសម្រាប់ទីពឹងសំណាក់ស្នាក់អាស្រ័យនៃគ្រហស្ថនឹងបព្វជិតខ្លួទៅក្នុងលោក គឺផ្ទះសំបែងកុដិសាលាប្រាង្គចេតិយជាដើម, កាលបើមន្ទិលគឺការចាស់ជុនជាបន្តុះត្រឹមហើយ, មិនឲ្យាហ៍មើលថែទាំជួសជុលឡើងវិញទេ រមែងប្រាក់បែកធ្លុះធ្លាយរេចរឹលបន្តិចម្តងៗ ដរាបតាល់តែរកកន្លែងសំណាក់ប្រ៉ាក់ប្រុនអាស្រ័យតទៅទៀតពុំបាន, នឹងបណ្តាលឲ្យដួលប្រែទេះ តែសេចក្តីទុក្ខវេទនាចំពោះខ្លួនឯងតែម្យ៉ាង, មិនត្រឹមតែទីសេនាសន សម្រាប់នៅពឹងពាក់ផ្អាល់ខ្លួនប៉ុណ្ណោះទេ សូម្បីតែប្រទេសជាតិមួយដែលជាប្រយោជន៍ធំទូទៅគ្រប់មនុស្សទាំងអស់, កាលបើបណ្តែតបណ្តោយមិនមើលការថែទាំចាត់ការឲ្យបានមានរបៀបរៀបរយត្រឹមត្រូវល្អទេ ឬ តំបណ្តោយឲ្យពួកក

បច្ចាមិត្តចូលមកលុកលុយរុកពានតាមអំពើចិត្តបានហើយ, ប្រទេសនោះឯងក្រែកជង្អាក់ជៀកាន់ការអាប់ឧនដូនជាបដោយធាប់រហ័សពុំខាន, នេះក៏ចាត់ជាមន្ទិលមួយដែរ ។

៣— មលំ វណ្ណោ សុ្ស កោសជ្ជំ សេចក្តីខ្ជិលច្រអូសជាមន្ទិលនៃពណ៌ ។ អធិប្បាយថា: តួរូបពាង់កាយរបស់មនុស្សប្រុស ស្រីពាំងស្រុងក្តី, ទោះវត្ថុសម្រាប់ប្រើប្រាស់ទូទៅពាំងអស់ក្តី, បើខ្ជិលច្រអូសមិនមុស្យាហ៍ចោកគក់លាងជុះជូតខាត់សំអាតឲ្យឃើញញាយទេ ទើងជាហេតុនាំបណ្តាលឲ្យរូបកាយរបស់យើងដែលអាស្រ័យនូវគ្រឿងមិនស្អាតមានពេគផ្សែង ។ កាលបើរូបកាយមានពេគហើយ ចិត្តដែលអាស្រ័យខាងក្នុងរូបកាយ ធ្លើម្តេចនឹងប្រព្រឹត្តទៅបានដោយស្រួល កាលបើចិត្តប្រព្រឹត្តទៅមិនស្រួលហើយ គំនិតប្រាជ្ញាដែលទៅអាស្រ័យនឹងចិត្ត ធ្លើម្តេចនឹងជុះជាលក្ខីស្វាងឡើងបាន កាលបើគំនិតប្រាជ្ញាមិនចំរើនក្ខីស្វាងហើយ ប្រយោជន៍ដែលយើងត្រូវការចង់បានក្នុងបច្ចុប្បន្ននេះ ទើងលោកខាងមុខធ្លើម្តេចនឹងសម្រេចប្រយោជន៍បាន ។

កាលបើយ៉ាងនេះគួរតែចូលចិត្តថា បណ្តាពេគពាំងអស់ សុទ្ធតែជាតួសត្រូវប្តូជាមេចោរជាអ្នកបំផ្លាញ នូវប្រយោជន៍នៃអស់យើងពាល់គ្នា ព្រោះសេចក្តីពិតថា អ្នកណាមួយទោះបីមានបុណ្យសំភ័ក្តី មានទ្រព្យសម្បត្តិច្រើនក្តី, មានប្រាជ្ញាច្រើនក្តី, មានកំឡាំងច្រើនក្តី, កាលបើ

ភេតចូលមកអាស្រ័យនៅក្នុងរូបកាយបានហើយ បុណ្យស័ក្តិជាដើមនោះ
ក៏ត្រឡប់ទៅជាឥតមានអានុភាព, ច្រើការមិនកើតទាំងអស់ ព្រោះចាល
ចាញ់អំណាចនៃភេតដែលចូលមកលុកលុយក្នុងរូបកាយ ។

មិនតែប៉ុណ្ណោះសោត ការដែលស្មោកគ្រោកមិនឧស្សាហ៍សំអាត
គ្រឿងប្រើប្រាស់ ឲ្យបានស្អាតបាតនេះជាហេតុនាំឲ្យអប្បសិរីសួស្តីគ្រប់
យ៉ាង មិនសូវមានការគោរព ពាក់អានអំពីសំណាក់បុគ្គលដទៃ សមដូច
បុរាណាចារ្យសិតថា :-

វិស្សែន វិភុសា វិបា វិទ្យា វិនយេន ច
វិក្កាយៃ បញ្ច វិតៅ ធរោ នាយាតិ គោរវំ ។

"ជនណាច្រាសចាកចោលគុណធម៌ ទាំង ៥ បវារសម្រាប់លោក
គឺមួយស្មៅកពាក់ស្អាតមានផោគ ពីរមិនស្មោកគ្រោកស្អិតស្អាង
កាយ" ។

បីសំដីផ្អែមល្ហែមពិសេស ប្លួនវិជ្ជាចេះដឹងសុះសាយ
ច្បាំនិន្ទ័យក្រឹត្យក្រមទាំងឡាយ ជននោះមិនងាយគេគោរព ។

ហេតុនេះគួរតែយើងឧស្សាហ៍សំអាតទីលំនៅជាដើម ដើម្បីនឹងក-
ាំងបិទផ្លូវកុំឲ្យភេតកើតឡើងបាន; ពិតមែនតែមានពុទ្ធភាសិតមួយកន្លែង
សំដែងថា រូបំ រោគនិឌ្ឍំ "រូបជាទីកប់នៃរោគ ឬជាទីអាស្រ័យនៅនៃ
ភេត", ដែលព្រះអង្គសំដែងដូច្នេះ ចំពោះតែងកន្លែងដែលភេតចូលទៅ

អាស្រ័យនៅគឺរូបកាយ បើឥតរូបកាយក៏ឥតមានរោគ តែមានរូបកាយ ហើយក៏ឈ្មោះថាមានរោគ ។ ឯរោគសមុដ្ឋាន គឺហេតុដែលនាំបណ្តាលឲ្យរោគកើតឡើងនោះ ព្រះអង្គមិនបានសំដែងចំពោះត្រង់ពាក្យថា "រូបំ រោគនិឝ្ឆ" នេះទេ រោគសមុដ្ឋាននោះ ព្រះអង្គមានសំដែងទុកក្នុងសូត្រ ឯទៀតដោយច្រើន មានគឺរមានទួសូត្រជាដើម ។

ម្យ៉ាងទៀត, ការសំអាតនេះ មិនមែនមានតែក្នុងដំណាក់បច្ចុប្បន្ននេះឡើយ ច្បាប់ក្នុងព្រះពុទ្ធសាសនាក៏មានសំដែងដោយច្រើន ។ គួយ៉ាងដូចក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់សមាធិនិទ្ទេសជាដើម មានសំដែងអំពីអប្បនាកោសល្យ ១០ យ៉ាង, ត្រង់អប្បនាកោសល្យទី ១ ឈ្មោះ វត្ថុវិសោធិកិរិយា សេចក្តីថា ធ្វើវត្ថុខាងក្នុងនឹងខាងក្រៅឲ្យស្អាត ។ ធ្វើវត្ថុខាងក្នុងឲ្យស្អាត គឺធ្វើរូបកាយឲ្យស្អាត មានកាត់ក្រចក កោរសក់នឹងដុំរះដុសលាងខ្លួនមិនឲ្យមានញើសក្អែលជាដើម ។ ធ្វើវត្ថុខាងក្រៅឲ្យស្អាត គឺសំអាតគ្រឿងស្លៀកពាក់ នឹងទីដេកទីអង្គុយជាដើមឲ្យបានស្អាតបាត ។ កាលវត្ថុខាងក្នុងនឹងខាងក្រៅស្អាតល្អហើយ ។ ទៅអង្គុយចំពោះព្រះកម្មដ្ឋាន ចិត្តនឹងចេតសិកក៏ប្រព្រឹត្តទៅដោយស្រួល កាលបើចិត្តនឹងចេតសិកស្រួលហើយ ញាណគឺប្រាជ្ញាដែលអាស្រ័យនៅនឹងចិត្ត ក៏ក្លាស្វាងរុងរឿងល្អ, ឧបមាដូចជាប្រទីបតឹចង្រៀងគោម កាលបើតួប្រទីបស្អាត ប្រេងក៏ល្អ ប្រឆេះក៏ល្អ លំផ្ងារក៏ស្អាតល្អ ពន្លឺប្រទីបនោះក៏ភ្លឺរុងរឿងឡើងបាន ។

កាលបើវត្ថុខាងក្នុងនឹងខាងក្រៅមិនស្អាតល្អហើយ ញាណ គឺប្រាជ្ញាមិនអាចភ្ជាប់រឿងបាន ។

សូមអស់លោក-អ្នកចាំងឡាយ ចុះឃ្លាសំអាតដូចសេចក្តីខាងលើនេះ នឹងបានត្រូវតាមដំណក្នុងបច្ចុប្បន្ននេះផង ត្រូវតាមច្បាប់ព្រះពុទ្ធសាសនាផង ព្រមទាំងបានប្រយោជន៍ផ្សេងៗផង មានកំចាត់បង់នូវភេចញអំពីកាយជាដើម កាលបើរាងកាយឥតមានភេគហើយឈ្មោះថាបានលាភដ៏ឧត្តមសមនឹងព្រះពុទ្ធភាសិតថា "អារោគ្យបរមា លាភា "មានលាភអ្វីមិនឧត្តមស្មើនឹងគ្មានភេគ" ។ សេចក្តីថា: អ្នកឥតភេគអាចនឹងទទួលនូវលាភគ្រប់យ៉ាងបាន ឯអ្នកដែលមានភេគ សូម្បីលាភឯណាមួយតើតែខ្លួនក៏មិនអាចទទួលយកបាន បើទុកជាបានក៏មិនអាចសោយសេចក្តីសុខព្រោះលាភនោះបានឡើយ ព្រោះខ្លួនជាអ្នកមានភេគ រកសេចក្តីសុខគ្មាន ។

៤- បមាទោ រក្ខតោ មលំ បមាទធម៌ជាមន្ទិលនៃបុគ្គលអ្នករក្សា ។ សេចក្តីថា: បមាទ: សព្ទនេះ ប្រែថាធ្វេសប្រហែស, បណ្តែតបណ្តោយកិច្ចការងារគ្រប់យ៉ាង, បមាទធម៌នេះ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់គ្រាស់សំដែងថាជាមេអកុសលគ្រប់យ៉ាង; ព្រោះថាបណ្តាធម៌ជាអកុសលទាំងឡាយ ដែលអាចដុះដាលរហូតលាស់ឡើងបានព្រោះមានបមាទធម៌ជាប្រមុខ ឬក៏មានបមាទធម៌ជាប់ទៅក្នុងសន្តានចិត្តពីមុនមកស្រាប់, ចុបមា

ដូចជាមេដំបូលប្រាសាទជាទីរួបរួមនៃគ្រឿងទ្រូសម្ភារៈ គ្រប់យ៉ាងមានផ្ទៅធ្លានជាដើម ។ បើមានធម៌នេះគាលបើចូលមកនៅក្នុងសន្តានជនណាមួយហើយ, ជននោះឯងប្រាកដជាក្លេចនឹកដល់សេចក្តីល្អ-ចំរើនគ្រប់យ៉ាង តែងញុំាងចិត្តរបស់ខ្លួនឲ្យឈ្លប់ងប់ក្នុងសេចក្តីអាក្រក់តែម្យ៉ាង, រមែងធ្វើអត្តភាពរបស់ខ្លួនឲ្យជ្រាក់ជ្រៅកាន់សេចក្តីទុក្ខអស់កាលជាអង្វែង ។

មិនតែប៉ុណ្ណោះឡើយ សូម្បីតែប្រទេសនិមួយៗដែលជ្រាក់ជ្រៅកាន់សេចក្តីអាប់ឧនដុនជាបថោកទាប ក៏ដោយសារស្មារដែលមានធម៌នេះដែរ ។

តែមានជនខ្លះចូលចិត្តសិប់ថា: ការចំរើនធំវិនាស, មានធំក្រសៃចតែនធំសំណាងវាសនារបស់ខ្លួនតែម្យ៉ាង ។ សូមអស់លោក-អ្នកចាំងឡាយកុំចូលចិត្តសិប់យ៉ាងនេះឡើយ, ត្រូវចូលចិត្តថា ការចំរើនធំវិនាស, មានធំក្រសៃចតែទំប្រឹងប្រែងព្យាយាមកសាងធ្វើនធំទំរកតែម្យ៉ាង, មិនមែនបដិសេធន៍សំណាងចោលទេ តែសូមជ្រាបថា,អម្បាលយ៉ាងព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គទំកសាងចំពេញបារមីអស់ ៤ អសង្ខ្យៃយ្យ ១ សែនកប្ប, ចុះដូចម្តេច ក៏ព្រះអង្គចាំធ្វើទុក្ករកិរិយាអស់ ៦ វស្សាថែមទៀត? សូមទេមវជនចាំងឡាយ ពិនិត្យពិចារណាតាមពាក្យខាងលើនេះចុះ ។

ទីបំផុតនៃធម្មទេសនានេះ សូមបន់ស្រន់ថា:ឲ្យទេមវជនចាំងឡាយបានប្រកបដោយសិរីសួស្តីជោគជ័យវាសនា គ្រប់ៗគ្នាទៅហោង ។

ចប់

អ្នកឧកញ៉ាឥសូរវៀង្ហ សំ - សុន

ជាអ្នកប្រែរៀបរៀង

(តមក)

មនុស្សខ្លះពោលថា ព្រះនិព្វានជារបស់អណ្តាល។ មិនមែនយើង មិនមែនជារបស់យើង មិនមែននរណា មិនមែនជារបស់នរណា។ បើដូច្នោះយើញថានៅម្នាងម្នាក់; យើងម្នាងព្រះនិព្វានម្នាងគឺយើងនឹងព្រះនិព្វានផ្សេងគ្នា, ព្យាយាមលាក់បិទបាំងចៀសវាងទៅឲ្យបាន តែនឹងលាក់បិទបាំងទៅមិនរួច, ឃើញខុស, បាននិយាយមកហើយខាងដើមថា វិភគធម្មនិព្វាននោះ ជាឈ្មោះរបស់សេចក្តីបរិសុទ្ធិ ព្រោះពាក្យផ្សេងៗ ដែលជាវេវចនៈរបស់ព្រះនិព្វានចង្អុលប្រាប់ហើយ ដូចវិសង្ខារ (អស់សង្ខារ) វិភគៈ (អស់ភគៈ) និពេធ (រលត់) គួព្រះនិព្វានឯងនោះក៏ប្រែថារលត់ គឺរលត់កិលេសនឹងទុក្ខអស់រលីងជាអាទិ; បើមិនមែនគួសេចក្តីបរិសុទ្ធិហើយ តើជាអ្វីវិញ? ក្រែងសេចក្តីបរិសុទ្ធិនោះជាលក្ខណៈអាការរបស់វត្ថុអ្វីនីមួយ ពោលគឺជាគុណត្រូវមាននាមគឺវត្ថុឯណាមួយត្រូវមានទីតគុណគឺសេចក្តីបរិសុទ្ធិនោះ នឹងនៅតាមទំនើងខ្លួនឯងមិនបានឬ?, ចុះអ្នកឯណាធ្លាប់ឃើញនៅទីណាខ្លះ ថាសេចក្តីបរិសុទ្ធិនៅតាមទំនើងខ្លួនឯងបាន តែងត្រូវមានវត្ថុជាទីតតាំងនោះមិនមែនឬ? ដូចសេចក្តីបរិសុទ្ធិរបស់ទឹក សេចក្តីបរិសុទ្ធិរបស់គ្រឿងស្លៀក

ជណ្តាប់ ទឹងសេចក្តីបរិសុទ្ធិរបស់កាដនៈផ្សេងៗ ជាដើម នៅដោយ
ទំនើងខ្លួនឯងផ្សេងចាកតែគ្នាបានកាលណា, ក៏កាលបើចូលចិត្តច្បាស់
ហើយថាព្រះនិព្វានជារបស់សេចក្តីបរិសុទ្ធិ ជាគុណមានតែជាទីចត
ដូច្នោះហើយ យើងប្លែខ្លួនខ្លះ ផ្សេងពីព្រះនិព្វាន ឬវៀកគងមិយ៉ាងណា
តែក្រែងដូចគ្នាទេមិនមែនឬ? ។ សម្តែងថា យើងងូតទឹកដុសខាត់មន្ទិល
ញើសក្អែលកងកាយម៉ត់ចត់ស្អាតហើយ អង្គុយដេកសប្បាយ, ផលនៃ
ការងូតទឹកគឺបានសេចក្តីបរិសុទ្ធិ ។ ប្រសិនបើគេសួរថា សេចក្តីបរិ-
សុទ្ធិនោះនៅទីណា? បើយើងមិនចង្អុលចុះត្រង់ខ្លួនយើង តើទៅចង្អុល
ឲ្យត្រង់ទីណាវិញ? ត្រូវចង្អុលចុះត្រង់ខ្លួនយើងនោះឯង ទើបនឹងយើញ
សេចក្តីបរិសុទ្ធិ ។ ប្រសិនបើគេសួរទៀត ថាយើងនោះនៅត្រង់ណា?
បើមិនចង្អុលចុះត្រង់សេចក្តីបរិសុទ្ធិ តើនឹងចង្អុលទីណា? ត្រូវចង្អុល
ចុះត្រង់សេចក្តីបរិសុទ្ធិនោះទៀត ផ្ងនចុះទៅកងទីជាមួយគ្នា ទៅណាក៏
មិនរួច ។ ឧទាហរណ៍មកនេះយើញបានថា យើងប្លែខ្លួនទឹងព្រះនិព្វាន
មានកងទីជាមួយគ្នា បំបែកចេញចាកគ្នាមិនបាន យើងក៏គឺព្រះនិព្វានៗ
ក៏គឺយើងនោះឯង ។ កាលបើដូច្នោះ ទឹងថាយើងប្លែខ្លួនខ្លះមិនមាន,
ព្រះនិព្វាន ជាអនត្តា (មិនមែនខ្លួនឬណា) បានយ៉ាងដូចម្តេច? ឆ្ងាប់
យើញឬទេ? គេចំរើនឧស្សាហ៍ព្យាយាមងូតទឹកដុសលាងញើសក្អែល
ឲ្យតែអស់ទឹកចាំងពាង ញើសក្អែលរបស់ខ្លួនទឹងបានជម្រុះជ្រុះបន្តិច

កំគ្មាន នៅក្រៅក្រសួងដែល ទៅបាននេះចក្តីបរិសុទ្ធិម៉ត់ចត់ នៅតែដ៏សសរផ្ទះទៅវិញ ដែលមិនជាយើង ជាអនត្តា (មិនមែនខ្លួនឯង) ។

អនិច្ចា:ពួកយើងក្នុងលោក អ្នកមិនមានទីពឹងនាំគ្នាបែរមុខទៅទីពឹងព្រះនិព្វានតាមព្រះពុទ្ធបរិហារ តែត្រូវអ្នកប្រាជ្ញទំនងសង្ឃឹមថាព្រះនិព្វានជាអនត្តាមិនមែនខ្លួនឯង នាំគ្នាងាកបែរទៅតាមគ្នា, ចុះគេវិនិច្ឆ័យយ៉ាងដូចម្តេចទើបក្លាយទៅជារឿងប្លែកដូច្នេះ? ។

វិភគធម៌ព្រះនិព្វាន ដែលជាសេចក្តីបរិសុទ្ធិនៃអសង្ខតធម៌ឬអមតៈតាមជាតុនោះ ជាយើងជាអត្តា (ខ្លួនឯង) ។ និយាយស្តាប់ងាយៗ ថាចិត្តនោះឯង ជាយើង ជាអត្តា (ខ្លួនឯង) ក៏បាន តែត្រូវសំគាល់យកចិត្តបរិសុទ្ធ ជាចិត្តលោកុត្តរៈ សង្ខតធម៌ដែលផ្សំអែបនៃបទៅនឹងអសង្ខតជាតុនោះ ជាអនត្តា (មិនមែនខ្លួនឯង) អសង្ខតជាតុដែលបានទទួលសេចក្តីបរិសុទ្ធិជានិព្វាន ឬជាវិភគធម៌ ហើយនោះឯង ជាយើង ជាអត្តា (ខ្លួនឯង) ជាអ្នកសោយផលនៃសេចក្តីបរិសុទ្ធិ ព្រះអង្គទើបត្រាស់ថា ជិព្ឆាំ បរមំ សុខំ "ព្រះនិព្វានជាសុខយ៉ាងក្រៃពេក" ដូច្នេះ ។ បើយើងឬខ្លួនមិនមានទេ ព្រះអង្គត្រាស់យ៉ាងនោះក៏មិនបាន យ៉ាងដូចយើងកាលងូតទឹក ដុសកែលមន្ទិលធ្វើកាយឲ្យបរិសុទ្ធស្អាតហើយ ក៏និយាយថាសប្បាយឬសុខដូច្នោះ សេចក្តីបរិសុទ្ធិនោះក៏នៅៗ ត្រង់ខ្លួនយើងនោះឯង យើងនោះឯងជាតួ

សេចក្តីបរិសុទ្ធិ នឹងជាអ្នកសោយផលនៃសេចក្តីបរិសុទ្ធិ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ហៅមនុស្សបរិសុទ្ធថាជាព្រាហ្មណ៍ ដូចព្រះពុទ្ធបរិហារនេះថា អនេញ្ជំ ឆបរាតកំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ សេចក្តីថា តថាគតពោលចំពោះអ្នកដែលមិនញាប់ញ័រមានខ្លួនដែលឆ្លងលាងហើយ អ្នកដឹងនោះថាជាព្រាហ្មណ៍ ។ ព្រាហ្មណ៍កងទីនេះ គឺព្រះអរហត្តផល មនុស្សអ្នកបានអត្តាហើយ ។ តាមពិតគួរនឹងពោលថា អ្នកមិនឃើញអត្តា (ខ្លួនឫណា) នោះជាអ្នកអភ័ព្វ តែគេត្រឡប់ពោលថាមនុស្សដែលឃើញអត្តា (ខ្លួនឫណា) នោះជាមិច្ឆាទិដ្ឋិវិញ ជាក់ទោសឲ្យអគ្គិយគាល់ក្បាលទង្គត់ប្រចាំលោក ទៅនិព្វានមិនបានត្រូវអន្ទោលវិលវល់ ដោយសង្សារវដ្ត ។ ចុះបើយើងឬខ្លួនមិនមានហើយ អ្វីទៅអគ្គិយគាល់ក្បាលទង្គត់ហ៎ ? ចុះអ្នកឯណាជាអ្នកផុតចាកការអគ្គិយគាល់ក្បាលទង្គត់ទៅបាន ? គួរនឹងថាមនុស្សមិនមានខ្លួននោះឯងអគ្គិយគាល់ក្បាលទង្គត់ប្រចាំលោកជាអ្នកវិលវល់ សេចក្តីឃើញក៏វិលវល់ និយាយចេញមកក៏វិលវល់ ធ្វើឲ្យអ្នកស្តាប់វិលវល់ទៀតជាចំនួនមិនគិតកងទីបំផុតទៅអគ្គិយគាល់ក្បាលទង្គត់ នៅជាមួយគ្នាតាំងអស់ ។

លោកខ្លះ អាងថាអត្តានោះ ជាបញ្ញត្តិ ឬសម្មុតិ បើជាបញ្ញត្តិចេញ ហើយក៏គ្មានអ្វី ។ ដែលថាអត្តាជាបញ្ញត្តិនោះត្រូវ, តែថាជាបញ្ញត្តិហើយ មិនមានអ្វីនោះ ចាត់ថាខុស ។ តំរាត្តផ្សេង។

ដែលយើងឃើញ យើងត្រូវឃើញដោយភ្នែកពីរយ៉ាង គឺសាច់ភ្នែក (មំសចក្ខុ) នេះមួយ៉ាង, ភ្នែកបញ្ញាដែលហៅថា បញ្ញាចក្ខុនោះមួយ៉ាង ។ ដូចរូបផ្សេង។ ខាងក្រៅ យើងមើលឃើញបានដោយសារសាច់ភ្នែក, តែសភាវធម៌ផ្សេង។ ខាងក្នុង ត្រូវយើងឃើញដោយបញ្ញាចក្ខុ, ព្រះអង្គត្រាស់ដឹងជាព្រះពុទ្ធក៏ទ្រង់អាស្រ័យព្រះបញ្ញាចក្ខុ ។ វត្ថុទាំងឡាយដែលច្បាកដដោយសាច់ភ្នែកនោះ នៅមិនទាន់ចាត់ជាបញ្ញត្តិឬ សម្មតិទេ លុះកាលណាបានគិតនឹកតែងតាំងឡើង ឬបានបញ្ចេញសំឡេងប្រកាសឈ្មោះវត្ថុនោះ។ ឲ្យអ្នកដទៃដឹងឃើញឡើង ទើបចាត់ជាបញ្ញត្តិឬ សម្មតិ ។ វត្ថុកើតមុន បញ្ញត្តិឬ សម្មតិកើតក្រោយ តួយ៉ាងដូចពែងវត្ថុមានឡើងមុន មនុស្សទើបគិតបញ្ញត្តិហៅវត្ថុនោះថាពែង ។ បើវត្ថុនោះមិនមាន ពាក្យដែលហៅថាពែងក៏មិនមាន ។ បញ្ញត្តិនឹងកើតមុនវត្ថុមិនបានទេ បើវត្ថុមិនមាននឹងបញ្ញត្តិហៅយ៉ាងដូចម្តេចក៏មិនបាន តែបើវត្ថុមាន សូម្បីយើងមិនបានបញ្ញត្តិហៅថាអ្វី ក៏វត្ថុនោះរមែងមានដោយប្រក្រតី ព្រោះដូច្នោះទើបថា មនុស្សដែលឃើញថាជតបញ្ញត្តិឬ សម្មតិ ហើយមិនមានអ្វីនោះជាខុសឥតត្រូវឡើយ ។ អត្ថានោះជាបញ្ញត្តិពិត តែបញ្ញត្តិចុះទៅកងវត្ថុដែលមាន ។ សូម្បី អនិច្ចំ ទុក្ខំ អនត្តា នោះក៏ជាបញ្ញត្តិដូចគ្នា រហូតដល់ធម៌ពាក្យប្រដៅដទៃ។ របស់ព្រះពុទ្ធជាម្ចាស់ដូចអរិយសច្ច ៤, ពោជ្ឈង្គ ៧ ជាដើមក៏ជាបញ្ញត្តិ ។ រួមសេចក្តីថាអ្វី។ ដែលយើងនិយាយស្តីហៅប្រើគ្នា ក៏ជាបញ្ញត្តិទាំងអស់ ។ វត្ថុនោះ។

គ្រាន់តែប្រកាសលក្ខណៈអាការៈ ឲ្យយើងដឹងឃើញចំពោះខ្លួនប៉ុណ្ណោះ កាលនឹងនិយាយស្តីក្នុងការកំត្រូវអាស្រ័យបញ្ញត្តិនឹងវត្ថុនោះៗ ដែលមានទៅ ។ មនុស្សនឹងតាំងបញ្ញត្តិឡើង ឬនឹងដកបញ្ញត្តិចេញក្តី វត្ថុនោះៗក៏មាននៅដោយប្រកតីជាធម្មតា មិនមែនអស់សូន្យទៅ ព្រោះតែដកបញ្ញត្តិរបស់មនុស្សឡើយ ។ បើសិនជាអស់សូន្យ ក៏សូន្យទៅព្រោះហេតុនៃវត្ថុនោះឯងអស់ទៅតាមធម្មតា ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រដៅឲ្យពិចារណាឃើញតាមសេចក្តីពិតក្នុងសង្ខារធម៌ ដោយសេចក្តីជា អនិច្ចំ ទុក្ខំ អនត្តា ហើយមិនឲ្យប្រកាន់ខ្ជាប់ក្នុងសង្ខារនោះប៉ុណ្ណោះ, ធ្វើដូចម្តេចទើបត្រូវដកបញ្ញត្តិ ឬសម្មតិ តាំងធ្វើវត្ថុដែលតាំងបញ្ញត្តិនោះឲ្យរលាយបាត់សូន្យទៅផង ហើយក៏រកពិតយ៉ាងដែលថានោះគ្មាន? ។ ទោសកើតមានព្រោះប្រកាន់ខ្ជាប់ដោយខ្លួនឯង មិនមែនទោសកើតមានព្រោះសម្មតិទេ ។ ក៏កាលបើដឹងថាជាបញ្ញត្តិហើយ ហេតុដូចម្តេចទើបវែសនិយាយយកតែខាងថាមិនមែនយើង មិនមែនអត្តា (ខ្លួនជ្ញាណ) ហ៎?, ខាងយើងខាងអត្តា (ខ្លួនជ្ញាណ) និយាយមិនបាន បដិសេធខាងសង្ខារធម៌ ដោយពាក្យថាអនត្តា (មិនមែនខ្លួន) ហើយ ហេតុម្តេចមិនហ៊ានទទួលព្រះនិព្វានថាជាអត្តា?, កាលបើដូច្នោះ ក៏មិនមានឧកាសដួបខ្លួនរបស់ឯង នៅបង្ហោសអង្អែលតែសង្ខារធម៌ ដែលមិនមែនរបស់ខ្លួនដកបង់ទៅ នឹងប្រតិបត្តិតាមព្រះពុទ្ធភាសិតថា អត្តា បិ អត្តនោ

ជាបើ "ខ្ញុំជាទីពឹងរបស់ខ្ញុំ" បានយ៉ាងដូចម្តេច? បើថាខ្ញុំរបស់ខ្ញុំនោះមិនមានទេ តើនឹងយកខ្ញុំអំពីណាមកទីពឹង? ។ ព្រោះដូច្នោះទើបគួរទទួលព្រះនិព្វានជាអត្តា (ខ្ញុំច្បាណ) កុំបដិសេធឡើយ, ព្រះនិព្វានជាទីពឹងដ៏ប្រសើរជាទីបំផុតហើយ តែពាក្យថាទទួលនោះមិនបានសំគាល់សេចក្តីថា ប្រកាន់ខ្ជាប់ក្នុងពាក្យបញ្ញត្តិដែលសម្រាប់ហៅប្រើ, បើប្រកាន់មាំក៏ពាប់ថាជាប់ក្នុងពាក្យបញ្ញត្តិដែលសម្រាប់ហៅប្រើ, អសង្ខតៈជាតុដែលបាននេះសេចក្តីបរិសុទ្ធិជានិព្វានហើយ មិនមានការប្រកាន់ខ្ជាប់ ។

មនុស្សខ្លះនិយាយថា "លះបង់រក្តដទៃៗហើយ ទៅប្រកាន់ខ្ជាប់ព្រះនិព្វានទៀត និយាយថាលែងក្រៅជាប់ក្នុង ។ បើប្រកាន់ព្រះនិព្វានពាក្យថាយើងក៏ត្រូវជាខន្ធ ៥ ព្រោះកើតជាពីរឡើងហើយ គឺយើងម្ចាស់ព្រះនិព្វានម្ចាស់ ។ កាលយើងជាខន្ធ ៥ ខន្ធ ៥ ជាយើងហើយ យើងក៏លះបង់ខន្ធ ៥ មិនបាន ព្រោះខន្ធ ៥ ជាយើង។ ចូលទៅប្រកាន់ព្រះនិព្វាន, លុះខន្ធ ៥ បែកវិលត់ យើងក៏ស្លាប់តាមខន្ធ ៥, តែព្រះនិព្វានមិនមែនស្លាប់ កាលបើដូច្នោះ យើងក៏រកផុតស្លាប់គ្មានទេ, ដែលនឹងផុតស្លាប់បានក៏លុះតែយើងត្រូវជាព្រះនិព្វាន ព្រោះព្រះនិព្វានជាយើងជាអត្តា (ខ្ញុំច្បាណ) ទើបនឹងបដិសេធខន្ធ ៥ លះបង់សេចក្តីប្រកាន់បាន ។ ចុះបើយើងជាព្រះនិព្វានហើយ ទៅគាញយកព្រះនិព្វានអ្វីទៀតហ:! ព្រោះដូច្នោះដែលនិយាយថា "គទៅប្រកាន់យកព្រះនិព្វានទៀត" ពាក្យនេះខ្ញុំស្តាប់មិនចូលចិត្តសោះ ។ (មានត)

ព្រះមហាឧត្តមរដ្ឋា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីវង្ស វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃ្លានបណ្ណាន្តរកម្ម ប៊ុ-ប៉ នៅពុទ្ធសាសនបណ្ឌិត្យអ្នកពិនិត្យកែ

(តមក)

ការរក្សាវាចានោះ គឺការប្រុងប្រៀងចាំពោះតែកន្លងផ្លូវដែលត្រូវ ។ បើអប់រំឲ្យប្រព្រឹត្តទៅកន្លងផ្លូវដែលខុស មិនមែនជាការរក្សាវាចាទេ ។ ព្រោះរបស់ដែលត្រូវរក្សា រមែងជារបស់មិនខុស បើខុសហើយ ក៏មិនមែនជារបស់ដែលគួររក្សា បើទំនៃតែរក្សា ក៏មុខជាខុសទៅតាមគ្នា សូម្បីការប្រែត្រឡប់សោត បើប្រែពីត្រូវទៅរកខុស ដូចជាត្រឡប់ពីស្មោះត្រង់ទៅរកវៀច ត្រឡប់ពីសុចរិតទៅរកទុច្ចរិត ក៏ជាសេចក្តីអាក្រក់ លុះតែប្រែពីខុសមករកត្រូវ ដូចជាប្រែខ្នងដែលអាក្រក់ឲ្យមកល្អវិញបាន ប្រែចិត្តអាក្រក់ឲ្យមកល្អបាន ឬក៏ឃាត់ចិត្តចាកអាក្រក់បាន មិនឲ្យធ្វើតាមអំពើដែលខុស ទើបចាត់ថាជាសេចក្តីល្អ ។ ហេតុនេះ លក្ខណៈនៃសេចក្តីស្មោះត្រង់ចំពោះវាចាដែលត្រូវរក្សាឲ្យមុឺងម៉ាត់ ទើបមានកំណត់ជា ៣ សណ្ឋាន គឺ :

១ — សំបថ ·— ការឲ្យសំដីហ្មត់ចត់របស់ខ្លួនដល់អ្នកដទៃ ជាលក្ខណៈនៃសំបថ ។ បើពោលឲ្យសំដីហ្មត់ចត់ដល់នរណា ក៏ពោល

ដោយសុទ្ធចិត្តពិតៗ ដូចជាឲ្យពាក្យសច្ចាប្រណិធានថា "នឹងមិនធ្វើឬធ្វើ" ដូច្នេះហើយ ក៏មិនគិតចិត្តប៉ាំងទុក ខំរក្សាឲ្យប្រព្រឹត្តទៅតាមសំបថនោះ ហៅថា រក្សាសំបថ ។ បើពោលស្បថ ដូចជាខ្ញុំពោលថាការដែលធ្វើសច្ចាប្រណិធានថា "នឹងតាំងចិត្តទទួលការពាដការដែលជានាទីរបស់ខ្លួន" ដូច្នេះហើយត្រឡប់ជាមិនធ្វើតាម ហៅថាខុសសំបថ ។ បើបង្ខំចិត្តឲ្យពោល ដូចជាមនុស្សប្រព្រឹត្តអាក្រក់ លុះត្រូវអាជ្ញាគ្របសង្កត់ ក៏ចេះតែពោលស្បថទៅថា "នឹងលែងប្រព្រឹត្តដូច្នេះទៀត" តែខាងក្រោយមក ក៏ត្រឡប់ជាប្រព្រឹត្តវិញ យ៉ាងនេះហៅថា កន្ទងសំបថជាការខូចសុទ្ធចិត្តរបស់ខ្លួនឯង ។ លោក-អ្នកចាំងឡាយ គប្បីចៃរក្សាសំបថទុកឲ្យស្មើនឹងជីវិត បើទុកជាត្រូវខូចបង់ជីវិត ក៏កុំឲ្យខូចបង់សច្ចៈ ។

๒- ប្តេជ្ញា :- ការឲ្យពាក្យទទួលត្រមដល់អ្នកដទៃថា "នឹងធ្វើ" ឬ "នឹងមិនធ្វើ" ជាលក្ខណៈនៃការប្តេជ្ញា ។ ពាក្យប្តេជ្ញាដែលយើងឲ្យដល់មនុស្សដទៃនោះ គេឲ្យក្នុងផ្លូវធានាអះអាងថា "នឹងធ្វើ" ក្តី គេឲ្យក្នុងផ្លូវលះវៀរថា "នឹងមិនធ្វើ" ក្តី ក៏រួមហៅថា "ប្តេជ្ញា" ដូចគ្នាទាំងអស់ ។ ការឲ្យប្តេជ្ញាចំពោះគេយ៉ាងណាហើយខំរក្សាឲ្យប្រព្រឹត្តទៅយ៉ាងនោះ ហៅថា រក្សាពាក្យប្តេជ្ញា ។ បើមិនរក្សាទេ ហៅថា ខុសពាក្យប្តេជ្ញា ។ សូមលោក-អ្នករក្សាពាក្យ

ប្តេជ្ញាខ្លួនឲ្យម៉ឺងម៉ាត់ចុះ សូមកុំភ្លេចថា "ធ្វើប្តេជ្ញាហើយប្រែចាកប្តេជ្ញាវិញ មិនប្លែកអ្វីអំពីការណាត់អ្នកដទៃឲ្យចោកខ្លួនឯងឡើយ" ។

๓ — សង្ឃា ·— ការឲ្យពាក្យយល់ព្រមដល់គ្នានឹងគ្នា ជាលក្ខណៈនៃពាក្យសន្យា ។ ការឲ្យពាក្យយល់ព្រមនោះ សូម្បីយើងធ្វើទៅដើម្បីឃុំគ្រងផ្លូវច្បាប់ទំលាប់ដែលហៅថា ទីតិក្រមក្តី ធ្វើទៅដើម្បីប្រយោជន៍ដទៃទៀតក្តី គង់ហៅថា សន្យាទាំងអស់ ។ សូមកុំភ្លេច! កាលនឹងឲ្យខសន្យាដល់នរណាមួយ ត្រូវត្រួតមើលខ្លួនដែនឹងអំណាចនៃពាក្យយល់ព្រមរបស់ខ្លួន ឲ្យដឹងសព្វគប់សិនថាចង្អៀត ខ្លួយត្រឹមណា លុះសន្យារួចហើយ ត្រូវប្រតិបត្តិតាមឲ្យបានត្រឹមនោះ កុំធ្វើទៅដោយវង្វេង ឬសន្ទិះសង្ស័យមិនជាក់លាក់ទាំងកុំភ្លេចប្រើសំនួនឲ្យហួសសេចក្តីពិត ដែលជាហេតុឲ្យអ្នកម្ខាងវង្វេងដើរតាមឬប្លែចិត្តខុស ។

កាលបើយល់ព្រមគ្នាធ្វើសន្យាហើយ គប្បីរក្សាឲ្យពិតត្រូកដទៅតាមសន្យានោះ សូម្បីមិនមានសាក្សី ក៏កុំក្រឡះប្រព្រឹត្តឲ្យខុសចាកសេចក្តីពិតក្នុងចិត្ត ដែលជាសាក្សីនៅប្រចាំក្នុងខ្លួនយើងស្រាប់នោះឡើយ ។ បើធ្វើយ៉ាងនេះបានហើយ ហៅថា រក្សាពាក្យសន្យា ។ បើមិនរក្សាទេ ហៅថា កន្ធង់ពាក្យសន្យា ។ លោក-អ្នកគប្បីធ្វើតាមពាក្យសន្យាចុះ ដោយហោចទៅ សូម្បីអ្នកទទួលសន្យាជាអ្នកតូច

កំលោក-អ្នកកុំក្រឡះប្តូរបំផ្លាស់សន្យានោះចោលឡើយ ត្រូវធ្វើតែតាម
ខសន្យា ដើម្បីរក្សាញាតិមិត្តនឹងប្រទេសជាតិស្រុកភូមិ ។ ចូរកុំទទួល
ខសន្យាក្នុងកិច្ចការដែលខ្លួនមិនអាចធ្វើបាន គួរប្រយ័ត្នរក្សាវាចាឲ្យគង់
វង់ ប្រតិបត្តិតាមពាក្យសន្យាឲ្យខ្ជាប់ខ្ជួន ។

ក្នុងលក្ខណៈស្មោះត្រង់ចំពោះវាចាទាំង ៣ ប្រការនេះ សំបថជា
ពាក្យស្បថ់ក្រឡា ។ យើងស្បថយ៉ាងណា ត្រូវប្រតិបត្តិយ៉ាងនោះ
នឹងក្រឡះលើកចេញមិនបាន ។ ឯប្តេជ្ញានឹងសន្យាវិញ បើអ្នកម្នាង
ទៀតយល់ព្រមផង ក៏អាចលើកចោលទៅបាន ។ តែបើយល់ព្រម
តែខ្លួនយើងម្នាក់ឯងទេ លើកចោលពុំបានឡើយ បើយើងធ្វើខុសមុនពេល
ដែលលើកចោល ឬ មុនពេលផ្លាស់ប្តូរនោះ ទុកថាជាការកន្ងងប្តេជ្ញា
នឹងសន្យា ។ បើលោក-អ្នកចង់ឲ្យមនុស្សទាំងពួងជឿនឹងរាប់អានខ្លួន
ត្រូវកុំល្មើស កុំក្រឡះពាក្យ កុំប្រែប្រួល កុំទំលាក់ចោលឬលើកចោល
នូវពាក្យសំដីរបស់ខ្លួនឡើយ ចូរមានវាចាសច្ចៈ រក្សាវាចាឲ្យមុឺងម៉ាត់
បើវាចាណាជារបស់ខ្លួន ចូររក្សាឲ្យពិតតាមវាចានោះកុំបីប្រែប្រួល ។

ស្មោះត្រង់បំពោះការងារ.— ការមានទិស្សយស្រឡាញ់ការ
ងារ ធ្វើអ្វីតាំងចិត្តធ្វើពិត ។ មានសម្បត្តិនៃសេចក្តីព្យាយាមទាំង ៣
ប្រការ គឺការព្យាយាម ការខ្មស្សាហ៍ នឹងការភ្ញាក់រឭកហ្មត់ចត់ ដែល
ជាគ្រឿងលើកកំឡាំងចិត្តឲ្យរឹងប៉ឹងខ្ជាប់ខ្ជួនក្នុងការ ប្រាសចាកកុសីត-

ភាព នឹងការច្រែអូសមិតពត់ នេះចាត់ជាលក្ខណៈនៃសេចក្តីស្មោះត្រង់ចំពោះការងារ ។ តាមពិតវិធីដែលនឹងធ្វើឲ្យយើងបានសមដូចចំណងនោះ ក៏គឺនិស្ស័យស្មោះត្រង់ចំពោះការងារ ។ និស្ស័យស្មោះត្រង់ចំពោះការងារនេះ មានសេចក្តីស្រឡាញ់ការងារយ៉ាងអស់ពីចិត្ត មានការយកចិត្តទុកជាក់មែន។ មានការទទួលការៈ ហាក់ដូចជាចង់ច្រណាំងច្រដែង មានការគាំងចិត្តធ្ងើយាងម្តងម៉ាត់ នឹងមានការយកចិត្តទុកជាក់ពិនិត្យពិច័យយ៉ាងហ្មត់ចត់ ជាលក្ខណៈ ។ ព្រោះថាបើយើងមានការគាំងចិត្តធ្វើពិតប្រាកដនៅក្នុងទីណា ត្រូវមានផ្លែអំណោយផលឲ្យបានសម្រេចឡើងក្នុងទីនោះ ។ ដូច្នេះ និស្ស័យនេះ ទើបពាក់ព័ន្ធជាឈើច្រត់មាស សម្រាប់នាំយើងទៅកាន់ទីសម្រេចផលនៃកិច្ចការទាំងពួង ។ អ្នកច្បាស់ថ្លាលទ្ធផលនៃការងារបស់ខ្លួន សូម្បីនឹងធ្វើកិច្ចការណា ក៏គួរធ្វើកិច្ចការនោះឲ្យពិត។ ។

ការងារគឺហេតុ ទុកដូចជាព្រះម្ចាស់សួគ៌ដែលបណ្តាលឲ្យកើតផល គឺប្រាក់ឬដើមទុន ។ ប្រាក់ឬដើមទុនគឺផល ទុកដូចជាបុត្រនៃព្រះម្ចាស់សួគ៌ដែលកើតមកអំពីការនិមិត្ត បណ្តាលនៃព្រះម្ចាស់សួគ៌ ។ ការប្រកបការងារ ជាហេតុបណ្តាលឲ្យក្លាយទៅជាអណ្តូងកើតនៃប្រាក់ឬដើមទុន ។ សូម្បីប្រាក់ឬដើមទុននោះ ក៏គឺផលរបស់ការងារដែលហ្មត់ចត់ ។ ហេតុនេះ កំឡាំងការងារ ទើបមានអំណាចលើប្រាក់

ឬ ដើមទុន ព្រោះយើងនឹងបានគ្រឿងឧបភោគ បរិភោគ គុណវុឌ្ឍិ នឹង សេចក្តីសុខ សេចក្តីចំរើន ត្រូវប្រើកំឡាំងការងារជានិច្ច ។ អញ្ចឹញ្ញ មើលចុះ សំពត់អាវគ្រឿងស្លៀកពាក់ - ជណ្តាប់ប្រើប្រាស់ដ៏ល្អៗ គ្រឿងតុបតែងផ្ទះសំបែងដ៏វិចិត្រតែគ្រាលក្អែក រថយន្ត រថភ្លើងនឹងអាកាសយាន ដែលធ្វើឲ្យការគមនាគមន៍ផ្លូវទឹកផ្លូវគោក នឹងផ្លូវអាកាសបានស្រួលឆ្ងាយ ពេញលោក ។ សូន្យបញ្ជាស្រែចំការដែលពីដើមឯងឥតសូន្យជាព្រៃសោះ កំភ្លុយទៅជាទីគួរគក់ភ្ញាក់ចិញ្ចែងដោយពន្លឺអគ្គិសនី ។ វត្ថុទាំងអស់នេះ សុទ្ធតែកើតមកអំពីកំឡាំងនៃការងារទាំងអស់ ឬសូម្បីវត្ថុនានាដទៃទៀត ក៏សុទ្ធតែជាផលនៃកំលាំងការងារដែរ ។

ធ្វើការដើម្បីទំនុកបំរុងជីវិត ធ្វើការដើម្បីកិត្តិយស នឹង ធ្វើការដើម្បីជាករណីយកិច្ច ចាត់ជាលក្ខណៈនៃការធ្វើការងារ ។ តែអ្នកដែលមានទិស្សយស្រឡាញ់ការងារ រមែងធ្វើការងារដើម្បីជាករណីយកិច្ច គឺធ្វើដោយឃើញថា ជានាទីដែលខ្លួនជាមនុស្សមួយដូចគេក្នុងលោកដែលត្រូវតែធ្វើ ហើយរាប់អានការងារដូចជាព្រះម្ចាស់សួគ៌ រាប់អានប្រាក់ ឬ ដើមទុន ដូចជាបុត្រនៃព្រះម្ចាស់សួគ៌ ព្រោះប្រាក់មាស ឬ ដើមទុន សម្រាលចេញមកពីការងារ ព្រមទាំងជាអ្នកចារឹកធន្លៈ វិរិយៈឧស្សាហៈ ព្យាយាម នឹងប្រឹងប្រែងម៉ឺងម៉ាត់ទុកក្នុងប្រអប់សីសៈ ដែរដើម្បីនឹងសារសៃនៃមនុស្សខ្លួនឯង ធ្វើអ្វី ក៏តាំងចិត្តធ្វើពិតៗ មិនរួញរាមិនខ្ជិល

ច្រអូសមិតពត់ ធ្វើហូរហែជានិច្ច ចំណាំចំពោះកិច្ចដែលធ្វើជាសំខាន់ ។
សូម្បីក្នុងខណៈដែលធ្វើ ក៏មានចិត្តប៉ុនប៉ងខ្ជាប់ខ្ជួននៅក្នុងកិច្ចនោះ ប្រៀប
ដូចគ្រីវិស័យដែលចង្អុលទៅទិសខាងដើងជានិច្ច តាំងសេចក្តីព្យាយាម
ពិត ព្យាយាមធ្វើហ័សរហួនពិតៗ គ្រប់ប្រការ ដំណើរការងារតាម
ទំនងបុរសឈើចាក់ស្រែះក្នុង ឬទឹកក្នុងជ្រោះជ្រលងដែលហូរច្រោះក្នុងឲ្យ
ក្លាយទៅជាស្ងួត នឹងធ្វើការងារដោយធន្លុះតាប់ចិត្ត រកាយចិត្ត មិនគិត
ថាការងារនោះធ្ងន់ឬស្រាលឡើយ មិនតែប៉ុណ្ណោះ ថែមទាំងគ្រប់
ឃើញការងារធ្ងន់ ថាជាគ្រឿងបង្ហាត់និស្ស័យឲ្យល្អក្រៃលែង ធ្វើឲ្យ
ស្គាល់ដំឡៃរបស់ច្បាក់ នឹងឲ្យចេះប្រើច្បាក់ជាប្រយោជន៍ទៅវិញ ជា
អ្នកមានចិត្តមាន: អត់ធន់ក្នុងការពាន់ពារទុបសគ្គ លះបង់សន្ដានកាយ
មាយ និស្ស័យថោកទាបចេញ ធ្វើឲ្យទៅជានិស្ស័យល្អ អាចធ្វើកិច្ចការ
គួប ធំ ងាយ លំបាក ធ្ងន់ ស្រាលឲ្យសម្រេចបានទាំងអស់ ។

គ្រែកឡើងអ្នកកម្មជា !!! ចូរគ្រែកឡើង ! នាំគ្នាខំបណ្តុះ
និស្ស័យស្មោះត្រង់ចំពោះការងារ ! ការងារចូរជាគ្រីវិស័យរបស់លោក
ចុះ ! ការងារនៅក្នុងទីណា ចូរយាត្រាឆ្ពោះទៅកាន់ទីនោះ ! កុំមើលង
ងាយការងារ ! ។ បើលោក - អ្នកស្មោះត្រង់ចំពោះការងារហើយ
អនាគតរបស់លោក - អ្នក ក៏នឹងបានភ្លឺថ្លា មានដងផ្លូវសម្រាប់ដើរទៅ
កាន់សេចក្តីចំរើនកាន់មុខ ។ មើលចុះ ការគាំងចិត្តធ្វើការងារពិតៗ

មិនខ្ជិលខ្ជា តែងក្លាយទៅជាទឹកដែម ពាំងស្រែមខ្ជើយ កំក្លាយទៅជាសំពត់ថ្មី ។ បើលោក - អ្នកមើលងាយការងារវិញ អនាគតរបស់លោក - អ្នក ក៏នឹងងងឹតឈ្លប់ មិនមានប្រវត្តិហេតុដ៏ល្អអ្វីមួយ ដែលនឹងចារឹកទុកឲ្យបច្ចុមាជនតាជនជាន់ក្រោយ នឹករឭកបានឡើយ ។ កាលលោក - អ្នកស្លាប់ទៅហើយ ក៏ហើយទៅតែម្តង មិនមាននរណាស្តុកចិត្តទេ ។ ដូច្នេះ លោក - អ្នកចូរធ្វើខ្លួនឲ្យជាមនុស្សពិតប្រាកដធ្វើការងារឲ្យពិតៗ ធ្វើរបស់អ្វី ត្រូវប្រើសេចក្តីពិតក្នុងរបស់នោះ កុំគ្រាន់តែថាឡើយ ត្រូវបែរមុខយកចិត្តទុកដាក់ក្នុងការងារឲ្យគ្រប់វេនប៉ុនប៉ងឲ្យវត្ថុដែលធ្វើនោះបានសម្រេចប្រយោជន៍ពិតៗ កុំជាមនុស្សខ្ជិលច្រអូសមិតពត់ឡើយ ព្រោះមនុស្សខ្ជិលច្រអូស ជាមនុស្សស្លាប់មុនស្លាប់ ។

មនុស្សខ្ជិលច្រអូសនោះ ទឹងកើតទៅជាមនុស្សពេញទីឡើងបានលុះតែគេដឹងខ្លួនខាន់ ហើយផ្ទាស់ចិត្តមកជាមនុស្សប្រឹងប្រែងរឹងបឹងធ្វើការងារដោយសេចក្តីអត់ធ្មត់វិញ ។ លោក - អ្នកត្រូវផ្ទាស់ចិត្តគំនិតពីសេចក្តីខ្ជិលច្រអូសមកកាន់ការឧស្សាហ៍ចុះ ត្រូវមានន័ស្ស័យស្រឡាញ់ការងារឲ្យមែនទែន កុំធុញទ្រាន់ចំពោះកិច្ចការ កុំនឿយណាយចំពោះសេចក្តីលំបាក កុំរួញរាចំពោះឧបសគ្គ ចូរប្រតិបត្តិតាមច្បាប់ទាំងក្រោមនេះគឺ :

๑ - ផ្គងដៃប្រកបការងារ ធ្វើកិច្ចធ្ងរតាមនាទីរបស់ខ្លួនកុំទៅសៀមកុំជាមនុស្សទំនេរ ចូរបង្ហាត់ឲ្យខ្លួនមានកំលាំងចិត្តខ្លាំងក្លែង ព្រោះចិត្តដែលទំនេរ ជាកំពែងរឹងមាំសេចក្តីល្អគ្រប់ផ្នែក ។

២ - ត្រូវបណ្តុះធន្ទុ:ឲ្យរួមគ្នាក្នុងកាលធ្វើកិច្ចអ្វីមួយ នឹងចម្រុះសេចក្តីព្យាយាមទាំងអស់ក្នុងកិច្ចនោះតែម្យ៉ាង កុំពយមាយ ឬសាកៅក្នុងកិច្ចការដទៃ។ បែរមុខចំពោះតែនឹងធ្វើឲ្យកិច្ចនោះបានសម្រេច ។

៣ - ត្រូវតាំងខ្លួនទុកឲ្យដូចជាអ្នកដែលចង់ចែកគេចូលទៅក្នុងចន្ទោះទ្វារដែលមានពួកមនុស្សខ្ចាន់ខ្ចាប់ដូច្នោះ គឺត្រូវប្រឹងប្រែងធ្វើការងារ ពាន្យាពារទុបសគ្គដោយពេញទំហឹង កុំរួញរា ឬខ្ជិលច្រអូសនៅអង្គុយសៀមឲ្យឆ្ងុយងោកអណ្តែតអណ្តង់ពយមាយ នឹងកុំវង្វែងអាងលេសថាកេគសង្កត់សង្កិនពិបាកចិត្តធ្វើមិនកើត ឬមិនមានអ្វីនឹងធ្វើ កុំបន្ទោសកំណើតរបស់ខ្លួនថាមិនល្អស្មើនឹងមិត្តភក្តិ ។

៤ - បើចួបរបស់ណាដែលជានាទីរបស់ខ្លួនហើយ គប្បីតាំងចិត្តធ្វើរបស់នោះឲ្យបានល្អពេញទី កុំមាក់ងាយដោយឃើញថាធាប់ដល់ហើយបង្អែបង្អង់ឡើយ គប្បីប្រញាប់ប្រញាល់ប្រកបកិច្ចនោះឲ្យទាន់កាលទាន់សម័យ ប្រយ័ត្នកុំឲ្យហួសពេលហួសវេលា តាំងចិត្តធ្វើឲ្យបានល្អយ៉ាងបំផុត ។

៥ - ប្រតិត្តឲ្យឆ្ងាប់ខ្លួនក្នុងកិច្ចដែលខ្លួនប្រកប មិនត្រូវរើរុះដោះដៃក្នុងកាលទេ ត្រូវខំអត់ធន់ ព្យាយាមប្រកបទៅដោយលំដាប់ នឹងត្រូវឲ្យមុឺងម៉ាត់ក្នុងកិច្ចដែលខ្លួនធ្វើនោះផង ប្រយ័ត្នកុំឲ្យប្រែប្រួល គឺបើនឹងធ្វើអ្វី ត្រូវធ្វើឲ្យបានពិត។ ។ (មានត)

១កញ្ញាវិបុលរាជសេនា ន្ងួ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះ១បាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ម៉ាន់ថង់ឆ្លើយថា បើលោកថង់ចាន១ងសុីឡុង នោះមិនត្រូវប្ដូនាងទេ ខ្ញុំបាទនឹងសុីឡុងជាមនុស្សធ្លាប់រាប់អានស្រឡាញ់គ្នាមកពីដើម យប់នេះខ្ញុំបាទនឹងសូមយកអាសាចេញទៅនិយាយលួងលោមយក១ងសុីឡុងឲ្យបាន ។ ចូវូបានស្ដាប់ក៏មានចិត្តត្រេកអរណាស់ហើយថា អ្នកចូរទៅតិតគូរធ្វើការតាមដំរេីបាជ្ញាចុះ ។ លុះវេលាយប់ម៉ាន់ថង់ក៏តែង១ងជាហានទៀវ បន្ទុំចូលទៅក្នុងបន្ទាយអៀវហង ឃើញសុីឡុងពាក់ត្រីសអុចខ្មៀនអង្គុយមើលសំបុត្រ ។ ម៉ាន់ថង់ក៏ចូលទៅគំនាប់ហើយដំរាបថា តាំងពីយើងបែកចាកគ្នាមកយូរហើយ អ្នកបានសេចក្ដីសុ១សប្បាយទេឬ ? ។ សុីឡុងបានឮសំដីក៏ងើបមុ១ឡើងមើល ឃើញគាហានបែក

មុខក៏តក់ស្លុតស្មារតី លុះប្រឹងសំឡឹងមើលច្បាស់ក៏ស្គាល់បាន ទើបសួរ
ថា អ្នកនេះឈ្មោះម៉ាន់ថង់នៅស្រុកសាន់យ៉ុងឬ? មានការអ្វីមករកយើង
ថ្ងៃនេះ? ។ ម៉ាន់ថង់តបថា ខ្ញុំបាទចូលធ្វើខ្ញុំកជការនៅនឹងចូធួ, កាលពី
ថ្ងៃមិញនេះខ្ញុំបានឃើញអ្នកចេញទៅប្រយុទ្ធគ្នានឹងខៅជួ ខ្ញុំមិនបានសាក
សួរអ្នកកន្លងវេលានោះ ព្រោះចាំចិត្តគិតថាយប់នេះនឹងវិលចូលមករក
ដៃលខ្ញុំមកនេះមិនមែនថាមិនខ្វាចសេចក្តីស្លាប់ទេ ទើបបន្ទុំចូលមកបរចា
នឹងអ្នកឲ្យបាន។ ស៊ីឡុងស្តាប់ហើយក៏អញ្ជើញឲ្យម៉ាន់ថង់អង្គុយក្នុងទីសម
គួរហើយថា អ្នកមានការមករកខ្ញុំនោះដោយកិច្ចធុរៈអ្វីនិយាយទៅចុះ ។

ម៉ាន់ថង់ឆ្លើយថា ខ្លួនអ្នកជាមនុស្សមានកំលាំងខ្លាំងពូកែគ្មាននរណា
ស្មើសោះ ចុះរាស់ពីព្រោះអ្វី បានជាមកនៅក្នុងកណ្តាប់ដៃអៀវហង
ហាន់សៀមដូច្នេះ ធម្មតាមនុស្សក្នុងសម័យនេះខ្ញុំយល់ឃើញថា ចូធួ
ជាអ្នកមានអធ្យាស្រ័យល្អប្រកបទាំងស្មារតីជ្រាជ្រាហាន មានចិត្តធូរ
ទូលាយស្រេកឃ្លានសេនាឥហានមិនឲ្យអនាទរសោះ កិត្តិស័ព្ទនោះ
អ្នកគង់ដឹងពូមកហើយ កាលអ្នកចេញទៅតយុទ្ធគ្នានឹងខៅជួនោះ ចូធួ
ឃើញអ្នកក៏មានចិត្តអាណិតពន់ប្រមាណ មិនបានបើកឲ្យឥហានជាញ់
ជ្រៃមកទៀតែឡើយ តែវាអ្នកមានរបួសពិការ ទើបប្រើខ្ញុំមកបរចាអញ្ជើញអ្នក
ទៅឲ្យបាន ដើម្បីនឹងរាប់អានសួរសុខទុក្ខពន្យល់ពីផ្លូវត្រូវនឹងខុស ខ្ញុំក៏
ពិគ្រោះឃើញថា អ្នកនៅក្នុងទីងងឹត ចូរប្រើរិះគិតទៅរកទីភ្លឺស្រឡះ

ទើបដឹងសេចក្តីសុខជាក់ច្បាស់តទៅ, ដែលខ្ញុំនាំសេចក្តីដ៏ជ្រៅឆ្ងាយខ្លួ-
លាយមកនិយាយនឹងអ្នកដូច្នេះ ក៏ព្រោះចិត្តស្រឡាញ់រាប់អាន អ្នកត្រូវ
តែគិតប្រមាណឲ្យសមនឹងអធ្យាស្រ័យចុះ ។

ស៊ីឡឹងបានស្តាប់ក៏សូប់សៀម ១ ស្របក់ហើយដកដង្ហើមធំរួចឆ្លើយថា
ខ្ញុំដែលមកផ្ញើខ្លួននៅនឹងអៀវហង, ហាន់សៀម ជាមនុស្សមានសតិបញ្ញា
តិចនេះ នឹងគិតការអ្វីក៏មិនសម្រេចទៅបាន តែចាំចិត្តព្រោះគិតឃើញ
ថា បានជានៅនឹងគ្នាមកយូរហើយ ចើនឹងដើរចាលសោះក៏មិនគួរ ។

ម៉ាន់ថងតបថា អ្នកមិនភ្លេចប្តូ? ពាក្យបុរាណថាខុតមក "បើសត្វ
នឹងធ្វើសំបុកជ្រកនៅ ក៏ត្រូវអាស្រ័យរកព្រៃស្តុក ទើបធ្វើសំបុកនៅជា
សុខបាន ទោះមានខ្យល់ព្យុះបក់បោកមកប៉ុន្មាន សំបុកនោះក៏មិនជ្រុះ
ធ្លាក់អន្តរាយ" ប្រការ ១ ទៀត ធម្មតាជាតិខាហានហើយ ត្រូវស្វែង
រកនាយចៅហ្វាយដែលជាមេទ័ពប្រកបដោយចិត្តធ្ងន់ល្អាយ រួសរាយរាប់
អានពួកក្រុមធំតូចមិនរើសមុខ ហើយចេះបត្តមន្ទុកបំរុងអ្នកនឿយហត់
នឹងចេះចាំស្តាត់ក្បួនពិជ័យសង្គ្រាម សូម្បីសត្រូវនឹងលើកមកប៉ងប្រមាថ
តិចច្រើនយ៉ាងណាក៏មិនរួញរាញើតកោតខ្លាច មានអំណាចនឹងការពារ
រក្សាសេនាខាហានមិនឲ្យអន្តរាយ បើអ្នកឯណាជួបនឹងនាយចៅហ្វាយ
ដ៏វិសេសដូច្នេះហើយ មិនបួលចៅផ្ញើខ្លួនផងគេគឺជាមនុស្សនោះគិតខុស
អំណោះតទៅមុខនឹងបានជួបតែទុក្ខ ពុំបានសុខក្សេមក្សាន្តឡើយ ។

ស៊ីឡង់ឮស្តាប់សព្វគ្រប់ហើយ ក្រោកលុតជង្គង់គំនាប់ម៉ាន់ថង់ ហើយថា អ្នកមានប្រសាសន៍ចាំងនេះខ្ញុំពេញចិត្តណាស់ បើដូច្នេះខ្ញុំនឹងទទួលធ្វើតាមពាក្យអ្នក ។ ម៉ាន់ថង់តបថា បើអ្នកនឹងជាប់ចិត្តគិតទៅធ្វើពាណិជ្ជកម្មជាមួយនឹងចូនូហើយ ចូរកាត់យកក្បាលអៀវហង់នឹងហាន់សៀមយកទៅធ្វើជាដំនូនចូនូចុះ ឈ្មោះអ្នកក៏នឹងបានគាប់ប្រសើរថ្លៃថ្លៃណាស់ ។ ស៊ីឡង់ឆ្លើយកាត់ថា ធម្មតាចាវព្រាវដែលបានទទួលទានជុំបាយរបស់នាយទៅហ្វាយរបស់ខ្លួនហើយ បើមិនពេញចិត្តគិតនឹងនៅតទៅទេ ក៏មិនត្រូវត្រឡប់ប្រទូសព៌ាយដល់នាយដែលឥតខុសវិញសោះ បើធ្វើដូច្នោះទុកជាមនុស្សខ្វៃស្តគុណអកតញ្ញូមិនល្អសោះ ដែលអ្នកឲ្យខ្ញុំធ្វើនោះ ខ្ញុំមិនយល់ព្រមតាមផងទេ ។ ម៉ាន់ថង់ឮហើយសរសើរថា ខ្លួនអ្នកពេញជាមនុស្សកតញ្ញូណាស់ ខ្ញុំនឹងបបួលយកតែខ្លួនអ្នកទៅនៅនឹងចូនូចុះ ។ រំលានោះស៊ីឡង់ក៏ប្រដែបរៀបចំរបស់ទ្រព្យប្រជាប់ខ្លួនគ្រប់ជួនអស់ហើយ ក៏នាំស្តីគ្រួកក្បួនប្រហែល ៣០ នាក់លបរត់ចេញពីសំណាក់នោះចូលទៅកន្លែងចូនូ កន្លងរំលាយប់ជាមួយនឹងម៉ាន់ថង់ ។ ឯអៀវហង់បានដំណឹងច្បាស់ជាស៊ីឡង់នាំស្តីគ្រួកក្បួនរត់ទៅចូលចូនូហើយ ក៏នឹកខឹងខ្លាំងណាស់លើកទាហាន ១ ពាន់តាមស៊ីឡង់ទៅកន្លងពេលយប់នោះ លុះទៅដល់កណ្តាលផ្លូវឃើញគំនរក្តឹងឆេះឡើងលើកំភ្លឺស្រឡះ ទទួលចូនូមើលច្បាស់ទៅឃើញអៀវហង់លើក

កងទ័ពចូលមក ចូឆូក៏លើកសេនាតាហានឡោមព័ទ្ធដុំវិញ ហើយ
ស្រែកប្រកាសថា យើងមកចាំនៅទីនេះតាំងពីព្រលប់ បើខ្លួនខ្លាំងពូកែ
កុំភយឡៅវិញ ។ អៀវហង៍ឃើញតាហានចូឆូឡោមព័ទ្ធដូច្នេះមិញ
ក៏ភ័យស្លុតរន្ធត់ស្មារតី ទឹងនាំតាហានរត់ទៅខាងណាក៏មិនរួចសោះ រំលេ
នេះទ្លួលហាន់សៀមលើកទ័ពតាមមកទៀត លុះឃើញកងទ័ពចូឆូឡោម
ព័ទ្ធអៀវហង៍នៅកណ្តាលដូច្នោះហើយ ហាន់សៀមក៏លើកពារ
ចំលាយចូលទៅឃកអៀវហង៍ចេញមកវិញបាន ។ ចូឆូឃើញដូច្នោះខំ
បរពលចូលចាក់កាប់សម្លាប់តាហានអៀវហង៍ស្លាប់ជាច្រើន ខ្លះដែល
រស់នៅក៏ចូលមកជាពួកក្រុមខាងចូឆូប្រហែល ២០០ ក្បាយ អៀវហង៍ទឹង
ហាន់សៀមឃើញថាទឹងតទល់ពុំបាន ក៏នាំតាហានដែលសល់នោះរត់
ទៅនៅទឹងអូនសុតឯខែត្រឡាំយ៉ុង ។

ចូឆូឈប់ទ័ពត្រឡប់មកទីដើមវិញ គ្រានោះម៉ាន់ថង់នាំខ្លួនស៊ីឡុង
ចូលទៅគំនាប់ចូឆូ ក្រឡេកឃើញម៉ាន់ថង់បានខ្លួនស៊ីឡុងមក ក៏ក្រោក
ទ្លួលស្រាកស្រួលរួសរាយឲ្យឃកមាសប្រាក់ទឹងសម្លៀកបំពាក់មកឲ្យជា
រង្វាន់ស៊ីឡុង ហើយតាំងឲ្យធ្វើជានាយតាហាន ។

ខណៈនោះ ចូឆូអញ្ជើញព្រះចៅហៀនតេស្តេចទៅដល់ស្រុកហ៊ូតា
ហើយរៀបសង់ជាទីព្រះពជកំង ឃ្លាំងដំណាក់តាមថ្នាក់របៀបត្រៀបត្រា
ព្រមទាំងទីក្រឡាព្រះគំនាល់ពជកេងរម្យដុំវិញព្រះពជកំង តាំងឲ្យដឹក

គួរបង្ហូរទឹកភ័ន្តជុំវិញ; ឯកំពែងនឹងសែនទោះមិញក៏លើកឲ្យខ្ពស់ស្រឡះ
នឹងគន់មើលយើញល្អណាស់គ្រប់ប្រាង្គប្រាសាទខាងក្នុង ព្រះចៅ-
ហៀនតេជ៍ឡើងគង់នៅក្នុងទីព្រះពដាំងក្រុងហ៊ូតោនោះ ហើយតាំង
ឲ្យតាំងស៊ុនទាំងនាហ្មឺន ៣០ នាក់ពេញទីជាសេនាបតី ។

ខណៈនោះ ចូធូក៏មានចិត្តកំរើកក្រៀវក្លា និយាយពដការពេញអំ-
ណាចគ្រប់មុខក្រសួងតួងតាំងខ្លួនឡើងជាមហាឧបពដធំ នាហ្មឺន
គ្រប់ក្រុមក៏នៅក្រោមបង្គាប់ស្តាប់ការ ។ ចូធូបានតាំងស៊ុនហុក, ស៊ុន
ស៊ីវ, គុយកែ, ឡៅហួ ទាំង ៤ នាក់នេះជានាហ្មឺនខាងរដ្ឋបាល;
តាំងម៉ាយ, ឡិកចោ, យិមដុន ៣ នាន់នេះជានាហ្មឺនខាងក្រសួងឃ្លាំង
នឹងដង្កែស្រូវ; ឆៀយ៉ុកជាចៅហ្វាយស្រុកតាំងប៉ែង អួនសេង នឹង
តាំងដៀវជាចៅហ្វាយស្រុកឡុកអៀង ម៉ាន់ថងជាចៅហ្វាយស្រុកហ៊ូតោ,
ហៃហ៊ូខុន, ហៃហួអៀន, ចោយិន, ចោហង ទាំង ៤ នាក់នេះជា
សេនាឯក; លីយ៉ាយ, លីខៀន, ង៉ាក់ជិន, អ៊ីកិម, ស៊ីឡុង ៥ នាក់នេះ
ជាសេនាចោ; ឡៅធូ, ខៀនអ៊ុយ ២ នាក់នេះជាសេនាត្រី; ចណ្តា
សេនាទាហានដែលមានថ្វីដៃខ្លាំងពូកែទាំងអស់នេះ សុទ្ធតែតាំងជានាហ្មឺន
មានបណ្តាស័ក្តិដូចគ្នា, ឯក្នុងក្រុងហ៊ូតោនោះ បើអ្នកឯណានឹងនិយាយ
ការពដការអ្វីៗ ក៏ត្រូវនាំសេចក្តីនោះមកប្តឹងចូធូជាមុន ទើបនាំគ្រាប
បង្គំទូលព្រះចៅហៀនតេជ្រាបជាក្រោយ ។ (មានត)

រឿងអាវក្សរថ្លែងរឿងម្ភៃប្រាំ

លោកសាង-សារីត លេខាធុការ ក្រសួងបរិវត្តិ

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(តមក)

រឿងទី ៦

អាវក្សនិយាយដូច្នេះថា: "នុមហាភដ! មានទីក្រុងមួយ ឈ្មោះក្រុងធម្មបុរៈ (Dharmpur) ឯព្រះចៅផែលគ្រងរាជ្យនៅក្រុងនេះ ព្រះនាមព្រះបាទធម្មសីល (Dharmshil) ស្តេចទ្រង់មានកុង្ស៊ីយ៍មួយនាក់ ឈ្មោះអន្ធក: (Andhak) ។ ថ្ងៃមួយនោះ លោកកុង្ស៊ីយ៍ក្រាបបង្គំទូលព្រះអង្គថា: "សូមទ្រង់ព្រះចម្រើនព្រះជន្មាយុ! សូមស្តេចទ្រង់សាងព្រះវិហារមួយថ្វាយទៅព្រះនាងទេវី ហើយសូមព្រះអង្គស្តេចយាងទៅចម្រើនធម៌ក្នុងព្រះវិហារនោះដរាបផង ព្រោះក្នុងសាស្ត្រា (câstras) មានចារថា កិច្ចប្រកបដោយធម៌នេះ ជាកិច្ចប្រពៃណាស់" ។ ព្រះករុណាក៏ទ្រង់គាស់បង្គាប់ឲ្យគេសង់ព្រះវិហារមួយ ហើយព្រះអង្គថ្វាយទៅព្រះនាងទេវី រួចស្តេចបានបំពេញការណ៍យកិច្ចរបស់ព្រះអង្គខាងសាសនា ក្នុងព្រះវិហារនោះ តាមបែបបញ្ញត្តិរបស់គម្ពីរ ។ មុនសូត្រធម៌ ព្រះអង្គគ្មានសោយអ្វីទេ ទោះបីទឹកក៏ទ្រង់មិនសោយដែរ ។ លុះព្រះអង្គទ្រង់ប្រព្រឹត្តតែយ៉ាងនោះ ជាន់បន្តិចមក ថ្ងៃមួយលោកកុង្ស៊ីយ៍ក្រាបបង្គំទូល

ព្រះអង្គថា: "សូមទ្រង់ព្រះចម្រើនជាច! មានភាសិតមួយដែលគេស្គាល់គ្រប់គ្នានិយាយថា ផ្ទះរបស់មនុស្សម្នាក់ៗ ដែលគ្មានបុត្រសង្សារផ្ទះនោះជាវាលទេស្មាត, បញ្ញារបស់មនុស្សត្រីរ៉ៃ ក៏ជាវាលទេ, ឯវត្ថុតាំងឡាយរបស់មនុស្សក្រក៏ជាវាលទេដែរ" ។

លុះស្តេចទ្រង់ព្រះសណ្តាប់ពាក្យអស់នោះ ព្រះអង្គយាងទៅកន្លែងព្រះវិហារព្រះនាងទេវី ហើយបង្ហែមព្រះហត្ថា តាំងបន់ស្រន់ឡើងថា: "នុព្រះនាងទេវីអើយ! ព្រះនាងដែលបានបំរើ វិស្ណុ (Vishnu) រុទ្រ (Rudra) នឹងឥន្ទ្រា (Indra) អស់ចំនួនច្រើនពីរទៀវតីនោះ ព្រះនាងដែលបានផ្តាញ់មារតាំងឡាយគឺ មហិសាសុរ (mahishasur) ចន្ឌ-មុន្ឌ (chand mund និង រក្តពីជ (Raktahji) នោះ ព្រះនាងទ្រង់បានរំងាប់ទុក្ខសោកតាំងពួងដែលនៅកន្លែងកពលោកនេះ ហើយព្រះនាងតែងតែមកជួយសង្គ្រោះដល់ជនជំនិតរបស់ព្រះនាងដែលមានទុក្ខនោះ ខ្ញុំមកនុនកាយ នៅលើដណ្តើរវិហាររបស់ព្រះនាងហើយ ដោយមានចិញ្ចឹមចិត្តសង្ឃឹមយ៉ាងខ្លាំងបំផុត – សូមលោកជួយធ្វើឲ្យបំណងរបស់ខ្ញុំបានសម្រេចផង" ។

កាលណាព្រះកុណាជាម្ចាស់ដីវិតលើតួង ទ្រង់បន់ស្រន់រួចស្រេចសំឡេងមួយលាន់ឮឡើងអំពីព្រះវិហារនោះទេវី ។ សំឡេងនោះនិយាយថា: "នុមហាភាជ! យើងសប្បាយចិត្តនឹងអ្នកណាស់, ចូរអ្នកសុំអ្វីតាមចិត្តអ្នកចុះថ្នាក់ទៅមើល?" ។

ព្រះពាជាទ្រង់មានព្រះពាជឫទ្ធារទៀតថា: សូមព្រះនាងជាមាតាជាប! ដ្បិតព្រះនាងតេញចិត្តនឹងទូលបង្គំជាខ្ញុំហើយ សូមជួយឲ្យខ្ញុំមានព្រះពាជបុត្រាមួយអង្គផង" ។

ព្រះនាងទេវីតូយឡើងថា: "មហាពាជ! ស្តេចនឹងមានព្រះពាជបុត្រមួយយ៉ាងពូកែ ដែលមានឈ្មោះល្បីល្បាញបំផុត" ។ ក្រោយមកព្រះមហាក្សត្រិយ៍ ទ្រង់ថ្វាយដង្វាយដែលមានឈើក្រអូប ថ្វាយផ្កាទឹកអប់នឹងម្ហូបផ្សេងៗ ឯទៀត រួចព្រះអង្គទ្រង់បន់ ។ ព្រះអង្គយាងមកបន់យ៉ាងដូច្នោះតែពាល់ថ្ងៃ ។

កន្ទុងច្រើនខែពាត្រីក្រោយមក ព្រះពាជបុត្រាមួយអង្គ ក៏ចាប់បដិសន្ធិកើតឡើង ។ ឯព្រះចៅធម្មសីល ស្តេចទ្រង់នាំព្រះពាជវង្សានុវង្ស ប្រកបដោយក្តៅនឹងល្បែងកំសាន្តគ្រប់យ៉ាង ទៅលាបំណន់ដល់ព្រះនាងទេវី ។

មានមួយថ្ងៃនោះ អ្នកបោកខោអាវម្នាក់ ដែលមកអំពីទីក្រុងជិតខាង បានដើរតម្រង់ទៅទីក្រុងនោះ ជាមួយមិត្តសំឡាញ់របស់ខ្លួនម្នាក់។ លុះកាលណាបានឃើញព្រះវិហាររបស់ព្រះនាងទេវី បុរសក៏ចូលទៅថ្វាយបង្គំព្រះ ។ ក្នុងពេលនោះ បុរសបានឃើញ កូនស្រីរបស់អ្នកបោកខោអាវម្នាក់ទៀត ដែលមានរូបឆោមល្អចំណាប់ ។ លុះបានឃើញនាង បុរសក្តីកក្តាំងស្មារតី រួចបានដើរចូលទៅកាន់ព្រះវិហារកាន់ពេលនោះដែរ ក៏ចូលទៅលុតជង្គង់សំពះដល់ទេពធីតានឹកយ៉ាងដូច្នេះ

"នុទេពធីតា! បើដោយអានុភាពរបស់ព្រះនាង ខ្ញុំបានរៀបការជាមួយស្ត្រីដ៏ល្អឆើតឆាយនេះ ខ្ញុំសូមថ្វាយសិរសារបស់ខ្ញុំ" ។ លុះបានសន្យាយ៉ាងទន្ទឹកដូច្នោះហើយ អ្នកសំពះរួចធ្វើដំណើរទៅកាន់ទីក្រុងជាមួយមិត្តរបស់អ្នកទៅ ។ ប៉ុន្តែ លុះបានទៅដល់ទីក្រុងនេះអ្នកកើតទុក្ខយ៉ាងធ្ងន់ ដោយសារឃ្លាតបែកអំពីនាង បណ្តាលឲ្យអ្នកខានដេក ខានផឹក ខានបរិភោគអាហារ ។ កន្លងចំនួនប្រាំបីយប់ប្រាំបីថ្ងៃ អ្នកនឹកដល់នាង ឯមិត្តរបស់អ្នក ដែលជាសាក្សីនៃព្រៃងំសំណាងកំសត់នេះ បានឱនក្បាលយំប់រឿងនេះ ប្រាប់ឪពុករបស់អ្នកគ្មានសល់ ។ លុះបានឮដូច្នោះ ឪពុករបស់អ្នកនេះ ព្រួយចិត្តជាខ្លាំង រួចគាំងគិតថា: "ដោយឃើញភាព ដែលវាលិចលង់នេះ បើវាមិនបាននាំនោះទេ ប្រាកដជាវាស្លាប់មិនខាន, អញត្រូវតែរៀបការឲ្យវាទៅ, គឺមានតែមធ្យោបាយមួយនេះទេ ដែលអាចជួយស្រោចស្រង់ជីវិតវា" ។

លុះគិតដូច្នោះ គាត់ទៅកន្លែងកូមិ ដែលឪពុករបស់នារីនៅនោះ ដោយមានកូនប្រុសរបស់គាត់ជូនទៅផង ហើយនិយាយទៅកាន់ឪពុករបស់នាងថា: "ខ្ញុំមានកិច្ចសូរលោកបន្តិច សូមលោកយល់ព្រម រួចខ្ញុំនឹងជំរាបជូនក្រោយ" ។

– បើសិនណាវាត្រូវដែលលោកសុំខ្ញុំនោះ ទៅកន្លែងអំណាចរបស់ខ្ញុំ ខ្ញុំជូនបាន មានប្រសាសន៍មកចុះ ។

លុះបានឮលពាក្យសន្យានេះស្រេចកាលណា គាត់ក៏សុំយុវតីឲ្យមកកូនរបស់ខ្លួន ។ ឯឪពុករបស់នាងក៏យល់ព្រម ហើយបានហៅព្រាហ្មណ៍ម្នាក់មក ព្រាហ្មណ៍នោះទាយតាមផ្កាយ កំណត់ពេលវេលាល្អរួចនិយាយថា: "ចូរនាំកូនប្រុសរបស់លោកមក រួចខ្ញុំនឹងជូនកូនស្រីរបស់ខ្ញុំ" ។

ដល់បានឮពាក្យនេះហើយ គាត់ក្រោកឡើង ត្រឡប់ទៅផ្ទះនៃខ្លួនវិញ ។ លុះកាលណាបានរៀបចំគ្រឿងប្រដាប់សម្រាប់អាពាហ៍ពិពាហ៍រួចស្រេចហើយ គាត់វិលមករៀបអាពាហ៍ពិពាហ៍កូននោះ រួចហើយត្រឡប់ទៅផ្ទះវិញ ដោយបាននាំកូនប្រុសនឹងកូនប្រសារស្រីរបស់គាត់ទៅជាមួយផង ហើយជនទាំងអស់នេះក៏បានរស់នៅដោយសេចក្តីសប្បាយរីករាយតទៅ ។

កន្លងក្រោយពីនោះបន្តិចមក មានព្រឹត្តិការណ៍យ៉ាងក្សេមក្សាន្តមួយក្នុងគេហដ្ឋានរបស់ឪពុកនាងជាកសិយា គេបានអញ្ជើញជនទាំងអស់គ្នាមកផ្ទះឪពុករបស់នាងនោះ ។ ដល់រៀបចំគ្រឿងប្រដាប់ប្រដារសព្វគ្រប់ហើយ ជនទាំងអស់នេះបានទៅដល់ជិតទីក្រុងព្រះវិហារនៃព្រះនាងខេមី ក៏លេចឡើង ពីមុខអ្នកទាំងអស់ ឯកូនប្រុសរបស់អ្នកបោកខោអាវ ក៏ទឹកឃើញបំណន់ ដែលខ្លួនបានធ្លាហើយ រួចនឹកក្នុងចិត្តថា: "អញគ្មានគុណធម៌ទេ, ហើយអញមិនមែនស្មោះចំពោះសោះ ព្រោះអញបានថ្វាយកិច្ចសន្ទនកុហកមួយទៅព្រះនាងខេមី" ។ លុះគិតឃើញ

ដូច្នោះ អ្នកនិយាយទៅមិត្តរបស់អ្នកទាំងអស់ថា: "នៅហ្នឹងហើយ? ខ្ញុំទៅថ្វាយបង្គំព្រះនាងទើសិន រួចខ្ញុំត្រឡប់មកវិញឥឡូវនេះ" ។ អ្នកនិយាយផ្តាំផ្ញើទៅកាយរបស់អ្នកដូច្នោះទៀត រួចដល់ទ្វីតទឹកក្នុងស្រះក្បែរព្រះវិហាររួចកាលណា អ្នកទៅដល់ពីមុខព្រះនាងទើ ទុបដៃរួចសំពះ ។ អ្នកហួតជារបស់អ្នកចេញ អារបំពង់កខ្លួនឯង ឯក្បាលរបស់អ្នក ក៏ជាប់អំពីជង្គង់ខ្លួនមួយរំពេច ហើយធ្លាក់ដល់ដី ។...

ចំណែកខាងមិត្តរបស់អ្នក ដោយចាំយូរពេកមិនឃើញត្រឡប់មកវិញ ក៏សម្រេចថាទៅមើល តើមានរឿងហេតុអ្វី ហើយនិយាយទៅនាងស្តីថា: "នៅហ្នឹងហើយ ខ្ញុំទៅរកគាត់ រួចនាំគាត់មកវិញ" ។ បុរសក៏ដើរចេញទៅបានចូលក្នុងព្រះវិហារ ស្រាប់តែក្អាក់ ដោយបានឃើញក្បាលមិត្តរបស់ខ្លួន ជាប់អំពីកងកាយនៅលើព្រះធរណី ។ ដល់ឃើញដូច្នោះ អ្នកគិតថា: "កពលោកយើងនេះជាចំណងមួយពេញដោយសេចក្តីលំបាក ។ គ្មានអ្នកណាមួយដឹងថាខ្លួនថ្វាយសិរសារបស់ខ្លួនដល់ទើរឡើយ ។ ប៉ុន្តែ គេមុខជានិយាយថា: អញបានសម្លាប់មិត្តរបស់អញ ដើម្បីយកតង្វាយដែលល្អចំណាប់នេះមិនខាន ។ ស្ងាប់ទៅវិញល្អជាជាងមានក្តៅឈ្នោះអាក្រក់ក្នុងស្ថានកណ្តាលនេះ" ។ លុះនិយាយដូច្នោះហើយ អ្នកចុះទៅលុបលាងកាយ រួចចូលទៅនៅពីមុខទេពធីតា សំពះព្រះនាង ហើយសូត្រធម៌ ។ រួចអ្នកទាញជារបស់អ្នកមកកាត់ក្បាលខ្លួនឯងទៅ... ។

ចំណែកខាងនាងស្តី ចាំមើលផ្លូវដកបង ។ ដោយតឹងខ្លួនផងដោយធុញទំនឹងឃ្លាំមើលផ្លូវផង ដោយអស់សង្ឃឹមថាបានចួបប្តីរបស់នាងវិញផង នាងក៏ដើរទៅរក ដល់ចូលទៅក្នុងព្រះវិហារ នាងត្រឹអស់អង្គកាយដោយបានឃើញខ្មោចតាំងពីរសន្ធឹងនៅលើដី ។ កាលណាឃើញខ្មោចនេះរួច នាងគិតហើយនិយាយថា "អ្នកតាំងពួងមិនជឿថា បុគ្គលតាំងពីរបានធ្វើពលីកម្មថ្វាយដីវិតដល់ព្រះនាងទេវីនោះទេ ប្រាកដជាគេនិយាយថាស្រីមេម៉ាយតិរ្ថិយនេះ បានធ្វើឃាតកម្មដល់ជនតាំងពីរមិនខាន ដោយប្រាថ្នាចង់ធ្វើអាក្រក់ដល់ជននោះ ។ ដូច្នេះអញគួរស្វាប់ទៅល្អជាជាងមានកេរ្តិ៍ឈ្មោះបែបនោះ" ។

លុះគិតដូច្នោះហើយ នាងទៅសំពះព័ទ្ធទេពធីតា កាលណានាងទៅលុបលាងខ្លួនរួច លើកជាវបំរុងនឹងសម្លាប់ខ្លួនឯង ស្រាប់តែព្រះនាងទេវីចុះពីលើស្មៅច្បងមក ចាប់ដៃនាងជាប់ ហើយនិយាយថា: "កូនស្រីសម្លាញ់? ចូរឯងសុំអនុគ្រោះមួយអំពើយើងចុះ ព្រោះយើងពេញចិត្តនឹងឯងណាស់" ។

នាងឆ្លើយទូលទៅព្រះនាងទេវីថា: "ទ្រង់ព្រះមេតាទូលព្រះបង្គំអើយ! បើព្រះអង្គពេញព្រះពជហឫទ័យនឹងទូលព្រះបង្គំជាកូនហើយ សូមព្រះអង្គប្រោសជនតាំងពីរនេះឲ្យរស់ឡើងវិញ" ។

នាងទេពធីតា បង្គាប់ឲ្យនាងយកក្បាលទៅដាក់លើដងអង្គកាយវៀងវាល់រូបវិញ ។ នាងអរឥន្ទត់ខ្លាំងពេក ទៅជាវិលតំនិតអស់ នាំ

ឲ្យនាងច្រឡំហើយ ដាក់ក្បាលមិនត្រឹមត្រូវទៅលើរូបវិញ ។ ឯព្រះនាងទៅវិ ដល់យកទឹកអប់ច្រោះទៅដនតាំងពីមានដីរិតក្រោកឡើងហើយតាំងប្រឈ្មោះគ្នា ។ ម្នាក់ៗ និយាយថា: "នាងជាប្រពន្ធអញ នាងជាប្រពន្ធអញ" ។

លុះនិទានដូច្នោះហើយ អាវក្យក្រាបបង្គំទូលសួរថា: "នុមហាភជ! តើអ្នកណាជាប្តីរបស់នាង ក្នុងបណ្តាជនទាំងពីរនេះ" ។

ឯព្រះចៅទ្រង់មានព្រះរាជឫង្ការតបវិញថា: "ចូរឯងស្តាប់? គម្ពីរមានចារថា ទន្ទេគង្គា (gange) ធំជាងទន្ទេទាំងអស់, គីរីឈ្មោះសុមេរុ (sumêru) ជាគីរីថ្កុំថ្កាជាងគីរីទាំងអស់, ដើមកប្បព្រឹក្ស (kalpaVrish) ឈ្មោះដើមឈើមួយដែលនៅស្ថានព្រះឥន្ទ ហើយមានអំណាចអាចឲ្យមនុស្សដែលចង់បានអ្វីបានទាំងអស់, ជាដើមឈើលេខមួយ ក្នុងបណ្តាដើមឈើទាំងអស់ ឯក្បាលជាអាវៈយវៈមួយដែលមានប្រយោជន៍ជាងអាវយវៈទាំងអស់ ។ ហេតុដូច្នេះនាងនោះ ជាប្រពន្ធរបស់បុរសដែលមានក្បាលរបស់ប្តីនាង" ។

លុះឮព្រះរាជឫង្ការដូច្នោះ អាវក្យត្រឡប់ទៅឮរខ្ជួនទៅលើដើមឈើ។ ឯមហាក្យត្រិយ៍ ស្តេចទ្រង់ថយទៅយកមកវិញ ចង់អាវក្យនោះហើយលើកអាវក្យដាក់លើអង្សា ហើយយាងទៅ ។

ចប់រឿងទី ៦, នៅមានរឿងទី ៧ តទៅទៀត ។

ឈុតទី ២ ឆាកទី ១

វណ្ណ៍តារា - វណ្ណ៍នារី - ភាណវិទ្ធិ

វណ្ណ៍តារា

សេចក្តីក្សាហានចិត្តមុតថ្លា អាចសម្រែចការគ្រប់ដំពូក
សម្រាប់ជិះធ្នង់ដូចជាទូក ចែវចូកទៅកាន់គ្រែយនាយបាន ។
ជាតិនេះកើតមកខ្លួនជាស្រី ក្រាថ្នាតែប្តីចិត្តក្សាហាន
ឱ! ទេវតាអើយជួយឲ្យបាន រួមក្រាណាដូចចិត្តខ្ញុំប៉ុនប៉ង ។
សូមព្រះវត្តគ្រែយបីប្រការ សម្រែចផលាខ្ញុំបំណង
បានប្តីក្សាហានខ្ញុំឥតហ្មង ខ្ញុំផ្សង់សច្ចាសូមសម្រែច ។

(វណ្ណ៍នារីចេញ)

ឱ! នាងវណ្ណ៍នារីអូនពីរបី អូនចង់បានប្តីយ៉ាងដូចម្តេច?
សូមនាងក្រាប់បងឲ្យដឹងកិច្ច បងជួយសម្រែចដូចក្រាថ្នា ។

វណ្ណ៍នារី

រូបកាយនៃមនុស្សខុសគ្នាច្បាស់ មារយាទថ្នាស់ចិត្តចិត្តា

ខ្ញុំសូមដំកបបង់វណ្ណ៍តារា　　បងខ្ញុំហើយណា ! ទើបហ៊ានច្រាប់ ។
សូមបង់ច្រណែអត័យទោស　　បើចិត្តខ្ញុំឧុសឥសូរស័ព្ទ
ភ្លាមៗបងខ្ញុំបានស្តាប់　　សូមបងកុំចាប់ច្រកាន់ខឹង ។

វណ្ណ៍តារា

និយាយទៅចុះមិនថាអ្វី !　　វណ្ណ៍នារីអូនស្រីសួនព្រលឹង
ថ្ងៃងងឹតចុះឲ្យបង់ដឹង　　បងមិនខឹងទេណាប្អូនស្រី ! ។

វណ្ណ៍តារី

បងមិនគួរថ្ងៃជាវាចា　　ខ្ញុំសូមអស់ទៅតាកតាំងបី
ស្រីដ៏ខ្ញុំគ្នាគិតរកប្តី　　គួរអើ ! ខ្ញុំនៅសែនចំបែង ។
កិច្ចការរៀនសូត្រធ្វើត្រង់ឆើយ　　កន្តើយមកគិតឯគ្រឿងលេង
តណ្ហាសម្រើបចិត្តជនក្មេង　　សង្រែងរូបកាយដោយស្នេហា ។

វណ្ណ៍តារា

នែ ! ប្អូនកុំគិតទៅរែងឆ្ងាយ　　គិតក្តីរៀងអាយនេះសិនណា
ឯកាមភគនឹងតណ្ហា　　មនុស្សក្នុងលោកាមានគ្រប់ថ្នាក់ ។
ចំរៀន ចំសូត្រ ចំធ្វើការ　　បំពេញតណ្ហានឹងភគៈ
ត្រង់នេះសូមប្អូនដឿឲ្យជាក់　　កំឡាំងភគៈរបស់បង ។

វណ្ណ៍តារី

ភគៈ ឬកាមនឹងតណ្ហា　　គ្មានអ្វីអស្ចារ្យខ្លួរបំណង

តើជាចិត្តហើយដែលចម្បង ចំណងអ្វីៗធំពុំស្មើ ។

វិណ្ណ៌តារា

ចិត្តធំជាងខ្លួនឬរូបកាយ វណ្ណ៌នារីនោមនាយច្រាបមកមើល៍
តើប្តីដូចម្តេចដែលច្រៀសវៀរ នាងស្មើច្រាបមកកុំខ្លាសអ្វី ! ។
ខានម៉ាក់មិននៅស្រួលនិយាយ

វិណ្ណ៌តារី

បងអើយចិត្តខ្ញុំស្រឡាញ់ប្តី

ដែលភាពល្អល្អះខន់សំដី និយាយអ្វីពាក្យផ្អែមល្ហែមគួរស្នេហ៍ ។
ទាំងឫកកិរិយាក៏សុភាព ភបទាប់សមឫកជាកូនខ្មែរ
ស្លូតត្រង់ត្រឹមត្រូវឥតបែកបែរ គ្មានគ្នេរក្បាសឮសេចក្តី ។

វិណ្ណ៌តារា

វណ្ណ៌នារីអូនឯងនៅគ្រាយណាស់ មិនទាន់យល់ច្បាស់ស៊ីវិល្ហៃ
គេលែងយកហើយភាពបែបប្តី ដែលឯងស្រដីមកនេះណា ។

វិណ្ណ៌តារី

ស៊ីវិល្ហៃ ! ស៊ីវិល្ហៃតែបងចុះ ! មិនឃើញកំឡោះហើយស្នេហា
ប្រុសត្រៃលក្បាច់កាចចិត្តហានក្លា មិនមានត្រូវការមេត្រីឡើយ ។
ក្លាហានចិត្តមុតឥតមានស្នេហ៍ ! មិនបែរមើលមុខមិនកៀកកើយ
មិនត្រែកត្រអាលខ្លាចបក់ចើយ កៀកកើយជាប្តីនាំទុក្ខធំ ។ (ចេញមួយ។)

វណ្ណតារា

ប្តីចិត្តក្លាហានមិនខ្លាចស្លាប់ គឺជាគូគាប់របស់ខ្ញុំ
នាងអើយចិត្តឯងនៅច្រឡំ តិចយំ! ខ្លះ! ប្តីចិត្តអាចារ្យ ។

ភាណារិទ្ធិ

អ្នកនាង! ម៉ាក់នាងនៅឬទេ? (គោះទ្វារ)

វណ្ណតារា

អ្នកមិននៅទេ អ្នកមានការ
អញ្ជើញជូនមាខ្ញុំទៅផ្សារ តើលោកមានការជួចម្តេចនែ! ។

ភាណារិទ្ធិ

ឧ! នារីស្រីស្រស់ឆោមឆាយ ចិត្តខ្ញុំសប្បាយក្នុងសំដី
នាងថ្លៃឯកាលណាគួរពិសម័យ អាល័យស្រឡាញ់កាន់តែខ្លាំង ។

វណ្ណតារា

លោកមានសេចក្តីស្នេហ៍ស្នេហា នឹងនាងវណ្ណតារាពេញកំឡាំង?

ភាណារិទ្ធិ

វិញ្ញាណផងបងតែងកាន់កាំង... ក្លេចភ្លាំងគិតដល់តែនាងថ្លៃ ។

វណ្ណតារា

បងស្រឡាញ់ ខ្ញុំឥតបើដឹង ប៉ុណ្ណឹងចិត្តខ្ញុំឥតសង្ស័យ
បើបងក្លាហានចិត្តសម័យ សូមបងលួកលៃជួយខ្ញុំផង! ។

ភាណារិទ្ធិ

ធនអ្វីមិនស្មើធនស្រីស្រេច (សប្បាយ) អាចរុករានដើរឥតសៅហ្មង
វណ្ណៈតារកអូនអើយសូមច្រាបបង សម្រេចបំណងដូនប្អូនបាន! ។

វណ្ណៈតារា

បង! ខ្ញុំមានទុក្ខធំអនេក ទ្រូងខ្ញុំស្ទើរបែកចិត្តរំខាន
ឥតុកខ្ញុំ វៀតមិញចាប់បាន ទៅឃុំឃាំងច្បាណានឹងច្របហារ ។
សូមបងអញ្ជើញទៅធ្វើសឹក សង្គ្រាមពន្ធឹកដោះយកចា"!...
ឲ្យរួចពីដៃយួនមោហា វណ្ណៈតាខ្ញុំត្រមជាគូគាប់! ។
អញ្ជើញទៅអ្នកច្រុសច្របសើរ

ភាណារិទ្ធិ (ត្រវីក្បាល)

ប្អូនអើយនាងប្រើបងឲ្យស្ងាប់
ចុះបើបងទៅយួនវាចាប់ សម្លាប់បងចោលក្រយដីវ៉ា" ។
ខានរួមស្នេហានឹងប្អូនស្រី នាងនឹងយកប្តីមួយទៀតណា
បើបងទៅស្ងាប់បង់អាសា គ្មាននរណាមួយនឹងឈឺឆ្អាល ។

វណ្ណៈតារា

អញ្ជើញទៅចុះកុំខ្លាចស្ងាប់ បើយួនវាចាប់ខ្ញុំគាក្បាល
កាន់ទុក្ខឲ្យបងឲ្យអស់កាល បំណាច់ត្រអាលនឹងរូបខ្ញុំ ។

ភាណវិទ្ធិ (ឈរដង្ហឹង)

បងមិនហានទៅទេប្អូនស្រី　　សឹកសង្គ្រាមដ៏យកចម្បាំងធំ
បងមិនទៅទេនាងក្រមុំ　　កុំច្រៀកែវបងឲ្យទៅស្ងាប់ ។

វណ្ណ៌តារា

កើតមកជាមនុស្សមិនត្រូវញ៉ាក　　ខោះក្រលំបាកវេរ្យញាតិអាប់
សូមអ្នកចាកចេញទៅឲ្យឆាប់!　　តិចខ្ញុំបង្អាប់ខ្លាសទេពតា ។

ភាណវិទ្ធិ (លុតដង្គង់អង្វរបើបបាតដៃ)

អ្នកនាងខ្ញុំសូមអង្វរចិត្ត　　សូមប្អូនអាណិតចិត្តស្នេហា
បងស្រឡាញ់ស្គមអស់កាយា　　វណ្ណ៌តារា! អ្នកស្រីថ្នើមដ៏វិត ។
សេចក្តីរៀនសូត្រកំអាក់ខាន　　អាហារមិនបានបម្សៅចិត្ត
ស្រឡាញ់ប្អូនស្រីបណ្តាលចិត្ត　　យប់បងគេងគិតមិនលក់ទេ ។
សូមនាងមេត្តាសង្ឃឹមបង　　ស្រស់កែវខ្ចូនល្អងគិតគាន់គ្នេរ
គឺប្រុអូនហើយល្អលើសគេ　　ធ្វើឲ្យបងគ្នេរសែនស្រឡាញ់ ។

ឈុតទី ២ ជាកទី ២

វណ្ណ៌តារា-ជលនារី-ភាណោនរ

ជលនារី

អ្នកបង! បងវណ្ណ៌នារីទៅទេ?　　ខ្ញុំមករៀនដើរ ទឹងអ្នកបង!
រៀនប៉ាក់ជរជ្ជាជាកម្រែង　　យ៉ាងល្អឥតគ្នងណាបងអើយ ។

វណ្ណ៌តារា

វណ្ណ៌នារី នៅហ្នឹង ! អម្បាញ់មិញ ឥឡូវគេចេញទៅណាហើយ
ឬនចាំមួយភ្លែតមិនយូរឡើយ បងទៅណាហើយកែវបណ្តូល ។

ភាណាឆរា (ចូលតប់ទ្វារ)

អ្នកនាង៍ អ្នកនាង៍វណ្ណ៌តារា

វណ្ណ៌តារា

នរណា ! នរណា ! អញ្ជើញចូល
ឃើបងគាណានពាសាច់ត្រសូល... មុខមូលម្តេចស្គមយ៉ាងនេះណា ?... ។

ភាណាឆរា

នាង៍មិនជ្រាបទេកិច្ចសង្គ្រាម យកឈាមទៅក្រាលផែនពសុធា
ការពារក្តីសុខកងភាព កម្ពុជាសព្វថ្ងៃតើយ៉ាងណា ។
កាលដែលពីរឿងទៅតស៊ូ យកជីវិតប្អូរសងរដ្ឋា
ជាមួយនឹងខ្មាំងគឺបច្ចា- មិត្រយួនមោហាអង់អាចក្រៃ ។
ពាចាប់សម្លាប់ជនជាតិខ្មែរ នៅឯលំដែនបែកខាងវៀត-
វែង ! ដែនខ្មែរខ្លាំងលើសលប់ក្រៃ តអស់ពាក្យបើអស្ចារ្យ ។
ហាលក្បែងហាលខ្យល់ឥតមានឈប់ ថ្ងៃបីគំរប់នឹងបច្ចា-
មិត្រថយក្រោយវិញ ! ចាប់ប្រហារ ជាតិខ្មែរនានានៅលំដែន ។

ឱ! សែនវេទនាពេញអស្ចារ្យ ដុតផ្ទះគេហាឥតសល់សែន
ខ្មែរនៅលើដែនវេទនាមែន ខ្ញុំសែនជាទុក្ខក្នែករហាម ។

វណ្ណគារា

រូបខ្ញុំជាស្រីធ្វើម្តេចម្តា នឹងបានធ្វើការខាងសង្គ្រាម
ជួយធ្វើការបងនឹងសងឈាម ទន្ទ្រានចូលលុកឥតភ័យកិត ។
កងទ័ពជាពលប្រសើរថ្លៃ ជាតិខ្មែរទាំងថ្លៃគួរប្រឹងគិត
ចូលធ្វើតាហានថ្លៃនៅចិត្ត ប្រយុទ្ធប្រឹងប្រែតយ៉ាងពេញទី ។

ភាណាឆរា

រូបនាងជាស្រីទំធ្វើការ នៅកងរង្គាឲ្យសួស្តី
ទុកឲ្យបងរក្សាផែនដី ខ្លួននាងជាស្រីទំធ្វើការ ។ (ញញឹមសួរទៅឆរាប)

វណ្ណគារា

បង! ហើយថ្ងៃមុជីវិតខ្ញុំ (ផលានាំអៀនតំបូលក្នុង)

(មានត)

រឿងប៉ាល់ធីតាស៊ីនី

លោកធើង-ជ្រើសស្ត្រាបារ្យ នៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែរៀបរៀង

(តមក)

នៅកន្លែងនុ៎ះ ទទួលមានស្រីមេម៉ាយម្នាក់ទៀត អាស្រ័យនៅប្រហែលមួយឆ្នាំមកហើយ ។ នាងនេះឈ្មោះម៉ារីតឹត ។ កាលពីដើម ខ្លួននាងជាស្រីអ្នកស្រែ នៅស្រុកព្រីតាញ ។ មានកូដូម៉ីក៏ម្នាក់ចង់បាននាង បុរុងនឹងរៀបការយកធ្វើជាភរិយាត្រឹមត្រូវ ។ តែខាងក្រោយដែលបានប៉ះពាល់ដល់ខ្លួនប្រាណគ្នានឹងគ្នាវេលាណា គេក៏រត់ចោលនាងបាត់ទៅ មិនគិតដល់នាងមានកូនក្នុងពោះ ។ នាងខ្មាសគេក៏រត់ចោលស្រុកអាត្មាមកនៅកន្លែងនេះហ្នឹងជាមួយនឹងពួងប្រុសម្នាក់ ។ នាងឡាតួរដើរតាមខ្ញុំស្រីៗ ។ បានប្រទះឃើញនាងម៉ារីតឹត កំពុងចំហៀកូន, នាងឡាតួរសប្បាយចិត្តនឹងបានជួបស្ត្រីដែលមានវាសនាដូចខ្លួន ។ នាងនិយាយដំណើរដើមទង់ នឹងសេចក្តីត្រូវការនៃខ្លួនប្រាប់ដល់នាងម៉ារីតឹត ។ បានស្តាប់រឿងសព្វគ្រប់ហើយ នាងនេះមានសេចក្តីមេត្តាដល់នាងឡាតួរពន់ពេក ។ ដោយសេចក្តីខ្វល់ខ្វាយចិត្តនឹងសេចក្តីស្នេហានាងម៉ារីតឹត និយាយរឿងរបស់ខ្លួនប្រាប់ដល់នាងអាគន្តុកាថា: "ខ្ញុំដែលលំបាកយ៉ាងនេះ គឺសមនឹងពុតរបស់ខ្ញុំ តែចំណែកខាងអ្នកដែលជាមនុស្សត្រឹមត្រូវ មិនគួរឡើយមកសមមានទុក្ខយ៉ាងដូច្នេះសោះ" ។

នាងម៉ារគឺរតែសុំនាងឡាត្តរធ្វើជាសំឡាញ់ រួមសុខរួមទុក្ខជាមួយគ្នា ។ នាងនេះត្រែកអរពន់ពេកទើបលាន់មាត់ថា "ព្រះជាម្ចាស់ឲ្យខ្ញុំដូតពីសេចក្តីទុក្ខត្រឹមហ្នឹងហើយ ឃ្លានជាបណ្តាលអ្នកជាមនុស្សដែរទៃសោះ ឲ្យមានចិត្តល្អ ចិត្តមេត្រីដល់ខ្ញុំឯងដែលកំពុងមានទុក្ខពេញខ្លួន ។

ពិតមែនជាខ្ញុំ (តាថាស់) នៅឆ្ងាយពីទីនេះប្រហែលជាងថ្ងៃមួយគ្រឹមែត្រ នៅខាងត្រើយភ្នំឡងឯណោះ ខ្ញុំក៏ស្គាល់នាងម៉ារគឺរតែដែរ ហើយខ្ញុំទុក្ខនាងនេះជាមនុស្សជិតខាងរបស់ខ្ញុំ ។ នៅឯក្រងអឺរុប គ្រាន់តែថ្ងៃមួយ ឬ កំពែងមួយនៅឃាំង អាចហាមឃាត់មិនឲ្យពួកសាច់ញាតិត្រកូលបានបួបជុំគ្នាអស់ឆ្នាំជាច្រើន នៅស្រុកអនាគតមិនដូច្នោះទេ បើគ្រាន់តែជាំងគ្នាដោយទៃព្យ ដោយភ្នំមួយ អ្នកស្រុកក៏អាចរាប់អានគ្នាជាបងប្អូន ជាអ្នកជិតខាងដែរ ។ ភ្នំជាន់ដែលអ្នកកោះហ្នឹងមិនទាន់សូវធ្វើដំនួញទៅប្រទេសភ្ងូគ្គ អ្នកជិតខាងភ្នំកោះសុទ្ធតែស្រឡាញ់រាប់អានគ្នា ហើយតែងតែជាទីសំណាក់អាស្រ័យ ជ័សបញ្ជូយដល់ជនបរទេសដែលជាអ្នកដំនួញ ។ កាលណាខ្ញុំដឹងថានាងម៉ារគឺរតែមានមិត្តសំឡាញ់ ខ្ញុំក៏មកជួយរាប់អាន ជួយទុក្ខជុរៈដល់នាងទាំងពីរណាដូចណា ។ លុះខ្ញុំដឹងថានាងឡាត្តរជិតនឹងសម្រាលកូន ខ្ញុំជ្រាប់នាងទាំងពីរឲ្យចែងដីចែកគ្នា ដើម្បីទុកឲ្យជាប្រយោជន៍ដល់កូនរៀងខ្លួនឲ្យហើយ ខ្ញុំចត្រែងលោអ្នកស្រុកមកវាតយកអស់ ចំណែកមួយនោ

ខាងលើទឹក ចំណែកមួយទៀតនៅខាងក្រោម ។ ដល់រៀបចំស្រេច ហើយ ខ្ញុំឲ្យនាងចាំងពីរចាប់ស្លាក ។ ដែលធ្លាក់បាននៅនាងឡាត្លូរ នាងម៉ារីតែត បានដីខាងក្រោម ។ ស្ត្រីទាំងពីរពេញចិត្តនឹងភាគដីរបស់ខ្លួន ។ តែនាងសុំកុំឲ្យបែកទីលំនៅពីគ្នា ព្រោះនាងនិយាយថា គ្រាន់យើងនឹងបានឃើញគ្នា បាននិយាយគ្នា ហើយនឹងបានជួយធុរៈគ្នា ទៅវិញទៅមក តែត្រូវនៅផ្ទះផ្សេងគ្នា ។ ខ្ញុំសង់ខ្ទមឲ្យនាងម៉ារីតែតមួយ នៅលើព្រំដីចំពាក់កណ្តាល ហើយសង់ខ្ទមមួយទៀតឲ្យនាងឡាត្លូរ នៅលើដីរបស់នាង តែជិតគ្នានឹងនាងម៉ារីតែត ។ ខ្ញុំទំទៅយកស្មៅគ្រឡះតាំងពីមាត់សមុទ្រមក ដើម្បីធ្វើខ្ទមឲ្យស្ត្រីចាំងពីរ ។ ឥឡូវនេះ អ្នកមើលចុះគ្មានអ្វីនៅសល់សោះទេ ហិនហោចអស់ហើយ ពេលវេលាតែងបំផ្លាញទីលំនៅឲ្យវិនាសឆាប់ណាស់ ។ នៅតែចិត្តខ្ញុំទេ ដែលតែងរលឹកអំពីរឿងនេះ អស់មួយជីវិតមិនចេះភ្លេច ។

ខ្ញុំគ្រាន់តែធ្វើខ្ទមទីពីរទើបនឹងហើយ នាងឡាត្លូរក៏សម្រាលកូនមកគឺកូនស្រី ។ ខ្ញុំជាឪពុកធម៌របស់កូននាង ម៉ារីតែត កុមារនុ៎ះឈ្មោះប៉ូល ។ នាងឡាត្លូរ អង្វរខ្ញុំឲ្យ។ នាមដល់កូនរបស់នាង ឲ្យសមគ្នានឹងនាមរបស់កូននាងជាសំឡាញ់នៃនាង ។ នាងម៉ារីតែត ឲ្យហៅថា វីរ៍ស៊ីនី ។

កាលនាង ឡាត្លូរ ចេញពីអាងភ្លើងហើយ ស្ត្រីចាំងពីរតាំងផ្តើមចាប់ធ្វើការរកស៊ី ។ ខ្ញុំជួយម្តងៗ។ ក្រៅពីនោះ ស្រែចតែលើកូនពីរនាក់

ធ្វើទាំងអស់ ។ គាត្តងជាបាវបំរើរបស់នាង ម៉ារីតែត ឈ្មោះឌូម៉ាំង គាត់
នេះពិតមែនតែចាស់ តែនៅមានកំឡាំងច្រើន ហើយធ្លាតរកទទួលទាន
ណាស់ ។ គាត់ជាំជំណាំច្រើនមុខផ្សេងៗគ្នា តាមទំនងដី ពោតត្រង់
កន្ទែងមិនសូវមានដី ស្រូវប៉ែត្រង់ដីល្អ ស្រូវធម្មតាត្រង់ដីទួនាប ត្រសក់
ឃ្មោក ត្រឡាច នៅកៀនថ្ម ដើម្បីឲ្យវាវរឡើង ដម្ងូងត្រង់ដីទឹកមិនដែល
លិច ដើម្បីឲ្យវាផ្អែម កប្បាសនៅទីទួល អំពៅត្រង់ដីខ្ពាំង ការ្ហូនៅ
លើខ្នងកំភួចៗ ចេកបណ្តាយតាមមាត់ស្ទឹង ទឹងនៅជុំវិញផ្ទះ ដើម្បីឲ្យ
បានម្ហូបផង ជាំថ្នាំខ្លះ ដើម្បីជក់កែអង្ករខ្លួនឯងទឹងម្ចាស់ ។ គាត់ទៅកាប់
ទុសឯព្រៃគុំ ទៅយកថ្មមកធ្វើថ្ពល់គ្រាន់ដើរ ។ គាត់ធ្វើការទាំងអស់នេះ
ដោយយកចិត្តទុកជាក់ទឹងដោយការប្រឹងប្រែង ។ គាត់ស្រឡាញ់នាង
ឡាតួរ ទឹងនាងម៉ារីតែត ស្មើភាគគ្នា ។ គាត់រៀបការនាងត្តងជាបាវបំរើ
របស់នាង ឡាតួរ ធ្វើជាប្រពន្ធ នៅថ្ងៃកំណើតនាងវីរ៉ូនី ។ តាត្តង
ស្រឡាញ់ប្រពន្ធគាត់ណាស់ នាងនេះឈ្មោះ ម៉ារី កើតនៅប្រទេស
ម៉ាដាគាស្កា ធ្លាតចេះតាញាក់ញើល្អី សំពត់ គួរជាទីស្នេហាដល់នាយ
ចៅហ្វាយ ។ នាងម៉ារីជាអ្នកចាត់ចែងខាងខាទនិយកោជនីយាហារ ចេះ
ចិញ្ចឹមមាន់ទា ហើយទឹងជាអ្នកទៅទិញអីវ៉ាន់បន្តិចបន្តួចឯផ្សារពេរ.ល្អី ។
មិនតែប៉ុណ្ណោះសោត ថែមទាំងមានចិញ្ចឹមពពែព័រសម្រាប់ឲ្យកូនក្មេង
ឃ្លាលេង ទឹងផ្តែមួយសម្រាប់ឲ្យចាំផ្ទះ ។

ចំណែកនាងទាំងពីរជាម្ចាស់ តែងថ្ពេចអម្បោះជានិច្ចតាំងពីព្រលឹមដល់ព្រលប់ ។ ការដែលនាងធ្វើនេះ មានសភាពដ៏ល្អមគ្រប់គ្រាន់ដល់ការស្វែកពាក់ខ្លួននាងនឹងមនុស្សក្នុងផ្ទះ តែទាស់គ្នានឹងតុដែលដ៏ប្រពៃពីបរទេស ។ នៅផ្ទះនាងដើរតែដើងទេ ហើយពាក់ស្បែកដើងតែថ្មីអាទិត្យ ដែលទៅវិហារសូត្រធម៌ ។ ស្ត្រីទាំងពីរមិនដែលទៅផ្សារទេ ថ្ងៃថ្ងៃតែនៅដិតជាងវិហារ ព្រោះនាងខ្ចាចគេមើលងាយ ដោយសារខ្លួនស្វែកពាក់សំពត់អាវមិនល្អដូចគេ ។ ប៉ុន្តែបើនិយាយឲ្យជាច់ស្រេចទៅ ការសុខទុក្ខមិននៅតែលើអ្នកស្រុកឡើយ ។ នាងម៉ាតែងតែនឹងឡាតួរ បើចេញដើរទៅទីក្រៅមានសេចក្តីព្រួយបន្តិច តែបើចូលមកដល់ទីលំនៅរបស់ខ្លួនវិញ មានសេចក្តីសប្បាយបរិបូណ៌ ។ អ្នកបំរើទាំងពីរ កាលណាបានឃើញនាងកំពុងដើរទៅឯផ្លូវបំពួមូស ជាកន្លែងដែលខ្លួនអាចក្រឡេកមើលឃើញ ក៏បបួលគ្នារត់ទៅដឹកដៃនាងឲ្យឡើងយ៉ាងស្រួលមិនឲ្យលំបាកឡើយ ។ នាងសំឡឹងមើលមុខបាវទាំងពីរ ឃើញថាមានចិត្តត្រេកអរណាស់ កាលបានឃើញនាង ។ នាងមានសេចក្តីសុខគ្រប់យ៉ាង គឺរូបក៏ស្អាត ឯកឆន្ទចិត្តក៏មាន វត្តគ្រប់បែបក៏មានប្រើប្រាស់អ្នកបំរើទាំងពីរ ជាមនុស្សខ្មែរហ៍ ហើយស្រឡាញ់នាងអស់ពីពោះ ។

ស្ត្រីទាំងពីរ ដោយអំណាចសេចក្តីត្រូវការចិញ្ចឹមជីវិតស្មើគ្នា ក៏តែងសោយទុក្ខវេទនាដូចគ្នា យកគ្នាធ្វើជាមិត្តភក្តិ រាប់អានគ្នាដូចបងប្អូន

បង្កើត មានសេចក្តីថ្នាំងថ្នាក់តែមួយ· មានប្រយោជន៍តែមួយ មានពេលអាហារតែមួយ ។ រាត្រីទាំងប៉ុន្មានរបស់នាង នៅជាមួយគ្នាទាំងអស់ ។ ម្យ៉ាងទៀត ប្រសិនបើក្មេងគឺកាមពីជាន់មុន ដែលខ្ជាំងជាងក្មេងគឺការកប់អាន លោតែត្រឡប់កើតឡើងវិញម្តងៗ គង់មានសាសនាយ៉ាងហ្មត់ចត់ថែមទាំងមានចំនៀមចំលាប់យ៉ាងច្រៃដួយផង អាចតម្រង់នាងឲ្យត្រង់ផ្លូវដើម្បីទៅកាន់លោកខាងមុខ ដូចជាអណ្តាតច្រមុះដែលជាប់ផុតពីច្រមេះហើយស្ទុះឡើងទៅលើអាកាស កាលណាគ្មានច្រមុះនៅលើផែនដី ។

កាលណាបានឃើញកុមារទាំងពីរ ដែលជាផលកើតមកអំពីកាមរាគច្របូកច្របល់ដោយសេចក្តីទុក្ខដូចគ្នា ចិត្តស្នេហាកាន់គ្នាទៅវិញទៅមក នៃនាងកើតឡើងជាខ្លាំងណា ។ នាងបួលចិត្តឲ្យកូនដេកកងអង្រឹងជាមួយគ្នា ។ នាងផ្ទាស់ប្តូរទឹកដោះគ្នាជាញឹកញយ ។ នាងឱ្យតបមានវាចាថា: "នែសំឡាញ់! យើងម្នាក់គោងគិតថាមានកូនពីរ ហើយកូនយើងវិញក៏ត្រូវគិតថាមានម្តាយពីរដែរ" ។ ហេតុដូច្នេះ ក្មេងទាំងពីរកំព្រាឪពុកដូចគ្នា តែងមានចិត្តខន់កាន់គ្នាទៅវិញទៅមក រាប់អានគ្នាដូចបងប្អូនពោះមួយ ។ តាំងពីថ្ងៃដែលស្តីទាំងពីរប្តូរទឹកដោះគ្នា ច្រៀបដូចជាពន្លកឈើពីរ ស្ថិតនៅលើរុក្ខជាតិពីរ ហើយជុះក្បែរគ្នា មានពួជតែមួយដែលព្យុះទើបតែនឹងបំបាក់រៃមកអស់ទៅ រោលពន្លកណាជាប់ចេញពីដើមរបស់ខ្លួន គេយកទៅបំប្លែងដើមជិតខាង ។ (មានត)

សំណៀរកំពាក់ខ្មែរ

របស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

(តចប់)

ហេតុដូចម្តេច ឋានជាយើងស្លៀកសំពត់ចងក្បាល? តើសំពត់ចងក្បាលនេះមានដើមកំណើតអំពីណាមក? តាមយើងឮថាស់ៗ ដំណាលមកយូរហើយថា សំពត់នេះយើងស្លៀកតាមសាសន៍ភូតិ្ត ។ ត្រង់នេះយើងមិនមានបំណងនឹងអធិប្បាយអំពីពង្សាវតារប្រទេសកម្ពុជា នឹងដើមកំណើតខ្មែរយើងទេ គឺយើងគ្រាន់តែសូមរំលឹកយ៉ាងសង្ខេបអំពីពង្សាវតារខ្មែរយើងបន្តិចថា: កាលពីដើមប្រទេសកម្ពុជាជាសមុទ្រដែលគោកទឹកបន្តិចម្តងៗ កើតមានមនុស្សសម្បុរជ្រះចូលមកនៅ, តមកជាព្រាហ្មណ៍គឺជាតិភូតិ្តដែលបានមកនៅក្នុងស្រុកជ្វាជាយូរហើយ មកពីស្រុកជ្វាចូលមកលុកលុយមកសោយរាជសម្បត្តិបង្កាត់កូនចៅលាយគ្នា រួចមកមានភូតិ្តសម្បុរខ្មៅហៅថាសាសន៍កម្ពុជាចូលមកបង្កាត់កូនចៅជាមួយនឹងអ្នកស្រុកនេះទៀត. ដូច្នេះយើញថាដើមកំណើតជាតិខ្មែរមកអំពីអ្នកស្រុកហ្វូណានជ្វាព្រាហ្មណ៍នឹងជាតិភូតិ្ត (ឥណ្ឌៀ) ដែលយើងហៅថាខ្មែរដើមឬកម្ពុ ។ សាសន៍ភូតិ្តខ្មែរដើម ឬជាតិកម្ពុនោះគង់សម័យឥឡូវឃើញច្រើនស្លៀកសំពត់វណ្ណសំឡុយ ឥតដេរជាយភ្ជាប់គ្នាទេ ហើយចាប់ចុងជាយនោះយកមកចុកនៅចង្កេះពីក្រោយ មានរបៀបបែបដូចជាយើងស្លៀកសំពត់

ចង់ក្បាច់ដែរ ; ដូច្នេះខ្មែរយើងស្លៀកសំពត់ចង់ក្បាច់មកអំពីតាមសាសន៍នេះទេតើដែលជាសាសន៍ដើមកំណើតរបស់ខ្មែរយើង ។ តាមចាស់ៗដំណាលរឿងព្រៃឆ្ងែ ដែលខាត់ចង់នឹងសំពត់ចង់ក្បាច់ថា : ខ្មែរយើងស្លៀកសំពត់ចង់ក្បាច់តាមសាសន៍ភូដ្ឋ ។ ដូចម្តេចបានជាភូដ្ឋស្លៀកសំពត់ចុងក្បាច់ ? យើងដឹងថាភូដ្ឋកាន់សាសនាច្រើនបែបណាស់ តែសាសនាដែលធំជាងគេ គឺព្រហ្មញ្ញសាសនា, ស្តេចខ្មែរយើងដែលកសាងនគរវត្តក៏ទុកចិត្តចំពោះព្រហ្មញ្ញសាសនាដែរ ។ កាលសម័យបុរាណខ្មែរយើងនិយមរាប់អានរឿងរាមកេរ្តិ៍ណាស់ ជារឿងរបស់ព្រះដែលគេគោរព, មើលចុះមានចាំងចំឡាក់រឿងរាមកេរ្តិ៍ នៅនឹងកំពែងប្រាសាទនគរវត្តជាគោលចារកែងផង ។ ពាក្យដែលយើងសរសេរតទៅនេះជាពាក្យដែលយើងឮចាស់ទុំគេដំណាលតៗគ្នាមកថា ហេតុដែលសាសន៍ភូដ្ឋស្លៀកសំពត់ចង់ក្បាច់ពីព្រោះភូដ្ឋគេគោរពចំពោះហនុមានដែលជាទេវបុត្ររបស់គេមួយ, ហនុមានជាសេនាឯករបស់ព្រះរាមាយន: ដែលយើងហៅថាព្រះរាម, ហនុមានបានធ្វើគុណចំណាច់ប៉ាយព្រះរាមជាច្រើនដូចយើងដឹងស្រាប់តែងរឿងរាមកេរ្តិ៍ ។ ដូច្នេះដើម្បីនឹងរំលឹកគុណហនុមាននោះគេត្រូវស្លៀកពាក់ស ពីព្រោះហនុមានមានសម្បុរស ហើយគេស្លៀកសំពត់ឲ្យមានកន្ទុយ ពីព្រោះហនុមានជាតិជាសត្វស្វាសមានកន្ទុយ ។ ខ្លះទៀតថាភូដ្ឋតាំងនោះជាពលនៅក្រោមអធិបតីភាពហនុមាន ប៉ុន្តែជា

គេតែងខ្ជូនស្លៀកពាក់ស ហើយបណ្តុះកន្ទុយយ៉ាងដូច្នោះ ។ ម៉ែនិយាយ
សារុបទៅ យើញថាសំពត់ចងក្បាច់ដែលខ្មែរយើងស្លៀកនេះ គឺយក
តាមសាសន៍ក្ងិតដែលជាសាសន៍ដើមកំណើតខ្មែរយើង ហើយដែលមាន
បំណងធ្វើតាមហនុមានដែលជាសត្វស្វាសមានឥទ្ធិឫទ្ធិដ៏ល្បីល្បាញ ដែល
ជាសេនាឯករបស់ព្រះរាម ។ តែឥឡូវនេះមិនតែប្រុសទេដែលស្លៀក
សំពត់ចងក្បាច់ ស្ត្រីក៏ស្លៀកដែរ ។ ក្នុងរជ្ជកាលព្រះករុណាឧភោគ្គម
(គ. ស. ១៨៣៥ ដល់ ១៨៦៤) គេស្លៀកចងក្បាច់ស្ទុយចុះទៅក្រោម
រួចមកទៅត្រឹមពាក់កណ្តាលកំភួនជើង, ដល់មកចុងរជ្ជកាលព្រះករុណា
ស៊ីសុវត្ថិ (គ. ស. ១៨៤០ ដល់ ១៩២៩) ឧត្តង្គរជ្ជកាលព្រះករុណា
ស៊ីសុវត្ថិមុនីវង្ស (គ. ស. ១៨៧៥ ដល់ ១៩៤១) គេចងក្បាច់ខ្លីចទៅ
ក្រោមជង្គង់បន្តិច គេថាធ្វើតាមសៀម; ចំណែកឯសៀម ទឹងខ្មែរជា
ប្រទេសនៅជិតគ្នា សៀមយកបែបសំពត់ចងក្បាច់ពីខ្មែរទៅស្លៀកៗ មិន
ត្រឹមតែប្រុសថែមចាំងស្ត្រីផង, លុះខ្មែរយើងឃើញថា ស្ត្រីស្លៀកល្អ
ដែរ ក៏នាំគ្នាស្លៀកតាមសៀម ។ អ្នកស្រុកបាត់ដំបង ទឹងសៀមកប
ដែលនៅជិតសៀម ធ្វើតាមសៀម ស្លៀកសំពត់ចងក្បាច់ខ្លីចនៅត្រឹម
ជង្គង់ គឺខ្លីជាងខ្មែរដែលនៅកង់កូមិកាគឯទៀត ។ ឥឡូវនេះគេមិន
សូវស្លៀកសំពត់ចងក្បាច់ទេ, គេស្លៀកតែក្នុងបុណ្យធំៗម្តងៗ ។

សំពត់សំឡុយធំជំស្បែកាន — តាមយើងស្មានមើលទៅ ថា សំពត់សំឡុយ ធំជំស្បែកានាដែលស្ត្រីខ្មែរបុកណាស្លៀកពាក់នោះ កំមក អំពីសាសន៍កុដ្ឋដែរ ។ ចូរយើងសង្កេតមើលស្ត្រីកុដ្ឋ តើស្លៀកពាក់ដូចម្តេច? គេស្លៀកសំពត់សំឡុយ ធំជំរុំសំពត់ដែលហៅថាសារី យើញ មានរបៀបប្រហែលគ្នាដែរ តែកុដ្ឋគេរុំច្រើនដុំ នៅចុងបន្តិចគេព័ទ្ធមកលើ ស្មា ។ ចំណែកខ្មែរយើងមានពីរយ៉ាង មួយយ៉ាងហៅថាស្បៃ ព័ទ្ធតែ មួយដុំខ្លួន ហើយទម្លាក់ទៅក្រោយវែងអន្លាយដិតដល់កែង, មួយយ៉ាង ទៀតហៅថាជួយ ព័ទ្ធច្រើនដុំហើយទម្លាក់ទៅក្រោយ ផ្អាក់ចុះវែងអន្លាយ ដែរ តែខ្មែរយើងព័ទ្ធរុំស្បៃធំជួយតែមួយកំណាត់ខ្លួនខាងលើហើយពាក់ ទៅលើស្មាឆ្វេងទម្លាក់ទៅក្រោយ ។ ចំណែកឯស្ត្រីកុដ្ឋរុំតាំងអំពីក្រោម ទៅដល់លើពាក់លើស្មាឆ្វេងដែរ ហើយទម្លាក់ទៅក្រោយបន្តិចឃើញថា ខុសគ្នាប៉ុណ្ណោះ ។ កាលពីព្រេងនាយ ខ្មែរយើងហើយធំជំកុដ្ឋ ខំនឹង ជាស្លៀកពាក់ដូចគ្នា, តែដោយសារនៅឆ្ងាយពីគ្នា មួយក៏យកផ្លូវស្រួល ផ្លូវកាត់បន្តិចទៅលើបន្តិចម្តង ។ កើតទៅជាស្បៃធំជួយទៅ ។ ឯកុដ្ឋចេះ តែចុះក្រោមទៅ។ សល់តែជាយបន្តិច ព័ទ្ធពាក់ទៅលើស្មា, តែមើល ចុះគោលទៅធំជដែល គឺសំពត់វែងព័ទ្ធរុំដុំខ្លួន ព័ទ្ធពាក់ទម្លាក់ពីលើស្មា ឆ្វេងទៅក្រោយ ។ សំពត់សំឡុយស្ត្រីកុដ្ឋឥតដេរជាយទេ តែស្លៀក សំពត់វែងធំកង្ហាញ់ស្លៀកត្រង់ថ្នក់ បើដូចជាគេដឹប លែងរំសាយទៅក្រោម

មួយដុំ, ចំណែកស្ត្រីខ្មែរយើងពីបុរាណស្លៀកសំពត់ឥតដេរជាយព្រលាំ
ទឹងស្ត្រីភ្លុំគ្គដែរ ហើយវែងណាស់ មានប្រវែងប៉ុនទឹងសំពត់ចង្កូន គឺ
៣ ម.២០ គេស្លៀកកង្ហាញ់ដីបជាយតាំងសងខាង ឲ្យនៅតែមួយដុំបន្តុះ
ទើបគេស្លៀកវាត់ជាយថ្នក់មួយចូលទៅក្នុង ខ្ទាក់ជាយថ្នក់មួយមកក្រៅ
មានសណ្ឋានរកចំដូចជាផ្ទៃតមួយនៅត្រង់ផ្ទៃត ឯពីមុខពីក្រោមផ្ទៃតទៅ
ក្រោមដីបរំសាយ ចំដូចជាសំពត់ស្ត្រីភ្លុំគ្គដែរ ។ ដូច្នេះខាងសំពត់មិន
ឃើញខុសគ្នាប៉ុន្មានទេ តែមកក្នុងសម័យឥឡូវសំពត់សំឡុយដែលខ្មែរ
យើងស្លៀកសព្វថ្ងៃ មានសណ្ឋានថ្លៃកពីសំពត់ដែលយើងស្លៀកពី
សម័យបុរាណ ទឹងថ្លៃកពីស្ត្រីភ្លុំគ្គហើយដោយជាតិយើងជាជាតិចូលចិត្ត
ស្វែងរកសេចក្តីស្រួល សេចក្តីរហ័ស, សំពត់ស្ត្រីខ្មែរសព្វថ្ងៃដេរភ្ជាប់
ជាយគ្នា តាំងសងខាង មានរាងដូចថង់ហើយមានប្រវែងប្រមាណតាំងពី
១ ម.៦០ ដល់ ១ ម.៩០ ប៉ុណ្ណោះ ។ កាលពីដើមយើងស្លៀកមានថ្នក់.
ឥឡូវថ្នក់នោះកាន់តែស្តួចស្តើងទៅហើយ, មានខ្លះស្លៀកព័ទ្ធឥតធ្វើជា
ថ្នក់ផង ។ សេចក្តីតែប៉ែបនេះ មានតាំងអំពីចុងរជ្ជកាលព្រះករុណា
មុនីវង្ស ដល់ព្រះករុណាជាអម្ចាស់ជីវិតយើងសព្វថ្ងៃ ដោយអារ្យធម៌
បែកអឺរុបចូលមកដល់ប្រទេសយើងកាន់តែច្រើនឡើង ។

នៅក្នុងរជ្ជកាលព្រះករុណានរោត្តម, ព្រះករុណាស៊ីសុវត្ថិនឹងព្រះ
ករុណាមុនីវង្ស ស្ត្រីខ្មែរអ្នកក្រុងច្រើនពាក់អាវសន្ទូះ ប្រុសខ្មែរក៏ពាក់

អាវសន្ទះដែរ តែមានសណ្ឋានប្លែកអំពីអាវសន្ទះស្ត្រីបន្តិច អាវសន្ទះស្ត្រីមានជង្គង់ខ្លួនជាប់ដល់ត្រគាមចង្កេះបន្តិច កម្ទួលតូចធំហាប៉ុនកមនុស្ស ពុះមុខជាប់សន្ទះរហូតដល់ចុងជង្គើម ដៃតស្មាដូចអាវចិន ខ្ទាប់ជាប់មកត្រឹមកួយដៃ, អាវសន្ទះបុរសដៃជាប់រហូតមកដល់កដៃ, ចំណែកខ្លួននឹងកដូចអាស្ត្រីដែរ តែបុរសច្រើនពាក់អាវនោះជាប់ក្នុងសំពត់ចងក្បិន, ចំណែកស្ត្រីខ្ទាប់ចុងខ្លួនអាវនៅត្រាសំពត់ ។ បុរសពាក់អាវសន្ទះសឹងតែគ្រប់កន្លែង, ចំណែកស្ត្រីវិញច្រើនតែអ្នកក្រុងទេ ដែលពាក់អាវសន្ទះហើយបង់កក្រមាសំយុង ។

នៅក្នុងរជ្ជកាលព្រះករុណានពេត្តម ស្ត្រីអ្នកក្រុងច្រើនស្លៀកសំពត់សំឡយពាទាក្រមាវែងដែលគេហៅតាមពាក្យសៀមថាជាហ៊ុំ ។

អារបំពង់រៃង — អាវនេះដេរថ្នេរ ៣ សង្ឃាង ខ្លួនកម្ទួលតូចធំហាប៉ុនកមនុស្ស ពុះមុខជាប់ចុះមកដល់ចុងជង្គើម ដៃតូចស្មាចរវែងជាប់ចុះមកដល់កដៃ ខ្លួនវែងសាយទៅត្រគាម យកកងរៀវស្មាចបង្កេះតាមថ្នេរ ៣, អាវនេះឃើញតែស្ត្រីទៅពាក់ៗ សឹងតែគ្រប់ទីកន្លែង, ឥឡូវឃើញតែស្រុកស្រែទេដែលនៅពាក់អាវនេះខ្លះ ។

តើអាវនេះកើតមានតាំងពីណាមក? ដោយយើងសង្កេតមើលទៅឃើញថាសាសន៍ចាមជាពាក់អាវនេះដែរ, សាសន៍ថៃដែលនៅក្នុងប្រទេសយួន ហើយដែលមានភាសាស្រដៀងគ្នា ទឹងសាសន៍សៀមខ្មែរ, តំពាក់

អាវប្រែហែលនេះដែរ ។ ចំណែកអាវនេះខ្ញុំឯងជាអាវបស់ស្ត្រីខ្មែរអំពីបុរាណហើយមើលទៅ, ពីព្រោះក្នុងពិធីច្រត់ព្រះនង្គ័លកាយបស់តាត្រសក់ផ្អែមយើញពាក់អាវនេះដែរ, តាមន័យទាំងនេះយើងយល់ថាអាវបំពង់វែងនេះខ្ញុំឯងជាមកអំពីសាសន៍ជ្វាទេឬ? ពីព្រោះសាសន៍ខ្មែរយើងតើតមកអំពីសាសន៍ជ្វាព្រាហ្មណ៍ ដែលនៅក្នុងស្រុកជ្វា កាលមកពីស្រុកជ្វាប្រែហែលជានាំអារ្យធម៌ជ្វាមកខ្លះមិនខាន ។ ស្ត្រីខ្មែរស្លៀកសំពត់ហូលពាក់អាវនេះនឹងបង់ក្រមា, ចំណែកស្ត្រីចាមជ្វាក៏ស្លៀកពាក់សណ្ឋាននេះដែរ ។

អារ៉ាហ្គាទិប – កាលក្នុងរជ្ជកាលព្រះករុណានរោត្តម (គ. ស. ១៨៣៥ ដល់ ១៩១៤) មានស្ត្រីស្ទៀមជាច្រើនចូលមកគាល់បំរើព្រះរាជា ។ ស្ត្រីអ្នកក្រុងជាន់នោះ ច្រើនស្លៀកសំពត់ចងក្សិនពាក់អាវហាតាទិប ធ្វើតាមស្ត្រីស្ទៀម ក្រវាត់ក្រមាព័ណ៌នៅចង្កេះ ខ្ទងស្ពាយឆៀង ។ អាវហាតាទិបនោះមានកត្រង់ បីដូចជាអាវកុតប្រុសតែធ្វើអំពីសំពត់ក្រណាត់ខ្ទន់ នៅជុំវិញកគេដាបដារសាយ ខ្ទមាត់មកក្រោម ៣ ជាន់ ដៃតូចវែងធ្លាក់ដល់ត្រឹមកដៃ នៅចុងដៃគេដាបដារខ្ទមាត់រំសាយក្រញូលមកលើចុងដៃ ២ ឬ - ៣ ជាន់ខ្ទិត ខ្ទងអាវពាក់ល្មមរឹតពងប៉ុនខ្លួន ធ្លាក់ចុះមកត្រឹមចង្កេះ ហើយមានដាបជាក់ជុំវិញចង្កេះ

ទៀត ។ គេឃើញមានពាក់អាវនេះតែអ្នកនៅក្នុងវាំង អ្នកនៅក្រុងទេ, ឯអ្នកស្រុកក្រៅមិនឃើញពាក់ឡើយ ។

អារ៉ែម៉ាទ្បាយ្ហូ— អាវនេះស្តើខ្សែពីដើមគេពាក់តូចធំសំពត់សំឡយ ចង់ក្រមា ដៃវែងធំ ធ្លាក់វែងចុះមកគ្រឹមពាក់កណ្តាលកំភួនដៃ កដូចកអាវសន្ទះ ខ្នងវែងធ្លាក់សាយចុះមុកដល់កំភួនជើង ដូចអាវបំពង់វែងដែរតែថ្នរចំហៀងខ្នងតែមួយ, អាវនេះទើបតែនឹងបាត់ឃើញពាក់ប្រមាណជាង ១០ ឬ ១៥ ឆ្នាំនេះទេ ។

ក្រុមដំគុំទៀមទម្លាប់ខ្មែរ

ជីវប្រវត្តិ

ព្រះសុធម្មបញ្ញត្តេរ កែវ-ជួប បៅអធិការ

វត្តកោះប្រាក់ ឃុំកោះទន្លឹម ស្រុកកំពង់សៀម ខេត្តកំពង់ចាម

ព្រះភិក្ខុ ម៉ី-សាន រៀបរៀង

ព្រះថេរៈព្រះនាមព្រះសុធម្មបញ្ញត្តេរ កែវ-ជួប អគ្គនេះ ជាអ្នកប្រាជ្ញផ្នែកវិន័យខាងព្រះពុទ្ធសាសនា មានសេចក្តីឃ្លាតែវល្អ មានកិត្តិយសសមគួរតាមសមត្ថភាពរបស់លោក ជាធម្មកថិកសំដែងធម៌បំភ្លឺដល់ជនានុជន ក្នុងនានាទិគមឲ្យបានភ្លឺស្វាង ឲ្យលះបង់អំពើខុសអាក្រក់ បែរមុខឈមទៅរកសេចក្តីត្រែវល្អ អស់កាលជាយូរឆ្នាំមកហើយ មានកិត្តិសព្ទពីពោះល្អរន្ធឺសុះសាយដរាបដល់មកសព្វថ្ងៃនេះ គួរសំដែងប្រវត្តិរបស់លោកជាលាយល័ក្ខណ៍អក្សរទុកជាទីរឭក ដូចតទៅនេះ ៖

លោកកើតកន្លងថ្ងៃសុក្រ ៧ កើតខែអាសាធ ឆ្នាំឆ្លូវនព្វស័ក ព. ស. ២៤១៩ (គ. ស. ១៨៧៦) បិតានាមកែវ មាតានាមអៀង នៅភូមិកោះគល់ ឃុំកោះមិត្រ ស្រុកកំពង់សៀម ខែត្រកំពង់ចាម ។

កាលលោកនៅជាកុមារ បានសិក្សាអក្សរនឹងលេខពីបិតាបានចេះខ្លះ លុះដល់អាយុ ១៥ ឆ្នាំ ទៅទៅរៀនអក្សរសាស្ត្រក្នុងសំណាក់លោកគ្រូសូត្រផង វត្តកោះរកា ក្នុងឃុំកោះរកា ស្រុកខែត្រជាមួយគ្នា បំពេញការសិក្សាអក្សរនឹងលេខថែមទៀត ដរាបដល់ចេះមើលចេះសរសេរបាន

ត្រមាំងរៀនធម៌នៃយបុរាំងបួសអស់ ១ ឆ្នាំ ។ ដល់អាយុ ១៦ ឆ្នាំទើប
បព្វជ្ជាជាសាមណេរ ។

លុះបព្វជ្ជាហើយ បានមើលគម្ពីរជាច្រើនគឺអភិធម្ម ៧ គម្ពី, អភិ-
ធម្ម៩បរិច្ឆេទ, ទសជាតក, បឋមសម្ពោធិ, បឋមត្រាស់ជាដើម
លោកបួសបាន ២វស្សា ដល់អាយុ ១៨ឆ្នាំ ត្រឡប់សឹកទៅជាឧបាសក
នៅត្រង់ត្រដែងគេហស្ថាន បានរក្សានិច្ចសីលជាប់មិនដាច់ធ្វើកិច្ចការបំរើមា-
តាបិតា អស់កាល ៤ឆ្នាំ ។ ដល់អាយុ ២២ឆ្នាំ កន្លងំឆ្នាំចសំរឹទ្ធិស័ក
នាថ្ងៃសុក្រ ៦ កើតខែអាសាធ ព. ស. ២៤៤១ ចូលមកឧបសម្បទាជា
ភិក្ខុភាវៈ កន្លងំពទ្ធសីមាវត្តកោះគល់ ឃុំកោះមិត្រ ស្រុកខែ្សត្រដែលវិញ
មានលោកគ្រូវិសុទ្ធិវង្សាសុី ជាព្រះឧបជ្ឈាយ៍ លោកគ្រូអរិយឃោសាទី
ជាកម្មវាចា លោកគ្រូទិព្វថេរ គង់ ជាអនុសាវនៃ បានឆាមបញ្ញត្តិថា
សុធម្មបញ្ញាតេរ ។

លុះឧបសម្បទាហើយ វស្សាទី ១ បានរៀនធម៌ភាណាវារៈនឹងបាតិ-
មោក្ខបាលីចាំស្អាត់ដល់ចប់, វស្សាទី ២ ទៅនៅវត្តកណ្តាលកោះសូទិន
រៀនសមណធម៌នឹងព្រះត្រៃបិដក បានប្រែមូលកច្ចាយនៈនឹងធម្មបទខ្លះ
កន្លងំសំណាក់លោកគ្រូអរិយឃោសាទី ជាកម្មវាចាចារ្យ ។ វស្សាទី ៣-៤
ត្រឡប់មកនៅវត្តកោះប្រាក់ បានរៀនមូលកច្ចាយនៈពីលោកគ្រូថេ-
រាធិការព្រះនាមធម្មគីរី កែ-យក់ រៀនធម្មបទពីលោកគ្រូអាចារ្យកែវ (កេ

ជា ១ ចាសក) ចានពាក់កណ្តាលខាងដើម ។ វស្សាទី ៩ ទៅនៅវៀន
ក្នុងសំណាក់លោកគ្រូអាចារ្យសន ចៅអធិការវត្តកំផែង ។ ត្រូចាតដំបង
ទីឯលោកគ្រូអាចារ្យ ជួប (១ ចាសក) ចានប្រែគម្ពីរធម្មបទទៅខាង
ចុងទៀតដរាបដល់ចប់ ហើយរៀនមូលកច្ចាយន ថែមទៀត ចានចំឡង
វិន័យចាតិមោក្ខ ទីឯខន្ធកវិភង្គពីលោកគ្រូអាចារ្យសន យកមកចែក
ឲ្យតិក្ខុសាមណេររៀនសូត្រ, លោកគង់នៅជាសុខសប្បាយក្នុងវត្តកំផែង
នោះ អស់រវាងពីរឆ្នាំ ។ ដល់វស្សាទី ៧ ក្នុងឆ្នាំកេងឆស័ក ព.ស.
២៤៤៧ កាលនេះលោកកំពុងតែមានព្យាយាមពេញព្រះទ័យទីឯការ
សិក្សានៅក្នុងទីនោះ . ក៏ស្រាប់តែមានឧបស័គ្គមកស្ទាក់ដំណើរឲ្យរអាក់
រអួល ដោយមានតិក្ខុជាមិត្តសព្រហ្មចារ្យដែលទៅពីស្រុកជាមួយគ្នាមាន
ជម្ងឺ លោកក៏ជូនតិក្ខុនោះមកកាន់ស្រុកកំណើតបំណងថានឹងត្រឡប់ទៅ
សិក្សាឯចាត់ដំបងវិញ តែដល់លោកនិមន្តមកដល់ស្រុកហើយក៏គង់នៅ
វត្តកោះច្រុកវហូតមកដល់សព្វថ្ងៃនេះ ដោយលោកមានព្រះទ័យច្រើន
ចង់គង់នៅជិតមាតាបិតាដែលមានជរាភាពបៀតបៀនផង ដោយពេល
នោះវត្តកោះច្រុកមានការសិក្សាព្រះវិន័យកាន់តែចំរើនមាំមួនឡើងផង
លោកក៏សិក្សាតទៅ គឺរៀនគម្ពីរធម្មបទថែមទៀត, មង្គលត្ថទីបនី, សារត្ថ-
សង្គហ, អាទិកម្ម, វិន័យមហាវគ្គខ្លះ ក្នុងសំណាក់លោកគ្រូអាចារ្យកែវ
(១ ចាសក) អស់ពីរឆ្នាំ ។

ស្បាទី ៩ ឆ្នាំមមីអដ្ឋស័ក ព. ស. ២៤៤៩ លោកមានវិជ្ជាល្មម នឹងបង្រៀនគេបាន, សម័យនោះ លោកគ្រូព្រះធម្មគិរី តែ យក់ ទៅអធិការជាអធិបតី បានចាត់និមន្តលោកឲ្យបង្រៀនធម្មវិន័យដល់កិក្ខុសាមណេរ, លោកក៏មានព្រះទ័យសោមនស្សជួយលើកដំកើងព្រះពុទ្ធសាសនា ទទួលធ្វើជាគ្រូបង្រៀនធម្មវិន័យ បានបង្ហាត់កិក្ខុសាមណេរឲ្យសូត្រធម្មត្រឹមត្រូវតាមអក្ខរាវិធីនឹងរៀមប្រែតួសីលអង្គសិក្ខាបទជាដើម ព្រមទាំងបង្រៀនលេខនព្វន្តដល់ពួកកុមារផង អស់ ៣ ឆ្នាំ ។ តពីនោះមក លោកបង្រៀនចាលីនៅទីកុដិរបស់លោក ។

ស្បាទី ១៦ កង្ហឆ្នាំឆ្លូវបញ្ចស័ក ព. ស. ២៤៥៦ បានទទួលនាទីជាគ្រូសូត្រ ហើយទទួលភារៈកិច្ចការក្នុងវត្តទាំងអស់ជំនួសព្រះតេជព្រះគុណព្រះធម្មគិរី តែ-យក់ ដែលមានជរាភាពបៀតបៀន ។ ស្បាទី ២៩ កង្ហឆ្នាំចអដ្ឋស័ក ព. ស. ២៤៨៩ ព្រះតេជព្រះគុណព្រះធម្មគិរី តែ-យក់ ទៅអធិការសុគតទៅ លោកក៏បានទទួលនាទីជាចៅអធិការឡើង ។

លោកបានទទួលគ្រឿងឥស្សរិយយសពីគឺ: មេដៃយ៍មាសអំពីព្រះករុណាម្ចាស់ជីវិតព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះចៅក្រុងកម្ពុជា ដោយគុណសម្បត្តិផ្សេងៗ (១៣ សីហា) ១. អស្សរៃទ្ធិមនីសាភតំណាអំពីព្រះករុណាម្ចាស់ជីវិតព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជា ដោយគុណបំណាច់វិជ្ជាផ្សេងៗ (១ វិច្ឆិកា ១៩៤៩) ១ ។

បុញ្ញកិរិយាវត្ថុ

ដែលព្រះសុធម្មបញ្ញត្តេរ កែវ-ជួប បានសាង

លោកបានធ្វើបុញ្ញកិរិយាវត្ថុជាច្រើនគឺ បានជួយសាងចេតិយធំ ១ ជាទីបញ្ចុះព្រះសារីរិកធាតុ មានព្រះធម្មគីរី កែ-យក់ ជាប្រធាន, ប៉ាន សាងកុដិ ១ សម្រាប់កិក្ខុ-សាមណេរនៅអាស្រ័យ, បានរាតទីវត្តដែលចង្អៀតស្កុកស្កាញដោយព្រៃ លើកដីគលប់ថ្មកឲ្យរាបស្មើទូលាយលើងស្អាត, បានដីកស្រែជាស្នាមក្បោះព័ទ្ធជុំវិញជាកសិណរបស់វត្ត, បានសាងសាលាចាលីវង ១ ខ្នង, បានទំនុកបំរុងឲ្យមានអាចារ្យបង្រៀនដល់កិក្ខុសាមណេរ, បានធ្វើបុណ្យឆ្លងសាលាចាលីវង, បានជួសជុលវិហារចាស់ឲ្យជាថ្មីមានសណ្ឋានថ្មីកខ្មើង. បានជួសជុលរបងនឹងក្បោងទ្វារវត្តចេតិយចាស់ឲ្យជាថ្មីឡើង, បានរចនាបល្ល័ង្កជាក្បាច់រំលេចពណ៌ដោយថ្នាំគំនូរ បានសាងបដិសណ្ឋារសាលា ១ សម្រាប់ទទួលភ្ញៀវធ្វើបុណ្យទំនៅសន្និបាតជំនុំការ, បានធ្វើបុណ្យឈាបនកិច្ចព្រះធម្មគីរី កែ-យក់ ថៅអធិការទំនបុណ្យឆ្លងវិហារ, ក្នុងបុណ្យនោះបានសាងព្រះពុទ្ធរូបពីរព្រះអង្គគឺមាស ១ ព្រះអង្គ ប្រាក់ ១ ព្រះអង្គ, បានសាងសាលារៀនពីរខ្នង ១ ខ្នងពីរថ្នាក់ ១ ខ្នងទៀត ៣ ថ្នាក់ជូនពុជការ, បានទំនុកបំរុងឲ្យមានគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ចាំរាំងដល់ពួកកុមារីតាមផ្លូវពុជការ, បានជួយសង្គ្រោះជីកនាំវិហារសាលាកុដិវត្តក្បាលកោះប្រាក់ ដែលមានកំយអំពីច្រាំងចាក់

យកមកសង់កុដិ វត្តរបស់លោក (១៩២៧). បានដួសដុលសាលាសម្រាប់ធ្វើបុណ្យដែលចាស់ទ្រេតទ្រោតឲ្យរឹងប៉ឹងមាំមួនឡើងវិញ, បានណែនាំមាតាបិតាឲ្យតាំងនៅក្នុងសីលធម៌; បានចាត់កិច្ចសាមណេរឲ្យទៅឲ្យសីលដល់មាតាបិតាទឹងក្រមញាតិរបស់លោកជានិច្ចរាល់ថ្ងៃសីល, បានព្យាបាលរក្សាជម្ងឺមាតាបិតា លុះដល់គាត់អនិច្ចកម្មទៅ បានធ្វើបុណ្យឈាបនកិច្ចជាទីបំផុត, កុដិបុណ្យនោះបានសាងព្រះពុទ្ធរូប ២ អង្គ គឺមាស ១ ព្រះអង្គ ប្រាក់មួយព្រះអង្គ, បានធ្វើបុណ្យឈាបនកិច្ចលោកគ្រូអាចារ្យតែវធម្មាចារ្យរបស់លោក, បានសាងអណ្តូងទឹក ១. បានធ្វើបុណ្យឈាបនកិច្ចលោកគ្រូអាចារ្យ ជួន-ជា ជាកាតិកត្តេរបស់លោក, បានទំនុកបំរុងបុណ្យឈាបនកិច្ចលោកគ្រូលន់ចៅអធិសការវត្តកប្បាលកោះប្រាក់, បានហែគម្ពីរទឹងបុរាណវត្តផ្សេងៗគឺ:គម្ពីរមនោរថបុរណីអដ្ឋកថា អង្គុត្តរនិកាយ និបាត ១៥ ខ្សែ, អនុដីការិកង្គ ១០ ខ្សែ, វិនយក្ខន្ធកនិទ្ទេស ១១ ខ្សែ, ឯកវិមតិវិនោទនីដីកាព្រះអាទិកម្ម ១៥ ខ្សែ, ការណាវ: ៩ ខ្សែ ជាដើម, ឯបុរាណវត្ថុ មានពូ, ក្រែទេសនា ស្មៅរមាំងកូស, ខ្សែរុំគម្ពីរលាយល័ក្ខណ៍អក្សរជាដើម; ទៅដំកល់ទុកក្នុងព្រះពុជបណ្ណាល័យកម្ពុជា នៅក្រុងភ្នំពេញ ក្នុងឆ្នាំថោះនព្វស័ក ព.ស ១៩២៧ ដោយការរួបរួមជាមួយនឹងព្រះធម្មគិរី តែ-យក់ ជាចៅអធិការ, បានសាងគម្ពីរជាច្រើនគឺ: ធម្មបទ ១ ចប់; មង្គលត្ថទីបនី ១ ចប់, សារត្ថសង្គហ ១ ចប់, មូលកច្ចាយន: ១

ចប់ គាណវារៈ ១ ចប់, អាទិកម្ម ១ ចប់; វិសុទ្ធិមគ្គ ១ ចប់, ព្រះវិន័យ ចិដកចុលីសម្រាយអក្សរខ្មែរ ១ ចប់, ។ ល ។ សៀវភៅឯក្រៅទៀត គឺ វចនានុក្រមខ្មែរ វុត្តោទ័យ, គិហិបដិបត្តិ, កច្ចាយនូបត្ថម្ភកៈ, វតនប្បកា (ពន្ធឹកែវ), វិជ្ជាចរណកថា, បព្វជ្ជាខន្ធកសង្ខេប ជាតិមោក្ខសង្ខេប, ។ ល ។ ជានសាង៉ចេតិយ ១ បញ្ចុះអដ្ឋិធាតុ ព្រះធម្មគិរី កែ-យក់ ជៀអធិការ នឹងមាតាបិតារបស់លោក, ជានចូលពុទ្ធិកសមាគមកម្ពុជវជ្ជ ជាកម្មិកសមាជិកមីមហាជាយក, ជានបង្កើតឲ្យមានធម្មទេសនាជាត់ ធម្មកថិក្នុងឲ្យសំដែងធម្មិកឯវិហារនឹងសាលាជុលីរងកាលថ្ងៃសីល, ជាន ចូលសមាគមគិលានសង្គ្រោះ សម្រាប់ព្រះសង្ឃខ្មែរ ចុះឈ្មោះសិនិទ្ធ-មាជិក ។ ល ។

ការប្រតិបត្តិ
របស់ព្រះសុធម្មត្ថេរ កែវ-ជួប

ព្រះមហាថេរអង្គនេះ លោកមានព្រះទ័យធ្ងន់ធ្ង សភាពទន់ភ្លន់ បរិបូណ៌ដោយសីលនឹងកល្យាណធម៌ មានចរិយាសណ្ដាប់ធ្នាប់សមរម្យ គួរជាទីរីករាយជ្រះថ្លានៃពុទ្ធសាសនិកជនទាំងឡាយ, ប្រកបដោយ កតញ្ញូតាធម៌នឹងវុឌ្ឍាបចាយនធម៌ លោកជាអ្នកតាំងនៅក្នុងសប្បុរសធម៌ ព្រមទាំងស្គាល់ហេតុផលល្អអាក្រក់ ស្គាល់ថ្នាក់លំដាប់នៃការចេះដឹង ជាដើមរបស់លោក ដឹងប្រមាណក្នុងការទទួលជាដើម នឹងពេលដែល

ត្រូវប្រែកបកិច្ចចាំឆ័ត្តង ស្គាល់ប្រជុំជនទីឆ័បុគ្គលដែលគួរសេពគប់ទីឆ័មិនគួរសេពគប់, ប្រែកបដោយសង្គហវត្ថុភាំឆ ៤ ប្រការ ច្រើនទៅដោយសេចក្តីសង្គ្រោះ អាណិតអាសូរចំពោះអ្នកតូច ដោយការចែកឲ្យទូរបច្ច័យ ៤ មានចីវរជាដើម ដល់កិក្ខុសាមណេរ ទីឆ័ចំណាយទេយ្យវត្ថុសាឆ័សាលារៀនជាដើម តែឆ័មានព្រះពុទ្ធដីកាប្រស័យទីឆ័ជនដែលចូលទៅរក ដោយភាក្យដ៏ពិរោះជាបិយវាចា ជាពាក្យគួរដល់កិច្ចការតាមផ្លូវច្បាប់ដ៏ពិតមិនលើសមិនខ្វះ មានព្យាយាមរឹងប៉ឹង ជ្រើសរើសធ្វើតែអំពើល្អប្រព្រឹត្តធ្វើកិច្ចជាប្រយោជន៍ដល់ពុទ្ធសាសនា ដល់ព្រះអគ្គលោកទីឆ័ជនដទៃ ។

គុណធម៌របស់លោកចាំឆ័នេះ ចាន់ជាទិដ្ឋធម្មិកត្ថ ជាតម្រាប់ដល់សាធុជនចាំឆ័ត្តង ជនដែលចាន់ប្រតិបត្តិតាម ក៏ចាន់សេចក្តីសុខស្រួលដោយសារលោក ។ ក្នុងពេលសន្និបាតម្តងៗ ឬពេលដែលជួបប្រៃសព្វទីឆ័អ្នកដែលចូលទៅរក ច្រើតែនាំយកភាក្យសុភាសិតមកថ្លែងជារឿយៗ។ មានសុភាសិតដូច្នេះជាដើមថា:

កុំស្មោកគ្រោកវាថោកការ កុំធឹកស្រាវាជាច់សីល
កុំស៊ីច្រើនវាច្រើនខ្លិល កុំកកិលវាថោកឫក ។
ការងារថោកថយព្រោះខ្ជីខ្ជា ជាច់សីលសត្យាព្រោះប្រមិក
ស៊ីហួសប្រមាណច្រអូសស្តឹក ថោកឫកព្រោះតែប្រកាន់កិល ។

ឱវាទរបស់ព្រះសុធម្មបញ្ញត្តេរ កែវ ជួប

កិក្ខុជាតិមោក្ខំ　　អាចរកកំឯចាំឯអបាយ
កិក្ខុថ្នាំឯឡាយ　　ត្រូវខ្ពស់ខ្ពាយរៀនប្រតិបត្តិ ។
កិក្ខុតិរោកុដ្ឋំ　　ក្រែវជញ្ជាំឯត្រិះបញ្ញត្តិ
ប្ជួសហើយបែរជាកាត់　　ចោលជញ្ជាំឯគឺវិន័យ ។
ដូចសត្វចរោខោ　　ខំមែកពោធិ៍ស៊ីផ្លែជ្រៃ
ឬថាដូចបក្សា　　លោតចុះចាកមែកវុក្ខា ។
ស្ងៀកស្បង់មិនគោរសក់　　ធ្លុះកញ្ចក់ឆ្មៃចនេត្រា
វិន័យឬសាសនា　　មិនទឹកនាសិក្សាសោះ ។

ថ្ងៃ ៣ ឬ ៤ ឆ្នាំខាលចត្វាស័ក

ព. ស. ២៤៩៣ គ. ស. ១៩៥១

អ្នករៀបរៀង កិក្ខុ ម៉ី - សាន

ភទ្ធមន្ទិរ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៤ . ខែឧសភា លេខ ៥

ព. ស. . ២៤៩៥ _ គ. ស. ១៩៥២



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពន្ធអាស៊ីទូប (តមក)	លោកវ៉ាយ - ប៊ុក	៣២៣
ពលរដ្ឋធម៌	ព្រះមហា ដែ—វង្ស	៣២៨
អត្តានុទិដ្ឋិ (តមក)	ឧកញ៉ា សំ - ស៊ុន	៣៣៩
ផ្នែកអក្សរសាស្ត្រ		
គុណសម្បត្តិនៃអ្នកទេស្ន	ព្រះទេពសត្ថា ស្សរ - ហាយ ...	៣៤៦
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ម ...	៣៥៤
រឿងសាមកុក (តមក)	ឧកញ៉ា ឆ្ង - កន	៣៦៣
រឿងអារក្សថ្លែងរឿងម្តែជ្រាំ (តមក)	លោក សាង - សាភ័ត	៣៧២
រឿងស្នេហាជាតិ (តមក)	លោក គង់ - លឹម	៣៧៦
រឿងប៉ូលនិងវីរ៉ស៊ីនី (តមក)	លោក ផេង - ជ្រឿ	៣៨៥
កំណត់ទឹកប្រវត្តិការណ៍		
ពិធីបុណ្យចូលឆ្នាំ នៅទីព្រះលានឧត្តរង ..	ព្រះមហាឧត្តមវិជ្ជា កែ - អឿន ..	៣៩៥
សេចក្តីកត់ហេតុក្នុងការប្រឡងមហាបរិយត្តិ .	អធិបតីនៃក្រុមសមាជិក	៣៩៩

មួយឆ្នាំមាន ១២ លេខ — ដំឡៃដាវ ១៧៣.០១

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

La lumière de l'Asie (suite).....	*M. Ray-Buc*	323
Balaratthadharma.....	*Vénérable CHHÈ-VONG*. . . .	328
Attânuditthi (suite).	*Oknha Sam-Sun*	339

PARTIE LITTERAIRE

Qualité d'un conéfrencier.....	*Vén.So-hay*	346
Education morale (suite).....	*Vén.Pœung-Pam*	354
Histoire de SAMKOK (suite)	*Oknha Nou-Kan*	363
Les vingt cinq récits du Mauvais Génie (suite)	*M. Sang-Savat*	372
L'Amour de la Patrie (pièces de Théâtre) (suite).....	*M. Kong-Lim*	376
Paul & Virginie (suite).....	*M. Phéng-Chrieu*	385

NOTES ET CHRONIQUES

Conte rendu de la fête religieuse à Nokor Thom (Siemreap) ....,.	*Vénérable KER-ŒUN*	395
Procès-verbal de l'examen des Ecoles de Pali à la pagode de Khléang-Soctrang (Sud Viet Nam)	*La Commission d'examen* . . .	399

Prix d'abonnement annuel comprenant (12 numéros:) 1$00

ពន្លឺអាស៊ីទ្វីប

វគ្គទី ៨

La Lumière de l'Asie

លោក ស៊ើរ-អេតវ៉ាំង អារណូលត៍ តែង

លោកវ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យប្រៃរៀបរៀង

(តមក)

ព្រោះហេតុដូច្នេះ, បុណ្យដែលបានសន្សំទុកមកយូរហើយ នាំឲ្យ
គ្រាប់ទៅដល់ស្ថានបរមសុខ. ឆ្ងាយពីបាបអកុសលណាមក តែត្រូវឲ្យ
ច្បាប់ព្រហ្មវិហារនោះស្ថិតនៅជាអធិបតេយ្យលើកពពាំងអស់មុនទឹងក្លើង
នេះកល្ប ។ ឧបាសិកាអើយ តើអ្វីជាឧបសគ្គ? គឺឯងឯតដែលផ្សាយចេញ
ពីអវិជ្ជា នាំឲ្យអ្នកពាំងអស់គ្នាវង្វេង, យកសភាពកាន់ច្រឡំថាជាសភាព
មែនពិត ហើយនាំឲ្យកើតទុក្ខតណ្ហាជ្រាបថ្នូរសភាពកាន់ច្រឡំនោះៗ!
ដល់សេចក្តីជ្រាបថ្នូរនោះ សម្រែចបានមកអ្នកៗ នៅជាប់ជំពាក់នឹងតាម
ភពដែលជាហេតុឲ្យកើតទុក្ខ ។ អ្នកដែលជ្រាបថ្នូរគ្រាប់ទៅតាមផ្លូវមជ្ឈិមា
បដិបទា (ផ្លូវកណ្តាល) ដែលវិចារណញ្ញាណបានកាប់ឆ្កាទុក្ខ ដែល
សន្តិភាពបានឈូសឆាយគ្រឹមឲ្យស្មើ, បើអ្នកជ្រាបថ្នូរទៅតាមផ្លូវដ៏ខ្ពស់
គឺព្រះនិព្វាន សូមអ្នកផ្តៀងសោតបសាទស្តាប់ចតុរារិយសច្ច ។

សច្ចធម៌ ទី ១ គឺទុក្ខ ។ អ្នកមិនត្រូវឲ្យគេរំលោកទេ! ជីវភាពដែល
អ្នកពេញចិត្ត ប្រកបដោយទុក្ខលំបាកជាយ៉ាងក្រៃលែង! ទុក្ខទាំងនោះ

ស្ថិតនៅសេចក្តីសប្បាយក្នុងអាមិស ដូចជាបក្សាភ្លើចាំងហើយហើរចុតទៅ ។ ទុក្ខព្រោះកើត, ទុក្ខព្រោះព្រួយលំបាក, ទុក្ខព្រោះវ័យខៅក្នែងឬវ័យចាស់, ទុក្ខព្រោះអាយុសង្ខារសេសៀរចូលទៅដិតជាប់នឹងទុក្ខអវសានគឺសេចក្តីស្លាប់, នេះហើយដែលមានក្នុងជីវភាពរាល់រូបគ្រប់គ្នា ។ សេចក្តីស្នេហាជាសភាពគួរឲ្យពេញចិត្ត តែអណ្តាតភ្លើងដែលឆាបសេចក្តីស្លាប់នោះត្រូវបំពាល់ទៅលើដើមទ្រូងដែលជាទីស្នេហារបស់អ្នក ទឹងបបូរមាត់ដែលអ្នកធ្លាប់ជញ្ជក់ទូវរសជាតិ ។ គុណសម្បត្តិខាងការតស៊ូវិសេសអស្ចារ្យ តែមានបក្សាគ្នាតវាំចាំហែកសាច់នាយហើយនឹងព្រះមហាក្សត្រ បរិភោគ ។ ព្រះធរណីគួរជាទីស្បុនិយភាពមែន តែជីវសត្វនៅក្នុងអជនប្រទេសបានពិឃាតគ្នាទៅវិញទៅមកដោយច្បាច្បាចន់រស់រៀងខ្លួន, មេយមានពណ៌ខៀវ, តែមនុស្សដែលឃ្លានស្រែកយ៉ាងណាក៏ដោយ ក៏មេយនោះមិនអាចបង្អុរទឹកភ្លៀងមួយដំណក់មកស្រោះឡើយ ។ ចូរអ្នកសួរអ្នកជម្ងឺអ្នកមានទុក្ខ, អ្នកដែលជាពន់ពេកគាន់ឈឺច្រត់ត្រាច់ឆ្អែតតែម្នាក់ឯង រង្គើកក្នុងអង្គថា: "តើអ្នកស្រឡាញ់ជីវិតអ្នកឬ" ។ អ្នកចាំងនោះមុខជាតបថា ខាកដែលខើបនឹងប្រសូត្រមកត្រូវតែយំ ។

សច្ចធម៌ទី ២ គឺហេតុដែលកើតទុក្ខ ។ តើទុក្ខនោះមិនមែនកើតមកពីខ្លួនឯងទេឬ ហើយមិនមែនកើតមកពីតណ្ហាឬ? មនោសញ្ចេតនានឹងវត្ថុដែលបំពាល់ដោយអារម្មណ៍ ទៅជួបប្រទះគ្នាហើយ ចិត្តតម្រេកកំណួល

នេះឡើង, ទើបត្រិស្ណា (តណ្ហា) នេះឡើងញ៉ាំងកាមារម្មណ៍នឹងសេចក្តី
ស្រែកឃ្វានឲ្យមានឡើងក្នុងពេលនោះ ។ អ្នកមានចិត្តចងភ្ជាប់ទៅនឹង
ស្រមោលអណ្តែតអណ្តង់ទៅក្នុងយល់សប្តិនិមិត្ត, អ្នកបានដំកល់ចំពោះ
មុខអ្នកនូវអាត្មានមានសភាពមិនពិត ហើយអ្នកធ្វើមបង្កើតឡើងជុំវិញនូវ
ទុកាសលោកមិនពិតទៀត ។ អ្នកមានភ្នែកភ្ញាក់មិនអាចមើលឃើញនូវ
ពន្លឺដ៏វិសេស ត្រចៀកថ្លង់ មិនអាចស្តាប់ឮនូវសំឡេងនៃពាយោមានស័ព្ទ
ពីរោះអស្ចារ្យដែលចេញពីស្ថានខ្ពស់ហួសស្ថានព្រះឥន្ទ្រាធិរាជទៅទៀត,
គឺចំពោះការស្រែកដង្ហោយនៃជីវភាពពិត ដែលមានតែបុគ្គលលះបង់ជីវ-
ភាពនៃលោក មានសភាពកាន់ច្រឡំអាចពោលបាន ។ ព្រោះហេតុ
ដូច្នេះ បានជាមានការតស៊ូព្រមទាំងការប្រព្រឹត្តិកាមភព ដែលនាំឲ្យកើត
សង្គ្រាមនៅលើផែនដី បានជាពួកសាមញ្ញជនតែងរងទុក្ខលំបាកដោយ
កាន់ច្រឡំ, តែងយំស្រោកដោយធម្មជាតិល្ងីល្ងើនៃសង្ខារ, បានជាឆ្នាំកាច
សាហាវ មានដើងប្រឡាក់ដោយលោហិតក្រហម ដោយឆ្នាំដែលប្រឡាក់
មន្ទិលដោយការពិឃាតនូវសត្វផ្សេងៗ, បានជាកន្លែងណាដែលមានគ្រាប់
ពូជដុះល្អ កន្លែងនោះមុខជាមានស្មៅ "ប៊ីរង" មានឫសអាក្រក់, ផ្កាមាន
ពិសពុលដុះជាមួយនោះមិនខាន, គ្រាប់ពូជល្អមិនងាយធ្លាក់ជម្រុះដុះនៅ
លើដីទំនេរដែលគួរការ ។ ហើយព្រលឹងចាកចេញពីខ្លួនដោយផឹកនូវទឹក
ពុល ឯកម្មកើតឡើងទៀតមានចំណងចង់ក្រែចផឹកនូវទឹកពុលនេះជាថ្មី

កាន់តែខ្លេឡើងទៀតឥតមានស្រាក, ដោយមនោសញ្ចេតនាមកប៉ះពាល់, អាត្មានោះក៏ចោមនស្សផុះផុលជាខ្លាំងធ្វើដំណើរជាថ្មីគ្មានឈប់ឈរ ។ ហើយច្បូតកាត់នូវបុណ្យចាបតទៅទៀត ។

សច្ចធម៌ទី ៣ គឺការលះបង់នៃទុក្ខ ។ គឺសន្តិភាពដែលត្រូវមានការតស៊ូដោយចំពោះការស្រឡាញ់អាត្មន ហើយនឹងការជាប់ជំពាក់កងដីវភាព, ព្រមទាំងការដកចេញពីដើមទ្រូងនូវកាមតណ្ហាដែលមានឫសចាក់ជ្រៅ នឹងធ្វើសង្គ្រាមខាងក្នុងឲ្យស្ងប់ស្ងាត់, ព្រោះហេតុដូច្នេះ ចានជាព្រហ្មវិហារមានសេចក្តីពេញចិត្តត្រង់ក្រែបយកនូវរសជាតិនៃសុកនិម្មិតប្រកបដោយអនន្តកាល, គេចានកិត្តិយសត្រង់ការសង្កត់សង្កិនខ្លួនឯងឲ្យនៅក្រោមឧបាទខ្លួន ហើយនឹងការពេញចិត្តរស់នៅពីលើពួកព្រហ្ម, ទេវតា, គេចានទ្រព្យប្រកបដោយអនន្តមាត្រ (អរិយទ្រព្យ) ព្រោះទ្រព្យទាំងនេះកើតឡើងដោយកិច្ចការធ្វើកុសល, ព្រមទាំងប្រព្រឹត្តនូវករណីយកិច្ចដោយចិត្តសទ្ធា, ដោយសុភវាចាព្រមទាំងជីវភាពបរិសុទ្ធស្អាត, អរិយទ្រព្យទាំងនោះមិនអាចរលត់រលាយទៅក្នុងដីវភាពចានទេ ហើយសេចក្តីស្លាប់មិនអាចធ្វើអរិយទ្រព្យទាំងនោះឲ្យវិនាសទៅចានឡើយ ។ ព្រោះហេតុដូច្នេះ ទុក្ខអាចវិនាសសាបសូន្យទៅចាន ក្នុងកាលដែលជីវិតរស់នៅនឹងក្នុងកាលសេចក្តីស្លាប់ផុតរលត់ជីវិត, តើចង្រៃដែលមាន

ប្រែងអុចអាចបំភ្លឺបានឬ? បំណុលចាស់ៗងអស់ តើគប់ណុលថ្មីឡើងទៀត, ដល់យូរៗទៅមុខជានឹងបានដល់សេចក្តីសុខមិនខាន ។

សច្ចធម៌ទី ៤ គឺផ្លូវ (មគ្គសច្ច) ។ ផ្លូវនេះមានសភាពធំ, ទូលាយ, ស្មើ, សម្រាប់ឲ្យដើរទាំងអស់គ្រាប់ស្រួល ជាតទៅកាន់អដ្ឋង្គិកមគ្គ (មគ្គប្រាំបី) ដែលគ្រាប់ទៅត្រង់សន្តិភាពនឹងទីជ្រក ។ ចូរអ្នកស្តាប់! មានស្នាមគំនូសជាច្រើន ដែលនាំទៅកាន់កំពូលភ្នំស្រួច ស្នាមក្លោះមានទឹកកកស្ថិតនៅជានិរន្តរ៍ ហើយមានពពកសុវណ្ណពណ៌អណ្តែតព័ទ្ធជុំវិញ ។ បើយើងឡើងតាមចង្កេះភ្នំ ដែលមានសភាពទេរចុះស្រួលឬមានជ្រោះ គុហាលំបាក, គេអាចទៅដល់កំពូលភ្នំ ដែលមានកតមួយផ្សេងទៀត ។ អ្នកណាដែលមានជើងមាំមួនអាចគ្រាប់ទៅតាមផ្លូវកន្តារចោតប្រកបដោយភ័យជាច្រើនដែលឡើងទៅតាមចង្កេះភ្នំនោះ, អ្នកពុំពូលភាពគ្រាប់ទៅតាមផ្លូវមួយផ្សេងវែង ហើយតែងឈប់សម្រាកជាច្រើនកន្លែង, អ្នកដំណើរនោះតែងគ្រាប់ទៅតាមផ្លូវភ្នំមានថ្មកំងំពលំបាកជាខ្លាំង ។ អ្នកក្លាហានចំប្រញាប់ប្រញាល់, អ្នកខ្សោយដើរយឺត, អ្នកទាំងអស់មុខជាថ្ងៃណានឹងបានដល់កំពូលភ្នំ មានទឹកកក មានវស្សាព្រះអាទិត្យក្តៅចាំងចែងមិនខាន ។ ការប្រតិបត្តិទីមួយគឺសមាធិដ្ឋ ។ ចូរអ្នកចំដើរដោយខ្ជាប់ព្រះធម៌, ដៀសវាងនូវអំពើល្មើស, ខុស, ចូរអ្នកប្រយ័ត្នត្រង់កម្មដែលធ្វើជោគវាសនារបស់មនុស្ស ហើយចូរអ្នកធ្វើមនោសញ្ចេតនារបស់អ្នកឲ្យទៅត្រាមទាក់ទងអ្នក ។

(មានត)

ព្រះមហា ធែ-រវិស្ស វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ទេសនាជាកិរិយឃោសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ ពេជ ទៃភទ្របទ ឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ (២៦—៩—៤៨)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមគោរពចំពោះព្រះរត្នត្រ័យដោយសេចក្តី ។ លំដាប់តពីនេះ សូមសំដែងធម្មទេសនាចែកជូនដល់អស់លោកអ្នកតាមសមគួរដល់កាល ។ ក្នុងឧកាសនេះ ទើសំដែងអំពីពលរដ្ឋធម៌ ឬហៅថា រុឌ្ឍិទេសពលធម៌ ប្រែថា ធម៌ជាកំឡាំងដល់រដ្ឋ ឬធម៌ញ៉ាំងសេចក្តីចំរើនដល់ប្រទេសមាន ៣ ប្រការ ។ ធម៌នេះបើកើតមានក្នុងប្រទេស និគមជនបទរដ្ឋដែនណា ប្រទេសនិគម ជនបទ ដែននោះ ទើងៅជាប្រទេសថ្លៃថ្លា វិសេស វិសាលជាអារ្យប្រទេស យ៉ាងធាប់ៗ ពុំខាននឡើយ ។ តែលុះត្រាតែប្រកបគ្រប់អង្គទាំង ៣ ទើបបានសម្រេចយ៉ាងនោះមែន ។ ធម៌ ៣ ប្រការនោះ គឺ មុនិសម្បទា (សម្បកបដោយអ្នកជ្ញាជ្ញ) ១, កោគសម្បទា (សម្បកបដោយកោគៈ) ១, សាមគ្គិសម្បទា (សម្បកបដោយសាមគ្គី) ១ ។ មុនិសម្បទា - ប្រទេសនិគមឯណាបរិបូណ៌ពេញលេញដោយអ្នកជ្ញាជ្ញ អ្នកចេះដឹងមិនខ្សោះវិជ្ជា ទោះបីវិជ្ជាណាក៏មានអ្នកចេះដឹងសព្វគ្រប់ ។ ចុះបុគ្គលអ្នកចេះដឹងនេះកើតពីណាមក? ឆ្លើយថា ពលរដ្ឋគឺកស្ត្រ ឲ្យបុត្របុសស្រីរៀនសូត្រគ្រប់គ្នា មិនមានរួញរា

មិនមានគិតចង់បាន កំឡាំងកូនប្រើច្រាស់ ឲ្យមើលថែរក្សាគោក្របី
ស្រែដំរី ឬឲ្យក្លែរកស៊ីឡើយ ម្យ៉ាងទៀតពលរដ្ឋ ឲ្យបុត្រៀនមិនមានរើស
មុខវិជ្ជា ឲ្យតែវិជ្ជាដែលជាហេតុនាំឲ្យបានសុខទឹងចំរើនដល់ត្រកូលទឹង
ប្រទេសជាតិមាតុភូមិ ក៏ត្រូវស្រុះស្រួងឲ្យបុត្រៀន ។ ខ្ញុំរយើងឲ្យកូនរៀន
ច្រើនសំឡឹងប្រយោជន៍ពីវិជ្ជាណាស់ គឺវិជ្ជាណារៀនទៅហើយកាន់ត្រ-
សួងមិនមានច្រាក់បំណាច់ចូលក្រៅ មិនត្រមឲ្យរៀនទេ ដូចវិជ្ជាខ្លួរលេខ,
ខ្លួរសព្ទ, តិកនិក, អាំងស៊ុញ័រ, ជាងឈើ, ជាងកំបោរ, ជាងខ្សែភ្លើង វិជ្ជា
អស់នេះខ្ញុំរយើងស្ទើរគ្មានសោះ សព្វថ្ងៃបើកជការសហរដ្ឋឲ្យត្រសួងទាំង
អស់នេះមក ខ្ញុំរយើងស្ទើរតែទុបដៃឈរមើលហើយ ព្រោះខ្ញុំមិនមាន
ចេះ ហេតុមិនចេះ ព្រោះមិនរៀន ហេតុអ្វីមិនរៀន? ព្រោះរៀនទៅកាន់
ត្រសួងមិនមានកម្រៃចូលក្រៅ ។ មានខ្ញុំរខ្លះទៀត, បើកូនរបស់ខ្លួនឃើញ
កូនគេទៅរៀន ក៏ចង់ទៅរៀនដែរ, បែរជានិយាយប្រាប់កូនថា អាអើយ!
ឯងមើលអញ មិនចេះកខ្វក់មួយផង មានគោក្របីពេញក្រោលអញចិញ្ចឹម
ទាំងអាឯងមួយសំបុកវស់ឋាន ឯងចាំទៅរៀនអី មើលតែគោក្របីប្រសើរ
ជាង ។ នែ! មនុស្សបែបនេះចំជាដេកផ្ដាប់មុខ ដេកមិនងើប, ងើបមិនបើក
ភ្នែក, បើកភ្នែកមិនមើលប្រទេសគេជិតខាង ។ ប្រទេសណាបើមានមនុស្ស
បែបនេះ ស្ទើរតែឯកពាជ្យពុំកើត បើទៅក្នុងប្រទេសណា នាំឲ្យធ្ងន់ផែនដី
ប្រទេសនោះ ព្រោះមនុស្សនោះយកខ្លួលជាទីអាង សមដូចសុភាសិតថា

អលសស្ស កុតោ សិប្បំ អសិប្បស្ស កុតោ ធនំ
អធនស្ស កុតោ មិត្តំ អមិត្តស្ស កុតោ សុខំ
អសុខស្ស កុតោ បុញ្ញំ អបុញ្ញស្ស កុតោ សិរី

ប្រែថា មនុស្សខ្ជិលមិនមានវិជ្ជា បើមិនមានវិជ្ជាមិនមានទ្រព្យ បើមិនមានទ្រព្យមិនមានមិត្រ បើមិនមានមិត្រមិនហានសេចក្តីសុខ បើគ្មានសុខមិនមានព្រះនិព្វាន. ប្រែសេចក្តីថា ម៉ែចមិនទៅព្រះនិព្វានចាំងអស់គ្នាទៅ ថាព្រោះមិនមានបុណ្យ ហេតុអ្វីមិនមានបុណ្យ ព្រោះគ្មានសុខ ហេតុអ្វីមិនមានសុខ ព្រោះគ្មានទ្រព្យសម្បត្តិ ហេតុអ្វីមិនមានទ្រព្យសម្បត្តិ ព្រោះគ្មានវិជ្ជា ហេតុអ្វីគ្មានវិជ្ជា ព្រោះខ្ជិល នែ! នៅលើខ្ជិលជាប្រធានសោះ សមនឹងសុភាសិតបារាំងថា La presse est la mere detous les vie កំដៅជាមេបាបជាមិត្រប់យ៉ាង ខ្ជិលបង្អិនសោក ខ្ជិលបានទុក្ខសោក ខ្ជិលអប្រាជ្ញា ខ្ជិលធ្លាក់នរក ខ្ជិលឥតវិជ្ជា ខ្ជិលចោកសាសនា ខ្ជិលជាតិលិចលង់, ហេតុនេះ សូមសប្បុរសឲ្យកុមារកុមារីរៀនសូត្រឡើង ដើម្បីបំពេញមុនិសម្បទានេះ ។

កាលបើប្រទេសសម្បូរណ៌ដោយមនុស្សអ្នកចេះដឹង ហើយនឹងមានបរទេសរឹបជាន់ ឈ្លួចឈ្មីមើលងាយយើងទេ ដូចជាផ្ទះមានរបងយ៉ាងដិតស្ងួជាស្តាពរ តែបើប្រទេសពេញលេញ ដោយមនុស្សអ្នក

ចេះដឹង ផ្លូវលោកផ្លូវធម៌ស្គុកស្គមច្រើនហើយ បែរជាខ្លះគោគសម្បទាវិញ
ក៏ពុំអាចកសាងក្រៃឡៃបូជាជាតិយើងឲ្យថ្លៃថ្នូរទៅកើត ។

ហេតុនេះ ត្រូវបំពេញគោគសម្បទា ១ ទៀត ឲ្យមានបរិបូណ៌
ឡើង ។ គោគសម្បទា ប្រែថា សម្បុកឲ្យពុកស្គុកស្គមក្រុះក្រវោយ
ទ្រព្យសម្បត្តិ ។ បើមានទ្រព្យសម្បត្តិ ទើបអាចបូជាក្រៃឡៃប្រទេសទៅ
បាន ។ ចុះទ្រព្យសម្បត្តិកើតឡើងពីណាមក? ឆ្លើយថាកើតមកអំពីកម្ម
២ យ៉ាង គឺកសិកម្ម ១ ពាណិជ្ជកម្ម ១ ហើយនឹងមានសម្បទា ៤ យ៉ាង ជា
គ្រឿងអបស្ងួបទៀតផង ។ កសិកម្ម គឺប្រកបស្រែចំការច្បារដំណាំគរបបួរ
ព្រោះ, បើទ្រព្យកើតឡើងដោយឱ្យត់ឱ្យាយហើយ នឹងកសាងប្រទេស
ជាតិពុំកើត, ស្រុកខ្មែរច្រើនតែប្រកបកិច្ចការនេះ ទៅខ្លះត្រង់ពាណិជ្ជការ
ច្រើន ស្ទើរតែគ្មាន ។ ពាណិជ្ជការនោះក្នុងផ្លូវពុទ្ធសាសនា សំដែង
ច្រើនណាស់ដែរ ខ្មែរកាន់ពុទ្ធសាសនាច្រើនមែន ធ្លាប់ដឹងតាមគោល
ដែលថាកែមកថាធម៌ ៨៤០០០ ព្រះធម្មក្ខន្ធ តែខ្មែរកាន់ច្បាលៗ កាន់
ត្រង់ណាស្រាលៗ ចោលត្រង់ណាមានប្រយោជន៍ថ្លៃថ្នូ ហើយពោលថាខ្មែរក្រ, ខ្មែរស្លូត, ខ្មែរបរជាតិជិះជាន់ ព្រោះខ្មែរកាន់ពុទ្ធសាសនា ។
ពោលនេះមិនសមសោះ ចុះជាតិដទៃគេកាន់ពុទ្ធសាសនាដែរ ម៉េចក៏គេថ្លៃ
ថ្នូម្ល៉ះ នេះឃើញជាខាស់ពីកាន់មែន ។ ដូចយ៉ាងពាណិជ្ជការ ក្នុងព្រះ
ពុទ្ធសាសនា មានសំដែងពិស្តារណាស់ ក្នុងទីនេះសូមអធិប្បាយ

តែ ៤ យ៉ាង គឺជង្ឃាណាជ ១, សកដាណាជ ១, នាវាណាជ ១, ឃរាណាជ ១ ។

ជង្ឃាណាជ គឺជួញដោយកំឡាំងស្មង ដូចរែករុញពុនលើ ១ ហារណ៍ដូចយ៉ាងរុញធុងគុយទាវ ធុងទឹកកកអស់នេះ សុទ្ធតែចូលលុយ ពាក់រយក្នុងមួយថ្ងៃ។ ប៉ុន្តែខ្មែរពុំត្រូវការធ្វើសោះ ច្រើនតែខ្ជិមធ្វើមខ្វាច ថោកទាប តែរបស់នេះខ្មែរត្រូវការចាំងក្រែចាំងនាហ្ន៎ មើលចុះអស់លោកអ្នកធ្វើការសព្វថ្ងៃ បើមិនបានគុយទាវឬកាហ្វេ ក៏មិនទាន់ចូលការទុយរួចទេ ។ បើថ្ងៃណាមួយចិនយួនក៏កង ឈប់ធ្វើគុយទាវឬកាហ្វេបីដួនថ្ងៃហើយ មុខជាខ្មែរអ្នកញៀនស្ទាបមាត់ នេះឃើញថាបុនខាងទទួលទានមែន ។

បើធ្វើ ជង្ឃាណាជ ទឹងគេវិញ មានតែក្អួម អំបោស ស្ទឹកត្នោត កំច្រែង ខ្ទមទ័ពមួយស្ទើរតែមើលរួបអ្នកវែកមិនឃើញ ដើរតាមផ្សារទើសគេ-ឯង បើជិះឡាន ជិះកប៉ាល់វិញ ម្ចាស់ឡាន-កប៉ាល់ទោះសូមអង្វរព្រោះគ្មានកន្លែងដាក់របស់ទាំងនោះឲ្យ ដល់លក់អស់របស់ទាំងនោះទៅ បែរចូលផ្ទះចិនវិញសំពត់ ឃ្លានចំនួន ៣-៤ ម៉ែត្រប៉ុណ្ណោះយ៉ាងច្រើន នេះឯង្ឃាណាជខ្មែរ ។

សកដាណាជ ជួញដោយរទេះឡាន ឬរត់ឈ្នួលតាមមគ្គវិថីផ្សេងៗ ។

នាវាណាជ ជួញដោយទូកឬកប៉ាល់ ។ សព្វថ្ងៃបើត្រូវការទៅ

ណាហើយចាំឡាន - កង្កាល់ ខ្មែរគ្មានសោះទេ សុទ្ធតែរបស់បរជាតិជាតិបញ្ចើក្អែកតាំងអស់ ។

ឃរពាណិជ ជំនួញក្នុងផ្ទះ គឺជាក់ទំនិញក្នុងផ្ទះហើយអង្គុយលក់ដូចផ្ទះលក់កង្កែងក្រែងតុំពេញសព្វថ្ងៃ បរជាតិឥតបែកញើសសោះ ចាក់ខ្មែរឡើងគ្នោត មករកផ្ទះឃើញចូលហួសទូដែកទៀត បរជាតិដែលមកសំណាក់អស្រ័យនឹងយើង ដូចជាជាតិបញ្ចើក្អែកទំដើមពាង ប្រដើមដៃពិតមែនរុក្ខជាតិនេះគល់ដល់ដី បើក្មេចខ្លួនមុខជាបញ្ចើក្អែកបឹតយកនុជាវាសអស់ មិនយូរប៉ុន្មានឃើញសុទ្ធតែបញ្ចើក្អែកព្រងើយ ចំណែកស្វឹកពាងដៃរិចរិលអស់នៅមានតែគល់ ខេមរៈយើងសព្វថ្ងៃមិនខុសពីរុក្ខជាតិនេះប៉ុន្មាន រកកល់លើសផង ! ទីក្រុងសព្វថ្ងៃផ្ទះឥដ្ឋផ្ទះថ្ម ក្លើងអគ្គិសនីក្តីចរាលវន្ទាល ម៉ាស៊ីនទឹក ខ្មែរទុកឲ្យបរជាតិនៅប្រើប្រាស់ ស៊ីយកខ្លួនទៅនៅបឹងជិតៗវិញ នេះពេញជាប្រសប់ខ្លួលក្បៀវមែន ស៊ីឲ្យក្បៀវដេកពួក ខ្លួនចុះដេកវានាប ចំជាចិត្តល្អ ។

ខេមរៈតាំងឡាយ កាលបើបានប្រកបពាណិជតាំង ៤ ប្រការនេះ ដូចបានអធិប្បាយខាងលើដោយសព្វគ្រប់ហើយ មុខជាខេមរដ្ឋប្រទេសយើងមៀនកាន់តែវឌ្ឍនធម៌ខាងកោគសម្បុទ្ធយ៉ាងធាប់ៗមិនខាន ព្រោះខ្មែរសម័យនេះប្រស័យសេដ្ឋកិច្ច ប្រទេសថ្មើង ជាតិថ្មៃ ប្រស័យយើង ។ ពាណិជ្ជកម្មនឹងកសិកម្ម តាំងពីរយ៉ាង បើយើងមានចិត្តឲ្យកោគទ្រព្យកុះករស្តុកស្តម្ភ លុះតែយើងចេះប្រកបពាណិជ្ជកម្មនោះធាប់ៗ ចុះបើ

ប្រទេសយើងតេញចិត្តតែត្រង់កសិកម្មប៉ុណ្ណោះ ដូចជាគោស៊ីចំបើងហើយ មិនស្មើស៊ីស្មៅខ្ចីផង ធ្លើម៉េចនឹងបានធំធាត់ឡើង ។ ខេមរជាតិខាំងឡាយ! សកលលោកខាំងមូលកំពុងស្វែងរកទ្រព្យខ្លាំងណាស់, ទ្រព្យនេះមានពីរយ៉ាងគឺ: ទ្រព្យមានវិញ្ញាណ ១, ឥតវិញ្ញាណ ១ ។ ទ្រព្យមានវិញ្ញាណបានដល់មនុស្ស - សត្វគ្រប់យ៉ាង, ទ្រព្យឥតវិញ្ញាណបានដល់ដែនទឹកដីមាសច្រាក់, លោកសន្និវាសខាំងមូលច្របូកច្របល់ នឹងរកទ្រព្យខាំងពីរយ៉ាងនេះណាស់ ។ សព្វថ្ងៃបើយើងមិនប្រឹងប្រយ័ត្ននឹងរក្សាការពារទេ យើងនឹងទៅជាទាស: របស់បរជាតិក្នុងលោកអសារឥតការ ។ ទ្រព្យនោះមានមកហើយអាចនឹងបិតថេរចរកាលទៅបាន លុះតែតែប្រកបដោយសម្បទា ៤ យ៉ាងទៀតគឺ ឧដ្ឋានសម្បទា ប្រឹងប្រែងរក បើរដ្ឋកិច្ចលវិញប្រឹងប្រែងរកមន្តវិជ្ជាណាដែលមានខ្លឹមសារ ដែលរៀនទៅហើយអាចមានប្រយោជន៍ការពារ ជាតិមាតុភូមិបាន យកមកសាបព្រោះបណ្តុះផ្សាំឲ្យពលរដ្ឋគឺកស្តារៀនសូត្រខាំងប្រុសស្រីឡើង ១, អារក្ខសម្បទា បើរៀនចេះដឹងហើយប្រឹងប្រែងរក្សាការពារជាតិមាតុភូមិ នឹងកេរ្តិ៍មត៌ករបស់ជាតិទុកឲ្យមក មិនឲ្យចោរប្លុះរើរុកពន្លូនភូតភរធ្វើបាបបង្ហោតប្រព័ញ្ចន់បាន ១, សមជីវិតា ចិញ្ចឹមជីវិតស្មើៗ គឺឲ្យដឹងប្រមាណក្នុងទ្រព្យរបស់យើងមានកន្លះថវិកាជាតិនៃវដ្ត គឺចាយវាយស្គាល់ប្រមាណមិនដល់ទៅខ្ជីបុលគេប្រើច្រាស់, គឺដំរីធំមិនចង់ធំតាមដំរី ១, កល្យាណមិត្តតា សេតគប់

នឹងមិត្តល្អ គឺមិត្តណាយើងសេពគប់ទៅហើយ មិនសំឡឹងរំពៃតយគន់ចង់បានទ្រព្យសម្បត្តិរបស់យើង គឺស៊ូជួយការពារសត្រូវនឹងណែនាំឲ្យបានសេចក្តីចំរើនដល់យើង ហើយថែមទាំងមិនលាក់បំណែនឹងមិត្តភក្តិ ស៊ូជួយបង្ហាត់បង្រៀនវិជ្ជាណាដែលគ្រូ ហើយជាអ្នកមិននិយាយកុហក ការបោកប្រាស់មិត្រផងគ្នា នេះហៅថា មិត្រល្អ ឬមិត្រដែលយើងគួរសេពគប់ ឬកល្យាណមិត្រ ១ ។ បើមានធម៌ទាំង ៤ យ៉ាងនោះ ទើបអាចការពារផលប្រយោជន៍របស់មាតុភូមិបាន បើប្រាសចាកសម្បទា ៤ នេះហើយ មិនអាចកុះករបំរើនទ្រព្យសម្បត្តិបានឡើយ សូម្បីសម្បត្តិទ្រព្យដែលបុព្វបុរស ទុកឲ្យមិនអាចនឹងការពារបានដែរ ។ ចុះសម្បទាត្រង់ទី ៤ គឺកល្យាណមិត្តតា ថាសេពគប់នឹងមិត្រល្អ តើមិត្របែបណា? មានលក្ខណៈយ៉ាងណាគួរយើងសំគាល់បាន?

បពិត្រសប្បុរសទាំងឡាយ! មិត្រដែលយើងគួរសេពគប់ មានលក្ខណៈ ៣ យ៉ាង សម្រាប់សំគាល់ដើម្បីឲ្យយល់ថាល្អទៅបាននោះ គឺ:

១ - អហិតេ បដិសេធេ មិត្រណែនាំហាមប្រាមមិត្រផងគ្នា មិនឲ្យធ្វើនូវអំពើណា មិនមានប្រយោជន៍ប្រាប់យ៉ាងនេះយ៉ាងនោះថា មិនមែនលទ្ធិប្រព្រឹត្តដើម្បីសេចក្តីចំរើនដល់ប្រទេសជាតិមាតុភូមិទេ ។

២ - ហិតេ អនុវត្តនំ មិត្រដឹកនាំបង្ហាត់បង្រៀនមិនលាក់លៀមបំពោះវិជ្ជា បញ្ញាដែលខ្លួនមាន, វិជ្ជាណារៀនទៅហើយអាចការពារផល

ប្រយោជន៍ប្រទេសជាតិមាតុភូមិ នឹងសត្រូវបច្ចាមិត្តគ្រប់យ៉ាងបាន ទើប
បង្ហាត់បង្រៀនវិជ្ជានោះ ។

៣ – ព្យសនេ អបរិច្ចាគោ មិត្តមិនលះបង់មិត្តក្នុងពេលមាន
សេចក្តីវិនាសអន្តរាយ អសន្តិសុខមកប៉ះពាល់ ស៊ូស្លាប់ជាមួយគ្នា,
បើមានគ្រឿងការពារវិសេសវិសាលឆ្នើម ស៊ូចែករំលែកមិនរិះគន់លាក់
លៀម មិនកំណាញ់ទឹងមិត្តផងគ្នា ។

លក្ខណៈ៣ យ៉ាងនេះហើយជាលក្ខណៈរបស់មិត្ត ឬ កល្យាណ-
មិត្ត. ដែលយើងគួរសេពគប់ ។ កាលបើខេមរៈចេះស្វែងរកមិត្តគួរ
សេពគប់ហើយ ចេះស្វែងរកទ្រព្យសម្បត្តិដោយពាណិជ្ជកម្មដែលជាផ្លូវ
នាំឲ្យចំរើនកោតទ្រព្យយ៉ាងនាប់នោះ ហើយមានធម៌ជាគ្រឿងរក្សាទ្រ-
ព្យដែលរកបានមក មិនឲ្យចោរលួចប្លន់ឆបំបាត់ប្រព័ន្ធបញ្ឆោតបាន
ហៅថា សម្បទា មានឧដ្ឋានសម្បទាជាដើម កល្យាណមិត្តតា សេព
គប់នឹងមិត្តល្អ ដូចបានសំដែងលក្ខណៈសព្វគ្រប់ស្រាប់ជាទីបំផុត ឈ្មោះ
ថាខ្មែរយើងមិនត្រឹមតែយកខ្លួយនឹងដោតវាសនាប្រទេសប៉ុន្នានទេ ហើយ
មានឈ្មោះថាវឌ្ឍនធម៌ជឿនឡើងជាលំដាប់ដែរ ។

តែបើមានមុនីសម្បទានឹងកោតសម្បទា ពេញលេញដោយអ្នក
ប្រាជ្ញ អ្នកចេះដឹងហើយ ស្តុកស្តម្ភមាំមួនដោយកោតទ្រព្យហើយ បើខ្វះ
ធម៌១ ខាងចុង គឺសាមគ្គីសម្បទាមិនបានបរិបូណ៌ដោយការព្រមព្រៀងគ្នា

ក៏មិនអាចនឹងឆ្លៃក្រៃឡៃប្រទេសយ៉ាងណាទៅបាន ។ ហេតុនេះ ត្រូវខ្មែរជាតិមានធម៌នេះផងទៀត គឺព្រមព្រៀងស្មុះស្មៅលមូលមួយគ្នា ទំនើលើក ជាក់ឲ្យព្រមគ្នា ឧទាហរណ៍ដូចទូកមួយដងគ្នា ១២ នាក់ បើម្នាក់បើកក្តោង ម្នាក់ទាញខ្សែក្តោង ម្នាក់លើកចែវ ម្នាក់កាន់ចង្កូតមិនមើលបំណាំគ្នា មិនត្រូវយកដើងពឹក, ហៅថាសាមគ្គីធម៌ កុំថាឡើយមនុស្សប្រតិបត្តិសូម្បីសត្វតិរច្ឆានប្រតិបត្តិក៏បានសេចក្តីសុខដែរ ។ ដូចជំនាន់ដើមមានសត្វចាប ៥០០ បាននៅជាប់លប់របស់ព្រាហ្មណ៍ម្នាក់ សត្វចាបមានសេចក្តីតក់ស្លុតតក់ស័យហួសពេក នាំគ្នាសុះសារឆ្ងាសប្រជាល់ស្មើរបោចពេមក្បាលអស់ គ្រានោះមានចាបមួយស្រែកថា យើងធ្វើយ៉ាងហ្នឹងមុខជាវិនាសមិនខានទេ ហេតុនេះអ្នកទាំងអស់គ្នាត្រូវធ្វើតាមខ្ញុំ ព្រោះខ្ញុំធ្លាប់ប្រតិបត្តិមកបានសេចក្តីសុខជាញយណាស់ ទើបពួកចាបឆ្លើយតបថា មានកលឧបាយដូចម្តេច? ចូរប្រាប់ភ្លាមៗមកយើង, កល់ទឹងទំពេកក្បាលអស់ហើយ, មើលសាមគ្គីធម៌នោះតើរូបពងយ៉ាងណា? ។ ទើបចាបនោះឆ្លើយឡើងថា សាមគ្គីធម៌គ្មានរូបពងអ្វីទេ គ្រាន់តែព្រមព្រៀងស្មុះគ្នាប៉ុណ្ណោះ គឺយើងទាំងអស់គ្នាត្រូវស្មុះគ្នាហើរឡើងតែម្តងព្រមគ្នា ។ ចាបទាំងអស់ទើបប្រតិបត្តិតាម ស្មុះហើរព្រមគ្នារបើកមាត់លប់ទៅ សមនឹងសុភាសិតបារាំងថា l'union fait la force សាមគ្គីជាកំឡាំង, កំឡាំងបំផុត សាមគ្គីមោះមុត ព្រមព្រៀងមូលមួយ កាយវាចាចិត្តស្មុះស្មៅល

ខំជួយ ចូរកែវែងឯង សួយជាតិដល់គ្រែយ ។ ចាបចាំងឡាយបានរួច
ខ្លួនទៅ, នេះកំឡាំងសាមគ្គីធម៌យ៉ាងហ្នឹង ។ យើងខ្មែរជាតិក៏ត្រូវមាន
សាមគ្គីធម៌យ៉ាងនេះដែរ ។

ធម៌ចាំង ៣ យ៉ាងនេះគឺ ១ មុនិសម្បទា, ២ កោគសម្បទា, ៣ សាមគ្គី-
សម្បទា, បើប្រទេសនិគមជនបទរដ្ឋដែនណាមានធម៌ចាំង ៣ យ៉ាងនេះ
គ្រប់គ្រាន់មិនខ្វះ ទឹងក្រៃប្រទេសនិគមនោះថ្ងៃថ្ងៃរបានធាប់ គឺមានអ្នក
ចេះដឹងច្រើន ១, មានកោគសម្ព័ន ១ មានការព្រមព្រៀងស្រុះស្រួល
មូលមាត់គ្នា ១ ។

ធម៌ចាំង៣នេះ ឲ្យឈ្មោះថា ពលរដ្ឋធម៌ ប្រែថាធម៌ជាកំឡាំងដល់
ប្រទេស សំដែងមកប៉ុណ្ណេះសន្ទុតថាចប់ ។

ទីបំផុតធម៌ទេសនានេះ សូមផ្សាយបុញ្ញភាសី គំនរបុណ្យនេះ ចែក
ជូនដល់អស់លោក · អ្នកសប្បុរសចាំងឡាយ ទោះបីធ្វើមរណភាពទៅ
ហើយក្តី នៅរស់ក្តី នៅទីដិតឆ្ងាយក្តី ។

ពុទ្ធាទិអាឝុភាវេន ឝុឞ្បន្នា បេ ឧបទ្ទវា
រោគា បេវិន្តុរាយា ច វិនស្សន្តុ អសេសតោ ។

ដោយអានុភាពនៃព្រះរតនត្រៃជាដើមនេះ ឧបទ្រពនឹងរោគន្តរាយ
ចាំងឡាយដែលកើតហើយ សូមឲ្យវិនាសចេញទៅកុំបីមានសេសសល់
ឡើយ ។

អ្នកឧកញ៉ាឥសរ្សរៃឆ្ងៃ សំ - សុផ

ជាអ្នកប្រៃរៀបរៀង

(តមក)

ក្នុងសាសនាព្រាហ្មណ៍ ប្រកាន់យកចិត្តជាប្រធាន ទើបហៅចិត្តនោះថាអាត្មំន គឺ អត្តា ។ សូម្បីមនុស្សដោយភាគច្រើនក្នុងពេលនេះដែលមិនសូវចំណាន ក្នុងធម៌ជាន់ខ្ពស់ ក៏គង់ដឹងថាចិត្តជាខ្លួនដែរ តែចំពោះចិត្តដែលមិនទាន់បានសេចក្តីបរិសុទ្ធិ ជាព្រះនិព្វាន ឬវិពគធម៌នៅឡើយ ។ សេចក្តីយើញយ៉ាងនោះ គួរពប់ថាវិបល្យាសភ្ញាំងភ្លាត់ខ្លះព្រោះចិត្តជាសង្ខារធម៌ របស់ផ្សំមិនបរិសុទ្ធដូចមាសដែលផ្សំដោយវត្ថុជាតុផ្សេងៗ លុះខ្ចប់ពណ៌សម្បុរគុណប្រយោជន៍ទៅហើយ ទើងហៅថាមាសដូចម្តេចបាន ។ សូម្បីដូច្នោះក៏គង់ល្អជាងមនុស្សដែលតាំងនៅក្នុងភូមិធម៌ជាន់ខ្ពស់ ហើយនោលបដិសេធថាយើងឬខ្លួនប្រាណមិនមាន ។ នាទីព្រះសម្ពុទ្ធព្រះអង្គទ្រង់បដិសេធដោយពាក្យថាអនត្តា (មិនមែនខ្លួនប្រាណ) បានតែមិនធ្លាប់ដួចយើញយ៉ាងច្បាស់ៗសោះ ដួចតែទ្រង់ព្យាករបដិសេធចំពោះសង្ខារធម៌ យ៉ាងក្នុងអនត្តលក្ខណសូត្រ គឺទ្រង់បដិសេធខន្ធ ៥ ដោយពាក្យថាអនត្តា ។ ចំណែកចិត្តនោះរួមជាពីរប្រែការ គឺអសង្ខតធាតុនឹងសង្ខារធម៌ ទើបគួរបញ្ញត្តិចិត្តថាអត្តា តាមសាសនា

ព្រាហ្មណ៍ថាន ព្រោះអដ្ឋកថាចារ្យក៏ថានបញ្ញត្តិហើយដូចគ្នា សម្រាប់ប្រើជាន់ខាងដែលនឹងឈានទៅរកជាន់ខ្ពស់ ទម្រាំនឹងបានដួងអត្តាដែលពិតប្រាកដ ។ សូម្បីព្រះសម្ពុទ្ធជាម្ចាស់ ក៏ទ្រង់យើញថាចិត្តសំខាន់ដូចគ្នា ទើបទ្រង់សំដែងព្រះធម្មទេសនា ដែលជាបដោយចិត្តទុកជាអនេកប្បការ ។ អ្នកសិក្សាទាំងឡាយកំឆ្លាប់ដឹងហើយ ដូចព្រះពុទ្ធភាសិតថា មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា "ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរ សម្រេចហើយអំពីចិត្ត" បិព្ពិទ្ធំ សុខារហំ "ចិត្តដែលហ្វឹកហ្វឺនហើយ នាំសេចក្តីសុខមកឲ្យ" ។ សូម្បីក្នុងសៀវភៅច្បាប់នេះ ក៏ថានិយាយដល់សេចក្តីសំខាន់របស់ចិត្តមកហើយ ក្នុងខាងដើម ។ សេចក្តីពិតថា យើងឬអត្តានោះ មនុស្សលោកវមែងប្រើជាពាក្យនិយាយគ្នា តាំងអំពីមុនព្រះពុទ្ធជាម្ចាស់របស់យើងកើតទៀតក្នុងលោកមកម្ល៉ះ រហូតមកដល់សព្វថ្ងៃនេះ តែសំគាល់ថាជាបញ្ញត្តិចំពោះតែរូបកាយនេះប៉ុណ្ណោះ, តែសេចក្តីចូលចិត្តរបស់សាមញ្ញសត្វលោកនោះចាត់ថាចូលចិត្តខុស ព្រោះជាធម្មជាតិមិនគួរជាយើងជាខ្លួនបានឈ្មោះថា យកចំណែកបដិសេធមកជាចំណែកទទួលគឺចូលចិត្តថាជាអត្តាកន្លងធម៌ដែលជាអនត្តា ដោយអំណាចអវិជ្ជាសេចក្តីល្ងង់ខ្លៅបិទបាំង ។ ក៏កាលបើចូលចិត្តដូច្នោះ តាំងចុះខ្ជាប់ខ្ជួនហើយនឹងឲ្យយើញថា ខន្ធ ៥ នោះ ជាអនត្តានោះវមែងមិនបាន កន្លងកាលតែមិន

បានអត្តាយ៉ាងដែរ ចូលមកជំនួស, សូម្បីខន្ធ ៥ នោះ កើតហើយ
ប្រែប្រួលបែកវិលត់ទៅប្រកាសសេចក្តីមិនទៀង ជាទុក្ខឲ្យឃើញច្បាស់
ក៏គង់មិនឃើញថាជាអនត្តា ព្រោះមិនឃើញអត្តាយ៉ាងដទៃថាមាននឹងល្អ
ជាង, ថែមទាំងធ្លើសេចក្តីចូលចិត្តថា អត្តានោះមិនមានកង្វល់ទាំងពួង ។
តាមមនុស្សដែលឃើញខុសទៅទៀត គួរតែឲ្យថែមសេចក្តីកាចទៅ
ទៀត ។ គ្រានេះវិតវិលល្ងីងល្ងើយចាប់អ្វីមិនបាន ជាប់ចូលក្នុងក្រសែនៃ
មនុស្សឆ្កួត អ្វីៗក៏ចូលជាអនត្តាទៅទំាងអស់ ចតទីណាក៏មិនជាប់ ។
ធម្មតារមែងត្រូវមានជាគូគ្នា : មានអនត្តាក៏ត្រូវមានអត្តាមកជាគូធៀបគ្នា
កង្វល់ទាំងពួងរមែងមានជាពីរនោះ នឹងថា អត្តា (ខ្លួនប្រាណ) មិនមាន
កង្វល់ទាំងពួងនោះមិនបាន ។ មនុស្សដែលមិនឃើញអត្តា កង្វល់ព្រះ
និព្វាន ដោយសេចក្តីចូលចិត្តរបស់ខ្លួនឯងហើយ សូម្បីនឹងនិយាយថា
ខន្ធ ៥ ជាអនត្តាក្តី ឬនិយាយថាអត្តាមិនមានកង្វល់ទាំងពួងក្តី ក៏ជាសេចក្តី
ដឹងមិនធៀបគ្នា គឺដឹងតែម្ខាង មិនដឹងទាំងពីរចំណែក ដឹងយ៉ាងនោះជា
សេចក្តីដឹងមិនពិត មិនមែនសេចក្តីដឹងដែលកើតអំពីបញ្ញារបស់ខ្លួនឯង
គ្រាន់តែដឹងតាមសញ្ញាដែលចាំបាន ឬ ដឹងតាមតម្រាដែលថាទុកប៉ុណ្ណោះ
គឺបានឃើញតម្រាឬ ឮគេនិយាយថា ខន្ធ ៥ ជាអនត្តា, កាលគិតដល់
ខន្ធ ៥ ពិចារណាចុះទៅកាលណា សញ្ញាដែលចាំទុកបានក៏ប្រញាប់
ចេញមកដណ្តើមប្រាប់មួយរំពេចថា មិនទៀងជាទុក្ខ ជាអនត្តា តែម្តង

ប៉ុណ្ណោះ ក៏អាចបញ្ជេញបានថាខ្ញុំឃើញអនត្តាហើយ គឺខន្ធ ៥ ជាអនត្តា មែនៗ, តែចិត្តនៅពារ៉ាំរ៉ែវ ព្រោះកាលបើបដិសេធខន្ធ ៥ ចេញហើយ ក៏មិនឃើញអ្វីដែលនឹងចាប់ ក៏ត្រឡប់ទៅចាប់ខន្ធ ៥ នោះម្តងទៀត ជាអត្តាទៀតហើយ, លុះពិចារណាថែមទៀត សញ្ញានោះក៏ថ្កាប់ថាមិនឃើញអ្វី ក្នុងខន្ធទាំង ៥ ដែលជាសារៈបានឡើយ ក៏ជាអនត្តាទៀត ហើយក៏វិលចូលទៅជាអត្តាទៀត, គ្រានេះអត្តា អនត្តា ក៏ដេកច្របូកច្របល់គ្នានៅទាំងពីរ ក្នុងខន្ធ ៥ នោះឯង, យ៉ាងនេះគួរហៅថា អនត្តា-សញ្ញា ឬ អនត្តាតម្រា ដូចយើងបានឮអ្នកឯណាគេនិយាយថា "មិនមាន" ដែលជាពាក្យបដិសេធ យើងក៏និយាយតាមគេផងថាមិនមាន តែលុះអ្នកឯណាម្នាក់ទៀតសួរឡើងថា អ្វីមិនមាន? យើងក៏ត្រូវតបថាមិនដឹង អ្នកដែលសួរក៏ដឹងថាយើងមិនដឹង ធៀបថាយើងមានធនបត្រក្លែង (ក្រដាសថ្កាក់ក្លែង) តែយើងមិនស្គាល់ កាលអ្នកស្គាល់ម្នាក់ឃើញ ក៏ថ្កាប់យើងថា ធនប័ត្រនេះក្លែងទេ ហើយយើងក៏ចំណាំធនប័ត្រនោះ ហើយថ្កាប់គេដទៃៗថា ធនប័ត្រសន្ធឹកនេះក្លែង តែលុះអ្នកឯណាម្នាក់ទៀតគេសួរយើងថា ធនប័ត្រពិតនោះដូចម្តេចទៅ? យើងក៏ពាល់មិនអាចថ្កាប់គេថា ធនប័ត្រពិតនោះដូចម្តេច ព្រោះដូច្នោះ យើងឯងក៏ពាប់ថាជាអ្នកមិនស្គាល់ធនប័ត្រក្លែងនោះដែរ ព្រោះមិនស្គាល់ធនប័ត្រពិតនោះ ពីមុនមក គ្រាន់តែស្គាល់តាមគេថ្កាប់ ប្រៃថាដឹងតាមសញ្ញាប៉ុណ្ណោះឯង

មិនមែនសេចក្តីដឹងពិតរបស់យើង ។ ឯសេចក្តីដឹងដែលកើតអំពីប្រាជ្ញារបស់ខ្លួនពិត។ នោះត្រូវដឹងតាំងពីខាងទុក្ខ ទឹងខាងបដិសេធ ដឹងតាំងខាងរបស់ពិត ដឹងតាំងខាងរបស់ផ្ទឹម ទើបចាត់ជាសេចក្តីដឹងពិត ។ ហេតុនោះ មនុស្សដែលមិនស្គាល់អត្តាហើយ ទឹងស្គាល់ថាខន្ធ៥ជាអនត្តានោះមិនបានទេ សូម្បីឃើញ ឬនិយាយ ក៏ឃើញឬនិយាយតាមសញ្ញាប៉ុណ្ណោះ មិនមែនការដឹងពិតឬការឃើញពិតរបស់ខ្លួនឯងទេ ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទឹងអរិយសាវ័កបស់ព្រះអង្គដែលជាអ្នកមានញាណចក្ខុដ៏សម្រែចមកអំពីអរិយមគ្គ លោកឃើញថាខន្ធ៥ជាអនត្តា ព្រោះលោកបានធម៌យ៉ាងដូចនៃ គឺព្រះនិព្វានជាអត្តាហើយ សេចក្តីដឹងរបស់លោក ចាត់ជាសេចក្តីដឹងពិត ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ទឹងព្រះបញ្ចវគ្គិយថា អមតធម៌តថាគតបានហើយ លុះតមកព្រះអង្គទ្រង់សំដែងខន្ធ៥ទាំងនោះថាជាអនត្តា ឲ្យព្រះបញ្ចវគ្គិយស្តាប់ ។ ដូច្នេះសូមលោកអ្នកពិចារណាមើលចុះ មនុស្សដែលមិនបានអត្តា ទឹងនិយាយថាខន្ធ៥ ជាអនត្តាដូចម្តេចបាន ។ ឯសាមញ្ញសត្វលោក ដែលប្រកាន់ខន្ធ៥ ជាអត្តា មិនឃើញថាជាអនត្តានោះ ក៏ព្រោះមិនបានញាណចក្ខុដែលសម្រែចមកអំពីអរិយមគ្គ យ៉ាងព្រះអរិយៈជាម្ចាស់, ឈ្មោះថា យកខាងខ្លួនសង្កត់ខាងបដិសេធ ដូចមនុស្សដែលប្រើមាសក្លែង ចូលចិត្តថាមាសពិត សូម្បីអាការក្លែងរបស់មាសនោះ

ប្រាកដឲ្យគេឃើញក៏ដោយ តែព្រោះគេដឹងតែម្នាង់ មិនឃើញមាស
យ៉ាងដទៃឡើយ ម្នាង់ចូលមកធៀបផង ក៏ចូលចិត្តថានេះហើយមាសពិត យក
ខាងទទួលសង្កត់ខាងបដិសេធទុក ក៏កាលគេឃើញថានេះឯងមាសសុទ្ធ
ហើយ ធ្វើម្តេចនឹងយល់ថាមាសក្លែងកើត ។ លុះកាលណាគេបានឃើញ
មាសមួយយ៉ាងដែលជារបស់ពិត មានពណ៌សណ្ឋានគុណប្រយោជន៍
ល្អជាងដែលគេប្រើនោះ កាលណោះគេទើបត្រឡប់ធ្វើសេចក្តីចូលចិត្ត
ជាថ្មីថានេះឯងជាមាសសុទ្ធ ដែលយើងប្រើមកនោះជារបស់ក្លែង, គ្រានេះ
អាការក្លែងរបស់មាសដើម ក៏ប្រកាសច្បាស់ឡើង ប្រាកដដល់ម្ចាស់
របស់មាសក្លែង ព្រោះគេបានឃើញមាសពិតៗ ឡើងទៀត ដែលនឹង
ធៀបឲ្យឃើញបានថាផ្សេងគ្នា. សេចក្តីដឹងរបស់អ្នកនោះចាត់ថាជាការ
ដឹងពិតមិនឃ្លៀងឃ្លាត ព្រោះបានសេចក្តីឈ្វាសវៃចាំងខាងទទួលនឹង
ខាងបដិសេធ ។ ដូច្នោះសាមញ្ញសត្វលោកអ្នកមានអវិជ្ជាបិទបាំង កាល
នៅមិនទាន់បានញាណចក្ខុ ដែលដូចជាពន្លឺស្វាងធ្លុះធម៌ចាំងពួងនឹង
អសង្ខតជាតុ មិនបានសេចក្តីបរិសុទ្ធិជានិព្វានដែលជាអត្តាពិតប្រាកដ
ហើយទេ តែងចូលចិត្តប្រកាន់ខន្ធ ៥ ថាជាអត្តា អនត្តាកងខន្ធ ៥ នោះក៏
រកប្រាកដដល់អ្នកល្ងង់ខ្លៅនោះគ្មាន, លុះកាលអសង្ខតធាតុបានសេចក្តី
បរិសុទ្ធិជានិព្វាន បានអត្តាយ៉ាងដទៃប្រសើរវិសេសហើយ ដកអត្តាកង
ខន្ធ ៥ ដែលចូលចិត្តខុសនោះចេញ ខន្ធ ៥ ក៏ជាអនត្តាមួយវារពេច ទើបភប់

ថាបានឃើញអនត្តាពិតៗ មិនមែនអនត្តាសញ្ញាឬអនត្តាតម្រា ដូចពោលហើយ ។ ព្រោះហេតុដូចតណិនាមកនេះឯង ក្នុងលោកទើបមិនមានអ្នកឯណាស្គាល់ ពាក្យថាអនត្តាមិនបានប្រើនិយាយគ្នា, មានចំពោះសេចក្តីដឹងសេចក្តីឃើញ របស់ព្រះពុទ្ធជាម្ចាស់ក្នុងព្រះពុទ្ធសាសនាប៉ុណ្ណោះ ។ អ្នកសិក្សាធម៌ចូលចិត្តអាងណាស់ថា អនត្តាជាធម៌ខ្ពស់ផុត តែមនុស្សក្នុងលោកមិនមានអ្នកណាស្គាល់, ក្នុងលទ្ធិសាសនាណាក៏មិនមានសំដែងអំពីសេចក្តីដឹងរបស់ព្រះពុទ្ធជាម្ចាស់យ៉ាងខ្ពស់បំផុត ព្រោះសាមញ្ញសត្វលោកក្តី មេសាស្តាចារ្យ មេគណាចារ្យឯណាក្តី មិនស្គាល់អត្តានោះឯងទើបមិនស្គាល់អនត្តា, ដែលមិនស្គាល់អត្តា ក៏ព្រោះមិនបានអរិយមគ្គ ៨ ប្រការ, អរិយមគ្គនោះសោតមានចំពោះក្នុងពុទ្ធសាសនា ជាសេចក្តីដឹងរបស់ព្រះពុទ្ធជាម្ចាស់ប៉ុណ្ណោះ ។ (មានត)

អ្នកមិនចេះឆ្អែត ៤ ពួក

ស្តេចមិនឆ្អែតសម្បត្តិអាណាបក្រ,
ប្រាជ្ញមិនឆ្អែតសុភាសិតពុទ្ធដីកា,
មហាសមុទ្រមិនឆ្អែតស្ទឹងនានា,
ឥឡេត្រាមិនឆ្អែតគន់រូបគាប់ ។

គុណសម្បត្តិនៃអ្នកទេសនា

ព្រះទេពសត្ថាស្សរៈ - ហោយ ក្រុមជំនុំព្រះត្រៃបិដក

តែងរៀបរៀង

លោកអ្នកទេសនាឬអ្នកនិយាយត្រូវប្រកបដោយគុណសម្បត្តិអ្វីខ្លះ? នេះជាប្រស្នាដែលគួរឆ្លើយដោយពិស្តារ ។ គុណសម្បត្តិរបស់លោកអ្នកទេសនាឬអ្នកនិយាយក្នុងមួយៗ មាន ២ ប្រការ គឺ គុណសម្បត្តិសាម័ញ ១ គុណសម្បត្តិជាន់ខ្ពស់ ១ ដូចសេចក្តីតទៅនេះ

១ — មាត៌រប៌ាស

២ — បិត្តអង់អាប

៣ — ឥតអៀនខ្មាស

៤ — សម្លេងឮខ្លាំង ។

គុណសម្បត្តិ ៤ យ៉ាងនេះមនុស្សសាម័ញច្រើនទទួលដឹង ស្គាល់និយមថាជាគុណសម្បត្តិល្អម្យ៉ាងដែរហើយ តែមិនទាន់ឋិតថាជាគុណដ៏ប្រសើរខ្ពង់ខ្ពស់ទេ, បើគ្រាន់តែមានគុណសម្បត្តិសាម័ញ ៤ យ៉ាងប៉ុណ្ណោះនឹងត្រូវបាត់ទៅជាទោសកំហុសដែងវិញខ្លះពុំខាន ព្រោះ :-

មាត៌រប៌ាស គឺសំដៅយកមាត់ដែលរួស ដែលនិយាយញាប់ ។ ការនិយាយរួសញាប់នេះមិនមែនសុទ្ធតែជាគុណទាំងអស់ទេ វាមែនធ្លាក់

ទៅជាគោសវិញខ្លះជាធម្មតា គឺនាំឲ្យក្លាត់ពាក្យពេចន៍, ឲ្យជ្រុលជ្រួសពាក្យដែលគួរលើកនិយាយមុន ត្រឡប់ទៅជាខោះក្រោយ, ឯពាក្យដែលគួរជាក់ទៅខាងក្រោយត្រឡប់ទៅជាមុន ។ ការនិយាយញាប់នេះជាគោសនាំឲ្យខ្លះរបៀបពាក្យរៀបរយគឺនាំឲ្យកម្រងពាក្យក្នុងប្រយោគដែលនិយាយនោះមិនមានជើងសម្ព័ន្ធត្រឹមត្រូវតាំងស្រៈព្យញ្ជនៈ ដែលត្រូវប្រកបឲ្យច្បាស់លាស់តាមសម្ងេឝអក្សរក៏មិនពេញបរិបូណ៌ តែងខ្វះខាតខ្លះសម្ងេឝជ្រុងស្រៈព្យញ្ជនៈនោះជាដរាប ។

ការនិយាយរហ័សនេះ បើបណ្តាយយូរៗ ទៅជាហេតុឲ្យធ្ងាប់ធ្ងាយប្រយោគនិយាយ នោះខ្លះសេចក្តីអស់ទៅក៏មាន ឲ្យពាក្យនោះរត់លឿនហួសគំនិតគាល់តែខ្លួនឯងក៏ស្តាប់មិនបានទៅក៏មាន ។ ការដែលថ្នឹកនិយាយឲ្យបានញាប់ហើយឲ្យច្បាស់លាស់គ្រប់ម៉ាត់នេះ ជាការក្រណាស់ ច្រើនតែនាំឲ្យខ្លះរបៀបគ្រប់យ៉ាង ដួនកាលគាន់តែញាប់មែនប៉ុន្តែចេះតែជួន ។ សាំ ។ ដដែល ។ មិនលឿនចំណេញទៅមុខសោះ តែបើអាចនិយាយបានទាំងរហ័សទាំងត្រឹមត្រូវក៏ជាការប្រសើរណាស់ ។ ត្រង់ពាក្យដែលគេធ្លាប់និយាយថា "សំដីជាឯក លេខជាខោ" នោះមិនមែនសំដៅយកសំដីញាប់ឡូប។ នោះឡើយ គឺសំដៅយកសំដីដែលចេញទៅជាពាក្យមានរបៀបសណ្តាប់ធ្នាប់, មានបែបបទត្រូវតាមច្បាប់ទំលាប់ជាសំដីដែលមានគំនិតដើរមុនទើបមានសម្ងេឝចេញទៅជាខាងក្រោយហើយជាពាក្យមានគោលជាគ្រឿងអាង ។

បិត្តអង់អាប គឺចិត្តក្ងៀវក្ងាវ, មោះមុតមិនញាប់ញ័រ, មិនតក់ស្លុត។ ការនិយាយប្តេជ្ញានាដោយចិត្តអង់អាចនេះ ដូនតាលក៏មានអាការសមរម្យ ដូនតាលក៏មិនសមរម្យដែលគួរឲ្យអ្នកស្តាប់រិះគន់ចាន ។ ការនិយាយនេះ បើបណ្តាយ ឲ្យចិត្តអង់អាចនិយាយឡើងដោយការលុះកង់អំណាចរបស់ចិត្តអង់អាចនោះ ក៏ច្រើនតែហួសប្រមាណនាំឲ្យខូចឲ្យខុសច្បាប់ ព្រោះអាងកម្លាំងសេចក្តីអង់អាចដែលនាំឲ្យកាន់ច្រឡំក៏មាន នាំឲ្យមានសេចក្តីប្រកាន់ខុសដោយអាងវោហារក៏មាន ។

ការទេសនាប្តូនិយាយ ដែលលុះអំណាចចិត្តអង់អាច ខ្លាំងហួសហេតុពេកនេះ ច្រើនតែទៅជាទោស គឺនាំឲ្យភ្លាត់ភ្លាំងច្បាប់ធំលាប់, នាំឲ្យភ្លេចគិតអំពីហេតុផល, អំពីការទើសទាក់ ក្នុងច្បាប់ទាំងពួង ព្រោះហេតុនោះ ការនិយាយដោយកម្លាំងចិត្តអង់អាចហួសពេកមិនមែនសុទ្ធតែជាគុណទាំងអស់ទេ តែងត្រូវប្រទៅជាទោសវិញខ្លះមិនខាន. មុនអំពីការទេសនា ប្តូនិយាយ ត្រូវស្ងប់កម្លាំងចិត្តឲ្យល្មម, ត្រូវថ្នមចិត្តឲ្យទន់ធន់ល្អ ទើបនិយាយជាការប្រសើរ ។ ព្រោះថាបើកម្លាំងចិត្តអង់អាចខ្លាំងពេកលុះត្រូវនិយាយក៏ច្រើនតែប្រើវោហារហួសប្រមាណ ដែលគួរឲ្យគេរិះគន់ចាប់ថ្នាក់ចាន ។

ពាក្យអៀងខ្មាស គឺសរជនខាងនិយាយកងកាលមិនគួរ ។ ការទេសនាប្តូនិយាយដែលប្រកបដោយសេចក្តីអៀនខ្មាសពេក ក៏សំដែងមិន

កើតដែរ តែបើបណ្តាយឲ្យតតះអៀនខ្មាសៈសោះក៏មិនកើត នឹងនាំឲ្យទៅជាទោស ព្រោះហេតុមិនចេះអៀនខ្មាស ។ ការនិយាយដោយឥតអៀនខ្មាសនេះច្រើនតែនាំឲ្យថោកភាព នាំឲ្យចុះតម្លៃសំដីរបស់ខ្លួន បើមិនច្រើនក៏តិច ឃើញថាជាទោសមួយកង្វះការនិយាយ ព្រោះហេតុនោះ កាលបើត្រូវការនិយាយឲ្យគេស្តាប់ ត្រូវពិនិត្យខ្លួនឯងមុនជាក់ឲ្យល្មមសិន គឺកុំអៀនខ្មាសពេក កុំឥតអៀនខ្មាសពេក ។

ការប្រព្រឹត្តធ្វើដោយកាយក្តី វាចាក្តី ចិត្តក្តី ដែលឥតអៀនខ្មាសនោះច្រើនតែត្រឡប់ទៅជាទោសគួរឲ្យគេនិន្ទាតបជ្រាយឃ្លានជាជាងប ។

ការសំដែងធម៌អាចប្តូរបកាសសេចក្តីអំពីចប្បាប់បញ្ញត្តិណាមួយ, បើនិយាយដោយប្រធាននៃការសំដែង មាន ២ យ៉ាងគឺ ឧគ្គហមុខ = ការសំដែងផ្ទាញ់ផ្ទាល់ជាប្រធាន ១, បគ្គហមុខ = ការសំដែងលើកសរសើរជាប្រធាន ១ ។

ការសំដែងប្រាប់ទោសអំពីសេចក្តីប្រព្រឹត្តខុស ចំពោះបុគ្គលអ្នកប្រព្រឹត្តខុសហើយទាញទៅរកអំពីការប្រព្រឹត្តត្រូវ ដើម្បីផ្ទាញ់ផ្ទាល់សង្កត់សង្កិនដោយធម៌ដោយវិន័យឲ្យអ្នកស្តាប់ពិចារណារកហេតុផលខុសត្រូវឲ្យឃើញចំពោះខ្លួនឯង; ការសំដែងដូច្នេះហៅថា "ឧគ្គហមុខ" ។

ការសំដែងប្រកាសគុណនៃសេចក្តីល្អ ដែលពួកអ្នកសប្បុរសបានប្រព្រឹត្តគោរពជឿកាន់ដោយត្រឹមត្រូវ ហើយទាញទៅរកអំពី

ការប្រព្រឹត្តផ្សេង។ ដើម្បីលើកសរសើរគាថាធម៌នេះ, ដូច្នេះ ហៅថា "បគ្គហមុខ" ។

ការសំដែងនេះ ទុកជាមានច្រើនយ៉ាងក៏គង់រួមមកដោយខ្លីមានតែ ២ យ៉ាងប៉ុណ្ណោះ ។ ការសំដែងធម៌ឬសូត្រឬធម៌ណាមួយដែលអាចធ្វើទៅបាន ក៏ព្រោះអាស្រ័យហេតុដែលឥតអៀនខ្មាស ទើបប្រព្រឹត្តទៅបាន ប៉ុន្តែបើសំដែងអាការវាតអាត តតែគ្រងល្អែង ឥតអៀនខ្មាសគ្រលហួសពេក ក៏ត្រឡប់ទៅជាទោសដល់ខ្លួនដែលនាំឲ្យថោកបុក ខូចតម្លៃចរិយាធម៌របស់ខ្លួនជាច្រើនដង ដោយហេតុតែដួញនិយាយឥតអៀនខ្មាស ។

សម្លេងឮខ្លាំង គឺសម្លេងលាន់ភ្ញាក់រំពង ជះចូលទៅប៉ះសោតប្បសាទនៃបុគ្គលដទៃ ។ សម្លេងឮនេះជាសម្បត្តិដ៏ប្រសើររបស់អ្នកនិយាយ ដែលអាចនាំឲ្យអ្នកស្តាប់ចូលចិត្តស្តាប់ជាប់តទៅ ឃានយូរមិនធាប់ធុញគ្រាន់ ដោយហេតុថា មិនចាំបាច់ធ្វើឥរិយាបថផ្លាស់ប្តូរណាស់ក៏អាចឮច្បាស់ឃាន ។ តែសម្លេងខ្លះគ្រាន់តែឮខ្លាំងប៉ុន្តែមិនពីរោះ។

សម្លេងពីរោះនេះពាក្យថាជាសម្បត្តិដ៏ល្អ, សូម្បីព្រះសម្មាសម្ពុទ្ធព្រះអង្គក៏មានលក្ខណៈដោយសម្លេងនេះដែរ ។ ឃាលីថា "ព្រហ្មស្សរោ កតក" ប្រែថា "ព្រះដ៏មានបុណ្យ មានសម្លេងដូចជាសម្លេងនៃព្រហ្ម" សម្លេងពីរោះនេះជាលក្ខណៈល្អមួយរបស់ព្រះសម្មាសម្ពុទ្ធ ។ សម្លេងពីរោះមានអង្គ ៥ ប្រការ គឺ:

១ – វិស្សដ្ឋោ សម្ងួនរលីងស្អាត

២ – វិញ្ញេយ្យោ សម្ងួនច្បាស់លាស់ងាយយល់បាន

៣ – មញ្ជុ សម្ងួនស្រទន់ពីពេះ

៤ – សវនីយោ សម្ងួនគួរឲ្យចង់ស្តាប់

៥ – ពិន្ទុ សម្ងួនត្រូវចំណុចចិត្តអ្នកស្តាប់

៦ – អវិសារី សម្ងួនមិនត្រែក មិនបែក

៧ – គម្ភីរោ សម្ងួនជ្រៅរំពងឮបានឆ្ងាយ

៨ – និន្នាទី សម្ងួនបន្ធឺមានទឹកដម ។

គុណសម្បត្តិដោយសម្ងួនដូចរៀបរាប់នេះជាការប្រៃសើរដោយខ្លែកដែរ តែបើអ្នកដែលគ្រាន់តែមានសម្ងួនប៉ុណ្ណោះ ក៏មិនទាន់សម្រេចផលល្អនៅឡើយ ព្រោះថាសម្ងួននេះ គ្រាន់តែជាគ្រឿង១បករណ៍នៃការសំដែងប៉ុណ្ណោះ កាលបើគុណសម្បត្តិខាងដើមមិនមានទេ ឬការចេះដឹងមានតិចតួចមិនគ្រប់គ្រាន់ក៏ប្រើប្រាស់សម្ងួននោះឲ្យមានប្រយោជន៍មិនកើតមួយទៀត សម្ងួននេះបើខ្វះការចេះដឹង, ខ្វះសីលធម៌សណ្តាប់ធ្នាប់ ក៏យកជាការមិនបាន ព្រោះមិនទាន់គ្រប់លក្ខណៈនៃគុណសម្បត្តិនៅឡើយ ។

គុណសម្បត្តិរបស់លោកអ្នកទេសនា ឬអ្នកនិយាយមាន ៤ យ៉ាង ដូចអធិប្បាយមកនេះ ជាគុណសម្បត្តិជាន់ទាប ឬសាមញ្ញពាយ៉ាង មិនទាន់រាប់ថាជាគុណសម្បត្តិជាន់ខ្ពស់គ្រប់លក្ខណៈនៅឡើយ ។

លោកអ្នកទេសនា ឬអ្នកនិយាយការត្រូវមានគុណសម្បត្តិ ៤ យ៉ាង ទៀត ទើបពេញទីជាគុណសម្បត្តិជាន់ខ្ពស់ដែលគួរសរសើរដោយពិត ។

គុណសម្បត្តិជាន់ខ្ពស់ ៤ យ៉ាងនោះ គឺ :

១ - ការចេះដឹងពាក្យព័ចន៍ យល់កិច្ចការច្រើន ចាំគោលធម៌-ច្បាប់ជាន់ច្រើន

២ - មានបដិភាណ គឺប្រាជ្ញាវាងវៃប្រកបដោយសមត្ថភាព

៣ - មានសប្បុរិសធម៌ ៧ ប្រការគ្រប់គ្រាន់

៤ - មានចិត្តបរិសុទ្ធ មិនញាប់ញ័រដោយលោកធម៌ពេក មិនប្រកបដោយអគតិ ។

គុណសម្បត្តិសាមញ្ញខាងដើម ៤ យ៉ាង ព្រមទាំងគុណសម្បត្តិជាន់ខ្ពស់ ៤ យ៉ាងនេះទៀតផ្សំបញ្ចូលគ្នាត្រូវជាគុណសម្បត្តិ ៨ យ៉ាង ។ លោកអ្នកទេសនា ឬអ្នកនិយាយការណាមួយ ក្នុងទីប្រជុំ, កាលបើប្រកបដោយគុណសម្បត្តិ ៨ យ៉ាងដូចពោលមកនេះ ទើបចាត់ថាជាបុគ្គលប្រសើរបំផុតក្នុងចំណោមអ្នកសំដែងទាំងឡាយ ។

លោកអ្នកសំដែងត្រូវប្រកបដោយអង្គ ៥ យ៉ាងតទៅទៀត គឺ :

១ - សំដែងតាមលំដាប់លំដោយ មិនកាត់ មិនរំលងគោលសេចក្តី

២ - សំដែងដោយអាងហេតុផល កុំឲ្យច្រឡំដោយធម្មាធិដ្ឋាន នឹងបុគ្គលាធិដ្ឋាន

៣— សំដែងដោយមេត្តា ប្រាថ្នាឲ្យបានប្រយោជន៍ដល់អ្នកស្តាប់

៤— មិនត្រូវសំដែងដោយការសំឡឹងលាកសក្ការៈ

៥· មិនត្រូវសំដែងដោយការលើកខ្លួនហើយបន្ទុះបង្អាប់អ្នកដទៃ

គឺសំដែងឲ្យសមតាមធម៌ដែលពិតមែន ប្រកបដោយហេតុការជាក់លាក់ ។

គុណសម្បត្តិទាំងនេះជាការគ្រប់គ្រាន់, លោកអ្នកទេសនាឬអ្នកធ្វើ

សន្ទិសីទ កម្រមានឆ្មាមានគុណសម្បត្តិទាំងនេះគ្រប់គ្រាន់ក្នុងខ្លួន ព្រោះហេតុ

នោះបណ្ឌិតគប្បីសិក្សាហាត់រៀនអប់រំជាមុន ។ វិធានការនៃកិច្ចសិក្សា

ដើម្បីឲ្យមានគុណសម្បត្តិទាំង ៨ យ៉ាងនេះ មិនមែនលើសវិស័យរបស់

មនុស្សគ្រប់គ្នាទេ គឺអាចហាត់ពត់ចិត្តខ្លួនានបង្វឹកឲ្យបានបទបែបនោះ។

ខ្លះមិនខាន បើទុកជាមានន័សម្ព័យធម្មជាតិរឹងថ្ឈឹងយ៉ាងណាក៏មិនហួសអំពី

ការបង្វឹកការខ្លួនានដ៏ក្រៃដែរ, បើទុកជាមិនបានគុណសម្បត្តិនោះគ្រប់

គ្រាន់ក៏គង់បានខ្លះមិនខាន ។

ចប់ ដោយសង្ខេបប៉ុណ្ណោះ ។

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុំង-ប៉ែម
អាចារ្យសាលាចាលីវង់ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ឌាធ្រក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យអ្នកពិនិត្យកែ

(តមក)

ស្មោះត្រង់បំពោះមុខក្រសួង.— មុខក្រសួងបានដល់ការណ៍យកចិត្ត ចំណែកខ្លួន នឹងការណ៍យកចិត្តដែលខ្លួនបានទទួលយល់ព្រមធ្វើជាមួយអ្នកដទៃ ឬធ្វើដោយទំនើងចិត្តខ្លួនឯង ព្រមទាំងការងារបស់ញាតិមិត្តពួកគណៈ ដែលគួរជួយដោយសាមគ្គីធម៌ ដែលខ្លួនត្រូវទទួលខុសត្រូវតាមហានៈរបស់ខ្លួនផង ដូចយ៉ាងខ្លួនជាឪពុកម្តាយរបស់គេ ជាបុត្រធីតារបស់លោក ឬជាអ្នកគ្រប់គ្រងគេ ជាអ្នកនៅក្រោមការគ្រប់គ្រងរបស់លោក ដែលកាលបើការងារនោះដំណើរទៅដោយរៀបរយល្អ ក៏ជាសេចក្តីល្អរបស់យើង បើវិនាសអន្តរាយខូចខាតទៅ ក៏ជាសេចក្តីខុសរបស់យើង ។

ការទៀងត្រង់នឹងត្រូវតាមធម៌ ជាហេតុឲ្យធ្វើពិតៗនឹងត្រឹមត្រូវបានតាមសមគួរដល់នាទី គឺការងារជាចំណែកខ្លួននឹងការងារដែលខ្លួនយល់ព្រមធ្វើជាមួយគេ ។ ដូច្នេះ ត្រូវកុំមានសេចក្តីប្រមាទធ្វេសប្រហែសកុំមាក់ងាយដំអក់ដំអឹង ឬមិនពិចារណា ឬក៏គេចវេះបៀសវាងឡើយ

ត្រូវចំយកចិត្តទុកដាក់ពិនិត្យមើលនឹងចំរក្សានាទីរបស់ខ្លួនឲ្យបានសម្រេច ផលល្អ សមដល់បំណងរបស់ខ្លួនយើង ឬសមដល់បំណងរបស់លោកអ្នក ដែលទុកចិត្តលើខ្លួនយើង ត្រូវធ្វើខ្លួនឲ្យជាទីជឿនៃមនុស្សជាច្រើន នេះជាលក្ខណៈនៃសេចក្តីស្មោះត្រង់ចំពោះមុខក្រសួង ។

យើងវាមែងមាននាទីប្រចាំខ្លួនដូចគ្នាទាំងអស់ តែនាទីនោះនឹងចំរើនកំរៃពោះយើងស្មោះត្រង់ចំពោះនាទីនោះ ។ ដូច្នេះ ត្រូវឲ្យស្គាល់ការងារក្នុងមុខក្រសួង ត្រូវរៀនរកវិធីដែលនឹងធ្វើឲ្យការងារចំរើនលូតលាស់ទៅខាងមុខ ត្រូវតាំងចិត្តថានឹងចំធ្វើឲ្យលុះត្រាតែបានសម្រេច មិនត្រូវគេចវេះ ឬលះបង់ធុរៈ មិនត្រូវបណ្តោយឲ្យការងារក្នុងមុខក្រសួងមិនបានសម្រេច នឹងមិនត្រូវយកពេលវេលានៃការងារ ក្នុងមុខក្រសួងទៅប្រើធ្វើកិច្ចដទៃទៀតទេ ត្រូវធ្វើការងារឲ្យពេញនឹងទៀងទាត់តាមពេលវេលា មិនត្រូវធ្វើក្រោយពេលកំណត់ ហើយឈប់មុនពេលកំណត់ឡើយ ។ បើយើងស្រឡាញ់ជីវិតរបស់យើងៗ ត្រូវកុំកន្ទុចពេលវេលា ព្រោះពេលវេលានេះឯងដែលផ្សំគ្នាឡើងជាជីវិតរបស់យើង ។ កិច្ចដែលនឹងទទួលកិច្ចដែលនឹងឲ្យ កិច្ចដែលនឹងធ្វើ បើអ្នកធ្វើមិនប្រញាប់ចាត់ការឲ្យទាន់ការទេ មុខជាត្រូវកាលវេលាក្រៃបដញ្ចក់យកវាសនៃធុរៈ ក្នុងមុខក្រសួងនោះៗ ឲ្យអស់ទៅពុំខាន ។ ការយឺតយូរនាំមកនូវសេចក្តីវិនាសអន្តរាយ ។ ហេតុនេះ សូមរីករាយចំពោះថ្ងៃនេះឲ្យហើយទៅ កុំជឿ

ទុកចិត្តថា ដល់ទៅថ្ងៃស្អែកទៀយ ព្រោះកាលវេលាជាអ្នកតែងដួសដុលវត្ថុដែលសេចក្តីកុហកបោកប្រាស មាយាសាវេយ្យ លាក់លាមបិទបាំងទុក ។ បើយើងបិទបាំងសេចក្តីខុស ផលទីបំផុត មុខជាត្រូវសេចក្តីអៀនខ្មាស ចំអកឡកឡឺយឲ្យពុំខាន ។

អ្នកស្មោះត្រង់ចំពោះមុខក្រសួង រមែងប៉ុនប៉ងដើម្បីធ្វើកិច្ចការក្នុងមុខក្រសួងដោយសេចក្តីទៀងត្រង់ ទឹងដោយមានៈអត់ធ្មត់ ប្រកាន់ពេលវេលាថាជាតួគោលច្បាប់ទំលាប់ដែលគេតាំងឡើង ដោយប្រាសចាកអគតិ ។ គប់ៗតែរយៈនៃពេលវេលា សុទ្ធតែជារបស់គួរការក្សាដើម្បីឲ្យវេលាកន្លងទៅដោយសេចក្តីរីករាយក្នុងការរក្សាមុខក្រសួង ។ អ្នកស្រែប្រាថ្នាធ្វើស្រែ អ្នកចំការប្រាថ្នាធ្វើចំការ ពួកជាងប្រាថ្នាធ្វើជាង អ្នកដំនួញប្រាថ្នាធ្វើដំនួញ ដោយសេចក្តីប្រឹងប្រែង អ្នកបួសខំព្យាយាមប្រតិបត្តិធម៌វិន័យដោយចិត្តបរិសុទ្ធ ខ្ពើមជាតគ្រប់គ្រង តាំងពីជាន់ទាបដល់ជាន់ខ្ពស់ ក៏ត្រូវប្រាថ្នាប្រកបនាទីរបស់ខ្លួនដោយស្មោះត្រង់ មិនគិតធុញកាស្តូបំបាត់ពាជការដែរ ។ មនុស្សគ្រប់គ្នាមានកិច្ចសំខាន់នៅត្រង់នាទីរបស់ខ្លួនទឹងនៅត្រង់ការប្រស្រ័យការងារគ្នាតាមនាទីដែលត្រូវជាប់ពាក់ព័ន្ធគ្នា ។ "កំឡាំងពីងស្នង ស្នងពីងកំឡាំង" ហេតុនេះមិនត្រូវរង្វេងសប្បាយក្តើតក្តើន ដោយសេចក្តីសុខផ្ទាល់ខ្លួន ទឹងមិនត្រូវរង្វេងយល់ខុសថាខ្លួនសំខាន់ជាងមនុស្សដទៃឡើយ ។

លោក-អ្នកប្រុស-ស្រីទាំងឡាយ ចូរស្មោះត្រង់ចំពោះមុខក្រសួងចុះ បើខ្លួនមានមុខក្រសួងដែលត្រូវធ្វើយ៉ាងណា ត្រូវប្រតិបត្តិតាមមុខក្រសួងយ៉ាងនោះ ដោយសេចក្តីស្មោះត្រង់កុងទីគប់ផ្ទៃង កុំលុះទៅក្នុងអំណាចអគតិ ព្រោះយល់មុខគ្នា កុំប្រើនាទី ឬអំណាចផ្លូវពាជការឲ្យជារឿងសម្រាប់ស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនដោយសេចក្តីលោភមិនមានអៀនខ្មាស ចំពោះអំពើទុច្ចរិតផ្សេងៗនោះឡើយ ដូចជាទទួលសំណូកនឹងទទួលដំនឹចិត្តដែលអ្នកជាខៃឲ្យ ដោយប្រាថ្នាកម្រៃក្នុងមុខងារនាទីរបស់ខ្លួនជាដើម ។ បើនាទី ដែលលោក-អ្នកធ្វើ ត្រូវលះបង់ទ្រព្យសម្បត្តិនឹងពងកាយ ដើម្បីទទួលយកលុទ្ធលភ្លួគ្នា ក៏គួរលះបង់ដោយសេចក្តីរឹតកាយចុះ កុំពោលបណ្តោះបណ្តែតេចវែងឡើយ ។ កលោបាយគប់បែបលោកអ្នកចូរផ្សាយទៅតែតាមរបៀបវិន័យ ។ សូម្បីនាទីដែលខ្លួនត្រូវទទួលខុសត្រូវនោះ ប្រសិនបើមានខុសភ្លាំងភ្លាត់ទៅក៏គួរទទួលកំហុសដោយពេញចិត្តចុះ កុំតែបន្ទុំយកតែខាងត្រូវ កុំបន្ទេបបន្ទុំ គឺប្រមូលយកតែខាងល្អមកជាក់ខ្លួន ហើយបញ្ជូនអាក្រក់ទៅឲ្យគេឡើយ បើធ្វើខុសត្រូវកាត់ចិត្តទទួលសារភាពទោសដោយស្មោះស្ម័គ្រ ។

បើលោក-អ្នកមានមុខងារជាប់ទាក់ទងដោយការបណ្តុះ ឬការរក្សាផលប្រយោជន៍ ក៏គួរជាមនុស្សខៀងត្រង់ ធ្វើការដោយសុចរិត កុំវៀចវេរបោកពស្តួ បំផ្លាញពាជការ ទឹងកុំធ្វើខ្ជិលឲ្យ ដោយប្រការផ្សេងៗឡើយ ។

បើមាននាទីជាអ្នកវិនិច្ឆ័យ ដូចយ៉ាងនាទីតុលាការ ដែលវិនិច្ឆ័យរឿងពិត
មិនពិត របស់បុគ្គលក្តី មាននាទីជាអ្នកគ្រប់គ្រង ដែលយឹតយោង
សេចក្តីល្អ សេចក្តីត្រូវរបស់បុគ្គលដែលនៅក្រោមការគ្រប់គ្រងក្តី កំសួរ
ជាមនុស្សត្រឹមត្រង់តាមធម៌ ឬយុត្តិធម៌ ធ្វើការឲ្យជាធម៌ កុំលំអៀងដោយ
ស្រឡាញ់ស្អប់ ខ្ជាចនឹងវង្វេងឡើយ ត្រូវតាំងចិត្តប្រតិបត្តិឲ្យត្រឹមត្រូវតាម
នាទីរបស់ខ្លួន ។

តាមពិត ការប្រតិបត្តិឲ្យត្រូវតាមនាទីនោះ រមែងជាវិធីនាំយើងទៅ
កាន់សន្តិសុខ នាំជាតិឲ្យឈានទៅរកសេចក្តីចំរើនរុងរឿង នឹងធ្វើលោក
នេះឲ្យជាទីនៅដ៏សមគួរដល់មនុស្សយើង ដែលជាសត្វប្រសើរជាងសត្វ
សត្វតិរច្ឆាន ។ អ្នកដែលស្មោះត្រង់ចំពោះនាទីនោះ កាលបើប្រតិបត្តិខុស
កង្វល់ក្រសួងម្តងៗហើយ តែងតែខ្មាសអៀនអន់ គួចចិត្តនឹងរន្ធត់ចិត្តកង
កំហុសរបស់ខ្លួន ចំណែកអ្នកដែលមិនស្មោះត្រង់វិញ ទុកជាធ្វើខុសក៏គ្មាន
ទឹករអែងអ្វី ធ្វើអ្វីច្រើនតែធ្វើទៅតាមអំពើចិត្តខ្លួន គ្មានទឹកក្រែងកង្វល់កំហុស
របស់ខ្លួនឡើយ សូម្បីស្បថស្បែរថានឹងធ្វើឲ្យជាប្រយោជន៍តាមមុខងារ
ក៏ដោយ លុះដល់ពេលធ្វើ ក៏បែរជាគិតការបោកបន្ទុំ បំបាត់គ្រប់ផ្លូវ
ទៅវិញ ។ លោក-អ្នកស្រឡាញ់ជាតិ នឹងប្រាថ្នាសន្តិសុខទាំងឡាយ
ចូរជាមនុស្សស្មោះត្រង់ចំពោះមុខក្រសួងចុះ ។

ស្មោះត្រង់បំពោះបុគ្គល.— ការស្មោះត្រង់ចំពោះបុគ្គលជា
អាការសំខាន់បំផុត ក្នុងកិច្ចទាក់ទងជាមួយមនុស្សដទៃ នាំឲ្យកើតសេចក្តី
ស្រឡាញ់ដិតដិតស្និទ្ធស្នាលទុកចិត្តគ្នាទៅវិញទៅមក ។ អ្នកណាមិន
ស្មោះត្រង់ចំពោះអ្នកដទៃ អ្នកនោះរមែងមិនជាទីទុកចិត្តនៃអ្នកដទៃ
ទំលាយខ្លួនឯងឲ្យសាបសូន្យខ្លួចកិត្តិយស មិនមាននរណានឹងរាប់អាន
ជឿទុកចិត្ត សូម្បីធ្វើការទាក់ទងនឹងនរណា ក៏គេមិនទុកចិត្ត មានតែគេ
រង្កៀសសង្ស័យ មិនច្បាស់ថានឹងសមាគមរួមជាមួយទៅវិញ ដូច្នេះ យើង
ទើបត្រូវតែស្មោះត្រង់ចំពោះគ្នានឹងគ្នា ។ សេចក្តីស្មោះត្រង់ចំពោះមិត្ត
គោរពកោតក្រែងចំពោះនាយចៅហ្វាយ . ឬប្រែមុខរបស់ខ្លួនទឹងគោរព
រាប់អានបូជាចំពោះលោក - អ្នកមានគុណ ជាលក្ខណៈនៃសេចក្តីស្មោះ
ត្រង់ចំពោះបុគ្គល ។ សេចក្តីស្មោះត្រង់ថ្នាក់នេះមាន ៣ ប្រភេទ ហៅ
ឈ្មោះតាមអាការថា ស្មោះត្រង់ចំពោះមិត្ត ១ គោរពកោតក្រែង ១ ទឹង
កតញ្ញូកតវេទី ១ ។

ល. ស្មោះត្រង់បំពោះមិត្ត.— គឺមនុស្សប្រព្រឹត្តត្រង់មិនគិតវៀច
វេរចំពោះមិត្តកក្តិ ។ កាលខ្លួនចងមេត្រីស្និទ្ធ ជាមិត្តនឹងអ្នកណាហើយ
ក៏ធ្វើខ្លួនឲ្យជាមិត្តពិត ។ របស់អ្នកនោះ មិនគិតអាក្រក់ចំពោះគ្នា មិនជា
មិត្តក្លែងក្លាយ. គឺមិនជាអ្នកកុហកមិត្ត មិនជាអ្នកមានតែមាត់ប្រស្រ័យ

តែមិនសង្គ្រោះតាមពិត នឹងមិនជាអ្នកប្រចុបប្រចែងដឹកនាំទៅតែកន្លែងវិនាស ជាអ្នកតាំងចិត្តអនុគ្រោះចំពោះមិត្ត រួមសុខរួមទុក្ខជាមួយគ្នា ជាស់តឿនក្រើនរំឭក នឹងណែនាំតែកន្លែងដែលជាប្រយោជន៍ដល់គ្នា ស្រឡាញ់គ្នាពិតៗ ។

លោក - អ្នកចូរស្មោះត្រង់ចំពោះមិត្ត ចូរថែរក្សាមេត្រីភាពចំពោះគ្នាដោយវិធីចេះហាមចិត្តរបស់ខ្លួន មិនឲ្យធ្វើចំពានជំនះទៅដោយកំឡាំងឫទ្ធិទោស: ត្រូវចេះអត់សង្កត់ចិត្តកុំឲ្យធ្វើតបក្នុងកាលដែលមិត្តភ័ក្តិធ្វើល្មើសមកលើ ត្រូវកាត់ចិត្តឲ្យអភ័យដល់គ្នា កុំឈឺចិត្តហើយសងសឹកដោយឲ្យរបស់ដែលខុសទៅមិត្តវិញឡើយ ចូរចរចាគ្នាដោយសំដីដ៏ពីរោះជាទីគាប់ចិត្តរាប់អានគ្នារហូតដល់ញាតិមិត្ត ដែលស្និទ្ធស្នាល ត្រូវចេះយកចិត្តគ្នា កុំសំដែងអាការមើលងាយគ្នា ត្រូវជួយខ្វល់ខ្វាយក្នុងកិច្ចធុរៈរបស់គ្នាតាមផ្លូវកាយវាចាចិត្ត ដោយគិតតែវត្ថុដែលជាគុណប្រយោជន៍ចំពោះគ្នា ចេះបែងចែកលាភផលដល់គ្នា ប្រព្រឹត្តខ្លួនឲ្យស្អាត កុំឲ្យជាទីខ្ទើយណាយប្អូរឆ្អើសដល់គ្នា ចាប់សេចក្តីគិតឃើញរបស់ខ្លួន ដើម្បីសម្រួលឲ្យត្រូមព្រៀងចូលគ្នាបាន កុំយកតែចិត្តរបស់ខ្លួនជាប្រមាណ ចេះគោរពនឹងគ្នា ប្រកាន់យកការត្រឹមត្រូវ គួរសមនឹងប្រយោជន៍ជាធំ កុំប្រកាន់យកតែតាមមតិរបស់ខ្លួនដោយទិដ្ឋិមានៈ នឹងកុំវិវាទគ្នា ព្រោះតែសេចក្តីយល់ឃើញផ្ទុយគ្នាឡើយ ។

២ គោរពកោតក្រែង.— ការស្រឡាញ់គោរពកោតក្រែងចំពោះនាយចៅហ្វាយ ឬ ប្រមុខរបស់ខ្លួន មិនគិតរៀបរៅទុយ៌សចំពោះលោកដូចជាគោរពចំពោះខ្លួនឯង មានចិត្តកោតក្រែងពិតៗ ធ្វើខ្លួនឲ្យជាកម្លាំងក្នុងកិច្ចការសារពើពិតៗ តាំងចិត្តធ្វើការងារតាមមុខត្រសួងដោយសេចក្តីស្មោះត្រង់ជានិច្ច មិនធ្វើតែចំពោះមុខសូម្បីកំបាំងមុខក៏ធ្វើដូចគ្នា កាលដល់ពេលដែលត្រូវការ ក៏បង្អោនខ្លួនធ្វើជាពលីការ ដើម្បីជាប្រយោជន៍នៃចៅហ្វាយនាយឬប្រមុខដែលខ្លួនគោរពកោតក្រែង នេះជាលក្ខណៈនៃការគោរពកោតក្រែង ។

លោក - អ្នកជាពលរដ្ឋរបស់ជាតិទាំងឡាយ! បើលោក - អ្នកបានបង្អោនខ្លួនយកលោកណាជាម្ចាស់ ជានាយចៅហ្វាយឬជាប្រមុខរបស់ខ្លួនហើយ គួរស្មោះត្រង់ គួរមានចិត្តគោរពកោតក្រែងចំពោះលោកនោះ កុំគិតរៀបរៅទុយ៌សចំពោះលោកឡើយ ដើម្បីឲ្យជាកម្លាំងក្នុងការងារទទឹងក្នុងការការពារអន្តរាយពិតៗ កាលដល់ពេលវេលាហើយ ក៏គួរបង្អោនខ្លួនធ្វើពលីការដើម្បីលោកកុំខាន ដូចជាខ្ញុំកដការ ដែលបានថ្វាយសច្ចប្រណិធាន យល់ព្រមយកព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាម្ចាស់របស់ខ្លួនហើយ គួរស្មោះត្រង់គោរពកោតក្រែងចំពោះព្រះអង្គដែលជាប្រមុខរបស់ជាតិ ។ បើលោក - អ្នកយកលោកណាជានាយចៅហ្វាយក៏គួរកោតក្រែងចំពោះលោកនោះ, ទៅកន្លងពួកគណៈណា គួរកោតក្រែង

ចំពោះប្រធានរបស់ពួកគណៈនោះ, នៅក្នុងគ្រួសារណា គួរគោរព ចំពោះប្រធាននៃគ្រួសារនោះ កុំគិតរៀចទុយ៊ិស ងាកចិត្តចេញអំពីនាយ ចៅហ្វាយឬប្រមុខរបស់ខ្លួននោះៗឡើយ ។ បើលោក - អ្នកប្រតិបត្តិបាន ដូច្នេះហើយ ក៏ឈ្មោះថាលោក - អ្នកមានលក្ខណៈគោរពគោតរែកង៏នៅ ពេញខ្លួន ។

ញ — កតញ្ញូកតវេទី — ភាពជាអ្នកដឹងគុណ ឬឧបការៈដែល លោកធ្វើចំពោះខ្លួន ហើយមិនលុបគុណលោក - ទង៏ប្រកាសគុណ របស់លោក ដែលមានចំពោះខ្លួនឲ្យប្រាកដដល់អ្នកដទៃ មិនបំបាត់ គុណលោក តបស្នង៏សង៏គុណលោក ទង៏គោរពរាប់អាន ដំកល់ លោកទុកក្នុង៏ដំណែង៏ជាអ្នកមានគុណូបការៈ នេះជាលក្ខណៈនៃកតញ្ញូ កតវេទី ។ កតញ្ញូកតវេទីនេះ សូម្បីទង៏ហៅឲ្យខ្លីថា "កតញ្ញូ" ដូច្នេះក៏ បាន ព្រោះយើង៏អាចដឹង៏បានថាអ្នកនេះ ជាមនុស្សកតញ្ញូនោះ ក៏ព្រោះ អាស្រ័យអាការៈ ដែលចេញប្រាកដមកខាង៏ក្រៅ មានការគោរព រាប់អានជាដើម ដែលជាអាការៈនៃកតវេទី ។

(មានត)

កណ្ដាទី ១២

ឧកញ៉ាវិបុលរាជសេនា នួ-កន ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
ធំងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ស៊ុនហុកឆ្លើយដំរាបចូលថា ទៅធ្លុជាតាហានមានកំឡាំងខ្លាំង ពួកគេក៏មែនហើយ តែថាមិនសូវមានគំនិតគិតឲ្យចំណាប់សោះ មួយទៀតក្នុងក្រងហ៊ូតោនេះលោកទើបនឹងលើកមកនៅថ្មី របៀបស្រុកក៏មិនទាន់ចាន់រៀបរយ, ដែលលោកនឹងឲ្យលើកទំពៅទៅចាំងវេលានេះ ខ្ញុំបាទមិនយល់ព្រមផងទេ ដ្បិតឡៅពីនឹងលីប៉ោនោះប្រៀបដូចខ្លា ១ គូ គំនិតខ្ញុំបាទគិតឲ្យខ្លាំង ២ នេះដណ្ដើមចំណីគ្នាស៊ីញ៉ែស្លាងជាង ព្រោះថាបើឡៅពីនឹងលីប៉ោ កើតទាស់គ្នាជាសឹកសត្រូវហើយ គង់ចាំងគ្នាទាល់តែវិនាសម្ខាងៗជាប្រាកដ រួចសឹមយើងគិតយកជ័យជំនះជាក្រោយតទៅ ឥឡូវនេះ សូមឲ្យលោកយកសេចក្ដីក្រាបបង្គំទូលព្រះចៅហៀនតេ ជាដ្បិត

ឡៅពីចៅហ្វាយស្រុកឈើដីវ នោះមិនមានបានតាំងជាសិប់ទេ សុំឲ្យមានព្រះរាជឧដ្ឋារគ្រាតាំងឡៅពីជាចៅហ្វាយស្រុកឈើដីវចុះ បើបានដូច្នោះហើយគង់នឹងតាំងចិត្តធ្វើរាជការមាំមួន ចំណែកលោកក៏ត្រូវមានសំបុត្រប្រាប្តូនឡៅថា លោកបានក្រាបពិតទូលឲ្យព្រះចៅហៀនតេជ្រាបសាំងឡៅពីជាចៅហ្វាយស្រុកឈើដីវ បើឡៅពីបានពេញទីជាចៅហ្វាយស្រុកឈើដីវហើយ លីចុ"នោះក៏រមែងប្រទូសរ៉ាយដល់អ្នកមានគុណជាមិនខាន យើងត្រូវបញ្ជូនឲ្យឡៅពីទីសម្ងាប់លីចុ"ចេញ ។

ចូឆូបានស្តាប់ពេញចិត្តណាស់ ក៏ចូលទៅទូលស្តេចព្រះចៅហៀនតេ សុំឲ្យមានព្រះរាជឧដ្ឋារទៅតាំងឡៅពីជាចៅហ្វាយស្រុកឈើដីវ ព្រះចៅហៀនតេក៏ជ្រាបឲ្យ ហើយទ្រង់ព្រះអក្សរឲ្យឡៅពីជាចៅហ្វាយស្រុកឈើដីវ ។ ចូឆូក៏ទទួលនាំចេញមក ហើយតែងសំបុត្រមួយច្បាប់អមគ្រាតាំងតាមពាក្យស៊ុនហុកថានោះ, ទើបចាត់បំរើស្និទ្ធឲ្យនាំគ្រាតាំងចេញទៅ ចូឆូក៏ផ្តាំនឹងបំរើឲ្យជ្រាបឡៅពីថា ចូឆូបានជួយពិតទូលសុំគ្រាតាំងបានជាទ្រង់ជ្រាបព្រះរាជទាន មួយយ៉ាងទៀត ឲ្យស្តាប់កិត្តិស័ព្ទថាឡៅពីនឹងគិតធ្វើលីចុ"ដូចម្តេចខ្លះបំរើក៏បានទៅដល់ស្រុកឈើដីវ ឡៅពីក៏ចេញមកទទួលគំនាប់តាមទំនៀមទម្លាប់ ហើយក៏មើលសំបុត្រនោះដឹងសេចក្តីមានសេចក្តីត្រេកអរជាពន្លឹក ទើបរៀបចំឲ្យបំរើនោះបរិភោគអាហារ ។ លុះអ្នកបំរើនោះបរិភោគរួចហើយក៏និយាយជំរាបឡៅពីថា ដែល

ព្រះចៅហៀនតេតាំងឲ្យលោកបានពេញទីជាចៅហ្វាយស្រុកឈីជីវនេះ ព្រោះចូរធ្វូលស្មើសុំឲ្យ និយាយហើយក៏ហុចសំបុត្រនោះឲ្យទ្បៅពីៗ ទទួលមើលដឹងសេចក្តីហើយនិយាយថា ចូរអ្នកនាំពតិមាន់ទៅដំរាបចូរធ្វូចុះ "ថាយើងសុំបង្អង់ឆ៍តិតសិន" លុះវេលាយប់ក៏ប្រជុំទីប្រឹក្សាថ្លាប់ថា ចូរធ្វូឲ្យសំបុត្រមកយើងឲ្យតិតសម្លាប់លីចោ"ចេញ តើអ្នកទាំងពួងនឹងយល់យើញដូចម្តេច? ។

តៀវហ៊ុយឆ្លើយ លីចោ"នោះចិត្តវាអាក្រក់ណាស់ មិនជាអ្នកស្គាល់គុណគេសោះ បើនឹងសម្លាប់វាចេញតាមពាក្យចូរធ្វូថា, ខ្ញុំក៏យល់យើញផង ។ ទ្បៅពីតបថា លីចោ"បានជាបៃមុខមកពឹងយើងហើយ បើយើងនឹងធ្វើអន្តរាយគេចេញវេលានេះក៏មិនល្អមើលសោះ ព្រោះតទៅមុខនរៈណានឹងមករកយើងទៀត ។ តៀវហ៊ុយឆ្លើយថា លោកនឹងធ្វើចិត្តល្អតនឹងមនុស្សកំណាចនោះមិនល្អទេ ទ្បៅពីក៏មិនស្តាប់តៀវហ៊ុយ ។

ថ្ងៃឯពីលីចោ"វិញ កាលបានដឹងដំណឹងថា ព្រះចៅហៀនតេមានព្រះដម្រាស់មកតាំងទ្បៅពីពេញទីជាចៅហ្វាយស្រុកឈីជីវហើយ ក៏ទៅសួរទ្បៅពីហើយថា ខ្ញុំបានឮដំណឹងថាលោកបានទទួលត្រាតាំងពេញទីជាចៅហ្វាយស្រុកនោះ ខ្ញុំបាទមានសេចក្តីត្រេកអរជើរក្រៃលែង ។ ទទួលតៀវហ៊ុយ កាន់ក្រប៊ីចូលទៅប្រឹងនឹងសម្លាប់លីចោ" ទ្បៅពីភ័យស្លុតក៏ស្ទុះទៅចាប់ក្រប៊ីចេញ លីចោ"និយាយនឹងទ្បៅពីថា តៀវហ៊ុយនេះមាន

សេចក្តីខឹងគំនុំនឹងខ្ញុំដោយហេតុអ្វី? ប៉ានជាមានសេចក្តីព្យាបាទប្រឆំនឹងសម្លាប់ខ្ញុំជាច្រើនដងហើយ ។ តៀវហ៊ុយបានឮក៏ឆ្លើយថា ប៉ានជាអញខឹងព្រោះខ្លួនឯងជាមនុស្សមិនស្គាល់គុណគេសោះ ចូរឆ្លក់បានផ្ញើសំបុត្រមកបង្អាអញឲ្យសម្លាប់ឯងចេញ ។ ឡៅពីឮដូច្នោះក៏ស្រែកគំហកហើយបង្គាប់ឲ្យនាំខ្លួនតៀវហ៊ុយចេញទៅក្រៅ ទើបឡៅពីនាំលីចោ" ចូលទៅខាងក្នុង ហើយហុចសំបុត្រចូរឲ្យមើល ហើយនិយាយរាយរឿងច្បាប់តាមបង្គាប់ចូរឆ្លាំមកគ្រប់ប្រការ ។

លីចោ"មើលសំបុត្រហើយក៏យំស្រក់ទឹកភ្នែកនិយាយថា ដែលចូរឆ្លគិតមកដូច្នេះច្បាស្ថានឹងឲ្យលោកនឹងខ្ញុំមានសេចក្តីរង្គើសចិត្តគ្នា ទៅជាសត្រូវតទៅមុខ ។ ឡៅពីតបថាអ្នកកុំរំពឹកឡើយ ទោះបីមាននរណាមកញុះញង់ប្រការម្តេច យើងក៏មិនត្រូវដឿស្តាប់ធ្វើអាក្រក់នឹងគ្នា ។ លីចោ" ប៉ានស្តាប់ក៏ត្រឡប់ធូរស្រាលក្នុងចិត្តនិយាយថា ដែលលោកចេញវាចាមកដូច្នេះព្រះគុណមិនមានទីបំផុត ។ ឡៅពីក៏បបួលលីចោ"បរិភោគអាហារទាល់តែថ្ងៃរសៀលល្ងាចហើយលីចោ"ក៏លាឡៅពីទៅស្រុកសៀវផាយវិញ ។

គួនអ៊ូតៀហុយ នាំគ្នាចូលទៅនិយាយនឹងឡៅពីថា លោកបណ្តោយឲ្យលីចោ"ត្រឡប់វិលទៅវិញ មិនសម្លាប់ចេញតាមសំបុត្រចូរឆ្លផ្ញើមកនោះតើដោយប្រការម្តេច? ។ ឡៅពីតបថា ឯសន្តានចិត្តចូរឆ្លនោះគិតនឹងចង់

ឲ្យយើងខាស់ទៃងគ្នានឹងលីប៉ោ" បានជាទូលស្នើសុំឲ្យព្រះចៅហៀនតេ តាំងយើងពេញទីជាចោហ្វាយស្រុក ហើយថែមទាំងសំបុត្រចូរមកទៀត ឲ្យយើងសម្ងាប់លីប៉ោចេញ គឺធ្វើឲ្យយើងនឹងលីប៉ោនោះមិញខាស់អធ្យាស្រ័យគ្នា បើខាងណាបរាជ័យហើយ ចូរឆ្ងូនឹងធ្វើសឹកនឹងអ្នកនោះ យកជ័យតែម្ដងមិនត្រួយរវល់ប៉ុន្មាន បើយើងនឹងធ្វើតាមគំនិតចូរឆ្ងូដែលបង្គាប់មកនេះមិនគួរសោះឡើយ ។ គួនអ៊ូស្តាប់ហើយក៏យល់ថាត្រូវ តែតៀរហ៊ុយនោះនៅទូចថា ខ្ញុំនឹងចាំសម្ងាប់លីប៉ោចេញឲ្យបាន តទៅមុខទើបមិនត្រួយ ។ ឡៅពីតបថា បើប្អូននឹងគិតធ្វើដូច្នេះ ក៏ដូចជាមនុស្សគ្មានសតិបញ្ញាសោះ ។

ឯបំរើដែលនាំព្រះដម្រាស់មក លុះបានដឹងព្រះគ្រិស្តសង្គ្រប់ប្រការដូចពាណិនាមកដូច្នេះហើយ ទើបលាឡៅពីត្រឡប់រំលៀងវិញ កាលបើបានទៅដល់ក្រងហ៊ីតោហើយក៏ចូលទៅដំណរការនោះឲ្យចូរឆ្ងូស្តាប់ថា ឡៅពីមិនបានធ្វើតាមបង្គាប់លោកទេ ។

ខណៈនោះចូរឆ្ងូបានប្រឹក្សានឹងស៊ុនហុកថា ការដែលអ្នកគិតឲ្យយើងធ្វើនោះឡៅពីក៏មិនព្រមធ្វើតាមទេ តើអ្នកនឹងគិតធ្វើដូចម្ដេចតទៅទៀត? ។ ស៊ុនហុកដំណរថា ខ្ញុំនឹងគិតកលល្បិចយូមួយយ៉ាងទៀតហៅថាខ្វាធំលេបខ្វាឃ្មុំ ។ ចូរឆ្ងូសួរថា ខ្វាធំលេបខ្វាឃ្មុំនោះគឺធ្វើកលដូចម្ដេច ។ ស៊ុនហុកដំណរថា ឯសន្ដានចិត្តលីប៉ោមិនជាមនុស្សត្រង់ល្អនឹងអ្នកឯណាសោះ សូមឲ្យលោក

ប្រើបំរើឲ្យទៅនិយាយប្រាប់អ្នកស៊ុតចៅហ្វាយស្រុកឡាំយ៉ុងថា ឥឡូវនេះ
ខ្ញុំពីមានសំបុត្រចូលទៅគាបទូលព្រះចៅហៀនតេ សុំសេនាខាហាន
លើកទៅវាយស្រុកឡាំយ៉ុងហើយ បើអ្នកស៊ុតឮហើយគង់ទឹងខឹងជា
ប្រាកដ ចិត្តអ្នកស៊ុតមិនអត់មុខជាលើកទ័ពទៅវាយខ្ញុំពីជាមុន ហើយ
ឲ្យលោកមានសំបុត្រប្រាប់ទៅខ្ញុំពីឲ្យលើកខាហានទៅវាយយកក្រុង
អ្នកស៊ុតវិញ កាលខ្ញុំពីទឹងអ្នកស៊ុតប្រយុទ្ធជាប់ដៃគ្នា បើខាងណាភ្លាត់
ចំណាប់ លីចោ"គង់ទឹងលើកទ័ពទៅព្រួតបន្ទែមជាប្រាកដ រួចសឹមលោក
គិតការតទៅ ។ ចូរឆ្លុយល់ឃើញត្រូវ កំរៀបចាត់បំរើឲ្យទៅប្រាប់អ្នកស៊ុត
ចៅហ្វាយស្រុកឡាំយ៉ុង" ហើយធ្វើសំបុត្រព្រះដម្រាស់ឲ្យបំរើកាន់ទៅ
ឲ្យខ្ញុំពីចៅហ្វាយស្រុកឈីដីវជាសេចក្តីថា ដ្បិតវេលានេះ អ្នកស៊ុត
ចៅហ្វាយស្រុកឡាំយ៉ុងរឹងទឹងមិនបានចំណុះចុះចូលព្រះចៅហៀនតេជា
ម្ចាស់ផែនដីទេ ឲ្យខ្ញុំពីលើកទ័ពទៅវាយបង្ក្រាបអ្នកស៊ុតឲ្យបាន ។
កាលខ្ញុំពីទទួលព្រះដម្រាស់ហើយក៏និយាយទទឹងបំរើកាន់ព្រះដម្រាស់
នោះថា ចូរអ្នកវិលទៅយកសេចក្តីបង្គំទូលព្រះចៅហៀនតេចុះថា ដែល
មានព្រះដម្រាស់បង្គាប់មកនោះ ខ្ញុំទឹងទទួលធ្វើតាមគ្រប់ប្រការ ។

ប៊ុតុកដំរាបខ្ញុំពីថា ដែលមានព្រះដម្រាស់បង្គាប់មកនេះ ខ្ញុំបាទ
យល់ឃើញថា ជាគំនិតខុយកលរបស់ចូរទ្រូ ។ ខ្ញុំពីតបថា "ដែល
មកស្មានថា ចូរទ្រូប្រែកលខុយនោះ ទោះបីយ៉ាងណា ក៏ជាតួព្រះដម្រាស់

ពិតប្រាកដ យើងត្រូវតែគិតធ្វើតាម" ហើយក៏បង្គាប់ឲ្យរៀបចាត់ចែងចែងសេនាគហានចាំឆ្លង ចាន់ប្រហែល ៣ ម៉ឺន ត្រៀមខ្មុកជាស្រេច ដល់ពេញឫក្សល្អកាលណាក៏នឹងលើកចេញទៅ ។

ស៊ុនខៀនដាក់បង្ហាញទៀតថា ដែលលោកនឹងលើកទ័ពទៅនោះ សុំឲ្យចាត់ចែងចែងសេនាគហាន ដែលមានថ្វីដៃនឹងដំរេះប្រាជ្ញាខ្មុកឲ្យនៅរក្សាស្រុក ។ ទ្បៅពីក៏យល់ព្រមផង, គួនអ៊ូធ្វើយដាក់បថា ខ្ញុំបាទសុំនៅរក្សាស្រុកបុះ ។ ទ្បៅពីតបថា ប្អូនជាទីប្រឹក្សារបស់យើងនឹងនៅម្តេចបាន ។ តៀវហ៊ុយធ្វើយឡើងទៀតថា បើលោកយកគួនអ៊ូទៅជាទីប្រឹក្សាហើយឲ្យខ្ញុំបាទនៅរក្សាស្រុកបុះ ។ ទ្បៅពីតបថាអ្នងឯងនេះចេះតែជឹកស្រាស្រវឹងនឹងដេរវាយគហានគ្មានប្រណីសោះ ថែមទាំងចិត្តនោះក៏ស្រាលរហ័សខោះគេនឹងស្តីរំលឹកក៏ពុំសូវស្តាប់ បើនឹងទុកចិត្តឲ្យនៅកាន់កាប់រក្សាស្រុកក្រែងមិនបាន ។ តៀវហ៊ុយធ្វើយថា ពីត្រឹមថ្ងៃនេះទៅមុខ ខ្ញុំបាទលែងទទួលគានស្រាសោះ ខោះបីនឹងធ្វើការអ្វីៗ ក៏ចាំប្រឹក្សាពិគ្រោះនឹងអ្នកមានសតិបញ្ញាសិន បើមានគេស្តីរំលឹកក៏ត្រូវតែស្តាប់គ្រប់ប្រការ ។

ប៊ុតុកធ្វើយថា ក្រែងមិនដូចពាក្យប្តេជ្ញាទេដឹង ។ តៀវហ៊ុយទឹងណាស់ធ្វើយតបថា តាំងពីខ្ញុំបានតាំងចិត្តធ្វើការជាមួយនឹងទ្បៅពីជាបងរំលងមកច្រើនឆ្នាំហើយ គ្មានខណៈឡើយនឹងចាប់ពិរុធខ្ញុំជារៀបបាន ហេតុម្តេចអ្នកមកហានគាយចិត្តខ្ញុំនោះមិនគួរទេ ។ ទ្បៅពីឃាត់ហាម

តៀវហ៊ុយថាកុំឲ្យខឹងសម្បានឹងប៉ុតុកឡើយ ដែលប្អូនឹងទួលនៅវត្ត
ស្រុកនោះបង់ក៏មិនថាន់ទុកចិត្តដែរ តែថាបានឲ្យសញ្ញាហើយនឹងនៅ
ក៏នៅចុះ តែត្រូវទុកតាន់តេង់ឲ្យនៅជាទីប្រឹក្សាផង នឹងបានជាសំគៀន
រំលឹកត្រឹកល្ងាច កុំឲ្យផឹកស្រាស្រវឹងពេក ទើបធ្វើការវត្តស្រុកទេស
ទឹងមិនតើតថ្លង់ការ ។ តៀវហ៊ុយទឹងតាន់តេង់ក៏ទទួលប្រសាសន៍ឡៅពី
គ្រប់ប្រការ ។

លុះបានពេលមង្គលឫក្ស ឡៅពីក៏លើកទ័ពចេញទៅស្រុកឡាំយ៉ុង,
ឯអ្នកស៊ុតជាចៅហ្វាយស្រុកឡាំយ៉ុងនោះ លុះដឹងថា "ឡៅពីមានសំបុត្រ
ទៅគ្រាបទូលព្រះចៅហៀនតេ សុំសេនាទាហានឹងលើកមកវាយស្រុក
របស់ខ្លួន" ក៏ខឹងណាស់ ស្តីដៀលត្មះឲ្យឡៅពីថា "ជាតិត្រកូលវាជា
អ្នកតូចញសំពត់លក់តើ ឥឡូវនេះបានធ្លៅចៅហ្វាយស្រុកប៉ុណ្ណោះ ក៏មក
ចេះតំរើកចិត្តគិតលើកទ័ពមកវាយស្រុកយើង។ ឯងឲ្យវាមកជាន់ដីយើង
ធ្លៀអ្វី" ថាហើយក៏ប្រើគីឡែងសេនាឯកជាមេទ័ពលើកទាហាន ១០ ម៉ឺន
ចេញទៅវាយស្រុកឈីដីវ ។

គីឡែងលើកកងទ័ពទៅដល់ស្រុកអ៊ុថៃ ឃើញកងទ័ពឡៅពីលើក
មកប្រទះគ្នា គីឡែងក៏ចុះទ័ពរបស់តាំងបន្ទាយ ប្រទល់គ្នាចម្ងាយល្មម
មើលគ្នាឃើញទៅវិញទៅមក ។ ឯឡៅពីឃើញគីឡែងជាពួកស្រុកសួ
តាំងលើកទ័ពមកក៏គិតថា សេនាទាហានយើងតិច គួរតាំងបន្ទាយជាប៉ែក

ធ្វេងស្តាំក្លាប់ទល់នឹងដើងកុំរហូតទៅទល់នឹងមាត់ទឹកទន្លេ ។ គីឡេង
យើញដូច្នោះក៏ឡើងសេះកាន់ដាវដែងមួន ៥០ នាឡិ បរពលចូលទៅ
ប្រទល់ដល់មុខបន្ទាយខ្មៅពី ហើយស្រែកដេរខ្មៅពីថា អាពួកមនុស្ស
ត្រៃ! ឯងមានថ្លៃដៃយ៉ាងណា ទើបអង់អាចលើកទ័ពមកធ្វើសង្គ្រាមនឹង
អញហួសចូលមកដល់ស្រុកអ៊ុំថៃ ជាដែនខ្មើងវៃត្រឡាំយ៉ុង ។ ខ្មៅពី
តបថា ចៅហ្វាយឯងឈ្មោះអ៊ួនសុតចេញជាក្សត់ខ្លាំងនឹងផែនដី មិន
ចំណុះព្រះចៅហៀនតេ។ ទ្រង់គ្រាស់ប្រើអញឲ្យលើកកងទ័ពមកប្រាប់
ប្រាមអ៊ួនសុតឲ្យចំណុះស្តេចជាម្ចាស់ផែនដី ហេតុអ្វីបានជាឯងមិនគំនាប់
អញជាព្រះរាជអាជ្ញា ថែមទាំងចរចាទគោះមើលងាយអញវិញ ទោស
ឯងមិញក៏ត្រូវប្រហារបង់ទូវដ៏រឹត ។

គីឡេងបានស្តាប់ក៏ត្រឡប់ក្រែវក្រោធ ប្រឡោតបរសេះត្រីដាវ
ចូលទៅប្រយុទ្ធនឹងខ្មៅពី គួនអ៊ូក៏បរសេះត្រីដាវចូលតនឹងគីឡេង បាន
៣០ក្បេង មិនទាន់ចាញ់ឈ្នះ គីឡេងអស់កម្លាំងស្រែកប្រាប់គួនអ៊ូថា
យើងឈប់ថ្ងូបកម្លាំងបន្តិចសិន រួចសឹមលេងគ្នាតទៅទៀត ។ គួនអ៊ូក៏ថយ
សេះវិលមកវិញ គីឡេងក៏បរសេះចូលបន្ទាយ ហើយប្រើស៊ុនចេងសេនា
វង់ចេញមកតយុទ្ធនឹងគួនអ៊ូ។ ក្រឡេកយើញក៏ញាក់សេះវិលត្រឡប់ទៅ
ស្រែកថា ខ្ញុំឯងនេះមិនសមគួរមកតនឹងយើងសោះ ចូរវិលត្រឡប់ទៅ
ប្រាប់គីឡេងនាយឯង ឲ្យចេញមកតនឹងយើងទៀតទើបនឹងសមថ្ងៃដៃគ្នា ។

(មានត)

រឿងអាវ័ក្សថ្លែងរឿងម្លៃថ្មាំ

លោកសាង-សារ៉ាត លេខាធិការ ក្រសួងបរិរញ្ញវត្ថុ

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(តមក)

រឿងទី ៣

អាវ័ក្សនិយាយថា "ទុមហារាជ! ព្រះរាជបុត្រីនៃព្រះចាម ចម្បាកេសវរ: (Champà Keshvar) ទឹងព្រះនាងសុលូចនា (Sulôchna) នៅទីក្រុងចម្បាបុរ: (champapur) មានរាងកាយសមល្អអស្ចារ្យពាល់តែគេថ្វាយព្រះនាមថា: តែកវនសុន្ទរី ប្រែថា ល្អលើសគេ កងកពពាំងប៉ាំនេះ គឺស្មានកណ្ដាល, ស្មានសួគ៌, ស្មានទេវក ។ រង់ព្រះកត្តព្រះនាង ប៉ាដូចព្រះច័ន្ទ, កេសា ដូចពពក, នេត្រាដូចកែកកាន់, ច្រមុះដូចចំពុះសេក, ផ្នត់កដូចកព្រាប, ទន្តាដូចគ្រាប់ផ្ទៃទឹម (ការទំពាមួនាំឲ្យឆ្មៃញាមានពណ៌ក្រហម ហើយធ្វើឲ្យបបូរមាត់ឡើងក្រហម) ។ បបូរមាត់របស់ព្រះនាង ឡើងពណ៌ក្រហមឆ្អិនឆ្អៅ ។ រាងកាយព្រះនាងរហ័សរហួនដូចខ្លារខិន ។ ព្រះហត្ថាទឹងព្រះបាទាព្រះនាងទន់ភ្លន់ដូចផ្កាឈូក សម្បុរព្រះនាងដូចផ្កាចម្ប៉ា" ហើយមួយថ្ងៃៗ ព្រះនាងរឹតតែល្អឡើងៗ ។

កាលណាព្រះនាងចម្រើនអាយុគេញ្ជូរបុកាយ ព្រះមហាក្សត្រីយ៍ទឹងព្រះអគ្គមហេសី ទ្រង់មានព្រះហឫទ័យព្រួយបារម្ភជាពន់ពេក ហើយ

ទ្រង់បានប្រកាសដំណឹងដល់ស្តេចគ្រប់ប្រទេសជិតខាង ដូចតទៅនេះថា: "កុងព្រះពជវង្សាខុវង្ស ព្រះបាទចម្បាកេសវរៈ មានព្រះពជបុត្រដែលល្អប្រពៃខ្លាំងណាស់ គោះទេវតាក៏ភ្ញាក់ស្មារតីដែរ គោះមនុស្សទើងអ្នកប្រាជ្ញខាំងពួងក៏មើលព្រះនាងដែរ" ។ ឯស្តេចគ្រប់ព្រះអង្គនោះ ទ្រង់បានឲ្យព្រាហ្មណ៍គួរប្រកាលព្រះអង្គ ថ្វាយមកព្រះបាទចម្បាកេសវរៈ ។

ដល់ព្រះបៅ ស្តេចទ្រង់ទទួលព្រះធាយាលក្ខ័ណ៍ខាំងអស់នោះហើយ ទ្រង់យកទៅបង្ហាញព្រះនាង ឲ្យព្រះនាងជ្រើសរើសតាមត្រូវព្រះចិត្តា ប៉ុន្តែព្រះអង្គទ្រង់គិតថាគ្មានស្តេចអង្គណាសមទើងព្រះនាងឡើយ ។ ឯចំណែកខាងព្រះនាងក៏គ្មានត្រូវព្រះចិត្តាលើស្តេចអង្គណាដែរ ទើបព្រះនាងមានព្រះសុរសុរីទូលទៅព្រះវរពជបិតាថា "សូមសម្តេចព្រះបិតាមេត្តាព្រះពជទានថ្វាយទូលព្រះបង្គំទៅអ្នកណាមួយ ដែលមានគុណសម្បត្តិខាំងបីយ៉ាងដូចខាងមុខនេះគឺមានរូបល្អ, មានកម្លាំង ទើងមានវិជ្ជាសាស្ត្រ" ។

ចំនួនច្រើនថ្ងៃក្រោយមកសាមីខ្លួនបួននាក់ ដែលមកអំពីប្រទេសនានា ចូលទៅបង្ហាញខ្លួន ។ ឯព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា "សូមឲ្យអ្នកគ្រប់គ្នាបង្ហាញនូវចំណេះវិជ្ជា ទើងសមត្ថភាពជាប់ខ្ចុងផង" ។ កុងបណ្តាជនខាំងអស់ ម្នាក់ធ្វើយទូលឡើងថា "ឯចំណេះដែលទូលព្រះបង្គំចេះនោះ គឺទូលព្រះបង្គំចេះធ្វើកំណាត់ ដែលមានដំរៀបជាមាសប្រាំដំឡឹង ។ កាលណាទូលព្រះបង្គំបានមាសនោះមក, ទូលព្រះបង្គំ

ឲ្យមាសមួយដំឡឹងទៅព្រាហ្មណ៍, ខ្ញុំព្រះបង្គំថ្វាយមួយដំឡឹងដល់ព្រះរតន៧ត្រែ, ខ្ញុំព្រះបង្គំយកមួយដំឡឹងមកពាក់, ខ្ញុំព្រះបង្គំឲ្យមួយដំឡឹងទៅប្រពន្ធរបស់ខ្ញុំព្រះបង្គំ រួចខ្ញុំព្រះបង្គំលក់មួយដំឡឹង ត្រាយបង្គស់យកប្រាក់មកទិញភោជនាហារសម្រាប់ខ្ញុំព្រះបង្គំ ។ នេះហើយជាតម្រិះ ដែលមានតែខ្ញុំព្រះបង្គំមួយទេ មាននោះ ឯរូបកាយរបស់ខ្ញុំព្រះបង្គំល្អ ដូចព្រះអង្គទតឃើញស្រាប់ហើយ" ។

បុរសទីពីរទូលថា "ខ្ញុំព្រះបង្គំចេះភាសាសត្វពាហនៈ នឹងសត្វបក្សាក្នុងទឹកលើគោកទាំងអស់ ។ គ្មានអ្នកណាម្នាក់មានកំឡាំងដូចខ្ញុំព្រះបង្គំទេ រួចសូមទ្រង់ទតមើលចុះ ខ្ញុំព្រះបង្គំមានរូបកាយល្អយ៉ាងណានោះ" ។

បុរសទីបីនិយាយថា: "ខ្ញុំព្រះបង្គំចេះគម្ពីរយ៉ាងជ្រៅជ្រះ គ្មានអ្នកណាមួយមកប្រៀបធៀបនឹងខ្ញុំព្រះបង្គំខាងវិទ្យាសាស្ត្រនេះទេ, រូបព្រះអង្គទតឃើញរូបកាយរបស់ខ្ញុំព្រះបង្គំស្រាប់" ។

បុរសទីបួនចាប់ផ្តើមទូលវិញថា: "ខ្ញុំព្រះបង្គំបានរៀនក្បួនគម្ពីរដូចជាអ្នកផងមិនដែលបានធ្វើដែរ ខ្ញុំព្រះបង្គំអាចថ្លែងសរបាន ឯរូបខ្ញុំព្រះបង្គំល្អឆើតឆាយលើជម្ពូទ្វីបនេះ, ត្រង់អង្គអាចទ្រង់អារកាត់រឿងនេះបាន" ។

លុះទ្រង់ព្រះសណ្តាប់សាមីខ្លួនទាំងបួនដូច្នោះហើយ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះបរិតក្តកង់ព្រះហឫទ័យជាពន់ពេក ។ ព្រះអង្គទ្រង់

ព្រះចិន្តាថា "សាមីខ្លួនទាំងបួនសុទ្ធតែមានតម្លៃស្មើៗគ្នា តើអញឲ្យទៅអ្នកណា? ។ លុះទ្រង់ព្រះដំរិះដូច្នោះ ព្រះអង្គយាងទៅកាជបុត្រីរបស់ព្រះអង្គ ។ ស្តេចទ្រង់មានព្រះរាជឫទ្ធានុភាពអំពីសមត្ថភាព របស់បុរសទាំងបួន ហើយទ្រង់សួរព្រះនាងថា: "តើបិតាឲ្យកូនទៅអ្នកណា?" ។ ព្រះនាងក៏មិនអាចអាក្រាត់បាន ព្រះនាងដាក់ព្រះភ័ក្ត្រពុំមានធ្វើយអ្វីឡើយ ហើយទ្រង់នៅស្ងាត់ស្ងៀម ។

លុះនិទានរឿងនេះចប់ហើយ អាវ៉ក្សក្រាបទូលសួរថា: "ឧព្រះបាទពិក្រម (Bikram) តើព្រះនាងត្រូវបានទៅអ្នកណា?" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជឫទ្ធានុភាពឆ្លើយតបវិញថា "អ្នកដែលបានធ្វើសំលៀកបំពាក់ ហើយបានលក់សំលៀកបំពាក់នោះជាបុរសដែលនៅក្នុងពួកសូទ្រ: (çùdras) - ឯបុរសដែលចេះភាសាសត្វនោះនៅក្នុងពួកវៃស្យ: (Vaiçya) - អ្នកដែលបានមើលសាស្ត្រា គឺជាព្រាហ្មណ៍ ឯអ្នកដែលប្រសប់ជាប្រពៃទៅរកគោលបំណងដែលគេមើលមិនឃើញ ហើយដែលមានតែសូរសំឡេងដឹកនាំនោះ គឺនៅក្នុងពួកព្រាហ្មណ៍ដែរហេតុដូច្នេះ ព្រះនាងត្រូវបានទៅបុរសគ្រោយនេះឯង" ។

លុះបានឮដូច្នោះ អាវ៉ក្សត្រឡប់ទៅព្យរខ្លួននៅលើដើមឈើវិញ ឯព្រះមហាក្សត្រិយ៍ស្តេចយាងទៅតាមលើកអាវ៉ក្សនោះអំពីដើមឈើ លុះចង់អាវ៉ក្សនេះរួចការណា ព្រះអង្គដាក់លើអង្សាហើយយាងទៅ ។

ចប់រឿងទី ៣, នៅមានរឿងទី ៨ ខាងក្រោយទៀត ។

(តមក)

លេខ ៤ ជាកទី ៣

វណ្ណនារី ឆលនារី ភាណនភ វណ្ណតារា

(ឆលនារី ចូលមកលបមើល)

វណ្ណនារី

សម័យ ! (ចូល)

វណ្ណតារា

យី ! ខ្ញុំក្មេចបំទ្វារ ! (ដើរទៅបិទទ្វារ)

ភាណនរា

អូន ! បងសូមលាទៅផ្ទះបង

វណ្ណតារា

កុំក្មេចបំណងរបស់ខ្ញុំ

ភាណនរា

សេចក្តីទុកចិត្តដ៏ឧត្តម អូនក្រមុំ ! បងមិនក្មេចទេ. ។

វណ្ណតារា

ដើម្បីបញ្ជាក់ចិត្តស្នេហា ជាគូសង្សារយើងតាំងខ្ទេ

ខ្ញុំដូនចិញ្ចៀនអ្នកមាសមេ នារីខ្ញុំគ្មានធំដូនបង ។
ទុកជាគោលតឹកតាងរូបខ្ញុំ

ភាណវារ

បងសូមអរគុណជាកន្លង

ចិញ្ចៀនកែវមណីជាចំណង គឺអូនឲ្យបងដោយស្នេហា ។
អូនបងសូមលាទៅសិនហ៎ើយ សង្ឃរាវៀមអើយថ្ងៃមុខ
មានជាសាក្សីគឺទេពតា យើងសូមសច្ចាជាគូស្នេហ៍ ។ (ចូល)

វិណ្ណាវារ

បានប្តីបែបនេះទើបពេញចិត្ត គំនិតសមជាមានយសស័ក្តិ
ចាំថ្ងៃណាមួយដំរាបម៉ាក់ ឲ្យបានដឹងជាក់ពីចិត្តខ្ញុំ ។

វិណ្ណាវារី

ក្រែមុំសម័យចិត្តគេល្អ (ចំអកឲ្យបង) ជាអ្នកមានធម៌សន្តោសធំ
ចេះស្រឡាញ់គ្នាឥតដំនុំ មេបាចាស់ទុំពុំដឹងជាន ។
គេកៀកគេកាន់ហាក់ស្និទ្ធស្នាល ត្រអាលតាមចិត្តដែលធ្លើបាន
សម័យឥឡូវទុំសប្បាណា កៅអីមួយបានគ្នាពីរនាក់ ។

វិណ្ណាវារ

សំដីយ៉ាងនេះគួរឲ្យធូរចិត្ត ព្រោះមិនដឹងកលកិច្ចពាក់ទាក់
សូមអូននិយាយឲ្យច្បាស់ជាក់ រវល់ក្នុណ៌អូនអើយបងមិនយល់ ។

វិណ្ណ៌ជារី

បុរសដែលកៀកគស្តី ហាក់ដូចជាប្តីរៀបមគ្គុល
ដៃម្ខាងខ្ចៃតលូកអង្អែលថ្ពាល់ ច្រមុះថើបញាល់សំរើបចិត្ត ។
តុអើយ! តុឯងឃើញឬទេ? តុស្នេហ៍ទាំងខ្ទេ គេរួមរឹត
កៅអីឯងម៉េចក៏មិនគិត ផ្តួលឲ្យគេរឹតរួមស្នេហា ។

វិណ្ណ៌ជារា

នុលោកទេពតា! អូនខ្ញុំឆ្កួត ប្រកួតស្រឡាញ់តុដើងមា
ចាំមើលដល់ម៉ាក់មកពីផ្សារ ឲ្យអ្នករៀបការតែម្តងទៅ ។

វិណ្ណ៌ជារី

កុំពត់ស្រឡៃ កុំប្រដៅស្រីខូច! ឫកពាមិនដូច អស់ស្រីនានា ។
មិនគិតមេឃា ចិញ្ចឹមរក្សា តាំងពីតូចមក ប្រឹតប្រែនប្រដៅ ។
ចង់ឲ្យកូនចៅ រស់នៅដោយធម៌ កេរ្តិ៍ឈ្មោះគង់ល្អ បវរសួស្តី ។
មិនចង់ឲ្យកូន ទៅជាអប្រិយ៍ អ័ប្បអស់រាសី ចង្រៃលក្ខណា ។
ប៉ុន្តែឯកូន ចិត្តចោរមោហា លបលួចស្នេហា បង្អាប់មែនទេ ។
នាំឲ្យអាស្រូវ កេរ្តិ៍ឈ្មោះក្រមញាតិ អស់អ្នកឯទៀត ពោលពាក្យនិន្ទា ។

ធិលជារី

បងនិយាយប្រដៅនរណា វណ្ណ៌តាភ អញ្ចឹញ្ជាទៅបាត់ហើយ
មានតែរូបខ្ញុំនៅកៀកកើយ បងអើយឮសូរសំដីបង ។

សំដីវិសេសខ្ញុំគួរស្តាប់ គួរបូលចិត្តចាប់ហើយត្រាប់ត្រង
ពាក្យសែនពីពេះកែកន្ទង ខ្ញុំចង់ចិត្តចាំពុំឲ្យឃ្លាត ។
ធ្វើម្តេចជាតិនេះសាច់ដង្កៃ អនាគតវ័យសូមជាញាតិ
ជាបងជាប្អូនត្រូវមានយោគ កុំបីឃ្លាតខ្ញុំឥតពាយមាយ ។

វិឡ្ហនារី

សច្ចាប្រណិធានជាពាក្យពិត គំនិតគិតឃើញទើបនិយាយ
ប្អូនសូមជួយបងជាការងាយ ។ស្បាហ៍ស្វាធ្យាយសាងទានសីល ។
ធ្វើបុណ្យឲ្យទានដល់ព្រះសង្ឃ ធ្វើចិត្តឲ្យផង់អស់មន្ទិល
។ស្បាហ៍ការនាកុំបីខ្វិល សរសៃត្រូវធ្វើឲ្យរមែរមែ ។
ធ្វើម្តេចយើងកើតជាតិជាខ្មែរ ប្រណិប័តន៍ខ្មែរជាអ្នកធំ
ប្អូនធ្វើយ៉ាងនេះទើបជួបជុំ បរមសែនសុខ អនាគត ។

ធិលនារី

សំដីគាន់តែផ្អែមពិសា សូមជាតិនានាដៀសឲ្យផុត
ពីក្រុមញាតិពាលគឺកំណាត់ ប្រាកដខ្ញុំសូមជួបនឹងបង ។
សូមថែរក្សាសេចក្តីសុខ ពីនេះទៅមុខមិនឲ្យហ្មង
ខ្ញុំសូមឲ្យជួបជាតិនេះម្តង (សើច) ចង់បងឲ្យហើយពីបច្ចុប្បន្ន ។
បងជួយបន់ស្រន់ឲ្យខ្ញុំផង បំណងចង់ស្រេចឲ្យទាន់ហាន
ធ្វើម្តេចទៅខ្ញុំនឹងចេះមន្ត គយគន់ដាក់ទាក់ឲ្យបានធាប់ ! ។

(សើចបូលក្នុង)

សុខា - វិណ្ណ៉ាវ៉ារី - វិណ្ណ៉ាតារា

សុខា

ជាតិមនុស្សបុរសទឹងស្ត្រី　　សែនពិបាកលៃគិតពេកណាស់
ណាមួយខ្ញុំកាន់តែចាស់　　ទ្រព្រះខ្ញុំសែនពិបាកចិត្ត ។
បុជ្ជា ! កន្ទុងតែងត្រូវការ　　នាយច្បាវការពារយ៉ាងប្រកិត
លុះផ្កាល្អឡើងតែងភ័យកិត　　នាយច្បាវព្រួយចិត្តកាន់តែខ្លាំង ។
យ៉ាងណាខ្ញុំជាមេបា　　រក្សាកូនស្រីដូចចម្បាំង
ការពារឲ្យសុខពេញកម្លាំង　　សម្រាំងកាយចិត្តឲ្យកូនល្អ ។
ឯកូនមិនដឹងចិត្តមាតា　　ប្រឹងតែពោលថាលំអៀងណា
ធ្លើផ្តើនទឹងម្តាយអកចិត្តធម៌　　ថែពីមានគគរហូតដល់ធំ ។
ម្តាយទាំងឡាយមានធម៌មេត្តា　　ដល់អស់បុត្រកូតូចនឹងធំ
ករុណាទេក្នាប្រមូលគ្នុំ　　មូលដុំមុខុតាចំពោះកូន ។
ដល់កូនធំឡើងចេះរឹង　　ម្តាយពឹងបន្ទិចឈរធ្វើសូន្យ
ជាតិនេះអកតូផុតពាយក្បួន　　មិនសួនសមស័ក្តិជាវង្សខ្ញុំ ។

វិណ្ណ៉ាវ៉ារី

អកម្តាយកុំព្រួយចិត្តធ្វើអ្វី　　ដល់ករណីណាដែលធ្វើហួស
ខ្ញុំដំរាបម៉ាកំពីគោស　　កំហុសតើឆ្កាកខ្មោចណា ។

គឺនាងវណ្ណាតាកជាបងខ្ញុំ ធ្វើឫកមិនសមទឹងវង្ស
ខ្ញុំបានឃើញជាក់ទឹងនេត្រា សង្សារគេឡើងមកត្រងើយ ។
អង្គុយថើបគ្នានៅកៅអី ជំតង្កែមីនុតហូសទៅហើយ
គេទុបគេតឹតគេកៀកកើយ ម៉ាក់អើយខ្ញុំមើលទឹងផលនារី ។

សុខា

វណ្ណានារីមាសម្តាយកូនសំឡាញ់ ឯងត្រូវចិត្តអញយ៉ាងពេញទី
ចូរចូលមកអាយកូនកែវមណី កូនហើយជាទីពឹងដល់ម្តាយ ។

វណ្ណាតារា

វាធ្វើដូច្នេះពេញអប្រិយ កេរ្តិ៍ឈ្មោះវាល្បីគ្រប់អូបសាយ
គ្រប់អូបច្រាសៗលាក់ដល់ម្តាយ អន្តរាយកេរ្តិ៍ឈ្មោះទឹងវង្ស ។
កូនស្រីត្រូវឯងប្រុងមារយាទ កុំឃ្លាតពីម្តាយណាកូនណា
ចូរកូនអាសូរដល់ខ្មោចចាំ ស្ងាប់បងអសារដោយគ្រោះថ្នាក់ ។

វណ្ណាតារី

អ្នកម្តាយវណ្ណាតាកគួរប្រដៅ ទុកឲ្យខ្ញុំហៅមកជួបម៉ាក់
តែទុកយូរទៅទឹងចុះថ្នាក់ (ចូល) ភ្លាក់ក្រមញាតិយើងចុះថោកទាប ។

សុខា

ហៅមក, ហៅមកកូនពីសិ មេចិត្តអប្រិយឫកសៀបច្រៀប
វាហ្នឹងសមតែយកទៅកៀប ដោយក្បៀបបណ្តើរកាត់ផ្សារថ្មី ។

(វណ្ណាតារាចេញដើរមួយៗ)

វណ្ណ៌តារាផ្កាយមាសនៅលើមេឃ ទៅត្រែកដន្ទេននៅកូនដី
រូបឯងសែនល្អហួសអស់ស្រី ម្តេចទៅពិស្ម័យនឹងមនុស្សពាប ។

វណ្ណ៌តារា

អ្នកម្តាយអត់ទោសដល់រូបខ្ញុំ កិរិយាខុត្តមយ៉ាងសុភាព
ម្តេចថាខ្ញុំខូចនឹងអ្នកពាប នរណាដំរាបបានម៉ាក់ដឹង ។
គេចេះនិយាយបង្កាច់កេរ្តិ៍ ឲ្យខ្ញុំខ្មាសគេកន្ទឹងជាន់ហ្នឹង
កន្ទឹងពេលនេះម៉ាក់សេចក្តីខឹង តឹងកន្ទឹងពាក្យនរពេកណាស់ ។
ក្តៅចិត្តឈឺឆ្អួលក្តួលក្នុងថ្លើម សម្បើមណាស់ម៉ាក់ជ្រាប់រហ័ស
ឲ្យដល់នាងខ្ញុំបានដឹងច្បាស់ នឹងអាលប្រកាសអស់ខេត្តា ។
សូមជាសាក្សីខ្ញុំសូត្រតង់ ដម្រង់ចិត្តខ្ញុំទៅសួគ៌ា
អត់ដង្ហើមស្លាប់មិនយូរយារ ចំពោះតែក្លាអ្នកម្តាយថ្លៃ ។

សុខា

ចូរអ្នកសៀមសិនកូនត្រលឹង កុំអាងតែខឹងចង់ប្រល័យ
សម្លាប់ខ្លួនឯងហួសវិស័យ មាសថ្លៃព្រះច្បាសមិនរួចទេ ។
បើកូនមិនខូចវិលគំនិត ម្តាយក៏ឥតបើថាអ្វីដែរ
ប្រយ័ត្នគំនិតកុំឲ្យវេរ ធ្លាក់កន្ទឹងទន្ទេរាមតណ្ហា ។
កុំឲ្យអាប់យសដល់រូបម្តាយ កេរ្តិ៍ឈ្មោះអន្តរាយដល់មេបា
កូនអើយត្រូវខ្មាសអស់ខេត្តា (សើរ) មើលឃើញអស់អាថិស្វាត់
កំបាំង ។

វណ្ណតារា

អ្នកម្ដាយបើកូនប្រព្រឹត្តធ្ងន់ រំលងនឹងចិត្តដោយកំឡាំង
តណ្ហាផង់ខ្ញុំមកពាំង អ្នកម្ដាយកុំចាំធ្វើសោះឡើយ ។
ទោះវាយឬចាក់សម្ងាប់ផង ខ្ញុំសូមវាប់ឆេំតាំងអស់ហើយ
ឲ្យតែរកទោសមុនជាគ្រើយ ខុសហើយសូមស្ងាប់ទៅប្រសើរ ។

(បេញ)

សុភា

ស្រីខូចលាក់ពុតរបៀបហ្នឹង ខុសហើយទៅរឹងបំពានលើ
គាល់តែពោះធំប៉ុនក្ដាន្លើ គេគយគន់មើលលាក់មិនបាន ។
មើលទៅសព្វៗ ដូចផ្លែល្វា ល្អជាតែក្រៅដូចរូបចាណ
វណ្ណតារាកូនខ្ញុំធ្លើរខាន ឲ្យបានក្រមញាតិចុះអន់ឆ្គោយ ។
នេះហៅថាកូនមិនទុកមុខ ឲ្យម្ដាយនុពករៀបចំឲ្យ
ភពួយខ្លួនវាមុនបណ្ដាយ រួចរៀបការគ្រោយតើល្អឬ? ។
មានកូនស្រីពីរចិត្តខុសគ្នា កិរិយាមាយាធំជាគី
មួយស្ដីបន្ទោសមិនធ្លើឮ មួយទៀតស្ដីឈឺប្រតិបត្តិតាម ។
ខូចមួយល្អមួយក៏មិនថា ធ្លើម្ដេចកូនក្លាកើតពីឈាម
ក្មេរវាអាក្រក់ល្អតែនាម វណ្ណតារាឈាមល្អ! មារយាទស្អុយ! ។

វិណ្ណានារី

វិណ្ណានារីនាមអន់ កើរ្តែកអូប តែច័ះហើយស្រូបអស់តាក់លុយ
ទោះបើតាលណាខ្ញុំប្រថុយ កើរ្តិ៍ខ្ញុំមិនសួយទេអ្នកម្តាយ ។

សុខា

ប្រយ័ត្នកិរិយា ទឹងមារយាទ កុំធ្វើឲ្យឃ្លាតបងអន្តរាយ
កុំដូចវណ្ណាតាកើរ្តិ៍វាសាយ យុវជនឯតឆ្ងាយដឹងពុំខាន ។

វិណ្ណានារី

អ្នកម្តាយកុំព្រួយលើរូបខ្ញុំ មិនមែនក្រែមុំចិត្តសាមាន្យ
ធ្វើឲ្យអ្នកម្តាយចិត្តមិនក្សាន្ត ដូចប្រាណវណ្ណាតាជាបងម្ល៉ើយ ។
គេលេបដុំភ្លើងពេញដើមក អំពើមិនល្អ ខ្ញុំតស្បើយ
ខ្ញុំក្តៅក្នុងចិត្តណាស់ម៉ាក់អើយ ម្ចាស់ហើយគេនៅតែខ្ជូនទៀត ។
ព្រះតន្ទូមានក្នែកដល់មួយពាន់ ក្នែកលោកគ្រប់គ្រាន់ទឹងមើលជាតិ
មនុស្សណាអាក្រែកកុំបីឃ្លាត អាឃាតស្វាប់ខ្លួនឲ្យប្លាត់ទៅ ។
រស់នៅធ្វើអ្វីណេនផែនដី រូបកាន់តិសប្បុរសមិនត្រូវ
ព្រះអើយឲ្យស្វាប់ទៅវិញទៅ កុំឲ្យកន្ទេញនាំទើសក្នែក ។

ចប់ ឈុតទី ២

(មានត)

រឿង ប៉ូល និង វីរ៉ស៊ីនី

លោកធ្លាង-ជ្រើរ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

កាលអាប៉ូលនិងវីរ៉ស៊ីនី ចេះនិយាយស្តីពាក្យជាបឋម គឺថាត្រូវស្រឡាញ់គ្នាជាបងជាប្អូន ។ ការបង្រៀនពាល់ថ្ងៃ តែតែធ្វើសេចក្តីស្នេហានៃកុមារទាំងពីរឲ្យជាខ្លាំងណាស់ ហើយតែងតែប្រព្រឹត្តឲ្យជាប្រយោជន៍ដល់គ្នានឹងគ្នា ។ ចំណែកវីរ៉ស៊ីនី មានឋានៈជាអ្នកចាត់ការខាងក្នុងផ្ទះសព្វគ្រប់ គឺត្រូវចេះសំចៃតែដែលរកបានមក សំអាតទីលំនៅរៀបចំស្មូដណ្តាំ ។ អាប៉ូលខាងការពិព្រ ពូថៅតូចមួយទៅដៃ ក៏តែងទៅជួយធ្វើការនៅស្មួនច្បារជាមួយឪពុកម្តាយ ហើយនឹងទៅពិនរកកាប់ឧស. ក្នុងពេលដែលវាទៅ. បើលោប្រទះឃើញផ្លែឈើខ្ចី ឬសំបុកចាប សូម្បីនៅដល់ចុងឈើ ក៏អាប៉ូលខំឡើងបេះ ឬយកមកផ្តើបន្ទាប់ជាមិនខាន ។

ដូនកាលគេឃើញតែម្នាក់ទេ តែគេអាចនាយថាមានមួយទៀត នៅក្បែរគ្នាជាប្រាកដ ។ ថ្ងៃមួយខ្ញុំចុះពីកំពូលភ្នំ ដែលអ្នកឯងមើលឃើញហ្នឹង ប្រទះនាងវីរ៉ស៊ីនី យកអៀមទៅក្បាលដើម្បីកុំឲ្យក្តៀងទឹក នៅក្បែរស្មួនរបស់វា ។ នៅពីចម្ងាយ ខ្ញុំស្មានថាតែនាងវីរ៉ស៊ីនីម្នាក់ឯងទេ ។ ខ្ញុំខំដើរមកយ៉ាងប្រញាប់ទឹងដួយដឹកដៃនាង លុះខ្ញុំមកដល់ ឃើញវីរ៉ស៊ីនី គោងដៃអាប៉ូលដើរនៅក្រោមអៀមជាមួយគ្នា សើចអើកចាំងពីនាក់ ។

ការសិក្សានៃកុមារទាំងពីរគឺត្រូវធ្វើឲ្យសប្បាយចិត្តទាំងអស់គ្នា ហើយជួយគ្នាទៅវិញទៅមក ។ ក្រៅពីនោះ វាល្ងង់ដូចជាអ្នកតាមិនចេះអានមិនចេះសរសេរឡើយ ។ វាមិនគិតរវល់ពីកាលដែលកន្ទុងទៅហើយទេ វាចង់ចេះ ចង់ដឹងតែក្នុងទីមួយក្រែលែក្បែរដើងក្តុំ ។ វាគិតថាលោកទាំងមូលមិនហួសពីកោះដែលវានៅនោះឡើយ ។ វាមិនគិតអ្វីថាឲ្យស្រួលជាជាងខ្លួនរបស់វាទេ ។ ចិត្តវាគិតយ៉ាងសំខាន់នោះ គឺត្រូវតែស្រឡាញ់គ្នាហើយនឹងទំធ្វើការរកស៊ី ។ មិនដែលមានរឿងអ្វីឥតប្រយោជន៍ ធ្វើឲ្យវាស្រក់ទឹកភ្នែក មិនដែលមានពាក្យអ្វីធ្វើឲ្យវាអផ្សុកឡើយ ។ វាមិនដឹងថាគេមិនត្រូវឲ្យមានពុតត្បុតផង នៅក្នុងក្រមវាទាំងប៉ុន្មានគឺមានគំនិតតែមួយ ។ មិនដឹងថាយ៉ាងដូចម្តេចហៅកុហក មិនដែលមានឈ្មោះណានិយាយបន្ទាបថាមានទេព្រោះ តែងជាក់ណែកម្ខាងដល់ក្មេងអកតញ្ញូផង ។ សេចក្តីស្នេហានៃកុមារទាំងពីរកើតតែពីសេចក្តីស្នេហានៃមាតារបស់វា ។ គេបង្ហាត់វាឲ្យតែស្រឡាញ់មាតាឲ្យអស់ពីក្នុងចិត្ត ។ បើកុមារទាំងពីរមិនបានទៅសូត្រធម៌ឯវិហារ នៅក្នុងផ្ទះគ្រប់ដោយ នៅចំការគ្រប់ដោយ សព្វទីកន្លែងវាតែងសម្លឹងសង្កេតទៅលើមេឃឲ្យទៅតាទាំងឡាយ បញ្ចូលចិត្តឲ្យតែវាមានចិត្តស្រឡាញ់ម្តាយវាកាល់គ្នា ។

ការប្រព្រឹត្តិល្អដូច្នេះ ស្ថិតនៅអស់រយៈជាកុមារភាព ដូចជាមេឃសឯទិសបូព៌ាឲ្យដឹងថាមុខជានឹងមានថ្ងៃរះមានពន្លឺល្អ ។ ឥឡូវនេះកិច្ចការ

កង់ផ្លុះ ទឹងក្រៅផ្លុះ ត្រូវជ្លាក់មកលើកុមារទាំងពីរដែលជាអ្នកដំនួសដៃដើងម៉ែក, ពេលមានរឿងវេសងកើតជិតក្តី នាងវីរ៍ស៊ីនី ក្រែកឡើងកាន់ក្តមទៅជង់ទឹកឯជ្រោះជិតខាង ដើម្បីយកមករៀបចុំដណ្តាំស្ង ។ ថ្ងៃរះពាក់កណ្តាលដើមឈើ នាងមាគីរីតនឹងអាប៉ូលចុះពីផ្លុះខ្ទមមកផ្លុះនាងឡាតូរ ហើយបបួលគ្នាតាំងអស់ទៅសូត្រធម៌ទៅក្រែមម្ចប់ដើមចេក ដែលមានផ្លែផ្អែមពីសា លុះសូត្រធម៌រួចក៏បរិភោគអាហារជាមួយគ្នាជាធម្មតា ។ អាប៉ូលកាន់តែពេញរូបពេញភាងមុខមាត់ស្អាតបាត ។ វីរ៍ស៊ីនី ជានអាយុ ១២ ឆ្នាំហើយ ភាងសៅក៏កាន់តែមានទ្រង់ទ្រាយល្អ សក់ក្រហមប្រឿងៗ ដុះគ្រុបពីលើក្បាល ក្អែកសម្បុរដូមេឃ បបូរមាត់ក្រហមឆលើសើចឡើងបៃបសមរម្យ នាកណ្តាលមុខសដូចបណ្តូលចេក ហើយស្រស់ញញឹមក្នុងពេលនិយាយស្តី បើគាលណាទៅស្ងៀម កន្ទុយក្អែកបៃបឈឿងបាញ់ទៅលើបន្ទប់ ទម្នង់ជាស្ត្រីមានចិត្តទន់ ហើយច្រើនសូតសង្ស ។ ចំណែកអាប៉ូលក៏ពេញចំទង់ភង់ខ្ពស់ជាងវីរ៍ស៊ីនី សម្បុរសណ្តែកបាយច្រមុះស្រួច ច្រវែងក្អែកទៅបៃបមុត ។ កំពុងធ្វើការ បើឃើញប្អូនស្រីវាមក វាឈប់ស្ងៀមហើយមកអង្គុយជិត ។ ពេលបាយ វាមិនសូវនិយាយគ្នាទេ ។ បើវាទៅស្ងៀម ទំនង់គ្រប់គ្រងបថ មើលទៅលំអដើងទេ គេស្មានថាជារូបភូនទេព្តាធ្វើពីថ្មកែវ តែបើវាក្រឡេកមកច្របះប្តញញឹមមកចំ គេត្រូវប់ថាជាក្មេងច្របកបដោយសេចក្តីសុខរីករាយជានិច្ចមិនបាច់ចាំសួរឲ្យដឹងចិត្តឬដឹងភាក្យ ។

ចំណែកនាង ឡាតួរ កាលណាឃើញកូនមានវ័យចំរើនឡើងពេញ
រូបពេញកាងហើយ ក៏មានសេចក្តីព្រួយនឹងកន្លែងចិត្តរឹងរឹតតែធំឡើង ។
ច្បងកាលនាងនិយាយប្រាប់ខ្ញុំថា: "បើអត់អំពីខ្ញុំទៅ វ៉ីស៊ីនី នឹងទៅ
ជាអ្វីទៅ បើគ្មានទ្រព្យសម្បត្តិសោះ?" ។

ទៅឯប្រទេសបារាំង នាងនេះមានម្តាយម៉ងមួយជាស្ត្រីមានទ្រព្យ
ប៉ុន្តែដកហើយ គឺគាត់នេះហើយដែលឃាត់នាងមិនឲ្យយកលោក ឡាតួរ
ធ្វើជាប្តី ដល់ឃាត់នាងមិនស្តាប់ក៏ប្តេជ្ញាថាឈប់ទំនុកបំរុងនាង ទោះបី
នាងដល់នូវសេចក្តីលំបាកយ៉ាងណាក៏ដោយ ។ តែពេលនេះឈប់ខ្វាស
ពាក្យដែលម្តាយម៉ងបានទំសន្យាទុកពីជាន់មុន នាងចេះតែឲ្យដំណឹងទៅ
ជានិច្ចដល់ម្តាយម៉ង អំពីប្តីទទួលអនិច្ចកម្ម អំពីកំណើតកូន អំពីសេចក្តី
ទុក្ខលំបាក ដែលនៅស្រុកគេតែក្បាលមួយ ។ តែនាងមិនដែលឃើញ
ម្តាយម៉ងតបសំបុត្រមួយមកវិញសោះ ។ នាង ឡាតួរក៏មិនអៀន តាំង
សរសេរសំបុត្រឆ្ងៃទៅទៀត សុំឲ្យអាណិតតែវ៉ីស៊ីនីចុះ បើមិនអាណិត
ដល់រូបនាងហ្នឹង ក៏ចាត់ឈឺប៉ុន្មានឆ្នាំកន្លងទៅហើយ នាង ឡាតួរមិន
ដែលបានទទួលដំណឹងអ្វីមួយពីម្តាយម៉ងសោះ ។

ក្នុងឆ្នាំ ១៧៣៨ បីឆ្នាំខាងក្រោយពីពេលការដែលតាំងលោកបួរដុណ្ណ
ឲ្យមកនៅត្រតត្រាក្នុងកោះដែលនាងនៅ នាងបានដឹងថា លោកនេះត្រូវ
ការឲ្យសំបុត្រមួយដល់នាង គឺម្តាយម៉ងផ្ញើមក ។ ម្តងនេះនាង ឡាតួរសុំ

ទៅឯពារ-ល្ហីលែងគិតត្រួយអំពីសំលៀកបំពាក់មិនស្អាត សេចក្តីសប្បាយ
លើកស្ទួយនាងផុតពីការគោរពចំពោះមហាជន ។ លោកប្តូរដុំណែឲ្យ
សំបុត្រមួយដល់នាង ។ ម្តាយមីងនិយាយបន្ទោសកុយកូនសំបុត្រនោះថា
ហ្នឹងហើយឯកសនាខ្លួនដែលយកមនុស្សផ្តេសផ្តាស អនាថា ធ្វើជាប្តី
ការចំណងហ្នឹងហើយតែងនាំទោសមកជាមួយផងឃើញឬទេ? សេចក្តី
ស្ងាប់មកឆក់យកពីមុខទៅ គឺធ្លាកដជាព្រះជាម្ចាស់លោកជាក់ទោសឲ្យ
ឯងបានទៅពួនទៅកូនកោះ ដើម្បីកុំឲ្យអាប់កេរ្តិ៍ឈ្មោះវង្សត្រកូលគឺល្ហ
ហើយបានទៅទៅកូនប្រទេសដែលងាយរកស៊ី ស្រួលរកធនធាន រៀវ
លែងតែមនុស្សកំដរ ។ លុះនិយាយប់ន្ទោសកុយសព្វគ្រប់ហើយ ម្តាយ
មីងត្រឡប់សរសើរខ្លួនឯងថា គាត់ជាមិនយកប្តីទៀត ព្រោះគិតកុំ
ឲ្យមានគ្រោះថ្នាក់ប្រែនលើកពេក ។ ការណ៍ពិតនោះគឺគាត់ធ្លាថ្នាំធំចង់
រៀបការតែនឹងប្រុសដែលមានវង្សត្រកូលត្រឹមត្រូវ ទោះបីប្រុសនោះគ្មាន
សម្បត្តិក៏ដោយ តែទោះបីទោពួកក្រុមព្រះវង្សដែលគេមិនសូវរវល់នឹងរូប-
សម្បត្តិ រៀវតែខ្ទេញចេញ ហ្នឹងក៏គ្មានអ្នកណាចង់យកគាត់មានរូប
អាក្រក់ចិត្តរឹង ធ្វើជាប្រពន្ធឡើយ ។

នាងម្តាយមីងបន្ថែមសេចក្តីបន្ទិចមកទៀតជាខាងក្រោយ សេចក្តី
កូនសំបុត្រថាគាត់បានគិតដូច្នេះជាស្រេចហើយ ទើបទំផ្ញើជាមួយនឹង
លោកប្តូរដុំណែមក ។ ដែលទំផ្ញើមកនេះ ដើម្បីបញ្ជាក់ឲ្យកុយយល់ថា

តាមទំនៀមឥឡូវនេះ គេត្រូវខ្ចប់អ្នកថែរក្សាជាងបច្ចាមិត្ត គាត់និយាយបង្កាច់កេរ្តិ៍ឯងហើយ ទើបធ្វើហាក់ដូចជាអាណិតគ្នាវិញ ដើម្បីសំដែងឲ្យជាក់ច្បាស់ដល់លោកឪពុកដុំណែថា ការរើនរូសចិត្តអាក្រក់នៃខ្លួនហ្នឹងវាសមនឹងពុតកេរ្តិ៍ ។

នាងឡាតូរ ពេលដែលទៅយកសំបុត្រ លោកឪពុកដុំណែធ្វើតោះតើយ មិនពាក់ទាក់រកនាងសោះ ។ ត្រង់ការសុខទុក្ខអំពីខ្លួននាងនឹងកូននាង មិនព្រមនិយាយសោះ គ្រាន់តែគេថា: យើងចាំដឹងគ្នាទៅពេលមុខ ហើយស្តីបន្ទោសថា: នាងធ្វើឲ្យម្តាយមើងពិបាកចិត្តយ៉ាងដូច្នេះគឺនាងឯងខុសហើយ ។

នាងឡាតូរត្រឡប់មកលំនៅអាត្មា ព្រួយសើរនឹងប្រែដើមទ្រូងពេញដោយសេចក្តីទុក្ខ ។ មកដល់ផ្ទះកាលណា អង្គុយចុះដកដង្ហើមធំ ចោះសំបុត្រទៅលើតុហើយមានវាចាទៅកាន់នាងសំឡាញ់ថា: "ឃើញទេ? ហ្នឹងហើយគឺផលនៃការអត់ធ្មត់ មិនចេញស្តីរវាង ១១ ឆ្នាំ" ។ ដោយពួកអ្នកផ្ទះគ្មាននរណាចេះអានអក្សរ នាងក៏ចាប់សំបុត្រមើលឲ្យអ្នកឈ្លាសស្តាប់ ។ គ្រាន់តែមើលសំបុត្រហើយក្តាម នាងម៉ាគីរីតនិយាយឡើងថា: "ចុះយើងមានបើត្រូវការអ្វីពីអ្នកអស់នោះ? ព្រះជាម្ចាស់មិនដែលលះបង់យើងចោលទេ គឺព្រះអង្គហើយជាបិតាយើង ។ ចុះយើងរស់នៅតាំងពីពេលនោះមកដល់សព្វថ្ងៃនេះ មិនបានសេចក្តីសុខឬ? ហេតុអ្វីក៏

សំឡាញ់ព្រួយចិត្ត? ហ្នឹងគឺខុកថាសំឡាញ់ឯងជាស្ត្រីគ្មានសេចក្តីក្លាហាន" ។ ដល់ឃើញនាងឡាតួរចេះតែយំ នាងម៉ារគីរតសុះទៅកៀកនុបហើយហៅថា: "នែសំឡាញ់? នែសំឡាញ់?" តែសំដីចេញមកមិនរួចព្រោះការខ្វែកខ្វួលចុកនៅក ។ វីរ៉ស៊ីនីឃើញដូច្នោះ ទឹកភ្នែកហូរហាមសុះទៅចាប់ដៃម្តាយខ្លួន នឹងនាងម៉ារគីរត ហើយនាំមកនុបនៅដើមទ្រូង, អាប៉ូលទឹងភ្ញាំង ក្អែកឡើងក្រហមដូចអណ្តាតភ្លើង ស្រែកគ្គាប់ដៃទន្ទ្រាំដើរ មិនដឹងគិតធ្វើដូចម្តេច ។ ឮដូច្នោះ ឌូម៉ាំងនឹងម៉ារីរត់មក ហើយទៅកន្ធរួម គេឮតែសំឡេងនៃសេចក្តីទុក្ខ "នុ!.., លោកស្រី!... លោកស្រីម្ចាស់! លោកម្តាយ!.. ចូរលោកកុំយំឡើយ" ។ អំណាចសេចក្តីស្នេហាសំដែងឡើងខ្លាំងពេកអាចរំលត់សេចក្តីទុក្ខនាងឡាតួរបាន ។ នាងនាំអាប៉ូលនឹងវីរ៉ស៊ីនីមកក្នុងដៃតាំងពីរ ហើយនិយាយប្រាប់ដោយទឹកមុខសប្បាយចិត្តថា: "នែកូន! អ្នកហ្នឹងហើយជាហេតុនាំឲ្យគេតទុក្ខដល់ម្តាយ ម្យ៉ាងទៀតគឺអ្នកហ្នឹងហើយធ្វើឲ្យម្តាយគេកាយ ។ នុ ព្រលឹងមាសម្តាយ! សេចក្តីទុក្ខមានតែពីចម្ងាយទេ ចំណែកការសប្បាយនៅជុំវិញម្តាយ" ។ អាប៉ូលនឹងវីរ៉ស៊ីនីស្តាប់ពាក្យដែលម្តាយនិយាយមិនបានទេ ហើយកាលណាក៏ឃើញនាងឡាតួរ នៅស្ងៀមមុខស្រស់ក៏ញញឹមជាក់ហើយបបោសអង្អែលនាង ។ ជនទាំងអស់ក៏នៅជាសុខសប្បាយដូច្នេះតរៀងទៅ ។

ចិត្តសុចរិតកាន់តែចំរើនឡើងដល់កុមារទាំងពីរជារាល់ថ្ងៃ ។ អាទិត្យមួយព្រលឹមស្រាង ។ លោដែលនាងម្ដាយទាំងពីរអញ្ជើញទៅសូត្រធម៌ឯវិហារបំភ្លឺមុន មានស្ត្រីពងម្នាក់មកនៅជ្រកក្នុងគុម្ពចេកក្បែរផ្ទះ ។ ស្រីនេះស្គមដូចជារាងឆ្អឹង ហើយមានសំពត់កណ្ដាចមួយវ៉ាំងចង្កេះ ។ វាវចូលមកក្រាបទៀបដើងនាង វីស៊ីនី ដែលកំពុងដណ្ដាំសូ ហើយមានវាចាថា: "ខ្ញុំ អ្នកស្រីក្រមុំអើយ! សូមនាងមេត្តាអាណិតខ្ញុំជាបាវគេ ហើយលួចរត់មកនេះផង ប្រហែលជាមួយខែហើយ ខ្ញុំដើរតែក្នុងក្តំ រកអាហារទទួលមានគ្មាន បរិភោគតែផ្លែឈើ អ្នកប្រមាញ់ទឹងខ្លែរបស់គេចេះតែដេញខ្ញុំ ។ ខ្ញុំរត់ចេញពីចៅហ្វាយខ្ញុំមក អ្នកនេះជាកូដម្ចីក៏ម្នាក់នៅឯស្ទឹងទៀ គេធ្វើជាបខ្ញុំខ្លាំងណាស់ ដូចនាងឃើញរូបខ្ញុំស្រាប់" ។ នាងពងបង្ហាញខ្នងក្រវេមក្រាមមកាសសុទ្ធតែស្នាមរំពាត់ ។ នាងនេះនិយាយថែមទៀតថា: "ខ្ញុំចង់ទៅលោតទឹកសម្លាប់ខ្លួនតើ! តែលុះភ្លេចដឹងថានាងក្រមុំនៅក្នុងទីនេះ ខ្ញុំមានចិត្តមួយគិតថា នៅកន្លែកមិភាគនេះ នៅមានមនុស្សចិត្តល្អដែរ បើដូច្នេះ អញកុំអាលសម្លាប់ខ្លួនសិន" ។ វីស៊ីនី ឮដូច្នោះមានចិត្តត្រិត្រចក៏ឆ្លើយថា: "កុំឯងអីម៉ង! ចូរមីងអញ្ជើញពីសាជាយសិនទៅ" ។ ហើយវីស៊ីនី ឱ្យនាងពងបរិភោគអាហារដែលនាងកំពុងចាត់ចែងនោះ ។ ដោយអំណាចអត់ឃ្លានថ្ងៃនាងពងស៊ីមួយរំពេចអស់គ្មានសល់ ។ ឃើញស្រីនេះឆ្អែតហើយ វីស៊ីនីនិយាយថា: "ខែម៉ង! ខ្ញុំចង់ទៅនិយាយសុំ

ទោសទីឯទៅហ្វាយលោកមីងឲ្យ តាលណាឃើញមីងដល់ទៅ គាត់មុខ
ជាមានសេចក្តីអាណិតមិនខាន មីងជូនខ្ញុំទៅផ្ទះគាត់បានប្តេះ ? នាងឆ្នង
ឆ្លើយថា: "ព្រះជាម្ចាស់អើយ! ការណ៍ត្រង់ហ្នឹងស្រួចលើនាង
ក្រមុំទាំងអស់ ខ្ញុំចេះតែតាមទៅទីណាក៏ដោយ" ។ វីរ៍ស៊ីនី ហៅបងក
មកហើយអង្វរឲ្យជូននាងទៅបន្តិច ។ នាងឆ្នងនាំកុមារកុមារីទាំងពីរ
ដើរតាមផ្លូវកណ្តាលព្រៃ កាត់ភ្នំយ៉ាងខ្ពស់ឆ្ងង់ស្ងឹងយ៉ាងធំ ។ ថ្ងៃត្រង់ជន
ទាំងបីនាក់ បានទៅដល់កូនភ្នំមួយនៅក្បែរមាត់ស្ទឹងភ្លៅ ។ នៅទីនោះ
គេឃើញផ្ទះមួយយ៉ាងស្អាត មានដំណាំដាំដុះយ៉ាងសម្បើមពួកបាវស្រី
ប្រុសជាច្រើន ធ្វើការតាមមុខត្រសួងរៀងខ្លួន ។ មនុស្សម្នាក់ជាទៅ-
ហ្វាយដើរចេះទៅមកកណ្តាលពួកកម្មករទាំងនោះ បៀមខ្សែរមួយនៅ
មាត់មានរំពាត់ផ្តៅមួយកាន់នៅដៃ ។ អ្នកនោះរាងដំបង សម្បុរខ្មៅបន្តិច
ក្អែកខ្លួចិញ្ចើមខ្មៅជិត ។ វីរ៍ស៊ីនីជាម្តាយទាំងណាស់ កាន់ដៃអាប៉ូលដើរ
ចូលទៅជិត ហើយនិយាយអង្វរសូមទោស សូមឲ្យអាណិតនាងឆ្នងជា
បាវផង ដែលនៅឈរខាងក្រោយនាង ។ មុនដំបូងអ្នកនោះ បៃតងធ្វើ
ព្រងើយមិនចង់ស្តាប់តែមកកាន់កៃងទាំងពីរ ដោយឃើញលំសៀកចំពាក់
មិនល្អ តែដល់ឃើញរូបនាងវីរ៍ស៊ីនីស្អាតសមរម្យ សំឡេងពិរោះ បន្ទន់ខ្លួន
ទៅសូមទោសដូច្នោះ អត់ទ្រាំមិនបាន កំដកខ្សែរពីមាត់ ហើយលើក
រំពាត់ផ្តៅបង្អុលទៅមេយ រួចនិយាយថា: "មិនអីទេ អញអត់ទោសឲ្យ

តែមិនមែនគិតដល់ព្រះដូចនាងថាឡើយ គឺដោយអំណាចការស្រឡាញ់
នាងឯង" ។ វីរ៍ស៊ីនី ធ្វើសញ្ញាឲ្យមាង់ត្នង់ចូលទៅរកចៅហ្វាយនាយ
របស់ខ្លួន ហើយនាងលាចេញ អាប៉ូលដើរតាមក្រោយ ។

កុមារទាំងពីរឡើងកាត់កំដូរដែល តាមផ្លូវដែលខ្លួនទើបនឹងចុះមក
លុះដល់កំពូលភ្នំ ក៏នាំគ្នាឈប់សំរាកកំឡាំង ក្រោមម្លប់ឈើមួយដើម
ហ្នាននាយផង ស្រែកទឹកផង ។ វានាំគ្នាដើរអត់បាយ ចម្ងាយប្រហែល
ប្រាំគីឡូម៉ែត្រ តាំងពីថ្ងៃរះឡើង ។ អាប៉ូលនិយាយនឹងវីរ៍ស៊ីនីថា:
"នែអូន! ប្រហែលជាងថ្ងៃត្រង់ហើយដឹង! បងដូចជាឃ្លានបាយស្រែក
ទឹក នៅទីនេះ យើងគ្មានអីស៊ីទេ យើងត្រឡប់ចុះទៅសូមបាយម្ចាស់
នាង្គង់នោះស៊ីសិន" ។ - "ទេបង! ខ្ញុំខ្លាចគាត់ទុះណាស់ បងឯង
មិនចាំពាក្យម្តាយយើងថាទេឬ? បាយមនុស្សកំណាច ដាក់ចូលក្នុងមាត់
ដូចជាដុំក្រួស" ។ - "បើដូច្នោះ យើងធ្វើដូចម្តេចទៅ? ឈើទាំងអស់
នេះ ផ្លែស៊ីមិនបានសោះ នៅទីនេះ មានតែផ្លែអម្ពិលនឹងផ្លែក្រចឆ្មារ" ។
- "ព្រះជាម្ចាស់មិនលែងអាណិតយើងទេ" ។ ដោយសច្ចភាព
សំដីសូមអាហារទៅជាសក្តិសិទ្ធិដូចចិត្ត ។ និយាយមិនទាន់ផុតពីមាត់
ស្រាប់តែឮសូរទឹកជ្រោះហូរចេញពីថ្មជិតខាង ដែលក្នុងទាំងពីរអង្គុយ ។
វានាំគ្នារត់សំដៅទឹកថ្លាដូចកញ្ចក់ លុះផឹកបួចគាស់ណា ក៏នាំគ្នាបេះព្រលិត
ដែលដុះក្បែរខាងស៊ីបន្តិច ដើម្បីបង្អន់ការឃ្លាន ។ (មានត)

ពិធីបុណ្យចូលឆ្នាំ

នៅទីព្រះលានខាងត្បូងស្រះព្រះវិហារ (ខេត្តសៀមរាប)

ព្រះមហាឧត្តមរាជ្ញា (រ៉ីយប្បញ្ញោ) កែ-អឿន វត្តព្រះព្រហ្មរត្ន

រៀបរៀង

កាលពីថ្ងៃអាទិត្យ ៤ កេីត ខែចេត្រ ឆ្នាំកេីចត្វាស័ក ព.ស. ២៤៩៥ ត្រូវនឹងថ្ងៃទី ១៣ ខែមេសា ឆ្នាំ ១៩៥២ ជាទិវាសចូលឆ្នាំថ្មី លោកវរៈសេនីយ៍ត្រី (សក្តិ ៤) ឈួនម្ងួលពេជ្រ ព្រមទាំងសហការី គឺក្រុមឯកទេស បានផ្តើមធ្វើបុណ្យដ៏ធំធ្ងាក់ ។ ក្នុងពិធីបុណ្យនេះមានការរៀបចំពេញជាច្រើន មានពេលសម្រាប់ព្រះសង្ឃ ទឹងពេលសម្រាប់ទទួលបដិសណ្ឋារៈដល់ពួកភ្ញៀវជាដេីម ពេលទាំងនោះសុទ្ធតែមានតាក់តែងវិចិត្រវចនាដោយបុប្ផជាតិផ្កាឈេីសស់ទឹងផ្កាំរយោលក្រជាស ទង់ជាតិធំ - តូចចងខ្វាត់ខ្វែង ។ លុះយប់ នៅកន្លែងធ្វើបុណ្យនោះ មានទេស្សនីយភាពយ៉ាងចំលែក គឺពន្លឺចង្កៀងអគ្គិសនីបញ្ចេញរស្មីចាំងចិញ្ចាចគ្រប់កន្លែង ។ លុះថ្ងៃមានសភាពរុងរឿងណាស់ដែរ រថយន្តជាងរយបានទៅបរមកមានទង់ជាតិចងនៅក្បាលរថយន្តបក់រេចៗ គ្រប់តែរថយន្ត គួរជាទីញាំងចិត្តឲ្យរីករាយ សប្បាយក្រៃពេក ។ ពាល់ទិវាត្រីបុណ្យនេះ គេសង្កេតឃេីញពួកប្រជាជនក្នុងខែត្រនេះ ព្រមទាំងខែត្រក្រៅមកជួបជុំកុះករមេីរដេរជាសពាសពេញណែនណាន់តាន់តាប់ពាប់សែននាក់ ។ បុណ្យនេះ

អ៊ុក: ធឹក ឧទ្ធារកិត្តិលេខ ប្រៀបប្រហែលគ្នានឹងពាជពិធីចំរើនព្រះជន្មវស្សា ព្រះករុណាជាម្ចាស់ជីវិតលើត្បូងនៅពាជធានីភ្នំពេញ ។ ពួកប្រជានិករទាំងប៉ុន្មាន ដែលបានមកកាន់ពិធីបុណ្យ តែងមានទឹកមុខរីករាយស្រស់ស្រាយ ហាក់ដូចជាមានសោមនស្សចេតនាចំពោះការកុសលនេះពន់ពេក ។

កម្មពិធី

ថ្ងៃទី ១ គឺថ្ងៃ ៤ កេច ខែចេត្រ (១៣ - ៤ - ៥២) វេលាម៉ោង ៧ យប់ ដួបជុំពុទ្ធបរិស័ទ្ធ នមស្សការព្រះរតនត្រ័យ រួចនិមន្តព្រះសង្ឃជាប្រធានអង្គចំរើនព្រះបរិត្ត, ម៉ោង ៩ យប់ លោកវរសេនីយ៍ត្រីថ្លង់ថ្លាបកថា រៀបរាប់អំពីពិធីបុណ្យ, ទឹងទួលអំណរដល់ពុទ្ធបរិស័ទ្ធដែលអញ្ជើញអំពីទីដ៏ឆ្ងាយមកជួយអនុមោទនាបុណ្យ, តពីនោះទៀងស្មោនជាតិជូនបង់ប្អូនរួមជាតំមើលកំសាន្ត ដរាបដល់ម៉ោង ១ ទើបឈប់ ។

ថ្ងៃទី ២ គឺថ្ងៃ ៥ កេច (១៤ - ៤ - ៥២) វេលាម៉ោង ១១ ព្រឹកដួបជុំពុទ្ធបរិស័ទ្ធនមស្សការព្រះរតនត្រ័យ, រួចជាក់ឆ្នាត អង្គាសចង្ហាន់ព្រះសង្ឃ, ម៉ោង ៥ រសៀលនិមន្តព្រះសង្ឃចំរើនព្រះពុទ្ធមន្ត, ម៉ោង ៦ កន្លះនិមន្តព្រះមហាឧត្តមវិជ្ជា កែ - អឿន វត្តព្រះព្រហ្មវត្តសំដែងធម្មទេសនាៗ ចប់ លោកវរសេនីយ៍ត្រី ថ្លង់ថ្លាបកថាជាសំគាល់ដល់បង់ប្អូន

រួមជាតិ; តពីនោះ ក្រុមយោសនាការគាមេរិកាំងបញ្ចាំងកុន នឹងលេង
ល្ខោនជាតិ ។

ថ្ងៃទី ៣ គឺថ្ងៃ ៦ កេចិ (១៩-៤-៥២) វេលាម៉ោង ១១ ព្រឹកជាក់
ជាត្រូ អគ្គាសចង្ហាន់ព្រះសង្ឃ, ម៉ោង ៥ កន្លះ និមន្តព្រះសង្ឃចំរើនព្រះ
បរិត្ត, ម៉ោង ៧ លោកវរសេនីយត្រី និមន្តព្រះមហាឧត្តមវិជ្ជា កែ-អឿន
ឲ្យថ្លែងធម្មទេសនា ជូនពរសិក្ខុសាធុការដល់ពុទ្ធបរិស័ទ នឹងឲ្យតាំងមេត្តា
ចិត្តផ្សាយផលដល់បុព្វបុរសដែលបានកសាងធ្វើសាទរបុណ្យ, ក្រោយ
នោះនិមន្តព្រះអាចារ្យ សុខ-សាន្ត វត្តព្រះព្រហ្មរតន៍ សំដែងធម្មទេសនា
ចប់ លេងល្ខោនជាតិ ដូចយប់មុន ។

ថ្ងៃទី ៤ គឺថ្ងៃ ៧ កេចិ (១៦-៤-៥២) ម៉ោង ១១ ព្រឹកដួបជុំពុទ្ធ-
បរិស័ទ នមស្សការព្រះរតនត្រ័យ, និមន្តព្រះសង្ឃសូត្រតហូរទៅធ្វើ
បុណ្យ នឹងបង្វឹកូលទុក្ខិសផលជូនដល់បុព្វបុរស, រួចប្រគេនចង្ហាន់ដល់
ព្រះសង្ឃ ម៉ោង ៨ យប់ និមន្តព្រះវិន័យធរ ឯក-ញឹម វត្តធម្មិស្សរភាម
សំដែងធម្មទេសនា ចប់ លេងល្ខោនជាតិដរាបដល់ម៉ោង ១ ទើបឈប់,
សម្គាល់ថាសម្តែចកិច្ចបុណ្យតែប៉ុណ្ណោះ ។

ដោយតេជានុភាពនៃកុសលកុសលដ៏ប្រសើរក្នុងពេលនេះ យើងខ្ញុំជា
ក្រុមកងឯកទេសខ្មែរ សូមថ្វាយព្រះពរជាកុសលចំពោះព្រះបិយមហាក្សត្រ
ដែលព្រះអង្គជាអគ្គសាសនូបត្ថម្ភ ព្រមទាំងព្រះពរជាទ្រព្យនុវង្ស សូមឲ្យ

ជានច្រើនស្ថិតនៅកន្លែងរីរាយជាសម្បត្តិជាសុខក្សេមក្សាន្ត ។ សូមជូនពុទ្ធ
នេះដល់គណៈរដ្ឋមន្ត្រី នឹង សូមប្រគេនដល់ព្រះសង្ឃគ្រប់អាវាស មន្ត្រី
នឹងបណ្តាជនខ្មែរ ដែលអាស្រ័យនៅក្នុងគ្រប់ខ័ណ្ឌសីមាក្នុងរដ្ឋទាំងមូល
សូមឲ្យជានប្រកបដោយសេចក្តីសុខសេចក្តីចំរើនគ្រប់ប្រការសព្វទិវាក្រ
កាលកុំបីអាក់ខានឡើយ ។ សូមតេជះព្រះរតនត្រ័យដែលជាឥតឥន់ពំនាក់
របស់ជាតិខ្មែរ សូមតេជានុភាពនៃពពួកទេវតា មានមហិទ្ធិឫទ្ធិនឹងទេព
តាមហេស័ក្តិ ដែលទទួលថ្នាក់តំណែងចុះមកកន្លែងនៅថ្ងៃនេះ ព្រមទាំងទេព្តា
ដែលស្ថិតនៅក្នុងអនន្តរបក្រវាឡទាំងប៉ុន្មាន សូមជួយឲ្យប្រទេសកម្ពុជា
ដៀសវាងឆ្ងាយពីសេចក្តីទុក្ខវេទនាផ្សេងៗ ឲ្យជានថ្កើងរុងរឿងនាប់ដូចអំពី
អតីតកាលឡើងវិញ, សូមជួយបណ្តុះបណ្តាលសតិបញ្ញាដល់បណ្តាជន
ជាតិខ្មែរ ឲ្យជានកើនចំរើនឡើង ហើយឱតទំធ្វើការងារល្អៗ ដែលជា
ប្រយោជន៍ដល់ប្រទេសជាតិមាតុភូមិ លះបង់នូវសេចក្តីឱលក្រអូសពីឥន្ទ-
សន្ធានឲ្យជ្រះស្រឡះតាំងចិត្តសុចរិតប្រព្រឹត្តការងារដ៏វិសេស ឲ្យជាន
ថ្កើងថ្កានធាប់ដូចជាពពួកជនទៅក្នុងអាវ្យប្រទេសនានា កុំបីឃ្លៀងឃ្លាត
ឡើយ ។

អ្នកធ្វើលំបាកស្មើរស្មាប់ តែមិនឈ្នះអ្នក
ដែលនៅស្ងៀម មានមាត់ចាំតែថា ។

ក. អ.

សេចក្តីកត់ហេតុ

ក្នុងការប្រទ្ឆងមហាបរិយត្តិ បឋមវិជ្ជា

នៅទីវត្តឃ្លាំង ខេត្តឃ្លាំង (កម្ពុជាក្រោម)

របស់អធិបតីនៃក្រុមសមាជិក

នៅថ្ងៃច័ន្ទ ១៥ កើតខែផល្គុន ឆ្នាំថោះត្រីស័ក ព.ស. ២៤៨៦ ត្រូវនឹងថ្ងៃទី ១០ មីនា គ ស. ១៩៤២ ក្រុមមេប្រយោគដែលលោកចាវហ្វាងសាលាបាលីជាន់ខ្ពស់បានជ្រើសរើសមក គឺ:

ព្រះគ្រូបញ្ញាវង្ស ចៅអធិការវត្តឃ្លាំង ... ជាអធិបតី

អ្នកមហា យ័ញ្ញ - ទីម
ព្រះមហា ថាច់ - ច្បាជ
ព្រះមហា ប៉ុល - ឈន
ព្រះមហា វិញ - គឿង

} ក្រុមសមាជិក

បញ្ជីនៃបេក្ខសមណៈ ចាំងអស់ចំនួន ១០៨ រូប ប៉ុន្តែដល់ពេលថ្ងៃដែលបើកទុកាសប្រទ្ឆងបានមកជួបជុំគ្នា មានចំនួន ៦៣ រូប ដែលមកអំពីខេត្តនានាមានខេត្តព្រះត្រពាំង ពលលាវនឹងឃ្លាំងជាដើម បានមកជួបជុំនៅសាលាបាលីវង់វត្តឃ្លាំង ។

ពេលម៉ោង ៨ ព្រឹក លោកចៅហ្វាយខេត្តឃ្លាំង ក៏បានអញ្ជើញមកដល់មន្ទីរសាលាបាលីវង់វត្តឃ្លាំង យកប្រយោគមកប្រគេនដល់លោកអធិបតីក្រុមសមាជិក បានលើកបង្ហាញដល់ពួកសិស្សដែលសុំប្រទ្ឆងថាប្រយោគដែលជាក់កន្លែងក្នុងតាំង ៩ នេះ បំពេញលំក្តជាការធ្ងើ តំបន់

ត្រឹមត្រូវណាស់ ស្រេចហើយលោកអធិបតីតាំងវៀបចំការនេះដោយបរិសុទ្ធ ។

ក្នុងរវាងប៉ុន្មានថ្ងៃដែលប្រឡង ប្រយោគសរសេរតាំងអស់នោះឥតមានហេតុថាស់ការណ៍អ្វីឡើយ ។

កូនសិស្សដែលប្រឡងជាប់ពេញទីមានចំនួន ៥៩ រូប គឺសិស្សក្នុងខេត្តឃ្លាំង ២៩រូប ខេត្តព្រះត្រពាំង ១៦ រូប, ខេត្តពលលាវ ១១ រូប ខេត្តត្រមួនស ៣ រូប ខេត្តកំពង់ធ្នាំង ១ រូប ។ ត្រមាំងចំនួនពីនុម្មាក់ៗមានស្រង់ឡើងជាក់ក្នុងសំបុត្រមួយបិទភ្ជាប់តាមសេចក្តីនេះ ។

សេចក្តីកត់ហេតុនេះ មាន ៤ ច្បាប់ទុកសម្រាប់ជាផ្លូវការ ។

ខេត្តឃ្លាំង ថ្ងៃព្រហស្បតិ៍ ៣ កេីត ខែផល្គុន ឆ្នាំថោះត្រីស័ក ព.ស. ២៤៩៦ ត្រូវនឹងថ្ងៃទី ១៣ មីនា គ.ស. ១៩៥២

លោកអធិបតីនៃក្រុមសមាជិក

ហត្ថលេខា, ថាច - លន

ក្រុមសមាជិក

១ - អ្នកមហា យ៉ញ - ទីម

២ - ព្រះមហា ថាច - ច្បាដ

៣ - ព្រះមហា ប៉ុល - ឈន

៤ - ព្រះមហា វិញ - គ្រឿន


ជានយល់ព្រម

អ្នកអធិបតីនៃក្រុមពុទ្ធសាសនបណ្ឌិត្យ

ហត្ថលេខា ឡាំ - ឯម

ភគ្គមសុទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៤ ខែមិថុនា លេខ ៦

ព.ស. ២៤៩៥ — គ.ស. ១៩៥២

ដំណឹងពិសេស

កាលពីថ្ងៃអង្គារទី ៩ ខែកញ្ញា ឆ្នាំ១៩៥២ វេលាព្រឹកម៉ោង ៧, ព្រះអរុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់បានស្តេចយាងទៅកាន់ទីចំណតយន្តហោះពោធិចិនតុង ដើម្បីជូនដំណើរគណៈប្រតិភូខ្មែរ ដែលត្រូវទៅប្រជុំធ្វើសន្និសីទលើកទី ២ នៃពុទ្ធិកសមាគមពិភពលោកនៅក្រុងតូក្យូ (ប្រទេសជប៉ុន) ដែលកំណត់វេលានៅថ្ងៃទី ២៥ កញ្ញា ទៅទល់នឹងថ្ងៃ ១៣ តុលាឆ្នាំ ១៩៥២ ។ គណៈប្រតិភូខ្មែរនោះ មានព្រះពោធិវង្ស ហួត - ខាត ជាងហ្វាងសាលាជាលីជាន់ខ្ពស់ ជាប្រធាន, ព្រះមហាថៃ - សុខដែលចេះស្ទាត់ភាសាចិន - ជប៉ុន នឹងលោកហ្លេ - ម៉ង់ - ប៉ាន់ ជាអ្នកបកប្រែភាសា ព្រមទាំងគហបតី បេ - យាន ដែលធ្វើដំណើរទៅជាឯកជន ។

ក្នុងខណៈដែលគណៈប្រតិភូនេះកោញដំណើរទៅ គេសង្កេតឃើញសម្តេចព្រះសុមេធាធិបតីសង្ឃនាយក, សម្តេចព្រះធម្មលិទ្ធ ឧត្តមប្រ៊ីក្សា នឹងព្រះសង្ឃច្រើនអង្គ ព្រមទាំងនាម៉ឺនធំ - តូច ឧបាសកឧបាសិកាជាច្រើនកុះករ បានជូនដំណើរគណៈប្រតិភូខ្មែរនោះទៅដល់ចំណតយន្តហោះ ពោធិចិនតុងដែរ ។

យើងបានដំណឹងមួយទៀតថា: ប្រទេសឥណ្ឌៀមានគណៈប្រតិភូទៅកាន់ទីនោះដែរ មានលោកម៉ាឡាល សេកេរៈដាប្រធាន ។ ក្នុងឱកាសដែលធ្វើដំណើរទៅនេះ គណៈប្រតិភូនោះបានដង្ហែព្រះសារីរិកធាតុ ដែលដាក់ក្នុងប្រអប់មាស១ទៅជាង ដើម្បីធ្វើអំណោយដល់ប្រទេសជប៉ុន ។ ព្រះសារីរិកធាតុនោះ មានទំហំប្រមាណប៉ុនគ្រាប់ស្ពៃ មានចំណាស់ជាង ២.០០០ ឆ្នាំមកហើយ ដែលគេយកពីក្នុងវត្តមួយ នៅប្រទេសឥណ្ឌៀ កាលពីគ្រិស្តសករាជ ១៨៧០ ។

ពុទ្ធសាសនបណ្ឌិត្យ



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពន្ធអាស៊ីទ្វីប (តមក)	លោកវ៉ាយ-ប៊ុក	៤០៣
សាមគ្គីកថា	ព្រះជាឡាត់ ជាន់-លី	៤០៩
អត្តានុទិដ្ឋិ (តមក)	ឧកញ៉ា សំ-ស៊ុន	៤១៧
ផ្នែកអក្សរសាស្ត្រ		
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ...	៤២៥
រឿងសាមកុក (តមក)	ឧកញ៉ា ទូ-កន	៤៣៧
រឿងអាវ៉ក្សថ្លែងរឿងម្តែប្រាំ (តមក)	លោក វ៉ាយ-ប៊ុក	៤៤៨
រឿងស្នេហាជាតិ (តមក)	លោក គង់-លឹម	៤៥៦
រឿងប៉ូលនិងវីរ៉ស៊ីនី (តមក)	លោក ផេង-ដ្រីវ	៤៦៦
កំណាត់នឹងប្រវត្តិការណ៍		
ពិធីបើកសាលាបរិយត្តិធម្មវិន័យ នៅវត្ត ព្រះព្រហ្មវត្តន៍ សៀមរាប	ព្រះមហាឧត្តមវិជ្ជា កែ-អឿន .	៤៧៥

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨៣.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE

		Pages
La lumière de l'Asie (suite).....	M. Ray-Buc	403
Sâmaggikathâ	Vén. Chon-Ly	409
Attânuditthi (suite).....	Oknha Sam-Sun	417

PARTIE LITTERAIRE

Education morale (suit.).....	Vén. Pœung-Pam	425
Histoire de SAMŒOK (suite)	Oknha Nou-Kan	437
Les vingt cinq récits du Mauvais Génie (suite)	M. Ray-Buc	448
L'Amour de la Patrie (pièces de Théâtre) (suite).....	M. Kong-Lim	456
Paul & Virginie (suite).....	M. Phéng-Chrieu	466

NOTES ET CHRONIQUES

Cérémonie d'ouverture de l'École de Pariyattidhammavinaya à vat PrahPromaratana-Siemreap.....	Vén. Ker-œurn	475

Prix d'abonnement annuel comprenant (12 numéros:) 18$00

វគ្គទី ៨

La Lumière de l'Asie

លោកស៊ឺរ - អេតវាំង អារណ្ឌលត៍ - តែង
លោករ៉ាយ - ប៊ុក ក្រមការ ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែជាខ្មែរ

(តមក)

ការប្រព្រឹត្តទីពីរគឺសម្មាសង្កប្ប: ។ ចូរអ្នកមានមនោសញ្ចេតនាដ៏ល្អ ចំពោះសត្វដែលមានជីវិតរស់នៅ: ត្រូវបំបាត់ពីសន្ដានចិត្តអ្នក នូវចិត្ត អសប្បុរស លោភៈ ទោស. គាល់តែដីវភាពរបស់អ្នកស្ថិតនៅ ដូចជាខ្យល់បក់រំភើយ។ ត្រជាក់ស្រួល ។

ការប្រព្រឹត្តទីបីគឺសម្មាវាចា ។ ចូរអ្នកត្រួតត្រាបបូរមាត់អ្នកឲ្យដូចជាបបូរមាត់នោះជាទ្វារព្រះបរមកដ៏ធំ ដែលព្រះមហាក្សត្រគង់នៅ; ត្រូវឲ្យវាចារបស់អ្នកប្រកបដោយសេចក្ដីសូប៊ន់មានសភាពត្រង់ ពិពោះ ប្រៀបដូចជាអ្នកពោលចំពោះព្រះភក្ត្រនៃព្រះករុណា ជាម្ចាស់ដីវិតលើត្បូងដែលទ្រង់គង់នៅទីនោះ ។

ការប្រព្រឹត្តទីបួនគឺសម្មាកម្មន្ត: ។ ត្រូវតែសកម្មភាពរបស់អ្នកនិមួយៗ តស៊ូនឹងការកំហុសឬជួយទ្រទ្រង់នូវកុសលធម៌ឲ្យចំរើនជាលំដាប់ដូចជាគេឃើញខ្សែច្រាក់ដែលយកគ្រាប់ថ្មកែវមកដោតក្រងធ្វើជាខ្សែកមួយឬដូចជាព្រហ្មវិហារដែលជាមូលដ្ឋាននៃសុភកម្មរបស់អ្នក ។

មានផ្លូវបួនខ្ពស់ជាងនេះទៀត ។ តែដើងអ្នកដែលមិនបានជាប់ជំពាក់ក្នុងលោកាមិស (លោកធម៌) អាចធ្វើដំណើរទៅតាមផ្លូវនោះបានគឺ សម្មាអាជីវៈ, សម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ ។ ដូច្នេះ បើស្លាបអ្នកមិនទាន់ដុះទេ, កុំឲ្យបង់ពិសោធន៍ហើយហើរទៅកាន់ព្រះអាទិត្យ; អាកាសនៅភូមិភាគខាងក្រោមមានសភាពស្រួលហើយ ត្រូវឲ្យបង់ដែលអ្នកនិយមប្រែមិនជាលំបាកណាស់ណាទេ ។ មានតែជីវសត្វដែលមានកំលាំងមាំមួនអាចចេញពីសំបុកដែលខ្លួនបានធ្វើមកយូរហើយ ។ ខ្ញុំដឹងថាការស្រឡាញ់ប្រពន្ធកូនជាការប្រសើរ; មេត្រីភាពនឹងការសប្បាយក្នុងជីវភាពគួរឲ្យស្រួលក្នុងចិត្តពន់ពេក ចិត្តសប្បុរសដែលកើតឡើងពីការប្រព្រឹត្តិទូវគុណធម៌ មានប្រយោជន៍ដ៏សំខាន់; តែការខ្វាចដែលជាសភាពខុសមែនពិត តែងចូលទៅស្ថិតនៅជាប់ក្នុងសន្តានចិត្ត ។ ចូរអ្នករស់នៅបែបនេះចុះគឺជាការណ៍ឃើញកិច្ចបស់អ្នក; ចូរអ្នកយកការពុំពិលភាពរបស់អ្នក ធ្វើជាផណ្តើរមាសហើយព្យាយាមប្រឹងឡើងទៅតាមផណ្តើរនោះដោយវិធីប្រតិបត្តិពាល់ទំាងត្រឹម ទូវកិច្ចការកំណ្តែចឡំឲ្យពាល់តែដឹងច្បាស់ថា វត្តុតាំងនេះធ្វើឲ្យយើងកំណ្តែចឡំមែន ទើបតែប្រែឲ្យទៅជាវត្តុពិតគួរជាទីពេញចិត្តបាន ។ ព្រោះហេតុដូចនេះ បានជាអ្នកអាចទៅដល់ទីខ្ពស់ស្រឡះឡើងយ៉ាងស្រួល, អ្នកយល់ថាការៈនៃបាបអកុសលដែលប្រព្រឹត្តនោះមិនជាធ្ងន់ប៉ុន្មានទេ, ហើយអ្នកនឹងបានអបរំខ្លួនចិត្តា-

នុភាពខ្លាំងក្លាត្រង់ការកាប់បំបាក់នៃចំណងសម្ផស្ស ហើយនឹងចូលទៅ
កាន់ផ្លូវអដ្ឋង្គិកមគ្គ ។ អ្នកណាដែលតាមមកដល់ទីនេះ ឈ្មោះថាបាន
ថ្នាក់ទីមួយ (បឋមជ្ឈាន) អ្នកនោះបានស្គាល់សុទ្ធិមគ្គ, នឹងអដ្ឋង្គិកមគ្គ
មិនយូរទេ អ្នកនោះនឹងបានទៅដល់ស្ថានដ៏ខ្ពង់ខ្ពស់គឺ និព្វាន (និព្វាន) ។

អ្នកណាបានទៅដល់ទុតិយជ្ឈាន (ថ្នាក់ទីពីរ) គឺមានចិត្តជ្រះថ្លាសុទ្ធ
ផុតពីវិចិកិច្ឆា, សេចក្តីព្រួយបារម្ភ ហើយនឹងសង្រ្គាមខាងក្នុង គឺបំបាក់ឲ្យ
សាបសូន្យនូវកាមច្ឆន្ទ លែងត្រូវការព្រះសង្ឃនឹងគម្ពីរសាស្ត្រ ត្រូវវិល
មកចាប់បដិសន្ធិកងមនុស្សលោកមួយជាតិទៀត ។

តពីនោះមក, ហៅថាតតិយជ្ឈាន (ថ្នាក់ទីបី) ទៅថ្នាក់នេះ ចិត្តមាន
សភាពដ៏បរិសុទ្ធស្អាត, ចិត្តនោះឡើងផុតទៅដល់ព្រហ្មវិហារចំពោះដ៏វ-
សត្វ នឹងសន្តិភាពជាសុក្រិត ។ ដីវភាពនៃលោកផុតកិច្ច, គុកនៃដីវភាព
វិនាសខ្ចាត់ខ្ចាយគ្មានសេសសល់ ។ តែមានបុគ្គលខ្លះមានចិត្តផុតពីភព
ដែលមានសត្វរស់នៅប្លែកដែលមើលឃើញដោយអាយតន: ហើយទើបចិត្ត
ទៅដល់តែបំណងជាអវសានថ្នាក់ទីបួនគឺចតុត្ថជ្ឈាន ដែលជាតែបំណងនៃ
សន្តបុគ្គល, ព្រះពុទ្ធនឹងព្រះសាវកជាអសេខបុគ្គល ។ អ្នកចូរមើល; ចាប
អកុសលទាំងដប់ដួលធ្លាក់ចុះទៅក្នុងធូលីដីតាមថ្នាក់ ឬ ឈានទាំងនោះដូច
ជាបច្ចាមិត្តកាចសាមាទ្យដែលពួកយោធា បានកាត់ក្បាលជាច់ស្ងាប់:
ដំបូងគឺ អត្តទត្តភាព, អសទ្ធា, វិចិកិច្ឆា, ព្យាបាទ, កាមច្ឆន្ទ ។ អ្នកណាបាន

...

ចំផ្លាញនូវបាបអកុសលទាំងប្រាំនេះ, អ្នកនោះបានឆ្លងទៅដល់ថ្នាក់ទីបី
កន្លងចំណោមទាំងបួនថ្នាក់; តែចិត្តនៅស្រឡាញ់ដីវភាពនៃលោក (លោ-
កាមិស) ចិត្តប្រាថ្នានូវស្ថានសួគ៌, សក្កាយទិដ្ឋិ, អវិជ្ជា, មាន: ។ ដូចជាអ្នក
ដែលឈរនៅលើកំពូលភ្នំដែលមានទឹកកក មានតែមេឃខៀវ, ល្វឹងល្វើយ
នៅពីលើដូចគ្នានឹងមនុស្សដែលសម្លាប់បាបអកុសលជាអរិសានបានទៅ
ដល់ស្ថានព្រះនិព្វាន ។

ពួកទេវតា ដែលនៅខាងក្រោមមានចិត្តបំណងចង់ឲ្យបានទៅដល់
ទីនោះដូចអ្នកដំណើរដែរ; បើទុកជាតែលោកវិនាសសាបសូន្យយ៉ាងណា
ក៏មិនអាចធ្វើចិត្តព្រះខីណាស្រពនោះ ឲ្យងាកបែររេទៅខាងណាបាន
ឡើយ; បំពោះបុគ្គលនេះដឹងភាពទាំងអស់, លោកបានស្គាល់អស់ហើយ
សភាពស្ងាប់គឺរលត់ដោយសាបសូន្យពិត; កម្មលែងសង់គេហដ្ឋានថ្មីឲ្យ
នៅតទៅទៀត ។ លោកលែងស្វែងរកអ្វីឡើយ, លោកនោះឈ្មោះថា
មានវត្តសព្វទាំងអស់, ចិត្តលោកនោះចូលទៅរួបរួមលាយជាមួយនឹង
បក្រវាឡ (ធម៌?) ។ បើអ្នកណាមួយពោលថាព្រះនិព្វានគឺគ្មានដីវសត្វ,
ចូរអ្នកតបទៅវិញថា អ្នកនោះកុហក; បើអ្នកណាពោលថាព្រះនិព្វានគឺ
សភាពរស់នៅ, ចូរអ្នកតបទៅអ្នកនោះវិញថា អ្នកកន្តែចឡំ ព្រោះអ្នក
ទាំងអស់គ្នាមិនដឹងអ្វីសោះឡើយពីព្រះនិព្វាននេះ. អ្នកទាំងអស់មិនស្គាល់
នូវពន្លឺដែលចាំងនៅលើចង្កៀងបែក ហើយការសុខនោះ គឺនៅក្រោ

ជីវភាពនឹងកាលឯនេះសោះ ។ ចូរអ្នកចូលទៅកាន់មគ្គសច្ច; គ្មានអ្វីក្នុងជាងការស្អប់ (ព្យាបាទ), គ្មានអ្វីលំបាកជាងតាមពាតប្តូរតាមតណ្ហា, គ្មានអ្វីបំភ័ន្តគំនិតជាងវេទនារម្មណ៍ឡើយ; ចូរអ្នកចូលទៅកាន់មគ្គសច្ច, អ្នកណាដែលបានទៅតស៊ូនឹងបាបអកុសលរបស់ខ្លួន អ្នកនោះឈ្មោះថាត្រាច់ទៅមុខហើយ ។ ចូរអ្នកចូលទៅកាន់មគ្គសច្ច, នៅទីនោះមានប្រភពជាច្រើនបាញ់ទឹកថ្លាត្រជាក់ស្រួល ចំពោះអ្នកណាដែលស្រែកឃ្លានឲ្យគ្រែបផឹកបានស្កប់ស្កល់, នៅទីនោះមានបុប្ផាអមតៈដុះនៅតាមផ្លូវនោះ, នៅទីនោះ កាលវេលាក៏ស្រួល, សុខសប្បាយ ។

ឃ្លាំងច្បាប់ (វិន័យ?) មានសភាពវិសេសជាងគ្រឿងអលង្ការទៅទៀត, ឧបាសៅនៃច្បាប់នោះមានសភាពឧត្តុង្គឧត្តមជាងទឹកឃ្មុំទៅទៀត សភាពឆ្ងាញ់ពិសាគ្មានវត្ថុអ្វីនឹងយកមកប្រៀបផ្ទឹមបានឡើយ ។ ដើម្បីនឹងរស់នៅបែបនេះ, ចូរអ្នកស្តាប់វិធានថ្កុំយ៉ាង :

កុំសម្លាប់, ធ្វើចិត្តអាណិតអាសូរដល់សត្វហើយកុំឲ្យហាមឃាត់វិត្តន៍សត្វតាំងពីសុទ្ធមសត្វឡើងទៅ ។

ឲ្យហើយទទួលទ្រព្យដោយសេរី, តែកុំឲ្យយកទ្រព្យគេដោយចិត្តលោភ, ប្តូរប្រែមធ្យោបាយជាទំនុកម្ម ប្តូរបន្លួច ។

កុំឲ្យពោលពាក្យកុហក, កុំឲ្យពោលពាក្យបេសុញ្ញវាចា, មុសាវាទ, កុំឲ្យពោលពាក្យមិនពិត; សភាពពិតគឺជាលំនាំបរិសុទ្ធខាងក្នុង ។

កុំឲ្យសេពសុភនឹងមេរ័យដែលធ្វើឲ្យចិត្តកករល្អក់; ធ្វើប្រាជ្ញាឲ្យភ្លឺ, ធ្វើកាយឲ្យបរិសុទ្ធ; កុំឲ្យប្រើទឹកសោម: ។

កុំឲ្យកន្ធឹងប្រពៃណីស្តីដែលជាប្រពន្ធសាមន្តជន ហើយកុំឲ្យប្រព្រឹត្តអំពើអកុសលផ្សេងៗ នឹងស្តីដោយខុសច្បាប់ប្តូរគ្រាជម្ងឺជាតិ ។

រួចព្រះសម្មាសម្ពុទ្ធជាបរមគ្រូព្រះអង្គទ្រង់ទេសនាអំពីតវណីយកិច្ចនៃបិតានឹងមាតា បុត្រា-បុត្រី, គូកន, មិត្តភ័ក្តិ, ព្រមទាំងពន្យល់អំពីអ្នកដែលមិនបានកាច់បំបាក់នូវប្រែក់នៃសម្ផស្ស ដែលមានជើងខ្លាយមិនអាចឡើងទៅតាមផ្លូវកន្តារប្រកបដោយជ្រោះគុហាលំបាកជាច្រើន, ឲ្យអ្នកនោះរចនាដំរៀបរបស់ខ្លួនដោយលៃលកក្នុងការប្រព្រឹត្តធ្វើនូវស្ថាននេះពាល់ទំពាល់តិ ។ កងការកុសល; ត្រូវឲ្យអ្នកទាំងនោះព្យាយាមតាច់ដើរបន្តិច ។ ទៅតាមផ្លូវអដ្ឋង្គិកមគ្គ; ត្រូវឲ្យបុគ្គលទាំងនេះស្រឡាញ់សព្វសត្វលោកដូចជាខ្លួនរបស់ឯង; ព្រោះបាបអកុសលកន្ធបច្ចុប្បន្នទាំងប៉ុន្មានជាលទ្ធផលនៃបាបដែលប្រព្រឹត្តពីអតីតជាតិ ហើយអ្នកដែលជាបុណ្យបច្ចុប្បន្នមកពីការកុសលដែលប្រព្រឹត្តពីជាតិមុន ។ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា មនុស្សណាប្រព្រឹត្តបែបនេះ, មនុស្សនោះ អាចចេញពីអត្តា (រូប) បាន ហើយអាចស្រោចស្រង់ពិភពលោកបាន ហើយអ្នកនោះអាចបានសេចក្តីសុខក្នុងអនាគតជាតិ ហើយរចនាខ្លួនឲ្យទៅជាបុគ្គលសុក្រិតហើយ ព្រះអង្គទ្រង់ព្រះពាជមានឧរ៉ាទថា ពីកាលមុន តថាគតសញ្ជរទៅកន្ធឹក្នុងភពគ្រែះ ក្នុងព្រៃវេឡុវន ។ (មានត)

សាមគ្គីកថា

ព្រះបាទ្បាត់ ចាន់-លី វត្តបទុមវតី ក្រុងភ្នំពេញ

ទេសនាជាក់វិទ្យុឃោសនៃស្នូនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ រោចខែភទ្របទ ឆ្នាំជូតសំរឹទ្ធិស័ក

ព. ស. ២៤៩១ (៣—១០—៤៨)

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រមទាំងព្រះសទ្ធម្មនឹងភពួកនៃព្រះអរិយសង្ឃ ដោយសេចក្តីគោរព ។

រួចហើយ អាត្មាភាពនឹងលើកយកពុទ្ធភាសិតមួយបាទត្រង់បទថា:

សុខា សង្ឃស្ស សាមគ្គី *មកសំដែងជាវេបុល្លធម្មទេសនា ផ្សាយតាមវិទ្យុកម្ពុជា ចែកជូនអស់លោក អ្នកទាំងឡាយស្តាប់ ដូចតទៅនេះ:-*

សុខា សង្ឃស្ស សាមគ្គី

"សេចក្តីព្រមព្រៀងនៃពួកឲ្យកើតសុខ"

សាមគ្គី បានដល់សេចក្តីព្រមព្រៀង ។ កាលពិចារណាមើលពួកសត្វនឹងវត្ថុទាំងពួង ដែលប្រព្រឹត្តទៅក្នុងលោកនេះ គួរកើតអស្ចារ្យពន់ពេក ព្រោះសំឡឹងឃើញដល់ការប្រុងផ្គុំចូលគ្នាជាពួកៗ របស់ជាតុនោះៗ ដែលប្រព្រឹត្តទៅដោយធម្មតា ឬមានអ្នកប្រុងផ្គុំតែងឡើង ១នេះយ៉ាងណា; ឯសត្វគឺពពួកមនុស្សនឹងតិរច្ឆានដែលមានរូបកាយជាច្រើនដ គឺធាតុ ៤ យ៉ាង បឋវី-អាបោ-តេជោ-វាយោ ផ្គុំចូលគ្នាហើយឲ្យកើតផល

គឺកំរើកកាយបាន ពោលវាចាបាន ឃើញបាន ស្តាប់បាន ហិតបាន លិទ្ធក្សបាន ពាល់ត្រូវបាន ដឹងខ្លួនបាន ដឹងសុខទុក្ខ ឬ ឧបេក្ខា ចេះកំណត់ចាំមុខការនានា គិតនេះគិតនោះបាន, កាលជាតុទាំង ៤ ប្រព្រឹត្ត ទៅដោយអាការៈព្រមព្រៀងគ្នាឲ្យកើតផលនេះបានត្រឹមណា ក៏បានឈ្មោះថារស់នៅត្រឹមណោះ បើជាតុទាំង ៤ មិនប្រព្រឹត្តទៅដោយអាការៈព្រមព្រៀងមិនឲ្យកើតផលនេះបានហើយក៏បានឈ្មោះថា "ស្លាប់" សត្វដែលបានឈ្មោះថារស់នៅ ក៏ព្រោះសេចក្តីព្រមព្រៀងរបស់ជាតុទាំង ៤ សូម្បីការបរិភោគថ្នាំកងវេលាឈឺ ក៏ដើម្បីជួយបំរុងសេចក្តីព្រមព្រៀងរបស់ធាតុទាំងបួនដែលមានទាក់តាំង ឬទល់ស្ងាក់ដំណើរដោយអំណាចប្រព្រឹត្តទៅខ្វាំងលើសលុបឬដួរៗជាងគ្នា វត្ថុនោះៗ នាយជាងធ្វាតប្រឆងផ្ទុធាតុនោះៗ ប្រកបចូលគ្នាឡើង មានគ្រឿងចក្រ ទឹងកម្ងាំងក្តើងជាដើម ក៏ឲ្យសំរេចផលតាមអំណាច ។

ប្រការមួយទៀត មនុស្សម្នាក់ៗ មានពាងកាយទឹងអវយវៈស្មើគ្នា មានកម្ងាំងក៏ស្មើៗគ្នាប៉ុណ្ណោះ មិនលើសថយជាងគ្នាប៉ុន្មាន តែអាចទឹងធ្វើការងារបានធំជាងខ្លួន ដូចយ៉ាងកសាងផ្ទះ តាំងស្រុកនគរ គ្រប់គ្រងគ្នាទឹងគ្នា តស៊ូអន្តរាយខ្វល់ខ្វាយរកសេចក្តីសុខឲ្យដល់គ្នាទឹងគ្នា តែកម្ងាំងម្នាក់ៗ កាលណាទឹងធ្វើបាន ការដែលធ្វើបានដូច្នោះក៏ព្រោះសេចក្តីព្រមព្រៀងជួយគ្នាទៅវិញទៅមក មិនថាតែពួកមនុស្ស សូម្បីសត្វ

តំរូវឲ្យគាត់ដូចគ្នា ព្រមព្រៀងគ្នាហើយក៏អាចធ្វើការលើសខ្លួនដូចករណ្តៀវកសំបុកបានធំៗ ហូរឆ្ងាមោច ហូរឆ្ងាំ ជួយគ្នាទំមនុស្ស ជួយគ្នាទាំមនុស្ស ឬធ្វើសត្វតិរច្ឆានដែលធំជាងឲ្យខ្លាចបាន ។

ពាក្យដែលបានភោលមកប៉ុណ្ណោះ ដើម្បីចង្អុលឲ្យឃើញថាសាមគ្គីគឺសេចក្តីព្រមព្រៀងមានគុណដល់មនុស្ស សមដូចពាក្យសុភាសិតថា សព្វេសំ សង្ឃភ្លូតាំ សាមគ្គី វុឌ្ឍិសាធិកា ប្រែថា "សាមគ្គីធ្វើឲ្យកើតសេចក្តីចំរើនរបស់មនុស្សទាំងឡាយ ដែលជាពួកជាគ្រុមឲ្យសម្រេច" ។

ឯសាមគ្គីនោះ មានប្រភេទជា ២ គឺ កាយសាមគ្គី "ព្រមព្រៀងដោយកាយ" ១, ចិត្តសាមគ្គី "ព្រមព្រៀងដោយចិត្ត" ១ ។ ការដែលបុគ្គលទាំងឡាយនៅក្នុងសេចក្តីបង្គាប់មេជាប្រធាន ១ ត្រូវតាំងចិត្តធ្វើតាមសេចក្តីបង្គាប់មេជាប្រធាននោះឲ្យព្រមៗគ្នា ដូចពួកមនុស្សធ្វើការងារព្រមព្រៀងគ្នា មានអូសទាញជាដើមក្តី ពួកទាហានព្រមព្រៀងគ្នាចូលតស៊ូសត្រូវក្តី ដូច្នេះជាកាយសាមគ្គី ។ ការដែលបុគ្គលទាំងឡាយនោះព្រមចិត្តគ្នាប្រកបកិច្ចដែលពោលហើយនោះ តាមកម្លាំងខ្លួនឯងក្តី មានមេជាអ្នកបង្គាប់ក្តី ចងមេត្រីដោយអំណាចមិត្តសន្តវៈគ្នាក្តី ដូច្នេះជាចិត្តសាមគ្គី ។ សាមគ្គីទាំង ២ ប្រភេទនេះ រមែងឲ្យផលតាមអំណាចកាលបើសាមគ្គីដើរទៅពេញទីហើយ វត្ថុអ្វីដែលផុតវិស័យឬដែលមិន

សម្រែចកំឥតអង្គីមាន, កំតែថាសាមគ្គីជាគុណដល់ពួកមិនមានវត្ថុអ្វីប្រៀប
ស្មើត្រឹមណា សេចក្តីបែកចាកសាមគ្គី កំជាទោសដល់ពួកមិនមានអ្វីស្មើ
ត្រឹមណោះ ។ កាយសាមគ្គីជាប្រធានខាងល្អៗ អាចឲ្យប្រព្រឹត្តទៅ
បាន ចំណែកចិត្តសាមគ្គីយល់ព្រមអាស្រ័យគ្នាទៅវិញទៅមក ដូច
សុភាសិតថា "ទះដៃម្ខាងមិនឮ" ។ បុគ្គលដែលនៅប្រាសចាកសាមគ្គី
រមែងមិនមានសុខមិនប្រសប់ប្រទះឃើញសេចក្តីចំរើន ហេតុដូច្នោះ ជន
អ្នកប្រាថ្នាសេចក្តីសុខ-ចំរើន កាលខ្លួននៅក្នុងពួកឬទៅប្រកបកិច្ចជាមួយ
អ្នកដទៃ គប្បីប្រាថ្នាសេចក្តីសាមគ្គីជាធំមិនគប្បីឃើញតែប្រយោជន៍ខ្លួន
មួយចំណែក គប្បីមានសេចក្តីអត់ធន់បន្ទុរបន្ទុយទិដ្ឋមាន:កាត់ខ្លី កាត់
វែងតាមពួក ។

មួយទៀត គប្បីតាំងចិត្តប្រកបដោយមេត្តា គិតអាណិតគ្នា ក្នុង
វេលាកាលធ្វើ, និយាយ, គិត, គប្បីមានចិត្តផ្សព្វផ្សាយដល់គ្នា ដោយ
លាភផល គប្បីប្រព្រឹត្តខ្លួនដោយមារយាទដ៏សុភាព មិនគប្បីប្រដែងគ្នា
ព្រោះទិដ្ឋិមាន: ។ កាលអ្នកពាល់គ្នាតាំងនៅក្នុងគុណធម៌ ដូចពោលមក
សាមគ្គីក៏កើតមានជាសេចក្តីល្អ សេចក្តីចំរើនមកដល់ខ្លួន ទើងអ្នកដទៃ
ព្រមតាំងនាយករបស់ពួកគណ: ។

សាមគ្គី គឺសេចក្តីព្រមព្រៀងនេះ ជាគុណធម៌ដ៏សំខាន់ បុគ្គល
គប្បីជាន់គួរប្រាថ្នា ក្នុងកិច្ចប្រពៃគប្បីឋាន: តាំងគតិលោក ទើងគតិធម៌,

មនុស្សអ្នកគ្មានមិត្រ មិនមានអ្នកពប់អាន ទើបត្រូវគេតិះដៀលថាជា
មនុស្សពាល ទើបមិនមានអ្នកណាគប់រក សមដោយពុទ្ធភាសិតថា
"គាត់ជាសំឡាញ់មិនមានក្នុងជនពាល" ។ អធិប្បាយថា ធម្មតាជន
ពាលមិនគាប់ចិត្តគប់អ្នកណាសោះឡើយ ។

មនុស្សម្នាក់កាលមានកិច្ចត្រូវតឡើង ក៏ត្រូវប្រឹកម្លាំងរបស់ខ្លួនឯង
មិនមានអ្នកណាជួយគាំពារមែនមានសេចក្តីចំបែងចិត្តជាប្រក្រតី ទើជា
ទីមើលងាយរបស់សត្រូវ ចំណែកអ្នកមានមិត្រច្រើនឈ្មោះថាមានកម្លាំង
ច្រើន ទើធ្វើកិច្ចណាក៏មានអ្នកជួយទំនុកបំរុង ដោយកម្លាំងកាយទើង
កម្លាំងសេចក្តីគិត ទើកម្លាំងទ្រព្យ ជាទីកោតក្រែងរបស់សត្រូវ ។
មិនចាប់មើលទៅឆ្ងាយទេ ជាធម្មតានៃវត្ថុទាំងពួងរួមចូលគ្នាច្រើនៗ
រមែងបំពេញកម្លាំងខ្លាំងក្លាឡើង ចំរៀកឈើមួយ កូនក្មេងអាចកាច់ចាក់
ជាកំណាត់បាន បើរួមចូលគ្នាជាចាប់ មនុស្សធំក៏កាច់បានដោយលំបាក;
គុណរបស់សាមគ្គី ឃើញបានដោយប្រការដូច្នេះ ។

សូមលើករឿង១ចាស កបុរសអាឡវី ឈ្មោះហត្ថក: អាឡវក:
ដែលជាមនុស្សមានពួកច្រើន មកសំដែងលួមជាគួយ៉ាងនៃវិធីចងសាមគ្គី ។
១ចាស កនេះបានត្រាបទូលព្រះដ៏មានបុណ្យថា ខ្លួនខ្ញុំនេះបានសង្គ្រោះ
មនុស្សដោយសង្គហវត្ថុ ៤ ប្រការ: គឺបានឲ្យចំណែកនៃវត្ថុផ្សេងៗ ១
បានពោលពាក្យជាទីគាប់ចិត្តដល់អ្នកស្តាប់ ១ បានប្រព្រឹត្តការឲ្យជា

ប្រយោជន៍ខ្លះទៀត ១ តាំងខ្លួនស្មើខ្លួនទៀតមិនប្រកាន់ថា ធំ - តូច ១ ។ អធិប្បាយថា: ពួកឯណាកាលមានសេចក្តីព្រមព្រៀងគ្នា រមែងដល់នូវសេចក្តីសុខ គឺ ១ - សុខកាយ ព្រោះពួកគណៈជួយគ្នាការពារអន្តរាយដែលនឹងគប្បីមានមកអំពីសត្រូវខាងក្រៅ កាលឈឺចាប់ក៏ជួយគ្នារក្សាព្យាបាល; ២ - សុខចិត្ត ព្រោះសេចក្តីស្ងប់រៀបរយក្នុងពួកគណៈ ដោយមានសេចក្តីសុខស្មើខ្លួនទៀតដូចគ្នា ។ កាលបើសេចក្តីព្រមព្រៀងឲ្យកើតសុខសមដូចសុភាសិតនេះហើយ អ្នកណារក្សាសាមគ្គីក៏ឈ្មោះថារក្សាសេចក្តីសុខ តែសេចក្តីសាមគ្គីនេះជាការណ៍យ៉ាកក្តី ដែលមនុស្សគាំងឡាយរួមគ្នាប្រតិបត្តិ ។

បណ្តាមនុស្សគាំងឡាយរមែងផ្សេងគ្នា ដោយទឹកចិត្តនឹងអធ្យាស្រ័យ ឬការសង្វែម កាយ វាចា ចិត្ត ឬានប្រែនតិចក៏ផ្សេងគ្នា អ្នកឯណានៅក្នុងពួកមិនរក្សាសេចក្តីស្ងប់ បណ្តាយឲ្យកិលេសដែលជាបដិបក្ខចំពោះសេចក្តីសាមគ្គីចូលគ្របសង្កត់ចិត្ត គាំងគ្មានទម្ង: គឺកម្លាំងសង្កត់ចិត្តទុកឲ្យទំនៅ មិនមានសញ្ញាម: គឺសេចក្តីសង្វែមកាយ វាចា ចិត្ត បណ្តាយឲ្យទៅតាមអារម្មណ៍ ដែលមកជន្ធដទ្ងេញ សំដែងកាន់កិលេសគ្រោតគ្រាត ចេញមកខាងក្រៅឲ្យប្រាកដដោយ កាយ វចី វិការ: ដូច្នេះហើយ អ្នកនោះរមែងទំលាយសេចក្តីជាទីគាប់ចិត្តរបស់មនុស្សដទៃ ទើបថាត់ថា សេចក្តីប្រតិបត្តិរបស់បុគ្គលនោះ ជាគ្រឿងទំលាយសេចក្តីសាមគ្គីឲ្យបែក

ប្រាក់ នឹងបានឈ្មោះថាទំលាយសេចក្តីសុខចុះព្រមគ្នា ដោយហេតុដូច្នេះ ហើយព្រះដ៏មានបុណ្យ ទើបទ្រង់ប្រដៅឲ្យមនុស្សព្រមព្រៀងគ្នាថា អ្នកទាល់គ្នាត្រូវប្រព្រឹត្តធម៌ គឺ: ព្យាយាមរំលត់កិលេសដែលមាននៅក្នុងសន្តានឲ្យស្រួប ដោយមិនមានសេសសល់ ព្យាយាមប្រយ័ត្នកុំឲ្យកិលេសនោះត្រឡប់កើតឡើងទៀតបាន ទើបនឹងបានឈ្មោះថា ដល់នូវសេចក្តីសុខដ៏យឺនយូរ ។

ខ្ញុំនេះសមដោយពុទ្ធភាសិតថា សមគ្គានំ តបោ សុខោ ប្រែថា "សេចក្តីព្រមព្រៀងគ្នារបស់ពួកជាហេតុឲ្យកើតសុខ" ។

សាមគ្គី មានផលដូច្នេះនេះ ក៏ត្រូវអាស្រ័យបុគ្គលនឹងធម៌ប្រកបចូលគ្នា បើមិនធ្វើដូច្នោះ សេចក្តីព្រមព្រៀងក៏មិនមាន; ទូកនឹងលឿនទៅកណ្តាលមហាសមុទ្រ ឲ្យដល់ច្រាំងដូចប្រាថ្នា ដោយកម្លាំងអ្នកទាល់គ្នាព្រមព្រៀងគ្នា បើមិនមានសេចក្តីព្រមព្រៀងគ្នាហើយ មុខជាលង់លិចទៅកណ្តាលសមុទ្រ ឬទូកចេញទៅចាកកំពង់មិនរួច ដោយមនុស្សអ្នកអុំឬអ្នកចែវ ទាស់អធ្យាស្រ័យនឹងគ្នា; សូម្បីមានមនុស្សជាមេដឹកនាំ ឬជានាយកយ៉ាងណាក៏ដោយ ព្រោះពួកអ្នកចែវ-អុំ មិនដឿស្តាប់តាមសេចក្តីបង្គាប់ សេចក្តីព្រមព្រៀងគ្នាក៏កើតឡើងមិនបាន មានរឿងកិក្ខុដែលនៅក្នុងដែនកោសម្ពិក:ជាគួយ៉ាង ។ ព្រោះតែសេចក្តីឈ្លោះប្រកែកគ្នាដោយសារតែសបន្ទិចបន្តួចប៉ុណ្ណោះ តើតវ៉ាទប់ពួកគណ: ព្រះសាស្តា

ទ្រង់ហាមឃាត់មិនត្រមទទួលស្តាប់សោះ ទើបទ្រង់យាងទៅតង់ត្រៃបាលិលេយ្យក: ៣ ខែ ពួកឧបាសក ឧបាសិកា សួរសាកដឹងហេតុនោះ។ កំឈប់ដាក់ជាត្រួត កិកុអម្បាលណោះគ្មានចង្ក្រាន់ស្រែកឃ្លានស្ទាំងស្តម ត្រមជានឹងគ្នាវិញ ឃើញគោសក្បាកដថាការបែកសាមគ្គីនាំឲ្យវិនាសធំ។ ប្រជាជនទាំងឡាយចូរអ្នករក្សាសាមគ្គីនេះទៀងមាំ កុំបណ្តោយឲ្យសាមគ្គីឃ្លាតរសាត់ពីកណ្តាប់ដៃអ្នកឡើយ ។

អាត្មាភាពសំដែងមកកន្លះសាមគ្គីកថា សន្តតថាចប់តែប៉ុណ្ណេះ ឯវំ ។

អានិសង្សសាមគ្គី

ពលរដ្ឋ ក្នុងរដ្ឋណា ក្លាចំណាប់
មានចិត្តជាប់ សាមគ្គី មីមួលឆ្គាំ
ព្រមព្រៀងគ្នា ធ្វើការងារ ជាសុខុម
ដ៏ឧត្តម ជាប្រយោជន៍ ប្រទេសជាតិ ។
ពលរដ្ឋ ក្នុងរដ្ឋនោះ ខ្ពង់ខ្ពស់ថ្លៃ
ជាតិដទៃ ភ័យរអា ពុំហ៊ានវាត
ពុំហ៊ានប្រើ អំពើកោង ការចង្អុជាតិ
សឹងរាវាត ឃ្លាតចេញឆ្ងាយ ខ្លាចសាមគ្គី ។

យ. អ.

អ្នកឧកញ៉ាឥសរ្សរង្ឃ សំ - សុខ ជាអ្នកប្រៃរៀបរៀង

(តមក)

ប្រហែលដែលពោលមកត្រឹមប៉ុណ្ណេះ ល្មមបានសេចក្តីចូលចិត្តរបស់ជនភាគច្រើន ដែលគ្រាប់យល់ថាយើងឬអត្តាមិនមានក្នុងទីចាំងពួនបានហើយ តែកប់ថា មិនសូវរៀបរយល្អទេ ព្រោះមានខ្វះច្រើនយ៉ាងផ្សេងទៀតដែលជាឡាក់ហាន នាំមកអាងដំណាស់ទៀតបាន ។ មានពុទ្ធភាសិតសំខាន់ ១ ខដែលធ្វើឲ្យមនុស្សភាគច្រើនចូលចិត្តថាយើងឬអត្តានោះមិនមានក្នុងទីចាំងពួន ចូលចិត្តអាងគ្រប់ពេលក្នុងកាលនិយាយគ្នា ដល់រឿងអត្តាអនត្តា ប្រកាន់ជាឡាក់ហានយ៉ាងរឹងប៉ឹង តែមើលទៅមិនគួរជាខ្លាំងក្លាអ្វីឡើយ ។ វេលានេះទើបលើកមកពោលទុកឲ្យឃើញចំពោះត្រង់ដែលត្រូវការថា: សព្វេ សង្ខារា អនិច្ចា, សព្វេ សង្ខារា ទុក្ខា, សព្វេ ធម្មា អនត្តា ដូច្នេះ ខាត់ជា ៣ វគ្គ ផ្សេងអាការគ្នា, វគ្គដើមថា សព្វេ សង្ខារា អនិច្ចា "សង្ខារធម៌ទាំងអស់មិនទៀង", វគ្គទី ២ ថា សព្វេ សង្ខារា ទុក្ខា "សង្ខារធម៌ទាំងអស់ជាទុក្ខ", វគ្គទី ៣ ថា សព្វេ ធម្មា អនត្តា "ធម៌ទាំងឡាយទាំងអស់ជាអនត្តា" ចាត់បានជា ៣, វគ្គយ៉ាងនេះឯង, បណ្តាវគ្គទាំង ៣ នោះ ត្រង់វគ្គចុងក្រោយដែលថា:

«ធម៌ទាំង ឡាយទាំងអស់ជាអនត្តា» នេះនាំឲ្យគេចូលចិត្តបានថាព្រះនិញ្វាន ជាអនត្តាផង ព្រោះសំឡឹងពាក្យថាធម៌ទាំង ឡាយទាំងអស់ជាអនត្តា ទើប គេចូលចិត្តថាព្រះនិញ្វាន ឬវិសង្ខារទាំងនិពេធ រាគតធម៌នោះ ក៏ជាអនត្តា ទាំងអស់ ។ ឃើញស្របគ្នាថាត្រូវត្រង់ស្អេហើយទេដឹង ទើបប្រកាន់ខុកជាគោលសេចក្តីយើញ ហើយនិយាយគ្នាថាព្រះនិញ្វានជាអនត្តា? ។ វគ្គទី ១ សំដែងសង្ខារធម៌ចង្អុលលក្ខណ មិនទៀង, វគ្គទី ២ សំដែងសង្ខារ ធម៌ចង្អុលលក្ខណ.ជាទុក្ខ, វគ្គទី ៣ ពោលផ្សែងថា ធម៌ទាំងឡាយជា អនត្តា ទើបនាំឲ្យគេចូលចិត្តថាសង្ខារធម៌ មិនទៀង ជាទុក្ខ ជាអនត្តា គ្រប់ទាំង ៣ លក្ខណ:; ចំណែកព្រះនិញ្វានត្រូវជារបស់ទៀងមិនមានទុក្ខ ទើបមិនមានស្រមោលចោលទៅក្នុង ២ ខាងដើមតែជាអនត្តា ព្រោះ ពាក្យថា «ធម៌ទាំងអស់» ស៊ីសេចក្តីទូលាយគ្រប់ទូទៅ ព្រោះដូច្នោះ ព្រះ និញ្វានក៏ជាអនត្តា ។ ស្តាប់ទើសត្រចៀកយ៉ាងម្ល៉េះទៅ? គួរនឹងថាគេ ប្រញាប់វិនិច្ឆ័យ រឿងនេះហួសពេក, តែការណ៍វិនិច្ឆ័យបែបនេះ កំតង់តើត អំពីរឿងរកអត្តាមិនដួច ទាំងឃើញថាអត្តាមិនមានក្នុងទីទាំងពួង តាំងចុះ សិប់ក្នុងចិត្តទៅហើយ ទើបគេប្រញាប់ធ្វើសេចក្តីចូលចិត្តថាព្រះនិញ្វានជា អនត្តាក្នុងព្រះពុទ្ធសាសនេះឯង ។ តែកំតង់មានអ្នកសង្ស័យក្នុងរឿងនេះ ច្រើនគ្នាដែរ ចំណែកអ្នកដែលអស់សង្ស័យ ហើយចូលចិត្តលើកឡើងអាង គ្រប់គ្រានោះមានទាំគាត់ទោស អ្នកដែលឃើញថាអត្តាមាន ថាត្រូវ

ឲ្យអង្គុយគាល់ក្បាលទង្គត់ ទៅនិព្វានមិនបាន ។ បើមិនប្រែញាប់ហួស ពេកទេ យើងត្រូវនឹកថា អនិច្ចំ ទុក្ខំ អនត្តា ៣ លក្ខណៈនេះ មានពោល មកគ្រប់កន្លែង សឹងតែសំដែងក្នុងត្រៃយខាងសង្ខារធម៌ ឬទៅក្នុងត្រៃយ ខាងលោកិយទេតើ នេះហេតុដូចម្តេច ទើបលែងឲ្យទៅប៉ះពាល់ទៅ ក្នុងត្រៃយលោកុត្តរវែង? ឯអនត្តានោះទុកបើដូចជាតួឧបទ្វៈ ចូលទីណា អន្តរាយទីនោះ ជាចំណែកបដិសេធ ចូលទៅក្នុងព្រះនិព្វាន ក៏ទៅបដិសេធ ព្រះនិព្វានទៀត, ក៏កាលព្រះនិព្វានត្រូវបដិសេធហើយ អរិយមគ្គ ៨ ប្រការដែលជាហេតុឲ្យកើតផល គឺព្រះនិព្វាននោះ យើងនឹងប្រតិបត្តិ ប្រតិបត្តិធ្វើអ្វី? ។ ព្រះពុទ្ធភាសិតនេះ សំដែងថា ធម៌ទាំងអស់ជាអនត្តា ប៉ុណ្ណោះ មិនបានសំដែងថាព្រះនិព្វានជាអនត្តាផងឡើយ, សូម្បីពាក្យថា "ធម៌ទាំងអស់" នោះស៊ីសេចក្តីដូលាយអាចដល់ព្រះនិព្វានផងក៏បាន ក៏គ្រាន់តែជាសេចក្តីស្មានទេ មិនគួរនឹងប្រញាប់ប្រញាល់វិនិច្ឆ័យដូច្នោះ ។ ក៏ពាក្យថា "ធម៌ទាំងអស់" ក្នុងព្រះពុទ្ធភាសិតនេះ គួរនឹងចូលចិត្តថា បានដល់អសង្ខតធាតុ ដែលមិនទាន់បានសេចក្តីបរិសុទ្ធិ ជាវិភគធម៌ឬ និព្វានទៅឡើយ គឺអសង្ខតធាតុរបស់សាមញ្ញសត្វ ដូចបាននិយាយ ខ្លះហើយ ក្នុងភាគដើមនៃសៀវភៅក្បាច់នេះ ។ អសង្ខតធាតុរបស់ សាមញ្ញសត្វ សូម្បីវិសេសប្រសើរល្អជាងសង្ខារធម៌ ក៏មិនសម្រេច ផលប្រយោជន៍ ព្រោះមិនស្អាត ដូចធាតុដែលនិយមមានមាសជាដើម

ផ្សំគ្នានឹងជាតុផ្សេង ។ ដែលមិនជាទិនិយម កាលមិនធ្វើការញែកលាង
ជម្រះឲ្យស្អាតមុនហើយ ក៏រកសម្រែចប្រយោជន៍ក្នុងការប្រើយ៉ាងណា
គ្មាន, ឯអសង្ខតជាតុរបស់សាមញ្ញសត្វលោកក៏ដូច្នោះឯង ត្រូវធ្វើឲ្យបាន
សេចក្តីបរិសុទ្ធិ ជាវិភគធម៌ឬនិព្វានជាមុន ទើបនឹងសម្រែចផលប្រយោជន៍
បាន ។

ពីនេះទៅនឹងនាំព្រះពុទ្ធភាសិតដែលបានលើកឡើង តាំងជាសេចក្តី
នៃសៀវភៅច្បាប់នេះខាងដើមជាច្រើនហើយនោះមកពោលម្តងទៀត
ដើម្បីនឹងបានធៀបឲ្យឃើញក្នុងព្រះពុទ្ធភាសិតថា សព្វេ ធម្មា អនត្តា
"ធម៌ទាំងពួងទាំងអស់ជាអនត្តា" យាវតា ភិក្ខវេ សង្ខតា វា អសង្ខតា
វា វិរាគោ តេសំ អគ្គមក្ខាយតិ "ម្នាលភិក្ខុទាំងពួង សង្ខតធម៌ក្តី
អសង្ខតធម៌ក្តី មានប្រមាណឯណា វិភគធម៌ (ហ្នឹងហើយ) តថា-
គតពោលថាជាកំពូលលើសលុប ជាឯធម៌ ២ ប្រការនោះ" ។ ឥឡូវ
នេះយើងពិចារណាឃើញធម៌ ៣ យ៉ាង គឺសង្ខតធម៌ ១ អសង្ខតធម៌ ១
វិភគធម៌ ១ ។ វត្ថុដែលចូលទៅផ្សំធ្វើឲ្យមួហ្មងប្រែបស់ដែលប្រែប្រួលកើត
រលត់ហៅថាសង្ខតធម៌, វត្ថុដែលមានដំហរជាប្រធាន មាំមួន ឋាវរៈ
ហៅថា អសង្ខតធម៌, សេចក្តីដែលបរិសុទ្ធិម៉ត់ចត់ បានដល់វិភគធម៌ដែល
ជាតួព្រះនិព្វាន ។ ព្រះពុទ្ធភាសិតនេះ ត្រូវធ្វើសេចក្តីចូលចិត្តថា សង្ខត-
ធម៌ នឹងអសង្ខតធម៌រួមគ្នា សូម្បីខ្វែងបានសំដែងញែកជា ២ ហើយក៏ពិត

កំត្រូវធ្វើសេចក្តីចូលចិត្តថារួមគ្នា ព្រោះវិភគធម៌ជាតួសេចក្តីបរិសុទ្ធិនោះ ជាផលនៃអរិយមគ្គ, សង្ខតធម៌ ទើងអសង្ខតធម៌ត្រូវជាកិច្ចរបស់អរិយមគ្គ; បើសង្ខតធម៌ ទើងអសង្ខតធម៌មិនរួមគ្នាទេ អរិយមគ្គក៏មិនមានកិច្ចដែលទើងត្រូវធ្វើ ព្រោះញែកគ្នាហើយ, ផលគឺវិភគធម៌សំដែងទុកធ្វើអ្វីទៀត; កិច្ចដែលអរិយមគ្គទើងត្រូវធ្វើ ក៏គឺកំចាត់សង្ខតធម៌ ដែលដូចជាមន្ទិលឲ្យអស់ចាកអសង្ខតធម៌ ឲ្យានសេចក្តីបរិសុទ្ធិជាសង្ខារ គឺវិភគធម៌នោះឯង; បើមិនធ្វើសេចក្តីចូលចិត្តថា រួមគ្នាដូចពោលហើយនោះទេ អសង្ខតធម៌ក្នុងទីនេះក៏ជាវិសង្ខារត្រូវគ្នានឹងវិភគធម៌នោះឯង, កាលបើដូច្នោះ ព្រះធម្មទេសនា ពុទ្ធភាសិតក៏តប្រយោជន៍ក្នុងការសំដែង អ្នកមិនចូលចិត្តក៏ទើងរករឿងថាមិនមែនជាពុទ្ធភាសិត, តែតាមពិតក៏ជាធម៌មានប្រឭាយមកជាឭាក់ហាន មាននៅក្នុងអគ្គប្បសាទសូត្រ ទើងរតនសូត្រ ក្នុងព្រះត្រៃបិដក ។

រឯសំដែលរួមគ្នា ត្រូវញែកនិយាយជា ៣ រឿងតាមវត្ថុ ដែលត្រាស់ថា "សង្ខតធម៌ក្តី អសង្ខតធម៌ក្តី មានប្រមាណឯណា វិភគធម៌ ទើងហើយតថាគតពោលថា ជាកំពូលខ្ពស់ជាងធម៌ ២ ប្រការ" នោះ បើប្រៀបសេចក្តីដូចយើងនិយាយថា ពែងមួយយ៉ាង, មន្ទិលមួយយ៉ាង, សេចក្តីបរិសុទ្ធិរបស់ពែងមួយយ៉ាង ។ បណ្តា ៣ ខនេះ ខទី ៣ យើងត្រូវចូលចិត្តថា ពែងញែកចេញចាកមន្ទិលហើយ ទើបនិយាយថាបរិសុទ្ធ

ព្រោះដូច្នោះ ២ ខាងដើម ត្រូវចូលចិត្តថារួមគ្នា ក៏គឺពែងមិនបរិសុទ្ធ ហេតុនោះដែលទ្រង់សំដែងដូច្នេះ ត្រូវចូលចិត្តថាទ្រង់មានព្រះបំណងចំពោះត្រង់អសង្ខតធម៌ ព្រោះជាធម្មជាតិដ៏ល្អមានឡាក់ហាន តែកាលច្បូកច្បឺនជាមួយនឹងសង្ខារធម៌ក៏ឥតប្រយោជន៍ ទើបទ្រង់សំដែងចង្អុលផល គឺវិភគធម៌ជាសេចក្តីបរិសុទ្ធក្នុង ១ ទី ៣, កាលទ្រង់ចង្អុលសេចក្តីបរិសុទ្ធិក្នុង ១ ទី ៣ ហើយ ក៏ទុកជាការតិះដៀលសង្ខារធម៌ក្នុង ១ ដើមទៅឯង ព្រោះសង្ខារធម៌បីដូចជាមន្ទិលធ្វើអសង្ខតធម៌ឲ្យសៅហ្មង ព្រោះដូច្នោះក្នុងទីនេះ ទើបត្រូវចូលចិត្តថារួមគ្នា ។ កាលបើបូរបចិត្តដូចពោលមកហើយនោះ ត្រូវយកព្រះពុទ្ធភាសិត ២ បែកទៅនោះមកធៀបគ្នាដូច្នេះគឺ សព្វេ សង្ខារា អនិច្ចា, សព្វេ សង្ខារា ទុក្ខា (សង្ខារទាំងឡាយទាំងអស់មិនទៀង, សង្ខារទាំងឡាយទាំងអស់ជាទុក្ខ) ២ ១នេះ ចុះក្នុងពាក្យថា សង្ខតា ភ (សង្ខតធម៌ក្តី); សព្វេ ធម្មា អនត្តា (ធម៌ទាំងឡាយទាំងអស់ជាអនត្តា) ១ចុងនេះ ចុះក្នុងពាក្យថា អសង្ខតា ភ (អសង្ខតធម៌ក្តី) ទើបឃើញថាបានថា ដែលថាធម៌ទាំងឡាយទាំងអស់ជាអនត្តានោះ ក៏គឺអសង្ខតធម៌ ក្នុងពាក្យថាអសង្ខតា ភ ដែលនៅមិនទាន់បានសេចក្តីបរិសុទ្ធិ ជាវិភគធម៌នោះឯង, អនត្តានោះឥតមានឈានឡើងទៅដល់វិភគធម៌ ឬនិព្វាន ដែលទ្រង់ពោលថាជាកំពូលខ្ពស់ក្នុង ១ ទី ៣ នោះទេ ។

តាមដែលបានពោលមកនេះ ពាក្យថាបានកំចាត់គ្រោលនៃសេចក្តីយើញ ដែលថាព្រះនិព្វានជាអនត្តានោះចេញ បានមួយចំណែកជាចំណែកដែលសំខាន់ ។

នៅមានទៀតដែលចូលចិត្តលើកឡើងអាងថា អត្តា មិនមានក្នុងធម៌តាំងពួង គឺព្រះពុទ្ធភាសិតថា បុគ្គលមត្តិ ធម្មមត្តិ ឥតិ ពាលោ វិហញ្ញតិ, អត្តា ហិ អត្តនោ គតិ, កុតោ បុត្តា កុតោ ធនំ ដូច្នេះ ប្រែថា "មនុស្សពាលវង្វេងក្តៅក្រហាយ ដោយសេចក្តីចូលចិត្តថាបុត្រារបស់យើងមាន ទ្រព្យរបស់យើងមាន, ខ្លួនរបស់ខ្លួនមិនមាន, ហើយនឹងយកបុត្រ យកទ្រព្យអំពីឯណាហ៎ ? " ។

ពាក្យថា អត្តា ហិ អត្តនោ គតិ "ខ្លួនរបស់ខ្លួនមិនមាន" នោះឯងនាំឲ្យចូលចិត្តថា អត្តា (ខ្លួនឯណា) មិនមានក្នុងធម៌តាំងពួង, មនុស្សឆ្នាតអាចគិតយើញដូច្នោះក៏បាន តែមនុស្សល្ងង់គង់មិនព្រមយើញផង ។ អនត្តា ក្នុងព្រះពុទ្ធភាសិតនេះ ចូលចិត្តថាទ្រង់សំគាល់យកសង្ខារធម៌ ក្នុងត្រៃយលោកិយ មិនមែនសំដៅយកព្រះនិព្វានជាត្រៃយលោកុត្តរទេ ។ ដែលពោលលើកបុត្រនឹងទ្រព្យជាដើមនោះ សំគាល់ចង្អាស់ដៅហើយថាជារឿងសង្ខារធម៌ ចំណែកខាងបដិសេធ ជាអនត្តា (មិនមែនខ្លួនឯណា) ។ ធម្មតាមនុស្សសាមញ្ញអន្ធការរមែងរង្គើរកខ្វឹមសារ នឹងសេចក្តីទៀងថាវៈក្នុងសង្ខារធម៌ លុះដល់មិនសមបំណង

កំចាន់សេចក្តីក្តៅក្រហាយ ព្រះអង្គទើបត្រាស់ថា អត្តា ហិ អត្តនោ នត្ថិ "ខ្លួនរបស់ខ្លួនមិនមាន" ហើយ កុតោ បុត្តា កុតោ ធនំ "នឹងយកបុត្រ យកទ្រព្យអំពីឯណា ហ៎ ។ ការរកសារៈ ឬរកអត្តា (ខ្លួនចុាណ) ក្នុងសង្ខារធម៌នោះ ស្មើគ្នានឹងការរកពុកមាត់នៅមាត់អណ្តើក នឹងរកស្នែងនៅក្បាលទន្សាយ រមែងមិនបានសម្រេចដូចសេចក្តីចុាថាទេ សូម្បីរកមិនបានក្នុងសង្ខារធម៌ អត្តាក៏គង់តែរកបានក្នុងព្រះនិព្វាន ។ អនត្តាក្នុងព្រះពុទ្ធភាសិតនេះ ទ្រង់សំគាល់យកសង្ខារធម៌ ដែលជាចំណែកខាងបដិសេធប៉ុណ្ណោះ នឹងបានតាក់តាមទៅដល់ព្រះនិព្វានក៏ទេ ។

តាមដែលនិយាយមកនេះ ពាប់ថាបានរំលឹកអានសំខាន់ ដែលនឹងលើកឡើងជាគ្រឿងជំនាស់បានមួយភាគទៀត ៖

(មានត)

ការបណ្តុះឯសុវ៉ែយ

ព្រះមហាឧត្តមរដ្ឋា ផលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាជាលីវង់ វត្តបទុមវតី ក្រុងកំពង់ចាម រៀបរៀង

ឃ្លុនបណ្ណានុរ័ក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនមណ្ឌិត្យអ្នកពិនិត្យកែ

(តមក)

អ្នកមិនដឹងគុណលោក ទឹងមិនតបស្នងសងគុណរបស់លោកដែលមានគុណូបការៈលើខ្លួន ហៅថាមនុស្សអកតញ្ញូ ។ បើគិតអាក្រក់ប្រទូសរ៉ាយ ចំពោះលោកអ្នកមានព្រះគុណ សូម្បីតែមិនសំដែងកិរិយាបំបិទបំបាំង មើលងាយលោកវិញ ហៅថាមនុស្សនិរគុណ ដូចជាមនុស្សដែលបានថ្នាក់ខ្ពង់ខ្ពស់ មានគោលចារឹកងើបឆឹមាំមួនឡើង ឥតុកម្ពាយទឹករត្សកមកលេង ខ្លួនក៏ត្រូវប់ជាទឹកអៀនខ្មាសអ្នកស្រុកអ្នកភូមិថាឥតុកម្ពាយខ្លួនថោកទាប ហើយក៏ភ្លេចធ្វើជាមិនស្គាល់, ឬដូចជាមនុស្សកំព្រាមកពីតូច មានគេអាណិតអាសូរ យកទៅចិញ្ចឹមបីបាច់ថែរក្សា លុះធំឡើងបានធ្វើជានាហ៊ឺនធំដុំ ក៏លែងអើពើទឹកនាដល់អ្នកចិញ្ចឹមសោះតែម្តង ត្រូវប់ជាសំដែងកិរិយាក្រអឺតក្រទមធ្វើឥតខ្លឹងចំពោះលោកវិញ នេះជាមនុស្សនិរគុណ ។ មនុស្សបែបនេះ សូម្បីដំបូងជាមនុស្សខ្ពង់ខ្ពស់ ក៏មិនមែនចំរើនទៅដល់ណា ក្នុងទីបំផុត គង់បានទទួលផលនៃការនិរគុណនោះទាន់ក្នុក ។

សុនខ កាលមានគេឲ្យអាហារបរិភោគ គង់ចេះបក់កន្ទុយ ក្រាប
ថាបដិគ្គាហដើង ប្រៃនេះលើដ ដើមមុខផ្សារពោះ ដោយចិត្តបរិសុទ្ធ
ដែរ ។ ឯមនុស្សអកតញ្ញូឬមនុស្សនិរគុណវិញ ព្រងើយកន្តើយចំពោះ
លោកអ្នកមានគុណ ប៉ុនតែខាងបង្អាប់បញ្ជាអ្នកមានគុណ ប្រទូសព្យ
ចំពោះអ្នកមានគុណ ងាកចិត្តចេញពីលោកអ្នកមានគុណ គឺបងពៀរចំពោះ
លោកវិញ សូម្បីមានអ្នកបំពាក់យសសក្តិឲ្យខ្ពស់ដល់ណា ក៏គង់ចុះទៅ
កាន់សន្ដានប្រកែតដើមរបស់ខ្លួនវិញ មិនខុសអ្វីអំពីកន្ទុយសុនខដែល
ខ្វៀនខ្វែរ សូម្បីខំបំពត់យ៉ាងណា ក៏មិនបាត់ង ឬដូចដើមឈើពិស
ទុកជាស្រោចទឹកអមឹតយ៉ាងណា ក៏មិនដែលបញ្ចេញផ្លែផ្អែមឆ្ងាញ់មក
ឲ្យដែរ ។

យើងមានឱកាសត្រាប់ធ្វើសមុទ្រដែលពិបាកធ្វើ មានដួងប្រទីប
ទុកសម្រាប់បំភ្លឺកន្លែងវេលាយប់ងងឹត មានផ្លិតទុកសម្រាប់បក់កន្លែងពេលក្តៅ
ស្អុះ មានកន្ទេរទុកសម្រាប់កំចាត់ការគម្រាមនៃដំរីចុះប្រែង តែបើយើង
មានមនុស្សអកតញ្ញូ ឬមនុស្សនិរគុណវិញ ក៏គ្រាន់តែដើម្បីបង្អាសេចក្តី
វិនាសប៉ុណ្ណោះ ព្រោះមនុស្សបែបនេះ សូម្បីយើងយកសម្បត្តិគាំងផែនដី
មកសូកឲ្យគេធ្វើល្អចំពោះខ្លួន ក៏មិនបានការ ។ ស្រែកច្រៀងឲ្យត្រៃ
ស្តាប់ អប់អសុកដោយគ្រឿងក្រអូប ដាំឈូកកង់ទីសួតបែកក្រហែង

ក្រៀងធ្លាក់ច្រែងក្នងស្រែអំបិល ពត់កន្ទុយសុនខឲ្យត្រង់ ទឹងតុបតែងមុខ
មនុស្សខ្វាក់ក្អែក នេះជាពាក្យឧបមានៃការលើកដំកើងមនុស្សនិរគុណ ។
ការលើកដំកើងនោះ មិនអាចធ្វើឲ្យចិត្តមនុស្សនិរគុណត្រែកអរបានឡើយ។
ការធ្វើគុណចំពោះមនុស្សនិរគុណ សូម្បីពាប់រយពាន់ដង ក៏សូន្យទៅដែរ
ដូចជាពោលពាក្យពីរោះឲ្យមនុស្សថ្លង់ស្តាប់ពាប់រយពាន់ម៉ាត់ ក៏ឥតអំពើ
ប្រៀនប្រដៅមនុស្សមានៈរឹងត្អឹងពិបាកប្រដៅ ពាប់រយពាន់ដងក៏ឥត
ប្រយោជន៍ ទឹងដូចជាដឹកនាំមនុស្សឆោតល្ងង់ខ្លៅឲ្យកើតប្រាជ្ញា ពាប់រយ
ពាន់បែប ក៏នឿយហត់ឥតអំពើ ។

ឯមនុស្សកតញ្ញូ តែងយើញគុណថាជាគុណ យើញទោសថាជា
ទោស គោរពកោតក្រែងចំពោះលោក - អ្នកមានគុណទឹងគោរពពាប់អាន
អើពើដឿស្តាប់លោក ទឹងរឭកតែសេចក្តីល្អរបស់លោកអំពីមុនមក សូម្បី
ធ្វើខុសបន្តិចបន្តួចក្នងគ្រាខ្លះ ក៏នៅតែមានកិរិយាសុភាពនុនលំទោនសរ-
សើរគុណរបស់លោក - អ្នកមានគុណ ទាំងកងឥតកំចាំងមុខ ទាំងកងឥត
ចំពោះមុខ ដែលជាហេតុនាំឲ្យចាប់ចិត្តស្រែលែង ។ លោក - អ្នកចូរជា
មនុស្សកតញ្ញូចុះ បើបានទទួលឧបការអំពីលោកណាហើយ គួរដឹងគុណ
លោកនោះ ហើយតបស្នងសងគុណលោកវិញ លើកដំកើងដំកល់លោក
ទុកក្នងដំណែងជាអ្នកមានព្រះគុណ រៀរចាកការលុបគុណមើលងាយ

លើកខ្លួនឯងធ្ងន់ធ្ងរនឹងលោក ឬគិតអាក្រក់ចំពោះលោក កុំប្រព្រឹត្តខ្លួនឲ្យត្រូវដំនៀលថាជាមនុស្សអកតញ្ញូ ឬជាមនុស្សនិរគុណឡើយ, ត្រូវសុចរិតស្មោះត្រង់តាមហ៊ានៈរបស់ខ្លួន គឺបើជាអ្នកតូច គួរគោរពកាន់អាន ធ្វើខ្លួនឲ្យងាយប្រដៅងាយខ្ចីខ្ចាន ដើម្បីស្តាប់ស្មោះត្រង់ សុចរិតចំពោះលោកទទួលបំរើធ្វើការងាររបស់លោកដែលមានព្រះគុណលើខ្លួន, បើជាអ្នកធំគួរមានមេត្តាករុណា សំដែងសេចក្តីស្រឡាញ់ សេចក្តីអាណិតអាសូរអើពើយកចិត្តទុកដាក់ ចំពោះអ្នកតូច ដែលមានឧបការជួយកិច្ចការរបស់ខ្លួន ។

ស្មោះត្រង់បំពោះគណៈ:— ធម្មតាមនុស្សយើង តែងត្រូវការនៅរួមគ្នាជាពួកជាគណៈ: មានការគ្រប់គ្រង នឹងមានច្បាប់ទំលាប់ជារបៀបសំរាប់ឲ្យធ្វើនឹងហាមឃាត់ ដើម្បីការពារនូវការបៀតបៀនគ្នានឹងគ្នា ទើបនៅរួមគ្នាបានដោយសេចក្តីសូបស្ងៀម ។ បើមនុស្សក្នុងពួកគណៈនោះ ទាំងអ្នកតូចទាំងអ្នកធំ មិនមានសេចក្តីស្រឡាញ់ពួកគណៈ: មិនមានសេចក្តីស្មោះត្រង់គោរពកោតក្រែង មិនមានកតញ្ញូនឹងសេចក្តីសុចរិត មិនប្រតិបត្តិតាមច្បាបទំលាប់ ឬក៏ងាកចិត្តចេញពីគ្នានឹងគ្នាហើយ ពួកគណៈនោះក៏តាំងនៅមិនបាន ព្រោះពួកគណៈឬជាតិ អាចតាំងនៅខ្ជាប់ខ្ជួននឹងចំរើនទៅបាន ក៏ព្រោះសេចក្តីស្មោះត្រង់របស់មនុស្សក្នុងពួកគណៈឬរបស់ពលរដ្ឋ នឹងរបស់ប្រធានឬអ្នកគ្រប់គ្រងប្រកបគ្នាធ្វើជា

តែប្រយោជន៍ដល់ពួកគណៈ: មិនដាក់ចិត្តចេញចាកពួកគណៈ: នាំគ្នារក្សានីតិក្រមចាំងអស់ជួចជា ។

១ - គោរពចំពោះព្រះភាជប្បញ្ញត្តិ ដើម្បីស្តាប់តោតក្រែងពាប់អានស្មោះត្រង់ចំពោះគ្នា តាមភាពអ្នកធំអ្នកតូច មិនលើសលើគ្នា ទំយកចិត្តទុកដាក់ម៉ឺងម៉ាត់ ចំពោះនាទីរបស់ខ្លួន ។

២ - មានសេចក្តីសាមគ្គីព្រមព្រៀងគ្នាជាពួកមួយ ជួយអនុគ្រោះគ្នារួមកាយរួមចិត្តគ្នាជួយធ្វើ ឧដ្ឋសង្គ្រោះឧបត្ថម្ភកិច្ចការផ្សេងៗ ដែលជាគ្រឿងចំរើនវុឌ្ឍរឿងនៃពួកគណៈ: មិនទាស់ទែងច្បែងគំនិតស៊ីឈ្ងួលលើគ្នា មិនរំជួលឈ្លោះសាកាក់រុកឲ្យឈួចសេចក្តីសាមគ្គីកង់ពួកគណៈ មិនជាសត្រូវបំផ្លាញគ្នាឯង ។

៣- ស្រឡាញ់ពួកគណៈ: មានចិត្តជ្រាបថាសេចក្តីសុខ សេចក្តីចំរើនដល់គ្នាដូចបងប្អូន នាំគ្នាជួយរក្សាសម្បត្តិរបស់ពួកគណៈ: ដូចជាសាសនា ភាសា អក្សរសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណី ដ៏ល្អជាដើម ឲ្យចំរើនវុឌ្ឍរឿងជាស្ថាពរ មិនឲ្យសាបសូន្យ មិនធ្វើការណាដែលជាគ្រឿងដំនាស់ដល់សេចក្តីវុឌ្ឍរឿងមាំមួន ឬជាកយន្តរាយដល់ពួកគណៈ: ។

៤ - ធ្វើខ្លួនឲ្យប្រព្រឹត្តទៅតែក្នុងផ្លូវដែលត្រូវធម៌ មិនធ្វើសេចក្តីក្តៅក្រហាយនឹងសេចក្តីវិនាសឲ្យកើតឡើងដល់ខ្លួនឯងនឹងពួកគណៈ: ដោយប្រព្រឹត្តឲ្យខ្ជិលត្រង់ជាកណ្តាលមិនឲ្យលំអៀង អ្នកខុសធ្វើទោសតាម

ខ្ញុស អ្នកត្រូវកំចំនុកបំរុងថែទាំ ឧបត្ថម្ភតាមត្រូវ រក្សាសេចក្តីសុចរិតទុកឲ្យ ជាគំរូដល់គ្នានឹងគ្នា ។

៥ - ជាមនុស្សមិនឃើញតែប្រយោជន៍ផ្ទាល់ខ្លួនម្យ៉ាង គិតដល់ ប្រយោជន៍របស់ពួកគណៈផង មិនប្រកាន់ទំដ្ឋមានៈរឹងរូស ចេះគោរពគ្នា តាមគ្នា តាំងចិត្តឲ្យប្រកបដោយមេត្តាករុណាពេលដែលនិយាយឬគិត មាន មារយាទរៀបរយមិនជាទីរង្កៀសរបស់ពួកគណៈ មានសេចក្តីយល់ឃើញ ស្របគ្នា ។

៦ - រៀរចាភការប្រកាន់ពួកគណៈ មិនជាមនុស្សនិស្ស័យចង្អៀត យល់ខ្លីថា "នេះជាពួកយើង ខ្ញុះជាពួកគេ" គឺជាមនុស្សនិស្ស័យទូលាយ ប្រកាន់ថា "អ្នកដែលនៅលើផែនពសុធាទាំងអស់ សុទ្ធតែជាពួកជាមួយ គ្នា" ហើយក៏មិនរិះគន់គ្នា ដាយជាតិត្រកូល ។

អស់លោក-អ្នកទាំងឡាយ ចូរស្តាប់ស្តាញ់របៀប ស្តាប់ស្តាញ់សេចក្តី សូបស្តៀមរៀបរយ ស្តាប់ស្តាញ់សេចក្តីត្រូវប្រព្រឹត្តតាមព្រះរាជប្បញ្ញត្តិ ទំនៀមទម្លាប់ស្រុកទេស សីលធម៌ របៀបការគ្រប់គ្រងការបង្ហាប់របស់ ពួកគណៈគោរពចំពោះសិទ្ធិនឹងប្រយោជន៍របស់មនុស្សដទៃ ស៊ូកាត់ចិត្ត លះបង់ប្រយោជន៍ សេចក្តីសុខចំណែកខ្លួន ដើម្បីប្រយោជន៍នឹងសេចក្តី សុខដល់មនុស្សដទៃដល់ពួកគណៈនឹងដល់ប្រទេសជាតិ ប្រព្រឹត្តខ្លួនឲ្យ ជាមនុស្សស្លូបស្តៀមមិនបះបោរ មានកាយ វាចា ចិត្ត សុភាពរាបសា

រឿរចាកសេចក្តីអាត្រេកអៀចខាប ដែលធ្វើឲ្យខូចកិត្តិយសនៃពួកគណៈ
ទឹងប្រទេសជាតិ ជាមនុស្សស្រប់រឿបរយ មិនចូលដៃគ្នាធ្វើការណាដែល
ខុសរបៀបបែបផែនច្បាប់ទំលាប់របស់ពួកគណៈ ឬដែលធ្វើឲ្យពួកគណៈ
របស់ខ្លួនកើតចលាចល នេះឈ្មោះថាលោក.អ្នករក្សាទីតំក្រម ជាអ្នក
ស្មោះត្រង់ចំពោះពួកគណៈ ។

លក្ខណៈនៃសេចក្តីស្មោះត្រង់ទាំង ៦ ប្រការ គឺស្មោះត្រង់ចំពោះ
ខ្លួនឯង, ស្មោះត្រង់ចំពោះភាព, ស្មោះត្រង់ចំពោះការងារ, ស្មោះត្រង់
ចំពោះមុខក្រសួង, ស្មោះត្រង់ចំពោះបុគ្គល ទឹងស្មោះត្រង់ចំពោះពួក
គណៈ ទាំងអម្បាលនេះ រមែងជាកំលាំងដ៏សំខាន់របស់បុគ្គលគ្រប់រូប
ដែលជាប់ទាក់ទងគ្នា ប្រហែលគ្នាទឹងសេចក្តីអង់អាច ជាកំលាំងរបស់
ទាហាន, សេចក្តីជ្រះថ្លាជាកំលាំងនៃទាយកទាយិកា ដូច្នោះ ។

មាតាបិតាទឹងបុត្រធីតា អ្នកគ្រប់គ្រងទឹងអ្នកដែលទៅក្នុងការគ្រប់
គ្រង អាចារ្យទឹងកូនសិស្ស មិត្តទឹងមិត្ត អ្នកទិញទឹងអ្នកលក់ ម្ចាស់
បំណុលទឹងកូនបំណុល រហូតដល់នាយចៅហ្វាយទឹងខ្ញុំកំដរ បើមិនស្មោះ
ត្រង់ចំពោះគ្នាហើយ ការជាប់ទាក់ទងគ្នា ទឹងត្រូវជាប់ចេញពីគ្នា មិន
មានសន្តិសុខរីយវឌ្ឍនាការស្ថាពរទៅបានឡើយ, បើមានសេចក្តីស្មោះ
ត្រង់ចំពោះគ្នាទៅវិញទៅមកហើយ ការជាប់ទាក់ទងគ្នា ទើបទឹងមាន
សន្តិសុខទឹងជាប់ខ្ជួនរៀបរយយូរអង្វែង ។ អ្នកតូច ក៏ទឹងបានជាទីពុក

ចិត្តបំផុតនៃអ្នកធំ អ្នកធំអាចប្រែទៅជាមុខជាមាត់ ជាជំនួសក្អែក ជំនួសត្រចៀក ទាំងកងទ័ពដ៏តំងកងទ័ព្ធាយបាន មិនជាទីរង្គើសសង្ឃឹយថា ជាមនុស្សវៀចវេរ ។ អ្នកធំ ក៏នឹងបានជាទីស្រឡាញ់រាប់អានគោរពកោតខ្លាចយ៉ាងខ្ពស់បំផុតនៃអ្នកតូច ជាហេតុឲ្យបាននៅជាសុខសប្បាយត្រជាក់ត្រជំទៅវិញទៅមក ។

អ្នកស្វែងរកសុខ ប្រយោជន៍ សុវត្ថិផល គួរប្រតិបត្តិឲ្យត្រឹមត្រូវតាមលក្ខណៈស្មោះត្រង់នេះ ឲ្យជាប់ជានិស្ស័យរបស់ខ្លួននឹងត្រូវអង់អាចកុំរួញរាកក្នុងការរក្សានិស្ស័យស្មោះត្រង់នេះទុក ទុកជាបានទទួលទោសយ៉ាងសាហ័សក៏ដោយ ក៏កុំរវែកទើបនឹងបានផុតចាកសម្ពុទ្ធុក្ខ លុះដល់សេចក្តីសុខនឹងប្រយោជន៍ ព្រមទាំងសុវត្ថិផល, បើប្រតិបត្តិមិនបានទេ ក៏នឹងត្រូវអណ្តែតបង្ហូរទៅក្នុងសម្ពុទ្ធុក្ខនោះ ព្រោះសេចក្តីសុខកើតមកអំពីសេចក្តីស្មោះត្រង់ សេចក្តីទុក្ខកើតមកអំពីការវៀចវេរ បើទុកជាយើងស្វែងរកសេចក្តីសុខ បានមកដោយផ្លូវវៀចវេរកុតករក៏ដោយ សេចក្តីសុខនោះតែងប្រកបដោយមន្ទិលគឺការភ្ញកភ្ញីយនឹងភ័យវិបត្តិផ្សេង ។ លុះតែសេចក្តីសុខ ដែលយើងស្វែងរកមកបានដោយសេចក្តីស្មោះត្រង់វិញ ទើបជាសុខប្រាសចាកមន្ទិលទោស នឹងមាំមួនខ្ជាប់ខ្ជួនសមនឹងឈ្មោះនៃសេចក្តីសុខពិត។ មិនបានច្រឡូកច្រឡំទៅដោយទុក្ខភ័យវិបត្តិណា ។ ទាំងអស់ ។

លោក-អ្នកស្រឡាញ់ជាតិ សាសនា ទឹងព្រះមហាក្សត្រិយ៍ ទាំងឡាយ! មនុស្សមានទិស្សយ័ស្មោះត្រង់ ជាមនុស្សប្រសើរ មានជីវិតជាក្រសែដ៏ត្រង់ល្អ ប្រហែលគ្នាទឹងដៃទឹកដែលស្ងប់ ទឹងតាំងខ្លួនបានត្រង់ល្អ ដូចគ្នាទឹងខ្សែបន្ទាត់ ដំណើរជីវិតទៅ ដោយសេចក្តីស្មោះត្រង់ដូចគ្នាទាំងអស់ ទាំងកិរិយា ទាំងវាចា ទាំងទឹកចិត្ត ជាចិត្តចំពោះអ្នកដទៃទួទៅ ចង់មេត្រីនឹងអ្នកដទៃ ដោយទឹកចិត្តពិតត្រង់ មិនមានក្នុងមិនមានក្រៅ ទឹងមិនមាននរណាមួយ អាចដឹកនាំឲ្យវៀចទៅបានជាមនុស្សមានសិរីសួស្តីជយមង្គលទៅក្នុងខ្លួន មិនខ្វាចក្រែងមនុស្សដទៃ ប្តូនឯងតិះដៀលថាជាមនុស្សវៀច មានកេរ្តិ៍ឈ្មោះល្អល្បីទួទៅថាជាមនុស្សស្មោះត្រង់ អាចរក្សាប្រទេសជាតិ ពួកគណៈ· ទឹងខ្លួនឯងទុកឲ្យមានកេរ្តិ៍ឈ្មោះបាន មានកិត្តិប្រវត្តិគ្រអូបកាយ ទាំងពេលកំពុងរស់នៅទាំងពេលស្លាប់ផុតទៅ ចារឹកគុណគឺសេចក្តីល្អ ទុកឲ្យមនុស្សជាន់ក្រោយនិយមរាប់អានទឹកព្រួក សរសើរ ដកឋដល់កល្បាវសាន ។

ដូច្នេះ ទើបលោក-អ្នក គួរអប់រំខ្លួន ឲ្យជាមនុស្សមានទិស្សយ័ស្មោះត្រង់ កុំឲ្យជាមនុស្សមានទិស្សយ័វៀចឡើយ ។ ព្រោះមនុស្សវៀចជាមនុស្សថោកទាប ជាសត្រូវចំពោះពួកគណៈទឹងជាតិ ជាអ្នកលក់ជាតិ លក់ញាតិ លក់ពួកគណៈ ចង់មេត្រីនឹងនរណាមួយមិនដែលបានយឺតយូរ ដំណើរជីវិតទៅជាពីរបែបរួមគ្នា គឺស្មោះត្រង់ ១ បែប វៀចវេរ ១ បែប

មិនមាននរណាមួយដឹកនាំឲ្យវៀចឡើយ គឺត្រឡប់វៀចតែខ្លួនឯង ត្រូវ
អំពើវៀចចោះត្រានៅនឹងមុខថាជាមនុស្សវៀច ឈ្មោះអាក្រក់ក៏ជាប់ជ
ខ្លួន្ទរាថមិនចេះផុត ។ លោក-អ្នកស្មោះត្រង់សួមជ្រាបថា បើលោក-
អ្នកសេពគប់នឹងមនុស្សស្មោះត្រង់ អាយុលោក-អ្នកនឹងវែង បើសេពគប់
នឹងមនុស្សវៀច អាយុលោក-អ្នកក៏ខ្លី ។ និស្ស័យស្មោះត្រង់ លើក
ជំកើងសេចក្តីល្អឲ្យអណ្តែតឡើង ទំលាយសេចក្តីអាក្រក់ឲ្យហិនហោច ។
ឯនិស្ស័យវៀចវេរវិញ ជួយគាស់សេចក្តីអាក្រក់ឲ្យជ្រាកជាឡើង សង្កត់
សេចក្តីល្អឲ្យលិចចុះទៅ ។ អ្នកវង្វេងដឿងចិត្តមនុស្សវៀច ឈ្មោះថា
ចូលដល់ក្នោងទ្វារនៃសេចក្តីវិនាសហើយ ត្រូវខ្លួលខ្ទុំលំបាកយ៉ាង
ក្រៃលែង ដូចមនុស្សអើលធ្លាក់ទោកក្នុងទឹកស្ងឹង ឬដូចមនុស្សចាប់ពស
មានពិសជាប់ក្នុងដៃ នឹងលែងក៏មិនបាន នឹងក្តាប់ទុកតទៅក៏ខ្លាច ។
មគ្គានៃបរមសុខបានសំអាតទុកជាស្រេច បុរាណខ្លួលមនុស្សស្មោះត្រង់
តែជាក់សម្រាសទុកជាខ្ចិច ដើម្បីកំងមនុស្សវៀច, ឯទ្វារនៃអបាយ
បានបើកយ៉ាងធំទុកសម្រាប់ខ្លួលមនុស្សវៀច តែបិទយ៉ាងជិត ដើម្បី
ឃាត់ខាំងមនុស្សស្មោះត្រង់ ។ ចូរចាំទុកថា ‘ មនុស្សមានវិជ្ជាល្អ
តែច្រាសចាកសេចក្តីស្មោះត្រង់ ក៏ទុកដូចជាសាកសពដែលប្រដាប់
ប្រដាដោយពេជ្រ” ។

សុភាសិតទីបំផុត

និស្ស័យវៀចវេរ រមែងហូតយកពិសដ៏ពន្លឹកវេរបស់ខ្លួនឯងមកសម្លាប់ខ្លួនឯងវិញ ។ លោក-អ្នកចាំង ឡាយ កុំសម្លាប់ខ្លួនឯងដោយអំពើវៀចឡើយ ចូរស្មោះត្រង់ ព្រោះកិត្តិគុណ នៅត្រង់សេចក្តីស្មោះត្រង់ យសសក្តិអគ្គជ្ញានមិនបានផ្តល់កិត្តិគុណដល់លោក-អ្នកទេ តាមពិត លោក-អ្នកត្រូវឲ្យកិត្តិយសដល់ដំណែងនាទី ដោយសេចក្តីស្មោះត្រង់របស់ខ្លួនឯងវិញ ។ ចិត្តវៀច អាចដឹកនាំឲ្យកាយវាចាវៀចផង ដូចរស់ល្វីងតែបន្តិចចូលទៅ អាចធ្វើទឹកឃ្មុំដែលមានចំនួនច្រើនឲ្យល្វីងបានដូច្នោះ ។ ចូរពត់ចិត្តវៀចឲ្យត្រង់ ដោយសេចក្តីស្មោះត្រង់ចុះ ។ មនុស្សស្មោះត្រង់ជាមនុស្សកំរិតតែប្រសើរក្រៃលែងឡើង ក្នុងពេលដែលសំដែងលក្ខណៈស្មោះត្រង់ចេញមក ។ មនុស្សវៀចវេរ ក៏កំរិតតែអាក្រក់ក្រៃលែងក្នុងពេលដែលក្លែងខ្លួនធ្វើជាមនុស្សស្មោះត្រង់ ។ បើចង់ឲ្យទៅជាមនុស្សស្មោះត្រង់ ក៏ចូរកុំវៀចវេរ ។ មនុស្សវៀច សូម្បីយកទៅជាក់បុកកំទេចក្នុងកន្ត្រាល់ ការវៀចវេរបស់គេ ក៏នៅតែមិនរត់ចេញអំពីខ្លួនបស់គេដែរ ។ អ្នកដែលចង់មេត្រីនឹងមនុស្សវៀច ទុកដូចជាបង្អាត់ក្ងើងឲ្យកក់ក្តៅ ដល់មនុស្សវៀច ហើយត្រឡប់ជុតខ្លួនឯងឲ្យឆេះវិញ ។ ចូរស្មោះត្រង់នឹងតាំងនៅដោយសេចក្តីស្មោះត្រង់ចុះ ស្ងាប់នៅកងសេចក្តីស្មោះត្រង់ ល្អជាងរស់នៅកងសេចក្តីវៀចវេរ ។

ឱម ស្មោះត្រង់ មហាស្មោះត្រង់ ឧមត្ត ពុទ្ធសំ

នេះជាគាថាសែកឲ្យពួកយើញដល់ជាតិជាអតីតថា "ខ្មែរយើង ធ្លាប់ជាខ្មែរដ៏ស្មោះត្រង់មកអំពីសម័យព្រៃឯនាយ; បុរសខ្មែរ គឺប្រុសអ្នកស្មោះត្រង់ចំពោះជាតិ; ស្ត្រីខ្មែរ គឺស្រីអ្នកស្មោះត្រង់ចំពោះជាតិ", សាធុ! សូមឲ្យនិស្ស័យស្មោះត្រង់នេះ ទៅជាមតិករបស់អ្នកកម្ពុជា តាមប្រពៃណីតទៅអនាគត ។

សច្ចៈត្រង់ ជាអង្គ គួរពាប់រក
អ្នកដែលយក សច្ចៈ ជាក់សន្ដាន
តែងមានឈ្មោះ ពីពេះ ទៅឆ្ងាយបាន
ជនច្រើនគ្រប់ណា បានស្ដាប់ ចាប់ចិត្តងាយ ។
ពាក្យកូតគ្រោង គួរវង ចេញឲ្យឆ្ងាយ
អ្នកកូតករ ទាំងឡាយ កើ្តស្អុយកាយ
តាំងអំពី លោកនេះ ដល់លោកនាយ
ជនសព្វាយ បានស្ដាប់ ស្អប់ខ្ពើមអើយ !!! ។

(មានត)

កណ្ដាលទី ១៦

ឧកញ៉ាវិបុលរាជសេនា ង្វ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវិឆ្ងាសបើបានអាន
ទំងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ស៊ុនចេង៍ឆ្លើយថា ខ្ញុំនអង់អាចមើលងាយយើង៍ណាស់ ខ្ញុំនក៏គ្រាន់តែជាសេនាគាហានមិនគាន់មានល្បិប៉ុន្មាន ហេតុម្ដេចហ៊ានលើកខ្ញុំនចង៍ប្រឡង៍ទង៍នាយអញ ។ គួនអ៊ីវ៉ាដូច្នោះក៏បរសេះចូលទៅប្រយុទ្ធទង៍សុនចេង៍បាន ១ ភ្លែត ក៏លើកជាវគាប់ស៊ុនចេង៍ធ្លាក់ពីលើសេះស្លាប់ ។ ឡៅពីបរពេលចូលប្រគាប់ធំលាយយកបន្ទាយគឺឡង៍បាន ។ គឺឡង៍នាំគាហានថយទៅតាំង៍បន្ទាយនៅក្បែរស្ទឹង៍សុកឈ្លួយិន ហើយលើកគាហានទៅប្ញនយកបន្ទាយឡៅពីជាច្រើនដង៍ក៏មិនបាន គាហានឡៅពីគាប់សម្លាប់គាហានគឺឡង៍ស្លាប់គ្រប់គ្រា ។ គឺឡង៍ទង៍ឡៅពីក៏តតាំង៍ច្បាំង៍គ្នាជាយូរថ្ងៃ ។

ឯតៀវហ៊ុយដែលនៅរក្សាស្រុកឈើដីវ ថែកមុខងារឲ្យតាន់តែង
ត្រួតនិយាយការខាងរដ្ឋបាល តៀវហ៊ុយឯងត្រួតត្រានិយាយការខាង
សេនាភាហាន ។ លុះកន្លងមក ១ ថ្ងៃ តៀវហ៊ុយឲ្យរៀបតុលៀងអាហារ
ហើយអញ្ជើញភ្នាក់ងារខាងភាហាន ទឹងរដ្ឋបាលមកបរិភោគព្រមគ្នា ។
តៀវហ៊ុយនិយាយថា កាលឡៅពីទឹងលើកកងទ័ពចេញទៅនោះ
បានកំជាប់ពាក្យទឹងយើងថាកុំឲ្យធឹកស្រាពេក តែថាថ្ងៃនេះយើងសប្បាយ
ចិត្តបានជាគិតដប់លៀងអស់លោក បរិភោគធឹកស៊ីឲ្យសប្បាយតែ ១ ថ្ងៃ
នេះ តទៅអស់លោកទឹងយើងកុំគប្បីស៊ីធឹកទៀតឡើយ យើងត្រូវតែតាំង
មុខធ្វើការរាជការ ទឹងរក្សាស្រុកឲ្យសុខសាន្ត ត្រាតែបានឡៅពីលើកទ័ព
ត្រឡប់មកវិញ" ថាហើយក៏ចាក់ស្រាហុចគំនាប់សព្វមុខមន្ត្រីព្រមគ្នា ។

នៅសល់តែចោប៉ាម្នាក់មិនព្រមទទួលពែងស្រា ហើយនិយាយ
ទឹងតៀវហ៊ុយថា ខ្ញុំបានស្បថសច្ចាន់ចំពោះមុខទេពតាថាលែងធឹកស្រា
ហើយ សុំឲ្យអត់ទោសចុះ ។ តៀវហ៊ុយតបថា ខ្លួនជាសេនាភាហាន
ហេតុម្តេចបានជាលែងធឹកស្រា. យើងត្រូវឲ្យធឹក ១ ពែងចុះ បើមិនទទួល
យើងក៏មិនព្រមស្តាប់ ។ ចោប៉ាទឹកខ្ជាចតៀវហ៊ុយក៏ទទួលគំនាប់ធឹក
ស្រា ១ ពែងទៅ ។ តៀវហ៊ុយក៏ចាក់ស្រាធឹកខ្លួនឯងអស់ប្រហែល ២០
ពែងធំ ហើយចាក់ឲ្យអ្នកឯទៀតធឹកជាលំដាប់គ្នា ទៅទៀត ។ តែចោ
ប៉ាអង្វរថា ខ្ញុំទទួលទានមិនបាន ។ តៀវហ៊ុយសើចហើយថា អម្បាញ់

មិញខ្ញុំនិយាយថាផឹកមិនបាន តែបានផឹកអស់ ១ តែងទៅហើយ ឥឡូវនេះ ឲ្យផឹកទៀតថាផឹកមិនបាន យ៉ាងនេះគឺខ្ញុំកូងមិនពាប់អានយើង។ ក៏មិនត្រូវស្តាប់ ត្រូវតែបង្ខំឲ្យផឹកទាល់តែបាន ។ ចោប៉ាក៏អង្វរមិនឧស្តួល, តៀវហ៊ុយទើបច្រឡោតថា "ខ្ញុំឯងជាអ្នកតូចជាងយើង ហើយអាចរំងឹងមិនព្រមផឹកស្រាដែលយើងឲ្យ ក៏យើញថាខ្ញុំមិនគោតខ្លាចយើង" ថាហើយក៏បង្ខាប់ឲ្យមនុស្សបំរើចាប់ខ្ញុំនចោប៉ាទៅវាយ ១០០ ខ្លាប់ ។

តាន់តេងយើញតៀវហ៊ុយធ្វើឡូឡា ក៏និយាយថា កាលឡៅពីរៀបដំណើរចេញទំពៅបានជាំផ្តាច់ ទុកនឹងអ្នកដូចម្តេចខ្លះ ។ តៀវហ៊ុយធ្វើយថា ខ្ញុំបានបែងមុខងារឲ្យអ្នកត្រួតការខាងរដ្ឋបាល ខ្ញុំត្រួតការខាងសេនាធាហាន ឥឡូវនេះចោប៉ាជាធាហានបែកខាងខ្ញុំទេ អ្នកមិនត្រូវមកនិយាយធ្វេងរំលងក្រែងឯ ។ ឯមនុស្សបំរើទាំងពួងក៏ទាញដៃចោប៉ាទៅវាយ ។ ចោប៉ាអង្វរករតៀវហ៊ុយថា ខ្ញុំបាទសុំទោសលោកម្តងចុះ ទោះបីលោកមិនយល់ដល់មុខខ្ញុំ ក៏សុំឲ្យឈ្វេងយល់ដល់កូនប្រសាខ្ញុំផង ។ តៀវហ៊ុយបានឮឈ្មោះលីចាំ ក៏ក្រដូចថែមទៀតថា "ខ្ញុំនិយាយមកនេះគ្រាន់ថានឹងបញ្ជីចិត្តយើង បានជាយកឈ្មោះអាលីចាំមកសំដែងឲ្យយើងខ្លាច យើងមិនមែនខ្លាចវាទេ ត្រូវតែឲ្យវាយខ្ញុំឥឡូវនេះឲ្យបាន ឲ្យសង្កើរក្បាលអាលីចាំជាកូនប្រសាខ្ញុំ ដែលខ្ញុំពាប់ថាល្អនោះ" ថាហើយក៏បង្ខំមនុស្សបំរើឲ្យចាប់ខ្ញុំនចោប៉ា ទៅវាយ

ប្រហែល ៥០ ខ្ចាប់ ។ នាហ្នឹងខ្ញុំកដការ - កំនាំគ្នាជួយអង្ករតរៀវហ៊ុយ ឲ្យឈប់វាយ ។ ចោប៉ាក៏ត្រឡប់ទៅដល់ទីលំនៅ ទំកក្តៅគំនុំចិត្តនឹងតៀវហ៊ុយពន់ប្រមាណណាស់ គិតហើយក៏សរសេរសំបុត្រឲ្យបំរើកាន់ទៅឲ្យលីចោ"ឯស្រុកសៀវផាយ ។

លីចោ"ប្តូនទទួលសំបុត្រហើយមើលក៏ឃើញសេចក្តីថា វេលានេះឡៅពីលើកកងទ័ពទៅវាយស្រុកឡាំយ"ង ខុកតៀវហ៊ុយឲ្យរក្សាស្រុកឈើដីវ តឡូវតៀវហ៊ុយផឹកស្រាស្រវឹងឲ្យវាយយើងឥតកំហុស ថែមទាំងស្តីទ្រគោះបញ្ឆោះមកដល់អ្នកជាកូនទៀត ហេតុនេះសុំឲ្យអ្នកលើកទាហានទៅវាយយកស្រុកឈើដីវនោះ នៅពេលាយប់នេះមុខជានឹងបានដោយងាយ ព្រោះតៀវហ៊ុយកំពុងដេកស្រវឹងពុំដឹងខ្លួន ។

លីចោដឹងដូច្នោះក៏ហៅតាន់កុងមកប្រឹក្សា តាន់កុងឆ្លើយថា ដែលតៀវហ៊ុយ មើលងាយនិយាយទ្រគោះមកដល់លោកដូច្នោះជាការអាក្រក់ខ្លាំងណាស់ លោកនឹងគាំទៅក្នុងស្រុកសៀវផាយ ឃើញមិនសប្បាយជាទីមាំមួនសោះ គ្រានេះបានចន្លោះស្រួលហើយ ត្រូវតែលើកទាហានទៅវាយយកស្រុកឈើដីវកុំបង្អង់ បើបានហើយ ទំងតាំងគិតការតទៅទៀត ។ លីចោ"យល់ឃើញត្រូវ ក៏ដម្រាឲ្យតាន់កុង នឹងកោសុំនកណ្តូបមួលទាហានបានត្រឹម ហើយនិយាយថាយើងលើកស្រួតទៅមុន ឲ្យអ្នកតាំង ២ លើកតទៅជាខាងក្រោយ ។ លីចោ"ក៏ពាក់គ្រឿងឡើងជិះសេះ

សិទ្ធថៅនាំគាហានប្រមាណ ៥០០ លើកទៅដល់ដើងកំពែងស្រុកឈីដាវ
នៅវេលាយាម ៣ ហើយស្រែកប្រាប់គាហានចាំទ្វារថាឲ្យបើកទ្វារជា
ប្រញាប់ ដ្បិតឡៅតីប្រើយើងមកពន្យល់ការរាជការនឹងតៀវហ៊ុយ ។
ខ្លួលើគាហានរបស់ចោប៉ាដែលចាំរក្សាទ្វារនោះ បានឮលីចោ៉ហៅ
ក៏រត់ទៅប្រាប់ចោប៉ា ។ ក៏ស្រួតរត់មកមើល លុះឃើញលីចោ៉ក៏ឲ្យបើកទ្វារ
ខ្លួល លីចោ៉ក៏លើកគាហានចូលទៅ ។

ឯប័ក្សពួកតៀវហ៊ុយ ឃើញលីចោ៉នឹងសេនាគាហានចូលទៅក្នុង
ស្រុកបាន ក៏ភ័យតក់ស្លុតរត់ទៅប្រាប់តៀវហ៊ុយ។ ភ្លាក់ឡើងកំពុងស្រវឹង
ស្រា ឮគាហានថា លីចោ៉លើកគាហានចូលមកយកស្រុកបានហើយ
តៀវហ៊ុយភ័យណាស់ ឡើងសេះកាន់ខ្លួនចេញមកដល់មាត់ទ្វារមកផ្ទះ
ឃើញគាហានលីចោ៉ព័ទ្ធជុំវិញក៏គិតថា "ខ្លួនអញនៅស្រវឹង កម្លាំងក៏តិច
ទឹងតស៊ូលីចោ៉មិនបាន" គិតដូច្នោះហើយក៏នាំយកគាហានដែលស្និទ្ធប្រ
ហែល ១៨ នាក់រត់ចេញចាកស្រុកឈីដាវទៅ ឯគ្រប់គ្នាឡើងតីក៏ចោល
ទៅក្នុងស្រុកនោះទាំងអស់ ។

លីចោ៉ដឹងថាតៀវហ៊ុយរត់ទៅហើយ ក៏មិនបានដេញដិតដោយព្រោះ
គោតញញើតថា តៀវហ៊ុយមានថ្វីដៃខ្លាំងពូកែ ។ ឯចោប៉ាទៅស្តៅផ្ទះ
ទឹងតៀវហ៊ុយណាស់ ក៏លើកគាហានប្រមាណ ១០០ នាក់ តាមតៀវហ៊ុយ
ទៅ ។ តៀវហ៊ុយក្រឡេកក្រោយឃើញចោប៉ាដេញតាម ក៏ញាក់សេះ

ត្រឡប់មកតយុទ្ធ នឹងចោប៉ាបាន ៣ ក្មេង ចោប៉ាកម្ចាំងតិចគេចបរសេះរត់មកគ្រោយ តៀវហ៊ុយក៏ដេញបណ្តាយទៅដល់ទល់នឹងមាត់ស្ទឹងប្រឹងស្រូតទៅទាន់ លើកខ្លួនចាក់ចោប៉ាធ្លាក់ពីលើសេះស្លាប់ ។ បណ្តាសេនាទាហានតៀវហ៊ុយដែលនោកក្នុងស្រុកឈើដីរប៉ុន្មាន ក៏ទាំងគ្នាបរវាត់ចេញទៅខ្លះ ។ លុះវេលាព្រឹកឡើង ទើបទៅប្រទះនឹងតៀវហ៊ុយ។ ក៏លើកតាមឡៅពីទៅស្រុកឡាំយ៉ុង ។

ឯលីចោ៉ាកាលបានស្រុកឈើដីរហើយ ក៏ឲ្យទាហាន ១០០ នាក់ទៅនៅយាមរក្សាកវិយាបុត្រឡៅពី មិនឲ្យនរណាប្រមាថមើលងាយ ។ កាលតៀវហ៊ុយទៅដល់ស្រុកអ៊ីថៃ ក៏ចូលទៅជ្រាប់សេចក្តីសុខទុក្ខដល់ឡៅពីគ្រប់ប្រការ បណ្តាសេនាទាហានក្នុងកងខ័ពដែលបានដឹងកិត្តិស័ព្ទថាលីចោ៉ាដណ្តើមយកស្រុកឈើដីរបាន ក៏មានចិត្តព្រួយរំខានទឹកដល់កវិយាបុត្រញាតិសន្តាន គប់ៗគ្នា នឹងធ្វើការក៏រសាយដៃ ពុំដូចថ្ងៃមុនសោះ ។ ឡៅពីដឹងចិត្តសេនាទាហានទាំងអស់ពុំមានក្លៀវក្លា ក៏ប្រើជ្រាជានិយាយយកចិត្តថា ធម្មតាមនុស្សយើងកើតមកពាល់គ្នាជាជាតិទាហានហើយ បើនឹងបង់ជីវិតទៅក៏មិនត្រូវជាទុក្ខ បើនឹងវាយបានស្រុកក៏មិនត្រូវត្រេកអរ ។

គ្លួនអ៊ូក៏សួរតៀវហ៊ុយថា ខ្ញុំនៅលោកមកនេះ បានទាំយកគ្រប់គ្រួរបស់បងយើងមកដែរឬទេ? ។ តៀវហ៊ុយឆ្លើយថាបងថ្លៃយើងទាំង ២

នាក់ ជ្រាក់កងកណ្តាប់ដៃសត្រូវទៅក្នុងស្រុកឈើដីវៀងអស់ទៅហើយ ។ គួនអ៊ីព្ធដូច្នោះក៏ញ៉ែអស់ទាំងខ្លួន កន្ត្រាក់យកខ្លួនកាន់ហើយទន្ទ្រាំចាំថា កាលទៀតជាបងរៀបនឹងចេញដំណើរមក លោកក៏ចាន់សុំខ្លួនទៅគ្រប់គ្រងរក្សាស្រុក ចាន់ទាំងចុះសញ្ញាថាម្តេចខ្លះ លោកគិតឃើញឬទេ? បើគ្រាន់តែខ្ញុចស្រុកឈើដីវៀងហើយ ម្តេចឡើយឲ្យបងទាំងគ្រប់គ្រងរបស់បងទៅទៀត បើដូច្នេះលោកនឹងគិតទៀតដូចម្តេច? ។ តៀវហ៊ុយឃើញគួនអ៊ូខឹងសម្បារថារំលើកសព្វគ្រប់ ក៏ជាក់មុខសញ្ជប់សញ្ជឹង តាំងតែទោមនស្សខ្នាស់អស់សេនាឥហានពន់ប្រមាណណាស់ ទើបហូតក្រប៊ីលើកឡើងប្រឆាំងនឹងអាកខ្លួនឯងសម្លាប់ ។ ទៀតពីឃើញក៏ស្ទុះប្រញាប់ចាប់ដណ្តើមយកក្រប៊ីបានហើយនិយាយថា "ពាក្យបុរាណមានពោលទុកថា ធម្មតាកិរិយាបុត្រនោះឧបមាដូចជាសំពត់អាវដែលស្លៀកពាក់បើរវៃកជ្រុះភ្លាក់ ក៏ត្រូវរកទៀតបាន ឯបងប្អូនញាតិសន្តានដូចជាដៃជើងទាំងខ្លួនស្តាំ បើប៉ាក់បែកវៃកស្រាំកម្រនឹងតភ្ជាប់បាន យើង ៣ នាក់ក៏ស្បថស្បាន់ទុកគ្នាជាចិត្តដ៏វិត ១ មកយូរហើយ ថ្ងៃបើខ្ញុចស្រុកឈើដីវៀងកិរិយាបុត្រប៉ុណ្ណោះជាការក្រៃវេ បើសម្លាប់ខ្លួនចេញហើយ ទឹងបានបេះដែលខ្ញុចនោះមកវិញកាលណា បើជីវិតសង្ខារយើងទៅតទៅមុខ យើងក៏គង់រកសេចក្តីសុខឡើងទៀតឲ្យបាន" និយាយហើយក៏យំសោក ។ គួនអ៊ូ. តៀវហ៊ុយឃើញទៀតពីយំកាលណា ក៏នាំគ្នាយំសោកជាមួយ ទាំងអស់គ្នា ។

ឯអ្នកស៊ុតលុះដឹងថា លីចុ៉ាយបានស្រុកឈើដីវហើយ ក៏ប្រើ
តាហានតាន់សំបុត្រទៅឲ្យលីចុ៉ា សេចក្តីថា ឲ្យលីចុ៉ាជួយច្បាំងវាយទ័ព
ឡៅពីឲ្យបែកចុះ យើងនឹងឲ្យសេះ ៥០០ ស្រូវ ៥០០ ម៉ឺនថាំង មាស ១ ម៉ឺន
ដំឡឹង ក្រៃ ១ ពាន់ផាប់ ។ លីចុ៉ាឃើញដូច្នោះក៏ពេញចិត្តណាស់ ចាត់
ប្រើតោស៊ុនលើកតាហាន ៥ ម៉ឺន ទៅវាយខ្ទប់ពីក្រោយទ័ពឡៅពី។ ក៏
ប្រឹក្សានឹងគួនអ៊ូ តៀវហ៊ុយថា យើងមានសេនាតាហានតិចណាស់ ឃើញ
ជាតស៊ូនឹងគេមិនបាន ។ លុះដល់ពេលយប់ធ្លាក់ភ្លៀងធំ ឡៅពីគួនអ៊ូ
តៀវហ៊ុយ ក៏លើកតាហានចេញពីបន្ទាយទៅស្រុកកងឡែង ។

តោស៊ុនដឹងថា ឡៅពីលើកទ័ពរត់ចេលបន្ទាយទៅហើយ ក៏
ហួសទៅដួបនឹងគីឡែងក្នុងបន្ទាយ ។ តោស៊ុនឧយាយថា ឥឡូវឡៅពី
រត់ចេញពីយប់មិញជាត់ទៅហើយ របស់ដែលចៅហ្វាយអ្នកនឹងឲ្យចៅ-
ហ្វាយខ្ញុំនោះដាយ៉ាងម្តេចទៅវិញ? ។ គីឡែងតបថា សេចក្តីទាំងនេះខ្ញុំ
នៅមិនទាន់ដឹងច្បាស់ដែរ បើខ្ញុំត្រឡប់ទៅដល់ស្រុកវេលាណា នឹង
សួរអ្នកស៊ុតឲ្យដឹង ។

នាយទ័ពទាំង ២ ក៏លើកត្រឡប់វិលទៅស្រុកតែសព្វគ្នា ។ ឯតោស៊ុន
បានដំរាបលីចុ៉ាថា ឡៅពីលើកទ័ពរត់ជាត់ទៅហើយ ខ្ញុំបានបានទៅ
ដួបសួរគីឡែងនាយទ័ពស្រុកឡាំយ៉ុង ពីរឿងរបស់ឲ្យដែលអ្នកស៊ុត
សន្យានឹងឲ្យនោះ គីឡែងថាចាំទៅសួរអ្នកស៊ុតជាចៅហ្វាយ បើបាន
សេចក្តីដូចម្តេច នឹងឲ្យដំណឹងជាក្រោយ ។

លីប៉ាបានស្តាប់ក៏ឲ្យពិការ់ក្នុងចិត្តគិតសង្ស័យ ទទួលឃើញបំរើអ្ងួនសុតនាំសំបុត្រទៅដល់ សេចក្តីថា អ្នកចាត់ប្រៃគោស៊ុនជានាយកងខ័ពលើកទៅទូបំផ្លាញក៏មែន តែមិនទាន់បានច្បាំងតាំងតគ្នា ហើយក៏ចាប់ផ្លាញមិនបាន បើបានខ្លួនផ្លាញវេលាណា យើងនឹងឲ្យបរស់តាមសញ្ញា ។ លីប៉ាបានស្តាប់សំបុត្រនោះរឹងណាស់ថា អ្ងួនសុតនោះចរចាមិនពិតទៀងទាត់ បើនឹងអត់តទៅទៀតក៏ពុំបាន ទើបប្រឹក្សានឹងសេនាតាហានថា យើងត្រូវលើកទ័ពទៅច្បាំងនឹងអ្ងួនសុតក្នុងគ្រានេះ ។

គាន់កុងធ្វើយថា ឥឡូវអ្ងួនស៊ុតលើកព្យហៈមកតាំងបន្ទាយនៅស្រុកឈើវឈុនជាទីសំខាន់ សេនាតាហានដែលមានថ្វីដៃក៏ខ្លាំងពូកែជ្រែនណាស់ តាំងចំណីត្រីសាច់ក៏បរិបូណ៌ត្រៃម បើលោកនឹងលើកទៅឥឡូវនេះ ក៏នឹងបរាជ័យមិនខាន សុំឲ្យលោកវិះគិតអានបញ្ចុះបញ្ចូលឲ្យផ្លាញមកចុកក្នុងស្រុកសៀវផាយវិញ បើយើងលើកទ័ពទៅក៏ត្រូវបានទីស្នាក់នឹងឲ្យផ្លាញ គួនអ្ងួ តៀវហ៊ុយជាកំលាំង យើងនឹងតាំងគិតការតទៅក៏នឹងបានសម្រេចដោយងាយ ។ លីប៉ាយល់ឃើញត្រូវ ក៏ចាត់បំរើឲ្យកាន់សំបុត្រទៅឲ្យផ្លាញ ។

ឯផ្លាញកាលលើកទ័ពរត់ទៅដល់ស្រុកកងឡែង ទទួលអ្ងួនសុតលើកទៅវាយស្រុកកងឡែងបែក ផ្លាញក៏រត់ចេញពីស្រុកនោះទៅទៀតប្រទះនឹងបំរើកាន់សំបុត្រលីប៉ាទៅដល់ ទទួលយកសំបុត្រមកមើលដឹង

សេចក្តីហើយ ក៏ពីគ្រានឹងគួនអ៊ួថា លីចុ៉ាឲ្យសំបុត្រមកអន្ទងយើង ទៅវិញ ចៅនឹងយល់យើញដូចម្តេច? ។ គួនអ៊ួជំរាបថា លីចុ៉ាជា មនុស្សចេះនិយាយពិរោះ តែជាពាក្យមុសាវាទមិនពិតត្រង់ណា បើយើង នឹងគប់ប្រសព្វយកជាគ្នាទៅ ក៏មិនបានល្អ ។ ទ្បៅពីតបថា ឥឡូវ លីចុ៉ាឲ្យមកអន្ទងយើងដោយសុភាពហើយ ត្រូវតែយើងទៅទើបគួរ ។

ក្នុងពេលដែលលីចុ៉ាឲ្យខាហានកាន់សំបុត្រទៅឲ្យទ្បៅពី ហើយខ្លាច ក្រែងទ្បៅពីមិនព្រមមកវិញ លីចុ៉ាក៏ចាត់ខាហានឲ្យនាំខ្លួននាងកាំហ៊ូ យិនទឹងនាងប៊ុហ៊ូយិនដែលជាកវិយាទ្បៅពីទៅដូនទ្បៅពី ដើម្បីនឹង ឲ្យទ្បៅពីអស់សេចក្តីសង្ស័យ ទទួលទ្បៅពីលើកទ័ពមកជួប ទឹងកវិយា កណ្តាលផ្លូវ ទ្បៅពីយើញកវិយាក៏សោមនស្សត្រេកអរណាស់ សាកសួរ ថា កាលលីចុ៉ាយកស្រុកឈើដីវិបាទៗពីគ័ក្តីវក្សាចៅទាំង ២ ដូចម្តេចខ្លះ?។ នាងកាំហ៊ូយិន, នាងប៊ុហ៊ូយិនជំរាបថា លីចុ៉ាចាត់ខាហាន ១០០ នាក់ ឲ្យនៅយាមល្បាតរក្សាយើងខ្ញុំមាំមួនណាស់ មិនឲ្យនរណាចូលចេញ តាមអំពើចិត្តឥតគួរសមនោះឡើយ ហើយចាត់ឲ្យមានស្រែបំរើបំរុងដូន ចំណីអាហារកាលវេលា ។ ទ្បៅពីនិយាយនឹងគួនអ៊ូ, តើវិហ៊ុយថា យើងបាននិយាយពីមុនមកហើយថា លីចុ៉ាគ្រាកដជាមានតតញ្ញូនឹង យើង គោះបីយ៉ាងណា ក៏មិនប្រទូសរ៉ាយដល់កវិយាយើងដែរ បើ ដូច្នេះ ត្រូវតែយើងចូលទៅជួបនឹងលីចុ៉ាទើបគួរ ។ ចំណែកខាងគួនអ៊ូ

យល់ព្រមហើយ តែតៀវហ៊ុយនៅជាប់អាឃាដព្យាបាទ ក៏និយាយថា ខ្ញុំមិនសុំឃើញមុខអាលីចោ"តទៀត ហើយបងគាំងពីរនឹងចង់ទៅក៏ទៅចុះ ខ្លួនខ្ញុំនឹងនាំបងថ្លៃទៅនៅស្រុកសៀវផាយមុន ហើយតៀវហ៊ុយក៏នាំកវិយាឡៅពីទៅស្រុកសៀវផាយ ឯឡៅពីនឹងគួនអ៊ូក៏ចូលទៅរកលីចោ" ។

លីចោ"ចេញមកទទួលហើយ ក៏អញ្ជើញឡើងលើទីគេហស្ថាន ហើយចាប់ផ្តើមនិយាយថា ខ្ញុំធ្វើការគាំងនេះ មិនមែននឹងឃើញទ្រព្យសម្បត្តិសព្វសារពើរបស់អ្នកទេ ដោយហេតុតៀវហ៊ុយប្អូនអ្នកដឹកស្រាស្រឹងចិត្តរំលោភធ្វើការហួសខ្នាត ខ្ញុំគិតខ្លាចគេព្យាបាទដល់ខ្ញុំនឹងកើតវឹកវរឡើង បានជាខ្ញុំលើកទាហានមកយកស្រុកនេះ ថ្វាយនឹងក្សត្រ ជូនអ្នកកុំឲ្យបែកបាក់អន្តរាយ ឥឡូវអ្នកមកដល់ ត្រូវខ្ញុំបែគល់ជូន ។

ឡៅពីតបថា ស្រុកនេះកាលពីមុនខ្ញុំបានលើកជូនអ្នកម្តងហើយ អ្នកមិនព្រមយក ឥឡូវអ្នកមកនៅស្រាប់ក៏ជាការគាប់ប្រសើរ គួរជាស្រុករបស់អ្នកហើយ ចូរនៅឲ្យបានសេចក្តីសុខចុះ ឯខ្លួនខ្ញុំសុំនាំបក្សពួកទៅនៅស្រុកសៀវផាយវិញ ។ លីចោ"និយាយលួងលោមឲ្យឡៅពីទទួលយក សុកដូចដើម ។ ឡៅពីមិនព្រមក៏លាលីចោ"ចេញទៅនៅស្រុកសៀវផាយ ។

(មានត)

រឿងអាវ៉ាក្យថ្លែងរឿងម្ចាស់ច្រាំ

លោក រ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

រឿងទីប្រាំបី

អាវ៉ាក្យក្រាបទូលព្រះមហាក្សត្រថា "បពិត្រមហារាជ! មានទីក្រុងមួយឈ្មោះមិថលាវតី (Mithalavati) ហើយនៅក្នុងទីក្រុងនោះ មានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាមគុណាធិប (Gunadhip)។ មានរាជបុត្រមួយអង្គទ្រង់ព្រះនាមធីរំទេវៈ (Chiramdév) ស្តេចចេញចាកប្រទេសឆ្ងាយ ដើម្បីនឹងចូលមកធ្វើការជាមួយនឹងមហារាជ។ ក្នុងមួយថ្ងៃៗ ព្រះអង្គម្ចាស់ទ្រង់ចូលមកសូមគាល់ព្រះមហាក្សត្រ តែមិនចេះបានព្រះរាជានុញ្ញាតឲ្យចូលគាល់សោះ។ ទ្រង់បានរង់ចាំអស់រយៈវេលាមួយឆ្នាំ មិនទាន់បានចូលគាល់ព្រះមហាក្សត្រនៅឡើយ, ទ្រង់ចាយប្លាក់ដែលយកមកក្នុងការធ្វើដំណើរនេះ អស់គ្មានសេសសល់ ហើយព្រះរាជគ្រួសារធ្លាក់ចុះកន្លងការណ៍លំបាក។

មានកាលថ្ងៃមួយ ព្រះមហាក្សត្រទ្រង់គង់អស្សត ដើម្បីនឹងយាងទៅគ្រាលបរបាញ់សត្វក្នុងព្រៃ, ព្រះអង្គម្ចាស់ធីរំទេវៈទ្រង់បានទៅជាមួយនឹងព្រះរាជបរិវារដែរ។ ក្នុងពេលដែលព្រះរាជបរិវារបានរង្វង់ចូល

ទៅកន្លែងមួយទៀត នៅតែព្រះអគ្គមហាសាវ័កធំរំទេះ ទន្ទឹងតាមពីក្រោយព្រះមហាកស្សបៈ ។ ក្នុងពេលនោះ ព្រះអគ្គមហាសាវ័កធំរំទេះ បានក្រាបទូលព្រះមហាកស្សបៈថា: "សូមព្រះករុណាថ្លៃវិសេសទន្ទឹងព្រះមេត្តាប្រោស, ព្រះពាជបរិវារបស់ព្រះអង្គនៅខាងក្រោយ ហើយទូលព្រះបង្គំបានជិះសេះលឿនមកជិតព្រះអង្គដើម្បីនឹងហៃព្រះអង្គជាព្រះពាជកិត្តិយស" ។

ព្រះមហាកស្សបៈទន្ទឹងព្រះសណ្តាប់ហើយ, ទន្ទឹងបញ្ឈប់ព្រះទីនាំងអស្សតរ, ហើយដល់ព្រះអគ្គមហាសាវ័កធំរំទេះមកដល់, ទន្ទឹងក៏បានធ្វើឆ្ងាំងព្រះនេត្រទៅកាន់ព្រះអគ្គមហាសាវ័កធំរំទេះ ហើយមានព្រះបន្ទូលសួរថា: "ម្តេចក៏ឯងស្គមអ្វីម្ល៉េះ?" ។

ព្រះអគ្គមហាសាវ័កធំរំទេះ ក្រាបទូលទៅព្រះមហាកស្សបៈវិញថា: "កាលណានាយចៅហ្វាយម្នាក់ចិញ្ចឹមមនុស្សពាន់ដងសែននាក់ តែមិនរវល់ថែទាំមនុស្សដែលស្ថិតនៅជិតខ្លួន គឺកំហុសនោះមិនមែនធ្លាក់ទៅលើនាយចៅហ្វាយទេ តែធ្លាក់ទៅលើជោគវាសនានៃមនុស្សនោះ ។ កាលណាពិភពលោកក្រឡេកទៅឃើញរស្មីហើយ មានតែបក្សាទីពុយមួយក៏មិនឃើញរស្មីនោះ តើកំហុសនោះធ្លាក់ទៅលើព្រះអាទិត្យឬ? តែទូលបង្គំឆ្លៀតពន់ពេកថាអ្នកណាដែលបានបីបាច់ថែរក្សាទូលបង្គំ ក្នុងពេលដែលទូលបង្គំនៅកន្លែងកំណើតនៃមាតា, ឥឡូវលែងថែទាំទូលបង្គំទៅវិញ តាំងពីទូលបង្គំប្រសូតចេញមកហើយ ត្រូវការបរិភោគអាហារថែមទៀត

តែទូលបង្គំយល់ថា គួរតែលេបនូសថពុលឲ្យស្លាប់ទៅប្រសើរជាង, កុំឲ្យតែជំពាក់នូវគោគទ្រព្យចំពោះឥស្សរជន ដែលបានឲ្យនូវគោគទ្រព្យនោះដោយកត្តញ្ញូតាធម៌ព្រមទាំងញាក់ចិត្តមើមគោមនស្សថែមទៀត ។

ចង់មេត្រីភាពនឹងមនុស្សគ្រាលទុច្ចរិត, សើចដោយគ្មានហេតុ, ឈ្លោះនឹងស្រី, បំរើមនុស្សថោកទាប, ជំនះលា, មិនចេះពោលពាក្យសំស្តីត នេះជាវត្តទាំង៦ប្រការមួយដែលនាំមនុស្សឲ្យថោកទាប ។

តាំងពីបដិសន្ធិមក, ព្រះអាទិទេពបានចារឹកទុកចំពោះជោគវាសនារបស់មនុស្សនូវរបស់ប្រាំយ៉ាង គឺ: ទីមួយអាយុ, រូបសកម្មភាព, គោគទ្រព្យ, វិទ្យាសាស្ត្រនឹងកេរ្តិ៍ឈ្មោះ ។ នុមហារាជ! ដរាបណាព្រះមហាក្សត្រស្ថិតនៅក្នុងគុណធម៌ ដរាបនោះព្រះរាជបរិវារមានចិត្តគោរពស្នេះស្នៀគនឹងព្រះអង្គ តែបើគុណធម៌នោះប្រាសចាកចេញពីព្រះអង្គវេលាណា, កល្យាណមិត្តរបស់ទ្រង់ត្រឡប់ទៅជាបច្ចាមិត្តហើយ, តាមការពិត, ការបំរើគោរពនាយចៅហ្វាយតែងមានប្រយោជន៍; កិច្ចការនោះមិនដែលឥតផលឡើយ" ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់នូវសេចក្តីពោលនៃព្រះអង្គម្ចាស់ធីរវរៈ ទ្រង់ព្រះតម្រិះមិនបានតបឆ្លើយទៅវិញភ្លាម តែទ្រង់មានបន្ទូលទៅកាន់ព្រះអង្គម្ចាស់ធីរវរៈ ថា: "យើងយ្យានចុាយ, ឯងត្រូវទៅរកអ្វីមកឲ្យយើងបរិភោគ" ។

ព្រះអង្គម្ចាស់ធីរំទេវៈ ក្រាបបង្គំទូលព្រះមហាក្សត្រថាៈ "សូមទ្រង់ព្រះមេត្តាជ្រោស ! ទូលបង្គំមិនមានបំរុងព្រះស្បែយសម្រាប់ទុកថ្វាយនៅទីនេះទេ" ។ ដល់ក្រាបទូលព្រះមហាក្សត្រចប់ហើយ ព្រះអង្គម្ចាស់ធីរំទេវៈ ក៏ចូលទៅកន្លែងដែលជាញ៉ាំបានឈ្វូសមួយ បានយកថ្នមដែកក្តៅដំបង្កាត់ភ្លើងហើយហាន់សាច់ឈ្វូសនោះ យកទៅចំអិនជាព្រះស្បែយហើយយកទៅថ្វាយព្រះមហាក្សត្រសោយ រួចទើបខ្លួនបរិភោគជាមួយគ្នាយ ។

ដល់ព្រះបាទគុណាធិបៈសោយឆ្អែតស្កប់ស្កល់ហើយ, ទ្រង់មានបន្ទូលទៅកព្រះអង្គម្ចាស់ធីរំទេវៈថាៈ "ឧកជបុត្ត ! ឥឡូវអ្នកចូរនាំយើងទៅកាន់ព្រះពជមានីវិញ ព្រោះយើងមិនស្គាល់ផ្លូវ" ។

ព្រះអង្គម្ចាស់ធីរំទេវៈ បានដង្ហែព្រះមហាក្សត្រទៅព្រះពជមានីវិញ។ ព្រះបាទគុណាធិបៈបានព្រះពជមានទៅព្រះអង្គម្ចាស់ធីរំទេវៈ ទូវព្រះពស្ត្រព្រមទាំងគោគទ្យមាសប្រាក់ជាច្រើន ហើយទ្រង់ត្រាស់បង្គាប់ឲ្យទៅធ្វើការកន្លែងព្រះបរមពជកំនង; តាំងពីនោះមកព្រះអង្គម្ចាស់ធីរំទេវៈជាមហាតលិកស្ថិតនៅជិតព្រះករុណា ។

មានមួយថ្ងៃ, ព្រះមហាក្សត្រទ្រង់បានចាត់ប្រើព្រះអង្គម្ចាស់ធីរំទេវៈទៅឯមាត់សមុទ្រអំពីរឿងផ្សេង។ ។ ដល់ព្រះពជបុត្តទ្រង់ស្តេចទៅដល់បានឃើញព្រះវិហារមួយ ដែលគេសាងថ្វាយនាងទេវីប្តូទេវធីតា ។

កន្លងមួយរំពេចនោះ មានឥន្ទ្រាភ្លាមក្នុងចេញពីព្រះវិហារនោះមកហើយ សួរទ្រង់ថា: "ហេតុដូចម្តេច ចានជាទ្រង់មកគង់ទៅទីនេះ? ។ ព្រះអង្គម្ចាស់ធីរទេវៈ ទ្រង់មានបន្ទូលតបទៅនាងកញ្ញាវិញថា: "ខ្ញុំមកទីនេះដើម្បីសេចក្តីសប្បាយក្នុងអាមិស ហើយខ្ញុំគ្រាន់តែឃើញលំអរបស់នាងចិត្តខ្ញុំទៅជាភ័ន្តភាំងស្មារតីជាពន្លឹក" ។

នាងកញ្ញាក៏ក្រាបទូលទ្រង់ថា: "បើទ្រង់មានចំណង់កន្លងតាមតណ្ហាចំពោះខ្ញុំម្ចាស់, សូមទ្រង់ស្តេចទៅស្រង់ព្រះទេពៈនៅឯត្រពាំងឯនោះខ្ញុំម្ចាស់នឹងស្តាប់ព្រះបន្ទូលទ្រង់តទៅទៀត" ។

ព្រះអង្គម្ចាស់ធីរទេវៈទ្រង់ចានសណ្តាប់ឮវាសួរបស់នាងកញ្ញាទ្រង់ក៏ដោះព្រះពស្ត្រចេញ, ចុះទៅក្នុងត្រពាំងស្រង់ព្រះគង្គា ។ ដល់ទ្រង់ស្រង់រួចហើយ ឡើងមកលើមាត់ត្រពាំងស្រាប់តែព្រះរូបទ្រង់នៅឈរក្នុងទីក្រុងគីព្រាជធានីនោះឯង ។ ដល់ទ្រង់ទតទៅឃើលហេតុប្លែកអស្ចារ្យយ៉ាងដូចនេះ, ទ្រង់ក៏ភ័យកក់ស្លុត, មិនដឹងនឹងគិតធ្វើយ៉ាងណា, ទ្រង់ក៏ចូលទៅក្នុងដំណាក់ផ្ទាស់ព្រះពស្ត្រផ្សេងទៀត ហើយក៏ចូលទៅក្នុងព្រះបរមរាជវាំង ក្រាបបង្គំទូលព្រះមហាក្សត្រឲ្យទ្រង់ជ្រាបអំពីរឿងអស្ចារ្យនេះ ។ ព្រះបាទគុណាធិប:ទ្រង់ព្រះសណ្តាប់ឮវាព្រះអង្គម្ចាស់ធីរទេវៈក្រាបទូលទ្រង់ៗ មានព្រះឱង្ការតបទៅវិញថា: "ឲ្យអ្នកបង្ហាញយើងនូវរឿងប្លែកដូចនេះ" ។ រួចព្រះមហាក្សត្រទ្រង់គ្រាស់

បង្គាប់ឲ្យរៀបចំរេហ៍ពលហើយព្រះអគ្គនឹងព្រះអគ្គម្ចាស់ធីរៈទេវៈ ទ្រង់គង់លើព្រះពជទីនាំងអស្សតរៈធ្វើព្រះពជដំណើរទៅកាន់ទីនោះដល់ប្លន់ថ្ងៃ. ព្រះមហាក្សត្រទ្រង់យាងទៅដល់មាត់សមុទ្រ, ទ្រង់ចូលទៅជាមួយព្រះអគ្គម្ចាស់ធីរៈទេវៈ ថ្វាយបង្គំក្នុងព្រះវិហារ ។ ដល់ព្រះមហាក្សត្រទ្រង់ចាកចេញពីព្រះវិហារ មានឥន្ទ្រាយុវតីនឹងទាសីម្នាក់ដើរមកឈរចំពោះព្រះភក្ត្រព្រះមហាក្សត្រ។ ទ្រង់ឃើញរូបឆោមលោមពណ៌នាងស្អាតល្អប្លែកអស្ចារ្យ, ទ្រង់មានព្រះទ័យទន់ទោរទន់ពេក, តែនាងបានក្រាបទូលទ្រង់ថា: "បពិត្រព្រះករុណា, មហាពជបើទ្រង់មានព្រះបន្ទូលត្រាស់បង្គាប់យ៉ាងណា, ខ្ញុំម្ចាស់នឹងប្រតិបត្តិតាមព្រះពជនុង្គារយ៉ាងនោះពុំហ៊ានខាន" ។

ព្រះមហាក្សត្រទ្រង់មានព្រះពជនុង្គារ ទៅកាន់នាងយុវតីវិញថា: "បើឃើញតែមតាមបញ្ជាត្តិរបស់ខ្ញុំ ចូរនាងតែមសុខចិត្តធ្វើជាភរិយានៃទាសារបស់ខ្ញុំចុះ" ។

នាងកញ្ញាក្រាបទូលព្រះមហាក្សត្រវិញថា "សូមទ្រង់ព្រះមេត្តាប្រោស, ម្តេចក៏ឲ្យខ្ញុំម្ចាស់ធ្វើជាភរិយាព្រះពជទាសាទៅកើត បើខ្ញុំម្ចាស់ជាទាសីនៃព្រះពជលំអរបស់ទ្រង់ដោយពិត?" ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា: "នាងឯងបានពោលអម្បាញ់មិញនេះថានាងតែមប្រតិបត្តិតាមបញ្ជាត្តិរបស់ខ្ញុំសព្វគ្រប់ប្រការ។

បុគ្គលដែលមានចិត្តស្មោះស្ម័គ្រតែងតែប្រតិបត្តិតាមកិច្ចសន្យារបស់ខ្លួនជាដាច់ខាត ។ តែងនាងទទួលធ្វើតាមកិច្ចសន្យានេះហើយ ចូរនាងត្រមសុខចិត្តធ្វើជាប្រពន្ធនៃខាសាខ្ញុំ" ។

នាងកញ្ញាក៏ក្រាបទូលព្រះមហាក្សត្រថា: "ខ្ញុំម្ចាស់យល់ព្រមធ្វើតាមព្រះពាជនដ្ឋានរបស់ព្រះបន្ទូលសូរសីហនាទសព្វគ្រប់ទាំងអស់" ។

ព្រះមហាក្សត្រទ្រង់ក៏បានធ្វើសមរសព្រះអង្គម្ចាស់ធីរវៈ: ទើនាងកញ្ញាតាមប្រពៃណីគន្ធវៈ (Gandhava) ហើយអ្នកទាំងពីរក៏លែព្រះមហាក្សត្រវិលត្រឡប់ទៅព្រះពាជនិវេសនដ្ឋានវិញ ។

អាវ័ក្សថ្ងៃនេះចប់សព្វគ្រប់ ហើយក្រាបទូលព្រះមហាក្សត្រថា: "បពិត្រមហាពាជ! តើអ្នកណាមានគុណធម៌ជាង ម្ចាស់ (ព្រះមហាក្សត្រ) ឬខាសា (ធីរវៈ)? ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលទៅនឹងអាវ័ក្សថា: "ខាសាមានគុណធម៌ជាង" ។

អាវ័ក្សក្រាបបង្គំទូលសួរព្រះមហាក្សត្រវិញថា "ព្រះមហាក្សត្រអង្គនេះ ទ្រង់ស្ងួលបង់នូវនាងកញ្ញាដែលមានរូបឆោមលោមពណ៌ ល្អជាពន្លឹក ហើយធ្វើអំណោយនូវស្ត្រីនោះមកព្រះមហាតលិកវិញ; តើទ្រង់មិនមែនពុំមានគុណធម៌ឬ?" ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលតបទៅនឹងអាកែ្សវិញថា "ការណ៍-យកិច្ចរបស់ស្តេចត្រូវតែធ្វើសេចក្តីល្អចំពោះប្រជាពលស្តេ ។ តើព្រះអង្គនេះមានគុណធម៌ប្លែកយ៉ាងណាទៅ, គ្រាន់តែបំពេញនូវការណិយកិច្ចរបស់ទ្រង់ប៉ុណ្ណោះ តាមសភាពផ្ទុយទៅវិញ, ភាសាដែលមិនបំពេញការ-ណិយកិច្ចគឺមានតែខ្លួនឯង ថែមទាំងព្រួយបារម្ភគិតដល់ប្រយោជន៍ របស់ម្ចាស់នោះទៀត ភាសានេះមិនគួរយើងនឹងមិនសរសើរគេទេឬ? ភាសានេះ គឺមានគុណធម៌ជាងម្ចាស់ខ្លួនទៅទៀត" ។

អាកែ្សបានស្តាប់នូវព្រះបន្ទូលហើយ ក៏ត្រឡប់វិលទៅព្យួរខ្លួននឹងរុក្ខជាតិវិញ ហើយព្រះមហាក្សត្រទៅចាប់ពាក្យអាកែ្សយកមកលើលើព្រះអង្សា (ស្មា) រួចទ្រង់នាំយកអាកែ្សនោះទៅ ។

ចប់រឿងទីប្រាំបី, នៅមានរឿងទីប្រាំបួនតទៅទៀត ។

កុំដេកចាំសំណាង

កុំដេកសង្ឃឹម បាំព្រេងសំណាង
ដៃលខ្វះកសាង ពីជាតិមុនណា
សាសន៍ណាដូច្នោះ សាសន៍នោះឈ្មោះថា
នាំដៃនអាត្មា ឲ្យជាទុំគេ ។

(តមក)

ឃុតទី ៣ ជាកទី ១

ភាណវិធី

(តែម្នាក់ឯង)

តែបអើយខ្ញុំបានទៅឃើញអ្នក! ដោយចិត្តខ្ញុំស្ញែតនឹងវណ្ណភាព
សមុទ្រមានទឹកដ៏ទៀវថ្លា ម្តេចក៏ពិសាសវើង ។
តែឡប់ជាបៃខ្ទះដើមក ជាក់តែវាឃើញសហើយខំផ្ចើង
តែបចូលក្នុងមាត់បៃវើង ទើបឈ្វេងគាញចេញយ៉ាងប្រញាប់ ។
វណ្ណភាពរូបកាងល្អវិសេស ឃើញហើយចង់ចេះតែលូកថាប់
ប៉ុន្តែមិនបានទៅកៀកជាប់ គួរកប់សមុទ្រៃបយ៉ាងណា ។
រថយន្តរត់ព័ទ្ធកុំចំហុត តាមឆ្នេរសមុទ្រដងបតូតា
បងមិនគន់ទេសាគរ នេត្រាបង់តែមើលស្រី ។
រថយន្តទាំងពីរបើកត្រសង បងឃើញតែខ្នងស្រស់ពីសី
អង្គុយក្នុងយានរត់កាត់ព្រៃ វិថីត្រង់ទៅវែងអន្លាយ ។
មកដល់កំពតថ្ងៃដិតត្រង់ បងឥតបង្អង់ចុះញុំាបាយ
ប៉ុន្តែនារីនាងដើរឆ្ងាយ ដល់តុញុំាបាយឆ្ងាយពីគ្នា ។

ចាយរួចឡើងយានទាន់ញញឹម ប៉ះច្រឹមបៃរចំមកកក្តៅ
លុះបង់ចាន់ឃើញវេលាណា ចិន្តាបង់តែតែកិស្ម័យ ។
ក្នុងចិត្តនឹកថាចាន់ជួបស្នេហ៍ ស្រស់តែវែរល័ក្ខណ៍ឥតសង្ស័យ
ឥឡូវអ្នកនាង់កាត់អាល័យ ពីថ្ងៃនេះទៅលែង់ឃើញហើយ ។
ខ្ញុំលាដែនតែបដោយស្មោះសរ លាហើយសាតមិនឃើញត្រើយ
ខ្ញុំលាវាយោបក់រំគើយ ខ្ញុំលែង់ងើបងើយមើលទៀតណា ។
លាហើយវិថីទៅកំពត ចូរអ្នកកុំក្រែាធចិត្តចិន្តា
លាហើយក្តុជាតិនឹងបពូតា ពីថ្ងៃនេះណាខ្ញុំចាកឆ្ងាយ ។
លាហើយ តុ, ឪ, ន៊ឹង់ភៅអី បង់ប្អូនប្រុសស្រីកុំនឹកស្តាយ
លាហើយបន្ទប់ដែលញុំាចាយ កម្ពុជាដែនអាយកុំសោកសោយ ។
ទៅស្រុកចាក់ង់រៀនវិជ្ជា ជម្ងឺង់កាពទៅថ្ងៃក្រោយ
ពីថ្ងៃនេះទៅលែង់ឲ្យឆ្ងាយ មិនឲ្យក្តីស្នេហ៍បំបែរបាន ! ។

(ងាកក្បាលហើយកណ្តៀត Castable ដើរចេញ)

ឈុតទី ៣ ជាកទី ២

ភាណនវ-ភាណវិទូ-មិត្តភាព-ផលនាវី

ភាណនវ

ឈប់សិន ! ភាណវិទូ បង់សំឡាញ់ បង់កុំអាលចេញទៅពីថ្ងៃ
អាកាសយានចេញមោ៉ង ៨ មិនអីទេបង់ខ្ញុំជូនទៅ ។

បងកុំប្រញាប់ទោះថ្ងៃណា ! កុំភ័យរសោះសោពេលឥឡូវ
ដំណើរប៉ុណ្ណឹងខ្ញុំគិតត្រូវ ដម្រូវចិត្តបងឲ្យសប្បាយ ។
បងនៅជួបជុំក្រុមញាតិពេញ ព្រោះបងត្រូវចេញចាកទៅឆ្ងាយ
ទៅស្រុកឆ្ការកំងនៅឯនាយ ស្ងាធ្យាយន័ផ្លូវច្បាប់សម្រាប់ជាតិ ។
បងចំរៀនអស់ប្រាំកាប់ពាន់ ចាស់សូពីរជាន់ មិនមានឃ្លាត
បើបងធ្វើខ័ពស្រុមាប់ជាតិ មិនឃ្លាតពីស័ក្តិធំអស្ចារ្យ ។

ភាណារិទ្ធិ

ទេ! ទេ! ទេ! កុំ! អូនប្រុសបង បែកខាងពលកងមិនត្រូវការ
ទៅច្បាំងឲ្យស្លាប់ដូចឆ្កែឆ្កួ. បងមិនត្រូវការទេប្អូនប្រុស ។
មួសាំដើរដេកហាលក្នុងព្រៃ សឹកសង្គ្រាមជ័យ អូនធ្វើចុះ
បងមិនធ្វើទេកងខ័ពនោះ មិនស៊ូរងគ្រោះព្រោះសង្គ្រាម ។

ភាណាស្ងួរ

វេទនាមែនពិតតែសប្បាយ ចានកាំភ្លើងស្ពាយទៅសងឈាម
បើទុកជាស្លាប់ដោយសង្គ្រាម ក៏គង់មាននាមមិនសូន្យដែរ ។
បងមិនត្រូវខ្លាចសេចក្តីស្លាប់ ជាតិកើតមកចាប់ជាឈាមខ្មែរ
ដោះជាតិឲ្យរួចពីដៃគេ ជាតិនេះបើគ្មេរគួរគ្រាន់ដែរ ។
បើសិនណា ចាក់ខ្លួប្លី ដូចបង ! ខ័ពកងយើកមិញកុំមកក្បែរ
ធ្វើឲ្យយើញជាក់ថាជាតិខ្មែរ លឿនណាស់បីខែខ្លាត់ខ្លួយអស់ ។

ភាណវិទ្ធិ

ប្អូនខាងស្រីក! បងអ្នកខាងប្រាប់ ធ្វើការបានធាប់ដោយសោមនស្ស
ជនជាតិខ្មែរយើងទទឹងបានស្រស់ ទុក្ខសោកខ្ចាត់អស់ចាកកាយ ។

ភាណាធរ

ប្រាប់គឺការសារសំដី យកមកធ្វើអ្វីគ្មានសោភា
កាលណាស្រុកកើតយុទ្ធនា វិជ្ជាខាងប្រាប់ធ្វើដូចម្តេច ។
ស្រុកយើងត្រូវការកំឡាំងពល យោធាសកលទើបសម្រេច
ពុះពារវាយទាំងឲ្យកំចេច តើប្រាប់សម្រេចឬក៏កាយ? ។
ចូរបងកុំរៀនខាងផ្លូវប្រាប់ ខ្លាចស្ងាប់ត្រូវរៀននយោបាយ
ដោះសារបញ្ហាផងទាំងឡាយ គ្រាន់ជាប្រឡាយទឹកបវរ ។

ភាណវិទ្ធិ

បងទៅរៀនខាងនយោបាយ ខ្លាំលាយគិតការដល់នគរ
ប៉ុន្តែខ្មែរខ្លះមិនស្មោះសរ បងកជាតិឯងលក់ឲ្យគេ ។

ភាណាធរ

មិនអីទេបង! ខ្មែរឥឡូវ គេប្រែនយល់ត្រូវមិនខុសទេ
នរណាហ៊ានលក់ជាតិឲ្យគេ ទុកឲ្យខ្ញុំគ្នេរសូមបងជ្រាប ។
អ្នកខ្លះខំផ្ទុំក្លែងឲ្យនេះ ខ្លះចង់អាងផេះបុកថោកទាប
ជនរបៀបនេះបុកសៀបប្រៀប គេធ្លៀបទៅថាជនឈាមជា ។

គេឲ្យឡើងទ្រែងទ្រែងនំខ្ពស់ ធ្វើចិត្តអស់រសមិនល្អជា
ប្រកួតប្រកាន់តែគ្នាគ្នា ទំលាក់ខ្លួនវាពីលើទ្រែង ។

ភាណវារីទ្វី

ដរោ ! ដរោ ! សុវាចា ដែលផ្អែមពីសាគួរមនុស្សល្ងង់
គិតទៅឲ្យឃើញកុំវិលវង់ ព្រោះល្ងង់ទើបថោកមារយាទ ។
ភាណាទក ! ដរោ ! នរោបាយ រៀនឲ្យលេបខាយបំរើជាតិ
ពីថ្ងៃនេះទៅចិត្តឥតឃ្លាត ស្ងាប់ត្រាមទង់ជាតិប្រសើរថ្ងៃ ។

ភាណវារ

សាធុ ! សាធុ ! ចិត្តស៊ូស្ងាប់ ខ្ពើមអើយស្តាប់ពាក្យដំបៃ
សូមសម្រេចការល្អប្រពៃ ដរោ ! ជាទិវ្ថាថ្កើងឥតក្រឿង ។

មិត្តភាព

នេះបងភាណវិទូអក្សរខ្មែរ អ្នកប្រាជ្ញលោកកែតែងជារឿង
ទស្សនាវដ្តីថ្មីសមសឿង កុំឆ្ងើងបងយកទៅខុកអាន ។
កុំក្លេចអក្សរសាស្ត្រជាតិខ្មែរ ភាសាកំដែរជាវិញ្ញាណ
ទៅស្រុកបារាំង ៥ ស្បាហ៍អាន កុំឲ្យរំខានក្លេចជាតិយើង ។

ធិលការ៉ី

ខំរៀនឲ្យចេះដូចយុត្តិវង្ស គឺទ្រែងហើយ បង ! ប្រសើរថ្កើង
គឺទ្រែងហើយដែលអ្នកដំកើង ដំឡើងកិត្តិយសកម្ពុជា ។

តើថាដោយសារនេះយាយ ឲ្យមានតណ្ហាយកដល់តាក
បងរៀនឲ្យបានចេះដូចគ្នា គ្រាន់តែស្គាល់ជាតឹងផ្លែកបាន ។

ឈុតទី ៣ ឆាកទី ៣

ភាណី ម៉ាក ភាណវិទ្ធិ ដល់នារី

ភាណី

បងទៅៗសឹមហ៊ានធ្វើសំបុត្រ! ចាំសិហុលីវ៉ុត មកឲ្យខ្ញុំ
ខ្ញុំចង់តែឃើញរូបក្រមុំ ក្លៅឥតស៊ុំរូបល្អ។ ។
ផ្ញើមកឲ្យញឹកកុំឲ្យខាន់ មើបានឯរូបគេជាក់ពណ៌
ស្នេហាស៊ូខ្ញាំងយ៉ាងណាហ្ន៎! សង្ឃឹមអរបានថើបរូបក្រដាស ។

ម៉ាក (វយក្បាល)

គេទំព្រៃជៅឲ្យបានល្អ ចុះអា! ឥតធម៌និយាយផ្តាស
ស្តាយអើយសែនស្តាយខ្លួនខ្ញុំចាស់ ចេះមិនជ្រេជ្រែនឹងប្រស័យ។
កូនខ្ញុំតាំងអស់សុទ្ធគ្រាន់បើ ឥឡូវនេះដើរគាន់សម័យ
ឯស្តាយខ្លួនខ្ញុំដូចជាថ្ងៃ រសៀលពេកវៃក្រៃចូលភាពចាស់ ។

ភាណី

ឱ! អាការហ្នឹងជាការដាយ មើឲ្យខ្ញុំតាយស្រួលថាណាស់
សំដីផងខ្ញុំមិនមែនផ្តាស មើប៉ាខ្លាចចាស់កុំចូលឆ្នាំ ។

ធីលង៉ារី

ចុះបងបើខ្ញុំខ្លួននៅក្មេង　　មិនចង់ដើរលេងមាឌមិនមាំ
ឲ្យចាស់បន្តិចទើបបានហ៎ំ　　ល្មមសមដើរលេងឥតខ្លាចអ្វី ។

ភាណី

ន.! អារីអូន! បងដឹងចិត្ត　　បងដឹងគំនិតអូនឯងថ្ម៎
ផលនារី! ប្អូនខ្ចីបងបានប្តី　　អូនស្រីចូលឆ្នាំឲ្យគ្រប់សាសន៍ ។
សាសន៍ខ្មែរ - ចាំង - ចិនទឹងយួន　　ចូលផ្ទួនតៗគ្នាល្អណាស់
បើអូនស្រីបងនាងចង់ចាស់　　ចូលឲ្យគ្រប់សាសន៍ក្នុង ១ ឆ្នាំ ។

ធីលង៉ារី

(អូនចេញទៅ រួចចូលមកវិញ) ។

ឈុតទី ៣ ឆាកទី ៤

ភាណវិទ្ធិ មិត្តាណា

មិត្តាណា

ការបណ្ដិតផងតាំងឡាយ　　លោកបានចែងចាយចងវិចិត្រ
គ្មានអ្វីប្រសើរថ្លៃវិសិដ្ឋ　　មកប្រៀបនឹងចិត្តមនុស្សបានឡើយ ។
ចិត្តថ្លៃវិសេសជាចំផុត　　ព្រះពុទ្ធសំដែងទុកមកហើយ
អ្នកធ្វើជាតូចធំក៏បើកដើយ　　ប្អូនអើយគ្មានអ្វីធំជាងចិត្ត! ។

ទៅរៀនស្រុកគេជាតិដទៃ លក់លៃមារយាទទីឆ៍គំនិត
បើទុកដូចម្តេចត្រូវអាណិត ឈៀងគិតមកសាសន៍យើងជាខ្មែរ ។
គឺជាតិ! សាសនា! ទឹងមហាក្សត្រិយ៍!

ភាណារិទ្ធិ

សព្វប៉ុន្មានមាត៌បងសូមប្រែ
អធិប្បាយឲ្យខ្ញុំយកទៅកែ ឲ្យក្លឹងដូចខែល្អប្រៃ ។

មិត្តាណា

ពាក្យចាំងបីមាត៌មានខ្ញឹមសារ គឺជាដើមអាទិ៍កងកណ្តាល
គួរជនជាតិខ្មែរចាំងប្រុងស្រឹង មេត្រីបង្អោនកាយគោរព ។
គឺជាជីវិតនៃរួមជាតិ មិនអាចឃ្លៀងឃ្លាតតែងចងជាប់
ទីពឹងប្រទេសដែលគួរគាប់ បួនអើយចាំជាប់ក្នុងដួងចិត្ត ។

ភាណារិទ្ធិ

សូមអធិប្បាយឲ្យពិស្តារ កថាវិសេសប្រសើរពិត
សំដីផងបងខ្ញើនសុចរិត ខ្ញុំសែនបួលចិត្តស្តាប់អស្ចារ្យ ។

មិត្តាណា

ជាតិ! គឺកំណើតយើងជាខ្មែរ បួនថែរក្សាកេរ្តិ៍នាមា
កុំក្លេចថាយើងជាតិកម្ពុជា ជាប់ល្បីខ្ចរខ្ចារទៅក្នុងលោក ។
បួនទៅចំរៀនយកជម្រៃ រៀនឲ្យបានចេះកុំក្លេចជាតិ

ឥស្សាស្រុកយើងដែលខ្វះសោក វិយោគសព្វថ្ងៃឪ្យអ្នកស្រាប់។
អសន្តិសុខមានគ្រប់ទិស ហាក់ដូចជាពិសឪ្យបានស្លាប់
បានដឹងថាជាតិយើងសឹងស្ងាប់ អស់ច្រើនអាចរាប់ក៏ពុំបាន ។

ភាណវារ៉ៃ

សាសនាមានន័យយ៉ាងដូចម្តេច សម្រេចបញ្ហាអស់រំខាន
បានស្លាប់សព្វបងចិត្តខ្ញុំក្សត្តិ ខ្ញុំសែនធួរក្សាន្តគិតដល់ជាតិ ។

មិត្តាណា

សាសនាគឺលទ្ធិព្រះពុទ្ធ ប្រពៃបរិសុទ្ធគួរកុំឃ្លាត
ធ្វើចិត្តធ្វើកាយកុំរវាត ថែរបៀតទៅរកចូលសាសន៍គេ ។
សាសនាមានគុណថ្លៃវិសេស បរទេសបានស្គាល់ស្រុកយើងដែរ
ហេតុនេះប្អូនអើយអ្នកកុំវេរ យកជាតិសាសន៍គេធ្វើសាសន៍យើង ។

ភាណវារ៉ៃ

មហាក្សត្រមានន័យយ៉ាងណាទៅ ខ្ញុំត្រូវការស្តាប់ឪ្យធាប់ឡើង
ឥឡូវឯងបងចង់ដំកើង ទំយាយធាប់ឡើងខ្ញុំចង់ឮក ។

មិត្តាណា

ប្អូនអើយមហាក្សត្រិយ៍ថ្ងៃត្រកាល អាណាព្យាបាលជាប្រមុខ
ព្រះអង្គតែងឪ្យសេចក្តីសុខ ពស្ត្រខ្មែរសព្វស្រុកបានសុខសាន្ត ។
ស្តេច! គឺជាគោលរបស់ជាតិ សូរសីហនាទថ្ងៃថ្កើងថ្កាន

ទន់ផ្អែមត្រជាក់មិនសាមាន្យ វិញ្ញាណប្អូនត្រូវចាំឲ្យជាប់ ។

ភាណារិទ្ធិ

ជយោ! ជាតិ! សាសនា! មហាក្សត្រិយ៍!!!

(ក្មួងទាំងអស់ទះដៃ)

ម៉ារ៉ា

ទៅចុះក្មួនប្រុស ឲ្យបានសុខ ផុតក... (ស្រក់ទឹកភ្នែក)

ភាណារិទ្ធិ

(លុតជង្គង់ឧបដើងផុត រួចសំពះក្រាបណាចេញទៅ) ។

ភាណានក-មិត្តាណា - ភាណារិទ្ធិ - មិត្តភាពចេញទៅត្រឡប់មកវិញ

(លោកម៉ាក់ធំនាងផលនារ៉ា ឈរសំឡឹងតាមមើលដំណើរ ។

រួចលោកម៉ាក់ចេញ) ។ (មានត)

មើលអ្វីច្រៃជាងមើលចាំងភ្លឺ?

មើលរបាំ រាប់ដោយឆ្នាំ ពុំប្រសើរ

ស្មើដោយមើល ពួកសៀវភៅ ក្បួនតារា,

មើលរបាំ តាំងខ្លួន ជាពាល,

មើលសៀវភៅ អាចទៅជា បណ្ឌិតឆើត

ឃ្លោ—អ៊ុន

រឿង ប៉ូលនិងវ៉ីស៊ីនី

លោក ធែង-ជ្រើរិសាស្ត្រាចារ្យ នៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែរៀបរៀង

(តមក)

លុះដើរចេញពីជ្រោះមក ក៏ក្រឡេកមើលឆ្ងេរឆ្ងាំវ៉ៃគ្រែងមានផ្លែឈើអ្វីល្មមស៊ីបាន ។ វ៉ីស៊ីនីសោះប្រទះឃើញឈើមួយដើម បែបដូចជាគ្នោត សន្ធឹកក្តោបដូចស្តែ នៅកណ្តាលស្លឹកមានបណ្តាលខ្ចីប្រកបដោយទឹកជារស ។ ដើមនោះមិនធំជាងក្តៅទេ តែខ្ពស់ចំនួនម៉ែត្រ ។ ស្រទាប់វ៉ែងពេក សូម្បីតែពូថៅក៏កាប់ស្ទើរតែមិនមុត ហើយអាប៉ូលគ្មានកាំបិតផង ។ គិតយកក្តៅដុត ក៏ស់គ្មានដែកក្តៅ ។ តែនៅទីនោះមានថ្ម ច្រើន ។ អាប៉ូលរើសថ្មមួយដុំមុខស្រួចដូចកាំបិត ក៏យកថ្មនុះ ចោះមែកឈើស្តួតមួយឲ្យមានប្រហោងឡើង ហើយតាំងសម្រួចមែកឈើស្តួតមួយដទៃទៀត ។ ក៏យកមែកឈើមានរន្ធជាន់ទឹងដើង យកមែកឈើស្រួចជាក់ក្នុងរន្ធនោះ ហើយគេតាំងវៃចុះវៃឡើង ។ មួយសន្ទុះ មានផ្សែងហុយចេញ មានរងើកក្រហម ។ គេតាំងប្រមូលស្មៅស្តួត ។ ទឹងមែកឈើជាប់យកទៅតវដុតនៅតល់ដើមគ្នោតនោះ ។ មិនយូរប៉ុន្មាន ឈើនោះរលាត់ក្រែង ។ អាប៉ូលយកក្តៅទៅដុតបកយកខ្ចប់ឆ្ងាល់តែបាន ។ កុមារទាំងគ្នាស៊ីទៅមួយចំហៀង ដុតមួយចំហៀងឲ្យឆ្អិន ហើយបរិភោគតទៅទៀត គង់មានរសជាតិឆ្ងាញ់ពិសាដូចគ្នា ។ ក្នុងពាក់ពីរបរិភោគបណ្តាលឈើ

ដោយសេចក្តីតែកាយ ព្រោះនឹកដល់កុសលដែលបានធ្វើហើយពីព្រឹក ប៉ុន្តែការសេបញ្ជាយមិនតាំងនៅយូរប៉ុន្មាន ព្រោះវាព្រួយនឹកដល់ម្ហាយដែលទុនមកបាត់យូរមិនបានត្រាប់ ។ រឿងនេះវ៉ីស៊ីនីនឹកជាងគេ ។ ចំណែកអាប៉ូលដឹងខ្លួនថាមានកំឡាំងបរិបូណ៌ឡើងវិញ ហើយនិយាយលួងប្អូនថាមិនយូរប៉ុន្មានទេ យើងនឹងទៅដួបលោកម្ហាយយើងវិញជាមិនខាន ។

កាលណាបរិភោគឆ្អែតហើយ ក្មេងទាំងពីរនាក់ព្រួយម្តងទៀត ព្រោះគ្មាននរណានាំផ្លូវទៅផ្ទះ ។ បងដែលមិនសូវតែយ មានវាចាទៅកប្អូនថា "ខ្លួយើងទៅត្រង់ទុះ ត្រូវយើងដើរតាមផ្លូវព្រឹកមិញ ឆ្លងកុំដែលអូនមើលឃើញឯណោះ ។ ចូរយើងចេញដើរទៅ អូនព្រលឹងបង" ។ កុំទុះគេហៅកុំដោះបើ ពីព្រោះកំពូលភ្នំបីធ្លាយដូចដោះ ។ វាចុះពីកុំឆ្លងកាត់ស្ទឹងខ្មៅទិសខាងជើង ហើយដើរប្រហែលមួយម៉ោង វាបានដល់ស្ទឹង ១ ទៀតយ៉ាងធំទៅក្បែរផ្លូវ ។ ចំណែកដើមួយកន្លែងធំនៃកោះហ្នឹងដុះសុទ្ធតែព្រៃមានគេស្គាល់តិចណាស់ ទោះបីសត្វថ្ងៃហ្នឹងហើយ បណ្តាស្ទឹងនឹងកុំតាំងឡាយក៏មិនខាន់មានឈ្មោះនៅឡើយ ។ ស្ទឹងដែលកុមារតាំងពីដើរទៅដល់ ហូរចាចសាចភាសពេញលើឋ ។ នាងវ៉ីរស៊ីនី ឮស្ទូរទឹកហូរបៃបខ្លាចបងមិនហានចុះឆ្លង ។ អាប៉ូលឱ្យប្អូនដំរើលើខ្នង ហើយចុះឆ្លងកាត់ស្ទឹងនោះធ្វើព្រងើយ អាប៉ូលនិយាយថា: "កុំភ័យអីព្រលឹងបង! បងមានកម្លាំងណាស់ កាលណាបានទៅដឹតអូនឯង ។ បើប្រសិនណាតា

ពីព្រឹកមិញមិនទទួលអង្ករអូនឯង បងស៊ូវាយតានោះឲ្យអូនឯងមើល" ។ វីរ៍ស៊ីនីឆ្លើយថា: "បងឯងហ៊ានវាយគាត់ដែរ បើគាត់ធំហើយគាចផងឯ?" ។ - "តុព្ចោ! ពុព្ចោ! បងស៊ូឲ្យអូនអាប់មុខឬអី? ការល្អទើបពិបាកធ្វើ ចំណែកការអាក្រែកង៉ាយធ្វើជាបំផុត" ។

កាលណាធូងស្ទឹងរួចហើយ អាប៉ូលចង់ឲ្យប្អូនស្រីវាជិះលើខ្នងដើរ គាត់ក្តុំដោះបើខ្លែត ដែលនៅចម្ងាយពីស្ទឹងប្រហែល ៥-៦ គីឡូម៉ែត្រ ។ តែមិនយូរប៉ុន្មានក៏អស់កំលាំងវាជាក់ជំនិះមកដី ហើយអង្គុយដង្ហក់ក្បែរគ្នា ។ វីរ៍ស៊ីនីប្រាប់ថា "បង! ថ្ងៃត្បហើយ បងឯងនៅមានកំលាំងខ្លែតដែរឬ? ខ្ញុំអស់កំលាំងណាស់ហើយ ទុកខ្ញុំនៅនេះសិនចុះ ហើយបងទៅប្រាប់លោកម្ចាយយើង កុំឲ្យលោកព័យ" ។ - "ខេ! ខេ! បងមិនឲ្យឃ្លាតពីប្អូនខេ បើយប់មកដល់ បងដុតភ្លើង រុំលំដើមគ្នោត យកខ្លះឲ្យអូនឯងស៊ីខ្លែតហើយ យកស្លឹកវាធ្វើជាដំរឲ្យអូនឯងដែក" ។ តែវីរ៍ស៊ីនីដោយអំណាចការឈប់សំពាក ក៏ត្រឡប់មានកម្លាំងឡើងវិញ ឈោងបេះស្លឹកឈើដែលគោរមកនៅមាត់ស្ទឹង យកមកខ្វាស់ធ្វើជាស្បែកជើងជាក់ត្រាប់ដើងដែលពង ពីព្រោះពីព្រឹកមិញ វាប្រញាប់ពេក មិនបានពាក់ខ្នាប់ដើងមក នាងគាច់មែកឫស្សីមួយ ដើរតិចៗ ដៃមួយកាន់ឈើច្រត់ ដៃមួយទៀតគោងស្មាបង ។

កុមារទាំងពីរដើរគ្រមៗក្នុងព្រៃដែលដុះខ្ពស់ៗ ព្រមទាំងស្លឹកដុះខ្ចាប់នាំចាំងភ្នែកមិនឲ្យមើលឃើញកុំដោះបីដែលខ្លួនកំពុងដើរលើ ហើយថែម

ព្រះអាទិត្យកំដៅតចូលរន្ធផង ។ ដើរបានបន្តិចទៅ ក្មេងតាំងពីរ ឃ្លាត ចេញមិនដឹងខ្លួនពីផ្លូវដែលខ្លួនកំពុងដើរ ហើយទៅចូលក្នុងព្រៃមានសុទ្ធ តែដើមឈើដើមវល្លិនឹងថ្នាកច្រកចេញគ្មាន ។ អាប៉ូលឲ្យវីរ៍ស៊ីនី អង្គុយចុះ បៃបថប់ខ្លាំង រត់ទ្វាទៅទ្វាមក ចេញទៅមាត់ព្រៃដើម្បីនឹងរកផ្លូវ តែអស់កម្លាំងពេករកមិនឃើញ ។ ក៏ឡើងលើចុងឈើមួយធំនឹងរកមើលភ្នំដោះបី តែក៏ឃើញតែចុងឈើខ្ទះដែលទៅជុំវិញ ដោយសារពន្លឺថ្ងៃជិតយប់ចាំងមក ពីព្រោះកន្លងពេលនោះស្រមោលភ្នំគ្របលើព្រៃតាំងមូល ហើយខ្យល់ក៏មិនសូវមាន តាមធម្មតាដែលជិតព្រលប់ ។ ស្ងាត់សូន្យ គេឮតែមាត់ប្រើសយុំមែ"ៗ ដើរកកន្ទែងជាប់ពីគេនឹងដេក ។ អាប៉ូល មានសង្ឃឹមថាមុខជាព្រានព្រៃណាមួយស្តាប់សំឡេងឮមិនខាន ក៏តាំងស្រែកថា "អ្នកអើយមកជួយនាងវីរ៍ស៊ីនីផង ! ។ មានតែសូរព្រៃងើយមកវិញថា "វីរ៍ស៊ីនី ! វីរ៍ស៊ីនិ !" ។ ចុះពីដើមឈើមកវិញ អស់កម្លាំងផង ព្រួយចិត្តផង ក៏រកទំនេរគិតឈប់ដេកក្នុងទីនោះ ។ តែគ្មានតាំងទឹក តាំងដើមគ្នោត តាំងមែកឈើងាប់ លួមយកមកបង្កាត់ភ្លើងបានសោះ ។ អាប៉ូលគាល់ច្រក ដឹងថាធ្វើអ្វីមិនកើត គិតអ្វីមិនសម្រេច តាំងយំតែម្តង ។ វីរ៍ស៊ីនីឃាត់ថា: "កុំយំអីបង ! បើបងចង់មិនឲ្យប្អូនព្រួយចិត្ត ។ គឺមកតែពីប្អូនទេតើជាហេតុ តាំងឲ្យបងមានទុក្ខនឹងជាហេតុឲ្យមានទុក្ខដល់លោកម្ចាយយើង ។ មិនត្រូវយើងធ្វើអ្វីតាំងអស់ សូម្បីការនោះជាកុសល

ក៏ដោយ បើមិនបានសួរលោកម្តាយ ។ ធ្វើម្តេចបងបានជាប្រែហែស ហើយ ពេលនេះ" ។ និយាយតែប៉ុណ្ណោះហើយ ទឹកភ្នែកហូរច្រោក ធ្លាក់មក ។ តែវីស៊ីនី និយាយច្រាបបងទៀតថា: "ណើយបង! បង់ ព្រះជាម្ចាស់ទៅ ព្រះអង្គមិនលែងអាណិតយើងទេ" ។

គាន់តែបង់ព្រះភ្លាម ស្រាប់តែឮសូរឆ្កែព្រុស ។ អាប៉ូលមាន ភាថា: " ច្បាស់ជាឆ្កែព្រានដែលមកជាញ៉ាប្រើសនៅនាឆ្នេះហើយមើល ទៅ" ។ បន្តិចទៀតឆ្កែព្រុសកាន់តែរន្ធឺនឡើង ។ វីស៊ីនី ស្តីថា: "ទេ! ដូចជាសំឡេងឆ្កែយើង ព្រោះខ្ញុំស្គាល់ច្បាស់សំឡេងវា បើដូច្នោះ ប្រហែលយើងមកជិតដើងកូរបស់យើងហើយ!" ។

មួយស្របក់ទៀត ហ្វីដែលមកដល់ជិតនៅដើងវា ព្រុសផង លូផង ចចផង លិទ្ធដែលលិទ្ធដើងកុមារទាំងពីរ ។ ក្មេងទាំងពីរមិនទាន់ក្រោក ឡើងផង ស្រាប់តែឆ្កែទាំងមកដល់ភ្លាម ។ ជនទាំងបីត្រេកអរពេក នៅធ្មឹងរកពាក្យអ្វីមួយមាត់យកមកនិយាយមិនកើត ។ ហើយទើបឆ្កែទាំង លោចេញស្តីថា: "តុចៅហ្វាយ! លោកម្តាយអ្នកព្រួយខ្លាំងណាស់ កាលណាមកពីវិហារវិញ រកអ្នកមិនឃើញ, ខ្ញុំទំដូនលោកស្រីដើររក សព្វអន្ទឹ គ្រប់ទីកន្លែង តែពុំឃើញសោះ ហើយសួរមាំរីដែលនៅ ធ្វើការជិតទីនោះ នាងនេះក៏ឆ្លើយច្រាបថា មិនដឹងជាទៅទីណាដែរ ។ ខ្ញុំគិតឃើញតម្រែមួយ; ខ្ញុំយកខោអាវចាស់ៗ របស់នាងទាំងពីរឲ្យហ្វី

ហិតកូនឲ្យស្គាល់ច្បាស់ ខ្ញុំតាំងលែងកឲ្យស្រង់កូនតាមដានដើងនាង ។ ហ្នឹកធ្វើបានដូចចិត្ត ។ ក៏ចេះតែនាំខ្ញុំរហូតមកដល់ស្ទឹងខ្មៅ ។ នៅខែខ្ទុះហើយដែលខ្ញុំបានដំណឹងថានាងទាំងពីរបានទាំបាវស្រីម្នាក់ល្មត់ នៅសូមទោសនឹងម្ចាស់ក ។ តឡូវតែតអំពើទេ ទោសដែលនាងសូមនោះ ម្ចាស់កចង់ដើងជាប់នឹងខ្សែមួយ កជាប់ឃ្នាងមានកងដែកមួយមានទំពក់ប៊ីយ៉ាងស្រួចពាក់ជាប់នៅក ។ តែឲ្យប់ពីនោះមកហ្នឹដែលនាំខ្ញុំដើរលើកំភ្លៃស្ទឹងខ្មៅ ក៏ប្រឹងព្រួសអស់ទំហឹងក: គឺនៅតែងកន្ទែងក្បែរមាត់ជ្រោះ ជិតដើមគ្រោតមួយដើមរលំហើយមានដុតក្ងើងនៅនេះហ្ន៎យ។ នៅឡើយ ។ រួចក៏នាំខ្ញុំមកដល់ទីនេះទៀតយើងនៅនឹងដើងកុំដោះបីទេ នៅប្រហែលជាប់ថ្ងៃមួយគឡូទៀតទើបដល់ផ្ទះយើង ។ សូមនាងពិសាឲ្យមានកម្លាំងឡើង" ។ និយាយតែប៉ុណ្ណោះហើយ ខ្លួម៉ាំងក៏ហុចនំផ្ទៃឈើនឹងផ្ទៃឃ្មោកមួយតេញទៅដោយបាន: លាយទឹក លាយស្រាទំពាំងបាយជូរ លាយទឹកត្រូច លាយស្ពានឹងទឹកមុស្កាត (muscade) ដែលម្តាយកុមារធ្លើទុកផឹកសម្រាប់ឲ្យមានកម្លាំងហើយត្រជាក់ខ្លួនស្រួល ។ វ៉ែស៊ីនី ទឹកជាពន់ពេក ដល់សេចក្តីទុក្ខនៃស្រីពួងដែលម្ចាស់ក៏ធ្វើបាបនឹងសេចក្តីព្រួយនៃម្តាយទាំងពីរ ។ នាងមានភាជដែល។ ជាច្រើនដងថា: "ន! លោកអើយ! ពិបាកធ្វើការកុសលអីម្ល៉េះទេ" ។ រៀលដែលអាប៉ូល នឹងវ៉ែស៊ីនី បានស្រួលខ្លួន

ហើយ ខ្ញុំចាប់ដុតក្លើង ហើយទៅរកនូវបណ្តាថ្មគំនរឡាយ នូវឈើ
ម្យ៉ាងឈ្មោះឈើមូល អាចឆេះគាំងនៅស្រស់ មានអណ្តាតធំ រួចគាត់
ធ្វើជាគប់ដួយដុតបំភ្លឺផ្លូវ ព្រោះយប់ឃ្លាសស់ហើយ ។ តែគាត់មាន
សេចក្តីលំបាកយ៉ាងធំ កាលណាគាត់រៀបចេញដំណើរ ដ្បិតអាប៉ូល
ន៏ងវ៉ែស៊ូន៏ ដើរពុំរួច ជាតដើងហើម ពងក្រហមគាំងអស់ ។ ខ្ញុំចាំមិន
ដឹងគិតជានឹងត្រូវចេញទៅរកអ្នកដទៃម្នាក់មកឲ្យជួយទៀត ឬត្រូវនៅដេក
ជាមួយកុមារកន្លែងនេះ ។ គាត្មងនិយាយថា: "ខ្ញុំមានតុកាសឯណា
ន៏អាចពន្យាងគាំងពីរតែម្តងក្នុងដៃខ្ញុំ! ព្រោះឥឡូវនាងក៏ធំៗ ហើយ។
ខ្ញុំក៏ជាផង" ។ កំពុងគិតគ្នាមិនដឹងជាទៅខាងណា ស្រាប់តែមានត្មង
មួយពួកលួចរត់ចេញពីម្ចាស់វាមក លេចឡើងព្រាតចំនួនជាម្ភៃម៉ែត្រ
ពីជនគាំងបី ។ មេហ្វូងចូលមកជិតអាប៉ូលន៏ងវ៉ែស៊ូន៏ ហើយស្តីថា:
"បពិត្រកុមារប្រុស! ចូរអ្នកកុំកិតក័យឡើយ យើងបានឃើញអ្នកដែរ
កាលដែលនាំស្រីត្មងម្នាក់ទៅសូមទោសអំពីម្ចាស់វា ដែលមានចិត្តអាក្រក់
នៅឯស្ងួនភ្នៅពីព្រៃកមិញ ហេតុដូច្នេះ ដោយក្តីកតញ្ញូ យើងសូមសែង
កុមារលើស្មារបស់យើងជូនទៅផ្ទះវិញ" ។ ខណៈនោះ មេហ្វូងឲ្យសញ្ញា
ដល់ត្មងម្នាក់មានខ្លួនធាត់ធំ ឲ្យយកមែកឈើធ្វើជាគ្រែស្មង ចោចវល្ចិយក
មកចង លើកកុមារគាំងពីរជាក់លើគ្រែ ហើយនាំគ្នាលើកសែងឡើង ។

ចំណែកឯម៉ាំងជាមគ្គុទ្ទេស កាន់ក្តើងតប់ដើរតាមមុខ ហើយមនុស្សគាំង អស់ធ្វើដំណើរចេញទៅ ហៅកន្ត្រែកវែសប្បាយចិត្ត ។ វីរ៍ស៊ីនី ពេញចិត្តកំមានវាចាទៅកាន់បងថា: "អ្នកបង! ព្រះជាម្ចាស់ព្រះអង្គមិនដែលលះបង់អ្នកណាដែលធ្វើអំពើល្អឡើយ" ។

ពាក់កណ្តាលអធ្រាត្រ ជនគាំងឡាយមកដល់ដើងកុ: នោកំពូលកុន្ទុះគេយើញមានក្តើងតប់កុំព្រែងព្រាត ។ គាន់តែឡើងកុំបានបន្តិចស្រាប់តែឮសូរមាត់ស្រែកសួរមក: "អ្នកឯងឬអី កូនមាសម្តាយ?" ។ កុមារនឹងឮដឹងគាំងឡាយ ស្រែកឆ្លើយតបទៅវិញថា: "បាទ! គឺយើងហ្នឹងមែនហើយ" ។ ម្តាយក៏នឹងនាងម៉ារី កាន់តប់មួយម្នាក់ដើរចូលមកក្រាម ។ នាងឡាតួរ សួរថា: "នែកូនសំឡាញ់ម្តាយ! ចុះហេតុឡប់មកពីណាវិញ? នាងធ្វើឲ្យម្តាយកើតទុក្ខអីម្ល៉េះទេ!" ។ វីរ៍ស៊ីនី ឆ្លើយថា: "យើងទើបនឹងត្រឡប់មកពីស្ទឹងភ្លៅ ទៅសុំទោសឲ្យស្រីម្នាក់លួចរត់ពីម្ចាស់វាមក, មុននឹងនាំទៅ យើងឲ្យគាត់បរិភោគផ្អែមព្រឹកមិញនៅផ្ទះយើង ព្រោះគាត់ឃ្លានស្ទើរស្លាប់ ឥឡូវលោកម្តាយមើលពួកគាំងអស់នេះលួចរត់ពីម្ចាស់ជូនយើងមក" ។ នាងឡាតួរសុំនុបកូនស្រីខ្លួនកនិយាយអ្វីពុំបួច ។ វីរ៍ស៊ីនីដឹងថាទឹកភ្នែកម្តាយហូរមកប៉ះមុខខ្លួនក៏មានវាចាថា: "លោកម្តាយធ្វើឲ្យកូនព្រួយពេក" ។ ម៉ារីតែរសប្បាយ

ចិត្តគាញ់អាប៉ូលមកនុចតែកង់ដៃហើយសួរថា: "ចុះចំណែកកូនឯងបានធ្វើការល្អនឹងគេដែរឬ?" ។ លុះមកដល់ផ្ទះកាលណា នាងឱ្យពួងទាំងប៉ុន្មានបរិភោគឆ្អែតស្កប់ស្កល់ ហើយពួកពួងទាំងនុះ ក៏ត្រឡប់រលៀវក្នុងព្រៃវិញ ឱ្យពរដល់អ្នកផ្ទះឱ្យបានសេចក្តីសុខសេចក្តីចំរើន ។

សេចក្តីសុខ នឹងសេចក្តីពេញចិត្ត តែងមានដល់ត្រកូលទាំងពីរជារៀងរាល់ថ្ងៃ ។ ជនទាំងអស់មិនដែលកើតទុក្ខ ព្រោះតែខ្លួនក្រីក្រឬការលោភលន់ហួសប្រមាណ ។ ត្រកូលទាំងពីរមិនដែលមានសេចក្តីច្បាស់ចង់បានក្តីឈ្នោះដែលកើតមកអំពីអំពើទុច្ចរិតឡើយ គ្រាន់តែបានសេចក្តីសុខស្រួលដូចសព្វថ្ងៃហ្នឹងបានហើយ ។ ទៅក្នុងកោះនោះក៏ដូចជាទៅក្នុងស្រុកចំណុះជាតិអ៊ីរុបឯទៀតដែរ គេតែងចង់ដឹងរឿងថ្មីៗពីការអាក្រក់ ត្រង់ការប្រព្រឹត្តល្អ នឹងឈ្នោះនៃជនទាំងនេះ គ្មាននរណាចង់ដឹងសោះ មានតែអ្នកដំណើរកង់ផ្លូវបំពេញមុះ សួរទៅអ្នកស្រុកខ្លះថា: "ឈ្នោះណាអាស្រ័យទៅខាងលើ ក្នុងចំណោមទាំងឡាយនុះ?" ។ អ្នកស្រុកទាំងឡាយក៏គ្មានស្គាល់ត្រកូលទាំងនោះដែរ ប៉ុន្តែគ្រាន់តែឆ្លើយប្រាប់ទៅអ្នកដំណើរវិញថា "គឺអ្នកខៀងត្រង់ទៅទីនោះ" ។ សេចក្តីនេះក៏ដូចជាផ្លាវីយ៉ូឡែត ដែលដុះក្រោមព្រៃស្បាតមានបន្ទាប់ អាចផ្សាយក្លិនក្រអូបទៅឆ្ងាយបានដែរ ពិតមែនតែគេពុំឃើញផ្កានោះ ។

(មានត)

ពិធីបើកសាលាបរិយត្តិធម្មវិន័យ
នៅវត្តព្រះព្រហ្មវត្ត ខេត្តសៀមរាប
ព្រះមហាឧត្តមវិជ្ជា (រឹម ប្បញ្ញោ) កែ-អឿន
រៀបរៀង

កាលពីថ្ងៃព្រហស្បតិ៍ ៨ កើតខែវិសាខ ឆ្នាំពេងចត្វាស័ក ព.ស. ២៤៨៩ ត្រូវនឹងថ្ងៃទី ១ ខែឧសភា គ.ស. ១៩៤៦, នៅវត្តព្រះព្រហ្មវត្ត ខេត្តសៀមរាប មានធ្វើពិធីបុណ្យដ៏ឧឡារិកហៅថា "ពិធីបើកសាលាបរិយត្តិធម្មវិន័យ" ។ កុងពិធីបុណ្យនេះមានទស្សនីយភាពល្អចំឡែកអស្ចារ្យ គឺសាលាធម្មសភាគេតាក់តែងគ្រឿងសក្ការបូជាថ្វាយដល់ព្រះរតនត្រ័យ ។ គ្រឿងសក្ការនោះវិចិត្រវចនាដោយស្លឹកឈើផ្កាឈើស្រស់ចំរុះពណ៌ទីខែៗនឹងផ្កាខ្សែក្រដាសចង់ជាតិ ចង់សាសនា តូចធំចង់ប្រទាក់ខ្ជាត់ខ្ជែងជាច្រើន ។ សាលានេះសម្រាប់ទទួលព្រះសង្ឃនឹងលោកភៀវហ្វាយស្រុក ជាឡាត់ស្រុកព្រមទាំងពុទ្ធបរិស័ទ ។ ផ្នែកខាងកុងសាលាធម្មវិន័យមានរៀបតុសម្រាប់សិស្សអង្គុយរៀន នឹងតុសម្រាប់គ្រូ ក្តារខៀនបញ្ឈរធំ ។ នៅបង្អួចខ្វាសាលាខាងកើត-ដើង-ត្បូង សុទ្ធតែចង់ចង់ជាតិ-សាសនា នឹងផ្កាវិយោលក្រដាសសំយុងជាលំអ ។ នៅខាងលើខ្វាធំខាងលិចបន្ទាប់ពីសាលាធម្មសភា មានចង់បន្ទាស់សុំក្តារមួយសន្ធឹកសរសេរជាក់សញ្ញាសាលាធម្មវិន័យ ហើយយកចង់ជាតិនឹងចង់សាសនា ១ គូរព័យ

បិទគ្របអក្សរជិតមិនឲ្យឃើញ, នៅខាងលើក្តារ ដម្កល់ព្រះពុទ្ធរូបស៊ុំ
កញ្ចក់ ១, នៅចុងក្តារតាំងសងខាង ដម្កល់ព្រះបរមរូបព្រះករុណាជាម្ចាស់
ជីវិតលើត្បូង ទង់ព្រះបរមនាយាល័ក្ខណ៍កាលទ្រង់ព្រះផ្នួសទង់រចនា
ដោយបុប្ផាផ្កាឈើស្រស់ ទង់ផ្កាត្រដាសរយោងទុកបំរុងឲ្យលោកចៅ-
ហ្វាយស្រុកនាញបើក, នៅខាងកើតមុខសាលាធម្មវិន័យ មានបង្គន់ជាតិ
សាសនាតូច-ធំ ដាក់ជាជួរកំពែងក្រៅ ។ នៅវេលាម៉ោង ២ កន្លះ
រសៀល ព្រះសង្ឃជាង ២០០ អង្គ មានព្រះសុមង្គលសីលាចារ្យមេ-
គណៈទង់ព្រះគ្រូបញ្ជាវិជ្ជាអនុគណជាប្រធាន ទង់ពុទ្ធបរិស័ទជាច្រើន
មើដេរជាសត្រៀបត្រា ឃានទង់មន្ត្រីទង់អញ្ជើញទៅជួបជុំនៅសាលាធម្ម-
សភា រង់ចាំទទួលបដិសណ្ឋារៈលោកចៅហ្វាយស្រុកចាឡាត់ស្រុក ។
វេលាម៉ោង ៣ រសៀល លោកចៅហ្វាយស្រុក ចាឡាត់ស្រុក អញ្ជើញ
ទៅដល់, ក្រោយនោះបន្តិចមក លោកចៅហ្វាយស្រុកថ្លែងការណ៍
ដោយឧគ្ឃោសនសព្វអំពីការបើកសាលាធម្មវិន័យ ទង់កិច្ចដែលត្រូវរៀន
សូត្រ, រួចហើយអញ្ជើញទៅកន្ត្រាក់ទាញខ្សែដែលចងនៅបង្ហាស់ស៊ុំក្តារ
នោះ ទង់តាំងគូទង់ផ្កាតាំងប្តូនាន កំរបើកចេញពីគ្នាទៅនៅចុងក្តារតាំង
ពីរខាង ។ ពេលនោះគេមើលឃើញអក្សរសរសេរនៅក្តារថា:

សាលាបរិយត្តិធម្មវិន័យ

"ធម្មវិនយោ សាសនស្ស មូលំ"

ធម្មវិន័យជាឫសគែវនៃសាសនា

ពេលនោះអាចារ្យវត្តស្រែកញាជង់ថា "សូមអញ្ជើញអនុមោទនា។" ពុទ្ធបរិស័ទតាំងឡាយអនុមោទនាថា សាធុ! សាធុ! ។ បន្ទាប់ពីនោះមក ព្រះមហាឧត្តមវិជ្ជា កែ-អឿន សូត្រសុន្ទរកថា ដូចមានសេចក្តីតទៅនេះ:

សុន្ទរកថា

ខ្ញុំព្រះករុណា, អាត្មាភាព ជាតំណាងព្រះតេជព្រះគុណព្រះគ្រូបញ្ញាវិជ្ជាអនុគណ ទឹងកិគុសាមណេរតាំងអស់ ព្រមទាំងពុទ្ធបរិស័ទជាចំណុះដើងវត្តនេះ ។

សូមពិតថេរវាចា ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មានព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណជាប្រធាន!

សូមចំរើនពរព្រះតេជព្រះគុណចៅហ្វាយស្រុក!

សូមចំរើនពរលោកចុង្ហាត់ស្រុក!

ទឹងអស់លោកអ្នកជាពុទ្ធបរិស័ទតាំងឡាយ!

សូមជ្រាប ។

ខ្ញុំព្រះករុណា អាត្មាភាព មានសេចក្តីត្រេកអរដ៏ពន្លឹកទឹងមានអំណរអរគុណយ៉ាងក្រៃលែង ចំពោះព្រះថេរានុត្ថេរៈគ្រប់អង្គ ព្រះតេជព្រះ

គុណ លោកអ្នកចាំងឡាយ ដែលបានខិមខ្ពអញ្ជើញមកជាមង្គលនឹងជាកិត្តិយសក្នុងឱកាសបុណ្យបើកសាលាបរិយត្តិធម្មវិនយនេះ ។

ក្នុងពេលនេះ ខ្ញុំព្រះករុណា អាត្មាភាព សូមសាសឰអំពីប្រវត្តិនៃសាលាធម្មវិន័យនេះដោយសង្ខេប ។ សាលាធម្មវិន័យនេះបានបើកវៀនពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៥០ ម្ល៉ងហើយ បានកូនសិស្សចូលរៀនថ្នាក់ត្រីចំនួន ៩៤ រូប ដល់ចុងឆ្នាំបានប្រឡងជាប់ ៥៤ រូប, ដល់ថ្ងៃទី ១៥ ខែឧសភាឆ្នាំ ១៩៥១ បានបើកចូលរៀនម្ដងទៀត បានកូនសិស្សចូលរៀនថ្នាក់ត្រីចំនួន ១២៤ រូប. ទឹងបង្កើតថ្នាក់ទោមួយថ្នាក់ទៀត បានកូនសិស្សចូលរៀន ២៨ រូប ដល់ចុងឆ្នាំកន្លងទៅហើយនេះ បានប្រឡងជាប់ថ្នាក់ត្រី ៧២ រូប, ថ្នាក់ទោ ២៥ រូប ។ ការដែលបានបើកចូលរៀនទឹងប្រឡងរួចមកហើយនេះ ដោយសេចក្ដីអនុញ្ញាតជាបណ្ដោះអាសន្នអំពីក្រសួងសម្ដេចព្រះសង្ឃនាយកទឹងក្រសួងធម្មការ ដោយការប្រែស្ថិតជាក់ខ្លឹងជាមួយទឹងព្រះតេជព្រះគុណ ព្រះមុនីកោសលមេគណ វត្តពោធិ៍-រាល ខែត្រចាត់ដំបង, ព្រោះខែត្រចាត់ដំបងនោះបានបង្កើតការរៀនធម្មវិន័យមកយូរឆ្នាំហើយ ។ ដល់មកក្នុងពេលនេះមានចុតហ្វាយអ្នកឧកញ៉ាឧបនាយកវង្គមន្ត្រីក្រសួងយុត្តិធម៌ទឹងធម្មការលេខ ៣៤៩ ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ១៩៥២ នេះ មានបញ្ជាការឲ្យបើកសាលានេះ ជាសាលាធម្មវិន័យពេញទីតាមលក្ខណៈច្បាប់, ហើយឲ្យនិមន្តព្រះសង្ឃ ៣

រូបៗ គ្រប់វត្តក្នុងស្រុកសៀមកបនេះ ឲ្យចូលមករៀនបំពេញវិជ្ជាធម្មវិន័យ ដើម្បីយកទៅធ្វើជាគ្រូបង្រៀនតាមវត្តនិមួយៗ តទៅទៀត ។

អាត្មាភាពសូមធ្វើជីវិតព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋនេះដល់ព្រះតេជព្រះគុណជាឥស្សរជន នឹងលោកអ្នកជាពុទ្ធបរិស័ទ ទាំងឡាយដោយការជួយឧបត្ថម្ភ ឲ្យបានចំរើនថ្កុំថ្កើងរុងរឿងជាកិយ្យាការរៀងទៅ ។

ក្នុងកាលជាអវសានៃសុន្ទរកថានេះ ខ្ញុំព្រះករុណា អាត្មាភាព សូមបួងសួងដល់គុណព្រះតេនត្រ័យ នឹងទេវតាទាំង ๑ ហ្នឹងលោកធាតុ សូមជួយបីបាច់រក្សាព្រះតេជព្រះគុណជាឥស្សរជនទាំងឡាយ ឲ្យបានប្រកបដោយសេចក្តីសុខ សេចក្តីចំរើន នឹងមានមហេស័ក្តិជាលំដាប់នឹងមានជន្មាយុយឺនយូរអង្វែង ដើម្បីនឹងជួយបីសួយមាតុភូមិឲ្យអណ្តែតត្រសែតទៅកាន់វឌ្ឍនធម៌ នឹងឯករាជ្យដោយបរិបូណ៌ នឹងបំពេញកិត្តិយសចំពោះទង់ជាតិមានច្បាសាទនគរវត្តជាដើមនិមិត្តរូប ។ ម្យ៉ាងទៀត សូមជូនសព្វសាធុការពរដល់លោកជាសិស្សានុសិស្សទាំងឡាយ ដែលបានចូលមកសិក្សាធម្មវិន័យក្នុងសាលានេះ សូមកុំឲ្យមានរោគាព្យាធិចូលមកបៀតបៀន ឲ្យបានសូតសាស់ចំរើនដោយចំណេះវិជ្ជានឹងវឌ្ឍនធម៌គ្រប់យ៉ាង ដើម្បីញុំាងព្រះពុទ្ធសាសនាឲ្យបានថ្កុំថ្កើងរុងរឿងទៅអនាគតកាល, នឹងសូមឲ្យលោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ ព្រមទាំងញាតិគ្រួសារ

ចុងប្រកបដោយសេចក្តីសុខ សេចក្តីចំរើន ក្នុងព្រះពុទ្ធសាសនាជាបច្ច័យដល់ព្រះនិព្វានជាអវសានជាតិកុំបីឃ្លាត ។

បន្ទាប់ពីសុន្ទរកថានេះ ព្រះគ្រូបញ្ញាវិជ្ជាអនុគណជាសំតៀនគ្រែនរំលឹកដល់សិស្សានុសិស្ស ដែលនិមន្តពីគ្រប់វត្តចូលមករៀនបំពេញវិជ្ជាធម្មវិន័យ នឹងជាសំតៀនលោកគ្រូចៅអធិការគ្រប់វត្តឲ្យជួយឧបត្ថម្ភសិស្សរបស់លោករៀងៗខ្លួន ។

លុះចប់ការណីយកិច្ចទាំងនេះហើយ ព្រះសង្ឃសូត្រជយន្តោគឹកកងរំពងឡើង គួរឲ្យមានសេចក្តីរីករាយក្រៃពេក ។ កិច្ចប៉ុណ្ណោះសន្មតថាចប់ពិធីបើកសាលាបរិយត្តិធម្មវិន័យ ។

ក្នុងយប់នោះវេលាម៉ោង ៩ គេនិមន្តព្រះមហាឧត្តមវិជ្ជា កែ - អឿន នឹងព្រះអាចារ្យ ឈន វត្តសាវ័ន្តក្រុងភ្នំពេញសំដែងធម្មទេសនា បុប្ផាវិសជ្ជនា, ទេសនាចប់ហើយ ក្រុមកងឯកទេសខ្មែរកំសាន្តជូនចង់ប្តូនរួមជាតិមើល ដរាបដល់ម៉ោង ១ យប់ទើបឈប់ ។

សិស្សានុសិស្សទាំងឡាយ !

មគ្គ - ផល - និព្វាន យើងពិបាកនឹងធ្វើឲ្យបានសម្រេចក៏មែនពិតហើយ តែត្រង់ចរិយា - មារយាទសណ្តាប់ធ្នាប់ល្អមិនពិបាកធ្វើប៉ុន្មានទេ គួរយើងខំនាំគ្នាធ្វើឲ្យមានឡើង ។

ក្នុងសៀវភៅកម្ពុជសុរិយាលេខ ៥ ឆ្នាំ ១៩៥២

មានខុសភ្លាំងភ្លាត់ ដូចខាងក្រោមនេះ ដោយមកពីយើង ច្រឡាប់ពេក គឺ:

ទំព័រ ៤	
ជួរដេកទី ២	
ត្រង់បញ្ហីរឿងជាអក្សរធ្ងាំង :	
	Qualité d'un conéfrencier
ត្រូវមើលថា :	Qualité d'un conférencier
ត្រង់ទំព័រ ៣៣០ បន្ទាត់ ១០ :	
	La presse est la mère de tous les vie
ត្រូវមើលថា :	La paresse est la mère de tous les vices
ត្រង់ទំព័រ ៣៤៩ បន្ទាត់ ១៣ :	
	ស្តេចមិនឆ្អែតសម្បត្តិអាណាបក្រ
ត្រូវមើលថា :	ស្តេចមិនឆ្អែតសម្បត្តិអាណារាស្ត្រ

ជូរឆ្នេះ យើងសូមអភ័យទោស អំពីអ្នកអានទាំងឡាយ ។

... ... ភ្នំពេញ ... ...
. ភោគពុម្ពព្រះបរមរាជវាំង .
... ... ១៩៥២ ... ...